2009

ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ( IASB )

International Accounting Standards Board (IASB®)

# ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ សម្រាប់អង្គភាពធុនតូចនិងមធ្យម

IFRS™ for SMEs

# ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ក្រុមប្រឹក្សាជាតិគណនេយ្យ

# ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ
# សម្រាប់អង្គភាពធុនតូចនិងមធ្យម

The International Financial Reporting Standard for Small and Medium-sized Entities is copyright of the IFRS Foundation. In the event that the International Financial Reporting Standard for Small and Medium-sized Entities has been amended to facilitate its adoption into national law this amendment will be clearly indicated in the text of the International Financial Reporting Standard for Small and Medium-sized Entities.

The authoritative text of the International Financial Reporting Standard for Small and Medium-sized Entities and other IASB publications is the text that is published by the IASB in the English language. Copies may be obtained from the IFRS Foundation. Please address publication and copyright matters to:

IFRS Foundation Publications Department, 30 Cannon Street, London EC4M 6XH, United Kingdom. Telephone: +44 (0)20 7246 6410 Fax: +44 (0)20 7246 6411 Web: www.ifrs.org

The IFRS Foundation has waived the right to assert its copyright in the International Financial Reporting Standard for Small and Medium-sized Entities in the territory of Cambodia in the Khmer language only. The IFRS Foundation reserves all rights outside of the aforementioned territory

# ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ
# សម្រាប់អង្គភាពធុនតូចនិងមធ្យម

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម គឺជាការរក្សាសិទ្ធិរបស់មូលស្ថាបនាស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ។ នៅពេល ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមត្រូវបានកែប្រែ ដើម្បីសម្រួលដល់ការទទួលយកទៅក្នុងច្បាប់របស់ជាតិ កំណែប្រែនេះនឹងត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងអត្ថបទរបស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។

អត្ថបទជាអជ្ញាព្រឹត្តរបស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម និងការបោះចេញផ្សាយផ្សេងៗទៀតរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិគឺជាអត្ថបទដែលបោះផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិដែលមានជាភាសាអង់គ្លេស។ ការថតចំលងអាចទទួលបានការអនុញ្ញាតិពីមូលស្ថាបនាស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ សូមបញ្ជាក់អំពីការបោះផ្សាយនិងការរក្សាសិទ្ធិទៅៈ

IFRS Foundation Publications Department, 30 Cannon Street, London EC4M 6XH, United Kingdom. Telephone: +44 (0)20 7246 6410 Fax: +44 (0)20 7246 6411 Web: www.ifrs.org

មូលស្ថាបនាស្តង់ដាររបាយការណ៍ទាក់ទងនឹងរញ្ញវត្ថុអន្តរជាតិលើកលែងសិទ្ធិការពារនូវការរក្សាសិទ្ធិរបស់ខ្លួនលើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ជាភាសាខ្មែរ និងនៅក្នុងប្រទេសកម្ពុជា។ មូលស្ថាបនាស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ រក្សាសិទ្ធិគ្រប់បែបយ៉ាងនៅក្រៅតំបន់ដូចពោលអះអាងខាងលើ។

# មាតិកា


សេចក្តីផ្តើម

ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម

អារម្ភកថា VIII

ផ្នែក

១ អង្គភាពធុនតូចនិងមធ្យម 1

២ បទបញ្ញត្តិ និង គោលការណ៍សាយភាយ 3

៣ ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ 15

៤ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ 21

៥ របាយការណ៍លទ្ធផលលំអិត និង របាយការណ៍លទ្ធផល 26

៦ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លទ្ធផល និងប្រាក់ចំណេញរក្សាទុក 30

៧ របាយការណ៍លំហូរសាច់ប្រាក់ 32

៨ កំណត់សម្គាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុយ 39

៩ របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក 41

១០ គោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និង កំហុសឆ្គង 49

១១ របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋាន 55

១២ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ 74

១៣សន្និធិ 83

១៤ការវិនិយោគនៅក្នុងញាតិសម្ពន្ធ័ 88

១៥ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន 93

១៦ទ្រព្យវិនិយោគ 97

១៧ ទ្រព្យ រោងចក្រ និង បរិក្ខារ 101

១៨ ទ្រព្យសកម្មអរូបដែលមិនមែនជាមូលនិធិពាណិជ្ជកម្ម 109

១៩ ការរួមបញ្ចូលគ្នានៃអាជីវកម្ម និង មូលនិធិពាណិជ្ជកម្ម 116

២០ ភតិសន្យា 123

២១ សំវិធានធន និង យថាភាព 133

ឧបសម្ពន្ធ-- សេចក្តីណែនាំអំពីការទទួលស្គាល់និងការវាស់វែងសំវិធានធន
២២ បំណុល និង មូលធន 138
ឧបសម្ពន្ធ-- ឧទាហរណ៍អំពី គណនេយ្យសម្រាប់បំណុលអាចបំប្លែងបាន របស់ក្រុមហ៊ុនបោះផ្សាយ
២៣ ចំណូល 144
ឧបសម្ពន្ធ-- ឧទាហរណ៍អំពីការទទួលស្គាល់ចំណូលតាមគោលការណ៍នៅក្នុងផ្នែក ២៣
២៤ អំណោយរបស់រដ្ឋាភិបាល 153
២៥ បន្ទុកហិរញ្ញវត្ថុ 155
២៦ ការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន 156
២៧ ការថយចុះតម្លៃនៃទ្រព្យសកម្ម 163
២៨ អត្ថប្រយោជន៍របស់បុគ្គលិក 173
២៩ ពន្ធលើប្រាក់ចំណេញ 187
៣០ ការប្តូររូបិយប័ណ្ណបរទេស 196
៣១ អតិផរណាខ្ពស់ 203
៣២ ព្រឹត្តិការណ៍បន្ទាប់ពីចុងការិយបរិច្ឆេទរាយការណ៍ 207
៣៣ ការលាត្រដាងព័ត៌មានរបស់ភាគីពាក់ពន្ធ័ 211
៣៤ សកម្មភាពពិសេស 217
៣៥ អន្តរកាលឆ្ពោះទៅស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម 222
សទ្ទានុក្រម 229

ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពតូចនិងមធ្យមត្រូវបានកំណត់នៅក្នុងផ្នែក១ផ្នែក៣៥ និងនៅក្នុងសទ្ទានុក្រម។ពាក្យកំណត់អត្ថន័យនៅក្នុងសទ្ទានុក្រមជាប្រភេទ**អក្សរដិតខ្មៅ** ខណៈដែលវាកើតមានលើកដំបូងនៅក្នុងផ្នែកនិមួយៗ។ ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពតូចនិងមធ្យម ភ្ជាប់មកជាមួយនឹងអរម្ភកថា សេចក្តីណែនាំអនុវត្តតារាងតទិ្វតកម្ម របាយការណ៍ហិរញ្ញវត្ថុគម្រូនិងការដាក់បង្ហាញ ព្រមទាំងបញ្ជីនៃការលាតត្រដាងព័ត៌មាន និង មូលដ្ឋាននៃការសន្និដ្ឋាន។

# អារម្ភកថា

## អំពីក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ

អ១ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០១ដែលជាផ្នែកមួយនៃមូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ (គ.ស.គ.អ)។

អ២ គោលដៅរបស់មូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិនិងនៃក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ÷

(ក) បង្កើតឡើង ដើម្បីប្រយោជន៍សាធារណៈនូវស្តង់ដារគណនេយ្យមួយដែលមានគុណភាពខ្ពស់អាចយល់បាន និងអាចអនុវត្តជាសាកលដែលទាមទារនូវព័ត៌មានដែលមានគុណភាពខ្ពស់ មានតម្លាភាព និងមានព័ត៌មានអាចប្រៀបធៀបបាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងការរាយការណ៍ហិរញ្ញវត្ថុផ្សេងទៀតដើម្បីជួយដល់អ្នកចូលរួមនៅក្នុងទីផ្សារមូលធនពិភពលោកនិងដល់អ្នកប្រើប្រាស់ផ្សេងទៀតដើម្បីធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

(ខ) ជម្រុញការប្រើប្រាស់និងការអនុវត្តដ៏ម៉ឺងម៉ាត់នូវស្តង់ដារទាំងនោះ។

(គ) ប្រសិនបើអាចធ្វើទៅបាន ក្នុងការបំពេញនូវគោលដៅ (ក) និង (ខ) គិតគូរអំពីសេចក្តីត្រូវការពិសេសរបស់អង្គភាពធុនតូចនិងមធ្យម និងសេចក្តីត្រូវការនៃវិបុលភាពនៃសេដ្ឋកិច្ច និង

(ឃ) នាំមកនូវភាពរួមគ្នានៃស្តង់ដារគណនេយ្យជាតិ និងស្តង់ដារគណនេយ្យអន្តរជាតិ និងស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទៅរកដំណោះស្រាយមួយប្រកបដោយគុណភាព។

អ៣ អភិបាលកិច្ចនៃមូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិមានអភិបាលចំនួន២២រូប។ការទទួលខុសត្រូវរបស់អភិបាល រួមមាន តែងតាំងសមាជិករបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ និងរបស់ក្រុមប្រឹក្សានិងគណៈកម្មាធិការតូចៗនានា ព្រមទាំងធានានូវហិរញ្ញប្បទានចំពោះអង្គភាពទាំងមូល។

អ៤ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិគឺជាអង្គភាពកំណត់ស្តង់ដាររបស់មូលនិធិគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ។ ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ មានសមាជិក ២៥ រូប ហើយត្រូវកើនឡើងរហូតដល់ ១៦ រូប នាកាលបរិច្ឆេទមិនលើសពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១២។សមាជិកលើសពី ៣ រូប អាចជាសមាជិកក្រៅម៉ោង។ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិទទួលបន្ទុកអនុម័តលើស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (ទាំងស្តង់ដារ ទាំងការបកស្រាយ) ព្រមទាំងឯកសារពាក់ព័ន្ធ ដូចជា ក្របខណ្ឌសម្រាប់រៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសេចក្តីព្រាងស្តង់ដារនិងឯកសារសម្រាប់ពិភាក្សា។មុននឹងក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិចាប់ផ្តើមប្រតិបត្តិការការងារស្តង់ដារគណនេយ្យអន្តរជាតិនិងការបកស្រាយពាក់ព័ន្ធត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សារបស់គណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ ដែលស្ថាប័ននេះត្រូវបានបង្កើតឡើង នាថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៣។ ដោយមានសេចក្តីសម្រេចពីក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ស្តង់ដារគណនេយ្យអន្តរជាតិ

និងការបកស្រាយពាក់ព័ន្ធ នៅតែអាចអនុវត្តបាន ដែលវាមានអំណាចដូចគ្នា ទៅនឹងស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិដែរ វាលែងតែ ឬរហូតទាល់តែស្តង់ដារទាំងនោះត្រូវបានធ្វើវិសោធនកម្មឬដកចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ។

## ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

អ៥ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ សម្រេចនូវគោលដៅរបស់ខ្លួនជាបឋមដោយការបង្កើត និងការបោះផ្សាយស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងជម្រុញឲ្យមានការប្រើប្រាស់ស្តង់ដារទាំងនោះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនិងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត។ការរាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត មានព័ត៌មានដែលផ្តល់ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ ដែលជួយដល់ការបកប្រែសំណុំនៃរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពរបស់អ្នកប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចផ្នែកសេដ្ឋកិច្ចក្របដោយប្រសិទ្ធភាព។ ពាក្យ "ការរាយការណ៍ហិរញ្ញវត្ថុ" រួមមានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ បូកនឹងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត។

អ៦ ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកំណត់នូវការតម្រូវនានាសម្រាប់ការទទួលស្គាល់ ការវាស់វែង ការបង្ហាញ និងការលាតត្រដាងព័ត៌មាន ដែលអនុវត្តចំពោះប្រតិបត្តិការ ព្រមទាំងព្រឹត្តិការណ៍និងលក្ខខណ្ឌដទៃទៀត ដែលមានសារៈសំខាន់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។ស្តង់ដារទាំងនោះអាចកំណត់ផងដែរអំពីប្រតិបត្តិការ ព្រឹត្តិការណ៍ និងលក្ខខណ្ឌចម្បងដទៃទៀត ដែលកើតឡើងនៅក្នុងឧស្សាហកម្មពិសេស។ ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ផ្អែកលើមូលដ្ឋាននៃក្របខណ្ឌ ដែលលើកឡើងអំពីទស្សនទានជាមូលដ្ឋានព័ត៌មាន ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ។គោលដៅរបស់ក្របខណ្ឌ គឺជួយសម្រួលដល់អនុលោមភាពនិងការធ្វើជាគំរូសមស្រប សម្រាប់ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។វាក៏ផ្តល់ផងដែរនូវមូលដ្ឋានសម្រាប់ការប្រើប្រាស់ការសម្រេចចិត្តនៅក្នុងបញ្ហានានាដែលទាក់ទិននឹងគណនេយ្យកម្ម។

## របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ

អ៧ ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិត្រូវបានបង្កើតឡើងដើម្បីអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅនិងចំពោះការរាយការណ៍ហិរញ្ញវត្ថុដទៃទៀត របស់អង្គភាពមានគោលដៅរកប្រាក់ចំណេញ។របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ នាំទៅរកសេចក្តីត្រូវការនូវព័ត៌មានរួមរបស់អ្នកប្រើប្រាស់ជាច្រើន ដូចជា ម្ចាស់ភាគហ៊ុន ម្ចាស់បំណុល និយោជិត និងសាធារណៈជនទូទៅ។ គោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុ គឺផ្តល់នូវព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលផ្នែកហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពមួយដែលព័ត៌មានទាំងនោះនអត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់ទាំងនោះក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

អ៨ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅគឺជារបាយការណ៍ដែល ផ្តល់នូវព័ត៌មានហិរញ្ញវត្ថុទូទៅដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ទូទៅដែលមិនទាមទារនូវព័ត៌មានដ៏ជាក់លាក់ណាមួយសម្រាប់ពួគេ។របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ រួមមានរបាយការណ៍ដែលបានបង្ហាញដាច់ដោយឡែក ឬជាមួយឯកសារជាសាធារណៈផ្សេងទៀត ដូចជា របាយការណ៍ប្រចាំឆ្នាំ ឬបរិយាយប័ណ្ណ។

## ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម

អ៩ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ក៏បង្កើតនិងបោះផ្សាយស្តង់ដារដាច់ដោយឡែកមួយសម្រាប់អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់អង្គភាពនិងការរាយការណ៍ហិរញ្ញវត្ថុដទៃទៀតដែលធ្វើដោយអង្គភាព ដែលតាមពាក្យនេះ នៅក្នុងបណ្តាប្រទេសជាច្រើន រួមមាន អង្គភាពធុនតូចនិងមធ្យម អង្គភាពឯកជននិងអង្គភាពដែលមិនទទួលខុសត្រូវជាសាធារណៈ។ស្តង់ដារនោះ គឺជាស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។

អ១០ ពាក្យ “អង្គភាពធុនតូចនិងមធ្យម”ដែលប្រើដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិត្រូវបានផ្តល់អត្ថន័យនិងពន្យល់ក្នុងផ្នែកទី១អំពីអង្គភាពធុនតូចនិងមធ្យម។ យុត្តាធិការជាច្រើននៅលើពិភពលោកបានបង្កើតនូវនិយមន័យផ្ទាល់ខ្លួនរបស់គេដល់ពាក្យអង្គភាពធុនតូចនិងមធ្យមនេះសម្រាប់គោលបំណងផ្សេងគ្នាជាច្រើន រួមទាំង ចែងអំពីកាតព្វកិច្ចក្នុងការរាយការណ៍ហិញ្ញវត្ថុ។ ជារឿយៗ និយមន័យតាមបែបជាតិឬបែបតំបន់ រួមបញ្ចូលនូវលក្ខណៈវិនិច្ឆ័យប្រកបដោយគុណវុឌ្ឍិដោយផ្អែកលើមូលដ្ឋាននៃ ចំណូល ទ្រព្យសកម្ម និយោជិត ឬកត្តាដទៃទៀត។ជាញឹកញាប់ ពាក្យ “អង្គភាពធុនតូចនិងមធ្យម” ត្រូវបានប្រើដោយ បញ្ជាក់ន័យ ឬរួមបញ្ចូលអង្គភាពតូចៗដោយមិនគិតថាតើអង្គភាពនោះបោះផ្សាយ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅសម្រាប់អ្នកប្រើប្រាស់ខាងក្រៅឬអត់នោះទេ។

អ១១ អង្គភាពធុនតូចនិងមធ្យមតែងតែបង្កើតរបាយការណ៍ហិរញ្ញវត្ថុតែសម្រាប់ការប្រើប្រាស់ដោយអ្នកគ្រប់គ្រងផ្ទាល់ខ្លួន ឬសម្រាប់តែការប្រើប្រាស់ដោយអាជ្ញាធរសារពើពន្ធ ឬសម្រាប់អាជ្ញាធររបស់រដ្ឋាភិបាលដទៃទៀតតែប៉ុណ្ណោះ។របាយការណ៍ហិរញ្ញវត្ថុដែលបង្កើតឡើងសម្រាប់តែគោលបំណងទាំងនោះមិនចាំបាច់ជារបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅទេ។

អ១២ ច្បាប់ពន្ធដារមានលក្ខណៈពិសេសសម្រាប់យុត្តាធិការនីមួយៗហើយគោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅខុសពីគោលដៅរបស់ប្រាក់ចំណេញជាប់ពន្ធដែលត្រូវរាយការណ៍។ដូចនេះ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំស្របតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ប្រហែលជាមិនអនុលោមទាំងស្រុងតាមគ្រប់ការវាស់វែងដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិសារពើពន្ធរបស់យុត្តាធិការទាំងនោះទេ។ យុត្តាធិការមួយមានលទ្ធភាពក្នុងការបន្ថយ “ប ន្ទុករាយការណ៍ទ្វេរដង”លើអង្គភាពធុនតូចនិងមធ្យម ដោយបង្កើតជារចនាសម្ព័ន្ធរបាយការណ៍ពន្ធដារជាការផ្ទៀងផ្ទាត់ពី

ចំណេញឬខាត ដែលត្រូវបានកំណត់ស្របតាម ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមនិងតាមមធ្យោបាយដទៃទៀត។

**សិទ្ធិអំណាចរបស់ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម**

អ១៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិតម្រូវឱ្យឬអនុញ្ញាតឱ្យអង្គភាពស្តង់ដារ ស្ថិតនៅលើអាជ្ញាធរច្បាប់និងនិយ័តករនិងលើអ្នកអនុម័តស្តង់ដារនៅក្នុងយុត្តាធិការផ្ទាល់របស់ខ្លួន។ វាជាការ ពិតណាស់សម្រាប់ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងសម្រាប់ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការកំណត់ជាក់លាក់មួយអំពីចំណាត់ថ្នាក់អង្គភាពដែលស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមត្រូវអនុវត្ត (ដូចដែលបានចែងក្នុងផ្នែកទី ១ នៃស្តង់ដារ) មានសារៈសំខាន់ណាស់ ដូចនេះ (ក)-ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិអាចសម្រេចលើការតម្រូវផ្នែកគណនេយ្យនិងការតម្រូវចំពោះការលាតត្រដាងព័ត៌មានដែលសមស្របសម្រាប់ថ្នាក់នៃអង្គភាពនោះ ហើយ (ខ)-អាជ្ញាធរច្បាប់និងនិយ័តករ អ្នកកំណត់ស្តង់ដារ និងអង្គភាពត្រូវរាយការណ៍និងសវនកររបស់ពួកគេត្រូវដឹងអំពីវិសាលភាពដែលចង់បាននៃភាពអាចអនុវត្តបាននូវស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម។ ការកំណត់យ៉ាងច្បាស់នេះក៏មានសារៈសំខាន់ដែរ ដូចនេះអង្គភាពដែលមិនមែនជាអង្គភាពតូច ឬ មធ្យមហើយមិនតម្រូវឱ្យអនុវត្តស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម មិនបាច់អះអាងថាគេអនុវត្តតាមស្តង់ដារនេះទេ (សូមមើល កថាខណ្ឌ ១.៥)។

**ការរៀបចំស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម**

អ១៤ ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យមត្រូវបានរៀបចំឡើងតាមប្រធានបទ ដោយប្រធានបទនីមួយៗត្រូវបានបង្ហាញតាមផ្នែកដែលបានបង់លេខដាច់ពីគ្នា។ លេខរបស់កថាខណ្ឌត្រូវបានធ្វើឡើងតាមទម្រង់ xx.yy ដែល xx គឺជាលេខផ្នែក ហើយ yy គឺជាលេខកថាខណ្ឌ។ លេខកថាខណ្ឌ ត្រូវបានធ្វើឡើងតាមទម្រង់ xx.yy ដែល xx គឺជាលេខផ្នែក ហើយ yy គឺជាលេខកថាខណ្ឌតាមលំដាប់លំដោយក្នុងផ្នែកនោះ។ ជាឧទាហរណ៍ដែលមានចំនួនទឹកប្រាក់ជារូបិយវត្ថុ ឯកតាសម្រាប់វាស់វែងជាឯកតារូបិយប័ណ្ណ (សរសេរអក្សរកាត់ថាCU )។

អ១៥ គ្រប់ ថាខណ្ឌ របស់ស្តង់ដារនៃការៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិមានសិទ្ធិអំណាចស្មើគ្នា។ ផ្នែកខ្លះរួមទាំងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំសម្រាប់អនុវត្តដែលមិនមែនជាផ្នែកនៃស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិទេ ប៉ុន្តែវាក៏ជាគោលការណ៍ណែនាំសម្រាប់អនុវត្តផងដែរ។

**ការថែរក្សាស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម**

អ១៦ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិរំពឹងថានឹងធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើទពិសោធន៍នៃការអនុវត្តស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់អង្គភាពធុនតូចនិងមធ្យម ដោយអង្គភាពទាំងនោះនៅពេលដែលរបាយការណ៍ហិរញ្ញវត្ថុរយៈពេលពីរឆ្នាំតាមស្តង់ដារនៃការរៀបចំ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិត្រូវបានបោះផ្សាយដោយអង្គភាពភាគច្រើន។ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិរំពឹងថានឹងស្នើសុំធ្វើវិសោធនកម្ម ដើម្បីលើកឡើងអំពីបញ្ហានានាអនុវត្តស្តង់ដារដែលបានបញ្ជាក់នៅក្នុងការត្រួតពិនិត្យឡើងវិញនោះ។ក្រុមប្រឹក្សានឹងពិចារណាផងដែរលើស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិថ្មីៗ និងដែលបានធ្វើវិសោធនកម្មរួច ដែលត្រូវបានអនុម័តតាំងពីស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ត្រូវបានបោះផ្សាយ។

អ១៧ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញលើការអនុវត្តដំបូងបានធ្វើរួចក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិរំពឹងថានឹងស្នើសុំធ្វើវិសោធនកម្មលើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមដោយបោះផ្សាយនូវសេចក្តីព្រាងមួយជាសាធារណៈរយៈពេល៣ឆ្នាំម្តង។ក្នុងការបង្កើតសេចក្តីព្រាងទាំងនោះក្រុមប្រឹក្សារំពឹងថានឹងពិនិត្យមើលឡើងវិញលើស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិថ្មី និងដែលបានធ្វើវិសោធនកម្មរួចដែលត្រូវបានអនុម័តក្នុងកំឡុង០៣ ឆ្នាំមុន ក៏ដូចជា នឹងពិនិត្យលើបញ្ហាដោយឡែកៗនានាដែលត្រូវបានក្រុមប្រឹក្សាបានយកចិត្តទុកដាក់លើវិសោធនកម្មដែលអាចធ្វើទៅបានលើស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ក្រុមប្រឹក្សាចង់ឲ្យវដ្ត០៣ឆ្នាំ គឺជាផែនការសាកល្បងមួយ ប៉ុន្តែមិនមែនជាការតាំងចិត្តប្រាកដប្រជាទេ។នាឱកាសនោះ ក្រុមប្រឹក្សាអាចកំណត់នូវបញ្ហាដែលវិសោធនកម្មលើ ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម អាចត្រូវបានពិចារណាមុនវដ្តរយៈពេលធម្មតាគឺ ០៣ឆ្នាំនោះ។ ការប្រែប្រួលនានាដែលក្រុមប្រឹក្សាអាចធ្វើឡើងឬ ស្នើឡើងលើស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិមិនត្រូវអនុវត្តលើស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមទេ លុះត្រាតែស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវបានធ្វើវិសោធនកម្ម។

អ១៨ ក្រុមប្រឹក្សារំពឹងថានឹងមានកាវិយបរិច្ឆេទចន្លោះយ៉ាងតិច ០១ឆ្នាំរវាងពេលដែលស្តង់ដារនៃការរៀបចំរបាយការណ៍រញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវបានបោះផ្សាយនិងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្ម។

# ផ្នែកទី ១ សហគ្រាសធុនតូចនិងមធ្យម

## វិសាលភាពរបស់ស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនេះ

១.១ ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវបានរៀបចំឡើងសម្រាប់ឲ្យសហគ្រាសធុនតូចនិងមធ្យមប្រើប្រាស់។ផ្នែកនេះពិពណ៌នាអំពីចរិកលក្ខណៈរបស់សហគ្រាសធុនតូចនិងមធ្យម។

## ការពិពណ៌នាអំពីចរិកលក្ខណៈរបស់សហគ្រាសធុនតូចនិងមធ្យម

១.២ សហគ្រាសធុនតូចនិងមធ្យម គឺជាសហគ្រាសនានាដែល ÷

(ក)មិនទទួលខុសត្រូវជាសាធារណៈ និង

(ខ)បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់ខាងក្រៅក្នុងគោលបំណងទូទៅ។ អ្នកប្រើប្រាស់ខាងក្រៅរួមមាន ម្ចាស់អង្គភាពដែលមិនមានការពាក់ព័ន្ធជាមួយ ការគ្រប់គ្រងអាជីវកម្មម្ចាស់បំណុលបច្ចុប្បន្ន និងម្ចាស់បំណុលសក្តានុពល ព្រមទាំងភ្នាក់ងារផ្តល់ឥណទាននានា។

១.៣ អង្គភាពមួយដែលទទួលខុសត្រូវជាសាធារណៈ ប្រសិនបើ ÷

(ក)បំណុលឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពនោះត្រូវបានដាក់លក់លើទីផ្សារជាសាធារណៈឬវាកំពុងតែស្ថិតក្នុងដំណើរការបោះផ្សាយលក់ឧបករណ៍ទាំងនោះលើទីផ្សារជាសាធាណៈ(ទីផ្សារហ៊ុនក្នុងស្រុក ឬ បរទេស ឬទីផ្សារ អូ-ស៊ី-ធី រាប់បញ្ចូលទាំងទីផ្សារក្នុងស្រុក និងតំបន់ផងដែរ) ឬ

(ខ)អង្គភាពមានទ្រព្យសកម្មដែលមានសមត្ថភាពធានាចំពោះក្រុមអ្នកក្រៅអង្គភាពដែលទ្រព្យសកម្ម នោះជារបស់អាជីវកម្មចម្បងនៃអង្គភាព។ជាទូទៅ ជាករណីរបស់ធនាគារ សហភាពឥណទាន ក្រុមហ៊ុនធនារ៉ាប់រងពាណិជ្ជករ ឬអន្តរការីមូលបត្រ មូលនិធិសង្គហធន និងធនាគារវិនិយោគ។

១.៤ អង្គភាពខ្លះក៏អាចមានទ្រព្យសកម្មដែលមានសមត្ថភាពធានាចំពោះក្រុមអ្នកក្រៅអង្គភាពពីព្រោះអង្គភាពទាំងនោះកាន់កាប់និងគ្រប់គ្រងធនធានហិរញ្ញវត្ថុដែលអតិថិជនឬសមាជិកហ៊ុនដែលមិនពាក់ព័ន្ធនឹងការគ្រប់គ្រងអង្គភាពបានប្រគល់ឲ្យក្រុមអ្នកខាងក្រៅទាំងនោះ។តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ អង្គភាពទាំងនោះកាន់កាប់និងគ្រប់គ្រងធនធានហិរញ្ញវត្ថុដោយហេតុផលបន្ទាប់បន្សំសម្រាប់អាជីវកម្មចម្បង(ឧទាហរណ៍ដូចជាករណីភ្នាក់ងារដឹកអ្នកដំណើរ ឬភ្នាក់ងារអចលនទ្រព្យ សាលារៀន ស្ថាប័ន សប្បុរសធម៌ សហគ្រាសប្រតិបត្តិការដែលតម្រូវឲ្យមានការដាក់ប្រាក់តំកល់ធម្មតារបស់សមាជិកនិងអ្នកលក់ដែលទទួលបានការបង់ប្រាក់មុនការផ្តល់ទំនិញឬសេវាដូចជាក្រុមហ៊ុនដែលផ្អែកលើអត្ថប្រយោជន៍ជាដើម)ដែលធ្វើឲ្យអង្គភាពទាំងនោះមិនទទួលខុសត្រូវ ជាសាធារណៈ។

១.៥ ប្រសិនបើអង្គភាពមានការទទួលខុសត្រូវជាសាធារណៈប្រើប្រាស់ស្តង់ដាររបាយការណ៍ទាកទងនឹងហិរញ្ញវត្ថុអន្តរជាតិនោះរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពនឹងមិនត្រូវបានពិពណ៌នាថាបានអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមទេបើ ទោះបីជាច្បាប់ឬវិធាននៅក្នុងយុត្តាធិការរបស់ខ្លួនបានអនុញ្ញាតឬតម្រូវឲ្យអង្គភាពដែលទទួលខុសត្រូវជាសាធារណៈអនុវត្តតាមស្តង់ដានេះក៏ដោយ។

១.៦ ចំពោះក្រុមហ៊ុនញាតិសម្ព័ន្ធដែលក្រុមហ៊ុនមេរបស់ខ្លួនប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ឬក៏ក្រុមហ៊ុនញាតិសម្ព័ន្ធនោះជាផ្នែកមួយនៃក្រុមហ៊ុនមដែលបានកើតពីការរួមបញ្ចូលគ្នាហើយដែលប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ក្រុមហ៊ុនញាតិសម្ព័ន្ធនោះមិនត្រូវបានហាមឃាត់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្ទាល់របស់ខ្លួនឡើយ ប្រសិនបើ ក្រុមហ៊ុនញាតិសម្ព័ន្ធខ្លួនឯងមិនមានការទទួលខុសត្រូវជាសាធារណៈ។ ប្រសិនបើ របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនបានពិពណ៌នាថាអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ក្រុមហ៊ុនញាតិសម្ព័ន្ធនោះត្រូវតែអនុលោមតាមរាល់វិធាននានានៃស្តង់ដារនេះ។

## ផ្នែកទី ២ ទស្សនទាន និង គោលការណ៍ទូទៅ

### វិសាលភាពនៃផ្នែកនេះ

២.១ ផ្នែកនេះបរិយាយអំពីគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យមនិងគុណភាពដែលធ្វើឲ្យព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម មានប្រយោជន៍ក្នុងការប្រើប្រាស់។វាក៏កំណត់ផងដែរនូវទស្សនទាននិងគោលការណ៍គ្រឹះនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម។

### គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម

២.២ គោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម គឺផ្តល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់នានាដែលមិនមានតួនាទីក្នុងការតម្រូវឲ្យគេផ្តល់របាយការណ៍ដើម្បីទទួលបាននូវសេចក្តីត្រូវការព័ត៌មានពិសេសនានា។

២.៣ របាយការណ៍ហិរញ្ញវត្ថុក៏បង្ហាញនូវលទ្ធផលនៃភាពជាអ្នកគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើធនធានដែលគេបានផ្តល់ការទុកចិត្ត។

### ចរិលក្ខណៈផ្នែកគុណវុឌ្ឍិនៃព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

#### ភាពអាចយល់បាន

២.៤ ព័ត៌មានដែលផ្តល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញតាមរបៀបមួយដែលអាចឲ្យអ្នកប្រើប្រាស់ដែលមានចំណេះដឹងសមរម្យខាងអាជីវកម្មនិងសេដ្ឋកិច្ចនិងគណនេយ្យ អាចយល់បាន និមានឆន្ទៈសិក្សាស្វែងយល់ពីតិមានដោយយកចិត្តទុកដាក់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏សេចក្តីត្រូវការនូវភាពអាចយល់បាន មិនអនុញ្ញាតឲ្យព័ត៌មានដែលពាក់ព័ន្ធត្រូវបានលុបបំបាត់យ៉ាងច្រើន ដែលនឹងនាំឲ្យពិបាកយល់ដល់អ្នកប្រើប្រាស់មួយចំនួនឡើយ។

#### ភាពពាក់ព័ន្ធឬភាពទាក់ទង

២.៥ ព័ត៌មានដែលផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែពាក់ព័ន្ធដល់សេចក្តីត្រូវការក្នុងការសម្រេចចិត្តរបស់អ្នកប្រើប្រាស់។ព័ត៌មានដែលមានគុណវុឌ្ឍិថាមានភាពពាក់ព័ន្ធ គឺនៅពេលដែលព័ត៌មាននោះអាចមានឥទ្ធិពលលើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយអាចជួយពួកគេឲ្យធ្វើការវាយតម្លៃលើព្រឹត្តិការណ៍អតីតកាល ព្រឹត្តិការណ៍បច្ចុប្បន្នកាល ឬព្រឹត្តិការណ៍អនាគតកាល ឬដោយអះអាង ឬកែតម្រូវនូវព្រឹត្តិការណ៍អតីតកាលរបស់ពួកគេ។

ភាពជាសារវន្ត

២.៦ ព័ត៌មានដែលមានភាពជាសារវន្តនិងមានភាពពាក់ព័ន្ធ ប្រសិនបើការលុបចោល ឬការរាយការណ៍ខុសអាចធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុនោះ។ភាពជាសារវន្តចំណុះទៅនឹងទំហំនៃធាតុឬកំហុសឆ្គងដែលបានវិនិច្ឆ័យតាមកាលទេសៈជាក់ស្តែងនៃការលុបចោលឬការរាយការណ៍ខុស។ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាមិនសមស្របឡើយដែលយើងចាប់ផ្តើមពីឬរំលងដោយមិនមានការកែកំហុសពីស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យមដើម្បីសម្រេចបាននូវការបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។

ភាពអាចជឿជាក់បាន

២.៧ ព័ត៌មានដែលផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែអាចជឿទុកចិត្តបាន។ព័ត៌មានមួយអាចជឿទុកចិត្តប្រសិនបើវាមិននាំឱ្យមានកំហុសឆ្គងជាសារវន្តនិងលម្អៀងព្រមទាំងបានបង្ហាញយ៉ាងស្មោះត្រង់ដោយវាអះអាងដើម្បីបង្ហាញឬមានការរំពឹងដោយមានហេតុផលដើម្បីបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលមានលម្អៀង(មានន័យថាដូចជាមិនអព្យាក្រឹត្យ) ប្រសិនបើរបាយការណ៍ទាំងនោះមានបំណងធ្វើឱ្យជះឥទ្ធិពលដល់ការសម្រេចចិត្តឬសេចក្តីសម្រេចចិត្តដើម្បីសម្រេចបាននូវលទ្ធផលដែលបានកំណត់ទុកជាមុន ឬលទ្ធផលចុងក្រោយ ដោយការជ្រើសរើសឬការបង្ហាញនូវព័ត៌មាន។

ខ្លឹមសារអាទិភាពលើទម្រង់

២.៨ ប្រតិបត្តិការនិងព្រឹត្តិការណ៍ដទៃទៀតព្រមទាំងលក្ខខណ្ឌនានាត្រូវតែបានរាប់បញ្ចូលនិងបង្ហាញដោយសមស្របទៅតាមកម្រិតសារៈសំខាន់នៃខ្លឹមសាររបស់វានិងរៀបចំទៅតាមទម្រង់ច្បាប់។ប្រការនេះនាំឱ្យបង្កើនបាននូវភាពអាចទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុ។

គោលការណ៍ប្រុងប្រយ័ត្ន

២.៩ ភាពមិនប្រាកដប្រជាដែលកើតពីព្រឹត្តិការណ៍និងកាលទេសៈជាច្រើនដែលមិនអាចជៀសផុតត្រូវបានទទួលស្គាល់ដោយការបង្ហាញអំពីប្រភេទនិងទំហំនៃព្រឹត្តិការណ៍និងកាលទេសៈទាំងនោះ និងដោយត្រូវមាន ការប្រុងប្រយ័ត្នក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។គោលការណ៍ប្រុងប្រយ័ត្នគឺជាការរួមបញ្ចូលនូវកម្រិតនៃការប្រុងប្រយ័ត្នសម្រាប់អនុវត្តន៍ការវិនិច្ឆ័យនានាដែលត្រូវធ្វើការប៉ាន់ស្មាន ដែលបានតម្រូវក្រោមលក្ខខណ្ឌនៃភាពមិនប្រាកដប្រជា ដូចជាថា ទ្រព្យសកម្មឬចំណូលមិនត្រូវបានបំផ្លើសនិងបំណុលឬចំណាយមិនត្រូវបង្ហាញមិនអស់។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តគោលការណ៍ប្រុងប្រយ័ត្នមិនអនុញ្ញាតឱ្យបំផ្លើសទ្រព្យសកម្ម ឬចំណូល ដោយគិតទុកជាមុន ឬបង្ហាញមិនអស់នូវបំណុលឬចំណាយដោយគិតទុកជាមុន។ ជារួមគោលការណ៍ប្រុងប្រយ័ត្ន មិនអនុញ្ញាតឱ្យមានលម្អៀងទេ។

### ភាពពេញលេញ

២.១០ ដើម្បីឲ្យមានភាពទុកចិត្តព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែមានលក្ខខណៈពេញលេញជាសារវន្ត និងមានតម្លៃ។ការលុបចោលណាមួយដែលអាចធ្វើឲ្យព័ត៌មានប្រែជាក្លែងក្លាយឬមិនពិត ហើយដូច្នេះ ធ្វើឲ្យភាពពាក់ព័ន្ធរបស់វាមិនអាចទុកចិត្តបាន និងមិនមានប្រសិទ្ធភាព។

### ភាពអាចប្រៀបធៀបបាន

២.១១ អ្នកប្រើប្រាស់ត្រូវតែអាចធ្វើការប្រៀបធៀបរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយគ្រប់ពេល ដើម្បី កំណត់អត្តសញ្ញាណនៃនិន្នាការស្ថានភាពហិរញ្ញវត្ថុនិងប្រសិទ្ធកម្មរបស់អង្គភាព។ អ្នកប្រើប្រាស់ក៏អាចប្រៀបធៀបរបាយការណ៍ការហិរញ្ញវត្ថុរវាងអង្គភាពផ្សេងៗគ្នា ដើម្បីវាយតម្លៃលើស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ដែលមានការពាក់ព័ន្ធគ្នារវាងអង្គភាពទាំងនោះ។ដូចនេះការវាស់វែងនិងការបង្ហាញអំពីឥទ្ធិពលហិរញ្ញវត្ថុរបស់ប្រតិបត្តិការដូចគ្នានិងរបស់ព្រឹត្តិការណ៍និងលក្ខខណ្ឌផ្សេងទៀតត្រូវតែអនុវត្តប្រកបដោយសង្គតិភាពទូទាំងអង្គភាពទាំងមូល និងគ្រប់ពេល សម្រាប់អង្គភាព និងសង្គតភាព រវាងអង្គភាពនានា។ បន្ថែមលើសនេះទៀតអ្នកប្រើប្រាស់ត្រូវតែទទួលបានព័ត៌មានអំពីគោលនយោបាយគណនេយ្យដែលប្រើ ប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងដឹងអំពីការប្រែប្រួលនានានៃគោលនយោបាយព្រមទាំងឥទ្ធិពលនៃការប្រែប្រួលទាំងនោះ។

### ភាពទាន់ពេលវេលា

២.១២ ដើម្បីឲ្យមានការពាក់ព័ន្ធព័ត៌មានហិរញ្ញវត្ថុ ត្រូវតែអាចមានឥទ្ធិពលលើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់។ ភាពទាន់ពេលវេលា ឬមានកាលកំណត់ច្បាស់លាស់ ទាក់ទងទៅនឹងការផ្តល់ព័ត៌មានក្នុងកំឡុងពេលនៃការសម្រេចចិត្ត។ ប្រសិនបើការរាយការណ៍ព័ត៌មាន បានពន្យាពេលហួសការសម្រេចចិត្ត ព័ត៌មាននោះនឹងលែងមានការពាក់ព័ន្ធ។ អ្នកគ្រប់គ្រងអាចត្រូវធ្វើការថ្លឹងថ្លែងរវាងរបាយការណ៍ព័ត៌មានពាក់ព័ន្ធដែលបានផ្តល់ទាន់ពេលវេលានិងវិធាននៃព័ត៌មានដែលគួរឲ្យទុកចិត្ត។ ដើម្បីទទួលបានតុល្យភាពរវាង ភាពពាក់ព័ន្ធ និងភាពគួរឲ្យទុកចិត្ត ការពិចារណាត្រង់ថា តើធ្វើយ៉ាងម៉េចដើម្បីបំពេញសចក្តីត្រូវការរបស់អ្នកប្រើប្រាស់ក្នុងការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចឲ្យបានល្អ។

### តុល្យភាពរវាងអត្ថប្រយោជន៍និងចំណាយ

២.១៣ អត្ថប្រយោជន៍ដែលទាញបានពីព័ត៌មានត្រូវតែលើសចំណាយនៃការផ្តល់ព័ត៌មាន។ ខ្លឹមសារសំខាន់នៃការវាយតម្លៃអំពីអត្ថប្រយោជន៍និងចំណាយគឺជាដំណើរការមួយនៃការវិនិច្ឆ័យ។ម្យ៉ាងវិញទៀត ចំណាយមិន ចាំបាច់ថាកើតឡើងពីអ្នកប្រើប្រាស់ដែលទទួលបានអត្ថប្រយោជន៍នោះទេ ហើយជារឿយៗអត្ថប្រយោជន៍នៃព័ត៌មានកើតឡើងពីអ្នកប្រើប្រាស់ពីខាងក្រៅជាច្រើនទៀត។

២.១៤ ព័ត៌មានអំពីការរាយការណ៍ហិរញ្ញវត្ថុ ជួយដល់អ្នកផ្តល់មូលធន (ដើមទុន) ធ្វើការសម្រេចចិត្តបានល្អ ដែលជាលទ្ធផលធ្វើឱ្យទីផ្សារមូលធនដំណើរការប្រកបដោយប្រសិទ្ធភាពនិងធ្វើឱ្យថ្លៃដើមមូលធនមានកម្រិតទាបនៅក្នុងសេដ្ឋកិច្ចទាំងមូល។អង្គភាពនិមួយៗក៏ទទួលបានអត្ថប្រយោជន៍ដែរ រួមមាន ភាពងាយស្រួលចូលក្នុងទីផ្សារមូលធន ទំនាក់ទំនងសាធារណៈល្អ និង អាចធ្វើឱ្យថ្លៃដើមមូលធនចុះទាប។អត្ថប្រយោជន៍អាចរាប់បញ្ចូលផងដែរ ដូចជាការសម្រេចចិត្តក្នុងការគ្រប់គ្រងកាន់តែប្រសើរ ពីព្រោះព័ត៌មានហិរញ្ញវត្ថុដែលប្រើប្រាស់ផ្ទៃក្នុងគឺយ៉ាងហោចណាស់ផ្អែកលើមូលដ្ឋានព័ត៌មានដែលរៀបចំសម្រាប់គោលបំណងទូទៅនៃគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ។

## ស្ថានភាពហិរញ្ញវត្ថុ

២.១៥ ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយ គឺជាទំនាក់ទំនងរបស់ទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់ នាកាលបរិច្ឆេទមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិញ្ញវត្ថុ។ ទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់ត្រូវបានឱ្យអត្ថន័យដូចខាងក្រោម ÷

(ក) ទ្រព្យសកម្មគឺជាធនធានដែលគ្រប់គ្រងត្រួតពិនិត្យដោយអង្គភាពដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតហើយដែលគេរំពឹងថានឹងទទួលបាននូវអត្ថប្រយោជន៍សេដ្ឋកិច្ចពីធនធាននោះសម្រាប់អង្គភាពនាពេលអនាគត។

(ខ)បំណុលគឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាពដែលកើតពីព្រឹត្តិការណ៍ពីអតីតកាលហើយដែលការបំពេញកាតព្វកិច្ចនេះនឹងរំពឹងថានឹងនាំឱ្យមានលំហូរចេញនូវធនធានដែលជាអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចពីអង្គភាព។

(គ)មូលធនផ្ទាល់គឺជាភាគកម្មដែលនៅសល់ក្នុងទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីកាត់កងជាមួយបំណុលរបស់ខ្លួន។

២.១៦ ធាតុមួយចំនួនដែលស្របជាមួយអត្ថន័យរបស់ទ្រព្យសកម្មឬបំណុលអាចមិនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មឬបំណុលទេនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុពីព្រោះធាតុទាំងនោះមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ដូចមានចែងនៅក្នុងកថាខណ្ឌ២.២៧-ស.៣២។ជាពិសេស ការរំពឹងថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលឬហូរចេញពីអង្គភាពត្រូវតែមានយ៉ាងពិតប្រាកដដើម្បីបំពេញបាននូវលក្ខណៈវិនិច្ឆ័យដែលគួរឱ្យជឿជាក់ មុននឹងទ្រព្យសកម្មឬបំណុលត្រូវបានទទួលស្គាល់។

## ទ្រព្យសកម្ម

២.១៧ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្មមួយ គឺជាសក្តានុពលដែលនាំឱ្យមាន លំហូរសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែលដល់អង្គភាពទោះបីដោយផ្ទាល់ឬដោយប្រយោលក្តី។លំហូរសាច់ប្រាក់ទាំងនោះអាចបានពីការប្រើប្រាស់ទ្រព្យសកម្មនោះ ឬពីការលក់បញ្ចេញចោលនូវ ទ្រព្យសកម្មនោះ។

២.១៨ ទ្រព្យសកម្មភាគច្រើន ដូចជាទ្រព្យ រោងចក្រ និងបរិក្ខា មានរូបរាងរបស់វា។ ប៉ុន្តែ រូបរាងមិនសំខាន់សម្រាប់អត្ថិភាពនៃទ្រព្យសកម្មនោះទេ។ទ្រព្យសកម្មខ្លះមានលក្ខណៈអរូបីយ។

២.១៩ ដើម្បីកំណត់អំពីអត្ថិភាពនៃទ្រព្យសកម្មមួយ សិទ្ធិរបស់កម្មសិទ្ធិករគឺមិនសំខាន់ឡើយ។ដូចជា ទ្រព្យដែលបានពីភតិសន្យាគឺជាទ្រព្យសកម្មមួយ ប្រសិនបើអង្គភាពគ្រប់គ្រងត្រួត ពិនិត្យលើអត្ថប្រយោជន៍ដែលរំពឹង ថានឹងទទួលបានពីទ្រព្យនោះ។

### បំណុល

២.២០ ចរិកលក្ខណៈចម្បងនៃបំណុល គឺថាអង្គភាពមានកាតព្វកិច្ចបច្ចុប្បន្នដែលត្រូវបំពេញតាមមធ្យោបាយ ពិសេសមួយ។កាតព្វកិច្ចអាចជាកាតព្វកិច្ចនីត្យានុកូលឬជាកាតព្វកិច្ចស្ថាបនា។កាតព្វកិច្ចនីត្យានុកូលគឺជាកាតព្វកិច្ចដែលអាចចាប់បង្ខំឱ្យអនុវត្តតាមផ្លូវច្បាប់ដែលជាផលនៃកិច្ចសន្យាណាមួយឬការតម្រូវខាងផ្លូវច្បាប់ណាមួយ។កាតព្វកិច្ចស្ថាបនាគឺជាកាតព្វកិច្ចមួយដែលចេញពីសកម្មភាពនានារបស់អង្គភាពមួយ÷

(ក)ពេលដែលអង្គភាពបានបង្ហាញដល់ភាគីផ្សេងទៀតថា អង្គភាពនឹងមានការទទួលខុសត្រូវនានាជាមួយភាគីពាក់ព័ន្ធនានាដោយផ្អែកលើទម្លាប់ដែលអនុវត្តកន្លងមក គោលនយោបាយដែលបានបោះផ្សាយ ឬសេចក្តីប្រកាសថ្មីៗដោយឡែកណាមួយ និង

(ខ)ជាលទ្ធផលពេលដែលអង្គភាពបានបង្កើតនូវការរំពឹងទុកសុពលមួយលើការទទួលខុសត្រូវចំពោះភាគីផ្សេងទៀតថាខ្លួននឹងបន្ថយការទទួលខុសត្រូវទាំងនោះ។

២.២១ ជាធម្មតា ការបំពេញកាតព្វកិច្ចបច្ចុប្បន្នពាក់ព័ន្ធនឹងការទូទាត់ជាសាច់ប្រាក់ ការផ្ទេរទ្រព្យសកម្មដទៃទៀត ការផ្តល់សេវាកម្មនានា ការជំនួសកាតព្វកិច្ចនោះជាមួយកាតព្វកិច្ចផ្សេងទៀត ឬការផ្លាស់ពីកាតព្វកិច្ចទៅជាមូលធនផ្ទាល់។កាតព្វកិច្ចមួយក៏អាចរំលត់តាមមធ្យោបាយផ្សេងទៀត ដូចជា ការលើកលែងពីម្ចាស់បំណុល ឬការធ្វើឱ្យបាត់បង់សិទ្ធិរបស់ម្ចាស់បំណុល។

### មូលធនផ្ទាល់

២.២២ មូលធនផ្ទាល់គឺជាសំណល់នៃទ្រព្យសកម្មបានទទួលស្គាល់បន្ទាប់ពីបានដកបំណុលបានទទួលស្គាល់។ វាអាចត្រូវបានចាត់ជាចំណាត់ថ្នាក់តូចៗនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ។ឧទាហរណ៍ នៅក្នុងអង្គភាពសាជីវកម្មមួយ ការចាត់ចំណាត់ថ្នាក់តូចៗអាចរួមបញ្ចូលនូវមូលនិធិដែលបានផ្តល់ដោយម្ចាស់ភាគហ៊ុន ប្រាក់ចំណេញរក្សាទុក និងចំណេញឬខាតដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធនផ្ទាល់។

### លទ្ធផលហិរញ្ញវត្ថុ

២.២៣ លទ្ធផលហិរញ្ញវត្ថុគឺជាទំនាក់ទំនងរវាងចំណូលនិងចំណាយរបស់អង្គភាពមួយក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍។ស្តង់ដានេះអនុញ្ញាតឱ្យអង្គភាពនានាបង្ហាញពីលទ្ធផលហិរញ្ញវត្ថុនៅក្នុងរបាយការណ៍តែមួយ

(របាយការណ៍ស្តីពីលទ្ធផលសរុប)ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុពីរ(របាយការណ៍ចំណេញ-ខាតនិងរបាយការណ៍ស្តីពីលទ្ធផលសរុប)។ជារឿយៗ លទ្ធផលសរុបនិងចំណេញខាតត្រូវបានប្រើប្រាស់ដើម្បីវាស់វែងលទ្ធផលហិរញ្ញវត្ថុឬប្រើជាមូលដ្ឋានសម្រាប់ការវាស់វែងដទៃទៀត ដូចជា ចំណេញពីវិនិយោគ ឬ ចំណេញក្នុងមួយចំណែកហ៊ុន។ចំណូលនិងចំណាយត្រូវបានឱ្យអត្ថន័យដូចខាងក្រោម÷

(ក)ចំណូលគឺជាកំណើននៃអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាលំហូរចូលឬកំណើនទ្រព្យសកម្មឬតំហយនៃបំណុលដែលជាលទ្ធផលនាំឱ្យមូលធនផ្ទាល់មានការកើនឡើង វាលែងតែកំណើនដែលទាក់ទិននឹងវិភាគទាននៃ មូលធនផ្ទាល់របស់វិនិយោគិន។

(ខ)ចំណាយគឺជាការថយចុះនៃអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍ក្នុងទម្រង់ជាការហូរចេញឬការថយចុះទ្រព្យសកម្មឬការកើនឡើងបំណុល ដែលជាលទ្ធផលនាំឱ្យមូលធនផ្ទាល់ថយចុះ វាលែងតែការថយនោះ បណ្តាលមកពីការបែងចែកដល់មូលធនផ្ទាល់របស់វិនិយោគិន។

២.២៤ ការទទួលស្គាល់ចំណូលនិងចំណាយបណ្តាលមកពីការទទួលស្គាល់និងការវាស់វែងដោយផ្ទាល់នៃទ្រព្យសកម្មនិងបំណុល។លក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ចំណូលនិងចំណាយត្រូវបានពិភាក្សាយ៉ាងច្បាស់នៅក្នុងកថាខណ្ឌ ២.២៧-២.៣២។

ចំណូល

២.២៥ និយមន័យនៃចំណូល សំដៅដល់ទាំងប្រាក់ចំណូលធម្មតា និងទាំងប្រាក់ចំណូលដោយឡែក។

(ក)ប្រាក់ចំណូលធម្មតាគឺជាចំណូលដែលកើតពីប្រតិបត្តិការសកម្មភាពធម្មតារបស់អង្គភាព ហើយវាសំដៅដល់ឈ្មោះចំណូលផ្សេងៗដូចជា ការលក់ ទំនិញនិងសេវាកម្ម ប្រាក់កម្រៃ ការប្រាក់ ភាគលាភ ការបង់តម្លៃសិទ្ធិ និងការជួល។

(ខ)ប្រាក់ចំណូលដោយឡែក គឺជាធាតុផ្សេងទៀតស្របតាមនិយមន័យរបស់ចំណូល ប៉ុន្តែវាមិនមែនជាចំណូលទេ។នៅពេលដែលចំណូលដោយឡែកត្រូវបានទទួលស្គាល់ក្នុង របាយការណ៍ស្តីពីលទ្ធផលសរុប ចំណូលទាំងនោះតែងតែបង្ហាញដាច់ដោយឡែកពីគេ ពីព្រោះការទទួលស្គាល់ចំណូលនេះមានប្រយោជន៍សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

ចំណាយ

២.២៦ និយមន័យរបស់ចំណាយរួមមានការខាតបង់នានាក៏ដូចជាចំណាយទាំងអស់ដែលកើតមានពីសកម្មភាពអាជីវកម្មធម្មតារបស់អង្គភាព។

(ក)ចំណាយដែលកើតមានពីសកម្មភាពអាជីវកម្មធម្មតារបស់អង្គភាព ឧទាហរណ៍ រួមមានដូចជា ថ្លៃដើមលក់ចេញ បៀវត្ស និងរំលស់។ ចំណាយទាំងនោះ ធ្វើឡើងក្រោមទម្រង់ជាលំហូរចេញ ឬការប្រើអស់នូវទ្រព្យសកម្ម ដូចជា សាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល សន្និធិ ឬទ្រព្យ រោងចក្រ និងបរិក្ខា។

(ខ)ការខាតបង់គឺជាធាតុផ្សេងទៀតដែលមានន័យដូចជាចំណាយដែរ ហើយដែលអាចកើតមានពី សកម្មភាពធម្មតារបស់អង្គភាព។នៅពេលដែលការខាតបង់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុបជាធម្មតា ការខាតបង់ទាំងនោះត្រូវបានបង្ហាញដាច់ដោយឡែកពីគ្នា ពីព្រោះការដឹងអំពីការខាតបង់ទាំងនោះមានប្រយោជន៍សម្រាប់ការធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។

### ការទទួលស្គាល់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ

២.២៧ ការទទួលស្គាល់គឺជាដំណើរការនៃការបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវរាល់ធាតុនានាដែលចាត់ជាទ្រព្យសកម្ម បំណុល ចំណូល ឬ ចំណាយ និងដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ÷

(ក)វាគួរឲ្យជឿជាក់ថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលមានជាប់ជាមួយធាតុនោះនឹងហូរចូល ឬចេញពីអង្គភាព និង

(ខ)ធាតុនោះមានថ្លៃដើម ឬ តម្លៃមួយដែលអាចវាស់វែងប្រកបដោយការទុកចិត្ត។

២.២៨ ការខកខានមិនបានទទួលស្គាល់ធាតុមួយដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យខាងលើមិនត្រូវបានធ្វើការកែតម្រូវដោយការលាតត្រដាងអំពីគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ ឬ ដោយកំណត់សម្គាល់ ឬ ការពន្យល់ណាមួយទេ។

### ភវនីយតាព នៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត

២.២៩ ទស្សនទាននៃភវនីយភាពត្រូវបានប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ដំបូង ដោយសំដៅដល់កម្រិតនៃភាពមិនប្រាកដប្រជា ដែលថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលមានជាប់ជាមួយធាតុនានានឹងហូរចូលក្នុងឬហូរចេញពីអង្គភាព។ ការវាយតម្លៃអំពីកម្រិតនៃភាពមិនប្រាកដប្រជា ដែលភ្ជាប់ជាមួយលំហូរនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ត្រូវបានធ្វើឡើងដោយផ្អែកលើ មូលដ្ឋាននៃភស្តុតាងដែលទាក់ទងនឹងលក្ខខណ្ឌនានា នាចុងការិយបរិច្ឆេទរាយការណ៍ដែលអាចធ្វើបានពេល ដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង។ ការវាយតម្លៃទាំងនោះត្រូវបានធ្វើឡើងដាច់ដោយឡែក សម្រាប់ធាតុសំខាន់ដោយឡែកៗពីគ្នា និងសម្រាប់ក្រុមនៃធាតុមិនសំខាន់ដោយឡែកៗពីគ្នា។

### ភាពអាចជឿជាក់បាននៃការវាស់វែង

២.៣០ លក្ខណៈវិនិច្ឆ័យទីពីរសម្រាប់ទទួលស្គាល់ធាតុមួយ គឺថាធាតុនោះមានថ្លៃដើម និងតម្លៃមួយដែលអាចត្រូវ បានវាស់វែងប្រកបដោយការជឿទុកចិត្ត។ក្នុងករណីជាច្រើន ថ្លៃដើម និងតម្លៃរបស់ធាតុមួយអាចដឹងបាន។ មាន

ករណីផ្សេងទៀត ធាតុមួយត្រូវតែធ្វើការការប៉ាន់ស្មានថ្លៃដើមនិងតម្លៃរបស់វា។ការប្រើប្រាស់ ការវាយតម្លៃដ៏សមហេតុផល គឺជាផ្នែកសំខាន់មួយនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ភាពគួរឲ្យជឿជាក់នោះទេ។នៅពេលដែលការប៉ាន់ស្មានសមហេតុផលមិនអាចធ្វើទៅបាន ធាតុនោះមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

២.៣១ ធាតុមួយដែលមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ អាចមានគុណវុឌ្ឍិសម្រាប់ការទទួលស្គាល់នាកាលបរិច្ឆេទក្រោយមក ដោយសារតែកាលទេសៈ ឬព្រឹត្តិការណ៍ដែលកើតមានឡើងពេលក្រោយ។

២.៣២ ទោះជាយ៉ាងណាក៏ដោយ ធាតុមួយដែលមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ អាចអនុញ្ញាតឲ្យធ្វើការលាតត្រដាងនៅក្នុងកំណត់សម្គាល់ ឬការពន្យល់ណាមួយ ឬក្នុងតារាងបន្ថែម។ វាមានភាពសមរម្យ នៅពេលព័ត៌មានអំពីធាតុនោះជាប់ពាក់ព័ន្ធនឹងការវាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងការប្រែប្រួលនានានៃស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយ ដោយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។

## ការវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ

២.៣៣ ការវាស់វែងគឺជាដំណើរការនៃការកំណត់នូវបរិមាណជារូបិយវត្ថុដែលអង្គភាពប្រើសម្រាប់វាស់វែង ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ការវាស់វែងទាក់ទិននឹងការជ្រើសរើសមូលដ្ឋានសម្រាប់ការវាស់វែង។ស្តង់ដានេះបញ្ជាក់អំពីថាតើមូលដ្ឋាននៃការវាស់វែងមួយណា ដែលអង្គភាពមួយត្រូវប្រើប្រាស់សម្រាប់វាស់វែងលើប្រភេទនានានៃទ្រព្យសកម្ម បំណុល ចំណូល និង ចំណាយ។

២.៣៤ មានមូលដ្ឋានសម្រាប់ការវាស់វែងពីរ គឺ ថ្លៃដើមដំបូងនិងតម្លៃទីផ្សារ ÷

(ក) សម្រាប់ទ្រព្យសកម្ម **ថ្លៃដើមដំបូង**គឺជាបរិមាណសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែលដែលបានទូទាត់ ឬជាតម្លៃទីផ្សារនៃតម្លៃតបស្នង(ថ្នូរ)ដែលបានផ្តល់ឲ្យដើម្បីទទួលបានទ្រព្យសកម្មនាពេលទទួលបានទ្រព្យសកម្មនោះ។សម្រាប់បំណុល ថ្លៃដើមដំបូង គឺជាបរិមាណចំណូលជាសាច់ប្រាក់ ឬសាច់ប្រាក់ប្រហាក់ប្រហែលដែលទទួលបានឬតម្លៃទីផ្សារនៃទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ដែលទទួលបានជាថ្នូរនឹងកាតព្វកិច្ច នាពេលដែលកាតព្វកិច្ចបានកើតមានឡើង ឬក្នុងកាលទេសៈខ្លះ (ដូចជា ពន្ធលើ ប្រាក់ចំណេញ)ដែលបរិមាណសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែល ត្រូវបានរំពឹងថានឹងត្រូវទូទាត់ដើម្បីដោះបំណុលដែលកើតមាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា។ ថ្លៃដើមដំបូងដែលបានបង់រំលស់ គឺជាថ្លៃដើមដំបូងរបស់ទ្រព្យសកម្មមួយ ឬបំណុលមួយបូក ឬ ដកជាមួយចំណែកនៃថ្លៃដើមដំបូងដែលទទួលស្គាល់ពីមុនថាជាចំណូល ឬចំណាយ។

(ខ)**តម្លៃទីផ្សារ**គឺជាបរិមាណដែលទ្រព្យសកម្មមួយអាចត្រូវបានធ្វើការដោះដូរ ឬ បំណុលមួយត្រូវបានទូទាត់ រវាងភាគីដែលអាចដឹងបាននិងមានបំណងធ្វើនៅក្នុងប្រតិបត្តិការ ជាធម្មតា។

## គោលការណ៍ទូទៅនៃការទទួលស្គាល់ និងការវាស់វែង

២.៣៥ ការតម្រូវនានាដើម្បីទទួលស្គាល់និងវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយនៅក្នុងស្តង់ដានេះគឺផ្អែកលើមូលដ្ឋាននៃគោលការណ៍ទូទៅដែលបានមកពីក្របខណ្ឌសម្រាប់រៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិនិងពីស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។នៅពេលដែលមិនមានការតម្រូវក្នុងស្តង់ដានេះដែលអនុវត្តជាពិសេសចំពោះប្រតិបត្តិការមួយឬចំពោះព្រឹត្តិការណ៍ឬលក្ខ ណ្ឌដទៃទៀតកថាខណ្ឌ១០.៤នឹងផ្តល់នូវគោលការណ៍ណែនាំសម្រាប់ធ្វើការវិនិច្ឆ័យណាមួយ ហើយកថាខណ្ឌ ១០.៥ នឹងបង្កើតនូវឋានានុក្រមមួយសម្រាប់អង្គភាពធ្វើតាម ក្នុងការសម្រេចលើគោលនយោបាយគណនេយ្យសមស្របក្នុងពេលដែលមានកាលទេសៈពិសេសនានាកើតឡើង។ កម្រិតទីពីរនៃឋានានុក្រមនោះតម្រូវឱ្យអង្គភាពមួយពិនិត្យលើនិយមន័យ លក្ខណៈវិនិច្ឆ័យក្នុងការទទួលស្គាល់ និងទស្សនទាននៃការវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ព្រមទាំងគោលការណ៍ ទូទៅដែលកំណត់នៅក្នុងផ្នែកនេះ។

## មូលដ្ឋានបង្គរ

២.៣៦ អង្គភាពមួយត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយប្រើការកត់ត្រាគណនេយ្យតាមមូលដ្ឋានបង្គរ លើកលែងតែព័ត៌មានអំពីលំហូរសាច់ប្រាក់។ ឈរលើមូលដ្ឋានបង្គរ ធាតុនានាត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម បំណុល មូលធនផ្ទាល់ ចំណូលឬចំណាយ នៅពេលដែលធាតុទាំងនោះ បំពេញបានតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ និងនិយមន័យរបស់ធាតុទាំងអស់នោះ។

## ការទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

### ទ្រព្យសកម្ម

២.៣៧ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលអង្គភាពជឿជាក់ថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតនឹងហូរចូលអង្គភាពហើយទ្រព្យសកម្មមានថ្លៃដើមមួយឬតម្លៃមួយដែលអាចវាយតម្លៃប្រកបដោយការជឿទុកចិត្ត។ទ្រព្យសកម្មមួយមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុទេ នៅពេលដែលចំណាយត្រូវបានកើតឡើង ហើយដែលអង្គភាពគិតថាចំណាយនោះនឹងមិននាំឱ្យមានលំហូរអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចចូលអង្គភាពហួសការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន។ប្រតិបត្តិការនេះបណ្តាលឱ្យមានការទទួលស្គាល់ចំណាយនៅក្នុងរបាយការណ៍លទ្ធផលសរុប(ឬនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើត្រូវបានបង្ហាញ)។

២.៣៨ អង្គភាពមួយមិនត្រូវទទួលស្គាល់ទ្រព្យសកម្មយថាហេតុ ថាជាទ្រព្យសកម្មមួយនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលដែលលំហូរនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់អង្គភាពមានភាព ពិតប្រាកដយ៉ាងជាក់

ច្បាស់ពេលនោះទ្រព្យសកម្មដែលពាក់ព័ន្ធមិនមែនជាទ្រព្យសកម្មយថាហេតុទេ ហើយការទទួលស្គាល់ទ្រព្យសកម្ម នោះអាចធ្វើទៅបាន។

បំណុល

២.៣៩ អង្គភាពមួយ ត្រូវទទួលស្គាល់បំណុលនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៅពេល ÷

(ក)អង្គភាពមានកាតព្វកិច្ចនាចុងការិយបរិច្ឆេទរាយការណ៍ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កាលពីអតីតកាល

(ខ) អាចជឿជាក់បានថា អង្គភាពនឹងត្រូវបានតម្រូវឲ្យផ្ទេរនូវធនធានដែលតំណាងឲ្យ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលត្រូវដោះស្រាយ និង

(គ)បរិមាណទឹកប្រាក់ដែលត្រូវទូទាត់ អាចធ្វើការវាស់វែងបានប្រកបដោយការទុកចិត្ត។

២.៤០ បំណុលយថាហេតុ គឺមានទាំងកាតព្វកិច្ចដែលអាចកើតមានតែពុំពិតប្រាកដ និងទាំងកាតព្វកិច្ចបច្ចុប្បន្ន ដែលមិនត្រូវបានទទួលស្គាល់ ដោយសារតែវាមិនបំពេញបានតាមលក្ខខណ្ឌមួយ ឬទាំពីរ នៃចំណុច (ខ)និង(គ) នៃកថាខណ្ឌ២.៣៩។អង្គភាពមិនត្រូវទទួលស្គាល់បំណុលយថាហេតុថាជាបំណុល លើកលែងតែបំណុលយថាហេតុរបស់អ្នកលក់នៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលផ្នែកទី ១៩ ស្តីពី ការរួមបញ្ចូល អាជីវកម្ម និងមូលនិធិពាណិជ្ជកម្ម)។

ចំណូល

២.៤១ ការទទួលស្គាល់ចំណូលគឺបានមកដោយផ្ទាល់ពីការទទួលស្គាល់និងការវាស់វែងទ្រព្យសកម្មនិងបំណុល។ អង្គភាពមួយត្រូវទទួលស្គាល់ចំណូលនៅក្នុងរបាយការណ៍លទ្ធផលសរុប(ឬនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើបានបង្ហាញ)នៅពេលដែលមានកំណើនអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតទាក់ទិនទៅនឹងកំណើននៃទ្រព្យសកម្ម ឬការថយចុះនៃបំណុល អាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន។

ចំណាយ

២.៤២ ការទទួលស្គាល់ចំណាយគឺបានមកដោយផ្ទាល់ពីការទទួលស្គាល់និងការវាស់វែងទ្រព្យសកម្មនិងបំណុល។ អង្គភាពមួយត្រូវទទួលស្គាល់ចំណាយនៅក្នុងរបាយការណ៍លទ្ធផលសរុប(ឬនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើបានបង្ហាញ) នៅពេលដែលមានកំណើនអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ទាក់ទិនទៅនឹងកំណើននៃទ្រព្យសកម្ម ឬការថយចុះនៃបំណុល អាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន។

លទ្ធផល ចំណូលសរុប និង ចំណេញ-ខាត

២.៤៣ លទ្ធផលចំណូលសរុប គឺជាភាពខុសគ្នានៃលេខគណិតរវាងចំណូលនិងចំណាយ។ វាមិនមែនជាធាតុមួយដោយឡែកនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគោលការណ៍នៃការទទួលស្គាល់ដាច់ដោយឡែកមិនមានការចាំបាច់សម្រាប់លទ្ធផលនោះដែរ។

២.៤៤ ចំណេញ-ខាត គឺជាភាពខុសគ្នានៃលេខគណិតរវាងចំណូល និងចំណាយ ក្រៅពីធាតុនានានៃចំណូលនិងចំណាយដែលស្តង់ដារនេះចាត់ថ្នាក់វាជាធាតុនៃចំណូលសរុបផ្សេងទៀត។វាមិនមែនជាធាតុមួយដោយឡែកនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគោលការណ៍នៃការទទួលស្គាល់ដាច់ដោយឡែក ក៏មិនមានការចាំបាច់សម្រាប់លទ្ធផលនោះដែរ។

២.៤៥ ស្តង់ដារនេះមិនអនុញ្ញាតឱ្យទទួលស្គាល់ធាតុនានានៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ ដែលមិនបំពេញបាននូវនិយមន័យរបស់ទ្រព្យសកម្មឬបំណុលដោយមិនគិតពីថាតើធាតុទាំងនោះកើតមកពីការអនុវត្តសញ្ញាណរួមនៃ "ទស្សនទានផ្គូរផ្គង" ដើម្បីវាស់វែងចំណេញ-ខាតនោះទេ។

## ការវាស់វែងនាពេលទទួលស្គាល់ដំបូង

២.៤៦ នាពេលទទួលស្គាល់ដំបូង អង្គភាពមួយត្រូវវាស់វែងទ្រព្យសកម្ម និងបំណុលតាមថ្លៃដើមដែលបានកំណត់មុនៗ លើកលែងតែស្តង់ដារនេះតម្រូវឱ្យវាស់វែងដំបូងដោយផ្អែកលើមូលដ្ឋានផ្សេង ដូចជា តាមតម្លៃទីផ្សារជាដើម។

## ការវាស់វែងបន្តបន្ទាប់

### ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

២.៤៧ អង្គភាពមួយវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុចំបងនិងបំណុលហិរញ្ញវត្ថុចំបងដូចដែលបានកំណត់នៅក្នុងផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុចំបងតាមថ្លៃដើមរំលស់ដកការថយចុះតម្លៃលើកលែងតែការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបម្លែងនិងដាក់លក់បាននិងការវិនិយោគលើភាគហ៊ុនធម្មតាដែលមិនអាចដាក់លក់បាន ដែលត្រូវបានដាក់ឱ្យទិញ-លក់ជាសាធារណៈ ហើយតម្លៃទីផ្សាររបស់ភាគហ៊ុនទាំងនោះអាចត្រូវបានវាស់វែងផ្សេងពីនេះប្រកបដោយការជឿទុកចិត្ត និងដែលត្រូវបានវាស់វែងតាមតម្លៃទីផ្សារដែលអាចប្រែប្រួលទទួលស្គាល់នៅក្នុងចំណេញ-ខាត។

២.៤៨ ជាទូទៅ អង្គភាពមួយវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ និ ងបំណុលហិរញ្ញវត្ថុដទៃទៀត តាមតម្លៃទីផ្សារ ដោយឱ្យមានការប្រែប្រួលតម្លៃទីផ្សារនេះ នៅក្នុងចំណេញ-ខាត លើកលែងតែស្តង់ដារនេះតម្រូវ ឬអនុញ្ញាតឱ្យមានការវាស់វែងដោយផ្អែកលើមូលដ្ឋានផ្សេងទៀត ដូចជា មូលដ្ឋានថ្លៃដើមឬថ្លៃដើមរំលស់។

### ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

២.៤៩ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុភាគច្រើនដែលអង្គភាពបានទទួលស្គាល់ដំបូងតាមថ្លៃដើមមុនៗ ត្រូវបានវាស់វែងពេលបន្តបន្ទាប់ដោយផ្អែកលើមូលដ្ឋានផ្សេងទៀត។ ឧទាហរណ៍ ដូចជា ÷

(ក)អង្គភាពមួយ វាស់វែងទ្រព្យ រោងចក្រ និងបរិក្ខា តាមថ្លៃដើមដែលបានរំលស់ និងចំនួនទឹកប្រាក់ដែលអាចស្តារឡើងវិញបាន។

(ខ)អង្គភាពមួយវាស់វែងសន្និធិតាមថ្លៃដើមទាបជាង និងថ្លៃលក់ ដកថ្លៃដើមបំពេញ និង ថ្លៃដើមលក់។

(គ)អង្គភាពមួយទទួលស្គាល់ការខាតបង់ដោយសារភាពសឹករិចរិល ទាក់ទិននឹងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដែលកំពុងតែប្រើប្រាស់ឬរក្សាទុកសម្រាប់លក់។ការវាស់វែងលើទ្រព្យសកម្មក្នុងបរិមាណទាបដូចនោះ ត្រូវបាន ធ្វើឡើងក្នុងគោលបំណងធានាថា ទ្រព្យសកម្ម មួយមិនត្រូវបានវាស់វែងក្នុងបរិមាណច្រើនជាងអង្គភាពរំពឹងថា នឹងទទួលបានពីការលក់ ឬការប្រើប្រាស់ទ្រព្យសកម្មនោះ។

២.៥០ សម្រាប់ប្រភេទនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដូចខាងក្រោម ស្តង់ដានេះអនុញ្ញាតឬតម្រូវឲ្យវាស់វែងតាមតម្លៃ ទីផ្សារ ÷

(ក)ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និង ក្រុមហ៊ុនរួមទុនដែលអង្គភាពត្រូវ វាស់វែងតាមតម្លៃទីផ្សារ (មើល កថាខណ្ឌ ១៤.១០ និង ១៥.១៥)។

(ខ)ទ្រព្យវិនិយោគដែលអង្គភាពត្រូវវាស់វែងតាមតម្លៃទីផ្សារ (មើល កថាខណ្ឌ ១៦.៧)

(គ)ទ្រព្យសកម្មផ្នែកកសិកម្ម(ទ្រព្យសកម្មជីវសាស្រ្ត និងផលិតផលកសិកម្មនាពេលប្រមូលផល) ដែលអង្គភាព ត្រូវវាស់វែងតាមតម្លៃទីផ្សារ ដកថ្លៃដើមលក់ដែលបាន ប៉ាន់ស្មាន (មើល កថាខណ្ឌ ៣៤.២)។

### បំណុលដែលមិនមែនជាបំណុលហិរញ្ញវត្ថុ

២.៥១ បំណុលភាគច្រើន លើកលែងតែបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដោយធ្វើការប៉ាន់ស្មានឲ្យបានល្អបំផុតលើ បរិមាណដែលអាចតម្រូវ ដើម្បីទូទាត់បំណុលនាកាលបរិច្ឆេទរាយការណ៍។

### ការទូទាត់/ការកាត់កង

២.៥២ អង្គភាពមួយមិនត្រូវទូទាត់ឬកាត់កងរវាងទ្រព្យសកម្ម និងបំណុល ឬរវាងចំណូល និងចំណាយ វាលែង តែស្តង់ដារនេះ បានតម្រូវ ឬអនុញ្ញាត។

(ក)ការវាស់វែងទ្រព្យសកម្ម ដោយដកចេញការទូទាត់ដែលបានផ្តល់ឲ្យសម្រាប់ការវាយតម្លៃ មិនត្រូវទូទាត់ ឬកាត់កងទេ ឧទាហរណ៍ដូចជា វិភាជន៍សម្រាប់ការលែងប្រើកើត (ភាពហួសសម័យ)នៃសន្និធិ និងវិភាជន៍ សម្រាប់ចំណូលដែលមិនអាចប្រមូលបាន។

(ខ)ប្រសិនបើ សកម្មភាពប្រតិបត្តិការរបស់អង្គភាពមិនរាប់បញ្ចូលការទិញនិងលក់ទ្រព្យសកម្មរយៈពេលវែងរួម ទាំងទ្រព្យសកម្មវិនិយោគនិងប្រតិបត្តិការផងនោះ អង្គភាពត្រូវរាយការណ៍នូវផលចំណេញនិងការខាតបង់តាម ការលក់បញ្ចេញចោលនូវទ្រព្យសកម្មទាំងនោះ ដោយដកចេញពីចំណូលពីការលក់បញ្ចេញចោលនូវតម្លៃ ក្នុងបញ្ជី របស់ទ្រព្យសកម្ម និងចំណាយលើការលក់ដែលពាក់ព័ន្ធ។

## ផ្នែកទី ៣

# ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

### វិសាលភាពរបស់ផ្នែកនេះ

៣.១ ផ្នែកនេះ ពន្យល់អំពីការបង្ហាញដ៏ត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមការតម្រូវដោយស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ហើយដែលមានគ្រប់ផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ។

### ការបង្ហាញដ៏ត្រឹមត្រូវ

៣.២ របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញឲ្យបានត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាពមួយ។ការបង្ហាញដ៏ត្រឹមត្រូវតម្រូវឲ្យបង្ហាញឡើងវិញដោយស្មោះត្រង់នូវឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍និងលក្ខខណ្ឌដទៃទៀត ស្របតាមនិយមន័យ និងលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដូចដែលបានចែងក្នុងផ្នែកទី ២ អំពីទស្សនទាន និងគោលការណ៍ទូទៅ។

(ក)ការអនុវត្តនូវស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម រួមជាមួយនឹងការលាតត្រដាងព័ត៌មានបន្ថែមទៀតបើមានការចាំបាច់ ត្រូវបានស ន្មត់ថាមានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុតាមគោលការណ៍នៃការបង្ហាញដ៏ត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់សហគ្រាសធុនតូចនិងមធ្យម។

(ខ)ដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌ១.៥ ការអនុវត្តនូវស្តង់ដារនេះដោយអង្គភាពមួយដែលទទួលខុសត្រូវជាសាធារណៈមិនមែនជាការអនុវត្តនូវគោលការណ៍នៃការបង្ហាញដ៏ត្រឹមត្រូវស្របតាមស្តង់ដានេះទេ។

ការលាតត្រដាងព័ត៌មានបន្ថែមដែលមានចែងក្នុងចំណុច(ក)ខាងលើ ចាំបាច់ត្រូវធ្វើ នៅពេលដែលអនុលោមតាមការតម្រូវពិសេសនានាក្នុងស្តង់ដារនេះនៅតែមិនគ្រប់គ្រាន់សម្រាប់ឲ្យអ្នកប្រើប្រាស់ អាចយល់អំពីឥទ្ធិពលនៃប្រតិបត្តិការពិសេសដោយឡែកនានាព្រឹត្តិការណ៍និងលក្ខខណ្ឌដទៃទៀតលើស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុហិរញ្ញវត្ថុរបស់អង្គភាព។

### អនុលោមភាពតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម

៣.៣ អង្គភាពដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនអនុលោមតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមត្រូវតែបង្ហាញឲ្យបានច្បាស់លាស់និងដោយស្មោះត្រង់អំពីអនុលោមភាពនោះនៅក្នុងកំណត់សម្គាល់។មិនត្រូវពិពណ៌នាក្នុងរបាយការណ៍ហិរញ្ញវត្ថុថាបានអនុលោមទៅនឹងស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមទេ លើកលែងតែរបាយការណ៍ហិរញ្ញវត្ថុទាំងនោះបានអនុលោមតាមគ្រប់ការតម្រូវនានានៅក្នុងស្តង់ដានេះ។

៣.៤ ក្នុងកាលទេសៈដ៏កម្រខ្លះនៅពេលណាដែលអ្នកគ្រប់គ្រងសម្រេចថាការអនុលោមតាមស្តង់ដានេះអាចនាំឱ្យខុសដែលកំហុសនេះអាចនាំឱ្យមានទំនាស់ ឬប៉ះពាល់ដល់គោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យមដូចបានចែងក្នុងផ្នែកទី២ អង្គភាពត្រូវងាកចេញពីការតម្រូវនោះ តាមវិធីដូចមានចែងក្នុងកថាខណ្ឌ ៣.៥ វាលែងតែក្របខណ្ឌនៃវិធានពាក់ព័ន្ធបានហាមអំពីការងាកចេញនោះ។

៣.៥ នៅពេលដែលអង្គភាពមួយងាកចេញពីការតម្រូវនៃស្តង់ដានេះ ស្របតាមកថាខណ្ឌ ៣.៤ ខាងលើ អង្គភាពត្រូវលាតត្រដាងនូវព័ត៌មានដូចខាងក្រោម ÷

(ក) ថាអ្នកគ្រប់គ្រងបានសម្រេចថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញយ៉ាងត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។

(ខ) ថាអង្គភាពបានអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម លើកលែងតែអង្គភាពបានងាកចេញពីការតម្រូវដោយឡែកណាមួយ ដើម្បីឱ្យការបង្ហាញដ៏ត្រឹមត្រូវអាចកើតមាន។

(គ) ចរិកលក្ខណៈនៃការងាកចេញរួមទាំងការកត់ត្រាដែលស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមតម្រូវព្រមទាំងហេតុផលថាតើហេតុអ្វីបានជាការកត់ត្រាបែបនេះអាចមានកំហុសនាកាលទេសៈដែលអាចមានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងផ្នែកទី២ ហើយថាតើហេតុអ្វីបានជាត្រូវអនុម័តយកការកត់ត្រាបែបនេះ។

៣.៦ នៅពេលដែលអង្គភាពមួយងាកចេញពីការតម្រូវតាមស្តង់ដារនេះនាការិយបរិច្ឆេទមុន ហើយដែលការងាកចេញនេះមានផលប៉ះពាល់ដល់បរិមាណនានាដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនា ការិយបរិច្ឆេទបច្ចុប្បន្ន អង្គភាពនោះត្រូវលាតត្រដាងព័ត៌មាននានាដែលមានចែងក្នុងកថាខណ្ឌ ៣.៥ (គ)។

៣.៧ ក្នុងកាលទេសៈដ៏កម្រខ្លះនៅពេលណាដែលអ្នកគ្រប់គ្រងសម្រេចថាការអនុលោមតាមការតម្រូវដោយស្តង់ដានេះអាចនាំឱ្យខុសដែលកំហុសនេះអាចនាំឱ្យមានទំនាស់ឬប៉ះពាល់ដល់គោលដៅរបស់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសធុនតូចនិងមធ្យម ដូចបានចែងក្នុងផ្នែកទី២ ប៉ុន្តែបើមានក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធហាមមិនឱ្យងាកចេញពីការតម្រូវអង្គភាពត្រូវតែរិះរកលទ្ធភាពជាអតិបរមាដើម្បីកាត់បន្ថយកំហុសដោយមិនអនុលោមតាមដែលបានដឹងរួចហើយថាមាន ដោយធ្វើការលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) ចរិកលក្ខណៈនៃការតម្រូវក្នុងស្តង់ដារនេះ ព្រមទាំងហេតុផលថា តើហេតុអ្វីបានជាអ្នកគ្រប់គ្រងបានសម្រេចថាការអនុលោមតាមការតម្រូវនាំឱ្យមានកំហុសនាកាលទេសៈ ដែលការតម្រូវមានទំនាស់ជាមួយគោលដៅនៃរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងផ្នែកទី២។

(ខ) សម្រាប់ការិយបរិច្ឆេទដែលត្រូវបង្ហាញនិមួយៗការកែតម្រូវលើធាតុនីមួយៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលអ្នកគ្រប់គ្រងបានសម្រេចអាចមានការចាំបាច់ដើមសម្រេចបាននូវការបង្ហាញមួយដ៏ត្រឹមត្រូវ។

## និរន្តរភាព

៣.៨ នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុអ្នកគ្រប់គ្រងរបស់អង្គភាពមួយដែលប្រើស្តង់ដារនេះត្រូវធ្វើការ វាយតម្លៃអំពីលទ្ធភាពរបស់អង្គភាពក្នុងការបន្តនិរន្តរភាពរបស់ខ្លួន។អង្គភាពមួយត្រូវតែមាននិរន្តរភាព លើកលែងតែអ្នកគ្រប់គ្រងមានបំណងជំរះបញ្ជីអង្គភាពឬបញ្ឈប់ប្រតិបត្តិការឬពុំមានជម្រើសអ្វីក្រៅពីធ្វើដូច្នេះ។ក្នុងការវាយតម្លៃថាតើការសន្មត់អំពីនិរន្តរភាពមួយសមស្របឬអត់ អ្នកគ្រប់គ្រងត្រូវយកចិត្តទុកដាក់គិតគូរអំពីព័ត៌មានដែលអាចមានអំពីអនាគតយ៉ាងហោចណាស់ ១២ខែ ឬច្រើនជាងនេះគិតពីកាលបរិច្ឆេទរាយការណ៍។

៣.៩ ក្នុងការវាយតម្លៃរបស់ខ្លួនអ្នកគ្រប់គ្រងបានដឹងអំពីភាពមិនប្រាកដប្រជាជាសារវន្តទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលទាត់ចោលការមន្ទិលសង្ស័យខ្លាំងលើលទ្ធភាពរបស់អង្គភាពក្នុងការបន្តនិរន្តរភាព អង្គភាពត្រូវលាតត្រដាងអំពីភាពមិនប្រាកដប្រជាទាំងនោះ។នៅពេលដែលអង្គភាពនោះមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋាននិរន្តរភាព អង្គភាពត្រូវលាតត្រដាងនូវបញ្ហានេះនិងមូលដ្ឋានដែលអង្គភាពប្រើដើម្បីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងហេតុផលដែលអង្គភាពមិនចាត់ទុកថាជានិរន្តរភាព។

## ភាពញឹកញាប់នៃរបាយការណ៍ហិរញ្ញវត្ថុ

៣.១០ អង្គភាពមួយត្រូវបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុទាំងអស់(រួមមាន ព័ត៌មានសរុប- សូមមើលកថាខណ្ឌ៣.១៤) យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ។នៅពេលដែលបញ្ចប់ការិយបរិច្ឆេទរាយការណ៍របស់អង្គភាពមានការប្រែប្រួល ហើយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានបង្ហាញសម្រាប់ការិយបរិច្ឆេទច្រើនជាងឬតិចជាងមួយឆ្នាំ អង្គភាពត្រូវលាតត្រដាងព័ត៌មាន ដូចខាងក្រោម ÷

(ក) ហេតុដែលបានរៀបរាប់ខាងលើ។

(ខ) ហេតុផលដែលប្រើការិយបរិច្ឆេទលើស ឬតិចជាមួយឆ្នាំ។

(គ) ហេតុដែលបរិមាណប្រៀបធៀបដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ(រាប់ទាំងកំណត់សម្គាល់ពាក់ព័ន្ធ) មិនអាចធ្វើការប្រៀបធៀបបានទាំងស្រុង។

## សង្គតិភាពនៃការបង្ហាញ

៣.១១ អង្គភាពមួយត្រូវរក្សាការបង្ហាញ និងចំណាត់ថ្នាក់នៃធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឲ្យដូចៗគ្នា ពីការិយបរិច្ឆេទមួយទៅការិយបរិច្ឆេទក្រោយទៀត វាលែងតែ ÷

(ក) ដោយសារតែមានការប្រែប្រួលជាចម្បងលើប្រភេទប្រតិបត្តិការរបស់អង្គភាពមួយ ឬដោយសារតែមានការពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ វាប្រាកដជាថាការបង្ហាញ ឬចំណាត់ថ្នាក់ផ្សេងទៀតអាចត្រូវបានធ្វើឡើងដោយយល់ថាលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសយកនិងការអនុវត្តគោលនយោបាយគណនេយ្យនៅក្នុងផ្នែកទី១០ស្តីពីគោលនយោបាយគណនេយ្យការប៉ាន់ស្មាន និងកំហុសឆ្គង ឬ

(ខ) ស្តង់ដារនេះតម្រូវឲ្យកែប្រែនូវការបង្ហាញ។

៣.១២ នៅពេលដែលការបង្ហាញ ឬចំណាត់ថ្នាក់ធាតុនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានការប្រែប្រួល អង្គភាពមួយត្រូវធ្វើចំណាក់ថ្នាក់ឡើងវិញនៅបរិមាណដែលអាចប្រៀបធៀប វាលែងតែចំណាត់ថ្នាក់ឡើងវិញនោះមិនអាចអនុវត្តបាន។នៅពេលបរិមាណដែលអាចប្រៀបធៀបបានមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ អង្គភាពត្រូវបង្ហាញនូវព័ត៌មានដូចខាងក្រោម ÷

(ក)ចរិកលក្ខណៈនៃចំណាត់ថ្នាក់ឡើងវិញ។

(ខ)បរិមាណនៃធាតុនិមួយៗ ឬថ្នាក់នៃធាតុនានាដែលបានធ្វើចំណាត់ថ្នាក់ជាថ្មី។

(គ)ហេតុផលដែលនាំឱ្យមានចំណាត់ថ្នាក់ឡើងវិញ។

## ព័ត៏មានប្រៀបធៀប

៣.១៤ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានប្រៀបធៀបចំពោះកាលបរិច្ឆេទដែលអាចប្រៀបធៀបបានមុនៗនូវរាល់បរិមាណដែលបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្នលើកលែងតែពេលដែលស្តង់ដានេះអនុញ្ញាត ឬតម្រូវផ្សេងពីនេះ។អង្គភាពត្រូវបញ្ចូលនូវព័ត៌មានប្រៀបធៀបសម្រាប់ព័ត៌មានលំអិត និងមានលក្ខណៈរៀបរាប់នៅពេលដែលព័ត៌មាននោះពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទបច្ចុប្បន្ន។

## ភាពជាសារវន្ត និងការរួមបញ្ចូលគ្នា

៣.១៥ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវថ្នាក់ជាសារវន្តនិមួយៗនៃធាតុប្រហាក់ប្រហែលគ្នា។ អង្គភាពត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវធាតុនានាដែលមានប្រភេទ ឬតួនាទីមិនដូចគ្នា លើកលែងតែធាតុទាំងនោះមិនមានភាពជាសារវន្ត។

៣.១៦ ការលុបចោល ឬការរាយការណ៍ខុសនូវធាតុនានាដែលចាត់ទុកជាសារវន្ត ប្រសិនបើធាតុទាំងនោះ អាចមានឥទ្ធិពលលើសេចក្តីសម្រេចផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុ។ភាពជាសារវន្តគឺអាស្រ័យលើទំហំ និងចរិកលក្ខណៈរបស់ការលុបចោយឬការរាយការណ៍ខុសដែលបានវិនិច្ឆ័យតាមកាលទេសៈជុំវិញ។ ទំហំ ឬចរិកលក្ខណៈនៃធាតុនោះ ឬទាំងទំហំនិងចរិកលក្ខណៈ អាចជាកត្តាកំណត់នៃភាពជាសារវន្ត។

## សំណុំនៃរបាយការណ៍ហិរញ្ញវត្ថុ

៣.១៧ សំណុំនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ ត្រូវរួមបញ្ចូលដូចខាងក្រោម ÷

(ក)របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ នាកាលបរិច្ឆេទរាយការណ៍

(ខ)មួយក្នុងចំណោមខាងក្រោម ÷

១)	របាយការណ៍លទ្ធផលសរុបតែមួយសម្រាប់កាិយបរិច្ឆេទរាយការណ៍ដែលបង្ហាញនូវរាល់ធាតុទាំងអស់នៃចំណូលនិងចំណាយដែលបានទទួលស្គាល់ក្នុងកំឡុងកាិរយបរិច្ឆេទ រួមទាំងធាតុទាំងនោះដែលត្រូវបានទទួលស្គាល់ក្នុងការគណនាចំណេញឬខាត(ដែលជាសរុបរងនៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុប) និងធាតុនានានៃលទ្ធផលសរុបដទៃទៀតឬ

២)	របាយការណ៍លទ្ធផលដាច់ដោយឡែក និងរបាយការណ៍ស្តីពីលទ្ធផលសរុបដាច់ដោយឡែក។ប្រសិនបើអង្គភាពមួយសម្រេចជ្រើសរើសការបង្ហាញនូវរបាយការណ៍ទាំងពីរគឺរបាយការណ៍លទ្ធផលនិងរបាយការណ៍ស្តីពីលទ្ធផលសរុប នោះនាំឱ្យរបាយការណ៍ស្តីពីលទ្ធផលសរុបត្រូវចាប់ផ្តើមគិតពីចំណេញឬខាត ហើយបន្ទាប់មកត្រូវបង្ហាញនូវធាតុនានានៃរបាយការណ៍លទ្ធផលសរុបដទៃទៀត។

(គ)របាយការណ៍នៃបម្រែបម្រួលមូលធុនផ្ទាល់ សម្រាប់កាិរយបរិច្ឆេទរាយការណ៍។

(ឃ)របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់កាិរយបរិច្ឆេទរាយការណ៍។

(ង)កំណត់សម្គាល់ដែលមានការសង្ខេបនូវគោលនយោបាយគណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងទៀត។

៣.១៨ ប្រសិនបើគ្រាន់តែមានការប្រែប្រួលលើមូលធនផ្ទាល់ក្នុងកំឡុងកាិរយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញដែលការប្រែប្រួលនោះបណ្តាលមកពីចំណេញ ឬខាត ការទូទាតលភាគលាភ ការកែប្រែនូវកំហុសឆ្គងនាកាិរយបរិច្ឆេទមុនៗ និងការប្រែប្រួលគោលនយោបាយគណនេយ្យ អង្គភាពអាចបង្ហាញនូវរបាយការណ៍លទ្ធផលនិងរបាយការណ៍ប្រាក់ចំណេញរក្សាទុកតែមួយគត់ជំនួសឱ្យរបាយការណ៍លទ្ធផលសរុបនិងរបាយការណ៍ប្រែប្រួលមូលធនផ្ទាល់(សូមមើលកថាខណ្ឌ ៦.៤)។

៣.១៩ ប្រសិនបើអង្គភាពមួយមិនមានធាតុនៃលទ្ធផលសរុបនានាកាិរយបរិច្ឆេទណាមួយដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ អង្គភាពអាចបង្ហាញតែរបាយការណ៍លទ្ធផល ឬអង្គភាពអាចបង្ហាញនូវរបាយការណ៍លទ្ធផលសរុប ដែលបន្ទាត់ក្រោមបំផុតនៃរបាយការណ៍ត្រូវដាក់ថា “ចំណេញឬខាត”។

៣.២០ ដោយសារទែកថាខណ្ឌ ៣.១៤ តម្រូវថាបរិមាណប្រៀបធៀបចំពោះកាិរយបរិច្ឆេទមុនៗសម្រាប់រាល់បរិមាណទាំងអស់ដែលបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ សំណុំនៃរបាយការណ៍ហិរញ្ញវត្ថុមានន័យថា យ៉ាងហោចណាស់អង្គភាពត្រូវបង្ហាញពីរនៃរបាយការណ៍ហិរញ្ញវត្ថុនិមួយៗនិងកំណត់សម្គាល់ដែលពាក់ព័ន្ធ។

៣.២១ នៅក្នុងសំណុំនៃរបាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុនិមួយៗដោយមានភាពលេចធ្លោស្មើៗ គ្នា។

៣.២២ អង្គភាពមួយអាចប្រើប្រាស់ចំណងជើងនៃរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីចំណងជើងដែលមាននៅក្នុងស្តង់ដានេះដរាបណាចំណងជើងនោះមិននាំឱ្យគេយល់ច្រឡំ។

## អត្តសញ្ញាណកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

៣.២៣ អង្គភាពមួយត្រូវបញ្ជាក់អត្តសញ្ញាណឱ្យច្បាស់នូវរបាយការណ៍ហិរញ្ញវត្ថុនិមួយៗនិងកំណត់សម្គាល់ ព្រមទាំងត្រូវបែងចែកឱ្យដាច់នូវរបាយការណ៍ទាំងនោះពីព័ត៌មាននានាផ្សេងទៀតនៅក្នុងឯកសារតែមួយ។បន្ថែមលើសពីនេះ អង្គភាពត្រូវបង្ហាញឱ្យបានច្បាស់នូវព័ត៌មានដូចខាងក្រោម ហើយត្រូវបង្ហាញវាម្តងទៀតប្រសិនបើមានការចាំបាច់ ដើម្បីឱ្យគេយល់អំពីព័ត៌មានដែលបង្ហាញទាំងនោះ ÷

(ក) ឈ្មោះរបស់អង្គភាពដែលរាយការណ៍និងការប្រែប្រួលលើឈ្មោះនេះ នាចុងការិយបរិច្ឆេទរាយការណ៍បន្តបន្ទាប់។

(ខ) ថាតើរបាយការណ៍ហិរញ្ញវត្ថុគ្របដណ្តប់អង្គភាតែមួយ ឬក្រុមអង្គភាព។

(គ) កាលបរិច្ឆេទចុងការិយបរិច្ឆេទរាយការណ៍និងការិយបរិច្ឆេទដែលគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ។

(ឃ) រូបិយបណ្ណសម្រាប់ប្រើក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលបានកំណត់នៅក្នុងផ្នែកទី៣០ ស្តីពីការប្តូររូបិយប័ណ្ណបរទេស។

(ង) កម្រិតនៃការបំពេញដែលប្រើប្រាស់ក្នុងការបង្ហាញបរិមាណនានានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប្រសិនបើមាន។

៣.២៤ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម នៅក្នុងកំណត់សម្គាល់ ÷

(ក) អាសយដ្ឋាននិងទម្រង់គតិយុត្តិរបស់អង្គភាព ប្រទេសដែលខ្លួនធ្វើអាជីវកម្មនិងអាស្រ័យដ្ឋាននៃការិយាល័យដែលបានចុះបញ្ជី(ឬទីតាំងចម្បងរបស់អាជីវកម្ម ប្រសិនបើវាផ្សេងពីការិយាល័យដែលបានចុះបញ្ជី)។

(ខ) ការពិពណ៌នាអំពីចរិកលក្ខណៈនៃប្រតិបត្តិការរបស់អង្គភាព និងសកម្មភាពចម្បងរបស់អង្គភាព។

## ការបង្ហាញព័ត៌មានដែលមិនតម្រូវដោយស្តង់ដារនេះ

៣.២៥ ស្តង់ដានេះមិននិយាយអំពីការបង្ហាញនូវព័ត៌មានរបស់ផ្នែកនៃអាជីវកម្ម ប្រាក់ចំណេញក្នុងមួយចំណែកហ៊ុន ឬការរាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នដោយសហគ្រាសធុនតូចឬសហគ្រាសធុនមធ្យមនោះទេ។

# ផ្នែកទី ៤
# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## វិសាលភាពនៃផ្នែកនេះ

៤.១ ផ្នែកនេះចែងអំពីព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនិងវិធីនៃការបង្ហាញវា។ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ(ជួនកាលហៅថា តារាងតុល្យការ) បង្ហាញអំពីទ្រព្យសកម្ម បំណុល និង មូលធនផ្ទាល់របស់អង្គភាព នាកាលបរិច្ឆេទកំណត់ណាមួយ គឺនាចុង**ការិយបរិច្ឆេទរាយការណ៍។**

## ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៤.២ យ៉ាងហោចណាស់នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុត្រូវបញ្ចូលនូវធាតុពាក់ព័ន្ធដែលត្រូវបង្ហាញ ដូចខាងក្រោម÷

(ក) សាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែល។

(ខ) គណនីអតិថិជន និង គណនីត្រូវទទួលផ្សេងទៀត។

(គ) ទ្រព្យសកម្មហិរញ្ញវត្ថុ (មិនរាប់បញ្ចូលបរិមាណដែលបង្ហាញនៅក្នុងចំណុច (ក) (ខ) (ញ) និង(ដ))

(ឃ) សន្និធិ។

(ង) ទ្រព្យ រោងចក្រ និងបរិក្ខា

(ច) ទ្រព្យវិនិយោគ ដែលគណនាតាមតម្លៃទីផ្សារតាមរយៈចំណេញ-ខាត។

(ឆ) ទ្រព្យសកម្មអរូបិយ។

(ជ) ទ្រព្យសកម្មជីវសាស្ត្រដែលគណនាតាមថ្លៃដើមដកការរំលស់និងការបាត់បង់តម្លៃដែលបានបូកយោង។

(ឈ) ទ្រព្យសកម្មជីវសាស្ត្រ ដែលបានគណនាតាមតម្លៃទីផ្សារតាមចំណេញ-ខាត

(ញ) វិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

(ដ) វិនិយោគនៅក្នុងក្រុមហ៊ុនត្រួតពិនិត្យរួមគ្នា។

(ឋ) គណនីអតិថិជន និងគណនីត្រូវសងផ្សេងទៀត។

(ឌ) បំណុលហិរញ្ញវត្ថុ (មិនរាប់បញ្ចូលបរិមាណដែលបង្ហាញនៅក្នុងចំណុច (ឋ) និង (ត))។

(ឍ) បំណុល និងទ្រព្យសកម្មសម្រាប់ការបង់ពន្ធរយៈពេលខ្លី (ឬពន្ធក្នុងគ្រា)។

(ណ) បំណុលជាពន្ធពន្យានិងទ្រព្យសកម្មជាពន្ធពន្យា(ទាំងនេះត្រូវតែចាត់ថ្នាក់ថាសម្រាប់រយៈពេលវែង)។

(ត) សំវិធានធន។

(ថ) ភាគកម្មមិនអាចត្រួតត្រាបានដែលបានបង្ហាញឡើងនៅក្នុងមូលធនផ្ទាល់ដាច់ដោយឡែកពីមូលធនផ្ទាល់ដែលអាចផ្តល់ជូនម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនមេ។

(ទ) មូលធនផ្ទាល់ដែលអាចផ្តល់ជូនម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនមេ។

៤.៣ អង្គភាពមួយត្រូវបង្ហាញនូវធាតុពាក់ព័ន្ធបន្ថែម ជាចំណងជើង និងជាសរុបរងនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៅពេលដែលការបង្ហាញបែបនេះមានការពាក់ព័ន្ធនឹងការយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

## ការបែងចែករវាងរយៈពេលខ្លី និងរយៈពេលវែង

៤.៤ អង្គភាពមួយត្រូវបង្ហាញអំពីទ្រព្យសកម្មរយៈពេលខ្លីនិងរយៈពេលវែងបំណុលរយៈពេលខ្លី និងរយៈពេលវែងដោយចាត់ថ្នាក់ដាច់ដោយឡែកពីគ្នានៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ស្របតាមកថាខណ្ឌ ៤.៥-៤.៨ លើកលែងតែ នៅពេលដែលបានបង្ហាញដោយផ្អែកលើមូលដ្ឋានសន្ទនីយភាព ផ្តល់នូវព័ត៌មានដែលអាចជឿទុកចិត្តបាន និងមានការជាប់ពាក់ព័ន្ធខ្លាំង។នៅពេលការលើកលែងនេះយកមកអនុវត្តរាល់ទ្រព្យសកម្ម និងបំណុលត្រូវតែបង្ហាញតាមលំដាប់សន្ទនីយភាពប្រហាក់ប្រហែល (លំដាប់ចុះ ឬឡើង)។

## ទ្រព្យសកម្មរយៈពេលខ្លី

៤.៥អង្គភាពមួយ ត្រូវចាត់ថ្នាក់ទ្រព្យសកម្មមួយថាជាទ្រព្យសកម្មរយៈពេលវែង នៅពេលដែល ÷

(ក) អង្គភាពរំពឹងថាអាចលក់ទ្រព្យសកម្មឬបម្រុងនឹងលក់ឬប្រើប្រាស់វានៅក្នុងវដ្តនៃប្រតិបត្តិការធម្មតារបស់អង្គភាព

(ខ) អង្គភាពរក្សាទុកទ្រព្យសកម្មជាសំខាន់សម្រាប់គោលបំណងដាក់លក់លើទីផ្សារ

(គ) អង្គភាពរំពឹងថាអាចលក់ទ្រព្យសកម្មក្នុងកំឡុងពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ឬ

(ឃ) ទ្រព្យសកម្មគឺជាសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែលលើកលែងតែវាត្រូវបានដាក់កំហិតថាមិនឱ្យមានការប្រែប្រួលឬប្រើប្រាស់ដើម្បីទូទាត់បំណុលសម្រាប់រយៈពេលយ៉ាងហោចណាស់១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

៤.៦ អង្គភាពមួយត្រូវចាត់ថ្នាក់ទ្រព្យសកម្មដទៃទៀតទាំងអស់ថាជាទ្រព្យសកម្មរយៈពេលខ្លី។ប្រសិនបើវដ្តប្រតិបត្តិការធម្មតារបស់អង្គភាពមិនអាចបញ្ជាក់បានច្បាស់លាស់រយៈពេលនៃប្រតិបត្តិការនោះត្រូវបានសន្មត់ថា ១២ខែ។

### បំណុលរយៈពេលខ្លី

៤.៧ អង្គភាពមួយ ត្រូវចាត់ថ្នាក់បំណុលមួយថាជាបំណុលរយៈពេលវែង នៅពេលដែល ÷

(ក)អង្គភាពរំពឹងថានឹងទូទាត់បំណុលក្នុងវដ្តប្រតិបត្តិការរបស់អង្គភាព

(ខ)អង្គភាពកាន់កាប់បំណុលសម្រាប់គោលបំណងចម្បង គឺការធ្វើពាណិជ្ជកម្ម

(គ)បំណុលនឹងដល់ពេលត្រូវទូទាត់សងក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ឬ

(ឃ)អង្គភាពមិនមានសិទ្ធិគ្មានលក្ខខណ្ឌដើម្បីពន្យាការទូទាត់បំណុលសម្រាប់យ៉ាងហោចណាស់រយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។

៤.៨ អង្គភាពមួយត្រូវចាត់ថ្នាក់បំណុលដទៃទៀតទាំងអស់ថាជាបំណុលរយៈពេលខ្លី។

### ការរៀបចំតាមលំដាប់លំដោយ និងទម្រង់នៃធាតុនានានៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ

៤.៩ ស្តង់ដានេះមិនពិពណ៌នាអំពីលំដាប់លំដោយឬទម្រង់នៃធាតុនានាដែលត្រូវបង្ហាញនោះទេ។កថាខណ្ឌ ៤.២ គ្រាន់តែផ្តល់ជាធម្មតានូវបញ្ជីនៃធាតុនានាដែលមានចរិកលក្ខណៈឬមុខងារផ្សេងៗគ្នាយ៉ាងគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យមានការបង្ហាញដាច់ដោយឡែកពីគ្នានៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុតែប៉ុណ្ណោះ។ បន្ថែមលើសនេះទៀត÷

(ក)ធាតុពាក់ព័ន្ធត្រូវបានរាប់បញ្ចូល នៅពេលដែល ទំហំ លក្ខណៈ ឬមុខងាររបស់ធាតុមួយឬ ការរួមបញ្ចូលគ្នានូវធាតុដែលមានលក្ខណៈស្រដៀងគ្នាដែលជាការបង្ហាញដាច់ដោយឡែកពីគ្នា ដែលមានភាពទាក់ទងគ្នានឹងការយល់ដឹងពីអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព, និង

(ខ)ការពិពណ៌នាដែលបានប្រើប្រាស់និងការរៀបតាមលំដាប់លំដោយនៃធាតុឬការសរុបធាតុស្រដៀងគ្នាអាចត្រូវបានកែប្រែអាស្រ័យទៅនឹងប្រភេទរបស់អង្គភាពនិងប្រតិបត្តិការរបស់វាដើម្បីផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងការយល់ដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព។

៤.១០ ការកែតម្រូវថាតើធាតុបន្ថែមនានាត្រូវបានបង្ហាញដាច់ដោយឡែកឬអត់នោះ គឺ អាស្រ័យលើការវាយតម្លៃនៃចំណុចទាំងអស់ដូចខាងក្រោម ÷

(ក)បរិមាណ ចរិកលក្ខណៈ និងសន្ទនីយភាពរបស់ទ្រព្យសកម្ម។

(ខ)មុខងាររបស់ទ្រព្យសកម្មនៅក្នុងអង្គភាព។

(គ)បរិមាណ ចរិកលក្ខណៈ និងការមកដល់ពេលវេលានៃបំណុល។

៤.១១ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានទាំងក្នុងរបាយការណ៍ស្ដីពីស្ថានភាពហិរញ្ញវត្ថុនិងទាំងក្នុងកំណត់សម្គាល់នូវចំណាត់ថ្នាក់រងនានានៃធាតុដែលពាក់ព័ន្ធដែលត្រូវបង្ហាញ ដូចខាងក្រោម ÷

(ក)ទ្រព្យ រោងចក្រ និងបរិក្ខា តាមចំណាត់ថ្នាក់សមស្របចំពោះអង្គភាព។

(ខ)គណនីអតិថិជននិងគណនីត្រូវទទួលផ្សេងទៀតដោយបង្ហាញដាច់ដោយឡែកអំពីបរិមាណដែលដល់កាលកំណត់សងដោយភាគីពាក់ព័ន្ធនានាបរិមាណដែលដល់កាលកំណត់សងពីភាគីដទៃទៀតនិងគណនីត្រូវទទួលដែលកើតមានពីប្រាក់ចំណូលបង្ករដែលមិនទាន់បានទទួល។

(គ) សន្និធិ ដោយបង្ហាញដាច់ដោយឡែកនូវសន្និធិ ÷

១) ដែលរក្សាទុកសម្រាប់លក់ក្នុងប្រតិបត្តិការធម្មតារបស់អាជីវកម្ម

២) ដែលស្ថិតនៅក្នុងដំណើរការផលិតកម្មសម្រាប់ការលក់

៣) ដែលស្ថិតក្នុងទម្រង់ជាសម្ភារៈ ឬការផ្គត់ផ្គង់ដែលត្រូវប្រើប្រាស់នៅក្នុងដំណើការផលិតកម្មឬនៅក្នុងការជួលសេវា។

(ឃ) គណនីអតិថិជនឬគណនីត្រូវសងផ្សេងទៀតដោយបង្ហាញដាច់ដោយឡែកពីគ្នានូវបរិមាណដែលត្រូវទូទាត់ឱ្យអ្នកផ្គត់ផ្គង់ ភាគីពាក់ព័ន្ធ ចំណូលពន្យា និងបង្ករផ្សេងទៀត។

(ង) សំវិធានធនសម្រាប់អត្ថប្រយោជន៍បុគ្គលិក និងសំវិធានធនផ្សេងទៀត។

(ច) ថ្នាក់នៃមូលធនផ្ទាល់ ដែលតម្រូវដោយស្តង់ដារនេះ ដូចជា គណនីដើមទុនដែលបានបង់ហើយ បុព្វលាភភាគហ៊ុន ប្រាក់ចំណេញរក្សាទុក ធាតុនានានៃចំណូលនិងចំណាយដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលចំណូលសរុបផ្សេងទៀត និងដែលបានបង្ហាញដាច់ដោយឡែកនៅក្នុងមូលធនផ្ទាល់។

៤.១២ អង្គភាពមួយដែលមានដើមទុនជាភាគហ៊ុនត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមទាំងក្នុងរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ និងទាំងក្នុងកំណត់សម្គាល់ៈ

(ក)សម្រាប់ថ្នាក់នៃដើមទុនជាមូលធននិមួយៗ÷

១) ចំនួនភាគហ៊ុនដែលបានអនុញ្ញាត។

២) ចំនួននៃភាគហ៊ុនដែលបានបោះផ្សាយនិងបានទូទាត់យ៉ាងពេញលេញនិងដែលបានបោះផ្សាយតែពុំទាន់បានទូទាត់ពេញលេញ។

៣) តម្លៃសន្លឹកហ៊ុនមធ្យម ក្នុងមួយភាគហ៊ុន ឬថាភាគហ៊ុនមិនមានតម្លៃសន្លឹកហ៊ុនមធ្យម។

៤) ការផ្ទួរផ្គងនៃចំនួនភាគហ៊ុនដែលនៅសល់នាដើមនិងចុងការិយបរិច្ឆេទ។

៥) សិទ្ធិ លក្ខខណ្ឌអនុគ្រោះ និងលក្ខខណ្ឌកំហិតនានាដែលមានភ្ជាប់ជាមួយថ្នាក់នោះ រួមបញ្ចូលទាំងលក្ខខណ្ឌកំហិតលើការបែងចែកភាគលាភ និងការទូទាត់ឡើងវិញនៃមូលធន។

៦) ភាគហ៊ុននៅក្នុងអង្គភាពដែលកាន់កាប់ដោយអង្គភាពឬដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនញាតិសម្ព័ន្ធរបស់ខ្លួន។

៧) ភាគហ៊ុនដែលបម្រុងទុកសម្រាប់បោះផ្សាយក្រោមជម្រើសនិងកិច្ចសន្យាលក់ភាគហ៊ុនដោយរួមបញ្ចូលទាំងលក្ខខណ្ឌនិងបរិមាណផង។

(ខ)ការពិពណ៌នាអំពីទុនបម្រុងនិមួយៗនៅក្នុងអង្គភាព។

៤.១៣ អង្គភាពមួយដែលគ្មានដើមទុនជាភាគហ៊ុន ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិឬ បរធនបាលកិច្ចត្រូវលាតត្រដាងព័ត៌មានឲ្យសមាមាត្រទៅតាមព័ត៌មាន ដែលតម្រូវដោយកថាខណ្ឌ៤.១២(ក)ដោយបង្ហាញនូវការប្រែប្រួលនានាក្នុងកំឡុងការិយបរិច្ឆេទលើប្រភេទមូលធនផ្ទាល់និមួយៗ ព្រមទាំងបង្ហាញអំពីសិទ្ធិ លក្ខខណ្ឌអនុគ្រោះ និងលក្ខខណ្ឌកំហិតនានាដែលភ្ជាប់ជាមួយប្រភេទមូលធនផ្ទាល់និមួយៗផង។

៤.១៤ នាកាលបរិច្ឆេទរាយការណ៍ ប្រសិនបើអង្គភាពមានចងដោយកិច្ចព្រមព្រៀងលក់ចំពោះទ្រព្យសកម្មសំខាន់ៗដែលត្រូវបញ្ចេញចោលឬក្រុមនៃទ្រព្យសកម្មនិងបំណុលអង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក)ការពិពណ៌នាអំពីទ្រព្យសកម្មមួយឬច្រើន ឬក្រុមនៃទ្រព្យសកម្មនិងបំណុល។

(ខ)ការពិពណ៌នាអំពីហេតុការណ៍ និងកាលដែលបានលក់ ឬផែនការលក់។

(គ)តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនិងបំណុលទាំងនោះ ប្រសិនបើការលក់បញ្ចេញចោលពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្មនិងបំណុល។

# ផ្នែកទី ៥
# របាយការណ៍លទ្ធផលសរុប និងរបាយការណ៍ចំណេញ-ខាត

## វិសាលភាព

៥.១ ផ្នែកនេះតម្រូវឱ្យអង្គភាពបង្ហាញនូវលទ្ធផលសរុបរបស់ខ្លួនសម្រាប់ការិយបរិច្ឆេទមួយដូចជាលទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទនោះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមួយឬពីរ។ផ្នែកនេះកំណត់អំពីព័ត៌មានដែលត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះនិងថាតើវាត្រូវធ្វើការបង្ហាញយ៉ាងដូចម្ដេច។

## ការបង្ហាញអំពីលទ្ធផលសរុបរួម

៥.២ អង្គភាពមួយត្រូវបង្ហាញលទ្ធផលសរុបរួមរបស់ខ្លួនសម្រាប់ការិយបរិច្ឆេទ ទាំង ÷

(ក)នៅក្នុងរបាយការណ៍លទ្ធផលសរុប តែមួយ ដែលក្នុងករណីនេះ របាយការណ៍លទ្ធផលសរុបបង្ហាញ អំពីសមាសធាតុនៃចំណូលនិងចំណាយទាំងអស់ដែលទទួលស្គាល់ក្នុងការិយបរិច្ឆេទនិងទាំង

(ខ)ក្នុងរបាយការណ៍ពីរគឺរបាយការណ៍ចំណេញ-ខាតនិងរបាយការណ៍លទ្ធផលសរុប ដែលក្នុងករណីនេះ របាយការណ៍លទ្ធផលបង្ហាញអំពីនូវរាល់ចំណូលនិងចំណាយទាំងអស់ដែលទទួលស្គាល់ក្នុងការិយបរិច្ឆេទ លើកលែងតែ ចំណូល-ចំណាយទាំងនោះត្រូវបានទទួលស្គាល់ក្នុងលទ្ធផលសរុបរួម ក្រៅពីចំណេញ-ខាត ដូចដែលបានអនុញ្ញាតឬតម្រូវដោយស្តង់ដានេះ។

៥.៣ ការផ្លាស់ប្តូរពីការប្រើទស្ស នទានរបាយការណ៍តែមួយទៅជាការប្រើទស្សនានរបាយការណ៍ពីរ ឬបញ្ច្រាសមកវិញ គឺជាការផ្លាស់ប្តូរនូវគោលនយោបាយគណនេយ្យដែលត្រូវអនុវត្តក្នុងផ្នែកទី១០ ស្តីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង។

## ទស្សនានរបាយការណ៍តែមួយ

៥.៤ តាមទស្សនៈរបាយការណ៍តែមួយ របាយការណ៍លទ្ធផលសរុបត្រូវតែរួមបញ្ចូលនូវរាល់សមាសធាតុទាំងអស់នៃចំណូលនិងចំណាយដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទវាលែងតែស្តង់ដារនេះតម្រូវផ្សេងពីនេះ។ស្តង់ដានេះផ្តល់នូវការកត់ត្រា(ចំណាត់ការ)ខុសគ្នាផ្សេងៗសម្រាប់កាលទេសៈដូចខាងក្រោម ÷

(ក)ឥទ្ធិពលនៃការកែតម្រូវកំហុសឆ្គង និងការផ្លាស់ប្តូរគោលនយោបាយគណនេយ្យត្រូវបានបង្ហាញថាជាការកែតម្រូវដែលមានលក្ខណៈប្រតិសកម្មនឹងការិយបរិច្ឆេទមុនៗជាមុនសិន ជៀសជាង ដាក់ថាជាផ្នែកនៃចំណេញ-ខាតក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង (មើលផ្នែកទី ១០)។

(ខ)លទ្ធផលសរុបបីប្រភេទផ្សេងទៀតត្រូវបានទទួលស្គាល់ថាជាផ្នែកមួយលទ្ធផលសរុបរួម ក្រៅពីចំណេញ-ខាត នៅពេលដែលលទ្ធផលសរុបកើតឡើង ÷

១) ចំណេញនិងខាតមួយចំនួនដែលកើតឡើងពីការប្តូររបាយការណ៍ហិរញ្ញវត្ថុនៃប្រតិបត្តិការបរទេស (សូមមើលផ្នែកទី ៣០ ស្តីពីការប្តូររូបិយប័ណ្ណបរទេស)។

២) ចំណេញ/ខាតដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់មួយចំនួន(សូមមើលផ្នែកទី២៨ស្តីពីអត្ថប្រយោជន៍បុគ្គលិក)។

៣) ការប្រែប្រួលមួយចំនួននៃតម្លៃទីផ្សារនៃឧបករណ៍ទប់ស្កាត់ហានិភ័យ(សូមមើលផ្នែកទី១២ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុភេសទៀត)។

៥.៥ យ៉ាងហោចណាស់ អង្គភាពត្រូវបញ្ចូលនៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុបនូវសមាសធាតុពាក់ព័ន្ធដែលបង្ហាញអំពីបរិមាណសម្រាប់ការិយបរិច្ឆេទដូចខាងក្រោម ÷

(ក) ចំណូល

(ខ) ថ្លៃដើមហិរញ្ញវត្ថុ

(គ) ចំណែកនៃចំណេ-ខាតនៃវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ(សូមមើលផ្នែកទី១៤ ស្តីពីវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ) និងនៅក្នុងក្រុមហ៊ុនត្រួតពិនិត្យរួមគ្នា (សូមមើល ផ្នែកទី ១៥ ស្តីពីវិនិយោគនៅក្នុងក្រុមហ៊ុន រួមទុន)ដោយត្រូវប្រើវិធីសាស្ត្រមូលធនផ្ទាល់។

(ឃ) ចំណាយលើការបង់ពន្ធ ដោយមិនរាប់បញ្ចូលពន្ធដែលបង់ចំពោះសមាសធាតុនានាដូចក្នុងចំណុច (ង) (ឆ) និង (ជ) ខាងក្រោម (សូមមើលកថាខណ្ឌ ២៩.២៧)។

(ង) បរិមាណតែមួយ ដែលសរុបនូវ ÷

១) ចំណេញ-ខាតមុនបង់ពន្ធនៃប្រតិបត្តិការមិនបន្ត និង

២) ចំណេញ-ខាតមុនបង់ពន្ធដែលត្រូវបានទទួលស្គាល់តាមការវាស់វែងតម្លៃទីផ្សារដកថ្លៃដើមលក់ឬទទួលស្គាល់តាមការលក់បញ្ចេញចោលនូវទ្រព្យសកម្មសុទ្ធដែលនាំឲ្យមានប្រតិបត្តិការមិនបន្ត។

(ច) ចំណេញ-ខាត(ប្រសិនបើអង្គភាពពុំមានសមាសធាតុនៃចំណូលសរុបដទៃទៀត ចំណេញ-ខាតនេះមិនចាំបាច់បង្ហាញនោះទេ)។

(ឆ) សមាសធាតុនិមួយៗនៃចំណូលសរុបដទៃទៀត (សូមមើលកថាខណ្ឌ ៥.៤ (ខ)) ដែលបានចាត់ថ្នាក់តាមប្រភេទ (មិនរាប់បញ្ចូលបរិមាណក្នុង ចំណុច (ជ))។

(ជ) ភាគចំណែកនៃចំណូលសរុបដទៃទៀតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធនិងក្រុមហ៊ុនត្រួតពិនិត្យរួមគ្នាត្រូវបានកត់ត្រាតាមវិធីសាស្ត្រមូលធនផ្ទាល់។

(ឈ) លទ្ធផលចំណូលសរុបរួម(ប្រសិនបើអង្គភាពពុំមានសមាសធាតុនៃចំណូលសរុបដទៃទៀត អង្គភាពអាចប្រើលក្ខខណ្ឌផ្សេងទៀតសម្រាប់លទ្ធផលនេះ ដូចជា ចំណេញ-ខាតជាដើម។

៥.៦ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានដាច់ដោយឡែកពីគ្នានូវធាតុនានាដូចខាងក្រោមនៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុប ថាជាវិភាជន៍សម្រាប់ការិយបរិច្ឆេទ ÷

(ក) ចំណេញ-ខាត សម្រាប់ការិយបរិច្ឆេទ ដែលអាចចាត់ទុកថាជា ÷

១) ភាគកម្មមិនអាចត្រួតពិនិត្យបាន

២) កម្មសិទ្ធិកររបស់ក្រុមហ៊ុនមេ

(ខ) លទ្ធផលសរុបរួម សម្រាប់ការិយបរិច្ឆេទ ដែលអាចចាត់ទុកថាជា ÷

១) ភាគកម្មមិនអាចត្រួតពិនិត្យបាន

២) កម្មសិទ្ធិកររបស់ក្រុមហ៊ុនមេ

**ទស្សនៈរបាយការណ៍ពីរ**

៥.៧ តាមទស្សនៈរបាយការណ៍ពីរ របាយការណ៍ចំណេញ-ខាតត្រូវតែបង្ហាញយ៉ាងហោចណាស់នូវសមាសធាតុពាក់ព័ន្ធដែលបង្ហាញជាបរិមាណដូចនៅក្នុងកថាខណ្ឌ ៥.៥(ក)-៥.៥(ច) សម្រាប់ការិយបរិច្ឆេទ ដោយដាក់ចំណេញ-ខាតនៅបន្ទាត់ចុងក្រោយ។របាយការណ៍ស្តីពីលទ្ធផលសរុបត្រូវចាប់ផ្តើមចំណេញ-ខាតនៅបន្ទាត់ទីមួយ និងត្រូវបង្ហាញយ៉ាងហោចណាស់នូវធាតុពាក់ព័ន្ធដែលបង្ហាញជាបរិមាណដូចនៅក្នុងកថាខណ្ឌ ៥.៥ (ឆ)-៥.៥ (១) និងកថាខណ្ឌ ៥.៦។

**ការតម្រូវនានាដែលអាចអនុវត្តចំពោះទស្សនៈទាំងពីរខាងលើ**

៥.៨ តាមស្តង់ដារនេះឥទ្ធិពលនៃការកែតម្រូវនូវកំហុសឆ្គង និងការប្រែប្រួលនៃគោលនយោបាយគណនេយ្យត្រូវបានបង្ហាញថាជាការកែតម្រូវដែលមានអនុភាពប្រតិសកម្មចំពោះការិយបរិច្ឆេទមុនៗជាជាងថាជាផ្នែកមួយនៃចំណេញ-ខាតក្នុងការិយបរិច្ឆេទដែលចំណេញ-ខាតនោះបានកើតមានឡើង។

៥.៩ អង្គភាពមួយត្រូវបង្ហាញនូវសមាសធាតុពាក់ព័ន្ធបន្ថែមទៀត ដូចជាចំណងជើងនិងសរុបរងនៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុប(និងក្នុងរបាយការណ៍ចំណេញ-ខាតប្រសិនបើវាបានបង្ហាញ) នៅពេលដែលការបង្ហាញនេះពាក់ព័ន្ធនឹងការយល់ដឹងអំពីលទ្ធផលហិរញ្ញវត្ថុហិរញ្ញវត្ថុរបស់អង្គភាព។

៥.១០ អង្គភាពមួយមិនត្រូវបង្ហាញឬពិពណ៌នាអំពីសមាសធាតុនានានៃចំណូលនិងចំណាយថាជា" សមាសធាតុពិសេស" នៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុប (ឬក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើត្រូវបង្ហាញ) ឬនៅក្នុងកំណត់សម្គាល់នោះទេ។

## ការវិភាគលើចំណាយ

៥.១១ អង្គភាពមួយត្រូវបង្ហាញអំពីការវិភាគលើចំណាយដោយធ្វើចំណាត់ថ្នាក់ និងដោយផ្អែកលើមូលដ្ឋាននៃប្រភេទចំណាយនិងតួនាទីរបស់ចំណាយនៅក្នុងអង្គភាពដែលផ្តល់ព័ត៌មានគួរជាទីទុកចិត្តនិងមានការពាក់ព័ន្ធ។

### ការវិភាគតាមប្រភេទចំណាយ

(ក) តាមវិធីសាស្រ្តនៃចំណាត់ថ្នាក់នេះ ចំណាយត្រូវបានបូកសរុបនៅក្នុងរបាយការណ៍លទ្ធផលសរុប ស្របតាមប្រភេទរបស់វា (ដូចជា រំលស់ ទិញសម្ភារៈ សោហ៊ុនដឹកជញ្ជូន អត្ថប្រយោជន៍បុគ្គលិក និងថ្លៃផ្សាយពាណិជ្ជកម្មជាដើម) ហើយដែលចំណាយទាំងនោះមិនត្រូវបានធ្វើវិភាជន៍ឡើងវិញទៅតាមមុខងារផ្សេងៗគ្នានៅក្នុងអង្គភាពឡើយ។

### ការវិភាគតាមតួនាទីរបស់ចំណាយ

(ខ) តាមវិធីសាស្រ្តនៃចំណាត់ថ្នាក់នេះ ចំនាយត្រូវបានបូកសរុបតាមតួនាទីរបស់វា ដូចចា ថាជាផ្នែកមួយនៃថ្លៃដើមលក់ ឬថ្លៃដើមចែកចាយ ឬថ្លៃដើមសកម្មភាពរដ្ឋបាលជាដើម។យ៉ាងហោចណាស់ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីថ្លៃដើមលក់របស់ខ្លួនតាមវិធីសាស្រ្តនេះដាច់ដោយឡែកពីចំណាយផ្សេងៗទៀត។

## ផ្នែកទី ៦
## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនផ្ទាល់ និងរបាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក

### វិសាលភាពនៃផ្នែកនេះ

៦.១ ផ្នែកនេះកំណត់អំពីលក្ខខណ្ឌតម្រូវនានាសម្រាប់ការបង្ហាញនូវការប្រែប្រួលនានានៃមូលធនផ្ទាល់របស់អង្គភាពសម្រាប់ការិយបរិច្ឆេទមួយទាំងនៅក្នុងរបាយការណ៍ស្តីពីបម្រែបម្រួលមូលធនផ្ទាល់និងទាំងនៅក្នុងរបាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក ប្រសិនបើបំពេញបាននូវលក្ខខណ្ឌពិសេស ហើយនិងជម្រើសរបស់អង្គភាព។

### របាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់

គោលបំណង

៦.២ របាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់បង្ហាញនូវចំណេ-ខាតរបស់អង្គភាពសម្រាប់ការិយបរិច្ឆេទរាយការណ៍មួយ បង្ហាញអំពីសមាសធាតុនានារបស់ចំណូលនិងចំណាយដែលបានទទួលស្គាល់នៅក្នុងលទ្ធផលសរុបផ្សេងទៀតសម្រាប់ការិយបរិច្ឆេទនោះ បង្ហាញអំពីឥទ្ធិពលនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យនិងការកែតម្រូវកំហុសឆ្គងដែល០ានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ព្រមទាំងបរិមាណនៃវិនិយោគដោយវិនិយោគិនលើមូលធនផ្ទាល់ និង ភាគលាភនិងវិភាគទានផ្សេងទៀត ដែលត្រូវផ្តល់ផ្តល់ជូនវិនិយោគិនលើមូលធនផ្ទាល់ នៅក្នុងកំឡុងការិយបរិច្ឆេទ។

### ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្តីពតីការប្រែប្រួលមូលធនផ្ទាល់

៦.៣ អង្គភាពមួយត្រូវបង្ហាញនូវរបាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ដោយបង្ហាញនៅក្នុងរបាយការណ៍នូវ ៖

(ក) លទ្ធផលសរុបរួមសម្រាប់ការិយបរិច្ឆេទ ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវបរិមាណសរុបដែលអាចផ្តល់ជូនម្ចាស់ក្រុមហ៊ុនមេ និងជូនភាគកម្មដែលមិនអាចត្រួតត្រាបាន។

(ខ) សម្រាប់សមាសភាគនីមួយៗនៃមូលធនផ្ទាល់ត្រូវបង្ហាញអំពីឥទ្ធិពលនៃការអនុវត្តប្រតិសកម្ម ឬការរាយការណ៍ឡើងវិញជាប្រតិសកម្មដែលបានទទួលស្គាល់ស្របតាមផ្នែកទី១០ស្តីពីគោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និងកំហុសឆ្គង។

(គ) សម្រាប់សមាសភាគនីមួយៗនៃមូលធនផ្ទាល់ត្រូវបង្ហាញអំពីការផ្ទៀងផ្ទាត់រវាងតម្លៃពិតគណនេយ្យនាដើមការិយបរិច្ឆេទនិងនាចុងការិយបរិច្ឆេទដោយលាតត្រដាងដាច់ដោយឡែកពីគ្នានូវការប្រែប្រួលនានាដែលជាលទ្ធផលនៃ ៖

១) ចំណេញ-ខាត។

២) សមាសធាតុនីមួយៗនៃលទ្ធផលសរុបផ្សេងទៀត។

៣) បរិមាណនៃវិនិយោគដោយម្ចាស់ហ៊ុន ព្រមទាំងភាគលាភនិងវភាគទានផ្សេងទៀតដែលត្រូវផ្តល់ជូនម្ចាស់ហ៊ុន ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវ ការបោះផ្សាយសន្លឹកហ៊ុន ប្រតិបត្តិការរតនភាគហ៊ុន (ភាគហ៊ុនអសកម្ម) ភាគលាភនិងវភាគទានផ្សេងទៀតដែលត្រូវផ្តល់ជូនម្ចាស់ហ៊ុន និងការប្រែប្រួលនានាលើភាគកម្មជាកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិននាំឲ្យការបាត់បង់សិទ្ធិត្រួតពិនិត្យ។

## របាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក

### គោលបំណង

៦.៤ របាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក បង្ហាញអំពីចំណេញ-ខាតរបស់អង្គភាព និងការប្រែប្រួលនានានៃប្រាក់ចំណេញរក្សាទុកសម្រាប់ការិយបរិច្ឆេទរាយការណ៍មួយ។ កថាខណ្ឌ ៣.១៨ អនុញ្ញាតឲ្យអង្គភាពមួយបង្ហាញនូវរបាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុកជំនួសឲ្យរបាយការណ៍លទ្ធផលសរុប និងរបាយាការណ៍ស្តីពីការប្រែប្រួលនៃមូលធនផ្ទាល់ ប្រសិនបើគ្រាន់តែមានការប្រែប្រួលទៅលើមូលធនផ្ទាល់របស់អង្គភាពក្នុងកំឡុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញ ហើយការប្រែប្រួលនោះបណ្តាលមកពីចំណេញ-ខាត ការទូទាត់ភាគលាភ ការកែតម្រូវនូវកំហុសឆ្គងនាការិយបរិច្ឆេទមុនៗ និងការប្រែប្រួលនូវគោលនយោបាយគណនេយ្យ។

### ព័ត៌មានដែលត្រូវបង្ហាញនៅក្នុង របាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក

៦.៦ អង្គភាពមួយត្រូវបង្ហាញនៅក្នុង របាយការណ៍ចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក នូវសមាសធាតុនានាដូចខាងក្រោម ដោយបន្ថែមលើព័ត៌មានដែលតម្រូវដោយផ្នែកទី៥ស្តីពីរបាយការណ៍លទ្ធផលសរុប និងរបាយការណ៍ចំណេញ-ខាត ៖

(ក) ប្រាក់ចំណេញរកសាទុកនាដើមការិយបរិច្ឆេទរាយការណ៍។

(ខ) ភាគលាភដែលបានប្រកាស ឬដែលបានទូទាត់ ឬអាចបង់បាននៅក្នុងកំឡុងការិយបរិច្ឆេទ។

(គ) ការរាយការណ៍ឡើងវិញនូវប្រាក់ចំណេញរក្សាទុកសម្រាប់កែតម្រូវនូវកំហុសឆ្គងដែលកើតមានក្នុងការិយបរិច្ឆេទមុនៗ។

(ឃ) ការរាយការណ៍ឡើងវិញនូវប្រាក់ចំណេញរក្សាទុក សម្រាប់ការប្រែប្រួលគោលនយោបាយគណនេយ្យ។

(ង) ប្រាក់ចំណេញរក្សាទុកនាចុងការិយបរិច្ឆេទរាយការណ៍។

## ផ្នែកទី ៧
## របាយការណ៍លំហូរសាច់ប្រាក់

### វិសាលភាពនៃផ្នែកនេះ

៧.១ ផ្នែកនេះកំណត់អំពីព័ត៌មានដែលត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ និងថាតើត្រូវបង្ហាញព័ត៌មាននោះយ៉ាងដូចម្តេច។របាយការណ៍លំហូរសាច់ប្រាក់ផ្តល់នូវព័ត៌មានអំពីការប្រែប្រួលនានាលើសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលរបស់អង្គភាព សម្រាប់ការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកពីគ្នានូវការប្រែប្រួលបាណពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

### សាច់ប្រាក់ប្រហាក់ប្រហែល

៧.២ សាច់ប្រាក់ប្រហាក់ប្រហែលមានរយៈពេលខ្លី និងជាវិនិយោគដែលមានសន្ទនីយភាពខ្ពស់ដែលគេរក្សាទុកសម្រាប់បំពេញនូវការសន្យាជាសាច់ប្រាក់ដែលមានរយៈពេលខ្លីជាជាងទុកសម្រាប់វិនិយោគឬសម្រាប់គោលបំណងផ្សេងទៀត។ដូចនេះ ការវិនិយោគមួយ ជាធម្មតាមានគុនសម្បត្តិជាសាច់ប្រាក់ប្រហាក់ប្រហែល តែនៅពេលដែលវិនិយោគនោះមានកាលកំណត់រយៈពេលខ្លី អាចនិយាយបានថា បីខែ ឬតិចជាងនេះគិតពីថ្ងៃទិញឬទទួលបាន។ឥណទានវិបារូប៍របស់ធនាគារ ជាធម្មតាត្រូវបានចាត់ទុកជាសកម្មភាពហិរញ្ញប្បទាន ដូចការខ្ចីដែរ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ឥណទានវិបារូប៍របស់ធនាគារ គឺជាសមាសភាគនៃសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលដែរ ប្រសិនបើឥណទានវិបារូប៍របស់ធនាគារទាំងនោះអាចត្រូវបានទូទាត់ឡើងវិញតាមតម្រូវការនិងបង្កើតបានជាផ្នែកសំខាន់មួយនៅក្នុងការគ្រប់គ្រងសាច់ប្រាក់របស់អង្គភាព។

### ព័ត៌មានដែលត្រូវបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់

៧.៣ អង្គភាពមួយ ត្រូវបង្ហាញនូវរបាយការណ៍លំហូរសាច់ប្រាក់ ដែលបង្ហាញឲ្យឃើញនូវលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទរាយការណ៍ដែលត្រូវបានចាត់ថ្នាក់តាមសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន។

### សកម្មភាពប្រតិបត្តិការ

៧.៤ សកម្មភាពប្រតិបត្តិការគឺជាសកម្មភាពបង្កើតចំណូលដ៏សំខាន់របស់អង្គភាព។ដូចនេះ លំហូសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការជាការទូទាត់បានមកពីប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងៗទៀត ព្រមទាំងលក្ខខណ្ឌនានាដែលអាចយកទៅកំណត់ថាជាចំណេញ- ខាត។ខាងក្រោមគឺជាឧទាហរណ៍អំពីលំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ ÷

(ក)ចំណូលជាសាច់ប្រាក់ពីការលក់ទំនិញ និងសេវាដែលបានផ្តល់។

(ខ)ចំណូលជាសាច់ប្រាក់ពីការបង់កប្រែសិទ្ធិ(សួយសារ) កម្រៃនានា កម្រៃជើងសារ និងចំណូលផ្សេងៗទៀត។

(គ) ចំណាយជាសាច់ប្រាក់ថ្លៃទំនិញនិងសេវាដល់អ្នកផ្គត់ផ្គង់។

(ឃ) ចំណាយជាសាច់ប្រាក់ដល់និយោជិក ឬក្នុងនាមនិយោជិត។

(ង) ចំណាយជាសាច់ប្រាក់ ឬការសងត្រឡប់នៃពន្ធលើប្រាក់ចំណេញ វាលែងតែចំណាយទាំងនោះអាចត្រូវបានកំណត់ដោយឡែក ជាមួយសកម្មភាពវិនិយោគនិងហិរញ្ញប្បទាន។

(ច) ចំណូលនិងចំណាយជាសាច់ប្រាក់ពីវិនិយោគ កម្ចី និងកិច្ចសន្យាផ្សេងទៀតទុកសម្រាប់គោលបំណងនៃទូទាត់ ឬសម្រាប់ការធ្វើពាណិជ្ជកម្ម ដែលស្រដៀងគ្នាទៅនឹងសន្និធិដែលបានទិញទុកសម្រាប់លក់វិញ។ ប្រតិបត្តិការខ្លះ ដូចជា ការលក់សមាសធាតុមួយនៃរោងចក្រដោយអង្គភាពផលិតកម្ម អាចនាំឲ្យចំណេញ ឬខាតកើត មាន ដែលត្រូវបាបបញ្ចូលទៅក្នុងចំណេញឬខាត។ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏លំហូរសាច់ប្រាក់ដែល ទាក់ទិនទៅនឹងប្រតិបត្តិការបែបនេះ គឺជាលំហូរសាច់ពីសកម្មភាពវិនិយោគ។

សកម្មភាពវិនិយោគ

៧.៥ សកម្មភាពវិនិយោគ គឺជាការទិញ និងការលក់បញ្ចេញចោលនូវទ្រព្យសកម្មរយៈពេលវែង និងវិនិយោគផ្សេងទៀតដែលមិនបានចាត់បញ្ចូលជាសាច់ប្រាក់ប្រហាក់ប្រហែល។ខាងក្រោមគឺជាឧទាហរណ៍អំពីលំហូរសាច់ប្រាក់ដែលកើតពីសកម្មភាពវិនិយោគ ÷

(ក) ការចំណាយជាសាច់ប្រាក់ដើម្បីទិញទ្រព្យ រោងចក្រ និងបរិក្ខា (រាប់បញ្ចូលទាំងទ្រព្យ រោងចក្រ និងបរិក្ខាដែលបានសាងសង់ខ្លួនឯង) ទ្រព្យសកម្មអរូបី និងទ្រព្យសកម្មរយៈពេលវែងដទៃទៀត។

(ខ) ចំណូលជាសាច់ប្រាក់បានពីការក់ទ្រព្យ រោងចក្រ និងបរិក្ខា ការលក់ទ្រព្យសកម្មអរូបីនិងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត។

(គ) សាច់ប្រាក់ចំណាយលើការទិញមូលធនផ្ទាល់ឬឧបករណ៍បំណុលរបស់អង្គភាពផ្សេងទៀត ព្រមទាំងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (លើកលែងតែ ការទូទាត់ឧបករណ៍ទាំងនោះដែលបានចាត់ជាសាច់ប្រាក់ប្រហែល ឬដែលបានរក្សាទុកសម្រាប់ដោះស្រាយបំណុល ឬសម្រាប់ពាណិជ្ជកម្ម)។

(ឃ) ចំណូលជាសាច់ប្រាក់ដែលបាណមកពីការលក់មូលធនផ្ទាល់ឬឧបករណ៍បំណុលរបស់សហគ្រាសផ្សេងទៀតនិងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន(លើកលែងតែការទូទាត់ឧបករណ៍ទាំងនោះដែលបានចាត់ជាសាច់ប្រាក់ប្រហែល ឬដែលបានរក្សាទុកសម្រាប់ដោះស្រាយបំណុល ឬសម្រាប់ពាណិជ្ជកម្ម)។

(ង) សាច់ប្រាក់បុរេប្រទាន និងកម្ចី ដែលបានធ្វើឡើងសម្រាប់ភាគីផ្សេងទៀត។

(ច) សាច់ប្រាក់ទទួលបានពីការបង់សងត្រឡប់នូវបុរេប្រទាន និងកម្ចីដែលបានធ្វើជាមួយភាគីផ្សេងទៀត។

(ឆ) សាច់ប្រាក់ទូទាត់កិច្ចសន្យានាពេលអនាគត កិច្ចសន្យាដែលនឹងមកដល់ កិច្ចសន្យាជម្រើស និងកិច្ចសន្យាដោះដូរ លើកលែងតែកិច្ចសន្យាទាំងនោះត្រូវបានធ្វើឡើងសម្រាប់ការជួញដូរ ឬពាណិជ្ជកម្ម ឬការទូទាត់ទាំងនោះ ត្រូវបានចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។

(ជ)ចំណូលជាសាច់ប្រាក់បានពីកិច្ចសន្យានាពេលអនាគត កិច្ចសន្យាដែលនឹងមកដល់ កិច្ចសន្យាជម្រើស និងកិច្ចសន្យាដោះដូរ លើកលែងតែកិច្ចសន្យាទាំងនោះត្រូវបានធ្វើឡើងសម្រាប់ការជួញដូរ ឬពាណិជ្ជកម្ម ឬចំណូលទាំងនោះត្រូវបានចាត់ថ្នាក់ជាសកម្មភាពហិរញ្ញប្បទាន។

នៅពេលដែលកិច្ចសន្យាមួយត្រូវបានកត់ត្រាថាជាការទប់ស្កាត់ហានិភ័យ (សូមមើលផ្នែកទី ១២ ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត) អង្គភាពត្រូវចាត់ថ្នាក់លំហូរសាច់ប្រាក់នៃកិច្ចសន្យានោះតាមរបៀបដូចគ្នានឹងលំហូរសាច់ប្រាក់នៃសមាសធាតុដែលត្រូវទប់ស្កាត់ហានិភ័យដែរ។

សកម្មភាពហិរញ្ញប្បទាន

៧.៦ សកម្មភាពហិរញ្ញប្បទាន គឺជាសកម្មភាពដែលធ្វើឱ្យមានការប្រែប្រួលទំហំនិងសមាសភាគនៃ មូលធនផ្ទាល់ដែលអាចបែងចែកបាននិងនៃកម្ចីរបស់អង្គភាពមួយ។ ខាងក្រោម គឺជាឧទាហរណ៍នៃ លំហូរសាច់ប្រាក់ ពីសកម្មភាពហិរញ្ញប្បទាន ÷

(ក) សាច់ប្រាក់ដែលទទួលបាណពីការបោះផ្សាយសន្លឹកហ៊ុន ឬឧបករណ៍បំណុលផ្សេងទៀត។

(ខ) ការទូទាត់ជាសាច់ប្រាក់ដល់ម្ចាស់សម្រាប់ទិញ ឬ សម្រាប់ទូទាត់សន្លឹកហ៊ុនរបស់អង្គភាព។

(គ) សាច់ប្រាក់ដែលទទួលបានពីការបោះផាយប័ណ្ណបំណុល កម្ចី ធនប័ត្រ សញ្ញាប័ណ្ណ ប័ណ្ណបញ្ចាំ និងកម្ចីរយៈពេលខ្លីនិងវែងដទៃទៀត។

(ឃ) សាច់ប្រាក់ ចំណាយ សម្រាប់សងប្រាក់កម្ចីដែលបានខ្ចី។

(ង) សាច់ប្រាក់ចំណាយដោយភតិកៈសម្រាប់កាត់បន្ថយបំណុលដែលនៅសល់ទាក់ទិននឹងភតិសន្យាហិរញ្ញវត្ថុ។

## ការរាយការណ៍លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ

៧.៧ អង្គភាពមួយត្រូវបង្ហាញអំពីលំហូរសាច់ប្រាក់ដែលបានពីសកម្មភាពប្រតិបត្តិការ ដោយប្រើ ÷

(ក)ទាំង វិធីសាស្ត្រប្រយោលដែលតាមវិធីសាស្ត្រនេះ ចំណេញឬខាតត្រូវបានកែតម្រូវដោយសារឥទ្ធិពលនៃប្រតិបត្តិការមិនមែនជាសាច់ប្រាក់ដោយសារការពន្យា ឬការបូកយោងនូវចំណូលឬចំណាយជាសាច់ប្រាក់ពីប្រតិបត្តិការពីអតីត ឬ នាពេលអនាគត ព្រមទាំងសមាសធាតុនានានៃចំណូល ឬចំណាយ ដែលមានជាប់ជាមួយលំហូរសាច់ប្រាក់សម្រាប់វិនិយោគ ឬសម្រាប់ធ្វើហិរញ្ញប្បទាន និងទាំង

(ខ)វិធីសាស្ត្រផ្ទាល់ ដែលតាមនោះចំណាត់ថ្នាក់សំខាន់នៃចំណូលសាច់ប្រាក់សរុប និងចំណាយសាច់ប្រាក់សរុប ត្រូវបានលាតត្រដាង។

### វិធីសាស្ត្រប្រយោល

៧.៨ តាមវិធីសាស្ត្រ ប្រយោល លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការត្រូវបានកំណត់ដោយការធ្វើការកែតម្រូវលើចំណេញ ឬខាត ដែលជាលទ្ធផលនៃ ÷

(ក)ការប្រែប្រួលក្នុងកំឡុងការិយបរិច្ឆេទនៃសារពើភ័ណ្ឌ និងនៃប្រតិបត្តិការដែលអាចទទួលបានចំណូល ឬដែលអាចធ្វើការចំណាយ។

(ខ)សមាសធាតុមិនមែនជាសាច់ប្រាក់ ដូចជា ការរំលស់ សំវិធានធន ពន្ធពន្យា ចំណូលបូកយោងដែលមិនទាន់បានទទួល (គេមិនទាន់បង់) ជាសាច់ប្រាក់ ផលចំណេញនិងខាតពីរូបិយប័ណ្ណបរទេស ដែលមិនទទួលស្គាល់ ចំណេញរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធដែលមិនទាន់បានបែងចែក និងភាគកម្មដែលមិនបានត្រួតពិនិត្យ និង

(គ)សមាសធាតុដទៃទៀតទាំងអស់ដែលអាចមានសាច់ប្រាក់ទាក់ទិនទៅនឹងការវិនិយោគឬការធ្វើហិរញ្ញប្បទាន។

### វិធីសាស្ត្រផ្ទាល់

៧.៩ តាមវិធីសាស្ត្រផ្ទាល់លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពប្រតិបត្តិការត្រូវបានបង្ហាញដោយការលាតត្រដាងព័ត៌មានអំពីថ្នាក់សំខាន់នៃចំណូលសាច់ប្រាក់សរុបនិងចំនាយសាច់ប្រាក់សរុប។ព័ត៌មានទាំងនេះអាចត្រូវបានទទួល ÷

(ក)ទាំងបានពីការកត់ត្រាគណនេយ្យរបស់អង្គភាព និង

(ខ)ទាំងបានដោយសារការកែតម្រូវការលក់ ថ្លៃដើមលក់ និងសមាសធាតុផ្សេងទៀតនៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុប (ឬក្នុងរបាយការណ៍ចំណេញ- ខាត ប្រសិនបើបានបង្ហាញ) សម្រាប់ ÷

១)ការប្រែប្រួលក្នុងកំឡុងការិយបរិច្ឆេទនៃសន្និធិ និងប្រតិបត្តិការដែលអាចទទួលបានប្រាក់ចំណូល ឬអាចធ្វើការចំណាយ

២)សមាសធាតុមិនមែនជាសាច់ប្រាក់ដទៃទៀត។

៣)សមាសធាតុដទៃទៀតទាំងអស់ដែលអាចមានសាច់ប្រាក់ទាក់ទិនទៅនឹងការវិនិយោគឬការធ្វើហិរញ្ញប្បទាន។

### ការរាយការណ៍អំពីលំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន

៧.១០ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវថ្នាក់ចម្បងនៃចំណូលជាសាច់ប្រាក់សរុបនិងចំណាយ ជាសាច់ប្រាក់សរុបដែលបណ្តាលមកពីសកម្មភាពវិនិយោគនិងសកម្មភាពហិរញ្ញប្បទាន។ លំហូសាច់ប្រាក់សរុប

ដែលកើតមកពីការទិញនិងពីការលក់បញ្ចេញចោលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬរបស់អង្គភាពអាជីវកម្មដទៃទៀតត្រូវបានធ្វើការបង្ហាញដាច់ដោយឡែក និងត្រូវចាត់ថ្នាក់ជាសកម្មភាពវិនិយោគ។

### លំហូរសាច់ប្រាក់ពីរូបិយប័ណ្ណបរទេស

៧.១១ អង្គភាពមួយត្រូវកត់ត្រាលំហូរសាច់ប្រាក់ពីប្រតិបត្តិការគិតជារូបិយប័ណ្ណបរទេស ជារូបិយប័ណ្ណមុខងារ ដោយអនុវត្តចំពោះបរិមាណនៃរូបិយប័ណ្ណបរទេសតាមអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបរទេស នាកាលបរិច្ឆេទមានលំហូរសាច់ប្រាក់។

៧.១២ អង្គភាពត្រូវប្រែសម្រួលលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្រៅប្រទេសតាមអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណ មុខងាររបស់អង្គភាពនិងរូបិយប័ណ្ណបរទេស នាកាលបរិច្ឆេទមានលំហូរសាច់ប្រាក់។

៧.១៣ ផលចំណេញនិងខាតដែលមិនទទួលស្គាល់ កើតពីការប្រែប្រួលនៃអត្រាប្តូររូបិយប័ណ្ណបរទេស មិនមែនជាលំហូរសាច់ប្រាក់ទេ។ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីផ្ទៀងផ្ទាត់រវាងសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលនាដើមនិងចុងការិយបរិច្ឆេទ អង្គភាពត្រូវតែបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់នូវឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់លើសាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលដែលរកបាន ឬដល់ពេលត្រូវចំណាយជារូបិយប័ណ្ណបរទេស។ ដូចនេះ អង្គភាពត្រូវវាស់វែងឡើងវិញនូវសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលដែលបានធ្វើឡើងក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍ (ដូចជា បរិមាណរូបិយប័ណ្ណបរទេសដែលរកបាន និងរូបិយប័ណ្ណបរទេសនៅក្នុងគណនីធនាគារ) តាមអត្រាប្តូរប្រាក់នាចុងគ្រា។អង្គភាពត្រូវបង្ហាញនូវផលចំណេញនិងខាតដែលមិនទទួលស្គាល់ដែលកើតមាន ដាច់ដោយឡែកពីលំហូរសាច់ប្រាក់ពីប្រតិបត្តិការ គឺពីសកម្មភាពវិនិយោគនិងសកម្មភាពហិរញ្ញប្បទាន។

### ភាគកម្ម និង ភាគលាភ

៧.១៤ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែកនូវលំហូរសាច់ប្រាក់ពីភាគកម្មនិងភាគលាភដែលទទួលបាន និងដែលបានទូទាត់។ អង្គភាព ត្រូវចាត់ថ្នាក់លំហូរសាច់ប្រាក់ឲ្យមានសង្គតភាពពីកាលបរិច្ឆេទមួយទៅការិយបរិច្ឆេទមួយជាប្រតិបត្តិការ គឺសកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញប្បទាន។

៧.១៥ អង្គភាពមួយអាចចាត់ថ្នាក់ភាគកម្មដែលបានចំណាយ ព្រមទាំងភាគកម្មនិងភាគលាភដែលបានទទួលជាលំហូរសាច់ប្រាក់ពីប្រតិបត្តិការ ពិព្រោះវាទាំងនោះត្រូវបញ្ចូលក្នុងចំណេញ ឬខាត។ ជាជម្រើស អង្គភាពអាចចាត់ថ្នាក់ភាគកម្មដែលបានចំណាយ ព្រមទាំងភាគកម្មនិងភាគលាភដែលបានទទួល ជាលំហូរសាច់ប្រាក់ពីការធ្វើហិរញ្ញប្បទាន និងលំហូរសាច់ប្រាក់ពីវិនិយោគ ដោយហេតុថាវាទាំងនោះ គឺជាថ្លៃដើមនៃការទទួលបានធនធានហិរញ្ញវត្ថុ ឬជាផលពីវិនិយោគ។

៧.១៦ អង្គភាពអាចចាត់ថ្នាក់ភាគលាភដែលបានទូទាត់ជាលំហូរសាច់ប្រាក់សម្រាប់ធ្វើហិរញ្ញប្បទានពីព្រោះវាគឺជាថ្លៃដើមនៃការទទួលបានធនធានហិរញ្ញវត្ថុ។ជាជម្រើស អង្គភាពអាចចាត់ថ្នាក់ភាគលាភដែលបានទូទាត់ ជាសមាសភាគមួយនៃលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ ពីព្រោះវាត្រូវបានទូទាត់ ក្រៅលំហូរសាច់ប្រាក់ពីប្រតិបត្តិការ។

## ពន្ធលើប្រាក់ចំណេញ

៧.១៧ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែកពីគ្នានូវលំហូរសាច់ប្រាក់ដែលកើតពីពន្ធលើចំណេញ និងត្រូវចាត់ថ្នាក់នូវលំហូរសាច់ប្រាក់ទាំងនោះ ថាជាលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ វាលែងតែសកម្មភាពទាំងនោះត្រូវបានបញ្ជាក់ជាពិសេសថាជាសកម្មភាពវិនិយោគនិងហិរញ្ញប្បទាន។
នៅពេលដែលលំហូរសាច់ប្រាក់សម្រាប់បង់ពន្ធត្រូវបានបង់លើសពីចំណាត់ថ្នាក់មួយនៃសកម្មភាព អង្គភាពត្រូវលាតត្រដាងអំពីបរិមាណនៃពន្ធដែលបានបង់នោះទាំងអស់។

## ប្រតិបត្តិការមិនមែនជាសាច់ប្រាក់

៧.១៨ អង្គភាពមួយត្រូវដកចេញពីរបាយការណ៍លំហូរសាច់ប្រាក់នូវប្រតិបត្តិការវិនិយោគនិង ហិរញ្ញប្បទានទាំង ឡាយណាដែលមិនតម្រូវឲ្យប្រើសាច់ប្រាក់ ឬសាច់ប្រាក់ប្រហាក់ប្រហែល។ អង្គភាពត្រូវលាតត្រដាងប្រតិបត្តិការទាំងនេះនៅត្រង់ណាក៏ដោយនៃរបាយការណ៍ហិរញ្ញវត្ថុ ក្នុងន័យថារបាយការណ៍នេះផ្តល់នូវគ្រប់ព័ត៌មានដែលពាក់ព័ន្ធនឹងប្រតិបត្តិការវិនិយោគនិង ហិរញ្ញប្បទាន។

៧.១៩ មានសកម្មភាពវិនិយោគនិងហិរញ្ញប្បទានជាច្រើនដែលមិនមានផលប៉ះបាល់ដោយផ្ទាល់ដល់លំហូរសាច់ប្រាក់រយៈពេលខ្លី ទោះបីជាសកម្មភាពទាំងនោះមានផលប៉ះពាល់ដល់រចនាសម្ព័ន្ធដើមទុននិងទ្រព្យសកម្មរបស់អង្គភាពក៏ដោយ។ ការដកចេញនូវប្រតិបត្តិការមិនមែនសាច់ប្រាក់ពិរបាយការណ៍លំហូរសាច់ប្រាក់ ស្របទៅនឹងគោលដៅរបស់របាយការណ៍លំហូរសាច់ប្រាក់ ពីព្រោះសមាសធាតុទាំងនេះមិនមានការជាប់ពាក់ព័ន្ធជាមួយលំហូរសាច់ប្រាក់ក្នុងការិយបរិច្ឆេទខ្លី។ ខាងក្រោម គឺជាឧទាហរណ៍នៃប្រតិបត្តិការមិនមែនសាច់ប្រាក់ ÷

(ក)ការទិញទ្រព្យសកម្ម ទាំងដោយសន្មត់ទទួលយកបំណុលពាក់ព័ន្ធដោយផ្ទាល់និងទាំងតាមរយៈភតិសន្យាហិរញ្ញវត្ថុ។

(ខ)ការទិញមូលធនផ្ទាល់ តាមរយៈការបោះផ្សាយមូលធន។

(គ)ការបំលែងបំណុល ទៅជាមូលធនផ្ទាល់។

៧.២០ អង្គភាពមួយត្រូវបង្ហាញនូវសមាសភាគនៃសាច់ប្រាក់ឬសាច់ប្រាក់ប្រហាក់ប្រហែលនិងត្រូវបង្ហាញអំពីការផ្ទៀងផ្ទាត់នៃបរិមាណដែលមានបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ជាមួយនឹងសមាសធាតុប្រហាក់ប្រហែលដែលមានបង្ហាញនូវក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គភាពមិន

បានតម្រូវឱ្យបង្ហាញនូវការផ្ទៀងផ្ទាត់នេះ ប្រសិនបើបរិមាណសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលដែលបាន បង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ ដូចគ្នាទៅនឹងបរិមាណដែលបានពិពណ៌នានៅ ក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ។

## ការលាតត្រដាងព័ត៌មានផ្សេងទៀត

៧.២១ អង្គភាពមួយត្រូវលាតត្រដាង អមជាមួយនឹងការពន្យល់របស់គណៈគ្រប់គ្រងអង្គភាព បរិមាណសមតុល្យសាច់ប្រាក់ និងសាច់ប្រាក់ប្រហាក់ប្រហែលសំខាន់ៗដែលអង្គភាពមាននិងដែលអង្គភាពមិនអាចប្រើប្រាស់បាន។ សាច់ប្រាក់និងសាច់ប្រាក់ប្រហាក់ប្រហែលដែលអង្គភាពមាន មិនអាចប្រើប្រាស់បាន ដោយសារតែមានហេតុផលណាមួយក្នុងចំណោមហេតុផលនានា ដូចជា ការត្រួតពិនិត្យលើការប្តូរប្រាក់ ឬការដាក់កំហិតខាងផ្លូវច្បាប់ ជាដើម។

## ផ្នែកទី ៨
## កំណត់សម្គាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

### វិសាលភាពនៃផ្នែកនេះ

៨.១ ផ្នែកនេះកំណត់អំពីគោលការណ៍ជាមូលដ្ឋាននៃព័ត៌មាននានាដែលត្រូវធ្វើការបង្ហាញនៅក្នុងកំណត់សម្គាល់របស់របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ស្តីពីលទ្ធផលសរុប របាយការណ៍ចំណេញ-ខាត (ប្រសិនបើត្រូវ បង្ហាញ) របាយការណ៍រួមនៃចំណេញ-ខាតនិងប្រាក់ចំណេញរក្សាទុក (ប្រសិនបើត្រូវបង្ហាញ) របាយការណ៍ស្តីពីការប្រែប្រួលមូលធនផ្ទាល់ និងរបាយការណ៍លំហូរសាច់ប្រាក់។ កំណត់សម្គាល់ ផ្តល់នូវការពិពណ៌នាលំអិត ឬផ្តល់នូវការបំបែកសមាសធាតុនានាដែលបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះ ព្រមទាំងព័ត៌មានអំពីសមាសធាតុដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលស្គាល់នៅក្នុងរបាយការណ៍ទាំងនោះ។ បន្ថែមលើការតម្រូវនៅក្នុងផ្នែកនេះស្ទើរតែគ្រប់ផ្នែកផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឱ្យលាតត្រដាងព័ត៌មានផ្សេងៗដែលជាធម្មតាក៏មានបង្ហាញនៅក្នុងកំណត់សម្គាល់។

### រចនាសម្ព័ន្ធនៃកំណត់សម្គាល់

៨.២ កំណត់សម្គាល់ត្រូវ ÷

(ក) បង្ហាញនូវព័ត៌មានអំពីមូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ ដោយស្របតាមកថាខណ្ឌ ៨.៥-៨.៧

(ខ) លាតត្រដាងព័ត៌មានដែលតម្រូវដោយស្តង់ដារនេះ ដែលមិនត្រូវបានបង្ហាញកន្លែងណាផ្សេងក្រៅពីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(គ) ផ្តល់នូវព័ត៌មានដែលមិនត្រូវបានបង្ហាញនៅកន្លែងណាផ្សេងក្រៅពីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ប៉ុន្តែវាពាក់ព័ន្ធនឹងការយល់ដឹងអំពីព័ត៌មានទាំងនោះ។

៨.៣ ប្រសិនបើអាចអនុវត្តបាន អង្គភាពត្រូវបង្ហាញនូវកំណត់សម្គាល់ក្នុងជាលក្ខណៈជាប្រព័ន្ធ។អង្គភាពត្រូវធ្វើសម្អាងប្រៀបធៀបនូវសមាសធាតិនីមួយៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុជាមួយនឹងព័តមាន ដែលមានការពាក់ព័ន្ធនានានៅក្នុងកំណត់សម្គាល់។

៨.៤ ជាធម្មតា អង្គភាពបង្ហាញនូវកំណត់សម្គាល់ តាមលំដាប់ដូចតទៅ ÷

(ក) ការអះអាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម (សូមមើលកថាខណ្ឌ ៣.៣)។

(ខ) ការសង្ខេបនូវគោលនយោបាយគណនេយ្យសំខាន់ៗដែលបានអនុវត្ត (សូមមើលកថាខណ្ឌ ៨.៥)

(គ) ព័ត៌មានគាំទ្រដល់សមាសធាតុនានាដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមលំដាប់លំដោយ ដែលក្នុងនោះការអះអាងនីមួយៗ និងសមាសធាតុពាក់ព័ន្ធនីមួយៗត្រូវបានបង្ហាញ និង

(ឃ) ការលាតត្រដាងព័ត៌មានផ្សេងៗទៀត។

**ការលាតត្រដាងព័ត៌មានអំពីគោលនយោបាយគណនេយ្យ**

៨.៥ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មាននៅក្នុងការសង្ខេបអំពីគោលនយោបាយគណនេយ្យគណនេយ្យសំខាន់ៗ ដូចខាងក្រោម ÷

(ក) មូលដ្ឋាននៃការវាស់វែង (ឬមូលដ្ឋាននានា) ដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

(ខ) គោលនយោបាយគណនេយ្យដទៃទៀតដែលបានប្រើប្រាស់ពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ។

**ព័ត៌មានអំពីការវិនិច្ឆ័យ**

៨.៦ នៅក្នុងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ ឬនៅក្នុងកំណត់សម្គាល់ផ្សេងទៀត អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការវិនិច្ឆ័យ ដោយឡែកពីអ្វីពាក់ព័ន្ធនឹងការប៉ាន់ស្មាន (សូមមើលកថាខណ្ឌ ៨.៧) ដែលធ្វើឡើងគណៈគ្រប់គ្រងក្នុងដំណើរការនៃអនុវត្តគោលនយោបាយគណនេយ្យរបស់អង្គភាព ហើយដែលមានឥទ្ធិពលយ៉ាងខ្លាំងលើគណនីយនានាដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**ព័ត៌មានអំពីប្រភពគន្លឹះនៃការប៉ាន់ស្មានភាពមិនប្រាកដប្រជា**

៨.៧ អង្គ ភាពមួយត្រូវលាតត្រដាងនៅក្នុងកំណត់សម្គាល់អំពីព័ត៌មាននានាស្តីពីការសន្មត់គន្លឹះដែលពាក់ព័ន្ធនឹងអនាគតកាល ព្រមទាំងប្រភពគន្លឹះនៃការបាន់ស្មានភាពមិនប្រាកដប្រជាដទៃទៀត នាការិយបរិច្ឆេទរាយការណ៍ ដែលមានហានិភ័យខ្ពស់បណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនិងបំណុលនាឆ្នាំសារពើពន្ធបន្ទាប់។ចំពោះទ្រព្យសកម្មនិងបំណុលទាំងនោះ កំណត់សម្គាល់ត្រូវបញ្ចូលនូវភាពលំអិតនៃ ÷

(ក) អនាគតរបស់ទ្រព្យសកម្មនិងបំណុលទាំងនោះ។

(ខ) តម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនិងបំណុលនាចុងការិយបរិច្ឆេទរាយការណ៍។

## ផ្នែកទី ៩
## របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

### វិសាលភាពនៃផ្នែកនេះ

៩.១ ផ្នែកនេះកំណត់អំពីកាលទេសៈដែលតាមនោះ អង្គភាពមួយបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរួម និងនីតិវិធីនៃការរៀបចំស្តង់ដារទាំងនោះ។ វាក៏បាន បញ្ចូលផងដែរនូវគោលការណ៍ណែនាំអំពីរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកនិងរបាយការណ៍ហិរញ្ញវត្ថុផ្សំ។

### ការតម្រូវឲ្យបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម

៩.២ លើកលែងតែកថាខ័ណ្ឌ ៩.៣ អនុញ្ញាតឬតម្រូវ ឲ្យអង្គភាពមេត្រូវបង្ហាញអំពីរបាយការណ៍ហិរញ្ញវត្ថុរួម ដែលក្នុងនោះអង្គភាពត្រូវបូករួមនូវវិនិយោគរបស់ខ្លួននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធស្របតាមស្តង់ដារនេះ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបញ្ចូលនូវរាល់ក្រុមហ៊ុនញាតិសម្ព័ន្ធទាំងអស់នៃក្រុមហ៊ុនមេ។

៩.៣ អង្គភាពមេ ឬក្រុមហ៊ុនមេ មិនចាំបាច់បង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរួម ប្រសិនបើ ÷

(ក) បំពេញបានតាមលក្ខខណ្ឌទាំងពីរខាងក្រោម ÷

១) អង្គភាពមេនិងអង្គភាពញាតិសម្ព័ន្ធគឺតែមួយ និង

២) អង្គភាពមេធំបំផុត(ឬអង្គភាពមេថ្នាក់កណ្តាល) រៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់គោលបំណងទូទៅដែលអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ ឬតាមស្តង់ដារនេះ ឬ

(ខ) អង្គភាពមេពុំមានអង្គភាពជាញាតិសម្ព័ន្ធ វាលែងតែអង្គភាពញាតិសម្ព័ន្ធនោះត្រូវបានទិញក្នុងបំណងលក់ ឬបញ្ចេញចោលក្នុងកំឡុងមួយឆ្នាំ។ អង្គភាពមេ ត្រូវកត់ត្រានូវអង្គភាពញាតិសម្ព័ន្ធ÷

១) តាមតម្លៃទីផ្សារដោយគិតតាមការប្រែប្រួលតម្លៃទីផ្សារដែលបានទទួលស្គាល់នៅក្នុងចំណេញឬខាត ប្រសិនបើតម្លៃទីផ្សារនៃចំណែកហ៊ុនអាចត្រូវបានវាស់វែងប្រកបដោយការទុកចិត្ត ឬ

២) គិតផ្សេងពីនេះ តាមថ្លៃដើមដកការថយចុះតម្លៃ។

៩.៤ អង្គភាពញាតិសម្ព័ន្ធគឺជាអង្គភាពមួយដែលត្រូវបានត្រួតពិនិត្យដោយអង្គភាពមេ។ការត្រួតពិនិត្យគឺជាអំណាចគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុនិងប្រតិបត្តិការរបស់អង្គភាព ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាពនោះ។ ប្រសិនបើ អង្គភាពមួយបង្កើតនូវអង្គភាពមួយដែលមានគោលបំណងពិសេសដើម្បីបំពេញគោលដៅតូចៗ និងដែលបានកំណត់ណាមួយ អង្គភាពត្រូវរួមបញ្ចូលនូវអង្គភាពដែលមានគោលបំណងពិសេស នៅពេលដែលសារៈសំខាន់នៃទំនាក់ទំនងបង្ហាញថា អង្គភាពដែលមានគោលបំណងពិសេសត្រូវបានត្រួតពិនិត្យដោយអង្គភាពនោះ (សូមមើលកថាខណ្ឌ ៩.១០-៩.១២)។

៩.៥ ការត្រួតពិនិត្យ ត្រូវបានសន្មត់ថាមាននៅពេលដែលអង្គភាពមេជាម្ចាស់ មានសិទ្ធិអំណាចបោះឆ្នោតច្រើនជាងពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតសរុបរបស់អង្គភាពតាមអង្គភាពញាតិសម្ព័ន្ធរបស់ខ្លួនដោយផ្ទាល់ឬដោយប្រយោល។កាសន្មត់នេះអាចកើតមានឡើងនៅក្នុងកាលទេសៈពិសេសនានា ប្រសិនបើការសន្មត់នោះអាចត្រូវបានបង្ហាញយ៉ាងច្បាស់ថាកម្មសិទ្ធិនេះមិននាំឲ្យមានការត្រួតពិនិត្យទេ។ ការត្រួតពិនិត្យ អាចមាននៅពេលដែលអង្គភាពមេមានសិទ្ធិអំណាចបោះឆ្នោតស្មើពាក់កណ្តាលឬក្រោមនេះនៃសិទ្ធិបោះឆ្នោតរបស់អង្គភាព ប៉ុន្តែអង្គភាពមេមាន ÷

(ក) សិទ្ធិអំណាចលើសពីពាក់កណ្តាលនៃសិទ្ធិបោះឆ្នោតដោយសារទទួលបានការព្រមព្រៀងពីវិនិយោគិនផ្សេងទៀត

(ខ) សិទ្ធិអំណាចគ្រប់គ្រងគោលនយោបាយប្រតិបត្តិការនិងគោលនយោបាយហិរញ្ញវត្ថុរបស់អង្គភាព តាមលក្ខន្តិកៈ ឬតាមការព្រមព្រៀងមួយ

(គ) សិទ្ធិអំណាចតែងតាំងឬដកហូតសមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាភិបាលឬនៃអង្គការគ្រប់គ្រងប្រហាក់ប្រហែល ហើយដែលការត្រួតពិនិត្យអង្គភាពត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ឬអង្គការគ្រប់គ្រងនោះ ឬ

(ឃ) សិទ្ធិអំណាចច្រានចោលនូវសម្លេងឆ្នោតពេលប្រជុំក្រុមប្រឹក្សាភិបាល ឬអង្គភាពគ្រប់គ្រងប្រហាក់ប្រហែល ហើយដែលការត្រួតពិនិត្យអង្គភាពត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ឬអង្គការគ្រប់គ្រងនោះ ។

៩.៦ ការត្រួតពិនិត្យអាចធ្វើទៅបាន ដោយសារមាននូវជម្រើស ឬឧបករណ៍បំប្លែង ដែលអាចអនុវត្តបានជាក់ស្តែង ឬដោយសារមានភ្នាក់ងារដែលមានលទ្ធភាពដឹកនាំសកម្មភាពដែលជាប្រយោជន៍អង្គភាពអនុវត្តការត្រួតពិនិត្យ។

៩.៧ ជាធម្មតាអង្គភាពញាតិសម្ព័ន្ធមួយ មិនត្រូវបានដក់ចេញពីការបញ្ចូលគ្នានោះទេ ពីព្រោះវិនិយោគិន គឺជាស្ថាប័នដាក់ទុនរកស៊ីរួមគ្នាមួយ ឬជាអង្គភាពស្រដៀងគ្នា។

៩.៨ អង្គភាពញាតិសម្ព័ន្ធមួយ មិនត្រូវបានដកចេញពីការ បញ្ចូលគ្នានោះទេ ពីព្រោះសកម្មភាពអាជីវកម្មរបស់វាមិនដូចគ្នាជាមួយនឹងសកម្មភាពអាជីវកម្មរបស់អង្គភាពដែលបានរួមបញ្ចូលគ្នាគ្នាដទៃទៀតទេ។ ព័ត៌មានដែលពាក់ពន្ធ័ត្រូវបានផ្តល់ដោយការបញ្ចូលគ្នានៃក្រុមហ៊ុនញាតិសម្ព័នទាំងនោះ និងដោយការលាតត្រដាងព័ត៌មានបន្ថែមនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្ទុប ស្តីពីសកម្មភាពអាជីវកម្មផ្សេងៗគ្នារបស់ក្រុមហ៊ុនញាតិសម្ព័ន។

៩.៩ អង្គភាពញាតិសម្ព័នមួយមិនអាចដកចេញពីការបញ្ចូលគ្នាបានទេ ពីព្រោះអង្គភាពនោះធ្វើប្រតិបត្តិការនៅក្នុងយុត្តាធិការដែលដាក់កំហិតនូវការតម្រូវនានាក្នុងការផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតចេញទៅក្រៅយុត្តាធិការ។

### អង្គភាពដែលបង្កើតឡើងសម្រាប់គោលបំណងពិសេស

៩.១០ អង្គភាពមួយអាចត្រូវបានបង្កើតឡើងដើម្បីបំពេញគោលដៅតូចៗណាមួយ (ដូចជា ដើម្បីធ្វើឱ្យមានអនុភាពដល់ភតិសន្យា សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍ ឬបោះផ្សាយមូលបត្រទ្រព្យសកម្មហិរញ្ញវត្ថុលក់ ជាដើម។ អង្គភាពបែបនេះ អាចមានទម្រង់ជាសាជីវកម្ម សង្គហធន សហកម្មសិទ្ធិ ឬជាអង្គភាពមិនរួមបញ្ចូលគ្នា។ ជារឿយៗ អង្គភាពមានគោលបំណងពិសេសត្រូវបានបង្កើតឡើងតាមកិច្ចព្រមព្រៀងតាមច្បាប់មួយដែលដាក់កំហិតនូវការតម្រូវយ៉ាងតឹងរឹងលើប្រតិបត្តិការរបស់អង្គភាពនោះ។

៩.១២ អង្គភាពធំមួយ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលនូវអង្គភាពខ្លួនឯង និងអង្គភាពដែលមានគោលបំណងពិសេសនានាដែលត្រូវបានត្រួតពិនិត្យដោយអង្គភាពនោះ។ បន្ថែមលើកាលទេសៈដូចដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ៩.៥ កាលទេសៈខាងក្រោម អាចចង្អុលបង្ហាញថាអង្គភាពមួយត្រួតពិនិត្យលើអង្គភាពដែលមានគោលបំណងពិសេស (វាមិនមែនជាបញ្ជីកាលទេសៈដែលមានលក្ខណៈដាច់ខាតទេ)÷

(ក) សកម្មភាពរបស់អង្គភាពដែលមានកោលបំណងពិសេស ត្រូវបានធ្វើឡើងក្នុងនាមអង្គភាពធំ ស្របតាមសេចក្តីត្រូវការដោយឡែកនៃអាជីវកម្មរបស់វា។

(ខ) អង្គភាពមេមានសិទ្ធិអំណាចសម្រេចចុងក្រោយលើសកម្មភាពរបស់អង្គភាពមានគោលបំណងពិសេសនោះ ទោះបីជាសេចក្តីសម្រេចប្រចាំថ្ងៃត្រូវបានធ្វើប្រតិភូកម្មដល់អង្គផាពមានគោលបំណងពិសេសក៏ដោយ។

(គ) អង្គភាពមេមានសិទ្ធិទទួលបាននូវផលប្រយោជន៍ច្រើនពីអង្គភាពមានគោលបំណងពិសេស ដូចនេះហើយហានិភ័យអាចកើតមានដោយចៃដន្យពីសកម្មភាពរបស់អង្គភាពដែលមានគោលបំណងពិសេស។

(ឃ) អង្គភាពមេទទួលយកហានិភ័យពីកម្មសិទ្ធិ ឬហានិភ័យដែលនៅសល់ច្រើនទាក់ទិននឹងអង្គភាពដែលមានគោលបំណងពិសេស ឬទាក់ទិននឹងទ្រព្យសកម្មរបស់អង្គភាពនេះ។

៩.១២ កថាខណ្ឌ ៩.១០ និង ៩.១១ មិនអនុវត្តចំពោះផែនការអត្ថប្រយោជន៍របស់បុគ្គលិកមុនៗ ឬចំពោះផែនការអត្ថប្រយោជន៍របស់បុគ្គលិករយៈពេលវែងនោះទេ ដែលផែនការទាំងនោះត្រូវអនុវត្តតាមផ្នែកទី ២៨ ស្តីពីផែនការអត្ថប្រយោជន៍បុគ្គលិក។

### នីតិវិធីក្នុងការរួមបញ្ចូលគ្នា

៩.១៣ របាយការណ៍ហិរញ្ញវត្ថុរួម បង្ហាញអំពីព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធំមួយថាជាអង្គភាពសេដ្ឋកិច្ចតែមួយគត់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម អង្គភាពត្រូវ ÷

(ក) ប្រមូលផ្តុំរបាយការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេព្រមទាំងក្រុមហ៊ុនញាតិសម្ព័ន្ធពាក់ព័ន្ធដោយច្របាច់បញ្ចូលគ្នានូវសមាសធាតុដូចគ្នានៃទ្រព្យសកម្ម បំណុល មូលធនផ្ទាល់ ចំណូល និងចំណាយ

(ខ) លុបចោលតម្លៃពិតគណនេយ្យនៃវិនិយោគរបស់ក្រុមហ៊ុនមេ នៅតាមអង្គភាពញាតិសម្ព័ន្ធ និងភាគចំណែកនៃមូលធនផ្ទាល់របស់អង្គភាពមេនៅក្នុងអង្គភាពញាតិសម្ព័ន្ធនីមួយៗ។

(គ) វាស់វែង និងបង្ហាញអំពីភាគកម្មដែលមិនអាចត្រួតពិនិត្យ នៅក្នុងចំណេញ ឬខាតរបស់អង្គភាពញាតិសម្ព័ន្ធនានាដែលបានរួមបញ្ចូលគ្នាសម្រាប់ការិតបរិច្ឆេទរាយការណ៍ដាច់ដោយឡែកពីភាគកម្មរបស់ម្ចាស់នៃអង្គភាពមេ។ និង

(ឃ) វាស់វែងនិងបង្ហាញអំពីភាគកម្មដែលមិនត្រួតពិនិត្យនៅក្នុងទ្រព្យសកម្មសុទ្ធរបស់អង្គភាព ញាតិសម្ព័ន្ធដែលបានរួមបញ្ចូលគ្នា ដាច់ដោយឡែកពីមូលធនផ្ទាល់របស់របស់ម្ចាស់ហ៊ុននៃអង្គភាពមេ។ អំពីភាគកម្មដែលមិនត្រួតពិនិត្យនៅក្នុងទ្រព្យសកម្មសុទ្ធរួមមាន ÷

១) បរិមាណនៃភាគកម្មដែលមិនត្រួតពិនិត្យនាកាលបរិច្ឆេទនៃការរួមបញ្ចូលគ្នាពីដើមទីដោយគើរគណនាស្របតាម ផ្នែកទី ១៩ ស្តីពី ការរួមបញ្ចូលអាជីវកម្ម និងមូលនិធីពាណិជ្ជកម្ម និង

២) ចំណែកហ៊ុនរបស់ភាគកម្មមិនត្រួតពិនិត្យនៃការប្រែប្រួលលើមូលធនផ្ទាល់ចាប់តាំងពីកាលបរិច្ឆេទរួមបញ្ចូលគ្នា។

៩.១៤ ភាគចំណែកនៃចំណេញឬខាត ព្រមទាំងការប្រែប្រួលលើមូលធនផ្ទាល់ដែលបានផ្តល់ដល់ម្ចាស់អង្គភាពមេ និងដល់ភាគកម្មមិនត្រួតពិនិត្យ ត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃភាគកម្មជាកម្មសិទ្ធិដែលមានស្រាប់ និងមិនបង្ហាញឲ្យឃើញអំពីការអនុវត្ត ឬអំពីការបម្លែងនៃសមភាគ ឬអំពីឧបករណ៍ដែលអាចបម្លែងបានតាមដែលអាចធ្វើទៅបាននោះទេ។

### សមតុល្យ និងប្រតិបត្តិការនៅក្នុងអង្គភាព

៩.១៥ សមតុល្យនិងប្រតិបត្តិការនៅក្នុងអង្គភាព រួមបញ្ចូលទាំងចំណូល ចំណាយ និង ភាគលាភ ត្រូវតែលុបចោលទាំងស្រុង។ចំណេញនិងខាតដែលកើតមកពីប្រតិបត្តិការនៅក្នុងអង្គភាព ដែលត្រូវបានទទួលស្គាល់នៅក្នុង ទ្រព្យសកម្ម ដូចជា សន្និធិ និង ទ្រព្យ រោងចក្រនិងបរិក្ខា ត្រូវតែលុបចោលទាំងស្រុង។ ការខាតបង់ខាងក្នុងអង្គភាពអាចបង្ហាញនូវភាពសឹករិចរិលដែលតម្រូវឲ្យទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម( សូមមើលផ្នែកទី ២៧ ស្តីពី ការសឹករិចរិលនៃទ្រព្យសកម្ម)។ផ្នែកទី ២៩ ស្តីពី ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះភាពខុសគ្នាជាបណ្តោះអាសន្នដែលកើតមានពីការលុបចោលនូវចំណេញនិងខាតដែលបណ្តាលកពីប្រតិបត្តិការខាងក្នុង។

### កាលបរិច្ឆេទរាយការណ៍ដូចគ្នាតែមួយ

៩.១៦ របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមេ និងរបស់អង្គភាពញាតិសម្ព័ន្ធរបស់ខ្លួនដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវតែរៀបចំនាកាលបរិច្ឆេទដូចគ្នា លើកលែងតែមិនអាចធ្វើបែបនេះបាន។

### គោលនយោបាយគណនេយ្យដូចគ្នាតែមួយ

៩.១៧ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវតែបានរៀបចំដោយប្រើគោលនយោបាយគណនេយ្យដូចគ្នាតែមួយ សម្រាប់ប្រតិបត្តិការនិងព្រឹត្តិការណ៍ដូចគ្នាព្រមទាំងក្នុងលក្ខខណ្ឌដែលមាននៅក្នុងកាលទេសៈដូចគ្នា។ប្រសិនបើសមាជិកនៃអង្គភាពមួយប្រើគោលនយោបាយគណនេយ្យដែលមិនមែនជាគោលនយោបាយដែលបានទទួលយកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ប្រតិបត្តិការដូចគ្នានិងសម្រាប់ព្រឹត្តិការណ៍ដែលមានក្នុងកាលទេសៈប្រហាក់ប្រហែលគ្នា ការកែតម្រូវសមរម្យមួយត្រូវបានធ្វើឡើងចំពោះរបាយការណ៍ហិរញ្ញវត្ថុក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម។

### ការទិញ និងការលក់បញ្ចេញចោលនូវអង្គភាពញាតិសម្ព័ន្ធ

៩.១៨ ចំណូលនិងចំណាយរបស់អង្គភាពញាតិសម្ព័ន្ធមួយ ត្រូវបានកត់ត្រាបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមដោយគិតចាប់តាំងពីកាលបរិច្ឆេទទិញ។ចំណូលនិងចំណាយរបស់អង្គភាពញាតិសម្ព័ន្ធមួយត្រូវបានកត់ត្រាបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម រហូតដល់កាលបរិច្ឆេទដែលអង្គភាពមេបញ្ឈប់ការត្រួតពិនិត្យលើអង្គភាពញាតិសម្ព័ន្ធនោះ។ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលសរុបរួម(ឬនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើត្រូវបង្ហាញ) ថាជាចំណេញឬខាតពីការលក់បញ្ចេញចោលអង្គភាពញាតិសម្ព័ន្ធ នូវរាល់ភាពខុសគ្នារវាងចំណូលពីការលក់បញ្ចេញចោលនូវអង្គភាពញាតិសម្ព័ន្ធនព្រមទាំងតម្លៃពិតគណនេយ្យរបស់វានាកាលបរិច្ឆេទលក់បញ្ចេញចោលដោយមិនរាប់បញ្ចូលបរិមាណបង្គរនៃភាពខុសគ្នានៃអត្រាប្តូរប្រាក់ដែលពាក់ព័ន្ធនឹងអង្គភាពញាតិសម្ព័ន្ធបរទេសដែលត្រូវបានទទួលស្គាល់ថជាមូលធនផ្ទាល់ស្របតាមផ្នែកទី ៣០ ស្តីពីការប្តូររូបិយប័ណ្ណបរទេស។

៩.១៨ ប្រសិនេបីអង្គភាពមួយឈប់ធ្វើជាអង្គភាពញាតិសម្ព័ន្ធមួយ ប៉ុន្តែវិនិយោគិន (អង្គភាពមេពីមុន) នៅតែបន្តធ្វើវិនិយោគនៅក្នុងអង្គភាពញាតិសម្ព័ន្ធពីមុន ការវិនិយោគនោះត្រូវបានរាប់ថាជាទ្រព្យសកម្មហិរញ្ញវត្ថុមួយ ស្របតាមផ្នែកទី ១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន (គោល) ឬ ផ្នែកទី ១២ ស្តីពី ការបោះផ្សាយឱ្យឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ចាប់ពីកាលបរិច្ឆេទដែលអង្គភាពនោះឈប់ធ្វើជាអង្គភាពញាតិសម្ព័ន្ធ ហើយដោយចែងថាអង្គភាពនេះមិនក្លាយជាអង្គភាពបុត្រសម្ព័ន្ធនោះទេ (ដែលផ្នែកទី ១៤ ស្តីពីវិនិយោគនៅក្នុងអង្គភាពបុត្រសម្ព័ន្ធបានអនុវត្តចំពោះករណីនេះ)ឬក្លាយជាអង្គភាពត្រួតពិនិត្យរួមគ្នា (ដែលផ្នែកទី ១៥ ស្តីពីវិនិយោគនៅក្នុងអង្គភាពរួមទុន បានអនុវត្តចំពោះករណីនេះ)។ តម្លៃពិតគណនេយ្យនៃវិនិយោគនាកាលបរិច្ឆេទដែលអង្គភាពឈប់ធ្វើជាអង្គភាពញាតិសម្ព័ន្ធត្រូវបានចាត់ទុកជាថ្លៃដើមនៃការវាស់វែងបឋមលើទ្រព្យសកម្មហិរញ្ញវត្ថុ។

### ភាគកម្មមិនត្រួតពិនិត្យនៅក្នុងអង្គភាពញាតិសម្ព័ន្ធ

៩.២០ អង្គភាពមួយត្រូវបង្ហាញអំពីភាគកម្មមិនត្រួតពិនិត្យនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុរួមនៅក្នុងផ្នែកមូលធនផ្ទាល់ ដាច់ដោយឡែកពីមូលធនផ្ទាល់របស់ម្ចាស់អង្គភាពមេដូចដែលតម្រូវដោយកថាខណ្ឌ ៤.២ (ថ)។

៩.២១ អង្គភាពមួយត្រូវលាតត្រដាងភាគកម្មមិនត្រួតពិនិត្យនៅក្នុងចំណេញ ឬ ខាតរបស់អង្គភាពធំ ដាច់ដោយឡែក នៅក្នុងរបាយការណ៍ស្តីពីលទ្ធផលសរុបដូចដែលបានតម្រូវដោយកថាខណ្ឌ៥.៦ (ឬនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើត្រូវបង្ហាញ ដូចដែលតម្រូវដោយកថាខណ្ឌ ៥.៧)។

៩.២២ ចំណេញ ឬខាត ព្រមទាំងសមាសភាគនីមួយៗនៃលទ្ធផលសរុបដទៃទៀត ត្រូវបានចាត់ទុកជារបស់ម្ចាស់នៃអង្គភាពមេ និងនៃភាគកម្មមិនបានត្រួតពិនិត្យ។ លទ្ធផលសរុបរួម ត្រូវបានចាត់ទុកជារបស់ម្ចាស់នៃអង្គភាពមេ និងនៃភាគកម្មមិនបានត្រួតពិនិត្យទោះបីជាលទ្ធផលភាគកម្មមិនបានត្រួតពិនិត្យត្រូវបានបដាញនូវសមតុល្យឱនភាពក៏ដោយ។

## ការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម

៩.២៣ កាលលាតត្រដាងព័ត៌មានដូចខាងក្រោម នឹងត្រូវបានធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ៖

(ក) ការបញ្ជាក់ថារបាយការណ៍ គឺជារបាយការណ៍ហិរញ្ញវត្ថុរួម។

(ខ) មូលដ្ឋាននៃការសន្និដ្ឋានថាមានការត្រួតពិនិត្យដោយផ្ទាល់ឬដោយប្រយោលតាមរយៈអង្គភាពញាតិសម្ព័ន្ធ នៅពេលដែលអង្គភាពមេមិនសិទ្ធិអំណាចបោះឆ្នោតលើសពីពាក់កណ្តាល។

(គ) ភាពខុសគ្នាណាមួយនៃកាលបរិច្ឆេទរាយការណ៍របស់របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមេ និងអង្គភាពញាតិសម្ព័ន្ធរបស់ខ្លួនដែលបានប្រើប្រាស់នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម។

(ឃ) ចរិកលក្ខណៈនិងវិសាលភាពនៃលក្ខខណ្ឌកម្រិតសំខាន់ៗ (ដូចជា លក្ខខណ្ឌដែលកើតពីកិច្ចសន្យាខ្ចីប្រាក់ ឬការតម្រូវតាមផ្លូវច្បាប់) លើលទ្ធភាពរបស់អង្គភាពញាតិសម្ព័ន្ធដើម្បីផ្ទេរដើមទុនទៅឲ្យអង្គភាពមេក្រោមទម្រង់ជាភាគលាភជាសាច់ប្រាក់ឬដើម្បីសងប្រាក់កម្ចី។

## របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក

### ការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក

៩.២៤ កថាខណ្ឌ ៩.២ តម្រូវឲ្យអង្គភាពមេមួយ បង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ខ្លួន។ ស្តង់ដានេះមិនតម្រូវឲ្យធ្វើការបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកសម្រាប់អង្គភាពមេឬអង្គភាពញាតិសម្ព័ន្ធមួយៗនោះទេ។

៩.២៥ របាយការណ៍ហិរញ្ញវត្ថុនានារបស់អង្គភាពមួយដែលមិនមានអង្គភាពបុត្រសម្ព័ន្ធ មិនមែនជារបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកនោះទេ។ ដូចនេះ អង្គភាពមួយដែលមិនមែនជាអង្គភាពមេ ប៉ុន្តែជាវិនិយោគគិននៅក្នុងអង្គភាពបុត្រសម្ព័ន្ធមួយ ឬមានជាភាគកម្មរបស់អ្នកដាក់ទុនរួមគ្នានៅក្នុងក្រុមហ៊ុនរួមទុនត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនលោមតាមផ្នែកទី ១៤ ឬ ផ្នែកទី ១៥ ប្រសិនបើអាចធ្វើបាន។ អង្គភាពនេះអាចជ្រើសរើសយកការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកបានដែរ។

### ការជ្រើសរើសយកគោលនយោបាយគណនេយ្យ

៩.២៦ នៅពេលដែលក្រុមហ៊ុនមេ ដែលជាវិនិយោគគិននៅក្នុងអង្គភាពបុត្រសម្ព័ន្ធមួយ ឬជាអ្នកដាក់ទុនរួមគ្នាដែលមានភាគកម្មនៅក្នុងភាពត្រួតពិនិត្យរួមគ្នារៀបចំរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ហើយបានពិពណ៌នាថា របាយការណ៍ខាងលើស្របតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម របាយការណ៍ទាំងនោះត្រូវតែអនុលោមតាមរាល់ការតម្រូវនានានៅក្នុងស្តង់ដានេះ។ អង្គភាពត្រូវអនុម័តយកគោលនយោបាយគណនេយ្យមួយសម្រាប់ការវិនិយោគនានារបស់អង្គភាពនេះនៅក្នុងអង្គភាពញាតិសម្ព័ន្ធ អង្គភាពបុត្រសម្ព័ន្ធ និងអង្គភាពដែលមាមានការត្រួតពិនិត្យរួមគ្នា ទាំងតាម ÷

(ក) ថ្លៃដើម ដកការថយចុះថ្លៃ និងទាំងតាម

(ខ) តម្លៃទីផ្សារដោយមានទាំងការប្រែប្រួលតម្លៃទីផ្សារដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យដូចគ្នាចំពោះរាល់វិនិយោគនានាតាមថ្នាក់តែមួយ ( អង្គភាពនេះនៅក្នុងអង្គភាពញាតិសម្ព័ន្ធ អង្គភាពបុត្រសម្ព័ន្ធ និងអង្គភាពដែលមាមានការត្រួតពិនិត្យរួមគ្នា) ប៉ុន្តែអង្គភាពអាចជ្រើសយកគោលនយោបាយខុសគ្នាសម្រាប់ថ្នាក់ខុសគ្នា។

### ការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក

៩.២៧ នៅពេលដែលក្រុមហ៊ុនមេ ដែលជាវិនិយោគគិននៅក្នុងអង្គភាពបុត្រសម្ព័ន្ធមួយ ឬជាអ្នកដាក់ទុនរួមគ្នាដែលមានភាគកម្មនៅក្នុងភាពត្រួតពិនិត្យរួមគ្នារៀបចំរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របាយការណ៍ទាំងនោះត្រូវតែលាតត្រដាងនូវព័ត៌មាន ÷

(ក) ថារបាយការណ៍នោះជារបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក និង

(ខ) អំពីការពិពណ៌នានូវវិធីសាស្ត្រដែលបានប្រើសម្រាប់កត់ត្រាវិនិយោគនានានៅក្នុងអង្គភាពញាតិសម្ព័ន្ធ អង្គភាពដែលមានការត្រួតពិនិត្យរួមគ្នានិងអង្គភាពបុត្រសម្ព័ន្ធហើយត្រូវកំណត់អត្តសញ្ញាណឲ្យច្បាស់អំពីរបាយការណ៍ហិរញ្ញវត្ថុរួម ឬរបាយការណ៍ហិរញ្ញវត្ថុចម្បងដែលមានការពាក់ព័ន្ធ។

## របាយការណ៍ហិរញ្ញវត្ថុផ្សំ

៩.២៨ របាយការណ៍ហិរញ្ញវត្ថុផ្សំ គឺជាបណ្តុំនៃរបាយការណ៍ហិរញ្ញវត្ថុឲ្យមានតែមួយរបស់អង្គភាពពីរ ឬច្រើនបញ្ចូលគ្នាដែលអង្គភាពទាំងនោះគ្រប់គ្រងដោយវិនិយោគិនតែមួយ។ស្តង់ដានេះមិនតម្រូវឲ្យអង្គភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្សំទេ។

៩.២៩ ប្រសិនបើវិនិយោគិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្សំ និងពិពណ៌នាថារបាយការណ៍ទាំងនោះអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម របាយការណ៍ទាំងនោះត្រូវតែអនុលោមតាមរាល់ការតម្រូវនានានៅក្នុងស្តង់ដារនេះ។ប្រតិបត្តិការនិងសមតុល្យរបស់អន្តរក្រុមហ៊ុនត្រូវលុបចោល និងចំណេញឬខាតដែលកើតពីប្រតិបត្តិការរបស់អន្តរក្រុមហ៊ុនដែលបានទទួលស្គាល់ក្នុង

ទ្រព្យសកម្មដូចជាសន្និធិ និងទ្រព្យ រោងចក្រ និងបរិក្ខា ក៏ត្រូវលប់ចោល ដូចនេះនាំឲ្យរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពដែលបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្គួបត្រូវតែរៀបចំឡើងនាកាលបរិច្ឆេទរាយការណ៍ដូចគ្នា ហើយបើមិនដូចនេះទេ របាយការណ៍នោះនឹងមិនអាចអនុវត្តបានទេ ម្យ៉ាងទៀត ត្រូវតែអនុវត្តនូវគោលនយោបាយគណនេយ្យឯកភាពសម្រាប់ប្រតិបត្តិការដូចគ្នានិងព្រឹត្តិការណ៍ផ្សេងទៀតដែលកើតក្នុងកាលទេសៈប្រហាក់ប្រហែលគ្នា។

### ការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្គួប

៩.៣០ របាយការណ៍ហិរញ្ញវត្ថុផ្គួប ត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) ការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុជារបាយការណ៍ហិរញ្ញវត្ថុផ្គួប។

(ខ) ហេតុផលដែលនាំឲ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្គួបនេះឡើង

(គ) មូលដ្ឋានសម្រាប់កំណត់ថាតើអង្គភាពណាខ្លះដែលបានបញ្ចូលក្នុង របាយការណ៍ហិរញ្ញវត្ថុផ្គួប។

(ឃ) មូលដានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្គួប។

(ង) ការលាតត្រដាងអំពីភាគីពាក់ព័ន្ធដែលតម្រូវដោយផ្នែកទី៣៣ស្តីពីការលាតត្រដាងព័ត៌មានភាគីពាក់ព័ន្ធ។

## ផ្នែកទី ១០
## គោលនយោបាយគណនេយ្យ ការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង

### វិសាលភាពនៃផ្នែកនេះ

១០.១ ផ្នែកនេះផ្តល់នូវគោលការណ៍ណែនាំអំពីការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យដែលបានប្រើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ វាក៏ចែងផងដែរអំពីការប្រែប្រួលនានាលើគោលនយោបាយគណនេយ្យ ព្រមទាំងការកែតម្រូវលើកំហុសឆ្គងដែលមានក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុន។

### ការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យ

១០.២ គោលនយោបាយគណនេយ្យគឺជាគោលការណ៍ពិសេស មូលដ្ឋាន សមត្ថិកម្ម វិធាន និងការអនុវត្តនានាដែលធ្វើឡើងដោយអង្គភាពក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

១០.៣ ប្រសិនបើស្តង់ដារនេះមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌពិសេសទេ អង្គភាពត្រូវអនុវត្តតាមស្តង់ដារនេះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គភាពមិនចាំបាច់ធ្វើតាមការតម្រូវនៅក្នុងស្តង់ដានេះ ប្រសិបបើធ្វើដូចនេះមិននាំឲ្យមានឥទ្ធិពលជាសារវន្តទេនោះ។

១០.៤ ប្រសិនបើស្តង់ដារនេះមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌពិសេសទេ អ្នកគ្រប់គ្រងរបស់អង្គភាពត្រូវប្រើការវិនិច្ឆ័យរបស់ខ្លួនក្នុងការបង្កើតនិងអនុវត្តគោលនយោបាយគណនេយ្យដែលមានព័ត៌មាននានា ៖

(ក)ដែលពាក់ព័ន្ធនឹងការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចដែលចាំបាច់សម្រាប់អ្នកប្រើប្រាស់ និង

(ខ)ដែលអាចជឿទុកចិត្តបាន ដែក្នុងនោះរបាយការណ៍ហិរញ្ញវត្ថុ ៖

១)-បង្ហាញដោយស្មោះត្រង់នូវស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព

២)-បង្ហាញឲ្យឃើញនូវសារៈសំខាន់នៃសេដ្ឋកិច្ចរបស់ប្រតិបត្តិការ ព្រឹត្តិការ និងលក្ខខណ្ឌដទៃទៀត និងមិនមែនគ្រាន់តែបំពេញបែបបទខាងផ្លូវច្បាប់នោះទេ

៣)-ដែលមានលក្ខណៈអព្យាក្រឹត្យ ដូចជា មិនមានលំអៀង

៤)-ដែលមានលក្ខណៈប្រុងប្រយ័ត្ន និង

៥)-ដែលមានលក្ខណៈពេញលេញប្រកបដោយភាពសារវន្ត។

១០.៥ ក្នុងការវិនិច្ឆ័យដូចបានពិពណ៌នាក្នុងកថាខណ្ឌ ១០.៤ អ្នកគ្រប់គ្រងត្រូវផ្អែកលើ និងត្រូវពិចារណាអំពីប្រភពដែលបានរៀបតាមលំដាប់ដូចខាងក្រោម ៖

(ក)ការតម្រូវនិងគោលការណ៍ណែនាំនៅក្នុងស្តង់ដារនេះ ទាក់ទងនឹងបញ្ហាស្រដៀងគ្នានិងបញ្ហាពាក់ព័ន្ធ និង

(ខ)ការកំណត់ លក្ខណៈវិនិច្ឆ័យទទួលស្គាល់ និងទស្សនទាននៃការការវាស់វែងលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ព្រមទាំងគោលការណ៍ទូទៅនៅក្នុងផ្នែកទី ២ ស្តីពីទស្សនទាន និងគោលការណ៍ទូទៅ។

១០.៦ ក្នុងការវិនិច្ឆ័យដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ១០.៤ អ្នកគ្រប់គ្រងក៏អាចពិចារណាលើការតម្រូវនានា និងគោលការណ៍ណែនាំនៅក្នុងស្តង់ដារនៃរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ទាក់ទងនឹងបញ្ហាស្រដៀងគ្នានិងបញ្ហាពាក់ព័ន្ធ។

## សង្គតិភាពនៃគោលនយោបាយគណនេយ្យ

១០.៧ អង្គភាពមួយត្រូវជ្រើសរើស និងអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ខ្លួនប្រកបដោយសង្គតិភាពចំពោះប្រតិបត្តិការដែលមានលក្ខណៈស្រដៀងគ្នា ព្រឹត្តិការដទៃទៀត ព្រមទាំងលក្ខខណ្ឌនានា វាលែងតែស្តង់ដារនេះបានតម្រូវ ឬអនុញ្ញាតជាពិសេស ឲ្យធ្វើចំណាត់ប្រភេទសមាសធាតុនានានៅក្រោមគោលនយោបាយផ្សេងដែលអាចធ្វើទៅបាន។ ប្រសិនបើស្តង់ដារនេះតម្រូវ ឬអនុញ្ញាតឲ្យធ្វើដូចនេះ គោលនយោបាយគណនេយ្យសមរម្យមួយអាចត្រូវបានជ្រើសរើសនិងអនុវត្តដូចគ្នាចំពោះប្រភេទនិមួយៗ។

## ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.៨ អង្គភាពមួយ ត្រូវផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់ខ្លួនតែនៅពេលដែលការផ្លាស់ប្តូរនោះ ៖

(ក)ត្រូវបានតម្រូវឲ្យមានការផ្លាស់ប្តូរតាមស្តង់ដារនេះ ឬ

(ខ)ធ្វើឲ្យរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់នូវព័ត៌មានលៃគួរជាទីទុកចិត្ត និងកាន់តែមានភាពទាក់ទងអំពីអនុភាពនៃប្រតិបត្តិការនៃព្រឹត្តិការណ៍ដទៃទៀតឬនៃលក្ខខណ្ឌនានាលើស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព លទ្ធផលហិរញ្ញវត្ថុ ឬលំហូរសាច់ប្រាក់។

១០.៩ ចំណុចខាងក្រោម មិនមែនជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យទេ ៖

(ក)ការអនុវត្តគោលនយោបយាគណនេយ្យសម្រាប់ប្រតិបត្តិការ ព្រឹត្តិការណ៍ដទៃទៀត ឬលក្ខខណ្ឌនានា ដែលមានភាពខុសគ្នាជាសារវន្តនៅនឹង ប្រតិបត្តិការ ព្រឹត្តិការណ៍ដទៃទៀត ឬលក្ខខណ្ឌនានា ដែលបានកើតមាននាពេលមុនៗ។

(ខ)ការអនុវត្តគោលនយោបាយគណនេយ្យថ្មីសម្រាប់ប្រតិបត្តិការ ព្រឹត្តិការណ៍ដទៃទៀត ឬលក្ខខណ្ឌនានាដែលមិនបានកើតមាននាពេលមុនៗ ឬដែលមិនមានភាពជាសារវន្ត។

(គ)ការផ្លាស់ប្តូរនូវវិធីសាស្ត្រថ្លៃដើម នៅពេលដែលការវាស់វែងតាមតម្លៃទីផ្សារដែលអាចជឿទុកចិត្តបាន មិនអាចធ្វើទៅបានទៀត(ឬផ្ទុយមកវិញ)សម្រាប់ទ្រព្យសកម្មដែលស្តង់ដារនេះបានតម្រូវផ្ទុយពីនេះ ឬបានអនុញ្ញាតឲ្យវាស់វែងតាមតម្លៃទីផ្សារ។

១០.១០ ប្រសិនបើស្តង់ដារនេះអនុញ្ញាតឲ្យមានការជ្រើសរើសយកការកត់ត្រាគណនេយ្យមួយ (រួមបញ្ចូលទាំងមូលដ្ឋាននៃការវាស់វែង) សម្រាប់ប្រតិបត្តិការពិសេស ឬសម្រាប់ព្រឹត្តិការណ៍ដទៃទៀត ឬសម្រាប់លក្ខខណ្ឌផ្សេងៗ ហើយអង្គភាពផ្លាស់ប្តូរនូវជម្រើសពីពេលមុនៗ នេះចាត់ថាជាការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

ការអនុវត្តការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.១១ អង្គភាពមួយ ត្រូវរាប់បញ្ចូលនូវការផ្លាស់ប្តូរលើគោលនយោបាយគណនេយ្យដូចខាងក្រោម ÷

(ក) អង្គភាពមួយត្រូវរាប់បញ្ចូលនូវការផ្លាស់ប្តូរលើគោលនយោបាយគណនេយ្យដែលបណ្តាលមកពីការផ្លាស់ប្តូរការតម្រូវនានាដោយស្តង់ដារនេះ ស្របតាមវិធានអន្តរកាលដែលបានបញ្ជាក់ច្បាស់នៅក្នុងការកែប្រែនេះ ប្រសិនបើមាន។

(ខ) ប្រសិនបើ អង្គភាពបានសម្រេចរើសយកការអនុវត្តតាមស្តង់ដារគណនេយ្យលេខ៣៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ:*ការទទួលស្គាល់និងការវាស់វែង*ជំនួសឲ្យការរើសយកការអនុវត្តតាមផ្នែកទី ១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និង ផ្នែកទី ១២ ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ដូចដែលបានអនុញ្ញាតដោយកថាខណ្ឌទី ១១.២ និងការតម្រូវនានាតាមការផ្លាស់ប្តូរនៃស្តង់ដារគណនេយ្យលេខ៣៩ អង្គភាពត្រូវរាប់បញ្ចូលយកការផ្លាស់ប្តូរនោះនៅក្នុងគោលនយោបាយគណនេយ្យ ដោយស្របតាមវិធានអន្តរកាល ដូចដែលបានបញ្ជាក់ច្បាស់នៅក្នុងស្តង់ដារលេខ ៣៩ ដែលបានកែប្រែ ប្រសិនបើមាន។

(គ) អង្គភាពមួយត្រូវរាប់បញ្ចូលដោយប្រតិសកម្ម នូវរាល់ការប្រែប្រួលនានាដទៃទៀតលើគោលនយោបាយគណនេយ្យ (សូមមើលកថាខណ្ឌ ១០.១២)។

ការអនុវត្តប្រតិសកម្ម

១០.១២ នៅពេលដែលមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យត្រូវបានអនុវត្តប្រតិសកម្មស្របតាមកថាខណ្ឌ ១០.១១ អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យថ្មីចំពោះរាល់ព័ត៌មានប្រៀបធៀបនានាសម្រាប់ការិយបរិច្ឆេទមុនៗនាដើមកាលបរិច្ឆេទដែលត្រូវអនុវត្ត ប្រសិនបើគោលនយោបាយគណនេយ្យថ្មីតែងតែត្រូវបានអនុវត្ត។នៅពេលដែលវាមិនអាចអនុវត្តបានដើម្បីកំណត់នូវឥទ្ធិពលសម្រាប់ការិយបរិច្ឆេទមួយនៃការប្រែប្រួលគោលនយោបាយគណនេយ្យស្តីពីព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមួយឬច្រើនដែលបានបង្ហាញ អង្គភាពត្រូវអនុវត្តគោលនយោបាយគណនេយ្យថ្មីចំពោះតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនិងបំណុល នាពេលចាប់ផ្តើមការិយបរិច្ឆេទដំបូងបំផុត ដែលការអនុវត្តដោយប្រតិសកម្មអាចធ្វើទៅបាន ដែលនេះអាចជាការិយបរិច្ឆេទបច្ចុប្បន្ន ហើយអង្គភាពត្រូវធ្វើការកែតម្រូវដែលឆ្លើយតបមួយចំពោះតុល្យការដើមគ្រានៃសមាសធាតុនីមួយៗនៃមូលធនផ្ទាល់សម្រាប់ការិយបរិច្ឆេទនោះ។

## ការលាតត្រដាងព័ត៌មានអំពីការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

១០.១៣ នៅពេលដែលការកែប្រែតាមស្តង់ដារនេះនាំឲ្យមានឥទ្ធិពលលើការិយបរិច្ឆេទបច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនៗ ឬអាចមានឥទ្ធិពលលើការិយបរិច្ឆេទខាងមុខ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) ចរិកលក្ខណៈនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

(ខ) បរិមាណនៃការកែតម្រូវសម្រាប់សមាសធាតុពាក់ព័ន្ធដែលមានផលប៉ះពាល់ក្នុង របាយការណ៍ហិរញ្ញវត្ថុនិមួយៗ បើអាចធ្វើទៅបាន សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទ មុនៗ នីមួយៗដែលបានបង្ហាញ។

(គ) បរិមាណនៃការកែតម្រូវទាក់ទិននឹងការិយបរិច្ឆេទមុននឹងវាត្រូវបានបង្ហាញ បើអាចធ្វើទៅបាន។

(ឃ) ការពន្យល់ប្រសិនបើវាមិនអាចអនុវត្តទៅបាន ដើម្បីកំណត់អំពីបរិមាណដូចដែលបានលាតត្រដាងនៅក្នុង ចំណុច (ខ) ឬ (គ) ខាងលើ។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់មិនចាំបាច់លើកឡើងម្តងទៀតអំពីការលាតត្រដាង ព័ត៌មាននេះទេ។

១០.១៤ នៅពេលដែលការផ្លាស់ប្តូរដោយស្ម័គ្រចិត្តលើគោលនយោបាយគណនេយ្យមានឥទ្ធិពលលើការិយបរិច្ឆេទ បច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនណាមួយ អង្គភាពត្រូវធ្វើការលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) ចរិកលក្ខណៈនៃការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

(ខ) ហេតុផលដែលនាំឲ្យអនុវត្តគោលនយោបាយគណនេយ្យថ្មី នាំមកនូវព័ត៌មានការតែអាចជឿទុកចិត្តបាន និងកាន់តែមានភាពពាក់ព័ន្ធ។

(គ) បរិមាណនៃការកែតម្រូវលើសមាសធាតុពាក់ព័ន្ធនិមួយៗដែលទទួលរងឥទ្ធិពល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយបង្ហាញដាច់ដោយឡែក ÷

១) សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។

២) សម្រាប់ការិយបរិច្ឆេទមុននិមួយៗដែលបានបង្ហាញ និង

៣) សរុបរួមសម្រាប់ការិយបរិច្ឆេទនានា មុនវាទាំងនោះបានបង្ហាញ។

(ឃ) ការពន្យល់ ប្រសិនបើអាចធ្វើទៅបាន ដើម្បីកំណត់បរិមាណដែលត្រូវលាតត្រដាងនៅក្នុងចំណុច (គ) ខាងលើ។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ មិនចាំបាច់បង្ហាញនូវចំណុចខាងលើឡើងវិញនោះទេ។

### ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ

១០.១៥ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ គឺជាការកែតម្រូវនូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មមួយ ឬបំណុលមួយ ឬជាបរិមាណនៃការប្រើប្រាស់ទ្រព្យសកម្មប្រចាំការិយបរិច្ឆេទ ដែលជាលទ្ធផលនៃការវាយតម្លៃលើស្ថានភាពនៃទ្រព្យសកម្មនិងបំណុលនាពេលបច្ចុប្បន្ន និងនៃអត្ថប្រយោជន៍និងដែលបានរំពឹងទុកនាពេលអនាគត ដែលមានជាប់នឹងទ្រព្យសកម្មនិងបំណុលទាំងនោះ។ ហេតុនេះហើយ ការផ្លាស់ប្តូរការប៉ានស្មានគណនេយ្យកើតមានពីព័ត៌មានថ្មី ឬការអភិវឌ្ឍថ្មី មិនមែនជាការកែតម្រូវកំហុសឆ្គងនោះទេ។ នៅពេលដែលមានការលំបាកក្នុងការបែងចែកឱ្យដាច់នូវការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ពីការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ ការផ្លាស់ប្តូរត្រូវបានចាត់ទុកជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ។

១០.១៦ អង្គភាពមួយត្រូវទទួលស្គាល់ឥទ្ធិពលនៃការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ លើកលែងតែការផ្លាស់ប្តូរដែលអនុ វត្តតាមកថាខណ្ឌ ១០.១៧ ដោយរាប់បញ្ចូលនាពេលអនាគតនៅក្នុងចំណេញ ឬខាត នូវ ÷

(ក)ការិយបរិច្ឆេទដែលមានការផ្លាស់ប្តូរ ប្រសិនបើការផ្លាស់ប្តូរនាំឱ្យមានផលប៉ះពាល់តែលើការិយបរិច្ឆេទនោះតែប៉ុណ្ណោះ ឬ

(ខ)ការិយបរិច្ឆេទដែលមានការផ្លាស់ប្តូរ ព្រមទាំងការិយបរិច្ឆេទនាពេលអនាគត ប្រសិនបើការផ្លាស់ប្តូរមានផលប៉ះពាល់ដល់ការិយបរិច្ឆេទទាំងពីរ។

១០.១៧ ក្នុងពេលដែលមានការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យក្នុងកម្រិតមួយដែលធ្វើឱ្យទ្រព្យសកម្មនិងបំណុលប្រែប្រួល ឬដែលពាក់ព័ន្ធនឹងសមាសធាតុមួយនៃមូលធនផ្ទាល់ អង្គ ភាពត្រូវទទួលស្គាល់នូវការផ្លាស់ប្តូរនោះដោយធ្វើការកែតម្រូវនូវតម្លៃពិតគណនេយ្យនៃសមាសធាតុពាក់ព័ន្ធរបស់ទ្រព្យសកម្ម បំណុល ឬមូលធនផ្ទាល់ដែលពាក់ព័ន្ធនោះ ក្នុងការិយបរិច្ឆេទដែលមានការផ្លាស់ប្តូរ។

### ការលាតត្រដាងព័ត៌មាន

១០.១៨ អង្គភាពមួយត្រូវលាតត្រដាងអំពីចរិកលក្ខណៈនៃការប្រែប្រួលការប៉ានស្មានគណនេយ្យ និងឥទ្ធិពលនៃការផ្លាស់ប្តូរលើទ្រព្យសកម្ម បំណុល ចំណូល និងចំណាយសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ ប្រសិបនបើអង្គភាពអាចធ្វើការប៉ានស្មាននូវឥទ្ធិពលនៃការផ្លាស់ប្តូរសម្រាប់ការិយបរិច្ឆេទមួយ ឬច្រើននាពេលអនាគត អង្គភាពត្រូវលាតត្រដាងអំពីការប៉ាន់ស្មានទាំងនោះ។

### ការកែតម្រូវចំពោះកំហុសឆ្គងដែលកើតមាននាការិយបរិច្ឆេទមុនៗ

១០.១៩ កំហុសឆ្គងដែលកើតមាននៅក្នុងការិយបរិច្ឆេទមុនៗ គឺជាការលុបចេញពីរបាយការណ៍ហិរញ្ញវត្ថុ និងការរាយការណ៍ខុសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពនាការិយបរិច្ឆេទមុនៗមួយ ឬច្រើន ដែលកើតចេញពីការខកខានមិនបានប្រើ ឬការប្រើខុសនូវព័ត៌មានដែលគួរជាទីទុកចិត្តបាន ដែល ÷

(ក)ព័ត៌មានទាំងនោះអាចប្រមូលបានពេលដែលរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុនៗនោះត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ និង

(ខ)ព័ត៌មានទាំងនោះ អាចរំពឹងថានឹងទទួលបាន និងកត់ត្រានៅក្នុងការរៀបចំ និងបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ។

១០.២០ កំហុសឆ្គងទាំងនោះ រួមមានឥទ្ធិពលនៃកំហុសជាតួលេខ កំហុសដែលកើតមានពីការអនុវត្តគោលនយោបាយគណនេយ្យ ការធ្វេសប្រហែស ឬការបកស្រាយខុសនូវហេតុការណ៍នានា ឬការបន្លំ។

១០.២១ អង្គភាពត្រូវកែតម្រូវដោយប្រតិសកម្មនូវកំហុសឆ្គងជាសារវន្តដែលកើតមាននាការិយបរិច្ឆេទមុនៗ នៅក្នុងកម្រិតមួយដែលអាចធ្វើទៅបាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់ខ្លួនដែលបានអនុញ្ញាតឲ្យបោះផ្សាយ បន្ទាប់ពីវាត្រូវបានស្តារឡើងវិញ ដោយ ÷

(ក)រាយការណ៍ឡើងវិញនូវបរិមាណប្រៀបធៀបនៃកំហុសឆ្គងដែលកើតមានក្នុងការិយបរិច្ឆេទមុនៗដែលបានបង្ហាញ ឬ

(ខ)រាយការណ៍ឡើងវិញនូវតុល្យការដើមគ្រានៃទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់ នាការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ ប្រសិនបើកំហុសឆ្គងបានកើតមានមុនការិយបរិច្ឆេទមុនដំបូងបង្អស់ដែលបានបង្ហាញ។

១០.២២ នៅពេលដែលមិនអាចកំណត់អានុភាពនៃកំហុសឆ្គងនាការិយបរិច្ឆេទជាក់លាក់មួយអំពីព័ត៌មានប្រៀបធៀបសម្រាប់ការិយបរិច្ឆេទមុនមួយឬច្រើនដែលបានបង្ហាញអង្គភាពត្រូវរាយការណ៍ឡើងវិញអំពីសមតុល្យដើមគ្រានៃទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់សម្រាប់ការិយបរិច្ឆេទដំបូងបង្អស់ដែលអាចធ្វើការរាយការណ៍ឡើងវិញដោយប្រតិសកម្មបាន (ដែលអាចជាការិយបរិច្ឆេទបច្ចុប្បន្ន)។

### ការលាតត្រដាងព័ត៌មានអំពីកំហុសឆ្គងនាការិយបរិច្ឆេទមុន

១០.២៣ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានអំពូកំហុសឆ្គងនាការិយបរិច្ឆេទមុន ដូចខាងក្រោម ÷

(ក)លក្ខណៈនៃកំហុសឆ្គងនាការិយបរិច្ឆេទមុន។

(ខ)បរិមាណក្នុងកម្រិតមួយដែលអាចធ្វើទៅបាននៃការកែតម្រូវលើសមាសធាតុនិមួយៗរបាយការណ៍ហិរញ្ញវត្ថុដែលមានផលប៉ះពាល់ សម្រាប់ការិយបរិច្ឆេទមុននិមួយៗដែលបានបង្ហាញ។

(គ)បរិមាណក្នុងកម្រិតមួយដែលអាចធ្វើទៅបាននៃការកែតម្រូវនាដើមការិយតបរិច្ឆេទមុនដំបូងគេបង្អស់ដែលបានបង្ហាញ។

(ឃ)ការពន្យល់អំពីហេតុដែលមិនអាចធ្វើការកំណត់អំពីបរិមាណដែលត្រូវលាតត្រដាងតាមចំណុច (ខ) ឬ (គ) ខាងលើ។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទតទៅមុខបន្តបន្ទាប់មិនចាំបាច់លាតត្រដាងព័ត៌មានដដែលខាងលើទេ។

## ផ្នែកទី ១១

## ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន

### វិសាលភាពនៃផ្នែកទី ១១ និង ១២

១១.១ ផ្នែកទី ១១ស្តីពីឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និងផ្នែកទី១២ ស្តីពី ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទាំងពីនេះទាក់ទងជាមួយនឹង ការទទួលស្គាល់ ការមិនទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងអំពី ឧបករណ៍ហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ)។ ផ្នែកទី ១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុ ជាមូលដ្ឋាន ហើយដែលមានការពាក់ព័ន្ធជាមួយអង្គភាពទាំងអស់។ ផ្នែកទី១២ អនុវត្តចំពោះអង្គភាពដទៃទៀត ដែលមានឧបករណ៍ហិរញ្ញវត្ថុនិងប្រតិបត្តិការស្មុគ្រស្មាញជាង។ ប្រសិនបើអង្គភាពមួយ មានតែប្រតិបត្តិការ ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ផ្នែកទី ១២ មិនអនុវត្តចំពោះអង្គភាពនោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក្តី ទោះបីជាអង្គភាពមានតែឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋានក៏ដោយ ក៏អង្គភាពត្រូវតែពិចារណាលើវិសាលភាពនៃ ផ្នែកទី១២ ដែរ ដើម្បីធានាថា អង្គភាពរបស់ខ្លួនត្រូវបានលើកលែង។

### ការជ្រើសរើសគោលនយោបាយគណនេយ្យ

១១.២ អង្គភាពមួយត្រូវធ្វើការជ្រើសរើសមកប្រើ នូវ ÷

(ក)វិធា នដែលមានចែងនៅក្នុងទាំងផ្នែកទី ១១ និងផ្នែកទី ១២ ទាំងស្រុង ឬក៏

(ខ)វិធាននៃការទទួលស្គាល់ និងការវាស់វែង តាមស្តង់ដារគណនេយ្យអន្តរជាតិលេខ ៣៩ ស្តីពីឧបករណ៍ ហិរញ្ញវត្ថុ ÷ ការទទួលស្គាល់និងការវាស់វែង និងត្រូវលាតត្រដាងព័ត៌មានតាមការតម្រូវក្នុងផ្នែកទី ១១ និង ១២ សម្រាប់គ្រប់ឧបករណ៍ហិរញ្ញវត្ថុទាំងអស់របស់ខ្លួន។ ការជ្រើសរើសយកតាមចំណុច(ក) ឬ ចំណុច(ខ) របស់ អង្គភាពគឺជាការជ្រើសរើសគោលនយោបាយគណនេយ្យ។ កថាខណ្ឌ ១០.៨-១០.១៤ បានចែងអំពីការតម្រូវ នានាដើម្បីកំណត់អំពីថាតើពេលណាដែលការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ អាចធ្វើទៅបាន ហើយតើ ការផ្លាស់ប្តូរនោះត្រូវយកមកគិតគូរយ៉ាងដូចម្តេច និងថាតើព័ត៌មានអំពីការផ្លាស់ប្តូរអ្វីខ្លះដែលត្រូវលាតត្រដាង។

### សេចក្តីផ្តើមអំពីផ្នែកទី ១១

១១.៣ ឧបករណ៍ហិរញ្ញវត្ថុគឺជាកិច្ចសន្យាមួយដែលនាំឲ្យមានកំណើនទ្រព្យសកម្មហិរញ្ញវត្ថុរបស់អង្គភាពមួយ និងបំណុល ឬឧបករណ៍មូលធនផ្ទាល់របស់អង្គភាពមួយផ្សេងទៀត។

១១.៤ ផ្នែកទី១១តម្រូវឲ្យប្រើវិធីសាស្ត្រថ្លៃដើមរំលស់សម្រាប់រាល់ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋានទាំងអស់ លើកលែង តែការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបម្លែងបាន និងមិនអាចលក់វិញបាន ព្រមទាំងភាគហ៊ុនធម្មតា ដែលមិនអាចលក់វិញបាន ហើយដែលបានដាក់ឲ្យទិញលក់ជាសាធារណៈ ឬដែលតម្លៃទីផ្សាររបស់វាអាចត្រូវ បានវាស់វែងប្រកបដោយការជឿទុកចិត្តបាន។

១១.៥ ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋានដែលស្ថិតក្រោមវិសាលភាពនៃផ្នែកទី១១ នេះ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ១១.៨។ ឧទាហរណ៍អំពីឧបករណ៍ហិរញ្ញវត្ថុដែលធម្មតាបំពេញបានតាមលក្ខខណ្ឌទាំងនោះ រួមមាន ÷

(ក) សាច់ប្រាក់។

(ខ) តម្រូវការនិងប្រាក់បញ្ញើមានរយៈពេលកំណត់នៅពេលដែលអង្គភាពជាអ្នកដាក់ប្រាក់បញ្ញើដូចជា គណនីធនាគារ។

(គ) លិខិតបំណុលពាណិជ្ជកម្មនិងបណ្ណ័បំណុលដែលរក្សាទុក

(ឃ) គណនី ធនប័ត្រ និងកម្ចីដែលត្រូវទទួលនិងដែលត្រូវបង់។

(ង) សញ្ញាប័ណ្ណ និងឧបករណ៍បំណុលប្រហាក់ប្រហែល។

(ច) ការវិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចលែងបាន និងភាគហ៊ុនធម្មតានិងភាពហ៊ុនបុរិមាដែលមិនអាចលក់វិញបាន។

(ឆ) កិច្ចសន្យាទទួលកម្ចី ប្រសិនបើកិច្ចសន្យាមិនអាចទូទាត់ជាសាច់ប្រាក់សុទ្ធ។

១១.៦ ឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាធម្មតាមិនបំពេញបានតាមលក្ខខណ្ឌដែលមានក្នុងកថាខណ្ឌ ១១.៨ និងដែលស្ថិតក្រោមវិសាលភាពនៃផ្នែកទី ១២ រួមមាន ÷

(ក) មូលបត្រមានទ្រព្យសកម្មជាគ្រឿងបន្ទាល់ ដូចជា កាតព្វកិច្ចហ៊ីប៉ូតែក កិច្ចសន្យាទិញយកវិញ ព្រមទាំងសំណុំនៃមូលបត្រដែលត្រូវទទួល។

(ខ) ជម្រើស សិទ្ធិ ប័ណ្ណធានា កិច្ចសន្យាដែលមានពេលអនាគត កិច្ចសន្យាបន្ត និង ការដោះដូរនៃអត្រាការប្រាក់ដែលអាចទូទាត់ជាសាច់ប្រាក់ ឬ ទូទាត់តាមរយៈការផ្លោះប្តូរឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

(គ) ឧបករណ៍ហិរញ្ញវត្ថុដែលបញ្ជាក់និងត្រូវបានកំណត់ថាជាឧបករណ៍ទប់ស្កាត់ហានិភ័យ អនុលោមតាមការតម្រូវនានាដែលមានក្នុងផ្នែកទី ១២។

(ឃ) ការសន្យាឲ្យអង្គភាពដទៃខ្ចីប្រាក់។

(ង) ការសន្យាទទួលយកបំណុល ប្រសិនបើការសន្យានោះអាចត្រូវបានដោះស្រាយដោយប្រើសាច់ប្រាក់។

## វិសាលភាពនៃផ្នែកទី ១១

១១.៧ ផ្នែកទី១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុដែលបំពេញបានតាមលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ ១១.៨ លើកលែងតែករណីមួយចំនួន ដូចខាងក្រោម ÷

(ក)វិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលត្រូវបានគិតបញ្ចូលស្របតាមផ្នែកទី ៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក តាមផ្នែកទី ១៤ ស្តីពីវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬតាមផ្នែកទី ១៥ ស្តីពីវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន។

(ខ) ឧបករណ៍ហិរញ្ញវត្ថុដែលបំពេញបានតាមអត្ថន័យរបស់មូលធនផ្ទាល់របស់អង្គភាព (សូមមើលផ្នែកទី ២២ ស្តីអំពីបំណុល និងមូលធនផ្ទាល់ និងផ្នែកទី ២៦ ស្តីពី ការទូទាត់ដោយផ្អែកលើចំណែកហ៊ុន)។

(គ)ភតិសន្យានានា ដែលអនុវត្តតាមផ្នែកទី ២០ ស្តីពីភតិសន្យា ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការមិនទទួលស្គាល់នូវការតម្រូវនានាដែលមានចែងក្នុងកថាខណ្ឌ ១១.៣៣ និង ១១.៣៨ ត្រូវអនុវត្តចំពោះការមិនទទួលស្គាល់ដោយភតិបតីលើភតិសន្យាដែលអាចទទួលបាន និងចំពោះការមិនទទួលស្គាល់ភតិសន្យាដែលអាចបង់សងដោយភតិក:។ ដូចគ្នានេះដែរ ផ្នែកទី ១២ អាចអនុវត្តបានចំពោះភតិសន្យាដែលមានចរិកលក្ខណៈដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.៣ (ច)។

(ឃ)សិទ្ធិនិងកាតព្វកិច្ចរបស់និយោជក តាមផែនការអត្ថប្រយោជន៍បុគ្គលិក ដែលត្រូវអនុវត្តតាមផ្នែកទី ២៨ ស្តីពីផែនការអត្ថប្រយោជន៍បុគ្គលិក។

**ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន**

១១.៨ គ្រប់អង្គភាពត្រូវចាត់ទុកឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម ថាជាឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ដោយស្របតាមផ្នែកទី ១១ ÷

(ក) សាច់ប្រាក់។

(ខ)ឧបករណ៍បំណុល (ដូចជា គណនី, កំណត់សម្គាល់ ឬប្រាក់កម្ចីដែលត្រូវទូទាត់ ឬប្រាក់កម្ចីដែលត្រូវទទួល) ដែលបំពេញបានតាមលក្ខខណ្ឌនានាដែលចែងនៅក្នុងកថាខណ្ឌ ១១.៩។

(គ)កិច្ចសន្យាក្នុងការទទួលបាននូវប្រាក់កម្ចី ដែល ÷

១) មិនអាចត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធ និង

២)កិច្ចសន្យា ត្រូវបានគេរំពឹងទុកថាបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ១១.៩ នៅពេលដែលកិច្ចសន្យាត្រូវបានអនុវត្ត។

(ឃ) វិនិយោគលើភាគហ៊ុនបុរិមាដែលមិនអាចបម្លែងបាន និងលើភាគហ៊ុនធម្មតា ឬភាគហ៊ុនបុរិមាដែលមិនអាចដាក់លក់វិញបាន។

១១.៩ ឧបករណ៍បំណុល ដែលបំពេញបានតាមលក្ខខណ្ឌនានានៅក្នុងចំណុច (ក)-(ឃ) ខាងក្រោម ត្រូវបានគិតគូរដោយអនុលោមតាម ផ្នែកទី ១១ ÷

(ក) ប្រាក់ចំណូលដែលផ្តល់ដល់អ្នកកាន់ឧបករណ៍ គឺជា ÷

១) បរិមាណ ថេរ

២) អត្រាចំណេញថេរក្នុងមួយរយៈពេលនៃជីវិតរបស់ឧបករណ៍

៣) ផលចំណេញប្រែប្រួលក្នុងមួយរយៈបេលនៃឧបករណ៍ ស្មើនឹងអត្រាការប្រាក់បានធ្វើសម្រង់ឬអត្រាការប្រាក់អាចអង្កេតបាន (ដូចជាLIBOR) ឬ

៤) ការបន្សំចូលគ្នារវាងអត្រាថេរនិងអត្រាប្រែប្រួល(ដូចជា LIBOR បូកថែម ២០០ចំណុចគោល) ដោយរួមមានទាំងអត្រាថេរនិងអត្រាប្រែប្រួលដែលវិជ្ជមាន(ឧ. ការដោះដូរអត្រាការប្រាក់ដែលមានអត្រាថេរវិជ្ជមានជាមួយអត្រាការប្រាក់ប្រែប្រួលអវិជ្ជមាននឹងមិនឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនេះឡើយ)។ ចំពោះផលនៃអត្រាការប្រាក់ថេរនិងអត្រាការប្រាក់ប្រែប្រួល ការប្រាក់ត្រូវបានគេគណនាដោយគុណអត្រាការប្រាក់ជាមួយនឹងរយៈពេលសមស្របមួយទៅនឹងប្រាក់ដើមនៅជាប់ជំពាក់នៅក្នុងអំឡុងគ្រា។

(ខ) ផ្អែកលើលក្ខខណ្ឌរបស់វា ពុំមានវិធាននៃកិច្ចសន្យាណាដែលនាំឲ្យអ្នកកាន់ឧបករណ៍បំណុលនោះបាត់បង់នូវបំណុលដើមរបស់គេ ឬបាត់បង់ការប្រាក់ដែលអាចផ្តល់ជូននាការិយបរិច្ឆេទបច្ចុប្បន្ន ឬការិយបរិច្ឆេទមុនៗនោះទេ។ក្នុងករណីដែលឧបករណ៍បំណុលមួយ ចំណុះឲ្យឧបករណ៍បំណុលដទៃទៀត វាមិនមែនជាឧទាហរណ៍ដែលអនុវត្តចំពោះវិធាននៃកិច្ចសន្យានេះទេ។

(គ) វិធាននៃកិច្ចសន្យានានា ដែលអនុញ្ញាតឲ្យអ្នកបោះផ្សាយប័ណ្ណបំណុល (កូនបំណុល) ធ្វើការទូទាត់ជាមុននូវឧបករណ៍បំណុល ឬអនុញ្ញាតឲ្យអ្នកកាន់ប័ណ្ណបំណុល (ម្ចាស់បំណុល) ប្រគល់ប័ណ្ណបំណុលត្រឡប់ទៅអ្នកបោះផ្សាយប័ណ្ណបំណុលមុនកាលកំណត់សង គឺមិនអាស្រ័យលើព្រឹត្តិការណ៍នាពេលអនាគតនោះទេ។

(ឃ) វាមិនមានប្រាក់ចំណេញដែលមានដាក់លក្ខខណ្ឌ ឬសំវិធានធនដែលត្រូវទូទាត់ឡើងវិញ លើកលែងតែអត្រាប្រាក់ចំណេញប្រែប្រួលដែលបានរៀបរាប់នៅក្នុងចំណុច (ក) និងវិធាននៃការទូទាត់មុន ដែលមានចែងនៅក្នុងចំណុច (គ)។

១១.១០ ខាងក្រោម គឺជាឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាធម្មតាបំពេញតាមលក្ខខណ្ឌនានានៅក្នុងកថាខណ្ឌ ១១.៩ ÷

(ក) គណនីទិញ- លក់ និងធនបត្រដែលអាចទទួលបាននិងធនបត្រដែលអាចទូទាត់បាន ព្រមទាំងកម្ចីពីធនាគារ ឬពីភាគីទី ៣ ផ្សេងទៀត

(ខ) គណនីអ្នកផ្គត់ផ្គង់ជារូបិយប័ណ្ណបរទេស។ ពុំន្តែទោះបីជាយ៉ាងណាក៏ដោយ រាល់ការប្រែប្រួលលើគណនីអ្នកផ្គត់ផ្គង់ ដែលបណ្តាលមកពីការប្រែប្រួលនៃអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់ថាជាចំណេញឬខាត ដូចដែលបានតម្រូវដោយកថាខណ្ឌ ៣០.១០។

(គ) កម្ចីដែលត្រូវផ្តល់ឱ្យ ឬទាពីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬញាតិសម្ព័ន្ធ ដែលដល់កាលកំណត់

(ឃ) ឧបករណ៍បំណុលដែលនឹងអាចទទួលបានភ្លាមៗ ប្រសិនបើអ្នកបោះផ្សាយប័ណ្ណបំណុលខកខានមិនបានបង់ការប្រាក់ ឬបង់ប្រាក់ដើម (វិធាននេះ មិនបំពានលើលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ ១១.៩)។

១១.១១ ឧទាហរណ៍នៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាធម្មតាមិនបំពេញតាមលក្ខខណ្ឌនានានៅក្នុងកថាខណ្ឌ ១១.៩ (ហើយដែលស្ថិតក្រោមវិសាលភាពនៃផ្នែកទី ១២) រួមមានដូចខាងក្រោម ÷

(ក) ការវិនិយោគក្នុងឧបករណ៍មូលធនផ្ទាល់របស់អង្គភាពផ្សេងទៀត លើកលែងតែភាគហ៊ុនបុរិមាដែលមិនអាចបម្លែងបាន ព្រមទាំងភាគហ៊ុនបរិមានិងភាគហ៊ុនធម្មតាដែលមិនអាចដាក់លក់វិញបាន (សូមមើលកថាខណ្ឌ ១១.៨ (ឃ))។

(ខ) ការប្តូរអត្រាការប្រាក់ ដែលបានទទួលជាលំហូរសាច់ប្រាក់ទោះបីវិជ្ជមាន ឬអវិជ្ជមាន

(គ) សិទ្ធិធ្វើជម្រើស និងកិច្ចសន្យានាពេលអនាគត ពីព្រោះចំណេញដែលត្រូវផ្តល់ជូនអ្នកកាន់ឧបករណ៍នោះមិនត្រូវបានកំណត់ ហើយមិនបំពេញបានតាមលក្ខខណ្ឌក្នុងកថាខណ្ឌ ១១.៩ (ក)។

(ឃ) ការវិនិយោគលើបំណុលមិនអាចបម្លែងបាន ពី  ព្រោះចំណេញចំពោះអ្នកកាន់ឧបករណ៍ អាចប្រែប្រួលតាមតម្លៃនៃភាគហ៊ុនជាមូលធនផ្ទាល់របស់អ្នកបោះផ្សាយប័ណ្ណបំណុល លើសពីតម្លៃរបស់វានៅលើទីផ្សារ។

(ង) ប្រាក់កម្ចីដែលអាចទទួលបានពីតតិយជន ហើយដែលផ្តល់ដល់តតីយជននោះនូវសិទ្ធិ ឬកាតព្វកិច្ច ឱ្យបង់មុន ប្រសិនបើបន្ទុកពន្ធដារ ឬការតម្រូវផែនកគណនេយយមានការប្រែប្រួល ពីព្រោះថា ប្រាក់កម្ចីបែបនេះមិនបំពេញតាមលក្ខខណ្ឌដែលចែងក្នុងកថាខណ្ឌ ១១.៩ (គ)។

## ការទទួលស្គាល់ជាដំបូងនូវទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

១១.១២ អង្គភាពមួយត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺនៅពេលដែលអង្គភាពនោះក្លាយទៅជាភាគីនៃកិច្ចសន្យាពាក់ព័ន្ធនឹងឧបករណ៍។

## ការវាស់វែងបឋម

១១.១៣ នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ជាដំបូង អង្គភាពត្រូវវាស់វែងទ្រព្យសកម្ម/បំណុលនោះតាមតម្លៃនាពេលប្រតិបត្តិការ (រួមទាំងបន្ទុកប្រតិបត្តិការ លើកលែងតែបន្ទុកនោះកើតមានពេលធ្វើការវាស់វែងដំបូងលើទ្រពយសកម្មនិងបំណុលហិរញ្ញវត្ថុ ដែលត្រូវធ្វើការវាស់វែងផ្អែកលើតម្លៃ

ទីផ្សារតាមរយៈចំណញ-ខាត) លើកលែងតែកិច្ចសន្យាបង្កើតឲ្យមានប្រតិបត្តិការហិរញ្ញប្បទាននៅក្នុងការអនុវត្តជាក់ស្តែង។ ប្រតិបត្តិការហិរញ្ញប្បទាន អាចកើតមានដោយភ្ជាប់ជាមួយការលក់ទំនិញ ឬសេវា ឧទាហរណ៍ដូចជា ប្រសិនបើការទូទាត់ត្រូវបានពន្យាលើសពីរយៈពេលអាជីវកម្មធម្មតា ឬការទូទាត់ត្រូវបានផ្តល់ហិរញ្ញប្បទានតាមអត្រាការប្រាក់ដែលមិនមែនជាអត្រាការប្រាក់ទីផ្សារ។ប្រសិនបើកិច្ចសន្យានាំឲ្យមានប្រតិបត្តិការហិរញ្ញប្បទាន អង្គភាពត្រូវវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុតាមថ្លៃជាក់ស្តែងនៃការទូទាត់នាពេលអនាគត បញ្ចុះមកត្រឹមអត្រាការប្រាក់លើទីផ្សារសម្រាប់ឧបករណ៍បំណុលប្រហាក់ប្រហែល។

| ឧទាហរណ៍- ទ្រព្យសកម្មហិរញ្ញវត្ថុ |
| --- |
| ១. ចំពោះប្រាក់កម្ចីរយៈពេលវែងដែលបានផ្តល់ដល់អង្គភាពមួយផ្សេងទៀត ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់តាមតម្លៃជាក់ស្តែងនៃសាច់ប្រាក់ដែលនឹងទទួលបាន ពីអង្គភាពនោះ (រាប់បញ្ចូលទាំងការទូទាត់ការប្រាក់ និងការបង់មុននូវប្រាក់ដើម)។ |
| ២. ចំពោះទំនិញដែលបានលក់ជូនអតិថិជនដោយឲ្យជំពាក់រយៈពេលខ្លី ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់ជាបរិមាណសាច់ប្រាក់មិនបានបញ្ចុះថ្លៃដែលអាចទទួលបានពីអង្គភាពនោះ ដែលជាធម្មតាតាមតម្លៃលើវិក័យបត្រ។ |
| ៣. ចំពោះវត្ថុ ឬទំនិញណាដែលបានលក់ទៅឲ្យអតិថិជនដោយឲ្យជំពាក់រយៈពេល២ឆ្នាំដោយគ្មានការប្រាក់ប្រាក់ដែលត្រូវទទួលបានត្រូវបានទទួលស្គាល់តាមថ្លៃលក់ជាសាច់ប្រាក់ជាក់ស្តែងនៃទំនិញ ឬវត្ថុនោះ។ ប្រសិនបើយើងមិនបានដឹងអំពីថ្លៃលក់ជាសាច់ប្រាក់ជាក់ស្តែងនោះថ្លៃលក់អាចត្រូវបាន ប៉ាន់ស្មានតាមតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ដែលត្រូវទទួលបានដែលបញ្ចុះដោយប្រើអត្រាការប្រាក់ទីផ្សារដែលលើសគេ សម្រាប់ប្រាក់ដែលត្រូវទទួលបានប្រហាក់ប្រហែល។ |
| ៤. ចំពោះការទិញភាគហ៊ុនធម្មតារបស់អង្គភាពផ្សេងទៀតដោយចំណាយជាសាច់ប្រាក់ ការវិនិយោគនេះត្រូវបានទទួលស្គាល់តាមបរិមាណសាច់ប្រាក់ដែលបានបង់ដើម្បីទទួលបានចំណែកហ៊ុន។ |

| ឧទាហរណ៍ - បំណុលហិរញ្ញវត្ថុ |
| --- |
| ១. ចំពោះប្រាក់កម្ចីដែលទទួលបានពីធនាគារ ការចំណាយត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃជាក់ស្តែងនៃសាច់ប្រាក់ដែលត្រូវបង់ឲ្យធនាគា(ឧទាហរណ៍ ការទទូទាត់ការប្រាក់ និងការបង់សងវិញនូវប្រាក់ដើម)។ |
| ២. ចំពោះទំនិញដែលទិញបណ្តាក់ពីអ្នកផ្គត់ផ្គង់ក្នុងរយៈពេលខ្លី ការទូទាត់ត្រូវបានទទួលស្គាល់តាមសាច់ប្រាក់ដែលមិនបានចុះតម្លៃ ដែលជំពាក់អ្នកផ្គត់ផ្គង់ ដែលជាធម្មតាតាមតម្លៃកំណត់ក្នុងវិក័យបត្រ។ |

ការវាស់វែងជាបន្តបន្ទាប់

១១.១៤ នាចុងការិយបរិច្ឆេទរាយការណ៍ អង្គភាពត្រូវវាយតម្លៃនូវឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដោយមិនកាត់ចោលនូវបន្ទុកប្រតិបត្តិការដែលអង្គភាពអាចចំណាយលើការលក់ឬការលក់បញ្ចេញចោលផ្សេងៗទៀតដូចខាងក្រោម ÷

(ក) ឧបករណ៍បំណុលដែលបំពេញបានតាមលក្ខខណ្ឌចែងក្នុងកថាខណ្ឌ ១១.៨ (ខ) នឹងត្រូវបានវាស់វែងតាមថ្លៃដើមដែលបានរំលស់ ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធិភាព។ កថាខណ្ឌ ១១.១៥ - ១១.២០ បានផ្តល់នូវការណែនាំក្នុងការកំណត់នូវថ្លៃដើមដែលបានរំលស់ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធិភាព។ ឧបករណ៍បំណុលដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មចរន្ត ឬបំណុលចរន្ត នឹងត្រូវបានវាស់វែងតាមបរិមាណសាច់ប្រាក់ដែលមិនទាន់បានបញ្ចុះ ឬតាមតម្លៃតបស្នងផ្សេងទៀតដែលរំពឹងថានឹងត្រូវទូទាត់សង ឬនឹងត្រូវទទួលបាន (ដូចជា ការធ្លាក់ចុះថ្លៃសរុប និង សូមមើលកថាខណ្ឌ ១១.២១ - ១១.២៦) វាលែងតែនៅក្នុងការជាក់ស្តែង កិច្ចសន្យាបានបង្កើតឲ្យមានប្រតិបត្តិការហិរញ្ញប្បទាន (សូមមើលកថាខណ្ឌ ១១.១៣)។ ប្រសិនបើ កិច្ចសន្យាបានបង្កើតឲ្យមានប្រតិបត្តិការហិរញ្ញប្បទាន អង្គភាពត្រូវវាស់វែងឧបករណ៍បំណុលតាមតម្លៃជាក់ស្តែងសម្រាប់ការទូទាត់នាពេលអនាគត ដោយបញ្ចុះតម្លៃតាមអត្រាការប្រាក់ទីផ្សារចំពោះឧបករណ៍បំណុលប្រហាក់ប្រហែល។

(ខ) ការសន្យាទទួលនូវកម្ចីតាមលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌ១១.៨ (គ) ត្រូវវាស់វែងដោយយកថ្លៃដើម (ជួនកាលពុំមាន) ដកជាមួយការថយចុះតម្លៃ។

(គ) ការវិនិយោគនៅក្នុងភាគហ៊ុនបុរិមាដែលមិនអាចបម្លែងបាន និងក្នុងភាគហ៊ុនធម្មតា ឬភាគហ៊ុនបុរិមាដែលមិនអាចលក់បាន ដែលបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ ១១.៨ (ឃ) ត្រូវធ្វើការវាស់វែងដូចខាងក្រោម (កថាខណ្ឌ ១១.២៧-១១.៣៣ ផ្តល់គោលការណ៍ណែនាំអំពីតម្លៃទីផ្សារ) ÷

១- ប្រសិនបើភាគហ៊ុនត្រូវបានដាក់លក់ជាសាធារណៈ ឬតម្លៃទីផ្សាររបស់វាអាចត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវផ្សេងពីនេះ ការវិនិយោគត្រូវតែវាស់វែងតាមតម្លៃទីផ្សារ តាមបម្រែបម្រួលនៃតម្លៃទីផ្សារដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាត។

២- សម្រាប់រាល់វិនិយោគបែបនេះទាំងអស់ ត្រូវវាស់វែងដោយយកថ្លៃដើម ដកជាមួយការថយចុះតម្លៃ។ ការថយចុះតម្លៃ ឬ ភាពដែលមិនអាចប្រមូលបាន ត្រូវតែធ្វើការបាន់ស្មានសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានចែងក្នុងចំណុច (ក), (ខ) និងចំណុច (គ)(២) ខាងលើ។កថាខណ្ឌ ១១.២១-១១.២៦ ផ្តល់ការណែនាំអំពីករណីនេះ។

វិធីសាស្ត្រថ្លៃដើមរំលស់ និងវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព

១១.១៥ ថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុមួយនាកាលបរិច្ឆេទរាយការណ៍និមួយៗ គឺជាបរិមាណសរុបនៃ ÷

(ក)ចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនាពេលទទួលស្គាល់ដំបូង

(ខ)ដក ជាមួយការទូទាត់មុនលើបរិមាណដើម

(គ)បូកឬដក វិលស់បូកយោងដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនដែលបានទទួលស្គាល់ដំបូង និងចំនួននាពេលដល់កាលកំណត់សង

(ឃ)ដកចេញ នូវការកាត់ចេញនូវការថយចុះតម្លៃឬការដែលមិនអាចប្រមូលបានក្នុងករណីវាជាទ្រព្យសកម្មរូបិយវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុដែលមិនមានអត្រាការប្រាក់បានកំណត់នឹងត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលខ្លី ឬបំណុលរយៈពេលខ្លី ត្រូវបានធ្វើការវាស់វែងជាដំបូងតាមបរិមាណមួយមិនបញ្ចុះតម្លៃស្របតាមកថាខណ្ឌ ១១.១៤(ក)។ ដូចនេះ ចំណុច(គ) ខាងលើមិនត្រូវបានអនុវត្តចំពោះចំពោះទ្រព្យសកម្មនិងបំណុលនោះឡើយ។

១១.១៦ វិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាសស្រ្តមួយនៃការគណនាថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុមួយ(ឬជាក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ) និងជាវិធីសាស្រ្តនៃការធ្វើវិភាជន៍ចំណូលពីការប្រាក់ឬចំណាយលើការប្រាក់តាមការិយបរិច្ឆេទពាក់ព័ន្ធ។អត្រាការប្រាក់ប្រសិទ្ធភាពគឺជាអត្រាដែលបញ្ចុះតម្លៃយ៉ាងជាក់លាក់លើការទូទាត់ឬការទទួលបានសាច់ប្រាក់ប៉ាន់ស្មា ននាពេល ទៅតាមអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ ឬ នៅពេលសមស្រប សម្រាប់រយៈពេលខ្លី ធ្វើការបញ្ចុះតម្លៃទភលើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ។ អត្រាការប្រាក់ប្រសិទ្ធិភាពត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មឬបំណុលហិរញ្ញវត្ថុនាពេលទទួលស្គាល់ដំបូង។តាមវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាពៈ

(ក)ថ្លៃដើមរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ(បំណុល) គឺចាតម្លៃបច្ចុប្បន្នចំណូលជាសាច់ប្រាក់នាពេលអនាគត(ចំណាយ) ដែលត្រូវបានចុះតម្លៃតាមអត្រាការប្រាក់ប្រសិទ្ធភាព និង

(ខ)ចំណាយលើការប្រាក់(ចំណូល)ក្នុងការិយបរិច្ឆេទស្មើនឹងតម្លៃពិតគណនេយ្យនៃបំណុលហិរញ្ញវត្ថុ(ទ្រព្យសកម្ម) នាការិយបរិច្ឆេទចាប់ផ្តើមមួយ គុណនឹងអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ការិយបរិច្ឆេទនោះ។

១១.១៧ នាពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព អង្គភាពត្រូវប៉ាន់ស្មានទូវលំហូរសាច់ប្រាក់ ដោយពិចារណាលើលក្ខខណ្ឌក្នុងកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ(ឧ. ការទូទាត់មុន ជម្រើសនៃការទិញត្រឡប់វិញ ឬជម្រើសប្រហាក់ប្រហែល) ព្រមទាំងការខាតបង់ឥណទានដែលបានដឹង ដែលបានកើតឡើង ប៉ុន្តែមិនត្រូវពិចារណាលើការខាតបង់ឥណទានដែលងាចកើតមាននាពេលអនាគត ដែលពុំទាន់កើតមាននោះទេ។

១១.១៨ នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព អង្គភាពត្រូវធ្វើរំលស់នូវសោហ៊ុយទាក់ទិនផ្សេងៗ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬដែលបានទទួល (ដូចជា 'points') ថ្លៃដើមប្រតិបត្តិការ និងបុព្វលាភ ឬការបញ្ចុះតម្លៃដទៃទៀតក្នុងកំឡុងអាយុកាលបាន់ស្មាននៃឧបករណ៍ លើកលែងតែចំណាយឬបន្ទុកដូចតទៅ។ អង្គភាពត្រូវប្រើរយៈពេលខ្លី ប្រសិនបើវាជារយៈពេលដែលសោហ៊ុយ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬដែលបានទទួល ថ្លៃដើមប្រតិបត្តិការ និងបុព្វលាភទាក់ទិននឹងរយៈពេលខ្លីនោះ។ ករណីនេះ វាអាចកើតមាននៅពេលដែលមាន បម្រែបម្រួលលើសោហ៊ុយទាក់ទិនផ្សេងៗ បន្ទុកហិរញ្ញវត្ថុដែលបានបង់ឬដែលបានទទួល ថ្លៃដើមប្រតិបត្តិការ និង បុព្វលាភ ឬការបញ្ចុះតម្លៃដទៃទៀត ត្រូវបានកំណត់ថ្លៃឡើងវិញតាមអត្រាទីផ្សារ មុនដល់កាលកំណត់នៃឧបករណ៍។ ករណីនេះ ការិយបរិច្ឆេទរំលស់ត្រឹមត្រូវ គឺការិយបរិច្ឆេទនៃថ្ងៃកំណត់ថ្លៃឡើងវិញចុងក្រោយ។

១១.១៩ សម្រាប់អត្រាប្រែប្រួលនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងនៃបំណុលហិរញ្ញវត្ថុ ការប៉ាន់ស្មានឡើងវិញតាម ដំណាក់កាលនៃលំហូរសាច់ប្រាក់ដែលបង្ហាញឲ្យឃើញនូវការផ្លាស់ប្តូរនូវអត្រាការប្រាក់លើទីផ្សារនាំឲ្យមានការកែប្រែនូវអត្រាការប្រាក់ប្រសិទ្ធភាព។ប្រសិនបើ អត្រាប្រែប្រួលនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងនៃបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ពីដំបូងក្នុងបរិមាណមួយស្មើនឹងបរិមាណដើមដែលត្រូវទទួលឬត្រូវបង់ នាពេលដល់កាលកំណត់ ការធ្វើការប៉ាន់ស្មានឡើងវិញនូវចំណាយលើការប្រាក់នាពេលអនាគត ជាធម្មតាមិននាំឲ្យមានផលប៉ះពាល់ខ្លាំងដល់តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលនោះទេ។

១១.២០ ប្រសិនបើអង្គភាពមួយផ្លាស់ប្តូរចំណូលឬចំណាយរបស់ខ្លួន អង្គភាពត្រូវកែតម្រូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ (ឬក្រុមនៃឧបករណ៍ហិរញ្ញវត្ថុ) ដើម្បីបង្ហាញឲ្យឃើញនូវលំហូរសាច់ប្រាក់ប៉ាន់ស្មានជាក់ស្តែង និងដែលបានកែតម្រូវ។ អង្គភាពត្រូវធ្វើការគណនាឡើងវិញនូវតម្លៃពិតគណនេយ្យដោយគិតតាមតម្លៃបច្ចុប្បន្ននៃលំហូសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត់ តាមអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃឧបករណ៍ហិរញ្ញវត្ថុ។អង្គភាពត្រូវទទួលស្គាល់ការកែតម្រូវនោះថាជាចំណូល ឬចំណាយ នៅក្នុងចំណេញឬខាត នាកាលបរិច្ឆេទផ្លាស់ប្តូរនោះ។

| |
|---|
| ឧទាហរណ៍នៃការកំណត់នូវថ្លៃដើមរំលស់សម្រាប់កម្ចីរយៈពេលប្រាំឆ្នាំដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព<br>នៅថ្ងៃទី 01 មករា 20X0 អង្គភាពមួយបានទិញសញ្ញាប័ណ្ណជាឯកតារូបិយប័ណ្ណចំនួន 900 ហើយ ចំណាយថ្លៃដើមប្រតិបត្តិការ50 ឯកតារូបិយប័ណ្ណ។ ការប្រាក់សម្រាប់40 ឯកតារូបិយប័ណ្ណ អាចទទួលបាន ជារៀងរាល់ឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំ រហូតដល់អស់បំណុល(ពីថ្ងៃទី31 ធ្នូ 20X0- 31 ធ្នូ 20X4)។ សញ្ញាប័ណ្ណ មានរំលស់ជាចាំបាច់ប្រមាណ50 ឯកតារូបិយប័ណ្ណ នៅថ្ងៃទី31 ធ្នូ 20X4។ |

| ឆ្នាំ | តម្លៃពិតគណនេយ្យដើមការិយបរិច្ឆេទ | ចំណូលការប្រាក់តាមអត្រា **6.9583%*** | លំហូរចូលសាច់ប្រាក់ | តម្លៃពិតគណនេយ្យចុងការិយបរិច្ឆេទ |
|---|---|---|---|---|
| | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ | ឯកតារូបិយប័ណ្ណ |
| 20X0 | 950.00 | 66.10 | (40.00) | 976.11 |
| 20X1 | 976.11 | 67.92 | (40.00) | 1,004.03 |
| 20X2 | 1,004.03 | 69.86 | (40.00) | 1,033.89 |
| 20X3 | 1,033.89 | 71.94 | (40.00) | 1,065.83 |
| 20X4 | 1,065.83 | 74.16 | (40.00) | 1,100.00 |
| | | | (1,100.00) | 0 |
| *អត្រាការប្រាក់ប្រសិទ្ធភាព 6.9583% ជាអត្រាដែលបញ្ចុះតម្លៃលំហូរសាច់ប្រាក់ដែលរំពឹងទុកលើសញ្ញាប័ណ្ណចំពោះតម្លៃពិតគណនេយ្យដើមដំបូង: | | | | |
| $40/(1.069583)^1 + 40/(1.069583)^2 + 40/(1.069583)^3 + 40/(1.069583)^4 + 1{,}140/(1.069583)^5 = 950$ | | | | |

ការថយចុះតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើម ឬថ្លៃដើមរំលស់

ការទទួលស្គាល់

១១.២១ នាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុណាមួយដែលត្រូវបានវាស់វែងតាមថ្លៃដើម ឬថ្លៃដើមរំលស់ដែរឬទេ។ ប្រសិនបើ មានភស្តុតាងជាក់ស្តែងនៃការថយចុះតម្លៃនេះ អង្គភាពត្រូវតែទទួលស្គាល់នូវការខាតបង់ដោយការថយចុះតម្លៃក្នុងចំណេញ ឬខាតជាបន្ទាន់។

១១.២២ ភស្តុតាងជាក់ស្តែងដែលទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានថយចុះតម្លៃ រួមទាំងទិន្នន័យដែលគួរឲ្យកត់សម្គាល់ដែលអ្នកកាន់កាប់ទ្រព្យសកម្មត្រូវមានការប្រយ័ត្នប្រយែងអំពីព្រឹត្តិការណ៍ដែលនាំឲ្យខាតបង់ដូចខាងក្រោម ÷

(ក) ការលំបាកផ្នែកហិរញ្ញវត្ថុគួរឲ្យកត់សម្គាល់របស់អ្នកបោះផ្សាយឧបករណ៍ ឬរបស់អ្នកជាប់កាតព្វកិច្ច

(ខ) ការមិនបំពេញតាមកិច្ចសន្យា ដូចជា ការបំពាន ឬអំពើល្មើសមិនបង់ការប្រាក់ ឬមិនបង់ប្រាក់ដើម។

(គ) ពេលមានហេតុផលខាងសេដ្ឋកិច្ច ឬខាងផ្លូវច្បាប់ទាក់ទិននឹងផលវិបាកផ្នែកហិរញ្ញវត្ថុ ម្ចាស់បំណុល ព្រមព្រៀង ផ្តល់សិទ្ធិឲ្យកូនបំណុលនូវសម្បទានមួយដែលតាមពិតម្ចាស់បំណុលមិនចង់ធ្វើ។

(ឃ) មានភាពជឿជាក់ថាកូនបំណុលនឹងឈានទៅរកការក្ស័យធុនឬមានការរៀបចំឡើងវិញផ្នែកហិរញ្ញវត្ថុផ្សេងទៀត

(ង) ទិន្នន័យគួរឲ្យកត់សម្គាល់បង្ហាញថា មានការកាត់បន្ថយលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ពីក្រុមទ្រព្យសកម្មណាមួយ ចាប់ពីពេលទទួលស្គាល់លើកដំបូងនូវទ្រព្យសកម្មទាំងនោះ ទោះបីជាការកាត់បន្ថយនោះមិនអាចកំណត់បាននៅឡើយលើទ្រព្យសកម្មនីមួយៗនៅក្នុងក្រុម ដូចជា លក្ខខណ្ឌសេដ្ឋកិច្ចក្នុងស្រុក ឬជាតិមិនអំណោយផល ឬការប្រែប្រួលមិនល្អនៃលក្ខខណ្ឌឧស្សាហកម្ម។

១១.២៣ មានកត្តាផ្សេងទៀតអាចជាភស្តុតាងនៃការថយចុះតម្លៃ រួមមានការប្រែប្រួលធំៗដែលមានឥទ្ធិពលមិនល្អត្រូវបានកើតឡើងពីបរិដ្ឋានបច្ចេកវិទ្យា ទីផ្សារ សេដ្ឋកិច្ចឬច្បាប់ដែល ជាអ្នកចេញឧបករណ៍ហិរញ្ញវត្ថុធ្វើប្រតិបត្តិការរបស់ខ្លួន។

១១.២៤ អង្គភាពត្រូវវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដូចខាងក្រោមដាចលដោយឡែកពីគ្នា អំពីការថយចុះតម្លៃរបស់វា ៖

(ក) ឧបករណ៍មូលធនផ្ទាល់ទាំងអស់ ដោយមិនគិតថាវាចម្បង ឬមិនចម្បង និង

(ខ) ទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀត ដែលមានសារៈសំខាន់ដាច់ដោយឡែកពីគ្នា។
អង្គភាពត្រូវវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុដទៃទៀតសម្រាប់ការថយចុះតម្លៃ ដោយឡែកៗពីគ្នា ឬជាក្រុមដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។

### ការវាស់វែង

១១.២៥ អង្គភាពត្រូវវាស់វែងការខាតបង់ដោយការថយចុះតម្លៃដោយប្រើឧបករណ៍ដូចតទៅដែលបានវាស់វែងតាមថ្លៃដើម ឬថ្លៃដើមរំលស់ ដូចខាងក្រោម ៖

(ក) ចំពោះឧបករណ៍ដែលវាស់វែងតាមថ្លៃដើមរំលស់ស្របតាមកថាខណ្ឌ១១.១៤(ក) ការខាងបង់ដោយការថយចុះតម្លៃគឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និងតម្លៃជាក់ស្តែងនៃលំហូរសាច់ប្រាក់ប៉ាន់ស្មានដែលបានបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមដំបូងរបស់ទ្រព្យសកម្មនោះ។ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុនោះ មានអត្រាការប្រាក់ប្រែប្រួល អត្រាចុះតម្លៃសម្រាប់វាស់វែងការខាតបង់បណ្តាលពីការថយចុះតម្លៃ គឺជាអត្រាការប្រាក់ប្រសិទ្ធភាពបច្ចុប្បន្នដែលបានកំណត់ក្នុងកិច្ចសន្យា។

(ខ) ចំពោះឧបករណ៍ដែលបានវាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃ ស្របតាមកថាខណ្ឌ ១១.១៤(ខ) និង

(គ)(២) ការខាតបង់ដោយការថយចុះតម្លៃ គឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និង ការប៉ាន់ស្មានដ៏ត្រឹមត្រូវ (ដែលមានការប្រហាក់ប្រហែលជាចាំបាច់)នៃបរិមាណ (ដែលអាចមានចំនួនសូន្យ ) ដែលអង្គភាពអាចទទួលបានពីទ្រព្យសកម្ម ប្រសិន បើឧបករណ៍ ត្រូវបានលក់ នាកាលបរិច្ឆេទរាយការណ៍។ ការបង្វិលត្រឡប់មកវិញ (ការបញ្ច្រាស)។

១១.២៦ ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ប្រសិនបើបរិមាណនៃការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃមាន ការថយចុះហើយការថយចុះនៃអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការមួយដែលបានកើតមានបន្ទាប់ពីការ ថយចុតម្លៃត្រូវបានទទួលស្គាល់ (ដូចជា ការតម្លើងតម្លៃអត្រាឥណទានរបស់កូនបំណុល) អង្គភាពត្រូវតែបង្វិល ត្រឡប់មកវិញនូវការខាតបង់បណ្តាលពីការចុះតម្លៃដែលបានទទួលស្គាល់ពីពលមុនៗ ដោយផ្ទាល់ ឬដោយ ការកែតម្រូវនូវគណនីវិភាជន៍។ ការបង្វិលត្រឡប់នេះ មិនត្រូវធ្វើលើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ (បរិមាណសរុបនៃគណនីវិភាជន៍) ដែលលើសពីអ្វីដែលតម្លៃពិតគណនេយ្យមានការថយចុះតម្លៃដែលមិនបាន ទទួលស្គាល់ពីមុន។អង្គភាពត្រូវទទួលស្គាល់បរិមាណនៃការបង្វិលត្រឡប់ទាំងអស់នៅក្នុងចំណេញ ឬខាតភ្លាម។

តម្លៃទីផ្សារ

១១.២៧ កថាខណ្ឌ ១១.១៤(គ)(១) តម្រូវឱ្យវិនយោគលើភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា ត្រូវតែធ្វើការវាស់វែងតាម តម្លៃទីផ្សារ ប្រសិនបើតម្លៃទីផ្សារនៃភាគហ៊ុនអាចត្រូវបានវាស់វែងគួរឱ្យទុកចិត្តបាន។ អង្គភាពត្រូវប្រើនូវចំណុច តាមលំដាប់លំដោយដូចខាងក្រោម ដើម្បីប៉ាន់ស្មានតម្លៃទីផ្សាររបស់ភាគហ៊ុន ÷

(ក)ភស្តុតាងប្រសើរបំផុតនៃតម្លៃទីផ្សារ គឺជាថ្លៃដែលបានស្រង់សម្រាប់ទ្រព្យសកម្មដែលអាចកំណត់បាននៅ ក្នុងទីផ្សារសកម្មមួយ។ ជាទូទៅ នេះគឺជាថ្លៃទិញបច្ចុប្បន្ន។

(ខ)នៅពេលដែលថ្លៃដែលបានស្រង់មិនអាចធ្វើទៅបានថ្លៃនៃប្រតិបត្តិការថ្មីៗរបស់ទ្រព្យសកម្មដែលអាចកំណត់ បាន ផ្តល់ជាភស្តុតាងនៃតម្លៃទីផ្សារ ដរាបណាមិនមាននូវការប្រែប្រួលធំដុំណាមួយនៃស្ថានភាពសេដ្ឋកិច្ច ឬនៃពេលវេលាកន្លងទៅដែលប្រតិបត្តិត្រូវបានធ្វើឡើង។ ប្រសិនបើអង្គភាព អាចបង្ហាញថាថ្លៃប្រតិបត្តិការកន្លង ទៅចុងក្រោយមិនមែនជាការប៉ាន់ស្មានដ៏ល្អនៃតម្លៃទីផ្សារនោះទេ (ឧទាហរណ៍ដូចជា ពីព្រោះថាវាបង្ហាញឱ្យ ឃើញនូវបរិមាណដែលអង្គភាពអាចទទួលបាន ឬអាចចំណាយលើប្រតិបត្តិការដោយបង្ខំ ការជម្រះបញ្ជីដោយ បង្ខំ ឬការលក់បង្ខំ) ថ្លៃនោះត្រូវបានធ្វើការកែតម្រូវ។

(គ)ប្រសិនបើទីផ្សារនៃទ្រព្យសកម្ម មិនមានដំណើរការ ហើយប្រតិបត្តិការថ្មីនៃទ្រព្យសកម្មដែលអាចកំណត់បាន ផ្ទាល់មិនអាចកំណត់នូវតម្លៃទីផ្សារបានល្អទេ អង្គភាពធ្វើការប៉ាន់ស្មាននូវតម្លៃទីផ្សារដោយប្រើនូវបច្ចេកទេស វាយតម្លៃ។ គោលដៅនៃការប្រើបច្ចេកទេសវាយតម្លៃនេះ គឺដើម្បីប៉ាន់ស្មានថាតើថ្លៃប្រតិបត្តិការណាដែលប្រើ នាកាលបរិច្ឆេទវាស់វែងលើដោះដូរធម្មតាដែលធ្វើឡើងដោយការចំណាយធម្មតានៅក្នុងអាជីវកម្ម។

ផ្នែកផ្សេងទៀតនៃស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិផ្សេងទៀត ធ្វើការយោងនូវគោលការណ៍តម្លៃទីផ្សារចែងក្នុងកថាខណ្ឌ ១១.២៧-១១.៣២ រាប់បញ្ចូលទាំង ផ្នែកទី ១២ , ផ្នែកទី ១៤, ផ្នែកទី ១៥ និងផ្នែកទី ១៦ ស្តីពីទ្រព្យវិនិយោគ។ ក្នុងការអនុវត្តគោលការណ៍ណែនាំនោះចំពោះទ្រព្យសកម្មដែលគ្របដណ្តប់ដោយផ្នែកទាំងនោះ ការយោងទៅដល់ភាគហ៊ុនធម្មតានិងភាគហ៊ុនបុរិមានៅក្នុងកថាខណ្ឌនេះត្រូវតែគិតបញ្ចូលនូវប្រភេទនានានៃទ្រព្យសកម្មដែលគ្របដណ្តប់ដោយផ្នែកទាំងនោះ។

បច្ចេកទេសវាយតម្លៃ

១១.២៨ បច្ចេកវាយតម្លៃ រួមមានប្រតិបត្តិការអាជីវកម្មធម្មតាថ្មីៗដែលបានប្រើសម្រាប់ទ្រព្យសកម្មដូចគ្នា រវាងភាគីដែលបានដឹងនិងមានបំណងដោយសំអាងលើតម្លៃទីផ្សារបច្ចុប្បន្នរបស់ទ្រព្យសកម្មមួយទៀតដែលដូចគ្នាជានិច្ចទៅនឹងទ្រព្យសកម្មដែលកំពុងតែបានវាស់វែង ការវិភាគអំពីលំហូរសាច់ប្រាក់ដែលបានបញ្ចុះ និងជម្រើសវិធីសាស្រ្តកំណត់ថ្លៃ។ប្រសិនបើមានបច្ចេកតែសវាយតម្លៃដែលប្រើប្រាស់ជាទូទៅដោយអ្នកចូលរួមក្នុងទីផ្សារដើម្បីកំណត់ថ្លៃទ្រព្យសកម្មហើយដែលបច្ចេកទេសនោះត្រូវបានបង្ហាញដើម្បីផ្តល់នូវការប៉ាន់ស្មានតម្លៃអាចឲ្យទុកចិត្តបានដែលទទួលបានពីប្រតិបត្តិការទីផ្សារជាក់ស្តែង អង្គភាពត្រូវប្រើបច្ចេកទេសនោះ។

១១.២៩ គោលដៅនៃការប្រើបច្ចេកទេសវាយតម្លៃគឺដើម្បីបង្កើតនូវថ្លៃនៃប្រតិបត្តិការដែលអាចយកមកប្រើក្នុងកាលបរិច្ឆេទវាស់វែងការប្តូរបាក់ជាប្រចាំដែលបណ្តាលមកពីសកម្មភាពអាជីវកម្មធម្មតា។តម្លៃទីផ្សារត្រូវបានប៉ាន់ស្មានដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលពីបច្ចេកទេសវាយតម្លៃដែលនាំឲ្យប្រើធាតុចូលទីផ្សារជាអតិបរមានិងដែលអាស្រ័យលើធាតុចូលដែលកំណត់ដោយអង្គភាពឲ្យបានកាន់តែតិចតាមតែអាចធ្វើទៅបាន។ បច្ចេកទេសវាយតម្លៃអាចត្រូវបានរំពឹងថាឈានដល់ការប៉ាន់ស្មានមួយនៃតម្លៃទីផ្សារ ប្រសិនបើ ÷

(ក) បច្ចេកទេសវាយតម្លៃបង្ហាញយ៉ាងត្រឹមត្រូវថាតើទីផ្សារវាយតម្លៃទ្រព្យសកម្មយ៉ាងដូចម្តេច ហើយ

(ខ) ធាតុចូលនៅក្នុងបច្ចេកទេសវាយតម្លៃជាសញ្ញាសមហេតុផលនៃការរំពឹងទុករបស់ទីផ្សារ ហើយការវាស់វែងលើហានិភ័យត្រឡប់ទៅជាចលករនានាដែលមានជាប់ជាមួយទ្រព្យសកម្ម។

ទីផ្សារអសកម្ម --ឧបករណ៍មូលធនផ្ទាល់

១១.៣០តម្លៃទីផ្សារនៃវិនិយោគលើទ្រព្យសកម្មដែលមិនមានថ្លៃទីផ្សារដែលបានស្រង់នៅក្នុងទីផ្សារសកម្មមួយត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវប្រសិនបើ ÷

(ក)អថេរតាមលំដាប់លំដោយនៃការប៉ាន់ស្មានតម្លៃទីផ្សារ មិនមានសារៈសំខាន់សម្រាប់ទ្រព្យសកម្ម

(ខ)ភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗតាមលំដាប់លំដោយអាចត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ហើ យបានប្រើប្រាស់នៅក្នុងការប៉ាន់ស្មានតម្លៃទីផ្សារ។

១១.៣១មានស្ថានភាពច្រើនណាស់ដែលចាត់ទុកថាមិនមានសារៈសំខាន់ ក្នុងនោះអថេរតាមលំដាប់លំដោយនៃការប៉ាន់ស្មានតសមហេតុផលលើតម្លៃទីផ្សារនៃទ្រព្យសកម្មដែលមិនមានថ្លៃទីផ្សារដែលបានស្រង់។ជាធម្មតា គេមិនអាចប៉ាន់ស្មានតម្លៃទីផ្សាររបស់ទ្រព្យសកម្មមួយ ដែលអង្គភាពបានទិញពីភាគីខាងក្រៅ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើបណ្តាការប៉ាស្មាន់សមហេតុផលនៃតម្លៃទីផ្សារមានសារៈសំខាន់ ហើយភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗមិនអាចត្រូវបានវាយតម្លៃដោយត្រឹមត្រូវ អង្គភាពត្រូវប្រានចោលមិនវាស់វែងទ្រព្យសកម្មតាមតម្លៃទីផ្សារ។

១១.៣២ប្រសិនបើការវាស់វែងលើតម្លៃទីផ្សារគួឲ្យទុកចិត្តមិនអាចធ្វើបានលើទ្រព្យសកម្មមួយដែលបានវាស់វែងតាមតម្លៃទីផ្សារបានតទៅទៀតទេ (ដូចជា ឧបករណ៍មូលធនផ្ទាល់ដែលវាស់វែងតាមតម្លៃទីផ្សារតាមរយៈចំណេញ ឬខាត) នោះតម្លៃពិតគណនេយ្យរបស់វានាកាលបរិច្ឆេទចុងក្រោយដែលទ្រព្យសកម្មអាចវាស់វែងបាន នឹងក្លាយទៅជាថ្លៃដើមថ្មីរបស់វា។ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មតាមបរិមាណថ្លៃដើមនេះ ដកជាមួយការថយចុះតម្លៃរហូតទាល់តែគេអាចធ្វើការវាស់វែងតម្លៃទីផ្សារគួរឲ្យទុកចិត្តបាន។

### ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ

១១.៣៣ អង្គភាពមួយត្រូវមិនទទួលស្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុ តែនៅពេលដែល ÷

(ក) សិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបានផុតកំណត់ ឬបានទូទាត់រួច ឬ

(ខ) អង្គភាពផ្ទេរដល់ភាគីផ្សេងទៀតនូវហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិសំខាន់ៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ

(គ) ទោះបីជាអង្គភាពបានថែរក្សានូវហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិសំខាន់ៗក៏ដោយ អង្គភាពបានផ្ទេរការត្រួតពិនិត្យលើទ្រព្យសកម្មដល់ភាគីផ្សេង ហើយភាគីផ្សេងមានលទ្ធភាពលក់ទ្រព្យសកម្ម ទាំងអស់ទៅឲ្យតតិយជនដែលមិនពាក់ព័ន្ធ ហើយភាគីផ្សេងនោះអាចអនុវត្តលទ្ធភាពនោះ ជាឯកតោភាគី និងដោយមិនចាំបាច់ដាក់លក្ខខណ្ឌបន្ថែមទៀតលើការផ្ទេរនោះ។ ករណីនេះ អង្គភាព ត្រូវ ÷

១- មិនទទួលស្គាល់ទ្រព្យសកម្ម និង

២- ទទួលស្គាល់ដាច់ដោយឡែកពីគ្នានូវសិទ្ធិនិងកាតព្វកិច្ចដែលមានឬដែលបានបង្កើតឡើងនៅក្នុងការផ្ទេរ។

តម្លៃពិតគណនេយ្យទ្រព្យសកម្មដែលបានផ្ទេរ នឹងត្រូវបានធ្វើវិភាជន៍រវាងសិទ្ធិនិងកាតព្វកិច្ចដែលមាន ហើយអ្វីដែលបានផ្ទេរត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃតម្លៃទីផ្សារទាក់ទិន នាកាលបរិច្ឆេទផ្ទេរ។ រាល់ភាពខុសគ្នារវាងតម្លៃតបស្នងដែលទទួលបាននិងបរិមាណទឹកប្រាក់ដែលទទួលស្គាល់និងមិនទទួលស្គាល់ស្របតាមកថាខណ្ឌនេះត្រូវតែទទួលស្គាល់នៅក្នុងចំណេញ ឬខាតក្នុងការិយបរិច្ឆេទផ្ទេរ។

១១.៣៤ ប្រសិនបើការផ្ទេរមិនបណ្តាលឲ្យមានការមិនទទួលស្គាល់ដោយសារតែអង្គភាពបានរក្សាទុកនូវហានិភ័យ និងប្រាក់រង្វាន់កម្មសិទ្ធិសំខាន់ៗនៃទ្រព្យសកម្មដែលបានផ្ទេរ អង្គភាពត្រូវបន្តទទួលស្គាល់ទ្រព្យសកម្មដែលបានផ្ទេរ

នៅក្នុងទ្រព្យសកម្មទាំងមូល ហើយត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុសម្រាប់តម្លៃតបស្នងដែលទទួលបាន។ ទ្រព្យសកម្មនិងបំណុលមិនត្រូវបានកាត់កងគ្នាឡើយ។សម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ អង្គភាពត្រូវទទួលស្គាល់នូវចំណូលពីការផ្ទេរទ្រព្យសកម្ម និងទទួលស្គាល់នូវចំណាយនានាដែលកើតមានពីបំណុលហិរញ្ញវត្ថុ។

១១.៣៥ ប្រសិនបើអង្គភាពដែលផ្ទេរផ្តល់នូវវត្ថុបញ្ចាំមិនមែនជាសាច់ប្រាក់ (ដូចជា ឧបករណ៍បំណុល ឬឧបករណ៍មូលធនផ្ទាល់) ដល់អ្នកទទួល គណនេយ្យកម្មសម្រាប់វត្ថុបញ្ចាំដែលធ្វើដោយអង្គ ភាពផ្ទេរនិងដោយអ្នកទទួលអាស្រ័យដោយថាតើអ្នកទទួលមានសិទ្ធិលក់ ឬធ្វើកិច្ចសន្យាបន្តលើវត្ថុបញ្ចាំ និងថាតើអង្គភាពផ្ទេរបានបំពានកិច្ចសន្យាឬទេ។ អង្គភាពផ្ទេរ និងអ្នកទទួល ត្រូវតែធ្វើគណនេយ្យកម្មលើវត្ថុបញ្ចាំដូចតទៅ ÷

(ក) ប្រសិនបើអ្នកទទួលមានសិទ្ធតាមកិច្ចសន្យាឬតាមទម្លាប់ក្នុងការលក់ ឬធ្វើកិច្ចសន្យាបន្តនូវវត្ថុបញ្ចាំ អង្គភាពផ្ទេរត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញលើទ្រព្យសកម្មដាច់ដោយឡែកពីគ្នាពីទ្រព្យសកមមផ្សេងៗទៀត នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ (ដូចជា ទ្រព្យសកម្មដែលបានឲ្យខ្ចី ឧបករណ៍មូលធនផ្ទាល់ដែលបានដាក់សន្យាឬប្រាក់ចំណូលបានពីការទិញវិញ)។

(ខ) ប្រសិនបើអ្នកទទួលលក់វត្ថុបញ្ចាំដែលជាប់កិច្ចសន្យា នោះអ្នកទទួលត្រូវទទួលស្គាល់នូវចំណូល ទាំងឡាយណាដែលបានពីការលក់ ព្រមតាំងបំណុលដែលបានវាស់វែងតាមតម្លៃទីផ្សារ នៅពេលខ្លួនបំពេញកាតព្វកិច្ចបង្វិលត្រឡប់នូវវត្ថុបញ្ចាំនោះ។

(គ) ប្រសិនបើអង្គភាពដែលផ្ទេរបំពាននូវលក្ខខណ្ឌនៅក្នុងកិច្ចសន្យានិងលែងមានសិទ្ធិរំលស់វត្ថុបញ្ចាំតទៅទៀត នោះអង្គភាពផ្ទេរត្រូវឈប់ទទួលស្គាល់នូវវត្ថុបញ្ចាំ ហើយអង្គភាពនេះត្រូវទទួលស្គាល់នូវវត្ថុបញ្ចាំថាជាទ្រព្យសកម្មដែលបានវាស់វែងលើកដំបូងតាមតម្លៃទីផ្សារ ឬ មិនទទួលស្គាល់ កាតព្វកិច្ចរបស់ខ្លួនក្នុងការបង្វិលសងត្រឡប់នូវវត្ថុបញ្ចាំនោះ ប្រសិនបើគេបានលក់វត្ថុបញ្ចាំនោះ ហើយ។

(ឃ) វាលែងតែបានចែងក្នុងចំណុច (គ) ខាងលើ អង្គភាពផ្ទេរត្រូវបន្តកាន់កាប់វត្ថុបញ្ចាំថាជាទ្រព្យសកម្មរបស់ខ្លួន ហើយអ្នកទទួលមិនត្រូវទទួលស្គាល់នូវវត្ថុបញ្ចាំថាជាទ្រព្យសកម្មរបស់ខ្លួនឡើយ។

ឧទាហរណ៍ ÷ ការផ្ទេរដែលបំពេញលក្ខខណ្ឌមិនទទួលស្គាល់

អង្គភាពមួយលក់គណនីអតិថិជនរបស់គេមួយចំនួនដល់ធនាគារមួយដែលមានតម្លៃទាបជាងបរិមាណចរិកពិត អង្គភាអ នៅតែបន្តប្រមូលចំណូលពីកូនបំណុលរបស់ខ្លួនក្នុងនាមធនាគារ ដោយរួមទាំងបានធ្វើរបាយការណ៍ប្រចាំខែដល់ធនាគារហើយធនាគារចំណាយដល់អង្គភាពនោះនូវកម្រៃតាមអត្រាទីផ្សារលើសេវាកម្មទទួលនូវចំណូលពីអតិថិជន។ អង្គ ភាព ត្រូវបានចាប់បង្ខំឲ្យបញ្ជូននូវបរិមាណសាច់ប្រាក់ដែលប្រមូលបានភ្លាមទៅធនាគារ ប៉ុន្តែអង្គជាពពុំមានកាតព្វកិច្ចចំពោះ ធនាគារចំពោះការយឺតយ៉ាវបង់ ឬមិនបានបង់របស់កូនបំណុលនោះទេ។ ករណីនេះ អង្គភាពបានផ្ទេរនូវហានិភ័យ និងប្រាក់រង្វាន់កម្មសិទ្ធិសំខាន់ៗលើប្រាក់ដែលអតិថិជន

ជំពាក់រួចហើយ។ ដូចនេះ អង្គភាពត្រូវលប់នូវប្រាក់ដែលអតិថិជន ជំពាក់ពីរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញ
របស់ខ្លួន (មានន័យថា ឈប់ទទួលស្គាល់វា) ហើយវាមិនបង្ហាញនូវបំណុល ពាក់ព័ន្ធនឹងចំណូលដែលទទួល
ពីធនាគារនោះទេ។ អង្គភាពទទួលស្គាល់នូវបំណុលក្នុងក្របខណ្ឌដែលគាត់បានប្រមូល មូលនិធិពីកូនបំណុល
ដែលមិនទាន់បានប្រគល់ទៅឱ្យធនាគារតែប៉ុណ្ណោះ។

ឧទាហរណ៍ ÷ ការផ្ទេរដែលមិនបំពេញលក្ខខណ្ឌមិនទទួលស្គាល់
ព្រឹត្តិការណ៍គឺដូចគ្នានឹងឧទាហរណ៍ខាងលើដែរលើកលែងតែថាអង្គភាពបានយល់ព្រមទិញត្រឡប់មកវិញពី
ធនាគារ នូវចំណូលដែលអតិថិជនជំពាក់ដែលកូនបំណុលនៅជំពាក់ថ្លៃដើម ឬការប្រាក់រយៈពេលលើសពី
១២០ ថ្ងៃ។ ករណីនេះ អង្គភាពបានរក្សាទុកនូវហានិភ័យពីការបង់ប្រាក់យឺតយ៉ាវ ឬការមិនបង់ប្រាក់ពី
សំណាក់កូនបំណុល ដែលចាត់ទុកថា ជាហានិភ័យចម្បងនៃសាច់ប្រាក់ដែលអតិថិជនជំពាក់នោះ។ ដូចនេះ
អង្គភាពមិនត្រូវចាត់ទុកថា សាច់ប្រាក់របស់ អតិថិជននោះត្រូវបានលក់ឱ្យធនាគារនោះទេ ហើយអង្គភាព
មិនត្រូវមិនទទួលស្គាល់វាទេ។ ផ្ទុយមកវិញ អង្គភាព ត្រូវចាត់ទុកចំណូលទទួលបានពីធនាគារថាជាប្រាក់កម្ចី
ដែលធានាដោយសាច់ប្រាក់ដែលអតិថិជនជំពាក។ អង្គភាព បន្តទទួលស្គាល់នូវសាច់ប្រាក់ដែលអតិថិជនជំពា
ថាជាទ្រព្យសកម្មមួយរហូតទាល់តែសាច់ប្រាក់នោះត្រូវបានប្រមូល ឬចាត់ទុកថាមិនអាចប្រមូលបាន។

### ការមិនទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុ

១១.៣៦ អង្គភាពមួយ ត្រូវមិនទទួលស្គាល់នូវបំណុលហិរញ្ញវត្ថុ (ឬមួយចំណែកនៃបំណុលហិរញ្ញវត្ថុ) តែនៅពេលដែលបំណុលនោះបានបញ្ចប់ មានន័យថា នៅពេលដែលកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាត្រូវបានបំពេញចប់ បានលើកលែង ឬផុតអាជ្ញាយុកាល។

១១.៣៧ ប្រសិនបើកូនបំណុល និងម្ចាស់បំណុលធ្វើការដោះដូរឧបករណ៍ហិរញ្ញវត្ថុរវាង គ្នាជាមួយនឹង លក្ខខណ្ឌចម្បងផ្សេងគ្នា អង្គភាពទាំងនោះត្រូវរាប់បញ្ចូលនូវប្រតិបត្តិការថាជាការបញ្ចប់បំណុលហិរញ្ញវត្ថុដើម ហើយថា ជាការទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មី។ ដូចគ្នានេះដែរ អង្គភាពមួយត្រូវរាប់បញ្ចូលនូវការកែប្រែសំខាន់ៗ លើលក្ខខណ្ឌនៃបំណុលហិរញ្ញវត្ថុដែលមានឬមួយចំណែកនៃបំណុលនោះ (មិនថាវានាំឱ្យ ឬមិននាំឱ្យមាន ផលវិបាកផ្នែកហិរញ្ញវត្ថុរបស់កូនបំណុល)ថាជាការលក់ចោលបំណុលហិរញ្ញវត្ថុដើម និងថាជាការទទួលស្គាល់ នូវបំណុលហិរញ្ញវត្ថុថ្មី។

១១.៣៨អង្គភាពត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាតនូវផាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃបំណុលហិរញ្ញវត្ថុ (ឬមួយផ្នែកនៃបំណុលហិរញ្ញវត្ថុ)ដែលបានលុបចោល ឬដែលបានផ្ទេរទៅភាគីផ្សេងទៀត និងរវាង តម្លៃតបស្នងដែលបានបង់ រួមទាំងទ្រព្យសកម្មមិនមែនជាសាច់ប្រាក់ទាំងឡាយណាដែលបានផ្ទេរ ឬបំណុលសន្មត់។

### ការលាតត្រដាងព័ត៌មាន

១១.៣៩ការលាតត្រដាងព័ត៌មានខាងក្រោម ត្រូវបានធ្វើឡើងដោយយោងលើការលាតត្រដាងព័ត៌មានអំពីបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត។ អង្គភាពដែលមានតែឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន (ហើយដែលមិនអាចអនុវត្តផ្នែកទី ១២) នឹងមិនមានបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃទីផ្សារ នៅក្នុងរបាយការណ៍ចំណេញ ឬខាត ហើយបើដូចនេះ មិនចាំបាច់ធ្វើការលាតត្រដាងព័ត៌មាននេះទេ។

### ការលាតត្រដាងព័ត៌មានអំពីគោលនយោបាយគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ

១១.៤០ ស្របតាមកថាខណ្ឌ ៨.៥ នៅក្នុងសេចក្តីសង្ខេបនៃគោលនយោបាយសំខាន់ៗរបស់ខ្លួន អង្គភាពត្រូវលាតត្រដាងអំពីមូលដ្ឋាននៃការវាស់វែង (ឬគោលការណ៍មូលដ្ឋាន)ដែលបានប្រើប្រាស់សម្រាប់ឧបករណ៍ ហិរញ្ញវត្ថុ ព្រមទាំងគោលនយោបាយគណនេយ្យផ្សេងៗទៀតដែលបានប្រើសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលទាក់ទិនទៅនឹងការយល់ដឹងអំពីរបាយការណ៍ហិរញ្ញវត្ថុ។

### របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ និង ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ

១១.៤១ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីតម្លៃពិតគណនេយ្យសម្រាប់ប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដូចខាងក្រោមនាកាលបរិច្ឆេទរាយការណ៍ជាចំនួនសរុប ទាំងនៅក្នុងរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុទាំងក្នុងកំណត់សម្គាល់ ÷

(ក)ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត (កថាខណ្ឌ ១១.១៤ (គ)១ និងកថាខណ្ឌ ១២.៨ និង ១២.៩)។

(ខ)ទ្រព្យសកម្មហិរញ្ញវត្ថុនានាដែលជាឧបករណ៍បំណុលវាស់វែងតាមថ្លៃដើមរំលស់ (កថាខណ្ឌ ១១.១៤ (ក))។

(គ)ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍មូលធនផ្ទាល់ដែលបានវាស់វែងតាមថ្លៃដើមដកការថយចុះ តម្លៃ (កថាខណ្ឌ ១១.១៤(គ)២ និងកថាខណ្ឌ ១២.៨ និង ១២.៩)។

(ឃ)បំណុលហិរញ្ញវត្ថុវាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត (កថាខណ្ឌ ១២.៨ និង ១២.៩)។

(ង)បំណុលហិរញ្ញវត្ថុ វាស់វែងតាមថ្លៃដើមរំលស់ (កថាខណ្ឌ ១១.១៤ (ក))។

(ច)កិច្ចសន្យាខ្ចីប្រាក់វាស់វែងតាមថ្លៃដើមដកការថយចុះតម្លៃ (កថាខណ្ឌ ១១.១៤ (ខ))។

១១.៤២អង្គភាពត្រូវលាតត្រដាងព័ត៌មានដែលអាចឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពដើម្បីវាយតម្លៃលើសារៈសំខាន់នៃឧបករណ៍ហិរញ្ញវត្ថុចំពោះលទ្ធផលហិរញ្ញវត្ថុនិងស្ថានផាពហិរញ្ញវត្ថុ។ ឧទាហរណ៍ សម្រាប់បំណុលរយៈពេលវែង ព័ត៌មានបែបនេះជាធម្មតាអាចរាប់បញ្ចូលនូវលក្ខខណ្ឌនៃឧបករណ៍បំណុល

(ដូចជា អត្រាប្តូរប្រាក់ បក្ខភាព(ការដល់កាលកំណត់សង) តារាងទូទាត់ឡើងវិញ ព្រមទាំងលក្ខខណ្ឌកំណត់នានាដែលឧបករណ៍បំណុលដាក់កំហិតទៅលើអង្គភាព)។

១១.៤៣ សម្រាប់គ្រប់ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុទាំងអស់ដែលវាស់វែងតាមតម្លៃទីផ្សារ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីមូលដ្ឋាននៃការកំណត់តម្លៃទីផ្សារ មានន័យថាជាថ្លៃទីផ្សារដែលបានស្រង់ក្នុងទីផ្សារសកម្មមួយ ជាបច្ចេកទេសវាយតម្លៃ។ នៅពេលដែលបច្ចេកទេសវាយតម្លៃត្រូវបានប្រើប្រាស់ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការសន្មត់នានាដែលបានអនុវត្តក្នុងការកំណត់តម្លៃទីផ្សារសម្រាប់ចំណាត់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ។ ឧទាហរណ៍ដូចជា ប្រសិនបើអាចធ្វើបាន អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីការសន្មត់នានាទាក់ទិនទៅនឹងអត្រានៃការទូទាត់មុន អត្រានៃការខាតបង់ឥណទានប៉ាន់ស្មាន និងអត្រាការប្រាក់ ឬអត្រាអប្បហា។

### ការមិនទទួលស្គាល់

១១.៤៥ ប្រសិនបើអង្គភាពបានផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុដល់ភាគីផ្សេងទៀត ក្នុងប្រតិបត្តិការមួយដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់មិនទទួលស្គាល់ (សូមមើលកថាខណ្ឌ ១១.៣៣-១១.៣៥) អង្គភាពត្រូវលាតត្រដាងព័តមានសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដូចខាងក្រោម ÷

(ក)ប្រភេទនៃទ្រព្យសកម្ម។

(ខ)ប្រភេទនៃហានិភ័យនិងប្រាក់រង្វាន់កម្មសិទ្ធិ ដែលអង្គភាពត្រូវបង្ហាញ

(គ)តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និងនៃបំណុលមានភ្ជាប់មកជាមួយ ដែលអង្គភាពបន្តទទួលស្គាល់។

### វត្ថុបញ្ចាំ

១១.៤៦ នៅពេលដែលអង្គភាពមួយបានយកទ្រព្យសកម្មហិរញ្ញវត្ថុជាវត្ថុបញ្ចាំសម្រាប់បំណុលហិរញ្ញវត្ថុ ឬបំណុលយថាហេតុ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចតទៅ ÷

(ក)តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានសន្យាជាវត្ថុបញ្ចាំ។

(ខ)លក្ខខណ្ឌទាក់ទិននឹងកិច្ចសន្យា។

### ការខកខាន និងការបំពានកម្ចីដែកត្រូវបង់

១១.៤៧ ចំពោះកម្ចីដែលត្រូវបង់ដែលបានទទួលស្គាល់នាកាលបរិច្ឆេទរាយការណ៍ ដែលនាពេលនោះមានការបំពានលក្ខខណ្ឌ ឬខកខានមិនបានសងបំណុលដើម ការប្រាក់ មូលនិធិបណ្តាក់ទុន (ប្រាក់សន្សំទុកសងបំណុលពេលអនាគត) ឬលកខណ្ឌរំលស់ ដែលមិនទាន់បានទូទាត់សងនាកាលបរិច្ឆេទរាយការណ៍ អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក)ភាពលម្អិតនៃការខកខាន ឬការបំពាននោះ។

(ខ)តម្លៃពិតគណនេយ្យនៃកម្ចីត្រូវបង់ដែលពាក់ព័ន្ធនាកាលបរិច្ឆេទរាយការណ៍។

(គ)មិនថាការបំពានឬការខកខានត្រូវបានទូទាត់សង ឬមិនថាលក្ខខណ្ឌនៃកម្ចីត្រូវបង់ត្រូវបានចរចារនោះទេ ការលាតត្រដាងត្រូវធ្វើមុនរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

**ធាតុនៃចំណូល ចំណាយ ចំណេញ ឬខាត**

១១.៤៨ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីធាតុនៃចំណូល ចំណាយ ចំណេញ ឬខាត ដូចខាងក្រោមៈ

(ក)ចំណូល ចំណាយ ចំណេញ ឬខាត រួមទាំងការប្រែប្រួលនៃតម្លៃទីផ្សារ បានទទួលស្គាល់ក្នុងៈ

១-ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត។

២-បំណុលហិរញ្ញវត្ថុ វាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត។

៣-ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមរំលស់។

៤ -បំណុលហិរញ្ញវត្ថុ វាស់វែងតាមថ្លៃដើមរំលស់។

(ខ)ចំណូលពីការប្រាក់សរុប និងចំណាយលើការប្រាក់សរុប (ដែលត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត។

(គ)បរិមាណនៃការខាតបង់ដោយការថយចុះតម្លៃសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

## ផ្នែកទី ១២
## ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត

### វិសាលភាពនៃផ្នែកទី ១១ និង ១២

១២.១ ផ្នែកទី១១ ស្ដីពី ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី ១២ ស្ដីពី ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ផ្នែកទាំងពីរនេះទាក់ទិនទៅនឹងការទទួលស្គាល់ ការមិនទទួលស្គាល់ ការវាស់វែង និងការលាតត្រដាងព័ត៌មានអំពីឧបករណ៍ហិរញ្ញវត្ថុ (ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ)។ ផ្នែកទី១១ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ហើយពាក់ព័ន្ធគ្រប់អង្គភាពទាំងអស់។ ផ្នែកទី១២ អនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុនិងប្រតិបត្តិការផ្សេងទៀតដែលមានលក្ខណៈស្មុគស្មាញជាង។ ប្រសិនបើ អង្គភាពមួយចូលរួមតែនៅក្នុងប្រតិបត្តិការឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ផ្នែកទី១២ មិនត្រូវបានអនុវត្តឡើយ។ ប៉ុន្តែទោះបីជាអង្គភាពទាំងនោះមានតែឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋានក៏ដោយ អង្គភាពនោះត្រូវចាត់ទុកវិសាលភាពនៃផ្នែកទី១២ ដើម្បីធានាថាវាត្រូវបាន លើកលែង។

### ការជ្រើសរើសគោលនយោបាយគណនេយ្យ

១២.២ អង្គភាពត្រូវជ្រើសរើសយកមកអនុវត្តនូវចំណុចណាមួយដូចខាងក្រោម ÷

(ក)វិធានទាំងស្រុងនៅក្នុងទាំងផ្នែកទី១១ និងផ្នែកទី១២ ឬ

(ខ)វិធាននៃការទទួលស្គាល់ និងការវាស់វែងតាម ស្តង់ដារគណនេយ្យអន្តរជាតិលេខ ៣៩ ស្តីពី ឧបករណ៍ហិរញ្ញវត្ថុ:*ការទទួលស្គាល់និងការវាស់វែង*ហើយនិង ការតម្រូវឲ្យលាតត្រដាបព័ត៌មានតាមផ្នែកទី១១ និងផ្នែកទី១២

ដើម្បីធ្វើគណនេយ្យកម្មនូវរាល់ឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួនទាំងអស់។ ការជ្រើសរើសរបស់អង្គភាពយកចំណុច (ក) ឬ (ខ) គឺជាជម្រើសនៃគោលនយោបាយគណនេយ្យ។ កថាខណ្ឌ ១០.៨-១០.១៤ មានចែងអំពីការតម្រូវនានាសម្រាប់កំណត់ថាតើនៅពេលមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ប្រសិនបើយល់ថាសមរម្យ ហើយតើការផ្លាស់ប្តូរនេះអាចត្រូវបានយកមកគិតគូរដែរឬទេ និងថាតើព័ត៌មានអ្វីខ្លះដែលត្រូវលាតត្រដាងអំពីការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ។

### វិសាលភាពនៃផ្នែកទី ១២

១២.៣ ផ្នែកទី ១២ អនុវត្តចំពោះគ្រប់ឧបករណ៍ហិរញ្ញវត្ថុលើកលែងតែឧបករណ៍មួយចំនួនដូចខាងក្រោមៈ

(ក)ឧបករណ៍ហិរញ្ញវត្ថុដែលគ្របដណ្ដប់ដោយផ្នែកទី ១១។

(ខ)ភាគកម្មក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (សូមមើលផ្នែកទី៩ ស្តីពី របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍

ហិរញ្ញវត្ថុដោយឡែក) នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ (សូមមើល ផ្នែកទី ១៤ ស្តីពី វិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ) និងនៅក្នុងក្រុមហ៊ុនរួមទុន (សូមមើលផ្នែកទី ១៥ ស្តីពី វិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន)។

(គ) សិទ្ធិនិងកាតព្វកិច្ចរបស់និយោជកតាមផែនការអត្ថប្រយោជន៍បុគ្គលិក (សូមមើលផ្នែកទី ២៨ ស្តីពី អត្ថប្រយោជន៍បុគ្គលិក)។

(ឃ) សិទ្ធិតាមកិច្ចសន្យាធានារ៉ាប់រង លើកលែងតែកិច្ចសន្យាធានារ៉ាប់រងនាំឲ្យមានការខាតបង់ចំពោះអង្គភាព ដោយសារលក្ខខណ្ឌនៃកិច្ចសន្យា ដែលមិនពាក់ព័ន្ធទៅនឹងទាំង ៖

១- ការប្រែប្រួលនៃហានិភ័យដែលត្រូវធានា

២- ការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេស

៣- ការខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដោយភាគីណាមួយ។

(ង) បករណ៍ហិរញ្ញវត្ថុដែលបំពេញបានតាមនិយមន័យនៃ មូលធនផ្ទាល់របស់អង្គភាព (សូមមើលផ្នែកទី ២២ ស្តីពី មូលធនផ្ទាល់ និងផ្នែកទី ២៦ ស្តីពី ការទូទាត់ដោយផ្អែកលើសន្លឹកភាគហ៊ុន)។

(ច) ភតិសន្យា (សូមមើលផ្នែកទី ២០ ស្តីពី ភតិសន្យា) លើកលែងតែភតិសន្យាដែលបណ្តាលឲ្យមានការខាតបង់ចំពោះភតិបតី ឬ ភតិកៈ ដោយសារតែលក្ខខណ្ឌនៃកិច្ចសន្យា ដែលមិនពាក់ព័ន្ធនឹង ៖

១- ការប្រែប្រួលថ្លៃនៃទ្រព្យសកម្មដែលបានធ្វើភតិសន្យា

២- ការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេស

៣- ការខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដោយភាគីណាមួយ។

(ឆ) កិច្ចសន្យាសម្រាប់តម្លៃតបស្នងយថាហេតុនៅក្នុងការរួមបញ្ចូលអាជីវកម្ម (សូមមើលផ្នែកទី ១៩ ស្តីពី ការរួមបញ្ចូលអាជីវកម្ម និងមូលនិធិពាណិជ្ជកម្ម)។ ការលើកលែងនេះ អនុវត្តតែចំពោះតែអ្នកទិញ។

១២.៤ កិច្ចសន្យាភាគច្រើនដើម្បីទិញ ឬលក់ធាតុមិនមែនហិរញ្ញវត្ថុណាមួយដូចជា ទំនិញ សារពើភ័ណ្ឌ ឬទ្រព្យ រោងចក្រ និងបរិក្ខា ត្រូវបានដកចេញពីផ្នែកនេះ ពីព្រោះថាវាទាំងនោះមិនមែនជាឧបករណ៍ហិរញ្ញវត្ថុទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ផ្នែកនេះអនុវត្តចំពោះគ្រប់កិច្ចសន្យាទាំងអស់ដែលដាក់ហានិភ័យលើអ្នកទិញ ឬអ្នកលក់ដែលមិនតំណាងឲ្យកិច្ចសន្យាទិញ ឬលក់ទ្រព្យសកម្មរូបិយ។ ឧទាហរណ៍ ផ្នែកនេះអនុវត្តចំពោះកិច្ចសន្យាដែលបណ្តាលឲ្យមានការខាតបង់ចំពោះអ្នកទិញ ឬអ្នកលក់ ដោយសារតែលក្ខខណ្ឌនៃកិច្ចសន្យាដែលិនពាក់ព័ន្ធនឹងការប្រែប្រួលនៃថ្លៃរបស់ធាតុមិនមែនហិរញ្ញវត្ថុ ការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស ឬការខកខានមិនបានបំពេញតាមកិច្ចសន្យាដោយភាគីណាមួយ។

១២.៥ បន្ថែមលើកិច្ចសន្យាដែលបានពិពណ៌នាក្នុងកថាខណ្ឌ ១២.៤ ផ្នែកនេះអនុវត្តចំពោះកិច្ចសន្យាទិញ ឬលក់ធាតុមិនមែនហិរញ្ញវត្ថុ ប្រសិនបើកិច្ចសន្យាអាចត្រូវបានទូទាត់ជាសាច់ប្រាក់ ឬជាឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ,

ឬទូទាត់ដោយការដោះដូររវាងឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើកិច្ចសន្យាគឺជាកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុដែលមានការលើកលែងដូចជាៈ កិច្ចសន្យាដែលធ្វើឡើងនិងបន្តធ្វើឡើងដើម្បីគោលបំណងទទួល ឬប្រគល់ធាតុមិនមែនហិរញ្ញវត្ថុស្របតាមការទិញដែលអង្គភាពរំពឹងទុក និងតម្រូវការលក់ឬការប្រើប្រាស់មិនមែនជាឧបករណ៍ហិរញ្ញវត្ថុដែលចែងក្នុងផ្នែកនេះ។

### ការទទួលស្គាល់ជាដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

១២.៦ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុលហិរញ្ញវត្ថុមួយតែនៅពេលដែលអង្គភាព ក្លាយជាភាគីនៃវិធានកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។

### ការវាស់វែងជាដំបូង

១២.៧ នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុលហិរញ្ញវត្ថុមួយត្រូវបានទទួលស្គាល់លើកដំបូង អង្គភាពត្រូវវាស់វែងនូវទ្រព្យស ឬបំណុលនោះតាមតម្លៃទីផ្សារ ដែលជាធម្មតាគឺជាថ្លៃនៃប្រតិបត្តិការ។

### ការវាស់វែងជាបន្តបន្ទាប់ទៀត

១២.៨ នាចុងការិយបរិច្ឆេទរាយការណ៍ នីមួយៗ អង្គភាពត្រូវវាស់វែងរាល់ឧបករណ៍ហិរញ្ញវត្ថុក្រោមវិសាលភាពនៃផ្នែកទី ១២ នេះ តាមតម្លៃទីផ្សារ ហើយត្រូវទទួលស្គាល់ការប្រែប្រួលនៃតម្លៃទីផ្សារនេះនៅក្នុងចំណេញ ឬខាត លើលែងករណីដូចតទៅៈ ឧបករណ៍មូលធនផ្ទាល់ដែលមិនត្រូវបានដាក់លក់ជាសាធារណៈ ហើយដែលតម្លៃទីផ្សាររបស់វាមិនអាចវាស់វែងឱ្យបានត្រឹមត្រូវទេ ហើយម្យ៉ាងទៀតកិច្ចសន្យាដែលទាក់ទិននឹងឱ្យបករណ៍ទាំងនោះបណ្តាលឱ្យមានការប្រគល់ឧបករណ៍នេះ អង្គភាពត្រូវវាស់វែងវាដោយយកថ្លៃដើម ដកការថយចុះតម្លៃ ប្រសិនបើគេធ្វើដូចនេះ។

១២.៩ ប្រសិនបើការវាស់វែងដែលគួឱ្យទុកចិត្តបានលើតម្លៃទីផ្សារមិនអាចអនុវត្តបានសម្រាប់ឧបករណ៍មូលធនផ្ទាល់ដែលមិនបានដាក់លក់ជាសាធារណៈ ប៉ុន្តែវាត្រូវបានវាស់វែងតាមតម្លៃទីផ្សាក្នុងចំណេញ ឬខាត នោះតម្លៃទីផ្សាររបស់វានាកាលបរិច្ឆេទចុងក្រោយដែលឧបករណ៍អាចវាស់វែង ត្រូវបានចាត់ទុកថាជាថ្លៃនៃឧបករណ៍។ អង្គភាពត្រូវវាស់វែងឧបករណ៍ដោយយកបរិមាណថ្លៃដើមដកការថយចុះតម្លៃ រហូតទាល់តែការវាស់វែងដែលគួរឱ្យទុកចិត្តមួយលើតម្លៃទីផ្សារអាចធ្វើទៅបាន។

### តម្លៃទីផ្សារ

១២.១០ អង្គភាពត្រូវអនុវត្តគោលការណ៍ណែនាំអំពីតម្លៃទីផ្សារក្នុងកថាខណ្ឌ ១១.២៧-១១.៣២ ការវាស់វែងលើចំពោះតម្លៃទីផ្សារស្របតាមផ្នែកនេះ ក៏ដូចជាចំពោះការវាស់វែងតម្លៃទីផ្សារស្របតាមផ្នែកទី ១១។

១២.១១ តម្លៃទីផ្សាររបស់បំណុលហិរញ្ញវត្ថុដែលត្រូវបង់តាមតម្រូវការមិនតិចជាងបរិមាណដែលអាចបង់បានតាមតម្រូវការ នោះការបញ្ចុះតម្លៃពីកាលបរិច្ឆេទដំបូងដែលបរិមាណនោះត្រូវបង់ដាច់ខាត។

១២.១២ អង្គភាពមិនត្រូវគិតបញ្ចូលនូវថ្លៃដើមប្រតិបត្តិការនៅក្នុងការវាស់វែងលើកដំបូងលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលនឹងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃទីផ្សារក្នុងចំណេញឬខាត។ ប្រសិនបើការទូទាត់ចំពោះទ្រព្យសកម្មមួយត្រូវបានពន្យា ឬត្រូវបានធ្វើហិរញ្ញប្បទាន តាមអត្រា ការប្រាក់ មិនមែនជាអត្រាទីផ្សារ អង្គភាពត្រូវវាស់វែងជាដំបូងនូវទ្រព្យសកម្មតាមតម្លៃជាក់ស្តែងនៃការទូទាត់នាពេលអនាគត ដោយបញ្ចុះតម្លៃតាមអត្រាការប្រាក់លើទីផ្សារ។

## ការថយចុះតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើម ឬតាមថ្លៃដើមរំលស់

១២.១៣ អង្គភាពត្រូវអនុវត្តគោលការណ៍ណែនាំស្តីពីការថយចុះតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដែលចែងក្នុងកថាខណ្ឌ ១១.២១-១១.២៦ ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលបានវាស់វែងដោយយកថ្លៃដើម ដកការថយចុះតម្លៃស្របតាមផ្នែកនេះ។

## ការមិនទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ

១២.១៤ អង្គភាពត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការមិនទទួលស្គាល់ក្នុងកថាខណ្ឌ ១១.៣៣-១១.៣៨ លើទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ ក្នុងក្របខណ្ឌនៃការអនុវត្តផ្នែកនេះ។

## គណនេយ្យទប់ស្កាត់ហានិភ័យ

១២.១៥ ប្រសិនបើបំពេញគ្រប់តាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ អង្គភាពអាចកំណត់នូវទំនាក់ទំនងទប់ស្កាត់រវាងឧបករណ៍ទប់ស្កាត់ហានិភ័យមួយ និង ធាតុទប់ស្កាត់ហានិភ័យមួយ តាមមធ្យោបាយណាមួយ ដើម្បីធ្វើឱ្យ មានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យ។ គណនេយ្យទប់ស្កាត់ហានិភ័យអនុញ្ញាត ឱ្យមានការទទួលស្គាល់នូវចំណេ ឬខាតលើឧបករណ៍ទប់ស្កាត់ហានិភ័យនិងលើធាតុដែលបានទប់ស្កាត់ហានិភ័យ នៅក្នុងចំណេញឬខាតនៅពេលតែមួយ។

១២.១៦ ដើម្បីផ្តល់លក្ខណៈសម្បត្តិគ្រប់គ្រាន់ដល់គណនេយ្យទប់ស្កាត់ហានិភ័យ អង្គភាពត្រូវអនុលោមតាមលក្ខខណ្ឌដូចតទៅ ÷

(ក) អង្គភាពកំណត់និងកសាងឯកសារនូវទំនាក់ទំនងទប់ស្កាត់ហានិភ័យ ធ្វើដូចនេះ ហានិភ័យអាចត្រូវបានទប់ស្កាត់ ធាតុទប់ស្កាត់ហានិភ័យនិងឧបករណ៍ទប់ស្កាត់ហានិភ័យត្រូវបានកំណត់យ៉ាងច្បាស់ ហើយហានិភ័យលើធាតុទប់ស្កាត់នោះ ត្រូវបានទប់ស្កាត់ដោយឧបករណ៍នោះ។

(ខ) ហានិភ័យដែលបានទប់ស្កាត់ គឺជាហានិភ័យមួយដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.១៧។

(គ) ឧបករណ៍ទប់ស្កាត់ហានិភ័យ មានដូចជាបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.១៨

(ឃ) អង្គភាពរំពឹងថា ឧបករណ៍ទប់ស្កាត់ហានិភ័យដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការទូទាត់ជាមួយហានិភ័យដែលបានទប់ស្កាត់កំណត់ជាមុន។ ប្រសិទ្ធភាពនៃការទប់ស្កាត់ គឺជាកម្រិតដែលការប្រែប្រួលលើតម្លៃទីផ្សារ ឬលើលំហូរសាច់ប្រាក់នៃធាតុដែលបានទប់ស្កាត់ដែលនាំឱ្យមានហានិភ័យដែលបានទប់ស្កាត់ វបានទូទាត់ជាមួយការប្រែប្រួលនៃតម្លៃទីផ្សារ ឬនៃលំហូរសាច់ប្រាក់នៃឧបករណ៍ទប់ស្កាត់។

១២.១៧ ស្តង់ដារនេះអនុញ្ញាតឱ្យមានការធ្វើគណនេយ្យសម្រាប់ទប់ស្កាត់ហានិភ័យសម្រាប់តែហានិភ័យដូចតទៅ ÷

(ក) ហានិភ័យលើអត្រាការប្រាក់នៃឧបករណ៍បំណុលវាស់វែងតាមថ្លៃដើមរំលស់។

(ខ) ហានិភ័យនៃអត្រាប្តូររូបិយប័ណ្ណបរទេស ឬអត្រាការប្រាក់ក្នុងកិច្ចសន្យាមួយច្បាស់លាស់ ឬប្រតិបត្តិការដែលមានការព្យាករណ៍ខ្ពស់។

(គ) ហានិភ័យថ្លៃនៃទំនិញដែលអង្គភាពមាន ឬ ក្នុងកិច្ចសន្យាមួយច្បាស់លាស់ ឬ ឬប្រតិបត្តិការដែលមានការព្យាករណ៍ខ្ពស់ក្នុងការទិញ ឬលក់ទំនិញនោះ។

(ឃ) ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេសដែលមានក្នុងវិនិយោគសុទ្ធ នៅក្នុងប្រតិបត្តិការជាមួយ បរទេស។

ហានិភ័យពីការប្តូររូបិយប័ណ្ណបរទេសនៃឧបករណ៍បំណុលមួយដែលបានវាស់វែងតាមថ្លៃដើមរំលស់មិនស្ថិតនៅក្នុងតារាងខាងលើទេ ពីព្រោះថាគណនេយ្យទប់ស្កាត់ហានិភ័យ មិនមានឥទ្ធិពលអ្វី ខ្លាំងលើរបាយការណ៍ហិរញ្ញវត្ថុឡើយ។ គណនីមូលដ្ឋាន កំណត់សម្គាល់ និងកម្ចីត្រូវសងនិងត្រូវទទួល ជាធម្មតាត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ (សូមមើលកថាខណ្ឌ ១១.៥ (ឃ))។ នេះរួមមានទឹកប្រាក់ដែលត្រូវសងដែលបានកំណត់ជារូបិយប័ណ្ណបរទេស។ កថាខណ្ឌ ៣០.១០ តម្រូវឱ្យមានការប្រែប្រួលលើតម្លៃពិតគណនេយ្យនៃទឹកប្រាក់ដែលត្រូវបង់ពីព្រោះថាការប្រែប្រួលលើអត្រាប្តូរប្រាក់ នឹងត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ដូចនេះ ទាំងការប្រែប្រួលលើតម្លៃទីផសាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ (ការដោះដូររវាងរូបិយប័ណ្ណមួយជាមួយរូបិយប័ណ្ណមួយទៀត) និងការប្រែប្រួលលើតម្លៃពិតគណនេយ្យនៃទឹកប្រាក់ដែលត្រូវបង់ទាក់ទិននឹងការប្រែប្រួលនៃអត្រាប្តូរប្រាក់អាចត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត ហើយអាចទូទាត់រវាងគ្នា លើកលែងតែមានភាពខុសគ្នារវាងអត្រាជាក់ស្តែង (ដែលបំណុលត្រូវបានវាស់វែងតាមនោះ) និងអត្រានាពេលអនាគត (ដែលការដោះដូរត្រូវបានវាស់វែង)។

១២.១៨ ស្តង់ដារនេះអនុញ្ញាតឱ្យធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ តែពេលដែលឧបករណ៍ទប់ស្កាត់ហានិភ័យមានលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ÷

(ក) វាគឺជាការដោះដូរអត្រាការប្រាក់ ការដោះដូររូបិយប័ណ្ណបរទេស កិច្ចសន្យាដោះដូររូបិយប័ណ្ណបរទេសនាពេលអនាគត ឬកិច្ចសន្យាដោះដូរទំនិញនាពេលអនាគត ដែលរំពឹងថានឹងមានឥទ្ធិពលខ្ពស់លើការទូទាត់ហានិភ័យដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១២.១៧ ដែលបានកំណត់ថាជាហានិភ័យដែលបានទប់ស្កាត់។

(ខ)វាជាប់ពាក់ព័ន្ធនឹងភាគី១ ផ្សេងពីអង្គភាពដែលរាយការណ៍ (មានន័យថា ក្រៅពីក្រុមហ៊ុន ផ្នែកណាមួយនៃក្រុមហ៊ុនឬអង្គភាពផ្ទាល់ដែលបានរាយការណ៍)។

(គ)បរិមាណជាសញ្ញាណរបស់វា ស្មើនឹងបរិមាណនៃឧបករណ៍ដើមដែលបានកំណត់ ឬស្មើនឹងបរិមាណជាសញ្ញាណនៃធាតុទប់ស្កាត់ហានិភ័យ។

(ឃ)វាមានកាលបរិច្ឆេទដល់កាលកំណត់ទូទាត់ដែលបាមកំណត់ មិនលើសពី ÷

១-ការដល់កាលកំណត់ទូទាត់នៃឧបករណ៍ហិរញ្ញវត្ថុដែលបានទប់ស្កាត់។

២-ការទូទាត់ដែលរំពឹងទុកនៃកិច្ចសន្យាទិញ ឬលក់ទំនិញ ឬ

៣-មានការកើតឡើងនូវការព្យាករណ៍រូបិយប័ណ្ណបរទេសដែលមានបក្ខភាពខ្ពស់ ឬប្រតិបត្តិការទិញលក់ទំនិញដែលបានទប់ស្កាត់។

(ង)វាមិនមានការទូទាត់ មិនមានការបញ្ចប់មុន ឬពុំមានលក្ខណៈពន្យា។

**ការទប់ស្កាត់ហានិភ័យអត្រាការប្រាក់ថេរនៃឧបករណ៍ហិរញ្ញវត្ថុមួយដែលបានទទួលស្គាល់ ឬហានិភ័យ ថ្លៃទំនិញសម្រាប់ទំនិញរក្សាទុកសម្រាប់លក់**

១២.១៩ ប្រសិនបើលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ១២.១៦ ត្រូវបានបំពេញ ហើយហានិភ័យដែលបានទប់ស្កាត់ គឺជាការបង្ហាញអំពីហានិភ័យអត្រាការប្រាក់ថេរនៃឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមរំលស់ ឬបង្ហាញអំពីហានិភ័យថ្លៃទំនិញនៃទំនិញមួយដែលអង្គភាពមាន អង្គភាពត្រូវ ÷

(ក)ទទួលស្គាល់នូវឧបករណ៍ទប់សាត់ហានិភ័យថាជាទ្រព្យសកម្មមួយ ឬបំណុលមួយ ហើយការប្រែប្រួលតម្លៃទីផ្សារនៃឧបករណ៍ទប់ស្កាត់ហានិភ័យនៅក្នុងចំណេញ ឬខាតនិង

(ខ)ទទួលស្គាល់នូវការប្រែប្រួលតម្លៃទីផ្សារនៃធាតុទប់ស្កាត់ហានិភ័យទាក់ទិនទៅនឹងហានិភ័យដែលបានទប់ស្កាត់នៅក្នុងចំណេញ ឬខាត ហើយត្រូវទទួលស្គាល់ថាជាការកែតម្រូវមួយចំពោះតម្លៃពិតគណនេយ្យនៃធាតុដែលបានទប់ស្កាត់។

១២.២០ ប្រសិនបើហានិភ័យដែលបានទប់ស្កាត់ គឺជាហានិភ័យនៃអត្រាការប្រាក់ថេរនៃឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមរំលស់ អង្គភាពត្រូវទទួលស្គាល់នូវការទូទាត់ជាសាច់ប្រាក់សុទ្ធតាមការិយបរិច្ឆេទលើការដោះដូរអត្រាការប្រាក់ ដែលវាជាឧបករណ៍ទប់ស្កាត់ហានិភ័យក្នុងចំណេញ ឬខាតនាការិយបរិច្ឆេទដែលការទូទាត់សុទ្ធត្រូវបានបូកបន្ត។

១២.២១អង្គភាពមិនត្រូវបន្តការធ្វើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ ដែលបានកំណត់នៅក្នុងកថាខណ្ឌ ១២.១៩ ប្រសិនបើ ÷

(ក) ឧបករណ៍ទប់ស្កាត់ហានិភ័យហួសកាលកំណត់ ឬត្រូវបានលក់ ឬត្រូវបានបញ្ចប់

(ខ) ការទប់ស្កាត់លែងបំពេញតាមលក្ខខណ្ឌសម្រាប់គណនេយ្យកម្មទប់ស្កាត់ហានិភ័យដែលបានកំណត់ក្នុងកថាខណ្ឌ ១២.១៦ ទៀតហើយ ឬ

(គ) អង្គភាពបដិសេធការកំណត់នោះ។

១២.២២ ប្រសិនបើគណនេយ្យកម្មទប់ស្កាត់ហានិភ័យមិនត្រូវបានបន្ត ហើយធាតុទប់ស្កាត់គឺជាទ្រព្យសកម្មឬបំណុលដែលបានគិតតាមថ្លៃដើមរំលស់ដែលមិនត្រូវបានឈប់ទទួលស្គាល់ នោះចំណេញ ឬខាតដែលទទួលស្គាល់ថាជាការកែតម្រូវលើតម្លៃពិតគណនេយ្យរបស់ធាតុទប់ស្កាត់ហានិភ័យ ត្រូវបានរំលស់នៅក្នុងចំណេញ ឬខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពសម្រាប់រយៈពេលជីវិតនៃឧបករណ៍ទប់ស្កាត់ហានិភ័យ។

**ការទប់ស្កាត់ហានិន័យអត្រាការប្រាក់អថេរនៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ ហានិន័យអត្រាប្តូររូបិយប័ណ្ណ ឬហានិន័យថ្លៃទំនិញ នៅក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន ឬប្រតិបត្តិការព្យាករណ៍ដែលមានបក្ខតាពខ្ពស់ ឬនៅក្នុងវិនិយោគក្នុងប្រតិបត្តិការបរទេស**

១២.២៣ ប្រសិនបើលក្ខខណ្ឌក្នុងកថាខណ្ឌ ១២.១៦ ត្រូវបានបំពេញ ហើយហានិភ័យទប់ស្កាត់គឺជា ÷

(ក) ហានិភ័យអត្រាការប្រាក់អថេរលើឧបករណ៍បំណុលដែលបានវាស់វែងតាមថ្លៃដើមរំលស់

(ខ) ហានិភ័យអត្រាប្តូររូបិយប័ណ្ណក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន ឬនៅក្នុងប្រតិបត្តការព្យាករណ៍ដែលមានបក្ខភាពខ្ពស់,

(គ) ហានិភ័យថ្លៃទំនិញក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន ឬនៅក្នុងប្រតិបត្តការព្យាករណ៍ដែលមានបក្ខភាពខ្ពស់ ឬ

(ឃ) ហានិភ័យអត្រាប្តូររូបិយប័ណ្ណនៅក្នុងវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេស

អង្គភាពត្រូវទទួលស្គាល់នៅក្នុង របាយការណ៍ចំណូលផ្សេងទៀតនូវចំណែកនៃការប្រែប្រួលលើតម្លៃទីផ្សារនៃឧបករណ៍ទប់ស្កាត់ហានិភ័យ ដែល អាចទូទាត់កាត់កងនូងការប្រែប្រួលលើតម្លៃទីផ្សារ ឬលើលំហូរសាច់ប្រាក់ដែលបានរំពឹងទុកនៃធាតុទប់ស្កាត់។ អង្គភាពត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាតនូវចំនួនលើសនៃតម្លៃទីផ្សាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យលើស ពីការប្រែប្រួលនៃតម្លៃទីផ្សារនៃលំហូរសាច់ប្រាក់ដែលបាន រំពឹងទុក (ជួនកាលហៅថា អប្រសិទ្ធភាពនៃការទប់ ស្កាត់ហានិភ័យ)។ចំណេញ ឬខាតដែលបានទប់ស្កាត់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលផ្សេងទៀត ត្រូវធ្វើការចាត់ថ្នាក់ឡើងវិញក្នុងចំណេញ ឬខាត នៅពេលដែលធាតទប់ស្កាត់ហានិភ័យត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ឬនៅពេលដែលទំនាក់ទំនងទប់ស្កា ត់ត្រូវបញ្ចប់។

១២.២៤ ប្រសិនបើហានិភ័យដែលបានទប់ស្កាត់ ជាហានិភ័យនៃអត្រាការប្រាក់អថេរក្នុងឱ្យបករណ៍បំណុល ដែលបាន វាស់វែងតាមថ្លៃដើមរំលស់ អង្គភាពត្រូវទទួលស្គាល់ជាបន្តបន្ទាប់នៅក្នុងចំណេញឬខាត នូវការទូទាត់ជាសាច់ប្រាក់ សុទ្ធតាមការិយបរិច្ឆេទ ពីការដោះដូរអត្រាការប្រាក់ដែលជាឱ្យបករណ៍ទប់ស្កាត់ហានិភ័យនាការិយបរិច្ឆេទដែល ការទូទាត់សុទ្ធត្រូវបានប្តូកបន្ត។

១២.២៥ អង្គភាពត្រូវបញ្ឈប់ការធ្វើគណនេយ្យកម្មសម្រាប់ទប់ស្កាត់ហានិភ័យដែលបានចែងនៅក្នុងកថាខណ្ឌ១២.២៣ ប្រសិនបើ ÷

(ក) ឧបករណ៍ទប់ស្កាត់ហានិភ័យហួសកាលកំណត់ ឬត្រូវបានលក់ ឬត្រូវបានបញ្ចប់

(ខ) ការទប់ស្កាត់លែងបំពេញតាមលក្ខខណ្ឌសម្រាប់គណនេយ្យកម្មទប់ស្កាត់ហានិភ័យដែលបានកំណត់ក្នុង កថាខណ្ឌ ១២.១៦ ទៀតហើយ ឬ

(គ) ក្នុងការទប់ស្កាត់ហានិភ័យនៃប្រតិបត្តិការព្យាករណ៍ប្រតិបត្តិការព្យាករណ៍លែងមានបក្ខភាពខ្ពស់ទៀតទេ ឬ

(ឃ) អង្គភាពបដិសេធការកំណត់នោះ។

ប្រសិនបើប្រតិបត្តិការព្យាករណ៍ ត្រូវបានរំពឹងថានឹងលែងកើតមានទៀតហើយ ឬប្រសិនបើឱ្យបករណ៍បំណុល ដែលបានទប់ស្កាត់ វាស់វែងតាមថ្លៃដើមរំលស់មិនត្រូវបានទទួលស្គាល់ទៀតទេ នោះរាល់ចំណេញ ឬការខាតបង់ លើឱ្យឧបករណ៍ទប់ស្កាត់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលផ្សេងទៀតត្រូវធ្វើការចាត់ថ្នាក់ឡើង វិញពីរបាយការណ៍នោះទៅចំណេញឬខាត។

## ការលាតត្រដាងព័ត៏មាន

១២.២៦អង្គភាពដែលអនុវត្តផ្នែកនេះ ត្រូវតែលាតត្រដាងព័ត៌មានទាំងអស់ដែលតម្រូវដោយផ្នែកទី ១១ ដោយបញ្ចូល ផងដែរនូវការលាតត្រដាងអំពីរបាយការណ៍ហិរញ្ញវត្ថុដែលស្ថិតក្រោមវិសាលភាពនៃផ្នែកនេះ ក៏ដូចជាការលាត ត្រដាងព័ត៌មានដែលស្ថិតក្រោមវិសាលភាពនៃផ្នែកទី ១១។ បន្ថែមលើសនេះទៀត ប្រសិនបើអង្គ ភាពប្រើ គណនេយ្យកម្មទប់ស្កាត់ហានិភ័យ អង្គភាពត្រូវលាតត្រដាងបន្ថែមនូវព័ត៌មានដែលមាននៅក្នុងកថាខណ្ឌ ១២.២៧-១២.២៩។

១២.២៧ អង្គភាពត្រូវលាតត្រដាងដាច់ដោយឡែកពីគ្នានូវការទប់ស្កាត់ហានិភ័យនៃប្រភេទទាំងបួននៃហានិភ័យដូចបាន ពិពណ៌នានៅក្នុងកថាខណ្ឌ ១២.១៧ ដូចខាងក្រោម ÷

(ក) ការពិពណ៌នានៃការទប់ស្កាត់។

(ខ) ការពិពណ៌នាអំពីរបាយការណ៍ហិរញ្ញវត្ថុដែលបានកំណត់ថាជាឧបករណ៍ទប់ស្កាត់ហានិភ័យ ព្រមទាំងតម្លៃទីផ្សារនៃឧបករណ៍តាំងនោះនាកាលបរិច្ឆេទរាយការណ៍។

(គ) ចរិកលក្ខណៈនៃហានិភ័យដែលបានទប់ស្កាត់ រួមទាំងពិពណ៌នាអំពីធាតុទប់ស្កាត់ហានីភ័យ។

១២.២៨ ប្រសិនបើអង្គភាពប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យ ដើម្បីទប់ស្កាត់ហានិភ័យពីអត្រាការប្រាក់ថេរ ឬ ហានិភ័យថ្លៃទំនិញនៃទំនិញដែលបានទិញ (កថាខណ្ឌ ១២ .១៩-១២.២២) អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) បរិមាណនៃការប្រែប្រួលលើតម្លៃទីផ្សាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ ដែលបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត។

(ខ) បរិមាណនៃការប្រែប្រួលលើតម្លៃទីផ្សាររបស់ធាតុទប់ស្កាត់ហានិភ័យ ដែលបានទទួលស្គាល់ នៅក្នុងចំណេញ ឬខាត។

១២.២៩ ប្រសិនបើអង្គភាពប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យសម្រាបទប់ស្កាត់ហានិភ័យអត្រាការប្រាក់អថេរ ហានិភ័យការប្តូររូបិយប័ណ្ណ ហានិភ័យថ្លៃទំនិញក្នុងកិច្ចសន្យាក្រុមហ៊ុន ឬសម្រាប់ទប់ស្កាត់ ប្រតិបត្តការព្យាករណ៍ដែលមានបក្ខភាពខ្ពស់ ឬសម្រាប់ទប់ស្កាត់វិនិយោគសុទ្ធលើប្រតិបត្តិការបរទេស (កថាខណ្ឌ ១២.២៣-១២.២៥) អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក)ការិយបរិច្ឆេទពេលដែលលំហូរសាច់ប្រាក់ត្រូវបានរំពឹងថានឹងកើតមាន និងពេលដែលលំហូរសាច់ប្រាក់នោះត្រូវបានរំពឹងថាវានឹងមានផលប៉ះពាល់ដល់ចំណេញ ឬខាត។

(ខ) ការពិពណ៌នាអំពីប្រតិបត្តិការព្យាករណ៍ដែលធ្លាប់បានប្រើគណនេយ្យកម្មទប់ស្កាត់ហានិភ័យពីពេលមុនៗ ប៉ុន្តែរំពឹងថាវានឹងមិនកើតឡើងទៀតទេ។

(គ) បរិមាណទឹកប្រាក់នៃការប្រែប្រួលលើតម្លៃទីផ្សាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យដែលត្រូវបានទទួលស្គាល់នៅក្នុរបាយការណ៍ចំណូលផ្សេងទៀត ក្នុងកំឡុងការិយបរិច្ឆេទ (កាថខណ្ឌ ១២.២៣)។

(ឃ) បរិមាណទឹកប្រាក់ដែលត្រូវចាត់ថ្នាក់ឡើងវិញពីរបាយការណ៍ចំណូលផ្សេងទៀតទៅក្នុងចំណេញ ឬខាតសម្រាប់ការិយបរិច្ឆេទ (កថាខណ្ឌ ១២.២៣-១២.២៥)។

(ង) បរិមាណទឹកប្រាក់នៃភាពលើសលើតម្លៃទីផ្សាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យ លើការប្រែប្រួលនៃតម្លៃទីផ្សាររបស់លំហូរសាច់ប្រាក់រំពឹងទុក ដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត (កថាខណ្ឌ ១២.២៤)។

## ផ្នែកទី ១៣

## សន្និធិ

### វិសាលភាពនៃផ្នែកនេះ

១៣.១ ផ្នែកនេះកំណត់នូវគោលការណ៍នានាសម្រាប់ទទួលស្គាល់ និងវាស់វែង សន្និធិ។ សន្និធិ គឺជា ទ្រព្យសកម្ម ÷

(ក)ដែលទុកសម្រាប់លក់ក្នុងសកម្មភាពអាជីវកម្មជាប្រចាំរបស់អង្គភាព

(ខ)ដែលមានក្នុងដំណើរការផលិតកម្មសម្រាប់ការលក់ឬ

(គ)ដែលមានទម្រង់ជាសម្ភារៈ ឬគ្រឿងផ្គត់ផ្គង់ ដែលប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ឬក្នុងការផ្តល់សេវាកម្ម។

១៣.២ ផែកនេះ អនុវត្តចំពោះគ្រប់សន្និធិ លើកលែងតែ ÷

(ក)ផលិតផលមិនទាន់សម្រេច(ការដ្ឋានកំពុងដំណើការ) ដែលកើតមាននៅក្នុងកិច្ចសន្យាសាងសង់ រួមបញ្ចូលដោយផ្ទាល់នូវសេវាពាក់ព័ន្ធនឹងកិច្ចសន្យា (សូមមើលផ្នែកទី ២៣ អំពី ចំណូល)។

(ខ)ឧបករណ៍ហិរញ្ញវត្ថុ (សូមមើល ផ្នែកទី ១១ អំពី ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន និង ផ្នែកទី ១២ អំពី ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត)។

(គ)ទ្រព្យសកម្មជីវសាស្រ្ត ដែលទាក់ទិនទៅនឹងសកម្មភាពនៅក្នុងវិស័យកសិកម្ម និង ផលិតផលកសិកម្ម នាកន្លែងប្រមូលផល (សូមមើលផ្នែកទី ៣៤ អំពី សកម្មភាពឯកទេស )។

១៣.៣ ផ្នែកនេះមិនអនុវត្តចំពោះការវាស់វែងសន្និធិដែលកាន់កាប់ដោយ ÷

(ក)ផលិតករនៃផលិតផលកសិកម្មនិងព្រៃឈើ ផលិផលកសិកម្មបន្ទាប់ពីប្រមូលផល ព្រមទាំងរ៉ែនិងផលិតផលរ៉ែ ដែលអាចវាស់វែងតាម តម្លៃទីផ្សារ ដកថ្លៃដើមលក់ ក្នុងចំណេញឬខាតឬ

(ខ)ឈ្មួញកណ្តាល និងអ្នកជួញដូរទំនិញ ដែលធ្វើការវាស់វែងសន្និធិរបស់គេតាមតំ្លៃទីផ្សារ ដកថ្លៃដើមលក់ ក្នុងចំណេញ ឬខាត

### ការវាស់វែងសន្និធិ

១៣.៤ អង្គភាពត្រូវវាស់វែងសន្និធិតាមថ្លៃដើមទាប និងត្រូវប៉ាន់ស្មានថ្លៃលក់ ដោយចេញដកថ្លៃដើមដែលត្រូវផលិតសម្រេចនិងលក់

### ថ្លៃដើមសន្និធិ

១៣.៥ អង្គភាពត្រូវបញ្ចូលក្នុងថ្លៃដើមនៃសន្និធិនូវរាល់ថ្លៃដើមទិញ ថ្លៃដើមបំប្លែង និងថ្លៃដើ មដទៃទៀតដែលបានកើតឡើងក្នុងការនាំយកសន្និធិទៅទីតាំងនិងលក្ខខណ្ឌទុដាក់របស់វា។

### ថ្លៃដើមទិញ

១៣.៦ ថ្លៃដើមទិញនៃ ការទិញរួមមាន ថ្លៃទិនិញ ពន្ធនាំចូលនិងពន្ធផ្សេងទៀត (លើកលែងតែសន្និធិទាំងនោះ ទទួលការអនុគ្រោះពីអាជ្ញាធរពន្ធ) ព្រមទាំងការដឹកជញ្ជូន លើកដាក់និងថ្លៃដើមផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញផលិតផលសម្រេច សម្ភារៈនិងសេវា។ អប្បហាពាណិជ្ជកម្ម ការបង្វិលឲ្យវិញនិងធាតុប្រហាក់ប្រហែលផ្សេងទៀត ត្រូវបានដកចេញ ដើម្បីកំណត់នូវថ្លៃទិញ។

១៣.៧ អង្គភាពអាចទិញសន្និធិក្រោមលក្ខខណ្ឌទូតាត់ពន្យា។ ករណីខ្លះ កិច្ចសន្យាមានចែងអំពីសមាសធាតុហិរញ្ញប្បទានដែលមិនបានចែង ឧទាហរណ៍ដូចជា ភាពខុសគ្នារវាងថ្លៃទិញសម្រាប់លក្ខខណ្ឌឥណទានធម្មតា និងបរិមាណដែលត្រូវទូទាត់ពន្យា។ករណីនេះ ភាពខុសគ្នាត្រូវបានទទួលស្គាល់ថាជាចំណាយការប្រាក់ក្នុងកំឡុងការិយបរិច្ឆេទនៃការធ្វើហិរញ្ញប្បទាន ដូចជាសម្ភារៈនិងការងារដោយប្រយោល។

### ថ្លៃដើមនៃការបំប្លែង

១៣.៨ ថ្លៃដើមបំប្លែងរបស់សន្និធិ រួមមានថ្លៃដើមដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងឯកតាផលិតកម្ម ដូចជាពលកម្មផ្ទាល់។ សន្និធិនោះគិតបញ្ចូលផងដែរនូវវិភាជន៍ចាប្រព័ន្ធនៃចំនាយផលិកម្មថេរនិងអថេរ ដែលបានកើតឡើង ក្នុងការបំប្លែងសម្ភារៈវត្ថុធាតដើមជាផលិផលសម្រេច។ ចំណាយផលិតកម្មថេរ គឺជាថ្លៃដើមផលិតកម្មដោយប្រយោលដែលមានលក្ខណៈមិនប្រែប្រួល ដោយមិនគិតពីទំហំនៃផលិតកម្ម ដូចជា ការកាត់រំលស់ និងការថែទាំអគារនិងសម្ភារៈរោងចក្រ ព្រមតាំងថ្លៃដើមនៃការគ្រប់គ្រងនិងរដ្ឋបាលរបស់រោងចក្រ។ ចំណាយផលិកម្មអថេរ គឺចាថៃដើមផលិតកម្មប្រយោលទាំងនោះ ដែលមានការប្រែប្រួលដោយផ្ទាល់ ឬស្ទើរតែផ្ទាល់ ជាមួយនឹងទំហំផលិតកម្ម ដូចជាសម្ភារៈវត្ថុធាតុដើមនិងពលកម្មមិនផ្ទាល់។

### វិភាជន៍នៃចំណាយផលិតកម្ម

១៣.៩ អង្គ ភាពត្រូវធ្វើវិភាជន៍ចំណាយផលិតកម្មថេរ ជាថ្លៃដើមបំប្លែងដោយផ្អែកលើមូលដ្ឋាននៃសមត្ថភាពជាធម្មតារបស់សម្ភារៈផលិតកម្ម។សមត្ថាពធម្មតាគឺជាផលិតកម្មដែលរំពឹងទុកថានឹងសម្រេចបានជាមធ្យមក្នុងការិបរិច្ឆេទ ឬរដូវកាលនានាក្រោមកាលៈទេសៈធម្មតា ដោយគិតបញ្ចូលទាំងការបាត់បង់សមត្ថភាពដែលបណ្តាលមកពីការថែរក្សាដែលបានគ្រោង។ កម្រិតផលិតកម្មជាក់ស្តែង អាចត្រូវបានប្រើប្រាស់ ប្រសិនបើវាប្រហាក់ប្រហែលនឹងសមត្ថភាពធម្មតា។ បរិមាណទឹកប្រាក់នៃចំណាយថេរដែលបានធ្វើវិភាជន៍ដល់ផ្នែកផលិតកម្មនិមួយៗ មិនមានការកើតឡើងដូចគ្នានោះទេ ដោយសារតែផលិតកម្មទាបឬរោងចក្រដែលមិនដើរនោះទេ។ចំណាយដែលមិនបានធ្វើវិភាជន៍ត្រូវបានទទួលស្គាល់ជាចំណាយនាការិយបរិច្ឆេទដែលចំណាយបានកើតឡើង។ ក្នុងកា រិយបរិច្ឆេទដែលផលិតកម្មមានកំណើនមិនធម្មតា បរិមាណទឹកប្រាក់នៃចំណាយថេរដែលបានធ្វើវិភាជន៍ដល់ផ្នែកផលិកម្មនីមួយៗត្រូវបានថយចុះ ដូចនេះសន្និធិមិនត្រូវបានវាស់វែងតាមថ្លៃដើមខាងលើនោះទេ។ចំណាយផលិតកម្មអថេរត្រូវបានធ្វើវិភាជន៍ដល់ផ្នែកនីមួយៗនៃផលិតកម្មដោយផ្អែកលើមូលដ្ឋាននៃការប្រើជាក់ស្តែងសម្ភារៈ។

### ផលិតផលបន្ទាប់បន្សំ និងអនុផល

១៣.១០ ដំណើរការផលិតកម្ម អាចមានផលិតផលលើសពីមួយត្រូវបានផលិតក្នុងពេលតែមួយ។ ឧទាហរណ៍ដូចជាករណីដែលថាផលិតផលបន្ទាប់បន្សំត្រូវបានផលិ ឬនៅពេលដែលមានផលិតផលចម្បងមួយនិងអនុផលមួយទៀត។ នៅពេលដែលថ្លៃដើមនៃវត្ថុធាតុដើម ឬនៃការបំប្លែងផលិផលនីមួយៗមិនអាចបែងចែកពីគ្នាឲ្យដាច់ អង្គភាពត្រូវធ្វើវិភាជន៍វត្ថុធាតុដើមនិងបំប្លែងទាំងនោះ រវាងផលិតផលដោយឈរលើមូលដ្ឋានមួយសមហេតុផល និងប្រាកដប្រជា។ ផ្អែកតាមប្រភេទរបស់វា អនុផលភាគច្រើនមិនសំខាន់ទេ។ នៅពេលមានករណីនេះ អង្គភាពត្រូវវាស់វែងនូវអនុផលទាំងនោះដោយយកថ្លៃលក់ ដកថ្លៃដើមផលិបង្ហើយនិងលក់ ហើយដកបរិមាណទឹកប្រាក់នេះពីថ្លៃដើមទំនិញចម្បង។ ជាលទ្ធផល តម្លៃពិតគណនេយ្យរបស់ផលិផលចម្បងមិនមានភាពខុសគ្នាខ្លាំងពីថ្លៃដើមរបស់វា។

### ថ្លៃដើមផ្សេងទៀតដែលបានបញ្ចូលក្នុងសន្និធិ

១៣.១១ អង្គភាពត្រូវគិតបញ្ចូលនូវថ្លៃដើមផ្សេងទៀតក្នុងថ្លៃដើមសន្និធិតែនៅពេលដែលថ្លៃដើមទាំងនោះបានកើតមាននៅក្នុងការនាំស្តុកទាំងនោះទៅដល់ទីតាំងទុកដាក់របស់វាពិ៌តបាកដ និងតាមលក្ខខណ្ឌរបស់វា។

១៣.១២ កថាខណ្ឌ១២.១៩(ខ)ចែងថា ក្នុងកាលៈទេសៈខ្លះ ការប្រែប្រួលនៃតម្លៃទីផ្សាររបស់ឧបករណ៍ទប់ស្កាត់ហានិភ័យក្នុងការទប់ស្កាត់ហានិភ័យអត្រាការប្រាក់ថេរ ឬហានិភ័យថ្លៃទំនិញនៃទំនិញមួយដែលធ្វើឡើងដើម្បីកែតម្រូវតម្លៃពិតគណនេយ្យនៃទំនិញនោះ។

### ថ្លៃដើមដែលត្រូវដកចេញពីសន្និធិ

១៣.១៣ ឧទាហរណ៍នៃថ្លៃដើមដែលត្រូវដកចេញពីថ្លៃដើមសន្និធិនិងត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយទាំងនោះបានកើតឡើង មាន ៖

(ក)បរិមាណទឹកប្រាក់មិនប្រក្រតីនៃសម្ភារៈដែលបានប្រើខ្ជះខ្ជាយ ពលកម្ម ឬថ្លៃដើមផលិកម្មផ្សេងទៀត។

(ខ)ថ្លៃដើមនៃការតម្កល់ទុក វាលែងតែថ្លៃដើមនោះមានសារៈសំខាន់ក្នុងកំឡុងពេលនៃដំណើការផលិតកម្មមុននឹងចាប់ផ្ដើមដំណាក់កាលផលិតកម្មបន្តទៀត។

(គ)ចំណាយរដ្ឋបាលបន្ទាប់បន្សំដែលមិនមែនជាចំណាយសម្រាប់នាំសន្និនិធិទាំនោះទៅកន្លែងរក្សារទុកដាក់របស់វាពិតប្រាកដ និងតាមលក្ខខណ្ឌរបស់វា។

(ឃ)ថ្លៃដើមលក់។

## ថ្លៃដើមសន្និធិសម្រាប់អ្នកផ្តល់សេវា

១៣.១៤ ក្នុងករណីដែលអ្នកផ្តល់សេវាមានសន្និធិ អ្នកនោះត្រូវវាស់វែងនូវសន្និធិទាំងនោះតាមតម្លៃដើមផលិតកម្មរបស់វា។ ជាបឋម ថ្លៃដើមនេះមានថ្លៃដើមពលកម្មនិងថ្លៃដើមចំណាយសម្រាប់បុគ្គលិកដែលជាប់ទាក់ទិនដោយផ្ទាល់ទៅនឹងការផ្តល់សេវា រួមទាំងបុគ្គលិកគ្រប់គ្រង និងចំណាយបន្ទាប់បន្សំចូលរួមផ្សេងទៀត។ ថ្លៃដើមពលកម្មនិងថ្លៃដើមផ្សេងទៀតសម្រាប់បុគ្គលិករដ្ឋបាលទូទៅ មិនត្រូវបានគិតបញ្ចូល ប៉ុន្តែត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលចំណាយនោះបានកើតឡើង។ ថ្លៃដើមនៃសន្និធិរបស់អ្នកផ្តល់សេវាកម្ម មិនរាប់បញ្ចូលអត្រាចំណេញ ឬចំណាយបន្ទាប់បន្សំពាក់ព័ន្ធផ្សេងទៀត ដែលតែងតែដាក់បញ្ចូលក្នុងថ្លៃយកដោយអ្នកផ្តល់សេវាកម្មនោះទេ។

## ថ្លៃដើមនៃផលិតផលកសិកម្មដែលប្រមូលពីទ្រព្យសកម្មជីវសាស្ត្រ

១៣.១៥ ផ្នែកទី៣៤ តម្រូវថាសន្និធិដែលមានផលិតផលកសិកម្មដែលអង្គភាពប្រមូលបានពីទ្រព្យសកម្មជីវសាស្ត្ររបស់ខ្លួនត្រូវតែបានវាស់វែងនាពេលទទួលស្គាល់លើកដំបូង តាមតម្លៃទីផ្សាររបស់វា ដកថ្លៃដើមលក់ប៉ាន់ស្មាននៅកន្លែងប្រមូលផល។ នេះក្លាយជាថ្លៃដើមនៃសន្និធិនាកាលបរិច្ឆេទនោះដើម្បីអនុវត្តផ្នែកនេះ។

ប ច្ចេកទេសសម្រាប់វាស់វែងថ្លៃដើម ដូចជា ការដាក់ថ្លៃដើមតាមបទដ្ឋាន វិធីសាស្ត្រលក់រាយ និងថ្លៃទិញថ្មីៗបំផុត

១៣.១៦ អង្គភាពអាចប្រើបច្ចេកទេសមួយចំនួន ដូចជា វិធីសាស្ត្រថ្លៃដើមបទដ្ឋាន វិធីសាស្ត្រលក់រាយឬថ្លៃទិញថ្មីៗបំផុតសម្រាប់វាស់វែងថ្លៃដើមសន្និធិ ប្រសិនបើលទ្ធផលប្រហាក់ប្រហែលថ្លៃដើម។ ថ្លៃដើមបទដ្ឋាន គិតបញ្ចូលនូវសម្ភារៈនិងវត្ថុក្នុងកម្រិតធម្មតា ពលកម្ម ប្រសិទ្ធ ភាពនិងសមត្ថភាពប្រើប្រាស់។ ប្រសិនបើចាំបាច់ ថ្លៃដើមទាំងនោះជាធម្មតាត្រូវពិនិត្យនិងកែតម្រូវឡើងវិញតាមលក្ខខណ្ឌជាក់ស្តែង។ វិធីសាស្ត្រលក់រាយ វាស់វែងថ្លៃដើមដោយកាត់បន្ថយតម្លៃលក់របស់សន្និធិតាមអត្រាភាគរយដុលសមរម្យមួយ។

## រូបមន្តថ្លៃដើម

១៣.១៧ អង្គភាពត្រូវវាស់វែងថ្លៃដើមសន្និធិនៃសន្និធិនានាដែលជាធម្មតាមិនអាចផ្លាស់ប្តូរគ្នាបាននិងទំនិញឬសេវាទាំងឡាយណាដែលបានផលិតនិងបំបែកដោយឡែកសម្រាប់គម្រោងពិសេសនានាដោយប្រើលក្ខណៈពិសេសនៃថ្លៃដើមរបស់វានីមួយៗ។

១៣.១៧ អង្គភាពត្រូវវាស់វែងថ្លៃដើមសន្និធិ លើកលែងតែវាបានកំណត់ដោយកថាខណ្ឌ ១៣.១៧ ដោយប្រើ វិធីសាស្ត្រចូលមុន-ចេញមុន(FIFO) ឬរូបមន្តថ្លៃដើមមធ្យមទម្ងន់។ អង្គ ភាពត្រូវប្រើរូបមន្តថ្លៃដើមដូចគ្នាដែរ ចំពោះសន្និធិទាំងឡាយណាដែលមានប្រភេទដូចគ្នា និងប្រើប្រាស់សម្រាប់អង្គ ភាព។ សម្រាប់សន្និធិដែលមានប្រភេទ ឬការប្រើប្រាស់ខុសគ្នា រូបមន្តថ្លៃដើមផ្សេងគ្នាអាចត្រូវបានកែតម្រូវ។ វិធីសាស្ត្រចូលក្រោយ-ចេញមុន (LIFO) មិនត្រូវបានអនុញ្ញាតដោយស្តង់ដារនេះទេ។

## ការថយចុះតម្លៃនៃសន្និធិ

១៣.១៩ កថាខណ្ឌ ២៧.២-២៧.៤ តម្រូវឲ្យអង្គភាពវាយតម្លៃនាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗថាតើមានសន្និធិដែលបានថយចុះតម្លៃដែរឬទេ មានន័យថា តម្លៃពិតគណនេយ្យមិនត្រូវបានស្តាឡើងវិញទាំងស្រុងបាន (មានន័យថា ដោយសារតែខូច ភាពហួសសម័យ ឬថ្លៃលក់ធ្លាក់ចុះ)។ ប្រសិនបើសមាសធាតុមួយ (ឬសមាសធាតុមួយក្រុម)នៃសន្និធិត្រូវបានថយចុះតម្លៃ កថាខណ្ឌទាំងនោះតម្រូវឲ្យអង្គផាពវាស់វែងសន្និធិដោយយលថ្លៃលក់វាដកថ្លៃដើមសម្រេចនិងលក់ ហើយត្រូវទទួលស្គាល់ថាជាការខាតបង់ដោយសារការថយចុះតម្លៃ។កថាខណ្ឌទាំងនោះ ក៏តម្រូវឲ្យបង្វិលត្រឡប់នូវការថយចុះតម្លៃមុនៗនោះក្នុងករណីខ្លះ។

## ការទទួលស្គាល់ថាជាចំណាយ

១៣.២០ នៅពេលដែលសន្និធិត្រូវបានលក់ អង្គភាពត្រូវទទួលស្គាល់នូវតម្លៃពិតគណនេយ្យរបស់សន្និធិទាំងនោះថាជាចំណាយក្នុងការិយបរិច្ឆេទ ដែលពេលនោះសំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់។

១៣.២១ សន្និខ្លះអាចត្រូវបានធ្វើវិភាជន៍ទៅគណនីយទ្រព្យសកម្មដទៃទៀត ឧទាហរណ៍ សន្និធិដែលបានប្រើប្រាស់ជាសមាសធាតុមួយនៃទ្រព្យ រោងចក្រនិងបរិក្ខាដែលបានសាងសង់។ សន្និធិដែលបានធ្វើវិភាជន៍ដល់ទ្រព្យសកម្មផ្សេងទៀត ដូចនេះត្រូវតែគិតបញ្ចូលជាបន្តបន្ទាប់ ស្របតាមផ្នែកពាក់ព័ន្ធទៅនឹងប្រភេទនៃទ្រព្យសកម្មនៃស្តង់ដានេះ។

## ការលាតត្រដាងព័ត៏មាន

១៣.២២ អង្គភាពត្រូវលាតត្រដាងព័តិមានដូចខាងក្រោម ៖

(ក) គោលនយោបាយគណនេយ ដែលមានអនុម័តក្នុងការវាស់វែងសន្និធិ រួមទាំងរូបមន្តថ្លៃដើមដែលបានប្រើ។

(ខ) តម្លៃពិតគណនេយ្យសរុបនៃសន្និធិ និងតម្លៃពិតគណនេយ្យក្នុងការធ្វើចំណាត់ថ្នាក់នានាដែលមានលក្ខណៈសមស្របចំពោះអង្គភាព។

(គ) បរិមាណនៃសន្និធិដែលបានទទួលស្គាល់ជាចំណាយក្នុងកំឡុងនៃការិយបរិច្ឆេទ។

(ឃ) ការខាតបង់ដោយការថយចុះតម្លៃដែលបានទទួលស្គាល់ ឬដែលបានបង្វិលត្រឡប់ក្នុងចំណេញឬខាតស្របតាមផ្នែកទី ២៧។

(ង) តម្លៃពិតគណនេយ្យរបស់សន្និធិដែលបានសន្យាដាក់ធានាបំណុល។

## ផ្នែកទី ១៤
## វិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

### វិសាលភាពនៃស្តង់ដារនេះ

១៤.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មសម្រាប់ ក្រុមហ៊ុនញាតិសម្ព័ន្ធ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់វិនិយោគិន ដែលមិនជាក្រុមហ៊ុនមេ ប៉ុន្តែមានវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមួយឬច្រើន។ កថាខណ្ឌ ៩.២៦ បង្កើតនូវតម្រូវការមួយចំនួនសម្រាប់ធ្វើគណនេយ្យកម្មនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក។

### ការឲ្យនិយមន័យលើក្រុមហ៊ុនញាតិសម្ព័ន្ធ

១៤.២ ក្រុមហ៊ុនញាតិសម្ព័ន្ធគឺជាអង្គភាពមួយរួមបញ្ចូលទាំងអង្គភាពដែលមិនបានរួមបញ្ចូលគ្នា ដូចជា ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលវិនិយោគិនមានឥទ្ធិពលខ្លាំងលើអង្គភាពនេះ ហើយដែលមិនមែនជា ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងមិនមានភាគកម្មនៅក្នុង ក្រុមហ៊ុនរួមទុន ។

១៤.៣ ឥទ្ធិ លខ្លាំងគឺ ជាអំណាចក្នុងការចូលរួមក្នុងការសម្រេចលើគោលនយោបាយប្រតិបត្តិការនិងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ប៉ុន្តែមិនមែនជាការត្រួតពិនិត្យឬការត្រួតពិនិត្យរួមគ្នាលើគោលនយោបាយទាំងអស់នោះទេ។

(ក) ប្រសិនបើវិនិយោគិនកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលនូវអំណាចបោះឆ្នោត២០% ឬលើសពីនេះនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វាត្រូវបានសន្មត់ថាវិនិយោគិនមានឥទ្ធិពលខ្លាំងហើយ លើកលែងតែអំណាចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាករណីនេះមិនអាចមាន។

(ខ) ផ្ទុយមកវិញ ប្រសិនបើវិនិយោគិនកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលនូវអំណាចបោះឆ្នោតតិចជាង ២០% ក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វាត្រូវបានសន្មត់ថាវិនិយោគិនមិនមានឥទ្ធិពលខ្លាំងហើយ លើកលែងតែអំណាចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាករណីនេះមិនអាចមាន។

(គ) ភាពជាកម្មសិទ្ធក្នុងចំណែកភាគច្រើនដោយវិនិយោគិនផ្សេងទៀត មិនត្រូវប្រានចោលនូវឥទ្ធិពលខ្លាំងពីវិនិយោគិននោះទេ។

### ការវាស់វែង--ការជ្រើសយកគោលនយោបាយគណនេយ្យ

១៤.៤ វិនិយោគិនត្រូវគិតបញ្ចូលនូវវិនិយោគរបស់ខ្លួនទាំងអស់នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដោយប្រើម៉ូដែលដូចតទៅ ÷

(ក) ម៉ូដែលថ្លៃដើម ក្នុងកថាខណ្ឌ ១៤.៥។

(ខ) ម៉ូដែលមូលធនផ្ទាល់ ក្នុងកថាខណ្ឌ ១៤.៨។

(គ) ម៉ូដែលតម្លៃទីផ្សារ ក្នុងកថាខណ្ឌ ១៤.៩។

**ម៉ូដែលថ្លៃដើម**

១៤.៥ វិនិយោគិនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វាលែងតែវិនិយោគទុននោះមានតារាងតម្លៃដែលបានបោះផ្សាយរួច (សូមមើលកថាខណ្ឌ ១៤.៧) ដោយយកថ្លៃដើម ដកការខាតបង់ដោយការថយចុះតម្លៃប្ញូកយោងពីមុនមក ដែលបានទទួលស្គាល់ ស្របតាមផ្នែកទី ២៧ ស្តីពី ការថយចុះតម្លៃនៃទ្រព្យសកម្ម។

១៤.៦ វិនិយោគិនត្រូវទទួលស្គាល់ថាជាចំណូលនូវរាល់ភាគលាភនិងវិភាគទានផ្សេងទៀតដែលទទួលបានពីការវិនិយោគ ដោយមិនចាំបាចលគិតថាវិភាគទាននោះ បានមកពីប្រាក់ចំណេញប្ញូកយោងរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលកើតមានមុន ឬក្រោយកាលបរិច្ឆេទទួលបាននោះទេ។

១៤.៧ វិនិយោគិនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលវិនិយោគទុននោះមានបោះផ្សាយតារាងតម្លៃដោយប្រើម៉ូដែលតម្លៃទីផ្សារ (សូមមើល កថាខណ្ឌ ១៤.៩)។

**វិធីសាស្រ្តមូលធនផ្ទាល់**

១៤.៨ តាមវិធីសាស្រ្តមូលធនផ្ទាល់នៃការធ្វើគណនេយ្យកម្ម វិនិយោគលើមូលធនផ្ទាល់ត្រូវបានទទួលស្គាល់ជាបឋមតាមថ្លៃប្រតិបត្តិការ (រួមបញ្ចូលទាំងថ្លៃដើមប្រតិបត្តិការ) និងត្រូវបានធ្វើការកែតម្រូវជាបន្តបន្ទាប់ ដើម្បីបង្ហាញនូវភាគកម្មរបស់វិនិយោគិនលើចំណេញឬខាតនិងអំពីរបាយការណ៍ចំណូលផ្សេងៗទៀតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ។

(ក) វិភាគទាន និងការកែតម្រូវផ្សេងទៀតលើតម្លៃពិតគណនេយ្យ ។ វិភាគទានដែលទទួលបានពីក្រុមហ៊ុនញាតិសម្ព័ន្ធកាត់បន្ថយតម្លៃទិតគណនេយ្យរបស់វិនិយោគទុន។ ការកែតម្រូវនានាលើតម្លៃពិតគណនេយ្យ ក៏អាចតម្រូវឲ្យថាជាវិបាកមួយនៃការប្រែប្រួលលើមូលធនផ្ទាល់របស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលកើតមកពីធាតុនានានៃចំណូលបន្ទាប់បន្សំផ្សេងទៀត។

(ខ) សិទ្ធិបោះឆ្នោតសក្តានុពល។ ទោះបីជាសិទ្ធិបោះឆ្នោតសក្តានុពល ត្រូវបានយកមកពិចារណាដើម្បីសម្រេចថាតើឥទ្ធិភលខ្លាំងមានឬអត់នោះ វិនិយោគិនត្រូវវាស់វែងនូវភាគកម្មរបស់ខ្លួននៅក្នុងចំណេញ ឬខាតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ព្រមទាំងចំណែកនៃការប្រែប្រួលនានាទៅលើមូលធនផ្ទាល់របស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដោយផ្អែកលើមូលដ្ឋាននៃភាគកម្មកម្មសិទ្ធិជាក់ស្តែង៕ការវាស់វែងទាំងនោះមិនបង្ហាញនូវការអនុវត្ត ឬការបំប្លែងដែលអាចកើតមាននៃសិទ្ធិបោះឆ្នោតសក្តានុពល។

(គ) មូលនិធិពាណិជ្ជកម្មវាទរហិត (មិនច្បាស់លាស់) និងការកែតម្រូវលើតម្លៃទីផ្សារ ។ក្នុងការទទួលបានវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វិនិយោគិនត្រូវគិតបញ្ចូលនូវភាពខុសគ្នា (តោះបីជាវិជ្ជមាន ឬអវិជ្ជមាន) រវាងថ្លៃដើមក្នុងការទទួលបានវិនិយោគ និងភាគកម្មរបស់វិនិយោគិននៃតម្លៃទីផ្សារនៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់បានរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ស្របតាមកថាខណ្ឌ ១៩.២២-១៩.២៤។ វិនិយោគិន ត្រូវកែតម្រូវភាគកម្ម

នៃចំណេញឬខាតរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ បន្ទាប់ពីបានទទួល ដើម្បីគិតដកវិលស់បន្ថែមលើទ្រព្យសកម្មដែលអាចរំលស់បានរបស់ក្រុមហ៊ុននេះ(រួមបញ្ចូលទាំងមូលនិធិពាណិជ្ជកម្មផង) ដោយផ្អែកលើមូលដ្ឋាននៃភាពលើសនៃតម្លៃទីផ្សារលើតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្មនោះ នាពេលដែលវិនិយោគត្រូវបានទទួល។

(ឃ)ការថយចុះតម្លៃ។ ប្រសិនបើមានការចង្អុលបង្ហាញថាវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធអាចត្រូវបានថយចុះតម្លៃ វិនិយោគិនត្រូវធ្វើតេស្តទៅលើតម្លៃពិតគណនេយ្យនៃវិនិយោគទុននោះសម្រាប់ការថយចុះតម្លៃស្របតាមផ្នែកទី២៧ ថាជាទ្រព្យសកម្មតែមួយ។ មូលនិធិពាណិជ្ជកម្មណាដែលបានបញ្ចូលជាផ្នែកមួយនៃតម្លៃពិតគណនេយ្យនៃវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធមិនត្រូវធ្វើតេស្តដាច់ដោយឡែកសម្រាប់ការថយចុះតម្លៃនោះទេ ប៉ុន្តែត្រូវបញ្ចូលជាការធ្វើតេស្តសម្រាប់ការថយចុះតម្លៃនៃវិនិយោគទុនទាំងមូល។

(ង)ប្រតិបត្តិការរបស់អ្នកវិនិយោគជាមួយក្រុមហ៊ុនញាតិសម្ព័ន្ធ។ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធមួយយកវិធីសាស្ត្រមូលធនផ្ទាល់មកប្រើប្រាស់ វិនិយោគិនត្រូវ បំបាត់ចោលនូវចំណេញនិងខាតដែលមិនទទួលស្គាល់តាំងពីដើមទីនៃប្រតិបត្តិការ(ក្រុមហ៊ុនពាតិសម្ពន្ធ័ទៅនឹងវិនិយោគិន)និងនៅចុងបញ្ចប់នៃប្រតិបត្តិការ(ពីវិនិយោគិនទៅក្រហ៊ុនពាតិសម្ពន្ធ័)ទៅតាមកម្រិតភាគកម្មរបស់វិនិយោគិននៅក្នុងក្រុមហ៊ុនញាតិសម្ពន្ធ័។ការខាតបង់មិនបានទទួលស្គាល់ពាក់ពន្ធ័នឹងប្រតិបត្តិការបែបនេះអាចផ្តល់ជាភស្តុតាងនៃការថយចុះតម្លៃនៃទ្រព្យសកម្មបានផ្ទេរ។

(ច)កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។ ក្នុងការអនុវត្តវិធីសាស្ត្រមូលធនផ្ទាល់ វិនិយោគិនត្រូវប្រើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ នាកាលបរិច្ឆេទដូចគ្នាជាមួយកាលបរិច្ឆេទរបស់ខ្លួន លើកលែងតែ ការអនុវត្តមិនត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នោះ។ប្រសិនបើមិនអាចអនុវត្តបាន វិនិយោគិនត្រូវប្រើរបាយការណ៍ហិរញ្ញវត្ថុថ្មីៗដែលអាចធ្វើទៅបានរបស់ក្រុមហ៊ុននេះជាមួយការកែតម្រូវនានាដែលត្រូវបានធ្វើឡើងដោយឥទ្ធិពលនៃប្រតិបត្តិការចម្បងឬនៃព្រឹត្តិការណ៍ដែលបានកើតឡើងរវាងចុងការិយបរិច្ឆេទគណនេយ្យ។

(ឆ)គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ។ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធគោលនយោបាយគណនេយ្យដែលខុសពីកោលនយោបាយគណនេយ្យរបស់វិនិយោគិន វិនិយោគិនត្រូវកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនញាតិសម្ព័ន្ធ ដើម្បីបង្ហាញអំពីគោលនយោបាយគណនេយ្យរបស់វិនិយោគិនក្នុងគោលបំណងអនុវត្តវិធីសាស្ត្រមូលធនផ្ទាល់ លើកលែងតែការអនុវត្តមិនអាចធ្វើដូចនេះបាន។

(ជ)ការខាតបង់នៃវិនិយោគទុនលើស។ប្រសិនបើចំណែកនៃការខាតបង់របស់វិនិយោគិនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធស្មើឬលើសតម្លៃក្នុងបញ្ជីនៃវិនិយយោគទុនរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ វិនិយោគិនមិនត្រូវបន្តទទួលស្គាល់ចំណែកនៃការខាតបង់របស់ខ្លួនបន្ថែមទៀតទេ។បន្ទាប់ពីភាគកម្មរបស់វិនិយោគិនត្រូវបានកាត់បន្ថយរហូតដល់សូន្យ វិនិយោគិនត្រូវទទួលស្គាល់ការខាតបង់បន្ថែមដោយសំវិធានធន (សូមមើលផ្នែកទី ២១ ស្តីពីសំវិធានធននិងយថាភាព) តែករណីដែលវិនិយោគិនបានបង្កើតឲ្យមានកាតព្វកិច្ចនីត្យានុកូល ឬកាតព្វកិច្ច

ស្ថាបនា ឬបានធ្វើការទូទាត់ ក្នុងនាមវិនិយោគិន។ ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធរាយការណ៍អំពីប្រាក់ចំណេញជាបន្តបន្ទាប់ នោះវិនិយោគិនត្រូវសន្មត់ទទួលស្គាល់ចំណែកនៃប្រាក់ចំណេញរបស់ខ្លួនក្នុងប្រាក់ចំណេញនោះ តែបន្ទាប់ពីចំណែកនៃប្រាក់ចំណេញរបស់ខ្លួនស្មើនឹងចំណែកនៃការខាតបង់ដែលមិនបានទទួលស្គាល់។

(ឈ) ការមិនបន្តវិធីសាស្ត្រមូលធនផ្ទាល់។ វិនិយោគិនត្រូវបញ្ឈប់ការប្រើប្រាស់វិធីសាស្ត្រមូលធនផ្ទាល់ចាប់ពីពេលដែលឥទ្ធិពលចម្បងបានបញ្ចប់។

១- ប្រសិនបើក្រុមហ៊ុនញាតិសម្ព័ន្ធ ប្រែក្លាយទៅជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន វិនិយោគិនត្រូវធ្វើការវាស់វែងឡើងវិញនូវភាគកម្មលើមូលធនផ្ទាល់ដែលមានពីមុនទៅរកតម្លៃទីផ្សារ និងត្រូវទទួលស្គាល់លទ្ធផលចំណេញឬខាតនៅក្នុងចំណេញ ឬខាត ប្រសិនបើមាន។

២- ប្រសិនបើវិនិយោគិនបាត់ឥទ្ធិពលចម្បងលើក្រុមហ៊ុនញាតិសម្ព័ន្ធ ដោយសារតែគេលកលចោលនូវវិនិយោគទុនរបស់ខ្លួនមួយផ្នែក ឬទាំងស្រុង នោះវិនិយោគិនត្រូវឈប់ទទួលស្គាល់នូវក្រុមហ៊ុននេះ ហើយម្យ៉ាងទៀតត្រូវទទួលស្គាល់នៅក្នុងចំណេញឬខាតនូវភាពខុសគ្នារវាងចំនួននៃចំណូលដែលទទួលបានបូករួមជាមួយនឹងតម្លៃទីផ្សារនៃភាគកម្មដែលរក្សាទុក និងម្យ៉ាងវិញទៀត ត្រូវទទួលស្គាល់នូវតម្លៃក្នុងបញ្ជីនៃវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនាកាលបរិច្ឆេទដែលឥទ្ធិពលនោះត្រូវបានបាត់បង់។ ក្រោយពីពេលនោះមក វិនិយោគិនត្រូវគិតបញ្ចូលនូវរាល់ភាគកម្មដែលបានរក្សាទុក ដោយប្រើផ្នែកទី១១ ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី ១២ស្តីពីការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ប្រសិនបើ ត្រឹមត្រូវ។

៣- ប្រសិនបើវិនិយោគិនបាត់បង់នូវឥទ្ធិពលដោយមកពីហេតុផលផ្សេង ក្រៅពីការលក់ចោលមួយផ្នែកនៃវិនិយោគទុនរបស់ខ្លួននោះ គាត់ត្រូវចាត់ទុកតម្លៃក្នុងបញ្ជីនៃវិនិយោគទុននាកាលបរិច្ឆេទនោះ ថាជាមូលដ្ឋានថ្លៃដើមថ្មី និងត្រូវគិតបញ្ចូលវិនិយោគទុនដោយប្រើផ្នែទី ១១ និងទី ១២ ប្រសិនបើត្រឹមត្រូវ។

### ម៉ូដែលតម្លៃទីផ្សារ

១៤.៩ នៅពេលដែលវិនិយោគមួយនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធត្រូវបានទទួលស្គាល់ជាដំបូង វិនិយោគិនត្រូវវាស់វែងវាតាមថ្លៃប្រតិបត្តិការ។ថ្លៃប្រតិបត្តិការមិនរាប់បញ្ចូលថ្លៃដើមប្រតិបត្តិការ។

១៤.១០ នាកាលបរិច្ឆេទរាយការណ៍នីមួយៗ វិនិយោគិនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធតាមតម្លៃទីផ្សារ ដោយគិតការប្រែប្រួលនៃតម្លៃទីផ្សារនេះដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើប្រាស់នូវគោលការណ៍វាយតម្លៃសមស្របមួយតាមកថាខណ្ឌ ១១.២៧-១១.៣២។ វិនិយោគិនដែលប្រើម៉ូដែលតម្លៃទីផ្សារ ត្រូវប្រើម៉ូដែលថ្លៃដើមសម្រាប់វិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ពេលវិនិយោគទុននេះមិនអាចវាស់តម្លៃតម្លៃទីផ្សារគួរឲ្យទុកចិត្ត ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

## ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

១៤.១១ វិនិយោគិនត្រូវចាត់ថ្នាក់វិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធថាជាទ្រព្យសកម្មរយៈពេលវែង។

## ការលាតត្រដាងព័ត៌មាន

១៤.១២ វិនិយោគិនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោម ÷

(ក) គោលនយោបាយគណនេយ្យ របស់ខ្លួនចំពោះវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ។

(ខ) តម្លៃក្នុងបញ្ជី នៃវិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ (សូមមើល កថាខណ្ឌ ៤.២ (ញ))។

(គ) តម្លៃទីផ្សារនៃវិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ដែលបានគិតគូរដោយប្រើវិធីសាស្ត្រមូលធនផ្ទាល់ ដែលមានតារាងថ្លៃបានបោះផ្សាយ។

១៤.១៣ ចំពោះវិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលបានគិតតាមម៉ូដែលថ្លៃដើម វិនិយោគិនត្រូវលាតត្រដាង នូវបរិមាណនៃភាគលាភនិងវិភាគទានផ្សេងតែៀតដែលត្រូវបានទទួលស្គាល់ថាជាចំណូល។

១៤.១៤ចំពោះវិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលបានគិតតាមម៉ូដែលមូលធនផ្ទាល់វិនិយោគិនត្រូវលាតត្រដាង ដាច់ដោយឡែកពីគ្នាអំពីចំណែកនៃប្រាក់ចំណេញ ឬខាតរបស់ខ្លួននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធនោះ ព្រមទាំង ចំណែកនៃប្រតិបត្តិការមិនបន្ត របស់ខ្លួននៅក្នុងក្រុមហ៊ុននេះផងដែរ។

១៤.១៥ ចំពោះវិនិយោគទុនក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធដែលបានគិតតាមម៉ូដែលតម្លៃទីផ្សារ វិនិយោគិនត្រូវលាតត្រដាង នូវព័ត៌មាននានាដែលតម្រូវដោយកថាខណ្ឌ ១១.៤១-១១.៤៤។

# ផ្នែកទី ១៥
## ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន

### វិសាលភាពនៃផ្នែកនេះ

១៥.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មនូវការរួមទុន ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់វិនិយោគិនដែលមិនមែនជាក្រុមហ៊ុនមេ ប៉ុន្តែដែលមានភាគកម្មរបស់អ្នករួមទុន នៅក្នុងក្រុមហ៊ុនរួមទុនមួយឬច្រើន។ កថាខណ្ឌ ៩.២៦ បង្កើតនូវលក្ខខណ្ឌតម្រូវនានាសម្រាប់ធ្វើគណនេយ្យកម្មនូវ ភាគកម្មរបស់អ្នករួមទុននៅក្នុងការរួមទុននៅក្នុង របាយការណ៍ហិរញ្ញវត្ថុដោយឡែក ។

### ការកំណត់និយមន័យការរួមទុន

១៥.២ ការត្រួតពិនិត្យរួមគ្នាគឺជាចែកគ្នាការត្រួតពិនិត្យដែលបានព្រមព្រៀងតាមកិច្ចសន្យាលើសកម្មភាពសេដ្ឋកិច្ចអ្វីមួយ ហើយវាកើតមានតែនៅពេលដែលសេចក្តីសម្រេចផ្នែកហិរញ្ញវត្ថុនិងប្រតិបត្តិការជាយុទ្ធសាស្ត្រទាក់ទិនទៅនឹងសកម្មភាពដែលតម្រូវឲ្យមានការព្រមព្រៀងជាឯកច្ឆ័ន្ទរបស់ភាគីដែលចែករំលែកការត្រួតពិនិត្យ (អ្នករួមទុន)។

១៥.៣ ការរួមទុនគឺជាកិច្ចសន្យាមួយដែលធ្វើឡើងដោយភាគីពីរនាក់ ឬច្រើននាក់ ក្នុងការធ្វើសកម្មភាពសេដ្ឋកិច្ចអ្វីមួយដែលជាកម្មវត្ថុនៃការត្រួតពិនិត្យរួម។ការរួមទុនអាចមានទម្រង់ជាប្រតិបត្តិការត្រួពិនិត្យរួមគ្នា ទ្រព្យសកម្ម ដែលមានការត្រួតពិនិត្យរួមគ្នា ឬជា អង្គភាពត្រួតពិនិត្យរួមគ្នា ។

### ប្រតិបត្តិការដែលបានត្រួតពិនិត្យរួមគ្នា

១៥.៤ ប្រតិបត្តិការរបស់ក្រុមហ៊ុនរួមទុនមួយចំនួន ពាក់ព័ន្ធនឹងការប្រេប្រាស់ទ្រព្យសកម្មនិងធនធានផ្សេងទៀត របស់អ្នករួមទុនជាជាងគាត់ទៅបង្កើតសាជីវកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គ ភាពផ្សេងទៀតឬពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធហិរញ្ញវត្ថុដែលដាច់ចេញពីអ្នករួមទុនខ្លួនឯង។ អ្នករួមទុននីមួយៗ ប្រើទ្រព្យ រោងចក និងសម្ភារៈរបស់ខ្លួនផ្ទាល់ ព្រមទាំងកាន់កាប់សន្និធិផ្ទាល់របស់ខ្លួន។ វាក៏ត្រូវរ៉ាប់រងចំណាយនិងបំណុលផ្ទាល់ខ្លួនរបស់ខ្លួនផងដែរ និងវាបង្កើតបានជាហិរញ្ញវត្ថុផ្ទាល់របស់ខ្លួនដែលតំណាងឲ្យកាតព្វកិច្ចរបស់គាត់។សកម្មភាពរបស់ក្រុមហ៊ុនរួមទុនអាចធ្វើឡើងដោយបុគ្គលិករបស់អ្នករួមទុនដែលអមដោយសកម្មភាពប្រហាក់ប្រហែលរបស់អ្នករួមទុន។ កិច្ចសន្យាដាក់ទុនរួមគ្នា តែងតែផ្តល់នូវមធ្យោបាយដែលតាមមធ្យោបាយនេះចំណូលពីការលក់នូវផលិតផលរួម ព្រមទាំងចំណាយដែលបានកើតមានឡើងជារួមត្រូវបានចែករំលែករវាងអ្នកដាក់ទុនរួមគ្នា។

១៥.៥ ចំពោះភាគកម្មរបស់អ្នករួមទុនក្នុងប្រតិបត្តិការត្រួតពិនិត្យរួមគ្នា អ្នករួមទុនត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននូវ ÷

(ក) ទ្រព្យសកម្មដែលអ្នករួមទុនត្រួតពិនិត្យ និងបំណុលដែលអ្នករួមទុនបង្កើតឡើង និង

(ខ) ចំណាយដែលអ្នករួមទុនបង្កើតឡើងនិងចំណែកនៃចំណូលដែលអ្នករួមទុនទទួលបានពីការលក់ទំនិញនិងសេវាដោយក្រុមហ៊ុនរួមទុន។

## ទ្រព្យសកម្មដែលបានត្រួតពិនិត្យរួមគ្នា

១៥.៦ ការរួមទុនមួយចំនួនពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យរួមគ្នាដោយអ្នករួមទុនលើទ្រព្យសកម្មមួយឬច្រើនដែលបានផ្តល់ទៅឲ្យនិងទទួលបានសម្រាប់ក្រុមហ៊ុនរួមទុន ហើយតែងតែមានកម្មសិទ្ធរួមគ្នាលើទ្រព្យសកម្មនោះ ហើយទ្រព្យនោះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងរួមទុន។

១៥.៧ ចំពោះភាគកម្មរបស់ខ្លួននៅក្នុងទ្រព្យសកម្មដែលត្រូវត្រួតពិនិត្យរួមគ្នាអ្នករួមទុនត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួននូវ ÷

(ក) ចំណែករបស់ខ្លួននៅក្នុងទ្រព្យសកម្មដែលត្រូបត្រួតពិនិត្យរួមគ្នាដែលបានចាត់ថ្នាក់ស្របតាមប្រភេទនៃទ្រព្យសកម្ម

(ខ) បំណុលនានាដែលបានកើតឡើង

(គ) បំណុលនានាដែលបានកើតឡើងរួមគ្នាជាមួយអ្នករួមទុនដទៃទៀត ទាក់ទិននឹងការរួមទុន

(ឃ) ចំណូលនានាដែលបានមកពីការលក់ ឬការប្រើប្រាស់នូវចំណែកលទ្ធផលនៃការរួមទុន ជាមួយនឹងចំណែកនៃចំណាយដែលបានកើតឡើងក្នុងការរួមទុន និង

(ង) ចំណាយនានាដែលបានកើតឡើងដោយសារតែភាគកម្មរបស់ខ្លួននៅក្នុងការរួមទុន។

## អង្គភាពដែលត្រួតពិនិត្យរួមគ្នា

១៥.៨ អង្គភាពត្រួតពិនិត្យរួមគ្នាគឺជាការរួមទុនមួយដែលទាក់ទិនទៅនឹងការបង្កើតក្រុមហ៊ុនសាជីវកម្មក្រុមហ៊ុនសហកម្មសិទ្ធិ ឬអង្គភាពផ្សេងទៀត ដែលអ្នករួមទុនមានភាគកម្មរបស់ខ្លួន។ អង្គភាពប្រតិបត្តិការដូច អង្គភាព ដទៃទៀតដែរ វាលែងតែ ខនៃកិច្ចសន្យារវាងអ្នករួមទុនបង្កើតឡើងនូវការត្រួតពិនិត្យរួមគ្នាលើសកម្មភាពសេដ្ឋកិច្ចរបស់អង្គភាព។

### ការវាស់វែង - ការជ្រើសរើសគោលនយោបាយគណនេយ្យ

១៥.៩ អ្នករួមទុនត្រូវគិតគូរនូវជាគកម្មរបស់ខ្លួននៅក្នុងអង្គភាពត្រួតពិនិត្យរួមគ្នា ដោយប្រើម៉ូដែលណាមួយដូចខាងក្រោម ÷

(ក) ម៉ូដែលថ្លៃដើម ក្នុងកថាខណ្ឌ ១៥.១០

(ខ) ម៉ូដែលមូលធនផ្ទាល់ ក្នុងកថាខណ្ឌ ១៥.១៣

(គ)ម៉ូដែលតម្លៃទីផ្សារ ក្នុងកថាខណ្ឌ ១៥.១៤

## ម៉ូដែលថ្លៃដើម

១៥.១០ អ្នករួមទុន ត្រូវវាស់វែងនូវវិនិយោគទុនរបស់ខ្លួននៅក្នុងអង្គផាពត្រួតពិនិត្យរួមគ្នា លើកលែងតែវិនិយោគទុននោះមានតារាងតម្លៃដែលត្រូវបានបោះផ្សាយរួចហើយ (មើល កថាខណ្ឌ ១៥.១២)ដោយយកថ្លៃដើម ដកការខាតបង់ដោយការថយចុះតម្លៃដែលបានទទួលស្គាល់តាមផ្នែកទី ២៧ ស្តីពី ការថយចុះតម្លៃទ្រព្យសកម្ម ។

១៥.១១ វិនិយោគិន ត្រូវទទួលស្គាល់នូវវិភាគទាននានាដែលទទួលបានពីវិនិយោគទុនថាជាចណ្ណូល ដោយមិនគិតពីថាតើវិភាគទានទាំងនោះបានមកពីប្រាក់ចំណេញដែលបានបូកយោងរបស់អង្គភាពត្រួតពិនិត្យរួមគ្នា ដែលបានកើតឡើងមុន ឬក្រោយកាលបរិច្ឆេទទទួលបាន។

១៥.១២ អ្នករួមទុនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួនក្នុងអង្គភាពត្រួតពិនិត្យរួមគ្នា ដែលវិនិយោគទុននោះមានតារាងថ្លៃដែលបានបោះផ្សាយដោយប្រើតម្លៃទីផ្សារ(សូមមើលកថាខណ្ឌទី ១៥.១៤)។

## វិធីសាស្ត្រមូលធនផ្ទាល់

១៥.១៣អ្នករួមទុនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួននៅក្នុងអង្គភាពត្រួតពិនិត្យរួមគ្នាតាមរយៈវិធីសាស្ត្រមូលធនផ្ទាល់ដោយប្រើនីតិវិធីនានានានៅក្នុងកាថាខណ្ឌ១៤.៨ (ដែលជំនួសដោយពាក្យ "ការត្រួតពិនិត្យរួមគ្នា" ដែលកថាខណ្ឌនោះសំដៅដល់ "ឥទ្ធិ លខ្លាំង" )។

## ម៉ូដែលតម្លៃទីផ្សារ

១៥.១៤ នៅពេលដែលវិនិយោគទុននៅក្នុងអង្គផាពត្រួតពិនិត្យរួមគ្នាត្រូវបានទទួលស្គាល់ជាដំបូង អ្នករួមទុនត្រូវវាស់វែងវិនិយោគទុននោះតាមថ្លៃប្រតិបត្តិការ។ ថ្លៃប្រតិបត្តិការ មិនរាប់បញ្ចូលថ្លៃដើមប្រតិបត្តិការទេ។

១៥.១៥ នាកាលបរិច្ឆេទរាយការណ៍ អ្នករួមទុនត្រូវវាស់វែងវិនិយោគទុនរបស់ខ្លួនក្នុងអង្គភាពត្រួតពិនិត្យរួមគ្នាតាមតម្លៃទីផ្សារស្របតាមការប្រែប្រួលតម្លៃទីផ្សារក្នុងចំណេញឬខាត ដោយប្រើគោលការណ៍ណែនាំស្តីពីការវាយតម្លៃក្នុងកថាខណ្ឌទី១១.២៧-១១.៣២។អ្នករួមទុនដែលប្រើម៉ូដែលថ្លៃទីផ្សារ ត្រូវប្រើម៉ូដែលថ្លៃដើមសម្រាប់វិនិយោគទុនក្នុងអង្គភាពត្រួតពិនិត្យរួមគ្នា ដែលវិនិយោគទុននោះមិនអាចវាស់វែងវាតាមតម្លៃទីផ្សារគួរឲ្យទុកចិត្តបានដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

## ប្រតិបត្តិការរវាងអ្នករួមទុន និងក្រុមហ៊ុនរួមទុន

១៥.១៦ នៅពេលដែលអ្នករួមទុនផ្តល់ឬលក់ទ្រព្យសកម្មដល់ក្រុមហ៊ុនរួមទុន ការទទួលស្គាល់នូវផ្នែកណាមួយនៃចំណេញឬខាតពីប្រតិបត្តិការត្រូវបង្ហាញនូវសារជាតិរបស់ប្រតិបត្តិការនោះ។ នៅពេលដែលទ្រព្យសកម្មត្រូវបានកាន់កាប់ដោយក្រុមហ៊ុនរួមទុននិងត្រូវបានផ្តល់ដល់អ្នករួមទុន ហើយអ្នករួមទុនបានផ្ទេរហានិភ័យនិងប្រយោជន៍ចម្បងលើកម្មសិទ្ធិ នោះនាំឲ្យអ្នករួមទុនត្រូវទទួលស្គាល់តែចំណែកនៃចំណេញឬខាតនោះដែលចូល

ជាភាគកម្មរបស់អ្នករួមទុនផ្សេងទៀត។ អ្នករួមទុន ត្រូវទទួលស្គាល់បរិមាណសរុបនៃការខាតបង់ នៅពេលដែលវិភាគទាន ឬការលក់ផ្តល់ភស្តុតាងអំពីការខាតបង់ពីការថយចុះតម្លៃ។

១៥.១៧ នៅពេលដែលអ្នករួមទុនទិញទ្រព្យសកម្មពីក្រុមហ៊ុនរួមទុន អ្នករួមទុនមិនត្រូវទទួលស្គាល់ចំណែករបស់ខ្លួនលើប្រាក់ចំណេញពីប្រតិបត្តិការរបស់ក្រុមហ៊ុនរួមទុន រហូតទាល់តែក្រុមហ៊ុនលក់ទ្រព្យសកម្មនោះទៅភាគីឯករាជណាមួយ។ អ្នករួមទុន ត្រូវទទួលស្គាល់ចំណែកនៃការខាតបង់របស់ខ្លួនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះដូចការទទួលស្គាល់ចំណូលដែរ លើកលែងតែការខាតបង់ទាំងនោះត្រូវបានទទួលស្គាល់ភ្លាមនៅពេលការខាតបង់ទាំងនោះបង្ហាញអំពីការខាតបង់ដោយសារការថយចុះតម្លៃ។

## ប្រសិនបើវិនិយោគិនមិនមានសិទ្ធិត្រួតពិនិត្យរួម

១៥.១៨ វិនិយោគិនក្នុងក្រុមហ៊ុនរួមទុនដែលមិនមានសិទ្ធិត្រួតពិនិត្យរួមត្រូវគិតគូរវិនិយោគទុនរបស់ខ្លួនស្របតាមផ្នែកទី ១១ ឬប្រសិនបើគាតមានឥទ្ធិពលខ្លឹងលើក្រុមហ៊ុនរួមទុន ស្របតាមផ្នែកទី ១៤ ស្តីពីវិនិយោគទុននៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ ។

## ការលាតត្រដាងព័ត៌មាន

១៥.១៩ វិនិយោគិននៅក្នុងក្រុមហ៊ុនរួមទុន ត្រូវលាតត្រដាងព័តិមាន ÷

(ក) គោលនយោបាយគណនេយ្យដែលក្រុមហ៊ុនប្រើដើម្បីទទួលស្គាល់ភាគកម្មរបស់ក្រុមហ៊ុន នៅក្នុងអង្គភាពដែលត្រួតពិនិត្យរួមគ្នា

(ខ) តម្លៃពិតគណនេយ្យនៃការវិនិយោគក្នុងអង្គភាពដែលត្រួតពិនិត្យរួមគ្នា (មើលកថា- ខណ្ឌ ៤.២ (ដ))

(គ) តម្លៃទីផ្សារនៃការវិនិយោគក្នុងអង្គភាពដែលត្រួតពិនិត្យរួមគ្នា ដោយប្រើវិធីសាស្ត្រមូលធនកម្ម ដែលតម្លៃទាំងនោះបានបោះផ្សាយនៅក្នុងតារាងតម្លៃ

(ឃ) ចំនួនសរុបនៃការសន្យាទាក់ទិនទៅនឹងការរួមទុន រួមបញ្ចូលទាំងចំណែកហ៊ុនរបស់ វិនិយោគិន នៅក្នុងកិច្ចសន្យាមូលធន ដែលបានកើតមានរួមគ្នាជាមួយអ្នកដាក់ទុករកស៊ីរួមគ្នាផ្សេងទៀត ក៏ដូចជា ចំណែកហ៊ុនរបស់វិនិយោគិននៃកិច្ចសន្យាមូលធននៃការ រកស៊ីរួមគ្នាខ្លួនឯង។

១៥.២០ សម្រាប់អង្គភាពត្រួតពិនិត្យរួមគ្នាដែលទទួលខុសត្រូវស្របតាមវិធីសាស្ត្រមូលធនផ្ទាល់ អ្នកដាក់ទុនរកស៊ីរួមគ្នាក៏ត្រូវលាតត្រដាងព័តិមានផងដែរនូវដែលតម្រូវដោយកថាខណ្ឌ ១៤.១៤ សម្រាប់ការវិនិយោគតាមវិធីសាស្ត្រមូលធនកម្ម។

១៥.២១ សម្រាប់អង្គភាពដែលត្រួតពិនិត្យរួមគ្នាដែលទទួលខុសត្រូវស្របតាមម៉ូដែលតម្លៃទីផ្សារ អ្នកដាក់ទុនរកស៊ីរួមគ្នាក៏ត្រូវលាតត្រដាង ព័តិមានដែលតម្រូវដោយកថាខណ្ឌ ១១.៤១-១១.៤៤។

# ផ្នែកទី ១៦
# ទ្រព្យវិនិយោគ

## វិសាលភាពនៃផ្នែកនេះ

១៦.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មលើវិនិយោគទុនជាអគារ ឬដី ដែលបំពេញបានតាមលក្ខខណ្ឌនៃទ្រព្យវិនិយោគ តាមកថាខណ្ឌ ១៦.២ និងលើភាគកម្មនៃទ្រព្យសម្បត្តិមួយចំនួនដែលកាន់កាប់ដោយភតិកៈក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលកថាខណ្ឌ ១៦.៣) ដែលត្រូវបានចាត់ទុកដូចជា ទ្រព្យសវិនិយោគ។ មានតែទ្រព្យវិនិយោគដែលតម្លៃទីផ្សាររបស់វាអាចត្រូវបានវាស់វែងគួឱ្យទុកចិត្តបានដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុតែប៉ុណ្ណោះ ដែលត្រូវធ្វើគណនេយ្យកម្មស្របតាមផ្នែកនេះតាមតម្លៃទីផ្សារក្នុងចំណេញ ឬខាត។រីឯ ទ្រព្យវិនិយោគដទៃទៀតទាំងអស់ ត្រូវបានធ្វើគណនេយ្យកម្មជាទ្រព្យ រោងចក្រ និងបរិក្ខា ដោយប្រើម៉ូដែលការខាតបង់ដោយរំលស់ថ្លៃដើម តាមផ្នែកទី ១៧ ស្តីពី ទ្រព្យ រោងចក្រនិង បរិក្ខា ហើយស្ថិតក្នុងវិសា លភាពនៃផ្នែកទី១៧ វាលែងតែការវាស់វែងតម្លៃទីផ្សារគួរឱ្យទុកចិត្ត នឹងអាចធ្វើទៅបាន ហើយត្រូវ គេបានរំពឹងថាតម្លៃទីផ្សារនឹងអាចវាស់វែងគួឱ្យទុកចិត្តបាន ផ្អែកលើមូលដ្ឋាននិរន្តរភាព។

## និយមន័យ និងការទទួលស្គាល់លើកដំបូងនូវទ្រព្យសវិនិយោគ

១៦.២ ទ្រព្យវិនិយោគ គឺជាទ្រព្យស (ដី ឬអគារ , ឬផ្នែកមួយនៃអគារ ឬទាំងពីរ) ដែលកាន់កាប់ដោយម្ចាស់របស់វា ឬដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ ដើម្បីទទួលបានចំណូលពីការជួល ឬសម្រាប់រំលស់លើមូលធន ឬសម្រាប់គោលបំណងទាំងពី លើកលែងតែសម្រាប់ ÷

(ក) ប្រើប្រាស់ក្នុងផលិតកម្ម ឬក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា ឬសម្រាប់គោលបំណងរដ្ឋបាល ឬ

(ខ) លក់ក្នុងអាជីវកម្មជាធម្មតា។

១៦.៣ ភាគកម្មជាទ្រព្យដែលកាន់កាប់ដោយភតិកៈ ក្រោមភតិសន្យាប្រតិបត្តិការអាចត្រូវបានចាត់ថ្នាក់ និងគិតថាជាទ្រព្យវិនិយោគដោយប្រើផ្នែកនេះ ប្រសិនបើ និងតែក្នុងករណីបើ ទ្រព្យនោះបំពេញបាននូវនិយមន័យនៃទ្រព្យវិនិយោគ ហើយភតិកៈអាចវាស់វែងតម្លៃទីផ្សាររបស់ភាគកម្មនៃទ្រព្យនោះដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។ ជម្រើសនៃការចាត់ថ្នាក់នេះអាចធ្វើទៅបានដោយឈរលើមូលដ្ឋានតាមប្រភេទនៃទ្រព្យ។

១៦.៤ ការប្រើប្រាស់ទ្រព្យចម្រុះ ត្រូវតែបែងចែកឱ្យដាច់រវាងទ្រព្យវិនិយោគ និង ទ្រព្យ រោងចក្រនិង បរិក្ខា រ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃទីផ្សាររបស់សមាសធាតុទ្រព្យវិនិយោគ និង ទ្រព្យ រោងចក្រ និងបរិក្ខា រ មិនអាចត្រូវបានវាស់វែងប្រកបដោយការជឿជាក់ ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ ទ្រព្យទាំងអស់ត្រូវតែចាត់ទុកជាទ្រព្យ រោងចក្រ និងបរិក្ខារ ស្របតាមផ្នែកទី ១៧។

### ការវាស់វែងនាពេលទទួលស្គាល់ដំបូង

១៦.៥ អង្គ ភាពត្រូវវាស់វែងទ្រព្យវិនិយោគតាមថ្លៃដើមរបស់វា នាពេលទទួលស្គាល់លើកដំបូង។ ថ្លៃដើមនៃការទិញទ្រព្យវិនិយោគមាន ថ្លៃទិញរបស់វា និងចំណាយចូលរួមផ្ទាល់នានា ដូចជា សោហ៊ុយច្បាប់និងសោហ៊ុយអន្តរកម្ម (ឈ្មួញកណ្តាល) ពន្ធលើការផ្ទេរទ្រព្យ និងថ្លៃដើមប្រតិបត្តិការដទៃទៀត។ ប្រសិនបើការទូទាត់ត្រូវបានពន្យាលើសពីលក្ខខណ្ឌឥណទានធម្មតា ថ្លៃដើម គឺជាថ្លៃជាក់ស្តែង នៃការទូទាត់នាពេលអនាគត។ អង្គភាពត្រូវកំណត់ថ្លៃដើមនៃទ្រព្យដែលបានសាងសង់ដោយខ្លួនឯង ស្របតាមកថាខណ្ឌ ១៧.១០-១៧.១៤។

១៦.៦ ថ្លៃដើមដំបូងនៃភាគកម្មចាទ្រព្យក្រោមភតិសន្យា ហើយដែលត្រូវ បានចាត់ថ្នាក់ថាជាទ្រព្យវិនិយោគត្រូវអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ២០.៩ ទោះបីជាភតិសន្យានោះអាចត្រូវបានចាត់ថ្នាក់ផ្សេងថាជាភតិសន្យាប្រតិបត្តិការ តាមវិសាលភាពនៃផ្នែកទី២ ស្តីពីភតិសន្យា។ និយាយម្យ៉ាងទៀត ទ្រព្យសកម្មត្រូវបានទទួលស្គាល់តាមតម្លៃទីផ្សារទាបរបស់ទ្រព្យនោះ និងតាមតម្លៃជាក់ស្តែងនៃការទូទាត់ភតិសន្យាអប្បបរមា។បរិមាណទឹកប្រាក់ប្រហាក់ប្រហែលត្រូវបានទទួលស្គាល់ថាជាបំណុលស្របតាមកថាខណ្ឌ ២០.៩។

### ការវាស់វែងបន្ទាប់ពីការទទួលស្គាល់

១៦.៧ ទ្រព្យវិនិយោគដែលតម្លៃទីផ្សាររបស់វាអាចត្រូវបានវាស់វែងគួឱ្យទុកចិត្តបាន ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុត្រូវតែធ្វើការវាស់វែងតាមតម្លៃទីផ្សារនាកាលបរិច្ឆេទរាយការន៍នីមួយៗ ដោយយោលលើការប្រែប្រួលនៃតម្លៃទីផ្សារដែលបានទទួលស្គាល់នៅក្នុងចំណេញឬខាត។ ប្រសិនបើ ភាគកម្មជាទ្រព្យតាមភតិសន្យាត្រូវបានចាត់ថ្នាក់ថាជាទ្រព្យវិនិយោគ ធាតុដែលបានគិតគូតាមតម្លៃទីផ្សារ គឺជាភាគកម្មនោះ ហើយមិនមែនជាទ្រព្យតាមភតិសន្យាទេ។ កថាខណ្ឌ ១១.២៧-១១.៣២ ផ្តល់នូវគោលការណ៍ណែនាំក្នុងការកំណត់នូវតម្លៃទីផ្សារ។អង្គភាពត្រូវគិតគូនូវទ្រព្យវិនិយោគផ្សេងទៀតទាំងអស់ ថាជា ទ្រព្យ រោងចក្រ និង បរិក្ខា ដោយប្រើម៉ូដែលការខាតបង់ដោយរំលស់ថ្លៃដើម តាមផ្នែកទី ១៧។

### ការផ្ទេរ

១៦.៨ ប្រសិនបើការវាស់វែងតម្លៃទីផ្សារដែលអាចទុកចិត្ត មិនអាចធ្វើទៅបានទៀតដោយគ្មាន ចំណាយឬកិច្ចប្រឹងប្រែងហួសហេតុលើធាតុមួយនៃទ្រព្យវិនិយោគដែលបានវាស់វែងដោយប្រើម៉ូដែលតម្លៃទីផ្សារនោះទេ លំដាប់តទៅអង្គភាពត្រូវចាត់ទុកនូវធាតុនោះថាជាទ្រព្យ រោបចក្រនិងបរិក្ខា ស្របតាមផ្នែកទី ១៧ រហូតទាល់តែការវាស់វែងដែលអាចជឿទុកចិត្តលើតម្លៃទីផ្សារអាចធ្វើទៅបាន។តម្លៃក្នុងបញ្ជីនៃទ្រព្យវិនិយោគនាកាលបិរច្ឆេទនោះ ក្លាយទៅជាថ្លៃដើមរបស់វាតាមផ្នែកទី១៧។កថាខណ្ឌ១៦.១០(ក)(៣) តម្រូវឱ្យលាតត្រដាងព័ត៌មានអំពីការប្រែប្រួលនេះ។ វាគឺជាការប្រែប្រួលនៃកាលទេសៈ និងមិនមែនជាការប្រែប្រួលនៃគោលនយោបាយគណនេយ្យទេ។

១៦.៩ វាលែងតែមានការតម្រូវដោយកថាខណ្ឌ ១៦.៨ អង្គភាពត្រូវផ្ទេរនូវទ្រព្យទៅជា ឬមកជាទ្រព្យវិនិយោគ តែនៅពេលដែលទ្រព្យបំពេញបាននូវនិយមន័យនៃទ្រព្យវិនិយោគជាមុន ឬលែងបំពេញតាមនិយមន័យនេះ។

## ការលាតត្រដាងព័ត៌មាន

១៦.១០ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីទ្រព្យវិនិយោគដោយគិតតាមតម្លៃទីផ្សារ ដោយបង្ហាញនូវចំណេញ ឬ ខាត (វាក្យខណ្ឌ ១៦.៧)ដូចខាងក្រោម ÷

(ក)វិធីសាស្រ្ត និង ការសន្មត់សំខាន់ៗនានា ដែលប្រើប្រាស់នៅក្នុងការកំណត់តម្លៃ ទីផ្សាររបស់ទ្រព្យវិនិយោគ

(ខ)ទំហំឬវិសាលភាពនៃតម្លៃទីផ្សាររបស់ទ្រព្យវិនិយោគ (ដូចដែលបានវាស់វែងឬបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ)ត្រូវបានកំណត់ដោយផ្អែកលើការវាយ តម្លៃដោយអ្នកវាយតម្លៃឯករាជដែលមានគុណវុឌ្ឍិខាងវិជ្ជាជីវៈនិងត្រូវបានគេទទួលស្គាល់ ហើយដែលមានបទពិសោធថ្មីៗនៅក្នុងតំបន់និងថ្នាក់នៃទ្រព្យវិនិយោគដែលត្រូវវាយតម្លៃ។ ប្រសិនបើមិនមានការវាយតម្លៃខាងលើត្រូវបានធ្វើឡើងទេ ការមិនបានធ្វើនោះ អង្គភាពត្រូវបង្ហាញផងដែរ។

(គ)អត្ថិភាព និងបរិមាណនៃលក្ខខណ្ឌកំហិតនានានៃភាពអាចកើតមានរបស់ទ្រព្យវិនិយោគឬ ការបង្វែចំណូល និងចំណាយនៃការលក់បញ្ចេញចោល។

(ឃ)កាតព្វកិច្ចតាមកិច្ចសន្យា ក្នុងការទិញ ការសាងសង់ ឬការបង្កើនទ្រព្យវិនិយោគឬកាតព្វកិច្ចតាមកិច្ចសន្យាសម្រាប់ការជួសជុល ការថែទាំ ឬ ការធ្វើឲ្យប្រសើរឡើង ទ្រព្យវិនិយោគ។

(ង)ការផ្ទៀងផ្ទាត់រវាងតម្លៃពិតគណនេយ្យនៃទ្រព្យវិនិយោគ នាដើមនិងចុងការិយបរិច្ឆេទត្រូវបង្ហាញដាច់ពីគ្នានូវ ÷

១-ធាតុបន្ថែមនានា ដោយបង្ហាញដាច់ដោយឡែកនូវធាតុបន្ថែមទាំងនោះ ដែល បានមកពីការទិញ ឬ លទ្ធកម្ម តាមរយៈការបញ្ចូលគ្នានៃអាជីវកម្ម

២- ចំណេញសុទ្ធ ឬ ខាតសុទ្ធ ពីការកែតម្រូវតម្លៃទីផ្សារ

៣-ការផ្ទេរទៅក្នុងទ្រព្យ រោងចក្រ និងបរិក្ខា នៅពេលដែលវិធានការអាច ទទួលយកបាននានានៃតម្លៃទីផ្សារមិនអាចធ្វើទៅបាន ដោយគ្មានចំណាយ ឬ កិច្ចប្រឹងប្រែងហួសហេតុ(មើល កថាខណ្ឌ ១៦.៨)

៤- ការផ្ទេរទៅ និង ផ្ទេរពីសារពើភណ្ឌ និងទ្រព្យដែលកាន់កាប់ដោយម្ចាស់។

៥- ការប្រែប្រួលផ្សេងៗទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញសម្រាប់ការិយបរិច្ឆេទមុនៗទេ។

**១៦.១១** ដោយអនុលោមតាម ផ្នែកទី ២០ ម្ចាស់ទ្រព្យវិនិយោគ ត្រូវផ្តល់នូវការលាតត្រដាងព័ត៌មានរបស់ ភតិបតី អំពីភតិសន្យាដែលម្ចាស់ទ្រព្យនោះបានចូលរួមជាភាគី។ អង្គភាពមួយដែលមានទ្រព្យវិនិយោគក្រោមភតិសន្យាហិរញ្ញវត្ថុ ឬភតិសន្យាប្រតិបត្តិការត្រូវលាតត្រដាងព័ត៌មានរបស់ ភតិបតីសម្រាប់ភតិសន្យាហិរញ្ញវត្ថុឬផ្តល់នូវការលាតត្រដាងព័ត៌មានរបស់ភតិបតីសម្រាប់ភតិសន្យាប្រតិបត្តិការនានាដែលអង្គភាពនោះបានចូលរួមជាភាគី។

## ផ្នែកទី ១៧
## ទ្រព្យ រោងចក្រ និងបរិក្ខា

### វិសាលភាព

១៧.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មសម្រាប់ ទ្រព្យ រោងចក្រ និងបរិក្ខា និង ទ្រព្យវិនិយោគ ដែលតម្លៃទីផ្សាររបស់វាមិនអាចត្រូវវាស់វែងគួឲ្យទុកចិត្តបាន ដោយគ្មាន ចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។ ផ្នែកទី ១៦ ស្តីពី ទ្រព្យវិនិយោគ អនុវត្តចំពោះទ្រព្យវិនិយោគដែលតម្លៃទីផ្សាររបស់វា អាចត្រូវបានវាស់វែងគួឲ្យទុកចិត្តបាន ដោយគ្មានចំណាយឬកិច្ចប្រឹងប្រែងហួសហេតុ។

១៧.២ ទ្រព្យ រោងចក្រ និងបរិក្ខា គឺជាទ្រព្យសកម្មរូបិយ ដែល ÷

(ក) ទុកសម្រាប់ប្រើក្នុងផលិតកម្ម ឬក្នុងការផ្គត់ផ្គង់ទំនិញនិងសេវា, ទុកសម្រាប់ជួលឲ្យអ្នកដទៃ ឬទុកសម្រាប់គោលបំណងរដ្ឋបាល, និង

(ខ) រំពឹងថានឹងត្រូវបានប្រើប្រាស់ក្នុងកំឡុងពេលលើសពីមួយការិយបរិច្ឆេទ។

១៧.៣ ទ្រព្យ រោងចក្រ និងបរិក្ខា មិនរាប់បញ្ចូលនូវ ÷

(ក) ទ្រព្យសកម្មជីវសាស្ត្រដែលទាក់ទិននឹងសកម្មភាពកសិកម្ម (សូមមើលផ្នែកទី៣ ៤ស្តីពីសកម្មភាពឯកទេស), ឬ

(ខ) សិទ្ធិលើធនធានរ៉ែ និងទុនបម្រុងលើធនធានរ៉ែ ដូចជា ប្រេង ហ្គាសធម្ម ជាតិ និងធនធានមិនកើតមានប្រហាក់ប្រហែលផ្សេងទៀត។

### ការទទួលស្គាល់

១៧.៤ អង្គ ភាពត្រូវអនុវត្តតាមលក្ខខណ្ឌនៃការទទួលស្គាល់ក្នុងកថាខណ្ឌ ២.២៧ ក្នុងការកំណត់ថាតើត្រូវទទួលស្គាល់ធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខា ឬអត់។ ដូចនេះ អង្គជាពត្រូវទទួលស្គាល់ថ្លៃដើមនៃធាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខា ថាជាទ្រព្យសកម្មប្រសិនបើ និងតែករណី ÷

(ក) វាប្រហែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលភ្ជាប់ជាមួយធាតុនោះនឹងហូរចូលអង្គភាព ហើយ

(ខ) ថ្លៃដើមនៃធាតុនោះ អាចត្រូវបានវាស់វែងគួរឲ្យទុកចិត្ត។

១៧.៥ គ្រឿងបន្លាស់និងសម្ភារៈសម្រាប់បម្រើសេវា ជាធម្មតាត្រូវបានទុកជាសន្និធិ និងត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ថាបានប្រើអស់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គ្រឿងបន្លាស់សំខាន់ៗ និសម្ភារៈទ្រទ្រង់ គឺជាទ្រព្យ រោងចក្រ និងបរិក្ខា នៅពេលដែលអង្គភាពរំពឹងថានឹងប្រើវាក្នុងកំឡុងពេលលើសមួយការិយបរិច្ឆេទ។ ដូចគ្នា

នេះដែរ ប្រសិនបើ គ្រឿងបន្លាស់ និងសម្ភារៈសម្រាប់បម្រើសេវា អាចត្រូវបានប្រើប្រាស់តែដើម្បីភ្ជាប់ជាមួយ ធាតុណាមួយនៃទ្រព្យ រោងចក្រ និងបរិក្ខាទាំងនោះត្រូវបានចាត់ទុកជា ទ្រព្យ រោងចក្រ និងបរិក្ខា។

១៧.៦ ផ្នែកនៃធាតុមួយចំនួនរបស់ទ្រព្យ រោងចក្រ និងបរិក្ខា អាចតម្រូវឲ្យដាក់ជំនួសក្នុងចន្លោះពេលជាធម្មតា (ដូចជា ដំបូលអគារ)។អង្គភាពត្រូវបន្ថែមនៅក្នុង តម្លៃក្នុងបញ្ជីរបស់ធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខា នូវថ្លៃដើមនៃ ការជំនួសផ្នែកនៃធាតុនោះ នៅពេលដែលថ្លៃដើមនោះត្រូវបានកើតឡើង ប្រសិនបើផ្នែកដែលជំនួយត្រូវបាន រំពឹងថានឹផ្តល់នូវផលប្រយោជន៍បន្ថែមនាពេលអនាគតដល់អង្គភាព។តម្លៃក្នុងបញ្ជីរបស់ផ្នែកទាំងនោះដែលត្រូវ បានជំនួស គឺមិនត្រូវបានទទួលស្គាល់តាមកថាខណ្ឌ ១៧.២៧-១៧.៣០ នៅទេ។ កថាខណ្ឌ ១៧.១៦ ចែងថា ប្រសិនបើសមាសធាតុសំខាន់នៃធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខា មានគំរូខុសគ្នាខ្លាំងលើការប្រើ អត្ថប្រយោជន៍សេដ្ឋកិច្ច អង្គ ភាពត្រូវធ្វើវិភាជន៍ថ្លៃដើមដំបូងនៃទ្រព្យសកម្មទៅសមាសធាតុចម្បងរបស់ខ្លួន ហើយត្រូវរំលស់សមាសធុនិមួយៗនេះដាច់ដោយឡែកសម្រាប់ មួយអាយុកាលរបស់សមាសធាតុនោះ។

១៧.៧ លក្ខខណ្ឌនៃការបន្តប្រតិបត្តិការលើធាតុមួយនៃទ្រព្យស រោងចក្រ និងបរិក្ខា (ដូច ជា ឡានក្រុង) អាចត្រូវធ្វើ អធិការកិច្ចចម្បងជាធម្មតាដើម្បីរកកំហុស ដោយមិនគិតថាតើផ្នែកនានានៃធាតុនោះត្រូវបានជំនួស។ នៅពេល ដែលអធិការកិច្ចចម្បងត្រូវបានធ្វើឡើង ថ្លៃដើមរបស់វាត្រូវ០ាទទួលស្គាល់តាមតម្លៃក្នុងបញ្ជីរបស់ធាតុនៃ ទ្រព្យ រោងចក្រ និងបរិក្ខា ថាជាការដាក់ជំនួស ប្រសិនបើលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ត្រូវបានបំពេញ។ រាល់តម្លៃក្នុងបញ្ជីដែលនៅសល់នៃថ្លៃដើមអធិការកិច្ចដែលបានធ្វើមុនៗ (ដែលចែកដាច់ពីផ្នែកជារូបវន្ត) មិន ត្រូវបានទទួលស្គាល់ទេ។ ការធ្វើបែបនេះដោយមិនគិតពីថាតើ ថ្លៃដើមអធិការកិច្ចដែលបានធ្វើមុនៗ ត្រូវបាន បញ្ជាក់នៅក្នុងប្រតិបត្តិការដែលក្នុងនោះធាតុនៃទ្រព្យត្រូវបានទិញ ឬសាងសង់ឡើង។ ប្រសិនបើចាំបាច់ ថ្លៃដើម ប៉ាន់ស្មាននៃថ្លៃដើមអធិការកិច្ចប្រហាក់ប្រហែលនាពេលអនាគតអាចត្រូវបានប្រើប្រាស់ជាសុច្ចនករមួយនៃអ្វី ដែលថ្លៃដើមនៃសមាសធាតុអធិការកិច្ចដែលមានស្រាប់ត្រូវបានធ្វើឡើង នៅពេលដែលធាតុនៃទ្រព្យត្រូវបាន ទិញឬសាងសង់ឡើង។

១៧.៨ ដីនិងអគារ គឺ ជាទ្រព្យសកម្មដែលអាចបំបែកចេញពីគ្នាបាន ហើយអង្គភាពត្រូវធ្វើគណនេយ្យកម្ម ដាច់ដោយ ឡែកពីគ្នា ទោះបីជាពេលនោះវាទាំងពីរត្រូវបានទិញក្នុងពេលជាមួយគ្នា។

### ការវាស់វែងនាពេលទទួលស្គាល់

១៧.៩ អង្គភាពត្រូវវាស់វែងទ្រព្យ រោងចក្រ និងបរិក្ខានាពេលទទួលស្គាល់លើកដំបូងតាមថ្លៃដើមរបស់វា។

### សមាសធាតុនៃថ្លៃដើម

១៧.១០ ថ្លៃដើមនៃធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខា មានដូចខាងក្រោម ÷

(ក)ថ្លៃទិញ រួមទាំងសោហ៊ុយច្បាប់ និងសោហ៊ុយជើងសារ ពន្ធនាំចូលនិងពន្ធលើការទិញដែលមិនអាចទា រមកវិញបាន បន្ទាប់ពីការកាត់កងអប្បហាពាណិជ្ជកម្មនិងការបង្វិលត្រឡប់។

(ខ)ថ្លៃដើមនានាដែលចូលរួមដោយផ្ទាល់ក្នុងការនាំយកទ្រព្យសកម្មទៅដល់ទីកន្លែងនិងលក្ខខណ្ឌចាំបាច់សម្រាប់វាដើម្បីអាចយកទៅប្រើបានតាមការចង់បានរបស់អ្នកគ្រប់គ្រង។ ថ្លៃដើមទាំងនោះអាចរាប់បញ្ចូលនូវថ្លៃដើមរៀបចំកន្លែង ការប្រគល់ទទួលបឋម ការដាក់តាំងបង្ហាញនិងការប្រមូលផ្តុំ ព្រមទាំងការសាកល្បងដំណើរការ។

(គ)ការប៉ាន់ស្មានជាបឋមនូវថ្លៃដើមនៃការរំលាយចោលឬការដកចេញនូវធាតុនិងការរក្សាទុកនូវទីតាំងដែលធាតុមួយនោះតាំងនៅ, គឺជាកាតព្វកិច្ចដែលអង្គភាពបង្ករឡើងទាំងនៅពេលដែលទ្រព្យនោះត្រូវបានទិញឬជាផលវិបាកដែលដោយការប្រើទ្រព្យនោះក្នុងអំឡុងពេលដ៏ជាក់លាក់មួយក្នុងគោលបំណងមិនមែនផលិតទំនិញសម្រាប់រយៈពេលនោះ។

១៧.១១ ថ្លៃដើមខាងក្រោម មិនមែនជាថ្លៃដើមនៃធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខាទេ ហើយអង្គភាពត្រូវទទួលស្គាល់នូវថ្លៃដើមទាំងនោះថាជាចំណាយនៅពេលដែលវាបានកើតឡើង ÷

(ក)ថ្លៃដើមនៃការដាក់ឲ្យដំណើរការគ្រឿងបរិក្ខាថ្មី

(ខ)ថ្លៃដើមនៃការណែនាំផលិតផល ឬសេវាថ្មី (រួមតាំងថ្លៃដើមផ្សាយពាណិជ្ជកម្មនិងសកម្ម ភាពឃោសនាផ្សេងទៀត)។

(គ)ថ្លៃដើមនៃការបើកអាជីវកម្មនៅទីតាំងថ្មីឬជាមួយអតិថិជនថ្មី(រួមបញ្ចូលទាំថ្លៃដើមបណ្តុះបណ្តាលបុគ្គលិក)។

(ឃ)ថ្លៃដើមចំណាយរដ្ឋបាលនិងចំណាយទូទៅផ្សេងទៀត។

(ង)បន្ទុកលើប្រាក់កម្ចី (សូមមើលផ្នែកទី ២៥ ស្តីពី បន្ទុកលើប្រាក់កម្ចី)។

១៧.១២ ចំណូលនិងចំណាយពាក់ព័ន្ធនឹងប្រតិបត្តិការបន្ទាប់បន្សំក្នុងកំឡុងពេលសាងសង់ឬអភិវឌ្ឍធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខា ត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត ប្រសិនបើប្រតិបត្តិការទាំងនោះមិនចាំបាច់នាំធាតុនោះទៅទីកន្លែងដែលចង់បានរបស់វា និងមិនមែនជាលក្ខខណ្ឌនៃប្រតិបត្តិការទេ។

ការវាស់វែងថ្លៃដើម

១៧.១៣ ថ្លៃដើមនៃធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខា គឺជាថ្លៃសាច់ប្រាក់សមមូលនាកាលបរិច្ឆេទទទួលស្គាល់។ ប្រសិនបើការទូទាត់ត្រូវបានពន្យាលើសពីលក្ខខណ្ឌឥណទានធម្មតា ថ្លៃដើមគឺជាតម្លៃជាក់ស្តែងនៃការទូទាត់នាពេលអនាគតទាំងអស់។

## ការដោះដូរទ្រព្យសកម្ម

១៧.១៤ ធាតុមួយនៃទ្រព្យ រោងចក្រ និងបរិក្ខា អាចត្រូវបានទទួលដោយការផ្លោះប្តូរជាមួយទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬជាមួយទ្រព្យសកម្ម, ឬគឺជាការបញ្ចូលគ្នាទាំងទ្រព្យសកម្មរូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។អង្គភាពត្រូវវាស់វែងថ្លៃដើមនៃទ្រព្យសកម្មដែលទទួលបានតាម តម្លៃទីផ្សារ វាលែងតែ (ក) ប្រតិបត្តិការផ្លោះប្តូរខ្វះខាតនូវសារជាតិពាណិជ្ជកម្ម ឬ (ខ)តម្លៃទីផ្សារនៃទាំងទ្រព្យសកម្មដែលទទួលបាន ទាំងទ្រព្យសកម្មដែលបោះបង់ចោលអាចត្រូវបានវាស់វែងគួឱ្យទុកចិត្តបាន។ ករណីនេះ ថ្លៃដើមរបស់ទ្រព្យសកម្ម ត្រូវបានវាស់វែងតាមតម្លៃក្នុង បញ្ជីរបស់ទ្រព្យសកម្មដែលបានបោះបង់ចោល។

## ការវាស់វែងបន្ទាប់ពីការទទួលស្គាល់លើកដំបូង

១៧.១៥ អង្គភាពត្រូវវាស់វែងធាតុទាំងអស់របស់ទ្រព្យ រោងចក្រ និងបរិក្ខា បន្ទាប់ពីការទទួលស្គាល់លើកដំបូង ដោយយកថ្លៃដើម ដករំលស់បូកយោងនិងការខាតបង់ដោយការថយចុះតម្លៃ បូកយោង។ អង្គភាពត្រូវទទួលស្គាល់ថ្លៃដើមសេវាប្រចាំថ្ងៃនៃធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខា ក្នុងចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលថ្លៃដើមបានកើតឡើង។

## ការដករំលស់

១៧.១៦ ប្រសិនបើសមាសធាតុចម្បងនៃធាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខា មានគំរូខុសគ្នាខ្លាំងនៃការប្រើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច អង្គ ភាពត្រូវវិភាជថ្លៃដើមដំបូងនៃទ្រព្យសកម្មទៅក្នុងសមាសធាតុចម្បងរបស់វា ហើយត្រូវធ្វើការដករំលស់លើសមាសធាតុនីមួយៗដាច់ដោយឡែកពីគ្នាក្នុងកំឡុងជីវិតនៃការប្រើរបស់វា។ទ្រព្យសកម្មដទៃទៀត ត្រូវបានដករំលស់ក្នុងកំឡុងជីវិតនៃការប្រើរបស់វា ថាជាទ្រព្យសកម្មតែមួយ។ ជាមួយការលើកលែងមួយចំនួនដូចជា ការដ្ឋានយកថ្មនិងទីតាំងប្រើសម្រាប់ការចាក់បំពេញដី, ដីមានអាយុកាលគ្មានកំនត់ ដូចនេះ វាមិនត្រូវបានដករំលស់ទេ។

១៧.១៧ បន្ទុកកាត់រំលស់សម្រាប់ការិយបរិច្ឆេទនីមួយៗត្រូវបានទទួលស្គាល់ក្នុងចំណេញឬខាត លើកលែងតែផ្នែកផ្សេងទៀតនៃស្តង់ដានេះ តម្រូវឱ្យថ្លៃដើមត្រូវ បានទទួលស្គាល់ថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម។ ឧទាហរណ៍ ការកាត់រំល ស់នៃទ្រព្យ រោងចក្រ និងបរិក្ខានៃការផលិតត្រូវបានបញ្ចូលក្នុងថ្លៃដើមនៃសន្និធិ (សូមមើល ផ្នែកទី ១៣ ស្តីពី សន្និធិ)។

## ចំនួនទឹកប្រាក់ដែលអាចកាត់រំលស់ និងការិយបរិច្ឆេទកាត់រំលស់

១៧.១៨ អង្គភាពត្រូវធ្វើវិភាជនូវចំនួនទឹកប្រាក់កាត់រំលស់ របស់ទ្រព្យសកម្មមួយដោយឈរលើមូលដ្ឋានជាប្រព័ន្ធក្នុងកំឡុងនៃអាយុជីវិតប្រើប្រាស់របស់វា។

១៧.១៩ កត្តានានា ដូចជា ការប្រែប្រួលនូវរបៀបប្រើទ្រព្យសកម្ម ការសឹករិចរិលធំៗដែលមិនបានគិតទុកមុន វិបុលភាព នៃបច្ចេកវិទ្យានិងការប្រែប្រួលលើថ្លៃទីផ្សារអាចបង្ហាញថាតម្លៃដែលនៅសល់ឬជីវិតនៃការប្រើប្រាស់ទ្រព្យសកម្ម បានប្រែប្រួលចាប់តាំងពីកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំនាពេលថ្មីៗនេះបំផុត។ ប្រសិនបើសុចនករទាំងនេះ កើតមាន អង្គ ភាពត្រូវពិនិត្យឡើងវិញការបាន់ស្មានរបស់ខ្លួនពីពេលមុនៗ ហើយត្រូវកែប្រែតម្លៃដែលនៅសល់ កែប្រែវិធីសាស្រ្តគិតរំលស់ ឬជីវិតនៃការប្រេប្រាស់ទ្រព្យសកម្ម ប្រសិនបើការរំពឹងទុកជាក់ស្តែងខុសគ្នា។ អង្គភាពត្រូវគិតថា ការប្រែប្រួលតម្លៃដែលនៅសល់ វិធីសាស្រ្តគិតរំលស់ ឬជីវិតនៃការប្រេប្រាស់ទ្រព្យសកម្ម ថាជាការប្រែប្រួលនៃ ការប៉ាន់ស្មានគណនេយ្យ ស្របតាមកថាខណ្ឌ ១០.១៥-១០.១៨។

១៧.២០ ការដករំលស់លើទ្រព្យសកម្ម ចាប់ផ្តើមនៅពេលដែលទ្រព្យនោះអាចយកទៅប្រើប្រាស់បាន មានន័យថាពេល ដែលវានៅក្នុងទីតាំងនិងក្រោមលក្ខខណ្ឌចាំបាច់សម្រាប់វា ដើម្បីអាចប្រតិបត្តិការបានតាមសេចក្តីត្រូវការរបស់ អ្នកគ្រប់គ្រង។ការដករំលស់ត្រូវបញ្ចប់នៅពេលដែលវាត្រូវបានឈប់ទទួលស្គាល់។ការដករំលស់មិនត្រូវបាន បញ្ឈប់ទេ នៅពេលដែលទ្រព្យសកម្មនោះ ក្លាយទៅជាគ្មានប្រយោជន៍ (គ្មានបានការ) ឬត្រូវបានដកចេញពី សកម្មភាពប្រើប្រាស់ វាលែងតែទ្រព្យសកម្មនោះត្រូវ បានដករំលស់ចប់សព្វគ្រប់។ប៉ុន្តែទោះបីជាយ៉ាងណាក៏ ដោយ ក៏តាមវិធីសាស្រ្តដែលប្រើដើម្បីដករំលស់ សោហ៊ុយក្នុងការរំលស់ អាចស្មើនឹងសូន្យ នៅពេលដែលគ្មាន ផលិតកម្ម។

១៧.២១ អង្គាភាពត្រូវចាត់ទុកកត្តាទាំងអស់ខាងក្រោមដើម្បីកំណត់អំពីជីវិតប្រើប្រាស់ទ្រព្យសកម្មមួយ ៖

(ក)ការប្រេប្រាស់ទ្រព្យសកម្មដែលបានរំពឹងទុក។ការប្រើប្រាស់ត្រូវបានវាយតម្លៃដោយយោងទៅលើសមត្ថភាព រំពឹងទុករបស់ទ្រព្យសកម្ម ឬ ទិន្នផលជារូបរាង។

(ខ)ការសឹករិចរិលជារូបរាងដែលបានរំពឹងទុកដែលអាស្រ័យទៅលើកត្តប្រតិបត្តិការ ដូច ជា ចំនួននៃវេននៃ ការប្រើទ្រព្យសកម្ម ព្រមទាំងកម្មវិធីជួសជុលនិងថែទាំ, និង ការថែទាំនិងថែរក្សាទ្រព្យសកម្មពេលលែងប្រើ។

(គ)ភាពហួសសម័យនៃពាណិជ្ជកម្ម ឬបច្ចេកវិទ្យា ដែលបណ្តាលមកពីការប្រែប្រួល ឬបសិដ្ឋកម្មនៃផលិតកម្ម ឬ ដែលបណ្តាលមកពីការប្រែប្រួលនៃតម្រូវការទិន្នផលផលិតផលឬសេវាលើទីផ្សារ របស់ទ្រព្យសកម្ម។

(ឃ)ការដាក់កម្រិតតាមផ្លូវច្បាប់ ឬការកម្រិតប្រហាក់ប្រហែលលើការប្រើប្រាស់ទ្រព្យសកម្ម ដូចជា ការហួស កាលបរិច្ឆេទនៃភតិសន្យាពាក់ព័ន្ធ។

## វិធីសាស្រ្តដករំលស់

១៧.២២ អង្គភាពត្រូវជ្រើសរើសវិធីសាស្រ្តដករំលស់មួយ ដែលបង្ហាញអំពីគំរូ ដែលក្នុងនោះអង្គភាពរំពឹងថានឹងប្រើ អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតរបស់ទ្រព្យសកម្ម។ វិធីសាស្រ្តដករំលស់ដែលអាចអនុវត្តបាន រួមមាន វិធីសាស្រ្តដករំលស់ថេរ វិធីសាស្រ្តកាត់បន្ថយសមតុល្យ និងវិធីសាស្រ្តដែលផ្អែកលើមូលដ្ឋាននៃ

ការប្រើប្រាស់ ដូចជា វិធីសាស្ត្រដករំលស់តាមឯកតានៃការផលិត។

១៧.២៣ ប្រសិនបើមានការចង្អុលបង្ហាញថា មានការប្រែប្រួលខ្លាំងនាកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំចុងក្រោយលើគំរូដែលតាមនោះអង្គភាពរំពឹងថានឹងប្រើអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃទ្រព្យសកម្មនាពេលអនាគត អង្គភាពត្រូវពិនិត្យឡើងវិញលើវិធីសាស្ត្រកាត់រំលស់បច្ចុប្បន្នរបស់ខ្លួន និងប្តូរវិធីសាស្ត្រដករំលស់ដើម្បីបង្ហាញឲ្យឃើញនូវគំរូថ្មី ប្រសិនបើ ការរំពឹងទុកបច្ចុប្បន្នខុសពីមុន។ អង្គភាពត្រូវចាត់ទុកការប្រែប្រួលនោះថាជាការប្រែប្រួលលើការប៉ាន់ស្មានគណនេយ្យ ស្របតាម កថាខណ្ឌ ១០.១៥១០.១៨។

## ការថយចុះតម្លៃ

### ការទទួលស្គាល់ និងការវាស់វែងការថយចុះតម្លៃ

១៧.២៤ នាកាលបរិច្ឆេទរាយការណ៍នីមួយៗ អង្គភាពត្រូវអនុវត្តតាមផ្នែកទី២៧ស្តីពីការថយចុះតម្លៃនៃទ្រព្យសកម្ម ដើម្បីកំណត់ថា តើធាតុណាមួយឬក្រុមនៃធាតុរបស់ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានថយចុះតម្លៃឬទេ ហើយប្រសិនបើដូច្នោះ តើវានឹងត្រូវទទួលស្គាល់និងវាស់វែងការខាតបង់ដោយសារការថយចុះតម្លៃយ៉ាងដូចម្តេច។ ផ្នែននេះនឹងពន្យល់ថា តើអង្គភាពគត្រូវពិនិត្យឡើងវិញលើតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មរបស់ខ្លួននៅពេលណានិងយ៉ាងដូចម្តេច ហើយថា តើអង្គភាពកំណត់នូវទឹកប្រាក់ដែលបានទទួលមកវិញលើទ្រព្យសកម្មយ៉ាងដូចម្តេចនិងតើអង្គភាពទទួលស្គាល់ឬធ្វើឲ្យការខាតបង់ដោយសារការថយចុះតម្លៃត្រលប់មកវិញនៅពេលណា។

### សំណងទូទាត់សម្រាប់ការថយចុះតម្លៃ

១៧.២៥ អង្គភាពត្រូវបញ្ចូលក្នុងចំណេញឬខាតនូវសំណងទូទាត់ពីទតិយជនសម្រាប់ធាតុនានានៃទ្រព្យ រោងចក្រ និងបរិក្ខាដែលបានចុះតម្លៃ, ត្រូវបានចាត់ទុកថាបានបាត់បង់ឬត្រូវបានបោះបង់ចោលតែនៅពេលដែលសំណងទូទាត់បានក្លាយជាចំនួនអាចទារមកវិញបាន។

### ទ្រព្យ រោងចក្រ និងបរិក្ខាទុកសម្រាប់លក់

១៧.២៦ កថាខណ្ឌ២៧.៩(ច) ចែងថា ផែនការលក់ចោលទ្រព្យសកម្មមុនកាលបរិច្ឆេទរំពឹងទុកដែលបានកំណត់ពីមុន គឺជាសុចនករនៃការថយចុះតម្លៃដែលធ្វើជាគន្លឹះនៃការគណនាបរិមាណទឹកប្រាក់ដែលទទួលបានមកវិញនៃទ្រព្យសកម្មសម្រាប់កំណត់ថា តើទ្រព្យសកម្មត្រូវបានថយចុះតម្លៃឬអត់។

## ការឈប់ទទួលស្គាល់

១៧.២៧អង្គភាពត្រូវឈប់ទទួលស្គាល់ធាតុមយនៃទ្រព្យ រោងចក្រ និងបរិក្ខា ÷

(ក)ពេលវាត្រូវបានលក់បញ្ចេញចោល ឬ

(ខ)នៅពេលដែលលែងមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងទទួលបានពីវា ឬពីការលក់បញ្ចេញចោល។

១៧.២៨ អង្គភាពត្រូវទទួលស្គាល់ចំណេញ ឬការខាតបង់លើការឈប់ទទួលស្គាល់ធាតុណាមួយនៃទ្រព្យសកម្ម រោងចក្រ និងបរិក្ខា ក្នុងចំណេញឬខាត នៅពេលដែលធាតុនោះលែងត្រូវបានទទួលស្គាល់ (វាលែងតែ ផ្នែកទី ២២ ស្តីពីភតិសន្យាបានតម្រូវផ្ទុយពីនេះលើការលក់និងការធ្វើភតិសន្យាត្រឡប់)។អង្គភាពមិនត្រូវធ្វើការចាត់ថ្នាក់ចំណេញឬខាតនេះទេ។

១៧.២៩ក្នុងការគំណត់កាលបរិច្ឆេទលក់បញ្ចេញចោលនូវធាតុមួយ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យក្នុង ផ្នែកទី ២៣ ស្តីពីចំណូលសម្រាប់ការទទួលស្គាល់ចំណូលពីការលក់ទំនិញ។ ផ្នែកទី ២០ អនុវត្តចំពោះការលក់បញ្ចេញចោលដោយការលក់និងការធ្វើភតិសន្យាត្រឡប់វិញ។

១៧.៣០ អង្គភាពត្រូវកំណត់នូវចំណេញឬខាត ដែលកើតចេញពីការមិនទទួលស្គាល់លើធាតុមួយនៃទ្រព្យរោងចក្រ និងបរិក្ខា ថាជាភាពខុសគ្នារវាងចំណូលពីការលក់បញ្ចេញចោលសរុប និងតម្លៃក្នុងបញ្ជីនៃធាតុនោះ ប្រសិនបើមាន។

## ការលាតត្រដាងព័ត៌មាន

១៧.៣១ អង្គភាពមួយត្រូវលាតត្រដាងព័ត៌មានអំពីថ្នាក់នៃទ្រព្យ រោងចក្រ និងបរិក្ខានិមួយៗ ដែលគិតថា សមរម្យ ដោយអនុលោមតាមកថាខណ្ឌទី ៤.១ (ក) ដូចតទៅ ÷

(ក) មូលដ្ឋានវាយតម្លៃដែលបានប្រើប្រាស់ដើម្បីកំណត់អំពីតម្លៃពិតគណនេយ្យសរុប

(ខ) វិធីសាស្ត្ររំលស់ដែលបានប្រើប្រាស់

(គ) អាយុកាលប្រើប្រាស់នៃបរិក្ខា និង អត្រារំលស់ដែលបានប្រើប្រាស់

(ឃ) តម្លៃពិតគណនេយ្យសរុប និងរំលស់បូកយោង (ដោយសរុបជាមួយផលបូកនូវ ការខាតបង់ដែលបាត់ទៅ) នាដើមនិងចុងការិយបរិច្ឆេទរាយការណ៍

(ង) ការផ្ទៀងផ្ទាត់តម្លៃពិតគណនេយ្យនៅដើមនិងចុងការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកនូវ ÷

១- ធាតុបន្ថែមផ្សេងៗ

២- ការដកចេញ

៣- ការទទួលបាន ឬលទ្ធកម្ម តាមរយៈការរួមបញ្ចូលអាជីវកម្ម

៤- ការផ្ទេរទ្រព្យវិនិយោគ ប្រសិនបើការវាស់វែងតម្លៃទីផ្សារដែលអាចជឿទុកចិត្ត ប្រែជាអាចធ្វើទៅបាន (មើលកថាខណ្ឌទី ១៦.៨)

៥- ការខាតបង់ដែលនាំឲ្យចុះតម្លៃត្រូវបានទទួលស្គាល់ឬត្រូវបានត្រឡប់ទៅជាចំណេញឬខាត ស្របតាម ផ្នែកទី ២៧

៦-ការរំលស់

៧-ការប្រែប្រួលផ្សេងទៀត។

ការផ្ទុផ្គងនេះ មិនចាំបាច់បង្ហាញទេសម្រាប់ការិយបរិច្ឆេទមុនៗ។

១៧.៣២ អង្គភាពមួយ ក៏ត្រូវបង្ហាញផងដែរនូវ ÷

(ក)អត្ថិភាព និង តម្លៃពិតគណនេយ្យរបស់ទ្រព្យ រោងចក្រ និងបរិក្ខា ដែលអង្គភាព បានកំណត់នូវកម្មសិទ្ធិ ឬ ទ្រព្យ រោងចក្រ និងបរិក្ខា ដែលត្រូវបានសន្យាដាក់ធានា បំណុល

(ខ)បរិមាណនៃចំណាយតាមកិច្ចសន្យាក្នុងទទួលបាននូវទ្រព្យ រោងចក្រ បរិក្ខា។

## ផ្នែកទី ១៨

## ទ្រព្យសកម្មអរូបីយមិនមែនជាមូលនិធិពាណិជ្ជកម្ម

### វិសាលភាពនៃផ្នែកនេះ

១៨.១ ផ្នែកនេះអនុវត្តចំពោះការធ្វើគណនេយ្យកម្មនូវរាល់ ទ្រព្យសកម្មអរូបីយ លើកលែងតែមូលនិធិពាណិជ្ជកម្ម (សូមមើល ផ្នែកទី ១៩ ស្តីពី ការរួមបញ្ចូលអាជីវកម្ម និងមូលនិធិពាណិជ្ជកម្ម) និងទ្រព្យសកម្មអរូបីយ ដែលកាន់កាប់ដោយអង្គភាពសម្រាប់លក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន (សូមមើលផ្នែកទី ១៣ ស្តីពី សន្និធិ និងផ្នែកទី ២៣ ស្តីពី ចំណូល)។

១៨.២ ទ្រព្យសកម្មអរូបីយ ទ្រព្យសកម្មមិនមែនរូបីយវត្ថុដែលអាចកំណត់បាន ដោយគ្មានរូបរាង។ ទ្រព្យសកម្មបែបនេះ អាចកំណត់បាននៅពេលដែល ៖

(ក) វាអាចបែងចែកដាច់បាន ដូចជា អាចបែងចែកដាច់ ឬញែកដាច់ពីអង្គភាព និងយកទៅលក់ ផ្ទេរ ផ្ទេរសិទ្ធិ ជួល ឬផ្លោះប្តូរ ទាំងជាលក្ខណៈដាច់ដោយឡែក ឬទាំងជាមួយកិច្ចសន្យា ជាមួយទ្រព្យសកម្ម ឬបំណុលពាក់ព័ន្ធ ឬ

(ខ) វាកើតចេញពីសិទ្ធិតាមកិច្ចសន្យាឬសិទ្ធិតាមផ្លូវច្បាប់ដទៃទៀតដោយមិនគិតដល់ថាតើសិទ្ធិទាំងនោះអាច ផ្ទេរឬអាចបំបែកបានពីអង្គភាព ឬពីសិទ្ធិនិងកាតព្វកិច្ចដទៃទៀតនោះទេ។

១៨.៣ ទ្រព្យសកម្មអរូបិយ រួមមាន ៖

(ក) ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ

(ខ) សិទ្ធិលើធនធានរ៉ែ និងទុនបម្រុងលើធនធានរ៉ែ ដូចជា ប្រេង ឧស្ម័នធម្មជាតិ និងធនធានមិនកើតឡើងវិញ ផ្សេងទៀត។

### ការទទួលស្គាល់

#### គោលការណ៍ទូទៅនៃការទទួលស្គាល់ទ្រព្យសកម្មអរូបិយ

១៨.៤ អង្គ ភាពត្រូវអនុវត្តតាមលក្ខខណ្ឌទទួលស្គាល់ដែលមានចែងក្នុងកថាខណ្ឌ២.២៧ ក្នុងការកំណត់ថាតើត្រូវទទួល ស្គាល់ទ្រព្យសកម្មអរូបិយយ៉ាងម៉េច។ ដូចនេះ អង្គភាពត្រូវទទួលស្គាល់នូវទ្រព្យសកម្មអរូបិយ ថាជាទ្រព្យសកម្ម មួយ ប្រសិនបើ និង ក្នុងករណីបើ ៖

(ក) វាគួឲ្យជឿជាក់ថា អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលបានរំពឹងទុករបស់វានាពេលអនាគតលើទ្រព្យសកម្ម នឹងហូរចូលអង្គភាព

(ខ)ថ្លៃដើម ឬតម្លៃរបស់ទ្រព្យសកម្ម អាចត្រូវបានចវាស់វែងគួរឲ្យទុកចិត្តបាន និង

(គ)ទ្រព្យសកម្មមិនបានមកពីការចំណាយដែលកើតមានផ្ទៃក្នុងអង្គភាពលើធាតុអរូបិយនោះ។

១៨.៥ អង្គភាពត្រូវធ្វើការវាយតម្លៃភវនីយភាពនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានរំពឹងទុកនាពេលអនាគត ដោយប្រើការសន្មត់សមស្របនិងអាចទទួលយកបាន ដែលបង្ហាញឲ្យឃើញនូវការប៉ាន់ស្មានដ៏ល្អរបស់អ្នកគ្រប់គ្រងលើលក្ខខណ្ឌសេដ្ឋកិច្ចដែលនឹងមានក្នុងជីវិតនៃការប្រើប្រាស់របស់ទ្រព្យសកម្ម។

១៨.៦ អង្គភាពមួយប្រើការវិនិច្ឆ័យដើម្បីប៉ាន់ស្មានកម្រិតនៃភាពច្បាស់លាស់ដែលភ្ជាប់ទៅនឹងលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលអាចទាក់ទាញឲ្យមានការប្រើប្រាស់នូវទ្រព្យសកម្មដោយផ្អែកលើភស្តុតាងដែលមាននៅពេលនៃការទទួលស្គាល់ដំបូង ដោយមានការផ្តល់ទំងន់ដ៏ខ្លាំងចំពោះភស្តុតាងពីខាងក្រៅ។

១៨.៧ លក្ខណៈវិនិច្ឆ័យក្នុងការទទួលស្គាល់ភវនីយភាពក្នុងកថាខណ្ឌ ១៨.៤(ក) តែងតែត្រូវបានចាត់ទុកគ្រប់គ្រាន់សម្រាប់ទ្រព្យសកម្មអរូបិយ ដែលបានទទួលដាច់ដោយឡែកពីគ្នា។

### ការទទួលបានជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្ម

១៨.៨ ទ្រព្យសកម្មអរូបិយដែលទទួលបានតាម ការរួមបញ្ចូលអាជីវកម្ម ជាធម្មតាត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មពីព្រោះតម្លៃទីផ្សាររបស់វាអាចត្រូវបានវាស់វែងជាមួយភាពទុកចិត្តគ្រប់គ្រាន់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ទ្រព្យសកម្មអរូបិយដែលទទទយលបានតាមការរួមបញ្ចូលអាជីវកម្មមិនត្រូវបានទទួលស្គាល់ នៅពេលដែលវាកើតមានពីសិទ្ធិតាមផ្លូវច្បាប់ ឬសិទ្ធិតាមកិច្ចសន្យា ហើយតម្លៃទីផ្សាររបស់វាមិនអាវាស់វែងបានគួរឲ្យទុកចិត្តព្រោះទ្រព្យសកម្មអាច ÷

(ក)មិនអាចញែកដាច់ពី មូលនិធិពាណិជ្ជកម្ម និងទាំង

(ខ)អាចញែកដាច់ពីមូលនិធិពាណិជ្ជកម្ម ប៉ុន្តែមិនមានប្រវត្តិឬភស្តុតាងនៃការប្រែប្រួលប្រតិបត្តិការសម្រាប់ទ្រព្យសកម្មដូចគ្នា ឬប្រហាក់ប្រហែល ហើយផ្ទុយមកវិញ ការប៉ាន់ស្មានតម្លៃទីផ្សារអាចអាស្រ័យដោយអថេរដែលមិនអាចវាស់វែងបាន។

### ការវាស់វែងដំបូង

១៨.៩ អង្គ ភាពត្រូវវាស់វែងទ្រព្យសកម្មអរូបិយជាដំបូងតាមថ្លៃដើមរបស់វា។

### ការទទួលបានដាច់ដោយឡែក

១៨.១០ ថ្លៃដើមរបស់ទ្រព្យសកម្មអរូបិយដែលទទួលបានដាច់ដោយឡែក មាន ÷

(ក)ថ្លៃទិញរបស់វា រួមទាំងពន្ធគយ និងពន្ធលើការទិញដែលមិនអាចទទួលមកវិញបាន បន្ទាប់ពីកាត់កងជាមួយ

អប្បហាពាណិជ្ជកម្មនិងការចុះថ្លៃ និង

(ខ) ថ្លៃដើមរួមផ្សំដោយផ្ទាល់នានាសម្រាប់រៀបចំទ្រព្យសកម្មសម្រាប់ប្រើប្រាស់តាមគោលបំណង។

### ការទទួលបានជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្ម

១៨.១១ ប្រសិនបើទ្រព្យសកម្មអរូបិយ ត្រូវបានទទួលតាមការរួមបញ្ចូលអាជីវកម្ម ថ្លៃដើមនៃទ្រព្យសកម្មអរូបិយ គឺជាតម្លៃទីផ្សាររបស់វានាកាលបរិច្ឆេទទទួលបាន។

### ការទទួលបានតាមមធ្យោបាយអំណោយរបស់រដ្ឋាភិបាល

១៨.១២ ប្រសិនបើទ្រព្យសកម្មអរូបិយត្រូវបានទទួលតាមរយៈ អំណោយរបស់រដ្ឋាភិបាល ថ្លៃដើមនៃទ្រព្យនោះ គឺជាតម្លៃទីផ្សាររបស់វានាកាលបរិច្ឆេទដែលអំណោយនោះត្រូវបានទទួល ឬនឹងអាចទទួលបាន ស្របតាមផ្នែកទី ២៤ ស្តីពី អំណោយរបស់រដ្ឋាភិបាល ។

### ការដោះដូរទ្រព្យសកម្ម

១៨.១៣ ទ្រព្យសកម្មអរូបិយអាចត្រូវបានទទួលតាមការផ្តោះប្តូរជាមួយទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬទ្រព្យសកម្ម, ឬការបញ្ចូលគ្នារវាងទ្រព្យសកម្មរូបិយវត្ថុនិងមិនមែនរូបិយវត្ថុ។ អង្គភាពត្រូវវាស់វែងថ្លៃដើមនៃទ្រព្យសកម្មអរូបិយនេះតាមតម្លៃទីផ្សារ វាលែងតែ (ក)- ប្រតិបត្តិការផ្តោះប្តូរខ្វះនូវសារជាតិពាណិជ្ជកម្ម ឬ (ខ)- តម្លៃទីផ្សារនៃទ្រព្យសកម្មដែលទទួលបាននិងទាំងទ្រព្យសកម្មដែលបោះបង់ចោលមិនអាចវាស់វែងបានគួរឲ្យទុកចិត្ត។ ករណីនេះ ថ្លៃដើមនៃទ្រព្យសកម្ម ត្រូវបានវាស់វែងតាម តម្លៃក្នុងបញ្ជី នៃទ្រព្យសកម្មដែលបានបោះបង់ចោល។

### ទ្រព្យសកម្មអរូបិយដែលកើតឡើងផ្ទៃក្នុង

១៨.១៤ អង្គភាពត្រូវទទួលស្គាល់ចំណាយដែលកើតឡើងផ្ទៃក្នុងលើធាតុអរូបិយ រួមបញ្ចូលទាំងចំណាយទាំងអស់សម្រាប់ទាំងសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍ ថាជាចំណាយ នៅពេលដែលវាបានកើតឡើង វាលែងតែ វាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្មដទៃទៀត ដែលបំពេញលក្ខខណ្ឌទទួលស្គាល់ក្នុងស្តង់ដានេះ។

១៨.១៥ ជាឧទាហរណ៍នៃការអនុវត្តកថាខណ្ឌមុនៗ អង្គ ភាពត្រូវទទួលស្គាល់ចំណាយលើធាតុនានាខាងក្រោម ថាជាចំណាយ និងមិនត្រូវទទួលស្គាល់ការចំណាយថាជាទ្រព្យសកម្មអរូបិយ ÷

(ក) ស្លាកយីហោដែលបង្កើតឡើងដោយផ្ទៃក្នុង ស្លាកសញ្ញា សិទ្ធិនៃការបោះផ្សាយ បញ្ជីអតិថិជន និងធាតុប្រហាក់ប្រហែលសំខាន់ៗ។

(ខ) សកម្មភាពចាប់ផ្តើម (ដូចជា ថ្លៃដើមចាប់ផ្តើម) ដែលរួមមានថ្លៃដើមបង្កបង្កើត ដូចជា ថ្លៃដើមខាងច្បាប់និងកិច្ចការលេខាធិការ ដែលបានកើតឡើងក្នុងការបង្កើតអង្គភាពតាមផ្លូវច្បាប់ ចំណាយក្នុងការបើករោងចក្រ ឬ

អាជីវកម្មថ្មី (ដូចជា ថ្លៃដើមមុនបើកដំណើការ) និងចំណាយសម្រាប់ចាប់ប្រតិបត្តិការថ្មី ឬចាប់ផ្តើមបង្ហាញផលិតផលឬដំណើរការថ្មី (ដូចជា ថ្លៃដើមបើកដំណើការដំបូង)។

(គ) សកម្មភាពបណ្តុះបណ្តាល។

(ឃ) សកម្មភាពផ្សព្វផ្សាយនិងផ្សាយពាណិជ្ជកម្ម។

(ង) ការរៀបចំទីតាំង ឬការរៀបចំផ្នែកឬអង្គភាពទាំងមូលឡើងវិញ។

(ច) មូលនិធិពាណិជ្ជកម្មដែលបង្កើតឡើងផ្ទៃក្នុង។

១៨.១៦ កថាខណ្ឌ១៨.១៥មិនបានរារាំងការទទួលស្គាល់ការចំណាយមួយថាជាទ្រព្យសកម្ម នៅពេលដែលការចំណាយលើទំនិញឬសេវាត្រូវបានធ្វើឡើងមុនដឹកជញ្ជូនទំនិញឬការផ្តល់សេវាកម្ម។

## ចំណាយពីអតីតកាលដែលមិនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្ម

១៨.១៧ ចំណាយលើធាតុអរូបិយមួយដែលត្រូវបានទទួលស្គាល់ដំបូងថាជាចំណាយមិនត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទក្រោយមកថាជាថ្លៃដើមទ្រព្យសកម្មនោះទេ។

## ការវាស់វែងបន្ទាប់ពីការទទួលស្គាល់

១៨.១៨ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មអរូបិយ ដោយយកថ្លៃដើមដករំលស់បូកយោងនានា និងដក ការខាតបង់ដោយការថយចុះតម្លៃបូកយោងនានា ។

## ការរំលស់ក្នុងកំឡុងជីវិតនៃការប្រើប្រាស់

១៨.១៩ សម្រាប់គោលបំណងនៃស្តង់ដានេះ រាល់ទ្រព្យសកម្មអរូបិយទាំងអស់ត្រូវបានចាត់ទុកថាមានអាយុកាលប្រើប្រាស់មានកំណត់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយមួយដែលកើតពីសិទ្ធិតាមផ្លូវច្បាប់ ឬកើតពីសិទ្ធិតាមកិច្ចសន្យាមិនត្រូវលើសពីកាលបរិច្ឆេទនៃសិទ្ធិតាមផ្លូវច្បាប់ ឬសិទ្ធិតាមកិច្ចសន្យា ប៉ុន្តែអាចមានរយៈពេលខ្លីអាស្រ័យដោយកាលបរិច្ឆេទដែលអង្គភាពរំពឹងថានឹងប្រើប្រាស់ទ្រព្យសកម្មនោះ។ ប្រសិនបើសិទ្ធិតាមកិច្ចសន្យាឬសិទ្ធិតាមផ្លូវច្បាប់ដទៃទៀត ត្រូវបានផ្ទេរក្នុងរយៈពេលកំណត់មួយ ដែលអាចត្រូវបានធ្វើឡើងវិញ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយត្រូវបញ្ចូលកាលបរិច្ឆេទធ្វើឡើងវិញ តែប្រសិនបើមានភស្តុតាងគាំទ្រដល់ការធ្វើឡើងវិញដោយអង្គភាពដោយគ្មានថ្លៃដើមចាំបាច់។

១៨.២០ ប្រសិនបើអង្គភាពមិនអាចធ្វើការប៉ាន់ស្មានគួរឲ្យទុកចិត្តលើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយ អាយុកាលត្រូវបានសន្មត់ ១០ ឆ្នាំ។

### រយៈពេលដករំលស់ និងវិធីសាស្ត្ររំលស់

១៨.២១ អង្គភាពត្រូវធ្វើវិភាជបរិមាណទឹកប្រាក់ដករំលស់លើទ្រព្យសកម្មអរូបិយ តាមមូលដ្ឋានជាប្រព័ន្ធក្នុងកំឡុងអាយុកាលប្រើប្រាស់។សោហ៊ុយរំលស់សម្រាប់ការិយបរិច្ឆេទនីមួយៗ ត្រូវបានទទួលស្គាល់ថាជាចំណាយ វាលែងតែផ្នែកផ្សេងទៀតរបស់ស្តង់ដារនេះតម្រូវឲ្យថ្លៃដើមត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្ម ដូចជា សន្និធិនៃទ្រព្យ រោងចក្រ និងបរិក្ខា។

១៨.២២ ការរំលស់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្មអរូបិយ អាចយកទៅប្រើប្រាស់បាន ដូចជា ពេលដែលវាត្រូវបានយកដល់ទីកន្លែងនិងស្របតាមលក្ខខណ្ឌចាំបាច់របស់វាអាចប្រើតាមការការចង់បានរបស់អ្នកគ្រប់គ្រង។ ការរំលស់ត្រូវផ្អាក នៅពេលដែលទ្រព្យសកម្មឈប់ត្រូវបានទទួលស្គាល់។ អង្គភាពត្រូវជ្រើសរើសវិធីសាស្ត្ររំលស់ដែលបង្ហាញអំពីគំរូដែលក្នុងនោះអង្គភាពអាចអាស្រ័យលើផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់ទ្រព្យសកម្មនាពេលអនាគត។ប្រសិនបើអង្គភាពមិនអាចកំណត់គំរូនោះគួឲ្យទុកចិត្តបាន អង្គ ភាពត្រូវប្រើវិធីសាស្ត្រដករំលស់ថេរ។

### តម្លៃសំណល់

១៨.២៣អង្គភាពត្រូវសន្មត់ថា តម្លៃដែលនៅសល់ របស់ទ្រព្យសកម្មអរូបិយស្មើនឹងសូន្យ វាលែងតែ ÷

(ក)មានកិច្ចសន្យាពីសំណាក់តតិយជនក្នុងការទិញទ្រព្យសកម្មនាចុងអាយុកាលប្រើប្រាស់របស់វា ឬ

(ខ)មានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ហើយ ÷

១- តម្លៃដែលនៅសល់អាចត្រូវបានកំណត់ដោយផ្អែកលើទីផ្សារនោះ និង

២- វាប្រហែលថាទីផ្សារនោះនឹងមាននាចុងអាយុកាលប្រេប្រាស់របស់ទ្រព្យសកម្ម។

### ការត្រួតពិនិត្យឡើងវិញលើការិយបរិច្ឆេទការរំលស់ និងវិធីសាស្ត្ររំលស់

១៨.២៤ កត្តានានា ដូចជា ការប្រែប្រួលនៃវិធីប្រើទ្រព្យសកម្មអរូបិយ ការប្រែប្រួលនៃការជឿនលឿននៃបច្ចេកវិទ្យា និងការប្រែប្រួលលើថ្លៃទីផ្សារអាចបង្ហាញថាតម្លៃដែលនៅសល់ឬអាយុកាលប្រើប្រាស់ទ្រព្យសកម្មអរូបិយត្រូវបានប្រែប្រួល ក្នុងកំឡុងកាលបរិច្ឆេទរាយការណ៍ប្រចាំឆ្នាំថ្មីៗបំផុត។ប្រសិនបើសុច្ចនករនេះកើតមាន អង្គភាពត្រូវត្រួតពិនិត្យឡើងវិញលើការប៉ាន់ស្មានមុនៗរបស់ខ្លួន ហើយត្រូវកែប្រែតម្លៃដែលនៅសល់ កែប្រែវិធីសាស្ត្ររំលស់ ឬអាយុកាលប្រើប្រាស់ ប្រសិនបើការបាន់ស្មានបច្ចុប្បន្នខុសគ្នា។អង្គភាពត្រូវចាត់ទុកការប្រែប្រួលលើតម្លៃដែលនៅសល់ កែប្រែវិធីសាស្ត្ររំលស់ឬអាយុកាលប្រើប្រាស់ថាជាការប្រែប្រួលលើ ការប៉ាន់ស្មានគណនេយ្យ ស្របតាមកថាខណ្ឌ ១០.១៥-១០.១៨។

ការស្តារឡើងវិញនៃតម្លៃក្នុងបញ្ជី - ការខាតបង់ដោយសារការថយចុះតម្លៃ

១៨.២៥ដើម្បីកំណត់ថាតើទ្រព្យសកម្មអរូបិយមួយត្រូវបានថយចុះតម្លៃ អង្គភាពត្រូវអនុវត្តផ្នែកទី ២៧។ ផ្នែកនោះពន្យល់ថាតើអង្គភាពត្រួតពិនិត្យឡើងវិញលើតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មរបស់ខ្លួនពេលណានិងយ៉ាងដូចម្តេច តើអង្គភាពកំណត់នូវបរិមាណទឹកប្រាក់ដែលអាចស្តារឡើងវិញ របស់ទ្រព្យសកម្មយ៉ាងដូចម្តេច ហើយតើនៅពេលណាអង្គភាពទទួលស្គាល់ ឬបដិសេធមិនទទួលស្គាល់ការខាតបង់ដោយសារការថយចុះតម្លៃ។

ភាពហួសសម័យ និងការលក់បញ្ចេញចោល

១៨.២៦ អង្គភាពត្រូវឈប់ទទួលស្គាល់ទ្រព្យសកម្មអរូបិយ និងត្រូវទទួលស្គាល់ចំណេញ ឬខាតក្នុងចំណេញ ឬខាត ÷

(ក)ពេលលក់បញ្ចេញចោល ឬ

(ខ)នៅពេលដែលលែងមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតត្រូវបានរំពឹងថាមិនមានពីការប្រើប្រាស់វាឬពីការលក់បញ្ចេញចោល។

ការលាតត្រដាងព័ត៌មាន

១៨.២៧ អង្គភាពត្រូវលាតត្រដាងព័ត៌មានសម្រាប់ចំណាត់ថ្នាក់និមួយៗនៃទ្រព្យសកម្មអរូបិយ ដូចខាងក្រោម ÷

(ក) អាយុកាលប្រើប្រាស់ និង អត្រារំលស់ដែលបានប្រើប្រាស់។

(ខ) វិធីសាស្ត្ររំលស់ដែលបានប្រើ។

(គ)តម្លៃពិតគណនេយ្យសរុប និងរំលស់បូកយោងនានា (ដោយសរុបជាមួយផលបូក នូវការខាតបង់ដែលបាត់ទៅ)នៅដើម និង នៅចុងការិយបរិច្ឆេទរាយការណ៍។

(ឃ)ធាតុពាក់ព័ន្ធដទៃទៀតនៅក្នុងរបាយការណ៍លទ្ធផលសរុប(និងនៅក្នុងរបាយការណ៍ចំណេញ-ខាត ប្រសិនបើត្រូវបានបង្ហាញ) ដែលត្រូវបញ្ចូលនូវរំលស់លើ ទ្រព្យសកម្មអរូបិយដែលកើតមានឡើង។

(ង)ការផ្ទៀងផ្ទាត់តម្លៃពិតគណនេយ្យនៅដើម និង ចុងការិយបរិច្ឆេទរាយការណ៍ ដោយបង្ហាញដាច់ដោយឡែកនូវ ÷

១) ធាតុបន្ថែមផ្សេងៗ

២)ការ ដកចេញ

៣) ការទទួលបាន ឬលទ្ធកម្ម តាមរយៈការរួមបញ្ចូលអាជីវកម្ម

៤) ការដករំលស់

៥) ការខាតបង់ដែលនាំឲ្យចុះតម្លៃ

៦) ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់នេះ មិនចាំបាច់បង្ហាញទេសម្រាប់ការិយបរិច្ឆេទមុនៗ។

១៨.២៨ អង្គភាពមួយត្រូវលាតត្រាងព័ត៌មានផងដែរនូវ ÷

(ក)ការពិពណ៌នា តម្លៃពិតគណនេយ្យ និង ការិយបរិច្ឆេទរំលស់ដែលនៅសល់របស់ ទ្រព្យសកម្មអរូបិយនីមួយៗ ដោយឡែកពីគ្នា ដែលចាំបាច់សម្រាប់របាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាព។

(ខ)ចំពោះទ្រព្យសកម្មអរូបិយដែលទទួលបានតាមរយៈអំណោយរបស់រដ្ឋាភិបាល ហើយដែលត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃទីផ្សារ (មើលកឋាខណ្ឌទី ១៨.១២) ÷

១-តម្លៃទីផ្សារដែលត្រូវបានទទួលស្គាល់ដំបូងសម្រាប់ទ្រព្យទាំងនោះ និង

២-តម្លៃពិតគណនេយ្យរបស់វា។

(គ)អត្ថិភាពនិងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មអរូបិយដែលអង្គភាពបានកំណត់កម្មសិទ្ធិដល់វាឬ ដែលបានសន្យាទុកជាធានាបំណុល។

(ឃ) បរិមាណនៃចំណាយតាមកិច្ចសន្យា ក្នុងការទទួលបាននូវទ្រព្យសកម្មអរូបិយ។

១៨.២៩ អង្គភាពត្រូវលាតត្រដាងព័ត៌មានអំពីចំនួនសរុបនៃចំណាយលើការស្រាវជ្រាវនិងការអភិវឌ្ឍដែលត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងកំឡុងការិយបរិច្ឆេទ (ដូចជា បរិមាណនៃចំណាយ ដែលកើតមានខាងក្នុងលើធាតុអរូបិយនានា ដែលមិនត្រូវបានគិតគូរថាជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្មផ្សេងទៀត ស្របតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ក្នុងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ)។

## ផ្នែកទី១៩
## ការបញ្ចូលអាជីវកម្មរួមគ្នា និង មូលនិធិពាណិជ្ជកម្ម

វិសាលភាពនៃផ្នែកនេះ

១៩.១ ផ្នែកនេះអនុវត្តចំពោះគណនេយ្យកម្មសម្រាប់កា**ការបញ្ចូលអាជីវកម្មរួមគ្នា** ស្តង់ដារនេះផ្តល់ការណែនាំពីការកំណត់អង្គភាពអ្នកទិញវាស់វែងថ្លៃដើមនៃការបញ្ចូលអាជីវកម្មរួមគ្នានិងការបែងចែកថ្លៃដើមនោះ ទៅទ្រព្យសកម្មដែលបានទិញ និង បំណុល និង សំវិធានធន សម្រាប់ **បំណុលយថាហេតុ** ដែលបានសន្មត។ អង្គភាព ក៏បង្ហាញពីគណនេយ្យកម្មសម្រាប់កេរ្តិ៍ឈ្មោះទាំងពេលវេលានៃការបញ្ចូលអាជីវកម្មរួមគ្នា និងឆ្នាំបន្តបន្ទាប់។

១៩.២ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នាលើកលែង:

(ក) ការបញ្ចូលអង្គភាពឬអាជីវកម្មក្រោមការគ្រប់គ្រងរួម។ការគ្រប់គ្រងរួមមានន័យថា រាល់អង្គភាពឬ អាជីវកម្មបញ្ចូលគ្នាត្រូវបានគ្រប់គ្រងចុងក្រោយដោយភាគីដូចគ្នាទាំងមុននិងក្រោយការបញ្ចូលអាជីវកម្ម ហើយការគ្រប់គ្រងនោះមិនមានអន្តរកាលទេ។

(ខ) ការបង្កើតក្រុមហ៊ុនរួមទុន។

(គ) ការទិញក្រុមទ្រព្យសកម្មដែលមិនបង្កើតអាជីវកម្ម។

និយមន័យនៃការរួមបញ្ចូលអាជីវកម្ម

១៩.៣ **ការបញ្ចូលអាជីវកម្មរួមគ្នា**គឺជាបញ្ចូលអង្គភាពឬអាជីវកម្មដោយឡែកៗទៅជាអង្គភាពរាយការណ៍តែមួយ។ លទ្ធផលនៃការបញ្ចូលអាជីវកម្មស្ទើរតែទាំងអស់គឺជាអង្គភាពមួយ អ្នកទិញ ដែលទទួលបានគ្រប់គ្រងអាជីវកម្មមួយឬច្រើនទៀត អ្នកលក់។ ថ្ងៃទិញគឺថ្ងៃដែលអ្នកទិញទទួលបានការគ្រប់ គ្រងត្រឹមត្រូវលើអ្នកលក់។

១៩.៤ ការបញ្ចូលអាជីវកម្មអាចត្រូវបានរៀបចំតាមវិធីផ្សេងគ្នាសម្រាប់ ហេតុផលច្បាប់ ពន្ធដារ ឬ ហេតុផលផ្សេងទៀត។អង្គភាពអាចជាប់ពាក់ព័ន្ធនឹងការទិញដោយអង្គភាពនូវដើមទុនរបស់អង្គភាពមួយទៀត ការទិញនៃទ្រព្យសកម្មសុទ្ធ របស់អង្គភាពមួយទៀត ការសន្មតនៃបំណុលរបស់អង្គភាព ឬ ការទិញផ្នែកខ្លះនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាព មួយទៀតដែលរួមគ្នាបង្កើតអាជីវកម្មមួយឬច្រើន។

១៩.៥ ការរួមបញ្ចូលអាជីវកម្មរួមគ្នាអាចមានប្រសិទ្ធិភាពដោយការបោះផ្សាយឧបករណ៍ដើមទុន ការផ្ទេរសាច់ប្រាក់សាច់ប្រាក់សមមូល ឬ ទ្រព្យសកម្មផ្សេងទៀត ឬក៏បញ្ចូលគ្នា។ ប្រតិបត្តិការអាច កើតឡើងរវាងម្ចាស់ភាគហ៊ុននៃអង្គភាពបញ្ចូលគ្នាឬរវាងអង្គភាពមួយ និង ភាគហ៊ុននៃអង្គភាពមួយទៀត។អង្គភាពអាចជាប់ទាក់ទិននឹងការបង្កើតនូវអង្គភាពថ្មីមួយដើម្បីគ្រប់គ្រងអង្គភាពបញ្ចូលគ្នា ឬទ្រព្យសកម្មសុទ្ធដែលបានផ្ទេរ ឬ ការរុះរើរចនាសម្ព័ន្ធនៃអង្គភាពមួយឬច្រើន។

**វិធីគណនេយ្យ**

១៩.៦ ការបញ្ចូលអាជីវកម្មទាំងអស់ត្រូវបានធ្វើគណនេយ្យកម្មដោយអនុវត្តវិធីសាស្ត្រទិញ។

១៩.៧ ដោយអនុវត្តវិធីសាស្ត្រទិញទាក់ទងនឹងជំហានមួយចំនួនដូចខាងក្រោមៈ

(ក) កំណត់អ្នកទិញ

(ខ) វាស់វែងថ្លៃបញ្ចូលអាជីវកម្មរួមគ្នា

(គ) នៅថ្ងៃទិញ បែងចែកថ្លៃនៃការបញ្ចូលអាជីវកម្មរួមគ្នាទៅទ្រព្យសកម្មដែលបានទិញនិង បំណុល និង សំវិធានធនសម្រាប់បំណុលយថាហេតុដែលបានសន្មត។

**ការកំណត់ពីអ្នកទិញ**

១៩.៨ អ្នកទិញត្រូវមានកំណត់សម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នា។ អ្នកទិញគឺជាអង្គភាពបញ្ចូលគ្នាដែលទទួលបាន ការគ្រប់គ្រងនៃអង្គភាពឬអាជីវកម្មបញ្ចូលរួមគ្នាផ្សេងទៀត។

១៩.៩ ការគ្រប់គ្រងគឺជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់អង្គភាព ដើម្បីទទួល បានអត្ថប្រយោជន៍ពីសកម្មភាព។ការគ្រប់គ្រងរបស់អង្គភាពមួយដោយអង្គភាព មួយទៀតត្រូវបានពិពិណនាក្នុង ផ្នែកទី៩ *របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។*

១៩.១០ ទោះបីអង្គភាពពេលខ្លះអាចលំបាកដើម្បីកំណត់ពីអ្នកទិញ ធម្មតាមានសញ្ញាមួយចំនួនដែល អាចកើតឡើងៈ

(ក) ប្រសិនបើ**តម្លៃសមស្រប**នៃអង្គភាពបញ្ចូលគ្នាធំជាងតម្លៃនៃអង្គភាពបញ្ចូលគ្នាមួយទៀត អង្គភាពដែលមាន តម្លៃសបស្រេបធំជាងគឺជាអ្នកទិញ។

(ខ) ប្រសិនបើការបញ្ចូលអាជីវកម្មចូលជាធរមានតាមរយៈនៃការដោះដូរនៃឧបករណ៍ទុនធម្មតា ដែលបោះឆ្នោត បានសម្រាប់សាច់ប្រាក់ឬទ្រព្យសកម្មផ្សេងទៀត អង្គភាពបានចំណាយសាច់ប្រាក់ ឬ ទ្រព្យសកម្មផ្សេងទៀតគឺជា អ្នកទិញ។

(គ) ប្រសិនបើការបញ្ចូលអាជីវកម្មកើតមានក្នុងការគ្រប់គ្រងនៃអង្គភាពបញ្ចូលអាជីវកម្មអាចមានលទ្ធភាពត្រួត ត្រាការជ្រើសរើសក្រុមគណៈគ្រប់គ្រងនៃអង្គភាពដែលបានបញ្ចូល អង្គភាពដែលគណៈគ្រប់គ្រងអាច មាន លទ្ធភាពត្រួតត្រាគឺជាអ្នកទិញ។

**ចំណាយនៃការបញ្ចូលអាជីវកម្មរួមគ្នា**

១៩.១១ អ្នកទិញត្រូវវាស់វែងចំណាយនៃការបញ្ចូលអាជីវកម្មរួមគ្នាជាតម្លៃសរុបនៃៈ

(ក) នៅថ្ងៃដោះដូរ តម្លៃសមស្របនៃទ្រព្យសកម្មដែលបានផ្តល់ បំណុលដែលបានកើតឡើងឬសន្មត និង ឧបករណ៍ដើមទុនដែលបានបោះផ្សាយដោយអ្នកទិញ ជាការដោះដូរសម្រាប់ ការគ្រប់គ្រងអ្នកទិញ បូកនឹង

(ខ) ចំណាយណាមួយដែលចូលរួមដោយផ្ទាល់ចំពោះការបញ្ចូលអាជីវកម្មរួមគ្នា។

ការកែសម្រួលចំពោះចំណាយនៃការបញ្ចូលអាជីវកម្មរួមគ្នាដែលយថាហេតុលើព្រឹត្តិការណ៍អនាគត

១៩.១២ នៅពេលកិច្ចព្រមព្រៀងបញ្ចូលអាជីវកម្មផ្តល់ឲ្យមានការកែសម្រួលចំពោះចំណាយនៃការបញ្ចូលអាជីវកម្មយថាហេតុលើព្រឹត្តិការណ៍អនាគត អ្នកទិញត្រូវបញ្ចូលនូវចំនួនទឹកប្រាក់ប៉ាន់ស្មាននៃការកែសម្រួលនៅក្នុងចំណាយនៃការបញ្ចូលអាជីវកម្មនៅថ្ងៃទិញប្រសិនបើការកែសម្រួលមានភាពប្រហែល និងអាចធ្វើការវាស់វែងដោយជឿជាក់។

១៩.១៣ ប៉ុន្តែ ប្រសិនបើការកែសម្រួលដែលមានសក្តានុពលមិនត្រូវបានទទួលស្គាល់នៅថ្ងៃទិញ ប៉ុន្តែឆ្នាំបន្តបន្ទាប់មានភាពប្រហែលនិងអាចវាស់វែងបានដោយជឿជាក់ នោះការតបស្នងបន្ថែមនឹងត្រូវបានទទួលស្គាល់ជាការកែសម្រួលចំពោះចំណាយនៃការបញ្ចូលអាជីវកម្ម។

ការបែងចែកចំណាយនៃការបញ្ចូលអាជីវកម្មរួមគ្នាចំពោះទ្រព្យសកម្មដែលបានទិញនិងបំណុលនិង បំណុលយថាហេតុសន្មត

១៩.១៤ នៅថ្ងៃទិញ អ្នកទិញត្រូវបែងចែកថ្លៃនៃការបញ្ចូលអាជីវកម្មរួមគ្នាដោយទទួលស្គាល់ទ្រព្យសកម្ម និងបំណុលរបស់អ្នកលក់និងសំវិធានធនចំពោះបំណុលយថាហេតុទាំងនោះដែលបំពេញលក្ខខណ្ឌ ទទួលស្គាល់ក្នុងកថាខណ្ឌ១៩.២០តាមតម្លៃសមស្របនៅថ្ងៃនោះ។ បើមានភាពខុសគ្នារវាងថ្លៃនៃការ បញ្ចូលអាជីវកម្មរួមគ្នា និងភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធរបស់ទ្រព្យសកម្ម បំណុល និង សំវិធានធនចំពោះបំណុលយថាហេតុដែលបានទទួលស្គាល់ត្រូវធ្វើគណនេយ្យកម្មដោយអនុលោម តាមកថាខណ្ឌ១៩.២២ ១៩.២៤ (ជាមូលនិធិពាណិជ្ជកម្មឬ ជា មូលនិធិពាណិជ្ជកម្មអវិជ្ជមាន)។

១៩.១៥អ្នកទិញត្រូវទទួលស្គាល់ដាច់ដោយឡែកនូវទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុរបស់ អ្នកលក់នៅថ្ងៃទិញតែក្នុងករណីដែលធាតុទាំងនោះបំពេញលក្ខខណ្ឌខាងក្រោមនៅថ្ងៃនោះ÷

(ក)ក្នុងករណីទ្រព្យសកម្មលើកលែងទ្រព្យសកម្មអរូបី វាមានភាពប្រហែលថាអត្ថប្រយោជន៍ សេដ្ឋកិច្ចអនាគតដែលភ្ជាប់មកជាមួយនឹងហូរទៅអ្នកទិញ ហើយតម្លៃសមស្របរបស់វាអាចវាស់វែងបានដោយជឿជាក់។

(ខ)ក្នុងករណីបំណុលលើកលែងតែបំណុលយថាហេតុ វាមានភាពទំនងថាលំហូរចេញនៃធនធាននឹងត្រូវបានតម្រូវឲ្យទូទាត់កាតព្វកិច្ច ហើយតម្លៃសមស្របរបស់វាអាចវាស់វែងបានដោយជឿជាក់។

(គ) នៅក្នុងករណីទ្រព្យសកម្មអរូបី ឬ បំណុលយថាហេតុ តម្លៃសមស្របអាចត្រូវបានវាស់វែងដោយជឿជាក់។

១៩.១៦របាយការណ៍លទ្ធផលសរុបរបស់អ្នកទិញត្រូវបញ្ចូលប្រាក់ចំណេញនិងខាតរបស់អ្នកលក់ បន្ទាប់ពីថ្ងៃទិញដោយការបញ្ចូលចំណូលនិងចំណាយដែលផ្អែកលើចំណាយនៃការបញ្ចូលអាជីវកម្មរួមគ្នាចំពោះអ្នកទិញ។ ឧទាហរណ៍ ចំណាយរំលស់ដែលបញ្ចូលបន្ទាប់ថ្ងៃទិញក្នុងរបាយការណ៍លទ្ធផលរបស់អ្នកទិញដែល ទាក់ទងនឹងទ្រព្យសកម្មដែលអាចដករំលស់បានរបស់អ្នកលក់ត្រូវផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលអាចដករំលស់បានទាំងនោះនៅថ្ងៃទិញ ពោលគឺចំណាយចំពោះអ្នកទិញ។

១៩.១៧ ការប្រើវិធីសាស្ត្រទិញចាប់ផ្តើមពីថ្ងៃទិញ ជាថ្ងៃដែលអ្នកទិញទទួលបានការគ្រប់គ្រងលើអ្នកលក់។ ពីព្រោះការគ្រប់គ្រងគឺជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់អង្គភាព ឬអាជីវកម្មដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់គេ វាមិនចាំបាច់សម្រាប់ ប្រតិបត្តិការមួយដែលត្រូវបិទ ឬ បញ្ចប់ដោយច្បាប់មុនពេលអ្នកទិញទទួលបានការគ្រប់គ្រង។ ហេតុ ការណ៍ និងសភាពការណ៍សមស្របទាំងអស់ជុំវិញការបញ្ចូលអាជីវកម្មរួមគ្នាត្រូវបានគេពិចារណាក្នុង ការវាយតម្លៃពេលអ្នកទិញបានទទួលការគ្រប់គ្រង។

១៩.១៨ ដោយអនុលោមតាមកថាខណ្ឌ១៩.១៤ អ្នកទិញទទួលស្គាល់ដាច់ដោយឡែកតែទ្រព្យសកម្ម បំណុលនិងបំណុលយថាហេតុរបស់អ្នកលក់ដែលបានកើតឡើងនៅថ្ងៃទិញ និងបំពេញលក្ខខណ្ឌ នៃការទទួលស្គាល់ក្នុងកថាខណ្ឌ ១៩.១៥។ ដូច្នេះ

(ក)អ្នកទិញត្រូវទទួលស្គាល់បំណុលដើម្បីបញ្ឈប់ឬកាត់បន្ថយសកម្មភាពនៃអ្នកលក់ដែលជា ផ្នែកនៃការបែងចែកចំណាយនៃការបញ្ចូលអាជីវកម្មតែពេលអ្នកលក់មានបំណុលបច្ចុប្បន្ន នៅថ្ងៃទិញ សម្រាប់ការរុះរើរចនាសម្ព័ន្ធដែលបានទទួលស្គាល់ដោយអនុលោតាមផ្នែកទី ២១*សំវិធានធន និង យថាហេតុ*និង

(ខ)ពេលដែលបែងចែកចំណាយនៃការបញ្ចូលអាជីវកម្ម អ្នកទិញមិនត្រូវទទួលស្គាល់បំណុល សម្រាប់ការខាតនៅពេលអនាគត ឬចំណាយផ្សេងទៀតដែលបានរំពឹងថានឹងកើតឡើងពីការ បញ្ចូលអាជីវកម្មរួមគ្នា។

១៩.១៩ ប្រសិនបើការធ្វើគណនេយ្យសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នាមិនមានភាពពេញលេញនៅចុងគ្រារាយការណ៍ដែលការបញ្ចូលគ្នាកើតមានឡើង អ្នកទិញត្រូវទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ នូវចំនួនទឹកប្រាក់សម្រាប់ធាតុដែលគណនេយ្យមិនពេញលេញ។ នៅក្នុងរយៈ១២ខែបន្ទាប់ថ្ងៃទិញ អ្នកទិញត្រូវកែសម្រួលត្រឡប់ថយក្រោយនូវចំនួនទឹកប្រាក់សំវិធានធនដែលបានទទួលស្គាល់ជាទ្រព្យសកម្ម និង បំណុលនៅថ្ងៃទិញ (ពោលគឺទទួលស្គាល់ទ្រព្យសកម្ម និង បំណុល ទោះបីជាពួកគេបានកើតឡើង នៅថ្ងៃទិញក៏ដោយ) ដើម្បីឆ្លុះបញ្ចាំងពីព័ត៌មានថ្មីដែលបានទទួល។ ក្រោយពី១២ខែ បន្ទាប់ពីថ្ងៃទិញ ការកែសម្រួលចំពោះការធ្វើគណនេយ្យកម្មសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នាត្រូវបានទទួលស្គាល់តែ ប៉ុណ្ណោះដើម្បីកែកំហុសឆ្គងដោយអនុលោមតាមផ្នែកទី១០ *គោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និង កំហុសឆ្គង*។

បំណុលយថាហេតុ

១៩.២០ កថាខណ្ឌ ១៩.១៤ បញ្ជាក់ថាអ្នកទិញទទួលស្គាល់សំវិធានធនសម្រាប់បំណុលយថាហេតុរបស់ អ្នកលក់ដាច់ដោយឡែកតែក្នុងករណីតម្លៃសមស្របអាចវាស់វែងបានដោយជឿជាក់។ ប្រសិនបើតម្លៃសមស្របមិនអាចវាស់វែងបានៈ

(ក)មានផលប៉ះពាល់លើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ជាមូលនិធិពាណិជ្ជកម្មឬធ្វើគណនេយ្យកម្មដោយអនុលោមតាមកថាខណ្ឌ១៩.២៤ និង

(ខ) អ្នទិញត្រូវលាតត្រដាងបង្ហាញព័ត៌មានអំពីបំណុលយថាហេតុនោះដូចដែលបានតម្រូវដោយ ផ្នែកទី២១ ។

១៩.២១បន្ទាប់ពីការទទួលស្គាល់ដំបូង អ្នកទិញត្រូវវាស់វែងបំណុលយថាហេតុដែលត្រូវបានទទួលស្គាល់ដាច់ដោយឡែកដោយអនុលោមតាមកថាខណ្ឌ១៩.១៤ តាមតម្លៃខ្ពស់ជាងនេះ

(ក) ចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ដោយអនុលោមតាមផ្នែកទី២១ និង

(ខ) ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់លើកដំបូងដកនឹងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ជាចំណូលដោយអនុលោមតាមផ្នែកទី២៣ *ចំណូល។*

មូលនិធិពាណិជ្ជកម្ម

១៩.២២ នៅថ្ងៃទិញ អ្នកទិញត្រូវៈ

(ក) ទទួលស្គាល់មូលនិធិពាណិជ្ជកម្មដែលបានទិញក្នុងការបញ្ចូលអាជីវកម្មរួមគ្នាជាទ្រព្យសកម្ម និង

(ខ)វាស់វែងជាលើកដំបូងនូវមូលនិធិពាណិជ្ជកម្មនោះតាមថ្លៃដើមដែលបានីភាពលើសនៃថ្លៃដើមនៃការចំណាយសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នា លើភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្មបំណុល និង បំណុលយថាហេតុដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ១៩.១៤។

១៩.២៣ បន្ទាប់ពីការទទួលស្គាល់លើកដំបូង អ្នកទិញត្រូវវាស់វែងមូលនិធិពាណិជ្ជកម្មដែលបានទិញក្នុងការបញ្ចូលអាជីវកម្មរួមគ្នាដកនឹងសំវិធានធនបូកបន្ត និង ការខាតដោយការធ្លាក់ចុះតំលៃៈ

(ក) អង្គភាពត្រូវអនុវត្តតាមគោលការណ៍ក្នុងកថាខណ្ឌ១៨.១៩២៨.២៤ សម្រាប់រំលស់មូលនិធិពាណិជ្ជកម្ម ប្រសិនបើអង្គភាពមិនធ្វើការប៉ាន់ស្មានដោយជឿជាក់ពីអាយុកាលមូលនិធិពាណិជ្ជកម្មអាយុកាលត្រូវបានគេសន្មតថាមាន រយៈ១០ឆ្នាំ។

(ខ)អង្គភាពត្រូវអនុវត្តតាមផ្នែកទី២៧ *ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម* សម្រាប់ការទទួលស្គាល់ និង ការវាស់វែងការធ្លាក់ចុះតម្លៃមូលនិធិពាណិជ្ជកម្ម។

អតិរេកលើចំណាយនៃភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុ

១៩.២៤ ប្រសិន ភាគកម្មរបស់អ្នកទិញក្នុងតម្លៃសមស្របសុទ្ធនៃទ្រព្យសកម្ម បំណុល និងសំវិធានធន បំណុលយថាហេតុ ដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ១៩.១៤ លើសចំណាយនៃការ បញ្ចូលអាជីវកម្មរួមគ្នា (ផ្លូលកាលសំដៅទៅលើមូលនិធិពាណិជ្ជកម្មអវត្តមាន) អ្នកទិញត្រូវ:

(ក) វាយតម្លៃឡើងវិញពីអត្តសញ្ញាណ និងវាស់វែងទ្រព្យសកម្ម បំណុល និងសំវិធានធនសម្រាប់បំណុលយថាហេតុរបស់អ្នកលក់ និង វាស់វែងចំណាយនៃការបញ្ចូលគ្នា និង

(ខ) ទទួលស្គាល់ភ្លាមក្នុងរបាយការណ៍ចំណេញ ឬខាតនូវអតិរេកណាដែលមានបន្ទាប់ពីការ វាយតម្លៃនោះ។

## ការលាតត្រដាងព័ត៌មាន

សម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នា ដែលចូលជាធរមានក្នុងគ្រារាយការណ៍

១៩.២៥ សម្រាប់ការបញ្ចូលអាជីវកម្មនីមួយៗដែលបានចូលជាធរមានក្នុងគ្រា អ្នកទិញត្រូវលាតត្រដាង ដូចខាង:

(ក) ឈ្មោះ និង ការរៀបរាប់ពីអង្គភាព ឬ អាជីវកម្មបញ្ចូលគ្នា

(ខ) ថ្ងៃទិញ

(គ) ភាគរយនៃឧបករណ៍ដើមទុនមានសិទ្ធិបោះឆ្នោតដែលបានទិញ

(ឃ) ចំណាយនៃការបញ្ចូលអាជីវកម្ម និង រៀបរាប់នៃសមាសធាតុនៃចំណាយនោះ (ដូចជា សាច់ប្រាក់ ឧបករណ៍ដើមទុន និងឧបករណ៍បំណុល)។

(ង) ចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅថ្ងៃទិញសម្រាប់ថ្នាក់នីមួយៗនៃទ្រព្យសកម្ម បំណុល និង បំណុលយថាហេតុរបស់អ្នកលក់ រួមទាំងមូលនិធិពាណិជ្ជកម្មផង។

(ច) ចំនួនទឹកប្រាក់នៃអតិរេកណាដែលបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ដោយអនុលោមតាមកថាខណ្ឌ ១៩.២៤ និងធាតុនីមួយៗក្នុងរបាយការណ៍លទ្ធផលសរុប (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបានបង្ហាញ) ករណីដែលអតិរេកត្រូវបានទទួលស្គាល់។

សម្រាប់ការរួមបញ្ចូលអាជីវកម្មទាំងអស់

១៩.២៦ អ្នកទិញត្រូវលាតត្រដាងពីការផ្ទៀងផ្ទាត់នៃតម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មនៅដើមគ្រានិងចុងគ្រារាយការណ៍ ដោយបង្ហាញដាច់ដោយឡែកនូវ:

(ក) ការផ្លាស់ប្តូរដែលកើតឡើងពីការរួមបញ្ចូលអាជីវកម្មរួមគ្នាថ្មី

(ខ) ការខាតបង់ដោយសារការធ្លាក់ចុះតម្លៃ

(គ) ការលក់ចោលនៃអាជីវកម្មដែលបានទិញពីមុន

(ឃ) ការប្រែប្រួលផ្សេងទៀត។

ការផ្ទៀងផ្ទាត់មិនចាំបាច់ត្រូវបង្ហាញសម្រាប់គ្រាមុនៗ។

## ផ្នែកទី២០

## ភតិសន្យា

### វិសាលភាពនៃផ្នែកនេះ

២០.១. ផ្នែកនេះគ្របដណ្តប់ការធ្វើគណនេយ្យកម្មភតិសន្យាទាំងអស់ លើកលែងតែៈ

(ក)ភតិសន្យាដើម្បីរុករក ឬប្រើប្រាស់ធនធានរ៉ែ ប្រេង ហ្គាសធម្មជាតិ និង ធនធានមិនបង្កើតឡើងវិញ (សូមមើលផ្នែកទី៣៤ សកម្មពិសេស)

(ខ) កិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណសម្រាប់ធាតុទាំងឡាយ ដូចជា ខ្សែភាពយន្តទស្សនីយភាព ការថតចំលងខ្សែភាពយន្ត ខ្សែភាពយន្ត អត្ថបទសរសេរ ប៉ាតង់ និងកម្មសិទ្ធិបញ្ញា (សូមមើលផ្នែកទី១៨ ទ្រព្យសកម្មអរូបីយលើកលែងមូលនិធិពាណិជ្ជកម្មក្រុមហ៊ុន)។

(គ)ការវាស់វែងទ្រព្យរក្សាទុកដោយភតិកៈដែលត្រូវបានធ្វើគណនេយ្យកម្មជាទ្រព្យវិនិយោគ និង ការវាស់វែងទ្រព្យវិនិយោគផ្តល់ដោយភតិបតីក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលផ្នែកទី១៦ ទ្រព្យវិនិយោគ)។

(ឃ)ការវាស់វែងទ្រព្យជីវសាស្ត្រដែលរក្សាទុកដោយភតិកៈក្រោមភតិសន្យាហិរញ្ញវត្ថុ និង ទ្រព្យជីវសាស្ត្រដែលផ្តល់ដោយភតិបតីក្រោមភតិសន្យាប្រតិបត្តិការ (សូមមើលផ្នែកទី៣៤)

(ង)ភតិសន្យាដែលអាចនាំដល់ការខាតបង់ចំពោះភតិបតី ឬ ភតិកៈដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងដែលមិនពាក់ព័ន្ធនឹងការផ្លាស់ប្តូរតម្លៃទ្រព្យសកម្មដែលបានធ្វើភតិសន្យា ការផ្លាស់ប្តូរអត្រាប្តូរប្រាក់ ឬ ការខូចខាតដោយភាគីណាមួយ (សូមមើលកថា ខណ្ឌ១២.៣(ច)។

(ច) ភតិសន្យាប្រតិបត្តិការដែលមានភាពស្មុគស្មាញ។

២០.២ ផ្នែកនេះអនុវត្តចំពោះកិច្ចព្រមព្រៀងដែលផ្ទេរសិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មទោះបីសេវាកម្មសំខាន់ៗផ្តល់ដោយភតិបតីអាចត្រូវបានស្នើឡើងក្នុងការជាប់ពាក់ពន្ធ័ជាមួយប្រើប្រាស់ឬការថែទាំទ្រព្យសកម្មនោះ។ ផ្នែកនេះមិនអនុវត្តចំពោះកិច្ចព្រមព្រៀងដែលជាកិច្ចសន្យាសម្រាប់សេវាកម្មដែលមិនផ្ទេរសិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មពីភាគីមួយទៅភាគីមួយទៀត។

២០.៣ កិច្ចព្រមព្រៀងខ្លះ ដូចជាកិច្ចព្រមព្រៀងជួលសេវាខាងក្រៅ កិច្ចសន្យាលើសេវាទំនាក់ទំនងដែល ផ្តល់សិទ្ធិលើសមត្ថភាព និង កិច្ចសន្យាទទួលឬទូទាត់ មិនគិតទៅលើទម្រង់ច្បាប់នៃភតិសន្យា ប៉ុន្តែគិតទៅលើការផ្ទេរសិទ្ធិដើម្បីប្រើប្រាស់សិទ្ធិដើម្បីប្រើប្រាស់ទ្រព្យសកម្មជាថ្នូរនៃការទូទាត់សង។កិច្ចព្រមព្រៀងបែបនេះជាភតិសន្យាទ្រព្យសកម្មជាក់ស្តែង និង ទ្រព្យសកម្មនោះត្រូវធ្វើគណនេយ្យកម្មក្រោមផ្នែកនេះ។

២០.៤ ភតិសន្យាត្រូវបានចាត់ថ្នាក់ជា**ភតិសន្យាហិរញ្ញវត្ថុ** ប្រសិនបើភតិសន្យានេះផ្ទេរហានិភ័យ និងផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះកម្មសិទ្ធិ។ ភតិសន្យាត្រូវបានចាត់ថ្នាក់ជា **ភតិសន្យាប្រតិបត្តិការ** ប្រសិនបើ ភតិសន្យានោះមិនផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះកម្មសិទ្ធិ។

២០.៥ ថាតើភតិសន្យាជាភតិសន្យាហិរញ្ញវត្ថុឬភតិសន្យាប្រតិបត្តិការ វាអាស្រ័យលើសារៈសំខាន់នៃ ប្រតិបត្តិការជាជាងទម្រង់នៃកិច្ចព្រមព្រៀង។ ឧទាហរណ៍ចំពោះហេតុការណ៍មួយចំនួន ដែលហេតុការណ៍មួយឬរួមគ្នា ជាធម្មតានាំដល់ភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ គឺៈ

(ក)ភតិសន្យាផ្ទេរកម្មសិទ្ធិនៃទ្រព្យសកម្មទៅឲ្យភតិកៈនៅចុងបញ្ចប់នៃភតិសន្យា។

(ខ)នៅចាប់ផ្តើមធ្វើភតិសន្យាភតិកៈមានសិទ្ធិពិសេសដើម្បីទិញទ្រព្យសកម្មតាមតម្លៃដែលត្រូវបានរំពឹងថានឹងមានតម្លៃ ទាបជាង**តម្លៃទីផ្សារ**នៅកាលបរិច្ឆេទដែលសិទ្ធិពិសេសត្រូវបានគេអនុវត្ត។

(គ)រយៈពេលនៃកិច្ចព្រមព្រៀងមានរយៈពេលភាគច្រើននៃអាយុកាលរបស់ទ្រព្យសកម្ម ទោះបី កម្មសិទ្ធិមិនត្រូវបានគេផ្ទេរឲ្យក៏ដោយ។

(ឃ)នៅពេលធ្វើភតិសន្យា តម្លៃបច្ចុប្បន្ននៃការសងភតិសន្យាអប្បបរមាមានចំនួនស្មើនឹងតម្លៃទីផ្សារនៃទ្រព្យសកម្មដែលបានធ្វើភតិសន្យា។

(ង)ទ្រព្យបានធ្វើភតិសន្យាដែលមានលក្ខណៈពិសេសដែលភតិកៈអាចប្រើទ្រព្យសកម្មនោះ ដោយគ្មានការផ្លាស់ប្តូរផ្នែកសំខាន់ៗ

២០.៦. ឧទាហរណ៍ពីហេតុការណ៍ដែលហេតុការណ៍នីមួយៗ ឬ រួមបញ្ចូលគ្នា អាចនាំឲ្យមានភតិសន្យា ដែលត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ គឺៈ

(ក)ប្រសិនបើភតិកៈអាចលុបចោលភតិសន្យា នោះការខាតបង់របស់ភតិបតីទាក់ទងនឹងការ លុបចោលគឺទទួលខុសត្រូវដោយភតិកៈ។

(ខ)ចំណេញ ឬ ខាត ពីការឡើងចុះ **តម្លៃកាកសំណល់**នៃទ្រព្យសកម្មបានភតិសន្យាបង្ករចំពោះភតិកៈ( ឧ. ក្នុងទម្រង់ការបញ្ចុះតម្លៃជួលស្មើនឹងភាគច្រើននៃចំណូលពីការលក់នៅចុង បញ្ចប់នៃភតិសន្យា)

(គ)ភតិកៈមានលទ្ធភាពបន្តភតិសន្យាសម្រាប់រយៈពេលទី២ ជាការជួលដែលមានតម្លៃទាបច្រើនជាងតម្លៃជួលនៅលើទីផ្សារ។

២០.៧. ឧទាហរណ៍ និងសូចនាករ នៅក្នុងកថាខណ្ឌ ២០.៥ និង ២០.៦ មិនតែងតែច្បាស់លាស់ទេ។ ប្រសិនបើវាមានភាពច្បាស់លាស់ពីលក្ខណៈផ្សេងទៀត នោះភតិសន្យាមិនផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗទាំងអស់ទាក់ទងនឹងកម្មសិទ្ធិ ភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។ ឧទាហរណ៍ នេះអាចជាករណីមួយប្រសិនបើកម្មសិទ្ធិនៃទ្រព្យសកម្មត្រូវបានផ្ទេរទៅឱ្យភតិកៈនៅចុងបញ្ចប់នៃភតិសន្យាសម្រាប់ការទូទាត់អថេរស្មើនឹងតម្លៃទីផ្សារនៃទ្រព្យសកម្ម ឬ ប្រសិនបើមានការជួល យថាហេតុ ជាលទ្ធផលដែលភតិកៈមិនមានហានិភ័យនិងផលប្រយោជន៍សំខាន់ៗទាំងអស់ទាក់ទងនឹងកម្មសិទ្ធិ។

២០.៨ ការចាត់ថ្នាក់ភតិសន្យាត្រូវបានធ្វើឡើងនៅពេលចាប់ផ្តើមធ្វើភតិសន្យា និង មិនផ្លាស់ប្តូរក្នុងកំឡុងពេលភតិសន្យាលុះត្រាតែភតិកៈ និង ភតិបតីយល់ព្រមផ្លាស់កិច្ចព្រមព្រៀងភតិសន្យា (មិនមែន ការបន្តកិច្ចព្រមព្រៀងធម្មតាមនោះទេ)នៅក្នុងករណីនេះ ការចាត់ថ្នាក់ភតិសន្យាត្រូវតែវាយតម្លៃឡើងវិញ។

## របាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈ-ភតិសន្យាហិរញ្ញវត្ថុ

### ការទទួលស្គាល់លើកដំបូង

២០.៩ នៅពេលចាប់ផ្តើមនៃរយៈពេលភតិសន្យា ភតិកៈត្រូវទទួលស្គាល់សិទ្ធិប្រើប្រាស់និងកាតព្វកិច្ច ក្រោមភតិសន្យាហិរញ្ញវត្ថុជាទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមចំនួន ទឹកប្រាក់ស្មើនឹងតម្លៃទីផ្សារនៃទ្រព្យដែលបានធ្វើភតិសន្យា ឬ ប្រសិនបើទាបជាងតម្លៃបច្ចុប្បន្ននៃការ ទូទាត់សងភតិសន្យាអប្បបរមាត្រូវបានកំណត់នៅពេលទទួលយកភតិសន្យាដំបូង។ ចំណាយផ្ទាល់ ដំបូងណាមួយរបស់ភតិកៈ(ចំណាយផ្សេងៗដែលចូលរួមដោយផ្ទាល់ក្នុងការចរចារនិងការរៀបចំភតិសន្យា) ត្រូវបានបញ្ចូលជាតម្លៃទ្រព្យសកម្ម។

២០.១០. តម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាអប្បបរមាត្រូវបានគណនាដោយប្រើអាត្រាការប្រាក់ដែលមានចែងនៅក្នុងភតិសន្យា។ ប្រសិនបើអត្រានេះមិនអាចកំណត់បាន គេអាចប្រើអត្រាខ្ចីប្រាក់របស់ភតិកៈបាន។

### ការវាស់វែងបន្តបន្ទាប់

២០.១១. ភតិកៈត្រូវញែកការទូទាត់ភតិសន្យាអប្បបរមារវាងចំណាយហិរញ្ញវត្ថុនិងការកាត់បន្ថយបំណុលដែលនៅសល់ដោយប្រើ **វិធីសាស្រ្តការប្រាក់មានប្រសិទ្ធិភាព**(សូមមើលកថាខណ្ឌ១១.១៥-១១.២០) ។ ភតិកៈត្រូវបែងចែកចំណាយហិរញ្ញវត្ថុចំពោះការិយបរិច្ឆេទនីមួយៗក្នុងកំឡុងពេលភតិសន្យា ដើម្បីបង្កើតអត្រាការប្រាស់ចុងឆ្នាំថេរលើសមតុល្យបំណុលនៅសល់។ ភតិកៈត្រូវគិតការជួលយថាហេតុ ជាចំណាយនៅក្នុងគ្រាដែលការជួលនោះកើតឡើង។

២០.១២. ភតិកៈត្រូវរំលស់ទ្រព្យសកម្មដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុដោយអនុលោម តាមផ្នែកពាក់ព័ន្ធនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់ប្រភេទទ្រព្យសកម្មនោះ។ឧទាហរណ៍ ផ្នែកទី១៧ ទ្រព្យរោងចក្រ និង បរិក្ខារ ផ្នែកទី១៨ ឬ ផ្នែកទី១៩ ការរួមបញ្ចូលអាជីវកម្ម និង មូលនិធិពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើមិនមានភាពច្បាស់លាស់ដែលថាភតិកៈនឹងទទួលយកកម្មសិទ្ធិនៅចុងបញ្ចប់នៃភតិសន្យា ទ្រព្យសកម្ម

នឹងត្រូវដករំលស់ ពេញលេញលើរយៈខ្លីជាងនៃរយៈភតិសន្យា និង អាយុកាលរបស់វា។ ភតិកៈត្រូវវាយតម្លៃផងដែរនៅកាលបរិច្ឆេទរាយការណ៍នីមួយៗថាតើទ្រព្យសកម្មដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុមាន ការធ្លាក់ចុះតម្លៃឬទេ។ ( សូមមើលផ្នែកទី២៧ *ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម*)។

ការលាតត្រដាងបង្ហាញ

២០.១៣. ភតិកៈត្រូវបង្ហាញដូចខាងក្រោមសម្រាប់ភតិសន្យាហិរញ្ញវត្ថុៈ

(ក) សម្រាប់ថ្នាក់ទ្រព្យសកម្មនីមួយៗ តម្លៃក្នុងបញ្ជីពិតនៅចុងគ្រារាយការណ៍។

(ខ) ទឹកប្រាក់សរុបនៃការទូទាត់ភតិសន្យាអប្បបរមានៅចុងគ្រារាយការណ៍សម្រាប់គ្រាដូចខាងក្រោមៈ

(១) មិនលើសពីមួយឆ្នាំ

(២) លើសពី១ឆ្នាំ និង មិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(គ) ការបរិយាយទូទៅពីកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិកៈរួមមានៈ ឧទាហរណ៍ៈ ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀងឬសិទ្ធិទិញពិសេសនិងខសន្យាសំខាន់ៗ ភតិសន្យាបន្ត និង ការ ដាក់កំហិតដែលបានកំណត់ដោយកិច្ចព្រមព្រៀងភតិសន្យា។

២០.១៤ លើសពីនេះទៅទៀត ការតម្រូវសម្រាប់លាតត្រដាងព័ត៌មានអំពីទ្រព្យសកម្មដោយអនុលោមជាមួយផ្នែកទី១៧ ១៨ ១៩ និងទី៣៤ អនុវត្តចំពោះភតិកៈសម្រាប់ទ្រព្យសកម្មដែលបានធ្វើភតិសន្យាក្រោមភតិសន្យាហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុរបស់ភតិកៈ - ភតិសន្យាប្រតិបត្តិការ

---

ការទទួលស្គាល់ និង ការវាស់វែង

២០.១៥.ភតិកៈត្រូវទទួលស្គាល់ការទូទាត់ភតិសន្យាក្រោមភតិសន្យាប្រតិបត្តិការ( ដកចេញថ្លៃដើមសេវាដូចជាការធានារ៉ាប់រង និងការថែទាំ) ជាចំណាយតាមមូលដ្ឋានថេរ លើកលែងតែៈ

(ក) មូលជាប្រព័ន្ធផ្សេងទៀតតំណាងឲ្យគំរូពេលវេលានៃផលប្រយោជន៍របស់អ្នកប្រើប្រាស់ ទោះបីការទូទាត់មិនអាចផ្អែកលើមូលដ្ឋាននោះបាន ឬ

(ខ) ការទូទាត់ទៅឲ្យភតិបតីត្រូវបានរៀបចំឡើងដើម្បីបង្កើនឲ្យស្របតាមអតិផរមាទូទៅដែលបានរំពឹងទុក (ផ្អែកលើសន្ទស្សន៍ ឬ ស្ថិតិដែលបានផ្សាយ) ដើម្បីតបស្នងសម្រាប់ការចំណាយដែលកើនឡើងដោយសារអតិផរណារបស់ភតិបតី។ ប្រសិនការទូទាត់ទៅឲ្យភតិបតីប្រែប្រួល ដោយសារកត្តាផ្សេងៗក្រៅពីអតិផរណាទូទៅ ដូច្នេះលក្ខ ណ្ឌ (ខ) មិនត្រូវបានបំពេញទេ។

| |
|---|
| ឧទាហរណ៍ ពីការអនុវត្តកថាខណ្ឌទី ២០.១៥ (ខ) |
| X រកស៊ីនៅក្នុងប្រទេសមួយដែលការព្យាករណ៍ស៊ីសង្វាក់គ្នាដោយធនាគារក្នុងស្រុកគឺសន្ទស្សន៍កម្រិតតម្លៃទូទៅ ដូចដែលរដ្ឋាភិបាលបានផ្សាយ នឹងមានការកើនជាមធ្យម១០ភាគរយក្នុងមួយឆ្នាំរយៈពេល៥ឆ្នាំ។ X ធ្វើភតិសន្យាទីកន្លែងធ្វើការខ្លះពីY សម្រាប់រយៈពេល៥ឆ្នាំភតិសន្យាប្រតិបត្តិការ។ ការទូទាត់ភតិសន្យាត្រូវបានរៀបចំដើម្បីឆ្លុះបញ្ចាំងអតិផរណាទូទៅប្រចាំឆ្នាំ១០ភាគរយរយៈពេលភតិសន្យា៥ឆ្នាំដូចខាងក្រោម |
| ឆ្នាំទី១ 100,000 ឯកត្តារូបិយប័ណ្ណ |
| ឆ្នាំទី២ 110,000 ឯកត្តារូបិយប័ណ្ណ |
| ឆ្នាំទី៣ 121,000 ឯកត្តារូបិយប័ណ្ណ |
| ឆ្នាំទី៤ 133,000 ឯកត្តារូបិយប័ណ្ណ |
| ឆ្នាំទី៥ 146,000 ឯកត្តារូបិយប័ណ្ណ |
| X ទទួលស្គាល់ចំណាយជួលប្រចាំឆ្នាំស្មើនឹងចំនួនទឹកប្រាក់ដែលបានជំពាក់ភតិបតីខាងលើ។ ប្រសិនបើការទូទាត់សងមិនច្បាស់លាស់ដើម្បីតបស្នងទៅឱ្យភតិបតីសម្រាប់ការកើនឡើងចំណាយអតិផរណា ដែលផ្អែកលើសន្ទស្សន៍ ឬស្ថិតិដែលបានផ្សាយទេ ដូច្នេះ X ទទួលស្គាល់ចំណាយជួលប្រចាំឆ្នាំតាមមូលដ្ឋាន: 122,000 ឯកត្តារូបិយប័ណ្ណ ឆ្នាំនីមួយៗ(ផលបូកបំណុលទាំងអស់ ចែកនឹង ៥ ឆ្នាំ) ។ |

**ការលាតត្រដាងព័ត៌មាន**

២០.១៦ ភតិកៈត្រូវបង្ហាញនូវព័ត៌មានដូចខាងក្រោមសម្រាប់ភតិសន្យាប្រតិបត្តិ:

(ក) ការទូទាត់ភតិសន្យាសរុបអប្បរមាសរុបអនាគតក្រោមភតិសន្យាប្រតិបត្តិការដែលមិនអាចលុបចោលបានសម្រាប់គ្រានីមួយៗដូចខាងក្រោមៈ

(១) មិនលើសពី១ឆ្នាំ

(២) លើសពី១ឆ្នាំ និងមិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(ខ) ការទូទាត់ភតិសន្យាដែលបានទទួលស្គាល់ជាចំណាយ

(គ) ការពិពណ៌នាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិកៈឧទាហរណ៍ រួមមាន ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចសន្យា ឬសិទ្ធិទិញពិសេសនិងឃ្លាសន្យាសំខាន់ៗ ភតិសន្យាបន្ត និង ការដាក់កំហិតដែលបានកំណត់ដោយកិច្ចព្រមព្រៀងភតិសន្យា។

### ការទទួលស្គាល់ និងការវាស់វែងលើកដំបូង

២០.១៧ ភតិបតីត្រូវទទួលស្គាល់ទ្រព្យសកម្មដែលរក្សាទុកក្រោមភតិសន្យាហិរញ្ញវត្ថុនៅក្នុងរបាយណ៍ស្ថា នភាពហិរញ្ញវត្ថុរបស់គេ និងបង្ហាញពួកគេជាគណនីត្រូវទទួលតាមតម្លៃស្មើនឹងតម្លៃវិនិយោគសុទ្ធ នៅក្នុងភតិសន្យា។ តម្លៃវិនិយោគសុទ្ធនៅក្នុងភតិសន្យាគឺជាតម្លៃវិនិយោគដុលរបស់ភតិបតីនៅក្នុងភតិសន្យាដែលបានធ្វើអប្បហាររួចតាមអត្រាការប្រាក់បញ្ជាក់នៅក្នុងភតិសន្យា។ ការវិនិយោគដុលនៅក្នុងភតិសន្យាគឺជាតម្លៃសរុបនៃៈ

(ក) ការទូទាត់ភតិសន្យាអប្បបរមាដែលត្រូវទទួលដោយភតិបតីក្រោមភតិសន្យាហិរញ្ញវត្ថុ និង

(ខ) តម្លៃកាកសំណល់មិនធានាបង្គរទុកសម្រាប់ភតិបតី។

២០.១៨ សម្រាប់ភតិសន្យាហិរញ្ញវត្ថុក្រៅពីភតិសន្យាទាក់ទងនឹងរោងចក្រផលិត ឬ ភតិបតីជាអ្នកលក់ ចំណាយផ្ទាល់ដំបូងដែលបានកើតឡើងនិងចូលរួមដោយផ្ទាល់នៅក្នុងការចរចារនិងរៀបចំភតិសន្យា) ត្រូវបញ្ចូលនៅក្នុងការវាស់វែងលើកដំបូងនៃភតិសន្យាដែលត្រូវទទួល និងកាត់បន្ថយប្រាក់ចំណូលដែលបានទទួលស្គាល់ក្នុងរយៈពេលភតិសន្យា។

### ការវាស់វែងបន្តបន្ទាប់

២០.១៩ ការទទួលស្គាល់ចំណូលហិរញ្ញវត្ថុត្រូវផ្អែកលើគំរូដែលឆ្លុះបញ្ចាំងពីអត្រាចំណូលថេរប្រចាំឆ្នាំ លើការវិនិយោគសុទ្ធរបស់ភតិបតីនៅក្នុងភតិសន្យាហិរញ្ញវត្ថុ។ ការទូទាត់ភតិសន្យាសម្រាប់គ្រា ដោយមិនបញ្ចូលថ្លៃសេវាកម្មត្រូវបានប្រើទល់នឹងការវិនិយោគដុលនៅក្នុងភតិសន្យាដើម្បីកាត់បន្ថយទាំងប្រាក់ដើមនិងចំណូលហិរញ្ញវត្ថុមិនទាន់ទទួលស្គាល់។ប្រសិនបើមានសញ្ញាដែលថាតម្លៃកាកសំណល់មិនធានាប៉ាន់ស្មានដែលបានប្រើនៅក្នុងការគណនាការវិនិយោគដុលរបស់ភតិបតីនៅក្នុងភតិសន្យាបានផ្លាស់ប្តូរជាសំខាន់ ការបែងចែកប្រាក់ចំណូលលើរយៈពេលភតិសន្យាគឺត្រូវបានកែប្រែ និង ការកាត់បន្ថយណាមួយទាក់ទងនឹងចំនួនទឹកប្រាក់ដែលបានបង្គរត្រូវបានទទួលស្គាល់ភ្លាមនៅក្នុង របាយការណ៍ចំណេញខាត។

### ភតិបតីជាអ្នកផលិតឬអ្នកលក់

២០.២០ អ្នកផលិតឬអ្នកលក់តែងតែផ្តល់ឲ្យអតិថិជននូវជម្រើសនៃការទិញឬភតិសន្យាទ្រព្យសកម្ម។ភតិសន្យាហិរញ្ញវត្ថុនៃទ្រព្យសកម្មដោយភតិបតីជាអ្នកផលិតឬអ្នកលក់ផ្តល់ការកើនឡើងចំណូលពីរប្រភេទៈ

(ក) ប្រាក់ចំណេញឬខាតដែលសមមូលទៅនឹងប្រាក់ចំណេញឬខាតកើតចេញពីការលក់ទ្រព្យសកម្មដែលកំពុងត្រូវបានធ្វើភតិសន្យា តាមតម្លៃលក់ធម្មតា ដោយឆ្លុះបញ្ចាំងពីទំហំអប្បហារពាណិជ្ជកម្ម និង

(ខ) ចំណូលហិរញ្ញវត្ថុក្នុងរយៈពេលភតិសន្យា

២០.២១ ចំណូលពីការលក់ដែលបានទទួលស្គាល់នៅពេលចាប់ផ្តើមនៃរយៈពេលភតិសន្យាដោយភតិបតីជាអ្នកផលិតឬអ្នកលក់គឺជាតម្លៃសមស្របនៃទ្រព្យសកម្មឬ ប្រសិនបើទាបជាង តម្លៃបច្ចុប្បន្ននៃ ការទូទាត់ភតិសន្យាអប្បបរមារដែលបង្គរសម្រាប់ភតិបតីត្រូវបានគេគណនាតាមអត្រាការប្រាក់ទីផ្សារ។ប្រសិនខុសគ្នា ថ្លៃដើមលក់ដែលបានទទួលស្គាល់នៅពេលចាប់ផ្តើមភតិសន្យាគឺជាថ្លៃដើម ឬ តម្លៃក្នុងបញ្ជីនៃទ្រព្យធ្វើភតិសន្យាដកចេញនូវតម្លៃបច្ចុប្បន្ននៃកាកសំណល់មិនធានា។ ភាពខុសគ្នារវាងចំណូលពីការលក់និងថ្លៃដើមលក់គឺជាប្រាក់ចំណេញលក់ដែលត្រូវបានទទួលស្គាល់ដោយអនុលោមតាមគោលនយោបាយរបស់អង្គភាពសម្រាប់ការលក់

២០.២២ប្រសិនបើមានអត្រាការប្រាក់ទាប ចំណេញពីការលក់ត្រូវបានកម្រិតចំពោះអត្រាការប្រាក់ដែលគួរប្រើប្រសិនបើអត្រាការប្រាក់ទីផ្សារត្រូវបានគេប្រើ។

ការលាតត្រដាងព័ត៌មាន

២០.២៣ ភតិបតីត្រូវបង្ហាញព័ត៌មានសម្រាប់ភតិសន្យាហិរញ្ញវត្ថុដូចខាងក្រោមៈ

(ក)ការផ្ទៀងផ្ទាត់រវាងការវិនិយោគដុលនៅក្នុងភតិសន្យានៅចុងបញ្ចប់គ្រារាយការណ៍ និងតម្លៃបច្ចុប្បន្ននៃគណនីត្រូវទទួលការទូទាត់ភតិសន្យាអប្បបរមានៅចុងគ្រារាយការណ៍។លើសពីនេះភតិបតីត្រូវបង្ហាញការវិនិយោគដុលនៅក្នុងភតិសន្យា និងតម្លៃបច្ចុប្បន្ននៃគណនីត្រូវទទួលការទូទាត់ ភតិសន្យាអប្បបរមានៅចុងគ្រារាយការណ៍ សម្រាប់គ្រានីមួយៗដូចខាងក្រោមៈ

(១) មិនលើសពី១ឆ្នាំ

(២) លើសពី១ឆ្នាំ និងមិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ

(ខ) ចំណូលហិរញ្ញវត្ថុមិនទាន់ទទួលស្គាល់។

(គ)តម្លៃកាកសំណល់មិនធានាដែលបង្គរទុកចំពោះអត្ថប្រយោជន៍របស់ភតិបតី។

(ឃ)ការដកបង្ការបូកបន្ថសម្រាប់គណនីត្រូវទទួលការទូទាត់អប្បបរមា

(ង)ការជួលយថាហេតុដែលបានទទួលស្គាល់ជាចំណូលនៅក្នុងគ្រា

(ច)ការពិពិណនាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិបតី ជាឧទាហរណ៍ រួមមានៈ ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀង ឬសិទ្ធិទិញពិសេសនិង ខសន្យាសំខាន់ៗ ភតិសន្យាបន្ត និងការដាក់កំហិតទាំងឡាយដែលបានកំណត់ដោយកិច្ចព្រមព្រៀង។

ការទទួលស្គាល់ និង ការវាស់វែង

២០.២៤ ភតិបតីត្រូវបង្ហាញទ្រព្យសកម្មជាកម្មវត្ថុចំពោះភតិសន្យាប្រតិបត្តិការនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយអនុលោមតាមប្រភេទទ្រព្យសកម្ម។

២០.២៥ភតិបតីត្រូវទទួលស្គាល់ចំណូលពីភតិសន្យាប្រតិបត្តិការ (ដោយមិនបញ្ចូលចំនួនទឹកប្រាក់សម្រាប់សេវាកម្មដូចជាធានារ៉ាប់រង និង ការថែទាំ) នៅក្នុងរបាយការណ៍ចំណេញ ឬខាត តាមមូលដ្ឋានថេរលើ រយៈភតិសន្យាលើកលែងតែ

(ក) មូលដ្ឋានជាប្រព័ន្ធផ្សេងទៀតតំណាងឲ្យគំរូពេលវេលានៃផលប្រយោជន៍របស់ភតិកៈពីទ្រព្យសកម្មបានធ្វើភតិសន្យា ទោះបីជាការទទួលបានការទូទាត់សងមិនផ្អែកតាមមូលដ្ឋាននោះក៏ដោយ ឬ

(ខ) ការទូទាត់សងទៅឲ្យភតិបតីត្រូវបានគេបង្កើតឡើងដើម្បីបង្កើនឲ្យស្របតាមអតិផរណាដែលបានរំពឹងទុក (ផ្អែកលើសន្ទស្សន៍ ឬ ស្ថិតិដែលបានផ្សាយ) ដើម្បីតបស្នងចំពោះការកើនឡើងថ្លៃអតិផរណាដែលបាន រំពឹងទុករបស់ភតិបតី។ ប្រសិនបើការទូទាត់សងទៅឲ្យភតិបតីប្រែប្រួលតាមកត្តាទាំងឡាយជាជាងអតិផរណា ដូច្នេះលក្ខ ណ្ឌ(ខ)មិនត្រូវបានបំពេញទេ។

២០.២៦ ភតិបតីត្រូវទទួលស្គាល់ជាចំណាយ រួមមាន រំលស់ដែលបានកើតឡើងនៅក្នុងការរកចំណូលពីភតិសន្យា។ គោលនយោបាយរំលស់សម្រាប់ទ្រព្យសកម្មភតិសន្យាដែលអាចដករំលស់បានត្រូវមានសង្គតិភាពជាមួយគោលនយោបាយរំលស់ធម្មតារបស់ភតិបតីសម្រាប់ទ្រព្យសកម្មស្រដៀងគ្នា។

២០.២៧ ភតិបតីត្រូវបូកបន្ថែមតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មភតិសន្យានូវថ្លៃដើមផ្ទាល់ដំបូងណាដែលភតិបតីបានចំណាយនៅក្នុងការចរចារនិងរៀបចំកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការ និងត្រូវទទួលស្គាល់ថ្លៃដើមនោះជាចំណាយលើរយៈពេលភតិសន្យាតាមមូលដ្ឋានដូចគ្នាជាចំណូលភតិសន្យា។

២០.២៨ ដើម្បីកំណត់ថាតើទ្រព្យសកម្មភតិសន្យាបានធ្លាក់ចុះ ភតិបតីត្រូវអនុវត្តផ្នែកទី២៧។

២០.២៩ ភតិបតីជាអ្នកផលិតឬអ្នកលក់មិនត្រូវទទួលចំណេញពីការលក់ណាមួយចំពោះកិច្ចព្រមព្រៀងប្រតិបត្តិការ ពីព្រោះវាមិនសមមូលនឹងការលក់។

ការលាតត្រដាងព័ត៌មាន

២០.៣០ ភតិបតីត្រូវលាតត្រដាងព័ត៌មានទាក់ទងនឹងភតិសន្យាប្រតិបត្តិការៈ

(ក) ការទូទាត់ភតិសន្យាអប្បបរមាអនាគតក្រោមភតិសន្យាប្រតិបត្តិការមិនអាចលុបចោលបានសម្រាប់គ្រានីមួយៗដូចខាងក្រោមៈ

(១) មិនលើសពី១ឆ្នាំ និង

(២) លើសពី១ឆ្នាំ និងមិនលើសពី៥ឆ្នាំ និង

(៣) លើសពី៥ឆ្នាំ។

(ខ) ការជួលយថាហេតុដែលបានទទួលស្គាល់ជាចំណូល។

(គ) ការពិពិណនាទូទៅនៃកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗរបស់ភតិបតី ឧទាហរណ៍ រួមមានៈ ព័ត៌មានអំពីការជួលយថាហេតុ ការបន្តកិច្ចព្រមព្រៀង ឬ សិទ្ធិទិញពិសេស និង ឃ្លាបន្ថែម និង ការកម្រិតទាំងឡាយដែលកំណត់ដោយកិច្ចព្រព្រៀងភតិសន្យា។

២០.៣១ លើសពីនេះ ការតម្រូវទាំងឡាយសម្រាប់ការលាតត្រដាងព័ត៌មានអំពីទ្រព្យសកម្មដោយអនុលោមតាមផ្នែកទី១៧.១៨.២៧ និង ៣៤ អនុវត្តចំពោះភតិបតីសម្រាប់ទ្រព្យសកម្មដែលបានផ្តល់ក្រោមភតិសន្យាប្រតិបត្តិការ។

## ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញ

២០.៣២ប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញទាក់ទិននឹងការលក់ទ្រព្យសកម្ម និងការជួលត្រឡប់មកវិញនូវទ្រព្យសកម្មដូចគ្នា។ការទូទាត់សងភតិសន្យា និងតម្លៃលក់ជាធម្មតាមានទំនាក់ទំនងគ្នាទៅវិញទៅមក ពីព្រោះពួកវាត្រូវបានចរចារជាកញ្ចប់។ការទទួលស្គាល់នៃប្រតិបត្តិការលក់និងភតិសន្យាត្រឡប់វិញផ្អែកលើភតិសន្យា។

### ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញកើតមាននៅក្នុងភតិសន្យាហិរញ្ញវត្ថុ

២០.៣៣ ប្រសិនបើប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញកើតមាននៅក្នុងភតិសន្យាហិរញ្ញវត្ថុភតិកៈ-អ្នកលក់មិនត្រូវទទួលស្គាល់ភ្លាមនូវផ្នែកលើសនៃចំណូលពីការលក់លើតម្លៃក្នុងបញ្ជីជាចំណូលទេ។ភតិកៈ-អ្នកលក់ត្រូវពន្យាផ្នែកលើសនោះ និង រំលស់វាតាមរយៈភតិសន្យា។

### ប្រតិបត្តិការលក់ និង ភតិសន្យាត្រឡប់វិញកើតមាននៅក្នុងភតិសន្យាប្រតិបត្តិការ

២០.៣៤ ប្រសិនបើប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញកើតមាននៅក្នុងភតិសន្យាប្រតិបត្តិការ ហើយគេច្បាស់ថាប្រតិបត្តិការត្រូវបានបង្កើតតាមតម្លៃសមស្រប ភតិកៈ អ្នកលក់ត្រូវទទួលស្គាល់ប្រាក់ចំណេញ ឬខាតភ្លាម លុះត្រាតែការខាតត្រូវតបស្នងចំពោះការទូទាត់សងភតិសន្យាអនាគតតាមតម្លៃទាបជាងទីផ្សារ។ នៅក្នុងករណីនោះ ភតិកៈ-អ្នកលក់ត្រូវពន្យានិងរំលស់ការខាតនោះតាមសមាមាត្រទៅនឹងការទូទាត់ភតិសន្យា តាមរយៈពេលដែលទ្រព្យសកម្មនោះត្រូវបានរំពឹងទុកថានឹងត្រូវប្រើ។ ប្រសិនបើតម្លៃលក់លើសពីតម្លៃសមស្រប ភតិកៈ-អ្នកលក់ត្រូវពន្យាផ្នែកលើសលើតម្លៃសមស្របនោះនិងរំលស់វាតាមរយៈដែលទ្រព្យសកម្មត្រូវបានរំពឹងទុកថានឹងត្រូវប្រើ។

**ការលាតត្រដាងព័ត៌មាន**

២០.៣៥ ការតម្រូវឲ្យលាតត្រដាងព័ត៌មានសម្រាប់ភតិកៈនិងភតិបតីអនុវត្តដូចគ្នាចំពោះប្រតិបត្តិការលក់និងភតិសន្យា។ ការពិពណ៌នាពីកិច្ចព្រមព្រៀងភតិសន្យាសំខាន់ៗដែលបានតម្រូវ ត្រូវរួមបញ្ចូនការពិពណ៌នាពីលក្ខខណ្ឌមិនប្រក្រតីឬទោលនៃកិច្ចព្រមព្រៀង ឬ លក្ខខណ្ឌនៃប្រតិបត្តិការលក់ និងភតិសន្យាត្រឡប់វិញ ។

## ផ្នែកទី២១
## សំវិធានធន និង យថាភាព

### វិសាលភាពនៃផ្នែកនេះ

២១.១ផ្នែកនេះអនុវត្តចំពោះ**សំវិធានធន**ទាំងអស់( ពោលគឺបំណុលមានចំនួនទឹកប្រាក់និងពេលវេលាមិនទៀងទាត់ **បំណុលយថាហេតុ** និង **ទ្រព្យសកម្មយថាហេតុ**លើកលែងសំវិធានទាំងឡាយដែល ត្រូវគ្របដណ្តប់ដោយផ្នែកផ្សេងទៀតនៃស្តង់ដារនេះ។ សំវិធានធនទាំងនោះរួមមានៈ

(ក)ភតិសន្យា (ផ្នែកទី២០ *ភតិសន្យា)* ។ ប៉ុន្តែផ្នែកនេះពាក់ព័ន្ធជាមួយនឹងភតិសន្យាប្រតិបត្តិការ ដែលមានលក្ខណៈស្មុគស្មាញ

(ខ) កិច្ចសន្យាសាងសង់ (ផ្នែកទី២៣ *ចំណូល*)

(គ) កាតព្វកិច្ចអត្ថប្រយោជន៍នយោជិត (ផ្នែកទី២៨ *អត្ថប្រយោជន៍និយោជិក*)

(ឃ) ពន្ធលើប្រាក់ចំណូល (ផ្នែកទី ២៩ *ពន្ធលើប្រាក់ចំណូល*)

២១.២ ការតម្រូវនៅក្នុងផ្នែកនេះមិនអនុវត្តចំពោះកិច្ចសន្យាប្រតិបត្តិលុះត្រាតែ កិច្ចសន្យានោះជាកិច្ចសន្យាស្មុគស្មាញ។ កិច្ចសន្យាប្រតិបត្តិគឺជាកិច្ចសន្យាដែលពុំមានភាគីណាមួយបានអនុវត្តកាតព្វកិច្ចណាមួយនៃកាតព្វកិច្ចទាំងឡាយ ឬ ភាគីទាំងពីរបានអនុវត្តកាតព្វកិច្ចមួយផ្នែកចំពោះទំហំស្មើគ្នា។

២១.៣ ពាក្យ**សំវិធានធន** ជួនកាល ត្រូវបានប្រើនៅក្នុងបរិការណ៍នៃធាតុមួយចំនួនជាការរំលស់ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម គណនេយ្យត្រូវទទួលមិនអាចប្រមូលបាន។ ទាំងអស់នោះគឺជាការកែសម្រួលនៃ **តម្លៃក្នុងបញ្ជី** នៃទ្រព្យសកម្ម ជាជាងការទទួលស្គាល់បំណុល និង ដូច្នេះហើយមិនបានគ្របដណ្តប់ដោយផ្នែកនេះទេ។

### ការទទួលស្គាល់លើកដំបូង

២១.៤ អង្គភាពមួយត្រូវទទួលស្គាល់សំវិធានធនតែប៉ុណ្ណោះនៅពេលដែលៈ

(ក) អង្គភាពមានកាតព្វកិច្ចនៅ **ថ្ងៃរាយការណ៍**ដែលជាលទ្ធនៃព្រឹត្តការណ៍អតីតកាល

(ខ)**ប្រហែលជាថា**( ពោលគឺ ប្រហែលកើតឡើងច្រើនជាងមិនកើតឡើង)អង្គភាពនឹងត្រូវតម្រូវ ឲ្យផ្ទេរធនធានសេដ្ឋកិច្ចនៅក្នុងការទូទាត់សង និង

(គ) ចំនួនទឹកប្រាក់នៃកាតព្វកិច្ចអាចប៉ាន់ស្មានដោយជឿជាក់

២១.៥ អង្គភាពត្រូវទទួលស្គាល់សំវិធានធនជាបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងទទួលស្គាល់ចំនួនទឹកប្រាក់សំវិធានធនជាចំណាយ លុះត្រាផ្នែកផ្សេងទៀតនៃស្តង់ដារនេះ តម្រូវឲ្យថ្លៃដើមនឹងត្រូវបានទទួល

ស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្ម ដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង ឧបករណ៍។

២១.៦ លក្ខខណ្ឌនៅក្នុងកថាខណ្ឌ ២១.៤(ក) (កាតព្វកិច្ចនៅថ្ងៃរាយការណ៍ជាលទ្ធផលនៃព្រឹត្តិការណ៍ អតីតកាល) មានន័យថាអង្គភាពមិនមានជម្រើសច្បាស់លាស់ចំពោះការទូទាត់សងកាតព្វកិច្ច។វាអាចកើតឡើង នៅពេលអង្គភាពមានកាតព្វកិច្ចផ្លូវច្បាប់ដែលអាចត្រូវបង្ខំដោយច្បាប់ ឬ នៅពេលដែលអង្គភាពមាន**កាតព្វកិច្ចសាងសង់** ពីព្រោះព្រឹត្តិការណ៍អតីតកាល(ដែលអាចជាសកម្មភាពរបស់អង្គភាព) បានបង្កើតឡើងនូវការរំពឹងត្រឹមត្រូវលើភាគីផ្សេងទៀតដែលអង្គភាពនឹងទទួលខុសត្រូវកាតព្វកិច្ច។ កាតព្វកិច្ចដែលនឹងកើតឡើងពីសកម្មភាពនាពេលអនាគតរបស់អង្គភាព (ឥរិយាបទអនាគតរបស់ ក្រុមហ៊ុន) មិនបំពេញលក្ខខណ្ឌនៅក្នុងកថាខណ្ឌ ២១.៤(ក) មិនថាតើកាតព្វកិច្ចទាំងឡាយនឹងកើតឡើង និង ទោះបីកាតព្វកិច្ចកាដោយ។ ដោយសារសំពាធពាណិជ្ជកម្មឬការតម្រូវផ្នែកផ្លូវច្បាប់ដើម្បីពន្យល់ថាអង្គភាពមួយអាចមានបំណងឬត្រូវការបង្កើតចំណាយដើម្បីប្រតិបត្តិក្នុងផ្លូវមួយជាក់លាក់នៅពេលអនាគត(ឧទាហរណ៍ដោយការបំពាក់តំរងផ្សែងនៅក្នុងប្រភេទរោងចក្រជាក់លាក់)។ ដោយសារអង្គភាព អាចជៀងវាងការចំណាយអនាគតដោយសកម្មភាពអនាគតរបស់គេ ជាឧទាហរណ៍ដោយការប្តូរវិធីសាស្ត្រប្រតិបត្តិការ ឬ ការលក់រោងចក្រ អង្គភាពមិនមានកាតព្វកិច្ចសម្រាប់ការចំណាយអនាគត និងពុំមានសំវិធានធនណាត្រូវបានទទួលស្គាល់។

### ការវាស់វែងលើកដំបូង

២១.៧ អង្គភាពត្រូវវាស់វែងសំវិធានធនតាមតម្លៃប៉ាន់ស្មាននៃចំនួនទឹកប្រាក់ដែលត្រូវការដើម្បីទូទាត់កាតព្វកិច្ចនៅថ្ងៃរាយការណ៍។ ការប៉ាន់ស្មានដ៏ល្អបំផុតគឺជាចំនួនទឹកប្រាក់ដែលអង្គភាពគួរបង់ដើម្បីទូ ទាត់កាតព្វកិច្ចនៅចុងគ្រារាយការណ៍ ឬ ដើម្បីផ្ទេរកាតព្វកិច្ចទៅឲ្យភាគីទីពនៅពេលនោះ។

(ក) នៅពេលសំវិធានធនជាប់ទាក់ទិនសំណុំធាតុច្រើន ការប៉ាន់ស្មាននៃចំនួនទឹកប្រាក់ឆ្លុះបញ្ចាំងពីមធ្យមនៃសមិទ្ធិផលដែលអាចកើតឡើងទាំងអស់ដោយភវនីយភាពជាប់ពាក់ព័ន្ធ។ដូច្នេះការធ្វើសំវិធានធននឹងខុសគ្នាដោយផ្អែកលើថាតើភវនីយភាពនៃការខាតនៃចំនួនទឹកប្រាក់គឺ ៦០ ភាគរយ ឬ ៩០ ភាគរយ ជាឧទាហរណ៍។ នៅពេលមានគំលាតសមិទ្ធិផលអាចកើតឡើងបន្តច្រើន ចំណុចនីមួយៗនៅក្នុងគំលាតគឺដូចទៅនឹងចំណុចផ្សេងទៀត ចំណុចចំកណ្តាលនៃគំលាតត្រូវបានប្រើ

(ខ) នៅពេលសំវិធាធនកើតឡើងពីកាតព្វកិច្ចទោល ភាពប្រហែលខ្លាំង សមិទ្ធិផលនីមួយៗអាចជាការប៉ាន់ស្មាននៃចំនួនទឹកប្រាក់ដែលតម្រូវឲ្យទូទាត់កាតព្វកិច្ច។ ប៉ុន្តែ ទោះបីក្នុងករណីបែបនេះក៏ដោយ អង្គភាពពិចារណាពីសមិទ្ធិផលដែលអាចកើតឡើងផ្សេងទៀត។ នៅពេលសមិទ្ធិផលដែលអាច កើតឡើងផ្សេងទៀត ភាគច្រើនខ្ពស់ឬភាគច្រើនទាបជាង សមិទ្ធិផលទំនងភាគច្រើន ការប៉ានស្មាននឹងជាចំនួនទឹកប្រាក់ខ្ពស់ជាងឬទាបជាង។

នៅពេលផលប៉ះពាល់តម្លៃពេលវេលានៃប្រាក់មានចំនួនធំ ចំនួនទឹកប្រាក់សំវិធានធននឹងជាតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលនៃប្រាក់។ ហានីយភ័យជាក់លាក់

ចំពោះបំណុលគួរត្រូវបានឆ្លុះបញ្ចាំងទាំងនៅក្នុងអត្រាអប្បហារ ឬនៅក្នុងការប៉ាន់ស្មាននៃចំនួនទឹកប្រាក់ដែលត្រូវការដើម្បីទូទាត់សងកាតព្វ ប៉ុន្តែមិនទាំងពីរទេ។

២១.៨ អង្គភាពត្រូវដកចេញនូវការចំណេញពីការលក់ចោលទ្រព្យសកម្មដែលបានរំពឹងពីការវាស់វែងនៃសំវិធានធន។

២១.៩ នៅពេលចំនួនទឹកប្រាក់ខ្លះ ឬទាំងអស់ដែលត្រូវការដើម្បីទូទាត់សងសំវិធានធន អាចត្រូវបានទូទាត់សងដោយភាគីផ្សេងទៀត (តាមរយៈធានារ៉ាប់រង) អង្គភាពត្រូវទទួលស្គាល់ការទូទាត់សងមកវិញនោះជាទ្រព្យសកម្មដោយឡែក តែក្នុងករណីវាច្បាស់ថាអង្គភាពនឹងទទួលបានសំណងលើការទូទាត់សងកាតព្វកិច្ច។សំណងដែលត្រូវទទួលបានត្រូវដាក់បង្ហាញនៅក្នុងរបាយការណ៍ស្ថានភាព ហិរញ្ញវត្ថុជាទ្រព្យសកម្ម និងមិនត្រូវកាត់កងជាមួយនឹងសំវិធានធនទេ។ នៅក្នុងរបាយការណ៍លទ្ធផលសរុប អង្គភាពអាចកាត់កងសំណងណាមួយពីភាគីផ្សេងជាមួយនឹងចំណាយដែលទាក់ទងនឹងសំវិធានធន។

## ការវាស់វែងឆ្នាំបន្តបន្ទាប់

២១.១០ អង្គភាពត្រូវកាត់កងសំវិធានធនចំពោះតែចំណាយទាំងឡាយណាដែលសំវិធានធនត្រូវបានទទួលស្គាល់ជាលើកដំបូងប៉ុណ្ណោះ។

២១.១១ អង្គភាពត្រូវពិនិត្យមើលឡើងវិញនូវសំវិធានធាននៅថ្ងៃរាយការណ៍ និងកែសម្រួលសំវិធានធន ទាំងនោះដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតនៃចំនួនទឹកប្រាក់ដែលតម្រូវឲ្យទូទាត់សងកាតព្វកិច្ចនៅថ្ងៃរាយការណ៍នោះ។ ការកែសម្រួលណាមួយ ចំពោះចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ពីគ្រាមុនត្រូវបានទទួលនៅក្នុងរបាយការណ៍ចំណេញ-ខាត លុះត្រាតែសំវិធានធនត្រូវបានទទួលស្គាល់ដំបូងជា ផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្ម (សូមមើលកថាខណ្ឌ ២១.៥). នៅពេលសំវិធានធនត្រូវបានវាស់វែង តាមតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលបានរំពឹងទុក ត្រូវបានតម្រូវឲ្យទាត់សងកាតព្វកិច្ច ភាពមិនបទ បែននៃការអប្បហារត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ចំណេញខាត នៅក្នុងគ្រាដែចំណាយហិរញ្ញវត្ថុនោះកើតឡើង។

## បំណុលយថាហេតុ

២១.១២ **បំណុលយថាហេតុ**គឺជាកាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែជាកាតព្វកិច្ចមិនជាក់ច្បាស់ ឬ ជាកាតព្វកិច្ចបច្ចុប្បន្នដែលមិនត្រូវបានទទួលស្គាល់ពីព្រោះបំណុលមិនបានបំពេញលក្ខខណ្ឌមួយឬទាំងពីរ (ខ) និង (គ) នៅក្នុងកថាខណ្ឌ២១.៤។ អង្គភាពមិនត្រូវទទួលស្គាល់បំណុលយថាហេតុជាបំណុល លើកលែងតែសំវិធានធនសម្រាប់បំណុលយថាហេតុរបស់អ្នកលក់នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា (សូមមើលកថា ខណ្ឌ ១៩.២០ និង ១៩.២១) ។ ការលាតត្រដាងព័ត៌មាននៃបំណុលយថាហេតុត្រូវបានតម្រូវដោយ កថាខណ្ឌ ២១.១៥ លុះត្រាតែភាពដែលអាចកើតមានឡើងនៃលំហូរចេញនូវធនធានកាន់តែឃ្លាត ឆ្ងាយ។ នៅពេលដែលអង្គភាពទទួលខុសកាតព្វកិច្ចរួម ឬ ច្រើន ផ្នែកនៃកាតព្វកិច្ចដែលត្រូវ បានរំពឹងថានឹងត្រូវបំពេញដោយភាគីផ្សេងទៀត ត្រូវបានចាត់ទុកជាបំណុលយថាហេតុ។

ទ្រព្យសកម្មយថាហេតុ

២១.១៣ អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មយថាហេតុជាទ្រព្យសកម្ម។ ការលាតត្រដាងនៃទ្រព្យសកម្មយថាហេតុត្រូវបានតម្រូវដោយកថាខណ្ឌ ២១.១៦ នៅពេលលំហូរចូលនៃអត្ថប្រយោជន៍ សេដ្ឋកិច្ចទំនងជានឹងកើតមាន។ ប៉ុន្តែនៅពេលលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតមកក្រុមហ៊ុនមានភាពជាក់ស្តែង ដូច្នេះទ្រព្យសកម្មទាក់ទិនមិនមានជាទ្រព្យសកម្មយថាហេតុទេ ហើយការទទួលស្គាល់មានភាពសមស្រប។

ការលាតត្រដាងព័ត៌មាន

---

ការលាតត្រដាងអំពីសំវិធានធន

២១.១៤ សម្រាប់ថ្នាក់សំវិធានធននីមួយៗ អង្គភាពត្រូវលាតត្រដាងបង្ហាញនូវព័ត៌មានដូចខាងក្រោមៈ

(ក) ការផ្ទៀងផ្ទាត់ដោយបង្ហាញ

(១) តម្លៃក្នុងបញ្ជីនៅដើមគ្រា និង ចុងគ្រា

(២) ការបន្ថែមក្នុងគ្រា រួមមានការកែសម្រួលដែលកើតចេញពីការផ្លាស់ប្តូរក្នុងការវាស់វែងចំនួនទឹកប្រាក់បញ្ចុះតម្លៃរួច

(៣) ចំនួនទឹកប្រាក់ដែលបានកាត់កងនឹងសំវិធានធនក្នុងគ្រា និង

(៤) ចំនួនទឹកប្រាក់មិនបានប្រើដែលកត់ត្រាបញ្រ្ចាស់ក្នុងគ្រា។

(ខ)ការរៀបរាប់ដោយសង្ខេបនៃលក្ខណៈនៃកាតព្វកិច្ចនិងចំនួនទឹកប្រាក់និងពេលវេលាដែលបានរំពឹងទុកនៃការទូទាត់សងដែលកើតមាន

(គ) សញ្ញានៃភាពមិនច្បាស់លាស់អំពីចំនួនទឹកប្រាក់ ឬពេលវេលានៃលំហូរចេញទាំងនោះ

(ឃ)ចំនួនទឹកនៃសំណងដែលរំពឹងទុកដោយបញ្ជាក់ពីចំនួនទឹកប្រាក់នៃទ្រព្យសកម្មណាមួយដែលត្រូវបានទទួលស្គាល់សម្រាប់សំណងដែលបានរំពឹងទុកនោះ។

ព័ត៌មានប្រៀបធៀបសម្រាប់គ្រាមុនមិនបានតម្រូវទេ។

ការលាតត្រដាងព័ត៌មានអំពីបំណុលយថាហេតុ

២១.១៥ លុះត្រាតែភាពអាចកើតមានឡើងនៃលំហូរចេញធនធាននៅក្នុងការទូទាត់សងមានភាពឃ្លាតឆ្ងាយសម្រាប់ថ្នាក់នីមួយៗនៃបំណុលយថាហេតុនៅថ្ងៃរាយការណ៍ អង្គភាពត្រូវលាតត្រដាងបង្ហាញពី រៀបរាប់ដោយសង្ខេបពីប្រភេទនៃបំណុលយថាហេតុ និង នៅពេលអាចអនុវត្តបានៈ

(ក) ការប៉ាន់ស្មាននៃផលប៉ះពាល់ហិរញ្ញវត្ថុ ត្រូវបានវាស់វែងដោយអនុលោមតាមកថាខណ្ឌ ២១.៧ - ២១.១១

(ខ) សញ្ញានៃភាពមិនច្បាស់លាស់ទាក់ទងនឹងចំនួនទឹកប្រាក់ ឬ ពេលវេលានៃលំហូរចេញណា មួយ និង

(គ) ភាពអាចកើតមានឡើងនៃសំណងណាមួយ

ប្រសិនបើ**មិនអាចអនុវត្តបាន**ដើម្បីធ្វើការបង្ហាញមួយ ឬច្រើន ហេតុការនោះត្រូវតែបង្ហាញ។

**ការលាតត្រដាងអំពីទ្រព្យសកម្មយថាហេតុ**

២១.១៦ ប្រសិនបើការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចមានលក្ខណៈប្រហែល (ទំនងកើតឡើងច្រើនជាងមិនកើតឡើង) ប៉ុន្តែមិនជាច្បាស់លាស់ទេ អង្គភាពត្រូវលាតត្រដាងពីការពិពណ៌នាពីប្រភេទទ្រព្យសកម្មយថាហេតុនៅចុង**គ្រារាយការណ៍**និងនៅពេលដែលអាចអនុវត្តបានដោយគ្មានចំណាយច្រើនហួសហេតុ ឬកិច្ចខំប្រឹងប្រែងហួសហេតុ ការប៉ាន់ស្មាននៃផលប៉ះពាល់ហិរញ្ញវត្ថុ ត្រូវបានវាស់វែងដោយប្រើគោលការណ៍ដែលបានកំណត់នៅក្នុងកថាខណ្ឌ២១.៧-២១.១១។ ប្រសិនបើមិនអាចអនុវត្ត បានដើម្បីធ្វើការលាតត្រដាងនេះ ព្រឹត្តិការណ៍នោះត្រូវតែបង្ហាញ។

**ការលាតត្រដាងដែលខូចខាតប្រយោជន៍**

២១.១៧ នៅក្នុងករណីដ៏កំរបំផុតការលាតត្រដាងនៃព័ត៌មានទាំងអស់ ឬមួយចំនួនដែលបានតម្រូវដោយ កថាខណ្ឌ ២១.១៤-២១.១៦អាចត្រូវបានរំពឹងថានឹងធ្វើឲ្យខូចធ្ងន់ធ្ងរនូវស្ថានភាពរបស់អង្គភាពនៅក្នុងជំលោះជាមួយភាគីផ្សេងទៀតចំពោះសំវិធានធាន បំណុលយថាហេតុ ឬ ទ្រព្យសកម្មយថាហេតុ។នៅក្នុងករណីនេះ អង្គភាពចាំបាច់បង្ហាញព័ត៌មាន ប៉ុន្តែត្រូវបង្ហាញប្រភេទទូទៅនៃចំលោះ រួមជាមួយនឹង ហេតុការណ៍នោះ និង មូលហេតុដែលព័ត៌មានមិនត្រូវបានលាតត្រដាងបង្ហាញ។

## ផ្នែកទី២២

## បំណុល និង ដើមទុន

### វិសាលភាពនៃផ្នែកនេះ

២២.១ ផ្នែកនេះបង្កើនគោលការណ៍សម្រាប់ការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុជាបំណុល ឬ ដើមទុន និង បង្ហាញពីការធ្វើគណនេយ្យកម្មសម្រាប់ឧបករណ៍ដើមទុនដែលបានចេញផ្សាយទៅឱ្យបុគ្គលទាំងឡាយ ឬ ភាគីផ្សេងទៀតដែលដើរតួរជាអ្នកវិនិយោគនៅក្នុងឧបករណ៍**ដើមទុន**(ពោលគឺ ក្នុងសមត្ថភាពជាម្ចាស់) ផ្នែកទី២៦ *ការទូទាត់ផ្អែកលើសន្លឹកហ៊ុន* បញ្ជាក់ពីគណនេយ្យកម្មលើប្រតិបត្តិការដែលអង្គភាព មួយទទួលទំនិញឬសេវាកម្ម (រួមមានសេវាកម្មរបស់និយោជិក) ជាតម្លៃតបស្នងសម្រាប់ឧបករណ៍ដើមទុន (រួមមាន ភាគហ៊ុន ឬ សិទ្ធិពិសេសទិញភាគហ៊ុន) ពីនិយោជិក និង អ្នកផ្គត់ផ្គង់ផ្សេងទៀត ដែលដើរតួនៅក្នុងសមត្ថភាពរបស់គេជាអ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្ម។

២២.២ ផ្នែកនេះត្រូវបានអនុវត្តនៅពេលចាត់ថ្នាក់ប្រភេទឧបករណ៍ហិរញ្ញវត្ថុទាំងអស់ លើកលែងតែៈ

(ក)ភាគកម្មទាំងឡាយនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ញ្ញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ដែលត្រូវធ្វើគណនេយ្យកម្មដោយអនុលោមតាមផ្នែកទី៩ *របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក*, ផ្នែកទី ១៤ *ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ* ឬ ផ្នែកទី១៥ *ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន*។

(ខ) សិទ្ធិនិងកាតព្វកិច្ចរបស់និយោជកក្រោមផែនការអត្ថប្រយោជន៍និយោជិក នឹងត្រូវអនុវត្តនៅ ក្នុងផ្នែកទី២៨ *អត្ថប្រយោជន៍និយោជិក*។

(គ)កិច្ចសន្យាសម្រាប់ការតបស្នងយថាហេតុនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា(សូមមើលផ្នែកទី១៩ *ការរួមបញ្ចូលអាជីវកម្មរួមគ្នា និង មូលនិធិពាណិជ្ជកម្ម*) ។ ការលើលែងនេះអនុវត្តតែ ចំពោះអ្នកទិញ។

(ឃ) ឧបករណ៍ហិរញ្ញវត្ថុ កិច្ចសន្យា និង កាតព្វកិច្ចក្រោមប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនត្រូវអនុវត្តផ្នែកទី២៦ លើកលែងតែ កថាខណ្ឌ២២.៣ -២២.៦ ត្រូវបានអនុវត្តចំពោះភាគហ៊ុនរតនៈដែលបានទិញ លក់ បោះផ្សាយ ឬលុបចោល ទាក់ទងនឹងផែនការសិទ្ធិទិញពិសេសរបស់និយោជិក ផែនការទិញភាគហ៊ុនរបស់និយោជិក និងរាល់កិច្ចព្រមព្រៀងទូទាត់ផ្អែកលើសន្លឹកហ៊ុនផ្សេងទៀត។

### ការចាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុជាបំណុល ឬដើមទុន

២២.៣ ដើមទុនគឺជាតម្លៃចុងក្រោយជាទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីដកបំណុលទាំងអស់របស់អង្គភាពនោះ។ បំណុលគឺជាកាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាពដែលកើតចេញពីព្រឹត្តិការណ៍អតីតកាល ការទូទាត់នៃកាតព្វកិច្ចត្រូវបានរំពឹងថានឹងកើតមានការហូរចេញពីធនធានរបស់អង្គភាពដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច។ ដើមទុនរួមបញ្ចូលការវិនិយោគដោយ**ម្ចាស់**អង្គភាពបូកបន្ថែមលើការវិនិយោគទាំង នោះដែលរកបានតាមរយៈប្រតិបត្តិការ

ដែលចំណេញ និង រក្សាទុកសម្រាប់ប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់អង្គភាពដកចេញការថយចុះចំពោះការវិនិយោគដែលជាលទ្ធផលនៃប្រតិបត្តិការមិនចំណេញ និង ការបែងចែកទៅឱ្យម្ចាស់។

២២.៤ ឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដែលបំពេញនិយមន័យ**បំណុល** ត្រូវបានចាត់ថ្នាក់ជាដើមទុន ដោយសារឧបករណ៍ហិរញ្ញវត្ថុទាំងនោះតំណាងឱ្យផលប្រយោជន៍ចុងក្រោយនៅក្នុងទ្រព្យសកម្មសុទ្ធរបស់អង្គ ភាព:

(ក) ឧបករណ៍លក់បានគឺជាឧបករណ៍ហិរញ្ញវត្ថុដែលផ្តល់អ្នកកាន់ឧបករណ៍នូវសិទ្ធដើម្បីលក់ឧបករណ៍ នោះត្រឡប់ទៅឱ្យអ្នកបោះផ្សាយបានជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬត្រូវបានហៅត្រឡប់មកវិញ ឬទិញមកវិញដោយស្វ័យប្រវត្តិដោយអ្នកបោះផ្សាយលក់នៅពេលកើតមានឡើងនៃព្រឹត្តិការណ៍មិនច្បាស់លាស់នាពេលអនាគត ឬមរណៈភាព ឬការចូលនិវត្តន៍របស់អ្នកកាន់ឧបករណ៍។ ឧបករណ៍អាចលក់បាន ដែលមានលក្ខណៈទាំងអស់ដូចខាងក្រោម ត្រូវចាត់ថ្នាក់ជា ឧបករណ៍ដើមទុនៈ

(១) ឧបករណ៍ផ្តល់សិទ្ធិឱ្យអ្នកកាន់នូវភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពនៅក្នុងព្រឹត្តិការណ៍នៃការជំរះបញ្ជីអង្គភាព។ ទ្រព្យសកម្មសុទ្ធរបស់អង្គភាពគឺជាទ្រព្យសកម្មទាំងឡាយ ណាដែលរក្សាបានបន្ទាប់ពីការដកចេញនូវការទាមទារទាំងអស់ចំពោះទ្រព្យសកម្ម របស់អង្គភាព។

(២) ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងថ្នាក់នៃឧបករណ៍ដែលគាំទ្រដល់ថ្នាក់ផ្សេងទៀតនៃឧបករណ៍ ។

(៣) ឧបករណ៍ហិរញ្ញវត្ថុទាំងអស់នៅក្នុងឧបករណ៍ដែលគាំទ្រដល់ថ្នាក់ផ្សេងទៀតនៃឧបករណ៍មានលក្ខណៈដូចគ្នាសុទ្ធសាធ។

(៤) ក្រៅពីកាតព្វកិច្ចតាមកិច្ចសន្យាសម្រាប់អ្នកបោះផ្សាយដើម្បីទិញមកវិញឬហៅមកវិញនូវឧបករណ៍ជាសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឧបករណ៍មិនបញ្ចូលកាតព្វកិច្ចតាមកិច្ចសន្យា ដើម្បីប្រគល់សាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតទៅឱ្យអង្គភាពផ្សេងទៀតឬដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយទៀតក្រោមលក្ខខណ្ឌដែលមិនអំណោយផលខ្លាំងដល់អង្គភាព និង វាមិនមែនជាកិច្ចសន្យាដែលនឹង ឬ អាចត្រូវបានទូទាត់ជាឧបករណ៍ដើមទិនផ្ទាល់របស់អង្គភាព។

(៥) លំហូរសាច់ប្រាក់រំពឹងទុកសរុបដែលចូលរួមចំណែកចំពោះឧបករណ៍លើអាយុកាលនៃឧបករណ៍ត្រូវបានផ្អែកជាសំខាន់លើប្រាក់ចំណេញឬខាត ការប្រែប្រួលនៅក្នុងទ្រព្យសកម្មសុទ្ធ ឬ ការផ្លាស់ប្តូរនៅក្នុងទ្រព្យសកម្មសុទ្ធដែលបានទទួលស្គាល់ ឬការប្រែប្រួលក្នុងតម្លៃសមស្របនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពដែលបានទទួលស្គាល់និងមិនបានទទួលស្គាល់លើអាយុកាលនៃឧបករណ៍ (ដកចេញនូវផលប៉ះពាល់ណាមួយរបស់ឧបករណ៍)។

(ខ) ឧបករណ៍ឬសមាសធាតុនៃឧបករណ៍ ដែលគាំទ្រដល់ថ្នាក់ឧបករណ៍ទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាដើមទុន ប្រសិនបើពួកវាកំណត់ឱ្យអង្គភាពមានកាតព្វកិច្ចដើម្បីប្រគល់ឱ្យភាគីមួយទៀតនូវសមាមាត្រភាគហ៊ុននៃតម្លៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពតែនៅពេលជំរះបញ្ជីប៉ុណ្ណោះ។

២២.៥ ខាងក្រោមជាឧទាហរ៍នៃឧបករណ៍ដែលត្រូវបានចាត់ថ្នាក់ជាបំណុលមិនមែនដើមទុនៈ

(ក) ឧបករណ៍ត្រូវបានចាត់ថ្នាក់ជាបំណុលប្រសិនបើការបែងចែកទ្រព្យសកម្មសុទ្ធនៅពេលជំរះបញ្ជីគឺជាកម្មវត្ថុចំពោះចំនួនទឹកប្រាក់អប្បបរមា(ពិដាន)។ឧទាហរណ៍ ប្រសិនបើនៅក្នុងការជំរះបញ្ជីអ្នកកាន់ឧបករណ៍ទទួលបានភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្ម ប៉ុន្តែចំនួននេះត្រូវបានកំណត់ដល់ពិដាន និងទ្រព្យសកម្មសុទ្ធដែលលើសត្រូវបានបែងចែកទៅឱ្យអង្គការសប្បុរសធម៌ ឬ រដ្ឋាភិបាល ឧបករណ៍មិនត្រូវបានចាត់ថ្នាក់ជាដើមទុនទេ។

(ខ) ឧបករណ៍ដែលអាចលក់បានត្រូវចាត់ថ្នាក់ជាដើមទុន នៅពេលដែលសិទ្ធិលក់ត្រូវបានអនុវត្ត ប្រសិនបើអ្នកកាន់ទទួលបាននូវភាគហ៊ុនតាមសមាមាត្រនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពដែលបានវាស់ វែងដោយអនុលោមតាមស្តង់ដារនេះ។ប៉ុន្តែប្រសិនបើអ្នកកាន់មានសិទ្ធិទទួលចំនួនទឹកប្រាក់ដែលបានវាស់វែងតាមមូលដ្ឋានមួយចំនួនផ្សេងទៀត (ដូចជា គោលការណ៍គណនេយ្យទទួលស្គាល់ជាទូទៅក្នុង ប្រទេស) ឧបករណ៍ត្រូវបានចាត់ថ្នាក់ជាបំណុល។

(គ) ឧបករណ៍ត្រូវបានចាត់ថ្នាក់ជាបំណុលប្រសិនបើវាតម្រូវឱ្យអង្គភាពធ្វើការទូទាត់ទៅឱ្យអ្នកកាន់មុនពេលជំរះបញ្ជី ដូចជាភាគលាភតាមការកំណត់។

(ឃ) ឧបករណ៍ដែលអាចលក់បានដែលត្រូវបានចាត់ថ្នាក់ជាដើមទុននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានចាត់ថ្នាក់ជាបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុម។

(ង) ភាគអទិភាពដែលកំណត់ឱ្យមានការហៅមកវិញដោយអ្នកបោះផ្សាយតាមចំនួនទឹកប្រាក់ថេរ ឬអាចកំណត់បាន នៅថ្ងៃអនាគតជាក់លាក់ ឬអាចកំណត់បាន ឬ ផ្តល់ឱ្យអ្នកកាន់នូវសិទ្ធិដើម្បីតម្រូវឱ្យអ្នកបោះផ្សាយហៅត្រឡប់មកវិញនូវឧបករណ៍នៅ ឬ បន្ទាប់ពីថ្ងៃជាក់លាក់សម្រាប់ ចំនួនទឹកប្រាក់ដែល អាចកំណត់បានគឺជាបំណុលហិរញ្ញវត្ថុ។

២២.៦ ភាគហ៊ុនរបស់សមាជិកនៅអង្គភាពសហប្រតិបត្តិការ និង ឧបករណ៍ស្រដៀងគ្នាគឺជាដើមទុន ប្រសិនៈ

(ក) អង្គភាពមានសិទ្ធិឥតលក្ខខណ្ឌដើម្បីបដិសេធការហៅមកវិញនៃភាគហ៊ុនរបស់សមាជិក ឬ

(ខ) ការហៅត្រឡប់មកវិញត្រូវបានគេហាមឃាត់ដោយឥតលក្ខខណ្ឌតាមច្បាប់ក្នុងស្រុក បទបញ្ញត្តិ ឬ ធម្មនុញ្ញគ្រប់គ្រងរបស់អង្គភាព។

## ការបោះផ្សាយភាគហ៊ុនដំបូង ឬ ឧបករណ៍ដើមទុនផ្សេងទៀត

២២.៧ អង្គភាពត្រូវទទួលស្គាល់ការបោះផ្សាយភាគហ៊ុន ឬឧបករណ៍ដើមទុនផ្សេងទៀតជាដើមទុនពេលអង្គភាពបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុទាំងនោះ និងភាគីមួយទៀតមានកាតព្វកិច្ចផ្តល់សាច់ប្រាក់ ឬធនធានផ្សេងទៀតទៅឱ្យអង្គភាពក្នុងការដោះដូរសម្រាប់ឧបករណ៍។

(ក) ប្រសិនឧបករណ៍ដើមទុនត្រូវបានបោះផ្សាយមុនអង្គភាពទទួលបានសាច់ប្រាក់ ឬធនធានផ្សេងទៀត អង្គភាពត្រូវបង្ហាញចំនួនទឹកប្រាក់ត្រូវទទួលជាការកាត់កងទៅនឹងដើមទុននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមិនមែនជាទ្រព្យសកម្ម។

(ខ) ប្រសិនអង្គភាពទទួលបានសាច់ប្រាក់ ឬ ធនធានផ្សេងទៀតមុនពេលឧបករណ៍ដើមទុនត្រូវបានបោះផ្សាយ ហើយអង្គភាពមិនអាចត្រូវបានតម្រូវឱ្យសងត្រឡប់វិញនូវសាច់ប្រាក់ ឬ ធនធានផ្សេងទៀតដែលបានទទួល អង្គភាពត្រូវទទួលស្គាល់ការកើនឡើងស្របគ្នានៅក្នុងដើមទុនរហូតដល់តម្លៃតបស្នងត្រូវបានទទួល។

(គ) រហូតដល់ឧបករណ៍ដើមទុនត្រូវបានទិញប៉ុន្តែមិនបោះផ្សាយហើយអង្គភាពមិនទាន់ទទួលបាននូវសាច់ប្រាក់ ឬ ធនធានផ្សេងទៀត អង្គភាពមិនត្រូវទទួលការកើនឡើងនៅក្នុងដើមទុន។

២២.៨ អង្គភាពត្រូវវាស់វែងឧបករណ៍ដើមទុនតាមតម្លៃសមស្របនៃសាច់ប្រាក់ ឬធនធានដែលបានទទួលឬនឹងទទួលបាន ដកចេញចំណាយផ្ទាល់នៃការបោះផ្សាយឧបករណ៍ដើមទុន។ ប្រសិនការទូទាត់ត្រូវបានពន្យា ហើយតម្លៃពេលវេលានៃលុយមានចំនួនច្រើន ការវាស់វែងលើកដំបូងត្រូវធ្វើតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

២២.៩ អង្គភាពត្រូវទទួលស្គាល់ចំណាយប្រតិបត្តិការនៃប្រតិបត្តិការដើមទុនជាការកាត់បន្ថយពីដើមទុន ដកចេញនូវអត្ថប្រយោជន៍ពន្ធលើប្រាក់ចំណូលដែលទាក់ទិន។

២២.១០ តើការកើនឡើងនៅក្នុងដើមទុនកើតឡើងពីការបោះផ្សាយភាគហ៊ុន ឬឧបករណ៍ដើមទុនផ្សេងទៀតត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានកំណត់ដោយច្បាប់។ ឧទាហរណ៍ តម្លៃចារិក(ឬតម្លៃមានតែនាមផ្សេងទៀត)នៃភាគហ៊ុន ហើយចំនួនទឹកប្រាក់ដែលបានបង់លើសពីចំនួនតម្លៃចារិក អាចត្រូវបានបង្ហាញដោយឡែក។

## ការលក់ សិទ្ធិពិសេស សិទ្ធិ និង លិខិតធានា

២២.១១ អង្គភាពត្រូវអនុវត្តគោលការណ៍នៅក្នុងកថាខណ្ឌ ២២.៧- ២២.១០ ចំពោះដើមទុនដែលបានបោះផ្សាយតាមមធ្យោបាយនៃការលក់នៃសិទ្ធិពិសេស សិទ្ធិ និង លិខិតធានា ព្រមទាំងឧបករណ៍ដើមទុន ស្រដៀងគ្នា។

## ការមូលធនកម្ម ឬ ការបោះផ្សាយភាគហ៊ុនជាប្រាក់បន្ថែម និង ការបំបែកភាគហ៊ុន

២២.១២ការធ្វើមូលធនកម្មឬប្រាក់បន្ថែម(ពេលខ្លះត្រូវបានសំដៅទៅលើភាគលាភជាភាគហ៊ុន)គឺជាការបោះផ្សាយ

ភាគហ៊ុនថ្មីទៅឲ្យម្ចាស់ភាគហ៊ុន នៅក្នុងសមាមាត្រចំពោះភាគហ៊ុនមានស្រាប់។ ឧទាហរណ៍ អង្គភាពអាចផ្តល់ឲ្យម្ចាស់ភាគហ៊ុននូវភាគលាភមួយ ឬ ភាគហ៊ុនសម្រាប់ប្រាក់បន្ថែមសម្រាប់ រាល់ភាគហ៊ុនចំនួន៥ ដែលបានកាន់កាប់។ ការបំបែកចំណែកហ៊ុន (ពេលខ្លះត្រូវបានសំដៅទៅលើការ បំបែកភាគហ៊ុន) គឺជាចែកភាគហ៊ុនដែលមានស្រាប់ជាចំណែកហ៊ុនច្រើន។ឧទាហរណ៍ នៅក្នុងការបំបែកចំណែកហ៊ុនម្ចាស់ភាគហ៊ុននីមួយៗអាចទទួលចំណែកហ៊ុនបន្ថែមមួយទៀតសម្រាប់ចំណែកហ៊ុនដែលបានកាន់កាប់។ ក្នុងករណីខ្លះ ចំណែកហ៊ុនដែលកំពុងជួញដូរពីមុនត្រូវបានលុបចោលនិងជំនួសដោយចំណែកហ៊ុនថ្មី។ការធ្វើមូលធនកម្ម និង បោះផ្សាយប្រាក់បន្ថែមនិងការបំបែកចំណែកហ៊ុនមិនបានផ្លាស់ប្តូរតម្លៃដើមទុនសរុបទេ។អង្គភាពត្រូវចាត់ថ្នាក់ឡើងវិញនូវចំនួនទឹកប្រាក់នៅក្នុងដើមទុន ដែលតម្រូវដោយច្បាប់។

### បំណុលអាចបំលែងបាន ឬ ឧបករណ៍ហិរញ្ញវត្ថុផ្សំស្រដៀងគ្នា

២២.១២ ក្នុងការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុបំណុលអាចបំលែងបាន ឬឧបករណ៍ហិរញ្ញវត្ថុផ្សំស្រដៀងគ្នាដែលមានទាំងសមាសធាតុបំណុល និង ដើមទុន អង្គភាពត្រូវបែងចែកចំណូលពីការលក់រវាង សមាសធាតុបំណុល និងសមាធាតុដើមទុន។ដើម្បីធ្វើការបែងចែក អង្គភាពត្រូវកំណត់ជាដំបូងនូវចំនួនទឹកប្រាក់បំណុល តាមតម្លៃសមស្របនៃបំណុលស្រដៀងគ្នាដែលមិនមានលក្ខណៈបំលែង ឬសមាសធាតុដើមទុនដែលពាក់ព័ន្ធស្រដៀងគ្នា។អង្គភាពត្រូវបែងចែកចំនួនទឹកប្រាក់ដែលនៅសល់ជាសមាសធាតុដើមទុន។ ចំណាយប្រតិបត្តិការត្រូវបានបែងចែករវាងសមាសធាតុបំណុលនិងសមាសធាតុដើមទុនដោយឈរលើមូលដ្ឋាននៃតម្លៃសមស្របដែលទាក់ទិន។

២២.១៤ អង្គភាពមិនត្រូវកែប្រែការបែងចែកនៅក្នុងគ្រាបន្តបន្ទាប់នោះទេ។

២២.១៥នៅក្នុងគ្រាបន្ទាប់ពីឧបករណ៍ហិរញ្ញវត្ថុត្រូវបានបោះផ្សាយ អង្គភាពត្រូវទទួលស្គាល់ជាប្រព័ន្ធនូវភាពខុសគ្នាណាមួយរវាងសមាសធាតុបំណុលនិងបំណុលប្រាក់ដើមនៅថ្ងៃផុតកំណត់ជាចំណាយ ការប្រាក់បន្ថែមដោយ **ប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព**(សូមមើលកថាខណ្ឌ ១១.១៥ - ១១.២០) ។ ឧបសម្ព័ន្ធចំពោះផ្នែកនេះពន្យល់ពីគណនេយ្យកម្មរបស់អ្នកបោះផ្សាយសម្រាប់បំណុលអាចបំលែងបាន។

### ភាគហ៊ុនរតនៈ

២២.១៦ **ភាគហ៊ុនរតនៈ**គឺជាឧបករណ៍ដើមទុនរបស់អង្គភាពដែលត្រូវបានបោះផ្សាយ និងក្រោយមក ត្រូវបានទិញត្រឡប់មកវិញដោយអង្គភាព។អង្គភាពត្រូវដកចេញពីអង្គភាពនូវតម្លៃសមស្របនៃតម្លៃតបស្នងដែលបានផ្តល់សម្រាប់ភាគហ៊ុនរតនៈ។ អង្គភាពមិនត្រូវទទួលស្គាល់ចំណេញ ឬខាតនៅក្នុង របាយការណ៍ចំណេញ ឬខាត លើការទិញ លក់ ការបោះផ្សាយ ឬ ការលុបចោលនៃភាគហ៊ុនរតនៈ។

## ការបែងចែកទៅឲ្យម្ចាស់ភាគហ៊ុន

២២.១៧អង្គភាពត្រូវកាត់បន្ថយដើមទុននូវចំនួនទឹកប្រាក់សម្រាប់ការបែងចែកទៅឲ្យម្ចាស់ភាគហ៊ុន (អ្នកកាន់ឧបករណ៍ដើមទុន) ដកចេញនូវអត្ថប្រយោជន៍ពន្ធលើប្រាក់ចំណេញដែលទាក់ទិន។ កថាខណ្ឌ២៩.២៦ ផ្តល់ការណែនាំលើការធ្វើគណនេយ្យកម្មសម្រាប់ពន្ធកាត់ទុកលើភាគលាភ។

២២.១៨ ពេលខ្លះអង្គភាពបែងចែកទ្រព្យសកម្មមិនមែនសាច់ប្រាក់ ជាភាគលាភទៅឲ្យម្ចាស់ភាគហ៊ុន។ពេលដែលអង្គភាពប្រកាសការបែងចែកបែបនេះ ហើយអង្គភាពមានកាតព្វកិច្ចបែងចែកទ្រព្យសកម្មមិនមែនសាច់ប្រាក់ទៅឲ្យម្ចាស់ភាគហ៊ុន។នៅចុង**គ្រារាយការណ៍** និង នៅថ្ងៃនៃការទូទាត់សង អង្គភាពត្រូវពិនិត្យមើលឡើងវិញ និងកែសម្រួលតម្លៃក្នុងបញ្ជីនៃបំណុលភាគលាភដើម្បីឆ្លុះ បញ្ចាំងពីការផ្លាស់ប្តូរក្នុងតម្លៃសមស្របនៃទ្រព្យសកម្មត្រូវបែងចែកជាមួយនឹងការផ្លាស់ប្តូរដែលបានទទួលស្គាល់នៅក្នុង ដើមទុនជាការកែសម្រួលចំពោះចំនួនទឹកប្រាក់នៃការបែងចែក។

## ភាគកម្មអប្បភាគនិងប្រតិបត្តិការជាភាគហ៊ុននៃក្រុមហ៊ុនបុត្រសម្ព័ន្ធរួម

២២.១៩ នៅក្នុង**របាយការណ៍ហិរញ្ញវត្ថុរួម**ភាគកម្មអប្បភាគនៅក្នុងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺត្រូវបានបញ្ចូលទៅក្នុងដើមទុន។ អង្គភាពត្រូវទទួលស្គាល់ការផ្លាស់ប្តូរនៅក្នុងភាគកម្មភាគច្រើនរបស់ក្រុមហ៊ុនមេនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនកើតមាននូវការបាត់បង់ការគ្រប់គ្រងជាប្រតិបត្តិការជាមួយអ្នកកាន់ដើមទុននៅក្នុងសមត្ថភាពរបស់គេជាអ្នកកាន់ដើមទុន។ ដូច្នេះតម្លៃក្នុង បញ្ជីនៃភាគកម្មអប្បភាគត្រូវកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរក្នុងភាគកម្មរបស់ក្រុមហ៊ុនមេនៅក្នុងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ភាពខុសគ្នាណាមួយរវាងចំនួនទឹកប្រាក់ដែលភាគកម្មអប្បភាគត្រូវបានគេកែសម្រួល ហើយតម្លៃសមស្របនៃតម្លៃតបស្នងដែលបង់ឬទទួល ប្រសិនបើមាន ត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងដើមទុន និង បែងចែកទៅឲ្យអ្នកកាន់ដើមទុនរបស់ក្រុមហ៊ុនមេ។ អង្គភាពមិនត្រូវទទួលស្គាល់ចំណេញ ឬខាតលើការផ្លាស់ប្តូរទាំងនេះ។ ជាមួយគ្នានេះ អង្គភាពក៏មិនត្រូវទទួលស្គាល់ការផ្លាស់ប្តូរណាមួយនៅក្នុង**តម្លៃក្នុងបញ្ជី**នៃទ្រព្យសកម្ម(រួមបញ្ចូលមូលនិធិពាណិជ្ជកម្មរបស់ក្រុមហ៊ុន) ឬ បំណុលដែលកើតចេញពីប្រតិបត្តិការបែបនេះ។

## ផ្នែកទី២៣
## ចំណូល

វិសាលភាពនៃផ្នែកនេះ

---

២៣.១ ផ្នែកនេះត្រូវបានអនុវត្តក្នុងគណនេយ្យកម្មសម្រាប់**ចំណូល**ដែលកើតឡើងពីប្រតិបត្តិការខាងនិងព្រឹត្តិការណ៍ខាងក្រោម:

(ក) ការលក់ទំនិញ(មិនថាតើត្រូវបានផលិតដោយអង្គភាពសម្រាប់គោលបំណងលក់ឬត្រូវបានទិញសម្រាប់លក់វិញ)

(ខ) ការផ្តល់សេវាកម្ម

(គ) កិច្ចសន្យាសាងសង់ដែលអង្គភាពជាអ្នកទទួលម៉ៅការសាងសង់

(ឃ) ការប្រើទ្រព្យសកម្មរបស់អង្គភាពដោយភាគីផ្សេងទៀតដែលផ្តល់ជាការប្រាក់ សួយសារអាករឬ ភាគលាភ។

២៣.២ ចំណូលឬចំណូលផ្សេងទៀតដែលកើតចេញពីប្រតិបត្តិការនិងព្រឹត្តិការណ៍ត្រូវបានដោះស្រាយនៅក្នុងផ្នែកផ្សេងទៀតនៃស្តង់ដារនេះ

(ក) កិច្ចព្រមព្រៀងភតិសន្យា (សូមមើលផ្នែកទី២០ *ភតិសន្យា*)

(ខ)ភាគលាភនិងចំណូលផ្សេងទៀតកើតចេញពីការវិនិយោគដែលត្រូវធ្វើគណនេយ្យកម្មដោយវិធីសាស្រ្តដើមទុន(សូមមើលផ្នែកទី១៤ *ការវិនិយោគក្នុងក្រុមហ៊ុនញាត្តិសម្ព័ន្ធ*និង ផ្នែកទី១៥ *ការវិនិយោគនៅក្នុងក្រុមហ៊ុនរួមទុន*)។

(គ) ការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃ **ទ្រព្យសកម្មហិរញ្ញវត្ថុ**និង **បំណុលហិរញ្ញវត្ថុ** ឬ ការ លក់ចោល (សូមមើលកថាខណ្ឌ១១ *ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញ*និង ផ្នែកទី១២ ការបោះផ្សាយឧបករណ៍ហិរញ្ញ វត្ថុ)។

(ឃ) ការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃ**ទ្រព្យវិនិយោគ**(សូមមើលផ្នែកទី១៦ *ទ្រព្យវិនិយោគ*)

(ង)**ការទទួលស្គាល់**ដំបូងនិងការប្រែប្រួលនៅក្នុងតម្លៃសមស្របនៃ**ទ្រព្យសកម្មជីវសាស្រ្ត**ទាក់ទងនឹងសកម្មភាពកសិកម្ម(សូមមើលផ្នែកទី៣៤ *សកម្មភាពពិសេស*)

(ច) ការទទួលស្គាល់ដំបូង នៃផលិតផលកសិកម្ម(សូមមើលផ្នែកទី៣៤)។

### ការវាស់វែងចំណូល

២៣.៣ អង្គភាពត្រូវវាស់វែងចំណូលតាមតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួលឬនឹងទទួល។ តម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួលឬនឹងទទួលត្រូវគិតពីចំនួនទឹកប្រាក់នៃអប្បបហារ អប្បបហារការទូទាត់ភ្លាម និង ប្រាក់សងមកវិញតាមទំហំដែលអនុញ្ញាតិដោយអង្គភាព។

២៣.៤ អង្គភាពត្រូវបញ្ចូលនៅក្នុងចំណូលតែលំហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានទទួល និងនឹងត្រូវទទួលដោយអង្គភាពនៅក្នុងគណនីផ្ទាល់ខ្លួន។ អង្គភាពត្រូវដកចេញពីចំណូលនូវចំនួនទឹកប្រាក់ទាំងអស់ដែលប្រមូលបានក្នុងនាមភាគីទី៣ ដូចជាពន្ធលក់ ពន្ធលើទំនិញនិងសេវា និងអាករលើតម្លៃបន្ថែម។ នៅក្នុងទំនាក់ទំនងភ្នាក់ងារ អង្គភាពត្រូវបញ្ចូលក្នុងចំណូលតែចំនួនទឹកប្រាក់កំរៃជើងសារ។ ចំនួនទឹកប្រាក់ដែល បានប្រមូលក្នុងនាមម្ចាស់ភាគហ៊ុនមិនមែនជាចំណូលរបស់អង្គភាពទេ។

### ការទូទាត់សងពន្យា

២៣.៥ នៅពេលលំហូរចូលសាច់ប្រាក់ឬសាច់ប្រាក់សមមូលត្រូវបានពន្យា និង ការកិច្ចព្រមព្រៀងចូលជាធរមានបានចូលរួមឲ្យមានប្រតិបត្តិការហិរញ្ញប្បទានតម្លៃសមស្របនៃតម្លៃតបស្នងគឺជា**តម្លៃបច្ចុប្បន្ន**នៃសាច់ប្រាក់អនាគតទាំងអស់ដែលបានកំណត់ដោយប្រើអត្រាការប្រាក់ជាប់បន្ទុក។ ប្រតិបត្តិការហិរញ្ញ ប្បទានកើតឡើង ឧទាហរណ៍ នៅពេលអង្គភាពផ្តល់ឥណទានគ្មានការប្រាក់ទៅឲ្យអ្នកទិញ ឬ ទទួលយកប័ណ្ណត្រូវទទួល ដែលមានអត្រាការប្រាក់ទាបជាងទីផ្សារពីអ្នកទិញជាតម្លៃតបស្នងសម្រាប់ការលក់ទំនិញ។ អត្រាការប្រាក់ជាប់បន្ទុកត្រូវបានកំណត់យ៉ាងច្បាស់ នៃៈ

(ក) អត្រាទូទៅសម្រាប់ឧបករណ៍ស្រដៀងគ្នារបស់អ្នកបោះផ្សាយជាមួយអត្រាឥណទានស្រដៀងគ្នា ឬ

(ខ)អត្រាការប្រាក់ដែលអប្បបហារតម្លៃធម្មតារបស់ឧបករណ៍ទៅតម្លៃលក់បានជាសាច់ប្រាក់នៃទំនិញ ឬ សេវាកម្ម។ អង្គភាពត្រូវទទួលស្គាល់ភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃប្រាក់ទទួលអនាគតទាំងអស់ និងតម្លៃធម្មតា នៃតម្លៃតបស្នងជាចំណូលការប្រាក់ដោយអនុលោមតាមកថាខណ្ឌ២៣.២៨ និង ២៣.២៩ និង ផ្នែកទី១១។

### ការដោះដូរទំនិញ ឬសេវាកម្ម

២៣.៦ អង្គភាពមិនត្រូវទទួលស្គាល់ចំណូលៈ

(ក) នៅពេលទំនិញឬសេវាត្រូវបានដោះដូរសម្រាប់ទំនិញឬសេវាដែលមានលក្ខណៈ និងតម្លៃស្រដៀងគ្នា , ឬ

(ខ)នៅពេលទំនិញ ឬ សេវាកម្មត្រូវបានដោះដូរសម្រាប់ទំនិញ ឬសេវាកម្មមិនស្រដៀងគ្នា ប៉ុន្តែប្រតិបត្តិការខ្វះស្ថានភាពជាលក្ខណៈពាណិជ្ជកម្ម

២៣.៧ អង្គភាពត្រូវទទួលស្គាល់ចំណូលនៅពេលទំនិញត្រូវបានលក់ឬសេវាកម្មត្រូវបានដោះដូរសម្រាប់ទំនិញឬសេវាកម្មមិនស្រដៀងគ្នាក្នុងប្រតិបត្តិការដែលមានស្ថានភាពជាលក្ខណៈពាណិជ្ជកម្ម។នៅក្នុងករណីនោះ អង្គភាពត្រូវវាស់វែងប្រតិបត្តិការនោះតាមៈ

(ក)តម្លៃសមស្របនៃទំនិញឬសេវាកម្មដែលបានទទួល កែសម្រួលដោយសាច់ប្រាក់ឬសាច់ប្រាក់សមមូលដែលបានផ្ទេរ ឬ

(ខ)ប្រសិនបើចំនួនទឹកប្រាក់ក្រោម(ក)មិនអាចត្រូវបានវាស់វែងដោយជឿជាក់ ដូច្នេះតាមតម្លៃសមស្របនៃទំនិញ ឬសេវាកម្មដែលបានលះបង់ត្រូវបានកែសម្រួលដោយសាច់ប្រាក់ ឬសាច់ប្រាក់សមមូលដែលបានផ្ទេរ ឬ

(គ)ប្រសិនបើតម្លៃសមស្របទាំងទ្រព្យសកម្មដែលបានទទួល និងទ្រព្យសកម្មមិនត្រូវលះបង់ចោលទេ អាចត្រូវបានវាស់វែងដោយជឿជាក់ ដូច្នេះតាមតម្លៃទ្រព្យសកម្មដែលបានលះបង់ត្រូវបានកែសម្រួលដោយចំនួនទឹកប្រាក់នៃសាច់ប្រាក់ ឬសាច់ប្រាក់ឬសាច់ប្រាក់សមមូលដែលបានផ្ទេរ។

## ការធ្វើអត្តសញ្ញាណនៃប្រតិបត្តិការចំណូល

២៣.៨ អង្គភាពធម្មអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំណូលនៅក្នុងផ្នែកនេះដាច់ដោយឡែកចំពោះប្រតិបត្តិការនីមួយៗ។ប៉ុន្តែ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះសមាសធាតុដែលអាចកំណត់បានដោយឡែកនៃប្រតិបត្តិការទោលនៅពេលចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនៃប្រតិបត្តិការ។ ឧទាហរណ៍ អង្គភាពអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះសមាសធាតុដែលអាច កំណត់បាននៃប្រតិបត្តិការទោលពេលតម្លៃលក់នៃផលិតផលរួមបញ្ចូលចំនួនទឹកប្រាក់ដែលអាចកំណត់បានសម្រាប់ការផ្តល់សេវាកម្មពេលក្រោយ។ ផ្ទុយទៅវិញ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យទទួលស្គាល់ចំពោះប្រតិបត្តិការពីរឬច្រើនជាមួយគ្នា នៅពេលជាមួយគ្នាដែរ ពេលអង្គភាពលក់ទំនិញនិងបានចុះកិច្ចព្រមព្រៀងដោយឡែកដើម្បីទិញមកវិញនូវទំនិញនៅថ្ងៃក្រោយ ដូច្នេះត្រូវបដិសេធចោលនូវផលប៉ះពាល់ខ្លាំងនៃប្រតិបត្តិការ។

២៣.៩ ពេលខ្លះ ជាផ្នែកមួយនៃប្រតិបត្តិការលក់ អង្គភាពផ្តល់ឱ្យអតិថិជនរបស់ខ្លួននូវរង្វាន់ពីភាពស្មោះត្រង់ដែលអតិថិជនអាចហៅមកវិញនៅពេលអនាគតចំពោះទំនិញឬសេវាបញ្ចុះតម្លៃឬមិនគិតតម្លៃ។ ក្នុងករណីនេះដោយអនុលោមតាមកថាខណ្ឌ២៣.៨ អង្គភាពត្រូវធ្វើគណនេយ្យកម្មលើឥណទានជា រង្វាន់ជាសមាសធាតុដែលអាចកំណត់បានដោយឡែកនៃប្រតិបត្តិការលក់ដំបូង។អង្គភាពត្រូវបែងចែកតម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ឬ នឹងត្រូវទទួលទាក់ទងនឹងការលក់ដំបូង រវាងឥណទានរង្វាន់ និង សមាសធាតុលក់ផ្សេងទៀត។ តម្លៃតបស្នងដែលបានបែងចែកទៅឱ្យឥណទានជារង្វាន់ត្រូវវាស់វែងដោយយោងទៅលើតម្លៃសមស្រប ពោលគឺ ចំនួនទឹកប្រាក់ដែលឥណទានជារង្វាន់ អាចត្រូវបានលក់ដាច់ដោយឡែក។

២៣.១០ អង្គភាពត្រូវទទួលស្គាល់ចំនួនពីការលក់ទំនិញពេលលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ។

(ក) អង្គភាពបានផ្ទេរទៅឱ្យអ្នកទិញនូវហានិភ័យនិងផលប្រយោជន៍សំខាន់ៗនៃកម្មសិទ្ធិនៃទំនិញ

(ខ) អង្គភាពមិនរក្សានូវការជាប់ពាក់ព័ន្ធលើការគ្រប់គ្រងបន្តក្នុងកម្រិតណាមួយដែលជាប់ទាក់ទងនឹងកម្មសិទ្ធិ និង មិនមានការគ្រប់គ្រងជាធរមានលើទំនិញដែលបានលក់ទៀតទេ។

(គ) ចំនួនទឹកប្រាក់ចនៃចំណូលអាចវាស់វែងបានដោយជឿជាក់

(ឃ) វាប្រហែលថា អត្ថប្រយោជន៍សេដ្ឋកិច្ចដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរមកកាន់អង្គភាព

(ង) ថ្លៃដើមដែលបានកើតឡើង ឬ នឹងកើតឡើងទាក់ទងនឹងប្រតិបត្តិការអាចវាស់វែងដោយជឿ ជាក់។

២៣.១១ ការវាយតម្លៃពីពេលណាដែលអង្គភាពមួយបាននូវហានិយភ័យសំខាន់ៗនិងផលប្រយោជន៍នៃកម្មសិទ្ធិទៅឱ្យអ្នកទិញ គឺតម្រូវឱ្យមានការត្រួតពិនិត្យនៃស្ថានភាពប្រតិបត្តិការ។ នៅក្នុងករណីភាគច្រើន ការផ្ទេរហានិភ័យនិងផលប្រយោជន៍នៃកម្មសិទ្ធិកើតឡើងព្រមគ្នាជាមួយនឹងការផ្ទេរកម្មសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់ទៅឱ្យអ្នកទិញ។នេះជាករណីសម្រាប់ការលក់ភាគច្រើន។នៅក្នុងករណីផ្សេងទៀត ការផ្ទេរហានិយភ័យនិងផលប្រយោជន៍នៃកម្មសិទ្ធិកើតមានឡើងនៅពេលខុសគ្នាពីការផ្ទេរកម្មសិទ្ធិស្របច្បាប់ ឬ ការផ្ទេរការកាន់កាប់។

២៣.១២ អង្គភាពមិនទទួលស្គាល់ចំណូលទេប្រសិនអង្គភាពនៅរក្សាបើហានិភ័យនៃកម្មសិទ្ធិសំខាន់ៗ។ ឧទាហរណ៍នៅក្នុងករណីដែលអង្គភាពអាចរក្សាហានិភ័យនិងប្រយោជន៍សំខាន់ៗនៃកម្មសិទ្ធិ គឺៈ

(ក)នៅពេលដែលអង្គភាពរក្សានូវកាតព្វកិច្ចសម្រាប់ការអនុវត្តមិនពេញចិត្តដែលមិនត្រូវបានគ្របដណ្តប់ដោយការធានាជាធម្មតា

(ខ)នៅពេលដែលការទទួលប្រាក់ចំណូលពីការលក់ជាក់លាក់មានលក្ខណៈយថាហេតុលើរបស់អ្នកទិញទំនិញ

(គ)នៅពេលដែលទំនិញត្រូវបានដឹកជញ្ជូនដែលជាកម្មវត្ថុត្រូវតំឡើង ហើយការតំឡើងគឺជាផ្នែកមួយសំខាន់នៃកិច្ចព្រមព្រៀងដែលមិនទាន់បានបំពេញចប់នៅឡើយ។

(ឃ)នៅពេលដែលអ្នកទិញមានសិទ្ធិចាត់ទុកជាមោឃៈនូវការទិញក្នុងហេតុផលដែលបានចែងនៅក្នុងកិច្ចសន្យា ឬតាមការសម្រេចជាឯកតោភាគីរបស់អ្នកទិញដោយគ្មានហេតុផលឡើយ ហើយអង្គភាពមិនប្រាកដអំពីភាវនីយភាពនៃបង្វិលទំនិញមកវិញ។

២៣.១៣ ប្រសិនបើអង្គភាពរក្សាទុកតែហានិយភ័យនៃកម្មសិទ្ធិមិនសំខាន់ ប្រតិបត្តិការគឺជាការលក់ ហើយអង្គភាពត្រូវទទួលស្គាល់ចំណូល។ឧទាហរណ៍ អ្នកលក់ទទួលស្គាល់ចំណូលពេលអង្គភាពរក្សា នូវកម្មសិទ្ធិស្របច្បាប់ចំពោះទំនិញតែឯងដើម្បីការពារការប្រមូលប្រាក់ដែលនៅជំពាក់។ស្រដៀងគ្នានេះ អង្គភាពត្រូវទទួលស្គាល់ចំណូលពេលអង្គភាពផ្តល់ឱ្យមានការបង្វិលប្រាក់វិញប្រសិនបើអតិថិជនរកឃើញថាទំនិញបានខូចឬមិនបានបំពេញចិត្ត

ក្នុងហេតុផលផ្សេងៗ ហើយអង្គភាពអាចប៉ាន់ស្មានពីការបង្វិលទំនិញមកវិញដោយជឿជាក់។ នៅក្នុងករណីបែបនេះ អង្គភាពទទួលស្គាល់សំវិធានធនសម្រាប់បង្វិលទំនិញមកវិញដោយអនុលោមតាមផ្នែកទី២១ *សំវិធានធន និង យថាហេតុ*។

## ការផ្តល់សេវាកម្ម

២៣.១៤ ពេលលទ្ធផលនៃប្រតិបត្តិការពាក់ព័ន្ធនឹងការផ្តល់សេវាកម្មអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់អង្គភាពត្រូវទទួលស្គាល់ចំណូលដែលទាក់ទងនឹងប្រតិបត្តិការនោះដោយយោងតាមដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនៅចុងគ្រារាយការណ៍(ជួនកាលត្រូវបានគេសំដៅលើវិធីសាស្ត្របញ្ចប់ការងារតាមភាគរយ)។ លទ្ធផលនៃប្រតិបត្តិការអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់នៅពេលលក្ខខណ្ឌខាងក្រោមទាំងអស់ត្រូវបានបំពេញៈ

(ក) ចំនួនទឹកប្រាក់អាចវាស់វែងដោយជឿជាក់

(ខ) វាប្រហែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលមកកាន់អង្គភាព។

(គ) ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការនៅចុងគ្រារាយការណ៍អាចវាស់វែងដោយជឿជាក់

(ឃ) ចំណាយដែលបានកើតឡើងចំពោះប្រតិបត្តិការនិងចំណាយត្រូវបញ្ចប់ប្រតិបត្តិការអាចវាស់វែងដោយជឿជាក់។

កថាខណ្ឌ២៣.២១ -២៣.២៧ ផ្តល់ការណែនាំសម្រាប់ការអនុវត្តវិធីសាស្ត្របញ្ចប់ភាគរយ។

២៣.១៥ពេលសេវាកម្មត្រូវបានបំពេញដោយចំនួនសកម្មភាពគ្មានកំណត់លើគ្រាជាក់លាក់អង្គភាពត្រូវទទួលស្គាល់ចំណូលតាមមូលដ្ឋានថេរលើគ្រាជាក់លាក់នោះ លុះត្រាតែមានភស្តុតាងដែលថាវិធីសាស្ត្រផ្សេងទៀតបង្ហាញពីភាពល្អប្រសើរជាងវិធីសាស្ត្រដំណាក់កាលនៃការបញ្ចប់ការងារ។ នៅពេលសកម្មភាពជាក់លាក់ មានសារៈសំខាន់ច្រើនជាងសកម្មភាពផ្សេងទៀត អង្គភាពពន្យាពេលការទទួលស្គាល់ចំណូលរហូតដល់សកម្មភាពសំខាន់ត្រូវបានអនុវត្ត។

២៣.១៦ នៅពេលដែលលទ្ធផលនៃប្រតិបត្តិការទាក់ទិននឹងការផ្តល់សេវាកម្មមិនអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ អង្គភាពត្រូវទទួលស្គាល់ចំណូលតែរហូតដល់ការចំណាយត្រូវបានទទួលស្គាល់ថានឹងអាចទទួលបានមកវិញ។

## កិច្ចសន្យាសាងសង់

២៣.១៧ នៅពេលដែលលទ្ធផលនៃ**កិច្ចសន្យាសាងសង់**អាចត្រូវបានប៉ាន់ស្មានដោយជឿជាក់ អង្គភាពត្រូវទទួលស្គាល់ចំណូលពីកិច្ចសន្យា និង ចំណាយលើកិច្ចសន្យាដែលទាក់ទងនឹងកិច្ចសន្យាសាងសង់ ជាចំណូលនិងចំណាយដោយអនុលោមតាមដំណាក់កាលនៃការបញ្ចប់សកម្មភាពកិច្ចសន្យានៅចុងគ្រារាយការណ៍(ជារឿយៗត្រូវបានគេសំដៅលើវិធីសាស្ត្របញ្ចប់តាមភាគរយ)។ការប៉ាន់ស្មានលទ្ធផល ដែលអាចជឿជាក់បានពីលទ្ធផលទាមទារ

ឲ្យមានការប៉ាន់ស្មានពីដំណាក់កាលនៃការបញ្ចប់ការងារ ចំណាយអនាគត និង ការប្រមូលប្រាក់។កថាខណ្ឌ ២៣.២១- ២៣.២៧ ផ្តល់ការណែនាំពីការអនុវត្តវិធី សាស្រ្តបញ្ចប់តាមភាគរយ។

២៣.១៨ ការតម្រូវនៃផ្នែកនេះជាធម្មតាត្រូវបានអនុវត្តដាច់ដោយឡែកចំពោះកិច្ចសន្យាសាងសង់នីមួយៗ។ ប៉ុន្តែនៅក្នុងស្ថានភាពមួយចំនួន វាចាំបាច់ត្រូវអនុវត្តផ្នែកនេះចំពោះសមាសធាតុដែលអាចកំណត់បានដាច់ដោយឡែកនៃកិច្ចសន្យាទោលឬ ក្រុមកិច្ចសន្យាជាមួយគ្នា ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនៃកិច្ចសន្យា ឬក្រុមកិច្ចសន្យា។

២៣.១៩នៅពេលកិច្ចសន្យាគ្របដណ្តប់លើទ្រព្យសកម្មមួយចំនួន ការសាងសង់នៃទ្រព្យសកម្មនីមួយៗត្រូវបានទទួលស្គាល់ជាកិច្ចសន្យាដាច់ដោយឡែកពេលៈ

(ក) សំណើដាចើដោយឡែកត្រូវបានត្រូវបានគេដាក់បញ្ជូនសម្រាប់ទ្រព្យសកម្មនីមួយៗ

(ខ) ទ្រព្យសកម្មនីមួយៗជាកម្មវត្ថុនៃការចរចារដាច់ដោយឡែក ហើយ អ្នកម៉ៅការសាងសង់ និង អតិថិជនអាចទទួលយក ឬ បដិសេធថាផ្នែកនៃកិច្ចសន្យាទាក់ទងនឹងទ្រព្យសកម្មនីមួយៗ និង

(គ) ចំណាយ និង ចំណូលនៃទ្រព្យសកម្មនីមួយអាចកំណត់បាន។

២៣.២០ក្រុមនៃកិច្ចសន្យា មិនថាតើជាមួយអតិថិជនទោល ឬជាមួយអតិថិជនច្រើនត្រូវទទួលចាត់ទុកជាកិច្ចសន្យាសាងសង់ទោល ពេលៈ

(ក) ក្រុមកិច្ចសន្យាត្រូវបានចរចារជាកញ្ចប់តែមួយ

(ខ)ពេលចូលជាធរមាន កិច្ចសន្យាទាំងឡាយមានទំនាក់ទំនងគ្នាយ៉ាងចិត្តស្និតដែលកិច្ចសន្យា ទាំងនោះគឺជាផ្នែកនៃគំរោងទោលជាមួយលំអៀងប្រាក់ចំណេញរួម និង

(គ) កិច្ចសន្យាត្រូវបានបំពេញក្នុងពេលដំណាលគ្នា ឬ តាមលំដាប់លំដោយ។

## វិធីសាស្រ្តបញ្ចប់តាមភាគរយ

២៣.២១វិធីសាស្រ្តនេះត្រូវប្រើដើម្បីទទួលស្គាល់ចំណូលពីការផ្តល់សេវាកម្ម (សូមមើកថាខណ្ឌ២៣.១៤២៣.១៦) និងពីកិច្ចសន្យាសាងសង់(សូមមើលកថាខណ្ឌ២៣.១៧-២០.២០)។អង្គភាពមួយត្រូវពិនិត្យឡើងវិញ នៅពេលចាំបាច់និងកែប្រែការប៉ាន់ស្មាននៃចំណូលនិងចំណាយដែលប្រតិបត្តិការសេវាកម្មឬកិច្ចសន្យាសាងសង់កំពុងដំណើរការ។

២៣.២២ អង្គភាពមួយត្រូវកំណត់ដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការ ឬ កិច្ចសន្យាដោយប្រើវិធីសាស្រ្តដែលវាស់វែងការងារដែលបានបំពេញប្រកបដោយជឿជាក់បំផុត។ វិធីសាស្រ្តដែលអាចកើតឡើងរួមមានៈ

(ក)សមាមាត្រដែលចំណាយបានកើតឡើងសម្រាប់ការងារដែលបានបំពេញត្រឹមថ្ងៃនេះចែកនឹងចំណាយវិធីសាស្រ្តប៉ាន់ស្មានសរុប។ចំណាយដែលបានកើតឡើងសម្រាប់ការងារដែលបានអនុវត្តត្រឹមថ្ងៃនេះមិនបញ្ចូល

ចំណាយទាក់ទងនឹងសកម្មភាពអនាគត ដូចជាវត្ថុធាតុដើម ឬ ការបង់មុន។

(ខ) ការស្ទាបស្ទង់នៃការងារដែលបានបំពេញ។

(គ) ការបញ្ចប់នៃសមាមាត្រជាក់ស្តែងនៃប្រតិបត្តិការសេវាកម្ម ឬ ការងារសាងសង់

ការទូទាត់ជាដំណាក់កាលនិងបុរេប្រទានដែលបានទទួលពីអតិថិជនជារឿយៗមិនឆ្លុះបញ្ចាំងពីការងារ ដែលបានអនុវត្ត។

២៣.២៣អង្គភាពត្រូវទទួលស្គាល់ចំណាយដែលទាក់ទងនឹងសកម្មអនាគតលើប្រតិបត្តិការឬកិច្ចសន្យា ដូចជាសម្រាប់វត្ថុធាតុដើម ឬ ការបង់មុន ជាទ្រព្យសកម្មប្រសិនបើវាប្រហែលថាចំណាយនឹងត្រូវទទួលបានមកវិញ។

២៣.២៤ អង្គភាពត្រូវទទួលស្គាល់ជាចំណាយភ្លាមនូវថ្លៃដើមណាដែលការទទួលបានមកវិញមិនទំនង ជាកើតមាន

២៣.២៥ នៅពេលដែលលទ្ធផលនៃកិច្ចសន្យាសាងសង់មិនអាចប៉ានស្មានដោយជឿជាក់ៈ

(ក)អង្គភាពត្រូវទទួលស្គាល់ចំណូលតែនៅពេលចំណាយសាងសង់បានកើតឡើងដែលចំណាយនោះនឹងអាចទទួលបានមកវិញ និង

(ខ) អង្គភាពត្រូវទទួលថ្លៃដើមនៃការសាងសង់ជាចំណាយនៅគ្រាដែលចំណាយនោះ មានកើតឡើង។

២៣.២៦ ពេលដែលវាទំនងជាថាថ្លៃដើមនៃកិច្ចសន្យានឹងលើសពីចំណូលនៃកិច្ចសន្យាសរុបក្នុងកិច្ចសន្យាកិច្ចសាងសង់ ការខាតបង់ត្រូវដែលបានរំពឹងទុកត្រូវទទួលស្គាល់ជាចំណាយភ្លាម ជាមួយនឹងសំវិធានធនស្របពេលគ្នាសម្រាប់កិច្ច សន្យាស្មុគស្មាញ(សូមមើលកថាខណ្ឌ២១)។

២៣.២៧ ប្រសិនបើការប្រមូលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ជាចំណូលសាងសង់មិនមានភាពប្រហែលទៀតទេ អង្គភាពត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលមិនអាចប្រមូលបានជាចំណាយជាជាងការកែសម្រួលនៃចំនួនទឹកប្រាក់ចំណូលសាងសង់។

## ការប្រាក់ សួយសារ និង ភាគលាភ

២៣.២៨ អង្គភាពត្រូវទទួលស្គាល់ចំណូលដែលបានកើតឡើងពីការប្រើប្រាស់ទ្រព្យសកម្មរបស់អង្គភាពដោយភាគីផ្សេងទៀត ដោយផ្តល់ជាការប្រាក់ សួយសារ និងភាគលាភដោយផ្អែកលើកថាខណ្ឌ ២៣.២៩ ពេលៈ

(ក) វាទំនងថាអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលកាន់អង្គភាព និង

(ខ) ចំនួនទឹកប្រាក់នៃចំណូលអាចវាស់វែងបានដោយជឿជាក់

២៣.២៩ អង្គភាពត្រូវទទួលស្គាល់ចំណូលលើមូលដ្ឋានដូចខាងក្រោមៈ

(ក) ការប្រាក់ត្រូវបានទទួលស្គាល់ដោយប្រើ**វិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព**ដូចបានរៀបរាប់នៅក្នុង កថាខណ្ឌ ១១.១៥-១១.២០។

(ខ) ស្ហួយសារត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្ករដោយអនុលោមតាមភាពជាក់ស្តែងនៃ កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ។

(គ) ភាគលាភត្រូវបានទទួលស្គាល់នៅពេលសិទ្ធិរបស់ម្ចាស់ភាគហ៊ុនត្រូវទទួលការទូទាត់ ត្រូវបានបង្កើតឡើង។

## ការលាតត្រដាងព័ត៌មាន

### ការលាតត្រដាងព័ត៌មានទូទៅអំពីចំណូល

២៣.៣០ អង្គភាពត្រូវបង្ហាញៈ

(ក) **គោលនយោបាយ**ដែលបានប្រើសម្រាប់ការទទួលស្គាល់ចំណូល រួមបញ្ចូលនូវវិធីសាស្ត្រដែលបានប្រើ ដើម្បីកំណត់ពីដំណាក់កាលនៃការបញ្ចប់ប្រតិបត្តិការទាក់ទងនឹងការផ្តល់សេវា កម្ម

(ខ) ចំនួនទឹកប្រាក់របស់ខ្ទង់ចំណូលនីមួយៗដែលបានទទួលស្គាល់ក្នុងកំឡុងគ្រា ដោយបង្ហាញដាច់ដោយឡែក ជាអប្បបរមា នូវចំណូលកើតចេញពីៈ

(១) ការលក់ទំនិញ

(២) ការផ្តល់សេវាកម្ម

(៣) ការប្រាក់

(៤) ស្ហួយសារ

(៥) ភាគលាភ

(៦) កំរៃជើងសារ

(៧) ជំនួយរបស់រដ្ឋាភិបាល

(៨) ប្រភេទចំណូលសំខាន់ៗផ្សេងៗទៀត

### ការលាតត្រដាងព័ត៌មានទាក់ទងនឹងចំណូលពីកិច្ចសន្យាសាងសង់

២៣.៣១ អង្គភាពត្រូវបង្ហាញនូវព័ត៌មានដូចខាងក្រោមៈ

(ក) ទឹកប្រាក់ចំណូលសាងសង់ដែលបានទទួលស្គាល់ជាចំណូលនៅក្នុងគ្រា

(ខ) វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ចំណូលសាងសង់ដែលបានទទួលក្នុងគ្រា

(គ) វិធីសាស្ត្រដែលបានប្រើដើម្បីកំណត់ដំណាក់ការនៃការបញ្ចប់កិច្ចសន្យានៅក្នុងដំណើរការ

២៣.៣២ អង្គភាពត្រូវបង្ហាញ៖

(ក) ចំនួនទឹកប្រាក់ដុលដែលអតិថិជនជំពាក់សម្រាប់ការងារសាងសង់ ជាទ្រព្យសកម្ម

(ខ) ចំនួនទឹកប្រាក់ដុលដែលអង្គភាពជំពាក់អតិថិជនសម្រាប់ការងារសាងសង់ ជាបំណុល

## ផ្នែកទី ២៤
## អំណោយរបស់រដ្ឋាភិបាល

### វិសាលភាពនៃផ្នែកនេះ

២៤.១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មសម្រាប់អំណោយរបស់រដ្ឋាភិបាលទាំងអស់។អំណោយរដ្ឋាភិបាលគឺជាជំនួយដែលផ្តល់ដោយរដ្ឋាភិបាលក្នុងទម្រង់នៃការផ្ទេរធនធានទៅឲ្យអង្គភាព ជាថ្នូរចំពោះការអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់កាលពីអតីតកាលឬនៅពេលអនាគតដែលទាក់ទងនឹងសកម្មភាពប្រតិបត្តិការទាំងឡាយរបស់អង្គភាព។

២៤.២ អំណោយរបស់រដ្ឋាភិបាលមិនរាប់បញ្ចូលទម្រង់នៃជំនួយរបស់រដ្ឋាភិបាលទាំងឡាយណាដែលអាចមានតម្លៃសមស្រប និងប្រតិបត្តិការជាមួយរដ្ឋាភិបាល ដែលមិនអាចញែកឲ្យដាច់ពីសកម្មភាពជួញដូរជាប្រក្រតីរបស់អង្គភាព។

២៤.៣ ផ្នែកនេះមិនគ្របដណ្តប់ទៅលើជំនួយរបស់រដ្ឋាភិបាលដែលត្រូវបានផ្តល់សម្រាប់អង្គភាពមួយនៅក្នុងទម្រង់ជាអត្ថប្រយោជន៍ដែលមានសម្រាប់ការកំណត់ពីប្រាក់ចំណេញជាប់ពន្ធ ឬប្រាក់ខាតពន្ធ ឬត្រូវបានកំណត់ ឬកម្រិតដោយឈរលើមូលដ្ឋាននៃបំណុលពន្ធលើប្រាក់ចំណេញ។ឧទាហរណ៍នៃអត្ថប្រយោជន៍ខាងលើគឺថ្ងៃឈប់សម្រាកជាប់ពន្ធលើប្រាក់ចំណេញ ឥណទានពន្ធវិនិយោគ ការអនុញ្ញាត ឲ្យមានរំលស់កើនឡើងតាមលំដាប់ និងការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណេញ។ ផ្នែកទី២៩ ពន្ធលើប្រាក់ចំណេញ បរិយាយពីការធ្វើគណនេយ្យកម្មលើពន្ធលើប្រាក់ចំណូល។

### ការទទួលស្គាល់ និង ការវាស់វែង

២៤.៤ អង្គភាពមួយត្រូវទទួលស្គាល់អំណោយរបស់រដ្ឋាភិបាលដូចតទៅៈ

(ក)អំណោយដែលមិនកំណត់ពីលក្ខខណ្ឌសមិទ្ធផលនាពេលអនាគតជាក់លាក់ទៅលើអ្នកទទួលអំណោយត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណូលនៅពេលដែលចំណូលពីអំណោយនោះ អាចទទួលបាន

(ខ)អំណោយដែលមិនកំណត់ពីលក្ខខណ្ឌសមិទ្ធផលនាពេលអនាគតជាក់លាក់ទៅលើអ្នកទទួលអំណោយត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណូលនៅពេលលក្ខខណ្ឌសមិទ្ធផលត្រូវបានបំពេញ។

(គ)អំណោយដែលបានទទួលមុនពេលលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ចំណូលត្រូវបានបំពេញត្រូវបានទទួលស្គាល់ជាបំណុល។

២៤.៥ អង្គភាពមួយត្រូវវាស់វែងអំណោយតាមតម្លៃសមស្របនៃទ្រព្យសកម្មដែលបានទទួល ឬត្រូវទទួលបាន។

២៤.៦ អង្គភាពមួយត្រូវលាតត្រដាងបង្ហាញអំពីអំណោយរបស់រដ្ឋាភិបាលដូចខាងក្រោមៈ

(ក)ប្រភេទនិងចំនួនទឹកប្រាក់ជាអំណោយរបស់រដ្ឋាភិបាលដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(ខ)លក្ខខណ្ឌមិនទាន់បានបំពេញនិងកត្តាយថាហេតុផ្សេងទៀតដែលភ្ជាប់ជាមួយអំណោយរបស់រដ្ឋាភិបាលដែលមិនត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណូល

(គ)ការបញ្ជាក់ពីទម្រង់ផ្សេងៗនៃជំនួយរបស់រដ្ឋាភិបាលដែលអង្គភាពទទួលបានផលប្រយោជន៍ដោយផ្ទាល់។

២៤.៧ សម្រាប់គោលនៃការលាតត្រដាងបង្ហាញព័ត៌មានដែលតម្រូវដោយកថាខណ្ឌ២៤.៦(គ) ជំនួយរបស់រដ្ឋាភិបាលគឺជាសកម្មភាពដោយរដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចជាក់លាក់ចំពោះអង្គភាពមួយ ឬ អង្គភាពច្រើន ដែលមានគុណវុឌ្ឍគ្រប់គ្រាន់ក្រោមលក្ខណៈវិនិច្ឆ័យច្បាស់លាស់។ ឧទាហរណ៍ រួមមានយោបល់បច្ចេកទេស ឬ ទីផ្សារដោយឥតគិតថ្លៃ ការផ្តល់ការធានា និង កម្ចីមានអត្រា ការប្រាក់សូន្យ ឬ ទាប។

# ផ្នែកទី ២៥

## បន្ទុកហិរញ្ញវត្ថុ

### វិសាលភាពនៃផ្នែកនេះ

២៥.១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មលើបន្ទុកលើប្រាក់កម្ចី។បន្ទុកលើប្រាក់កម្ចីគឺជាបន្ទុកការប្រាក់និងបន្ទុកផ្សេងទៀតដែលអង្គភាពបានចំណាយទាក់ទិននឹងការខ្ចីប្រាក់។ បន្ទុកលើប្រាក់កម្ចីរួមមាន ÷

(ក)ចំណាយការប្រាក់ដែលបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ដូចដែលបានបរិយាយ នៅក្នុងផ្នែកទី១១ ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញ។

(ខ)បន្ទុកហិរញ្ញវត្ថុទាក់ទងនឹងភតិសន្យាហិរញ្ញវត្ថុដែលបានទទួលស្គាល់ដោយអនុលោមតាមផ្នែកទី២០ ភតិសន្យា

(គ)ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណលើការខ្ចីរូបិយប័ណ្ណបរទេសរហូតដល់ភាពខុសគ្នាទាំងនោះត្រូវបានចាត់ទុកជាការកែសម្រួលចំពោះបន្ទុកការប្រាក់។

### ការទទួលស្គាល់

២៥.២ អង្គភាពមួយត្រូវទទួលស្គាល់បន្ទុកលើប្រាក់កម្ចីទាំងអស់ជាចំណាយនៅក្នុងរបាយការណ៍ចំណេញឬខាតក្នុងគ្រាដែលបន្ទុកនោះបានកើតឡើង។

### ការលាតត្រដាងបង្ហាញព័ត៌មាន

២៥.៣ កថាខណ្ឌ ៥.៥(ខ) តម្រូវឲ្យមានលាតត្រដាងបង្ហាញពីបន្ទុកហិរញ្ញវត្ថុ។ កថាខណ្ឌ១១.៤៨ (ខ) តម្រូវ ឲ្យលាតត្រដាងបង្ហាញពីការចំណាយការប្រាក់សរុប (ដោយប្រើប្រាស់ វិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព) សម្រាប់បំណុលហិរញ្ញវត្ថុដែលមិនតាមតម្លៃសមស្របតាមរយៈរបាយការណ៍ចំណេញឬខាត។ផ្នែកនេះមិនតម្រូវឲ្យមានការលាតត្រដាងបង្ហាញបន្ថែមទៀតទេ។

# ផ្នែកទី ២៦
# ការទូទាត់ផ្អែកលើសន្លឹកហ៊ុន

## វិសាលភាពនៃផ្នែកនេះ

២៦. ១ ផ្នែកនេះបញ្ជាក់ពីការធ្វើគណនេយ្យកម្មប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន រួមមាន៖

(ក)ប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនជាដើមទុន ដែលអង្គភាពទិញទំនិញ ឬ សេវា ដោយតម្លៃតបស្នងជាឧបករណ៍ដើមទុនរបស់អង្គភាពនោះ(រួមមានភាគហ៊ុន ឬ សិទ្ធិទិញឬលក់ភាគហ៊ុននាពេល អនាគត) ,

(ខ)ប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន ជាសាច់ប្រាក់ ដែលអង្គភាពទិញទំនិញ ឬសេវា ដោយការកើតឡើងនូវបំណុលចំពោះអ្នកផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះនូវចំនួនទឹកប្រាក់ដែលផ្អែកលើថ្លៃ(ឬតម្លៃ) នៃសន្លឹកហ៊ុនរបស់អង្គភាព ឬ ឧបករណ៍ដើមទុនផ្សេងទៀតរបស់អង្គភាព និង

(គ)ប្រតិបត្តិការដែលអង្គភាពទទួល ឬ ទិញទំនិញ ឬសេវា និង លក្ខខណ្ឌនៃការរៀបចំផ្តល់ឲ្យទាំងអង្គភាព ឬ អ្នកផ្គត់ផ្គង់ទំនិញឬសេវាជាមួយជម្រើស ថាតើអង្គភាពទូទាត់ប្រតិបត្តិការជាសាច់ប្រាក់ (ឬទ្រព្យសកម្មផ្សេងទៀត) ឬ ដោយការចេញឲ្យផ្សាយឧបករណ៍ដើមទុន។

២៦.២ ប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន ជាសាច់ប្រាក់ រួមមានសិទ្ធិបង្កើនភាគហ៊ុន។ ឧទាហរណ៍ អង្គភាពអាចផ្តល់សិទ្ធិបង្កើនភាគហ៊ុនទៅឲ្យនិយោជិកជាផ្នែកមួយនៃកញ្ចប់ប្រាក់កម្រៃដែលនិយោជិកនឹងមានសិទ្ធិទទួលចំពោះការទូទាត់សាច់ប្រាក់អនាគត(ក្រៅពីឧបករណ៍ដើមទុន)ដោយផ្អែកលើការកើនឡើងនៅក្នុងតម្លៃភាគហ៊ុនរបស់អង្គភាពពីកម្រិតជាក់លាក់មួយក្នុងរយៈពេលជាក់លាក់មួយ។ ឬ អង្គភាពអាចផ្តល់ឲ្យ និយោជិកនូវសិទ្ធិដើម្បីទទួលការទូទាត់សាច់ប្រាក់អនាគតដោយផ្តល់ទៅឲ្យពួកគេនូវសិទ្ធិចំពោះភាគហ៊ុន (រួមបញ្ចូលភាគហ៊ុនដែលត្រូវបោះផ្សាយនៅពេលមានការអនុវត្តសិទ្ធិពិសេសទិញលក់សន្លឹកហ៊ុននាពេលអនាគត) ដែលអាចហៅទិញត្រឡប់មកវិញបានទាំងដល់ពេលកំណត់(នៅពេលឈប់បំពេញការងារ)ឬនៅពេលដែលនិយោជិកអនុវត្តសិទ្ធិពិសេស។

## ការទទួលស្គាល់

២៦.៣ អង្គភាពមួយត្រូវទទួលស្គាល់ទំនិញឬសេវាដែលបានទទួលឬបានទិញនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុននៅពេលដែលអង្គភាពទទួលបានជាទំនិញ ឬ ជាសេវាកម្ម។ អង្គភាពត្រូវទទួលស្គាល់ការកើនឡើងនៅក្នុងគណនីមូលនិធិប្រសិនបើទំនិញ ឬសេវាត្រូវបានទទួលនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន តាមគណនីមូលនិធិឬបំណុល ប្រសិនបើទំនិញឬសេវាត្រូវបានទិញនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនតាមរយៈសាច់ប្រាក់។

២៦.៤ នៅពេលទំនិញ ឬសេវាដែលបានទទួល ឬបានទិញនៅក្នុងប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនមិនបំពេញឲ្យលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ទ្រព្យសកម្ម អង្គភាពត្រូវទទួលស្គាល់ទំនិញ ឬ សេវានោះជាចំណាយ។

### ការទទួលស្គាល់នៅពេលដែលមានលក្ខខណ្ឌផ្ទេរឲ្យ

២៦.៥ នៅពេលដែលការទូទាត់ផ្អែកលើសន្លឹកហ៊ុនទៅឲ្យនិយោជិកផ្ទេរឲ្យភ្លាម និយោជិកមិនតម្រូវឲ្យបំពេញសេវាកម្មក្នុងគ្រាជាក់លាក់មួយទេ មុនពេលនិយោជិកទាំងនោះមានសិទ្ធិទទួលដោយឥតលក្ខខណ្ឌនូវការទូទាត់ផ្អែកលើសន្លឹកហ៊ុន។នៅក្នុងអវត្តមាននៃភស្តុតាងចំពោះការជំទាស់ អង្គភាពត្រូវសន្មតជាមុនថា សេវាកម្មដែលបានផ្តល់ដោយនិយោជិកជាតម្លៃតបស្នងសម្រាប់ការទូទាត់ផ្អែកលើសន្លឹកហ៊ុន។នៅក្នុងករណីនេះ នៅថ្ងៃផ្តល់ក្រុមហ៊ុនត្រូវទទួលស្គាល់សេវាដែលបានទទួលពេញលេញ ជាមួយនឹងការកើនឡើងគណនីមូលនិធិ ឬ ដើមទុន។

២៦.៦ ប្រសិនបើការទូទាត់ផ្អែកលើសន្លឹកហ៊ុនមិនបានផ្ទេរឲ្យទេរហូតដល់និយោជិកបំពេញសេវាក្នុងរយៈពេលមួយកំណត់ អង្គភាពត្រូវសន្មត់ជាមុនថា សេវា កម្មទាំងឡាយដែលត្រូវផ្តល់ដោយភាគីម្ខាងទៀត ជាតម្លៃតបស្នងសម្រាប់ការទូទាត់ផ្អែកលើសន្លឹកហ៊ុននឹងត្រូវបានទទួលនៅពេលអនាគតក្នុងកំឡុងពេលផ្ទេរឲ្យ។អង្គភាពត្រូវទទួលស្គាល់សេវាទាំងនោះនៅពេលដែលសេវាត្រូវបានផ្តល់ដោយនិយោជិកក្នុងកំឡុងគ្រាផ្ទេរឲ្យ ជាមួយនឹងការកើនឡើងនៅក្នុងគណនី ឬ បំណុល។

### ការវាស់វែងប្រតិបត្តិការទូទាត់ដោយផ្អែកលើសន្លឹកហ៊ុនដែលទូទាត់តាមមូល និធិផ្ទាល់

#### គោលការណ៍នៃការវាស់វែង

២៦.៧ ប្រតិបត្តិការទូទាត់ដោយផ្អែកលើសន្លឹកហ៊ុនតាមមូលនិធិ អង្គភាពត្រូវវាស់វែងទំនិញ ឬសេវាកម្មបានទទួល និងការកើនឡើងនៅក្នុងគណនីមូលនិធិ តាមតម្លៃសមស្របនៃទំនិញ ឬសេវា កម្មបានទទួល រហូតដល់តម្លៃសមស្របនោះមិនអាចត្រូវបានប៉ាន់ស្មានដោយជឿជាក់។ប្រសិនបើអង្គភាពមិនអាចប៉ាន់ស្មានដោយជឿជាក់ តម្លៃសមស្របនៃទំនិញ ឬ សេវាកម្មដែលបានទទួល អង្គភាពត្រូវវាស់វែងតម្លៃរបស់ទំនិញ និង សេវាកម្ម នោះ និងការកើនឡើងនៅក្នុងមូលនិធិ ដោយយោងតាមតម្លៃសមស្របនៃឧបករណ៍មូលនិធិដែលបានផ្តល់។ដើម្បីអនុវត្តសេចក្តីតម្រូវនេះចំពោះប្រតិបត្តិការជាមួយនិយោជិក និង អ្នកដទៃទៀត ដែលផ្តល់សេវាកម្ម ស្រដៀងគ្នា អង្គភាពត្រូវវាស់វែងតម្លៃសមស្របសេវាកម្មដែលបានទទួលទាំងនោះ ដោយយោងតាមតម្លៃសមស្របនៃឧបករណ៍មូលនិធិដែលបានផ្តល់ ពីព្រោះជាធម្មតាគេមិនអាចប៉ាន់ស្មានដោយជឿជាក់នូវតម្លៃសមស្របនៃសេវាដែលបានទទួល។

២៦.៨ សម្រាប់ប្រតិបត្តិការជាមួយនិយោជិក(រួមមាន អ្នកដទៃទៀតដែលផ្តល់សេវាស្រដៀងគ្នា ) តម្លៃសមស្របនៃឧបករណ៍មូលនិធិត្រូវបានវាស់វែងនៅថ្ងៃផ្តល់។សម្រាប់ប្រតិបត្តិការជាមួយភាគីផ្សេងៗដែលមិនមែន និយោជិក កាលបរិច្ឆេទការវាស់វែងគឺជាកាលបរិច្ឆេទដែលអង្គភាពទទួលបានទំនិញ ឬ ភាគីម្ខាងទៀតផ្តល់សេវាកម្ម។

២៦.៩ ការផ្តល់ឧបករណ៍មូលនិធិអាចមានលក្ខខណ្ឌចំពោះនិយោជិកដែលបានបំពេញក្ខខណ្ឌផ្ទេរឲ្យជាក់លាក់ទាក់ទងនឹងសេវាឬសមិទ្ធិផល។ឧទាហរណ៍ ការផ្តល់ភាគហ៊ុន ឬការផ្តល់សិទ្ធិពិសេស ក្នុងការទិញឬលក់ សន្លឹកហ៊ុននៅពេលអនាគតទៅឲ្យនិយោជិកជាធម្មតាមានលក្ខខណ្ឌទៅលើ និយោជិកដែលបានបន្សល់ទុកនៅក្នុងកិច្ចសន្យាការងាររបស់អង្គភាពសម្រាប់រយៈពេលជាក់លាក់មួយ។ អាចមានលក្ខខណ្ឌលើសមិទ្ធិផលការ ងារដែលត្រូវបំពេញ ដូចជាអង្គ ភាពសម្រេចបាននូវការលូតលាស់ដែលបានកំណត់នៅក្នុងប្រាក់ចំណេញ (លក្ខខណ្ឌផ្ទេរឲ្យមិនមែនទីផ្សារ) ឬ ការកើនឡើង ជាក់លាក់នៅក្នុងភាគហ៊ុនរបស់អង្គភាព (លក្ខខ ណ្ឌផ្ទេរទីផ្សារ) ។ លក្ខខណ្ឌផ្ទេរទីផ្សារទាក់ទិននឹង សេវានិយោជិកជាមួយ ឬ ចំពោះលក្ខខណ្ឌសមិទ្ធិផលមិនមែនទីផ្សារត្រូវតែពិចារណានៅពេលការ ប៉ាន់ស្មានចំនួននៃឧបករណ៍មូលនិធិដែលរំពឹងទុកនឹងផ្ទេរឲ្យ។ ជាបន្តបន្ទាប់ ប្រសិនបើចាំបាច់ អង្គភាពត្រូវប្រែការប៉ាន់ស្មាននោះ ប្រសិនបើព័ត៌មានថ្មីបង្ហាញថា ចំនួនឧបករណ៍មូលនិធិដែលបាន រំពឹងទុកនឹងផ្ទេរឲ្យខុសពីការប៉ាន់ស្មានមុន។ នៅកាលបរិច្ឆេទផ្ទេរឲ្យ អង្គភាពត្រូវកែប្រែការប៉ាន់ស្មានស្មើនឹងចំនួននៃឧបករណ៍មូលនិធិដែលបានផ្ទេរឲ្យចុងក្រោយ។លក្ខខណ្ឌផ្ទេរទីផ្សារទាំងអស់ និងលក្ខខណ្ឌមិនផ្ទេរទាំងអស់ត្រូវពិចារណានៅពេលដែលប៉ាន់ស្មានតម្លៃសមស្របនៃភាគហ៊ុន ឬ សិទ្ធិពិសេសនៅថ្ងៃវាស់វែងជាមួយនឹងការកែសម្រួលបន្តបន្ទាប់ដោយមិនគិតពីសមិទ្ធិផល។

ភាគហ៊ុន

២៦.១០ អង្គភាពមួយត្រូវវាស់វែងតម្លៃសមស្របនៃភាគហ៊ុន( និង ទំនិញ ឬសេវា កម្មពាក់ព័ន្ធ ដែលបានទទួល) ដោយប្រើឋានុក្រមវាស់វែងពាលំដាប់ថ្នាក់:

(ក) ប្រសិនបើតម្លៃទីផ្សារអាចដឹងបានមានសម្រាប់ឧបករណ៍មូលនិធិដែលបានផ្តល់គេត្រូវប្រើតម្លៃនោះ

(ខ)ប្រសិនបើតម្លៃទីផ្សារអាចដឹងបានមិនមានទេនោះ គេត្រូវវាស់វែងតម្លៃសមស្របនៃឧបករណ៍មូលនិធិដែលបានផ្តល់ ដោយប្រើទិន្នន័យទីផ្សារដែលអាចដឹងបានជាក់លាក់របស់អង្គភាព ដូចជា:

(១)ប្រតិបត្តិការថ្មីៗជាភាគហ៊ុនរបស់អង្គភាព ឬ

(២)ការវាយតម្លៃត្រឹមត្រូវនិងឯករាជ្យថ្មីៗរបស់អង្គភាព ឬ ទ្រព្យសកម្មសំខាន់

(គ)ប្រសិនបើតម្លៃទីផ្សារដែលបានដឹងមិនកើតមាន និងការទទួលបាននូវការវាស់វែងតម្លៃសមស្របប្រកបដោយជឿជាក់ក្រោម (ខ) មិនអាចអនុវត្តបាន គឺត្រូវវាស់វែងដោយប្រយោលនូវ តម្លៃសមស្របភាគហ៊ុន ឬសិទ្ធិបង្កើនភាគហ៊ុន ដោយប្រើវិធីសាស្ត្រវាយតម្លៃដែលប្រើទិន្នន័យទីផ្សាររហូតដល់អាចអនុវត្តបានដើម្បីប៉ាន់ស្មានអ្វីដែលតម្លៃនៃឧបករណ៍ទុនទាំងនោះអាចមាននៅថ្ងៃ ផ្តល់ឲ្យនៅក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានការព្រមព្រៀងគ្នា។នាយករបស់អង្គភាពត្រូវប្រើការវិនិច្ឆ័យរបស់គេដើម្បីអនុវត្តការវាយតម្លៃសមស្របបំផុតដើម្បីកំណត់តម្លៃសមស្រប។ វិធីសាស្ត្រណាក៏ដោយដែលបានប្រើត្រូវតែមានសង្គតិភាពជាមួយវិធីសាស្ត្រវិធីតម្លៃ ទាំងដែល អាចទទួល យកបានជាទូទៅសម្រាប់ការវាយតម្លៃឧបករណ៍ទុន។

**សិទ្ធិពិសេសសម្រាប់ទិញឬលក់សន្លឹកហ៊ុន និង សិទ្ធិបង្កើនភាគហ៊ុនតាមដើមទុន**

២៦.១១ អង្គភាពមួយត្រូវវាស់វែងតម្លៃសមស្របនៃសិទ្ធិពិសេសទិញ ឬសន្លឹកហ៊ុន និង សិទ្ធិបង្កើនភាគហ៊ុនតាមដើមទុន (ទំនិញ ឬ សេវាទាក់ទិនដែលបានទទួល) ដោយប្រើប្រាស់នូវឋានុក្រមវាស់វែងបីកម្រិត ដូចខាងក្រោមៈ

(ក)ប្រសិនបើតម្លៃទីផ្សារដែលអាចដឹងបាន កើតមានទេ គឺគេត្រូវប្រើតម្លៃនោះ។

(ខ)ប្រសិនបើតម្លៃទីផ្សារដែលអាចដឹងបានមិនកើតមានទេនោះត្រូវវាស់វែងតម្លៃសមស្របនៃសិទ្ធិ ពិសេសទិញ ឬលក់សន្លឹកហ៊ុននិងសិទ្ធិបង្កើនភាគហ៊ុនដែលគេបានផ្តល់ដោយប្រើទិន្នន័យទីផ្សារដែលគេអាចដឹងបានចំពោះ អង្គភាពជាក់លាក់ណាមួយ ដូចជា(ក) សម្រាប់ប្រតិបត្តិការថ្មីៗក្នុងអនុវត្តសិទ្ធិពិសេសទិញ ឬលក់សន្លឹកហ៊ុន។

(គ) ប្រសិនបើតម្លៃទីផ្សារដែលអាចអង្កេតបានមិនមានហើយការទទួលបាននូវការវាស់វែងប្រកបដោយភាព ជឿជាក់នៃតម្លៃសមស្របតាមចំណុច(ខ)មិនអាអនុវត្តបាន ការវាស់វែងដោយប្រយោលពីតម្លៃសមស្របនៃ សិទ្ធិទិញភាពហ៊ុនឬសិទ្ធិទិញភាគហ៊ុនពេលតម្លៃកើនឡើងដោយប្រើវិធីសាស្ត្រកំណត់ថ្លៃសិទ្ធិពិសេស។ ធាតុ ចូលសម្រាប់វិធីសាស្ត្រ(ដូចជាតម្លៃភាគហ៊ុនមធ្យម តម្លៃពេលអនុវត្តសិទ្ធិ ការប្រែ ប្រួលដែលបានរំពឹងទុក អាយុកាលសិទ្ធិពិសេស ភាគលាភអនាគត និង អត្រាការប្រាក់មិនមានហានិភ័យ) គួរប្រើទិន្នន័យទីផ្សារចំពោះ ទំហំធំបំផុតដែលអាចធ្វើទៅបាន។ កថាខណ្ឌ២៦.១០ ផ្តល់ការណែនាំ ពីការកំណត់តម្លៃសមស្របនៃភាគហ៊ុន ដែលបានប្រើនៅក្នុងការកំណត់តម្លៃភាគហ៊ុនមធ្យម។អង្គភាពត្រូវទាញយកការប៉ាន់ស្មាននៃការប្រែប្រួល អនាគតដែលមានសង្គតភាពនឹងវិធីសាស្ត្រវាយតម្លៃដែល បានប្រើដើម្បីកំណត់តម្លៃសមស្របនៃភាគហ៊ុន។

**ការផ្លាស់ប្តូរកិច្ចព្រមព្រៀងនិងលក្ខខណ្ឌដែលឧបករណ៍ដើមទុនត្រូវបានផ្តល់**

២៦.១២ ប្រសិបើអង្គភាពផ្លាស់ប្តូរលក្ខខណ្ឌផ្ទេរក្នុងឥរិយាបទដែលមានប្រយោជន៍ចំពោះនិយោជិក ឧទាហរណ៍ ដោយ ការកាត់បន្ថយតម្លៃអនុវត្តសិទ្ធិឬកាត់បន្ថយរយៈពេលផ្ទេរឬដោយការផ្លាស់ប្តូរឬលុបចោលលក្ខខណ្ឌបំពេញ ការងារអង្គភាពត្រូវយកលក្ខខណ្ឌផ្ទេរដែលបានផ្លាស់ប្តូរទៅពិចារណានៅក្នុងការធ្វើគណនេយ្យកម្មប្រតិបត្តិការ នៃការទូទាត់ផ្អែកលើសន្លឹកហ៊ុន ដូចខាងក្រោមៈ

(ក)ប្រសិនបើការផ្លាស់ប្តូរបង្កើនតម្លៃសមស្របនៃឧបករណ៍ដើមទុនដែលបានផ្តល់(ឬការកើនឡើងចំនួន ឧបករណ៍ដើមទុនដែលបានផ្តល់ឲ្យ)ដែលបានវាស់វែងភ្លាមៗពីមុន និងបន្ទាប់ពីការផ្លាស់ប្តូរ អង្គភាពត្រូវបញ្ចូល តម្លៃសមស្របបន្ថែមដែលបានផ្តល់ឲ្យក្នុងការវាស់វែងនៃចំនួនទឹកប្រាក់ដែលបានទទួលស្គាល់សម្រាប់សេវាកម្ម ដែលបានទទួលជាតម្លៃតបស្នងចំពោះឧបករណ៍ដើមទុនដែលបានផ្តល់។ តម្លៃសមស្របដែលបានផ្តល់ គឺជាភាពខុសគ្នារវាងតម្លៃសមស្របនៃឧបករណ៍ដើមទុនដែលបានកែប្រែនិងតម្លៃឧបករណ៍ដើមទុនដំបូង ដែលឧបករណ៍ទាំងពីត្រូវបានប៉ាន់ស្មាននៅថ្ងៃផ្លាស់ប្តូរ។ ប្រសិនបើការផ្លាស់ប្តូរកើតឡើងក្នុងកំឡុងពេលផ្ទេរ តម្លៃសមស្របបន្ថែមដែលបានផ្តល់ត្រូវបានបញ្ចូលនៅក្នុងការវាស់វែងនៃចំនួនទឹកប្រាក់ដែលបានទទួល

ស្គាល់សម្រាប់សេវាកម្មដែលបានទទួលក្នុងគ្រាពីថ្ងៃផ្លាស់ប្តូរហូតដល់ថ្ងៃដែលឧបករណ៍ដើមទុនដែលផ្លាស់ប្តូររួចផ្ទេរ បន្ថែមលើចំនួនទឹកប្រាក់ដែលផ្អែកលើតម្លៃសមស្របនៃថ្ងៃផ្តល់ឧបករណ៍ដើមទុនដំបូងដែលត្រូវបានទទួលស្គាល់ក្នុង រយៈពេលផ្ទេរដំបូងដែលនៅសេសសល់។

(ខ)ប្រសិនបើការផ្លាស់ប្តូរកាត់បន្ថយតម្លៃសមស្របសរុបនៃការរៀបចំការទូទាត់ផ្អែកលើភាគហ៊ុន ឬម្យ៉ាងវិញទៀតមិនមានអត្ថប្រយោជន៍ចំពោះនិយោជិត ទោះបីយ៉ាងណាក៏ដោយអង្គភាពត្រូវបន្តទទួលស្គាល់សេវាកម្មដែលបានទទួលជាតម្លៃតបស្នងសម្រាប់ឧបករណ៍ដើទុនដែលបានផ្តល់ ខណៈពេលដែលការផ្លាស់ប្តូរនោះមិនបានកើតឡើងក៏ដោយ។

ការលុបចោល និង ការទូទាត់សង

២៦.១៣ អង្គភាពត្រូវទទួលស្គាល់ការលុបចោល ឬការទូទាត់ប្រាក់វង្វាន់ផ្អែកលើភាគហ៊ុន ជាការពន្លឿននៃការផ្ទេរ ដូច្នេះហើយ អង្គភាពត្រូវទទួលស្គាល់ភ្លាមនូវចំនួនទឹកប្រាក់ដែលត្រូវបានទទួល ស្គាល់សម្រាប់សេវាកម្មដែលបានទទួលលើគ្រាផ្ទេរដែលនៅសល់។

## ប្រតិបត្តិការទូទាត់ផ្អែកលើចំណែកហ៊ុនដែលទូទាត់សាច់ប្រាក់

២៦.១៤ សម្រាប់ប្រតិបត្តិការទូទាត់ផ្អែកលើចំណែកហ៊ុនដែលទូទាត់ជាសាច់ប្រាក់ អង្គភាពត្រូវវាស់វែងទំនិញឬសេវាកម្មដែលបានទិញ និង បំណុលដែលបានកើតឡើងតាមតម្លៃសមស្របនៃបំណុល។ រហូតដល់បំណុលត្រូវបានសង អង្គភាពត្រូវវាស់វែងឡើងវិញនូវតម្លៃសមស្របនៃបំណុលនៅ**ថ្ងៃរាយការណ៍**នីមួយៗ និង នៅថ្ងៃសង ជាមួយនឹងការផ្លាស់ប្តូរតម្លៃសមស្របដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតសម្រាប់គ្រា។

## ប្រតិបត្តិការទូទាត់ផ្អែកលើចំណែកហ៊ុនជាមួយនឹងជម្រើសសាច់ប្រាក់

២៦.១៥ប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុនមួយចំនួនផ្តល់ឲ្យអង្គភាពឬភាគីជាដៃគូនូវជម្រើសក្នុងការទូទាត់សងប្រតិបត្តិការជាសាច់ប្រាក់ (ឬទ្រព្យសកម្មផ្សេងទៀត) ឬ ដោយការផ្ទេរនៃឧបករណ៍ដើមទុន។ នៅក្នុងករណីបែបនេះ អង្គភាពត្រូវទទួលស្គាល់ប្រតិបត្តិការជាប្រតិបត្តិការទូទាត់ដោយផ្អែកលើភាគហ៊ុន លើកលែងតែ

(ក) អង្គភាពមានការអនុវត្តពីមុនក្នុងការទូទាត់សងដោយការបោះផ្សាយឧបករណ៍ដើមទុន ឬ

(ខ)ជម្រើសពុំមានលក្ខណៈពាណិជ្ជកម្មពីព្រោះសាច់ប្រាក់ទូទាត់មិនមានទំនាក់ទំនងទៅនឹងតម្លៃសមស្របនៃឧបករណ៍ដើមទុន ហើយទំនងនឹងមានតម្លៃទាបជាងតម្លៃសមស្របនៃឧបករណ៍ដើមទុនឬនៅក្នុងលក្ខខណ្ឌ (ក)និង(ខ) អង្គភាពត្រូវទទួលស្គាល់ប្រតិបត្តិការជាប្រតិបត្តិការទូទាត់ផ្អែកលើ ភាគហ៊ុន ដោយអនុលោមតាមកថាខណ្ឌ ២៦.៧-២៦.១៣។

## ផែនការជាក្រុម

២៦.១៦ ប្រសិនបើប្រាក់រង្វាន់ដែលការទូទាត់ផ្អែកលើភាគហ៊ុនត្រូវបានផ្តល់ដោយ**ក្រុមហ៊ុនមេ**ទៅឱ្យនិយោជិក នៃ**ក្រុមហ៊ុនបុត្រសម្ព័ន្ធ**មួយឬច្រើននៅក្នុងក្រុម ហើយក្រុមហ៊ុនមេបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមដោយប្រើស្តង់ដារាយការណ៍សម្រាប់សហគ្រាសធុននិងមធ្យម**ស្តង់ដារាយការណ៍ហិរញ្ញវត្ថុពេញលេញ** ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានអនុញ្ញាតឱ្យទទួលស្គាល់ និងវាស់វែងចំណាយដែលទូទាត់ផ្អែកលើភាគហ៊ុន(និង វិភាគទានមូលធនដែលទាក់ទិនដោយក្រុមហ៊ុនមេ) ដោយឈរលើមូលដ្ឋាននៃការបែងចែកដ៏សមស្របនៃចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុមទាំងមូល។

## ផែនការអណាត្តិរដ្ឋាភិបាល

២៦.១៧នៅក្នុងប្រទេសមួយចំនួនមានកម្មវិធីដែលបានបង្កើតក្រោមច្បាប់ដោយអ្នកវិនិយោគដើមទុន (ដូចជានិយោជិក) មានលទ្ធភាពទិញដើមទុនដោយគ្មានការផ្តល់ទំនិញឬសេវាដែលអាចកំណត់បាន ជាពិសេស (ឬ ដោយផ្តល់ទំនិញ ឬ សេវាកម្មដែលទាបជាងតម្លៃសមស្របនៃឧបករណ៍ដើមទុនដែលបានផ្តល់)។ នេះបង្ហាញថា តម្លៃតបស្នងផ្សេងទៀតត្រូវបានទទួល ឬ នឹងត្រូវទទួល (ដូចជាសេវារបស់ និយោជិកអតីតកាល ឬ អនាគត)។ ទាំងនេះគឺជាប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុនដែលទូទាត់ដោយ ដើមទុនដែលស្ថិតក្នុងវិសាលភាពនៃផ្នែកនេះ។អង្គភាពត្រូវវាស់វែងទំនិញឬសេវាកម្មមិនអាចកំណត់បានដែលបានទទួល (ឬ នឹងត្រូវទទួល)ជាភាពខុសគ្នារវាងតម្លៃសមស្របនៃការទូទាត់ផ្អែកលើភាគហ៊ុន និងតម្លៃសមស្របនៃទំនិញឬសេវាកម្មកំណត់បានដែលបានទទួល (ឬនឹងត្រូវទទួល) ត្រូវបានវាស់វែងនៅថ្ងៃផ្តល់។

## ការលាតត្រដាងព័ត៌មាន

២៦.១៨អង្គភាពមួយត្រូវបង្ហាញព័ត៌មានខាងក្រោមអំពីប្រភេទ និង ទំហំនៃកិច្ចព្រមព្រៀងទូទាត់ផ្អែកលើភាគហ៊ុនដែលបានកើតឡើងក្នុងកំឡុងពេលៈ

(ក)ការរៀបរាប់ពីប្រភេទនីមួយៗនៃកិច្ចព្រមព្រៀងទូទាត់ផ្អែកលើភាគហ៊ុនដែលបានកើតឡើង នៅពេលណាមួយក្នុងកំឡុងគ្រា ដោយរួមបញ្ចូលនូវលក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀងនីមួយៗ ដូចជា ការតម្រូវផ្ទេរ លក្ខខណ្ឌអតិបរមានៃជម្រើសដែលបានផ្តល់ ហើយវិធីសាស្ត្រនៃការសង (ឧ. មិនថាតើជា សាច់ប្រាក់ ឬ ដើមទុន)។ អង្គភាពជាមួយនឹងប្រភេទស្រដៀងគ្នាខ្លាំងនៃកិច្ចព្រមព្រៀងការទូទាត់ផ្អែកលើភាគហ៊ុនអាចសរុបព័ត៌មានទាំងនេះ។

(ខ) ចំនួន និង តម្លៃមធ្យមអនុវត្តសិទ្ធិពិសេសទិញភាគហ៊ុនសម្រាប់ក្រុមសិទ្ធិពិសេសនីមួយៗដូច ខាងក្រោមៈ

(១) មាននៅដើមគ្រា

(២) ត្រូវបានផ្តល់នៅក្នុងគ្រា

(៣) ត្រូវបានពិន័យក្នុងគ្រា

(៤) ត្រូវបានអនុវត្តក្នុងគ្រា

(៥) អស់សុពលភាពក្នុងគ្រា

(៦) នៅសល់ចុងគ្រា

(៧) ដែលអាចអនុវត្តនៅចុងគ្រា

២៦.១៩សម្រាប់កិច្ចព្រមព្រៀងទូទាត់ផ្អែកលើភាគហ៊ុនដែលទូទាត់ជាដើមទុន អង្គភាពត្រូវបង្ហាញព័ត៌មានអំពីរបៀបដែលអង្គភាពវាស់វែងតម្លៃសមស្របនៃទំនិញឬសេវាកម្មដែលបានទទួល ឬតម្លៃនៃឧបករណ៍ដើមទុនដែលបានផ្តល់។ប្រសិនបើវិធីសាស្រ្តវាយតម្លៃត្រូវបានប្រើ អង្គភាពត្រូវបង្ហាញវិធីសាស្រ្តនិងហេតុផលសម្រាប់ការផ្លាស់ប្តូរវា។

២៦.២០ សម្រាប់កិច្ចព្រមព្រៀងទូទាត់ផ្អែកលើចំណែកហ៊ុនដែលទូទាត់ជាសាច់ប្រាក់ អង្គភាពត្រូវបង្ហាញព័ត៌មានអំពីបំណុលត្រូវបានវាស់វែង។

២៦.២១ សម្រាប់កិច្ចព្រមព្រៀងទូទាត់ផ្អែកលើចំណែកហ៊ុនដែលត្រូវបានផ្លាស់ប្តូរក្នុងកំឡុងគ្រា អង្គភាពត្រូវបង្ហាញការពន្យល់នៃការផ្លាស់ប្តូរទាំងនោះ។

២៦.២២ប្រសិនបើគឺជាផ្នែកនៃផែនការទូទាត់ផ្អែកលើភាគហ៊ុនរបស់ក្រុម ហើយអង្គភាពទទួលស្គាល់និងវាស់វែងការចំណាយការទូទាត់ផ្អែកលើភាគហ៊ុនដោយផ្អែកលើមូលដ្ឋាននៃការបែងចែកនៃការចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុមទាំងមូល។ អង្គភាពត្រូវបង្ហាញហេតុការនោះ និង មូលដ្ឋានសម្រាប់ការបែងចែក (សូមមើលកថាខណ្ឌ ២៦.១៦)។

២៦.២៣ អង្គភាពត្រូវបង្ហាញព័ត៌មានដូចខាងក្រោមអំពីផលប៉ះពាល់នៃប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុននៅលើរបាយការណ៍ចំណេញ ឬខាតរបស់អង្គភាពសម្រាប់គ្រា និងនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុៈ

(ក) ការចំណាយសរុបដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតសម្រាប់គ្រា

(ខ) តម្លៃក្នុងបញ្ជីសរុបនៅចុងគ្រាសម្រាប់បំណុលដែលកើតពីប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុន

# ផ្នែកទី២៧
# ការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្ម

## កម្មវត្ថុនិងវិសាលភាព

២៧.១ **ការខាតពីការធ្លាក់ចុះតម្លៃ**កើតឡើងនៅពេលដែល**តម្លៃក្នុងបញ្ជី**នៃទ្រព្យសកម្មលើពី**តម្លៃទទួលបានមកវិញ** ។ ផ្នែកនេះត្រូវបានអនុវត្តក្នុងការទទួលស្គាល់ការធ្លាក់ចុះនៃទ្រព្យសកម្មទាំងអស់ លើកលែងតែចំណុចខាងក្រោម ដែលផ្នែកដទៃទៀតនៃស្តង់ដារនេះបង្កើតឡើងនូវការតម្រូវការធ្លាក់ចុះ គំលៃ:

(ក) **ទ្រព្យសកម្មពន្ធពន្យា**(សូមមើលផ្នែកទី២៩ *ពន្ធលើប្រាក់ចំណូល)*។

(ខ) ទ្រព្យសកម្មកើតចេញពី**អត្ថប្រយោជន៍និយោជិត**(សូមមើលកថាខណ្ឌ ២៨ *អត្ថប្រយោជន៍និយោជិត)*។

(គ) **ទ្រព្យសកម្មហិរញ្ញវត្ថុ** នៅក្នុងវិសាលភាពនៃផ្នែកទី១១ *ឧបករណ៍ហិរញ្ញវត្ថុធម្មតាម* ឬ ផ្នែកទី១១ *ឧបករណ៍ហិរញ្ញវត្ថុធម្មតា* ឬ ផ្នែកទី១២ *ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត*។

(ឃ) **ទ្រព្យវិនិយោគ**ដែលវាស់វែតតាមតម្លៃសមស្រប (សូមមើលកថាខណ្ឌទី១៦ *ទ្រព្យវិនិយោគ*)។

(ង)**ទ្រព្យសកម្មជីវសាស្ត្រ**ពាក់ទងនឹងសកម្មភាពកសិកម្មដែលវាស់វែងតាមតម្លៃសមស្របដកចំណាយប៉ាន់ស្មានដើម្បីលក់ (សូមមើលកថាខណ្ឌទី៣៤ *សកម្មភាពពិសេស)*។

## ការធ្លាក់ចុះនៃតម្លៃសន្និធិ

### តម្លៃលក់ដកថ្លៃដើម្បីបញ្ចប់ និងថ្លៃដើម្បីលក់

២៧.២អង្គភាពត្រូវវាយតម្លៃនៅថ្ងៃរាយការណ៍នីមួយៗថាតើសន្និធិណាមួយខ្លះបានធ្លាក់ចុះតម្លៃ។ អង្គភាពត្រូវវាយតម្លៃដោយការប្រៀបធៀបតម្លៃក្នុងបញ្ជីនៃធាតុនីមួយៗនៃសន្និធិ(ឬក្រុមនៃសន្និធិស្រដៀងគ្នាសូមមើលកថាខណ្ឌ២៧.៣)ជាមួយនឹងតម្លៃលក់ដកថ្លៃដើម្បីបញ្ចប់និងថ្លៃដើម្បីលក់។ប្រសិបើធាតុនៃសន្និធិ (ឬក្រុមនៃសន្និធិស្រដៀងគ្នា)ធ្លាក់ចុះតម្លៃ អង្គភាពត្រូវកាត់បន្ថយតម្លៃក្នុងបញ្ជីនៃសន្និធិ(ឬក្រុមសន្និធិ)ទៅជាតម្លៃលក់ដកថ្លៃដើមដើម្បីបញ្ចប់និងលក់។ការកាត់បន្ថយនោះគឺជាការ ខាតពីការធ្លាក់ចុះតម្លៃ និង ត្រូវទទួលស្គាល់ភ្លាមនៅក្នុងរបាយការណ៍ចំណេញឬខាត។

២៧.៣ប្រសិនបើគេមិនអាចកំណត់ពីតម្លៃលក់ដកថ្លៃបញ្ចប់និងលកសម្រាប់ធាតុសន្និធិម្តងមួយៗបានទេ អង្គភាពអាចបញ្ចូលធាតុទាំងអស់នៃសន្និធិដែលទាក់ទងនឹងខ្សែសង្វាក់ផលិតផលដូចគ្នាដែលមានគោលបំណងស្រដៀងគ្នា ឬការប្រើប្រាស់ចុងក្រោយហើយត្រូវបានផលិត និងផ្សព្វផ្សាយនៅក្នុងតម្លៃ ភូមិសាស្ត្រដូចគ្នាសម្រាប់គោលបំណងនៃការវាយតម្លៃពីការធ្លាក់ចុះ។

### ការបញ្ច្រាស់នៃការធ្លាក់ចុះតម្លៃ

២៧.៤ អង្គភាពត្រូវធ្វើការវាយតម្លៃថ្មីតម្លៃលក់ដកថ្លៃបញ្ចប់និងលក់នៅថ្ងៃរាយការណ៍បន្ទាប់។ នៅពេលដែលស្ថានភាពដែលបានធ្វើឱ្យសន្និធិធ្លាក់ចុះតម្លៃកាលពីមុនមិនកើតឡើងទៀតទេ ឬ នៅពេលដែលមានភស្តុតាងច្បាស់នៃការកើនឡើងក្នុងតម្លៃលក់ដកថ្លៃដើម្បីបញ្ចប់និងលក់ ដោយសារស្ថានភាពសេដ្ឋកិច្ចបានប្តូរ អង្គភាពត្រូវបញ្ច្រាស់មកវិញនូវចំនួនទឹកប្រាក់ដែលបានធ្លាក់ចុះ (ពោលគឺ ការបញ្ច្រាស់មិនត្រូវលើសពីចំនួនទឹកប្រាក់នៃការខាតពីការធ្លាក់ចុះតម្លៃដំបូង) ដូច្នេះតម្លៃថ្មីក្នុងបញ្ជីគឺជាតម្លៃទាបជាងថ្លៃដើម និងតម្លៃលក់កែប្រែរួចដកថ្លៃដើម្បីបញ្ចប់និងលក់។

## ការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្មក្រៅពីសន្និធិ

### គោលការណ៍ទូទៅ

២៧.៥ តែក្នុងករណីដែលចំនួនទឹកប្រាក់ដែលត្រូវទទួលបានមកវិញនៃទ្រព្យសកម្មតិចជាងតម្លៃក្នុងបញ្ជី អង្គភាពត្រូវកាត់បន្ថយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មមកតម្លៃដែលត្រូវទទួលបានមកវិញ។ ការកាត់បន្ថយនេះគឺជាការខាតពីការធ្លាក់ចុះតម្លៃ។ កថាខណ្ឌ២៧.១១ - ២៧.២០ ផ្តល់ការណែនាំពី ការវាស់វែងចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញ។

២៧.៦ អង្គភាពត្រូវទទួលស្គាល់ការខាតពីការធ្លាក់ចុះតម្លៃភ្លាមនៅក្នុងរបាយការណ៍ចំណេញឬខាត។

### សូចនាករនៃការធ្លាក់ចុះតម្លៃ

២៧.៧ អង្គភាពត្រូវវាយតម្លៃនៅថ្ងៃរាយការណ៍នីមួយៗថាតើមានសញ្ញាណាមួយដែលទ្រព្យសកម្មអាចធ្លាក់ចុះតម្លៃ។ ប្រសិនបើសញ្ញាណាមួយកើតឡើង អង្គភាពត្រូវប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យសកម្ម។ប្រសិនបើមិនមានសញ្ញានៃការធ្លាក់ចុះទេ អង្គភាពមិនចាំបាច់ប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលត្រូវទទួលបានមកវិញទេ។

២៧.៨ ប្រសិនបើអង្គភាពមិនអាចប៉ាន់ស្មានតម្លៃដែលអាចទទួលបានមកវិញនៃទ្រព្យសកម្មនីមួយៗទេ អង្គភាពត្រូវប៉ាន់ស្មានតម្លៃដែលអាចទទួលបានមកវិញ**នៃអង្គភាពរកសាច់ប្រាក់**ពោះទ្រព្យសកម្មណា ដែលអង្គភាពកាន់កាប់។ នេះអាចក្លាយជាករណីមួយដោយសារការវាស់វែងនៃចំនួនទឹកប្រាក់ដែលទទួលបានមកវិញតម្រូវឱ្យធ្វើការព្យាករណ៍លំហូរសាច់ប្រាក់ និងជួនកាលទ្រព្យសកម្មនីមួយៗមិនអាចបង្កើតលំហូរសាច់ប្រាក់ដោយខ្លួនឯងបាន។អង្គភាពរកសាច់ប្រាក់របស់ទ្រព្យសកម្មមួយគឺជាក្រុមនៃទ្រព្យសកម្មដែលអាចកំណត់បានទាបបំផុតដែលរួមបញ្ចូលទ្រព្យសកម្ម ហើយបង្កើតលំហូរសាច់ប្រាក់ចូលដែលមានភាពឯករាជ្យច្រើនពីលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មផ្សេងទៀត ឬ ក្រុមទ្រព្យសកម្ម ផ្សេងទៀត។

២៧.៩ ក្នុងការវាយតម្លៃថាតើមានសញ្ញាដែលទ្រព្យសកម្មអាចត្រូវបានធ្លាក់ចុះតម្លៃ អង្គភាពត្រូវពិចារណា ជាអប្បបរមានូវសញ្ញាដូចខាងក្រោមៈ

*ប្រភពព័ត៌មានខាងក្រៅ*

(ក) ក្នុងកំឡុងគ្រា តម្លៃទីផ្សាររបស់ទ្រព្យសកម្មបានធ្លាក់ចុះយ៉ាងខ្លាំងច្រើនជាងការរំពឹងទុកដែលជាលទ្ធផលនៃការកន្លងហួសពេលវេលា ឬ ការប្រើប្រាស់ធម្មតា។

(ខ) ការផ្លាស់ប្តូរដ៏សំខាន់ៗជាមួយនឹងផលប៉ះពាល់អាក្រក់មកលើអង្គភាពបានកើតមានឡើងក្នុងកំឡុងគ្រា ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងបរិស្ថានបច្ចេកវិជ្ជា ទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ ដែលអង្គភាពធ្វើអាជីវកម្ម ឬក្នុងទីផ្សារដែលទ្រព្យសកម្មមានគោលបំណងពិសេស។

(គ)អត្រាការប្រាក់ទីផ្សារឬអត្រាទីផ្សារនៃចំណូលលើការវិនិយោគផ្សេងទៀតបានកើនឡើងក្នុងកំឡុងគ្រា ហើយការកើនឡើងទាំងនោះទំនងជាត្រូវប៉ះពាល់យ៉ាងខ្លាំងនូវអត្រាអប្បហារដែលបានប្រើក្នុងការគណនាតម្លៃទ្រព្យសកម្មកំពុងប្រើ និង ការធ្លាក់ចុះនូវតម្លៃសមស្របរបស់ទ្រព្យសកម្មដកថ្លៃដើម្បីលក់

(ឃ) តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពច្រើនជាងតម្លៃសមស្របប៉ាន់ស្មានរបស់អង្គភាពទាំងមូល (ការប៉ាន់ស្មានបែបនោះអាចត្រូវបានធ្វើឡើង ក្នុងទំនាក់ទំនងទៅនឹងការលក់នៃផ្នែកមួយ ឬ ទាំងអស់នៃអង្គភាពដែលមានសក្តានុពល។

*ប្រភពព័ត៌មានខាងក្នុង*

(ង) មានភស្តុតាងពីភាពហួសសម័យ ឬ ការខូចខាតរូបរាងនៃទ្រព្យសកម្ម។

(ច) ការប្រែប្រួលខ្លាំងជាមួយផលប៉ះពាល់អាក្រក់មកលើអង្គភាពបានកើតមានឡើងក្នុងគ្រា ឬត្រូវបានរំពឹងថាកើតឡើងនៅពេលអនាគតដ៏ខ្លី ក្នុងទំហំ ឬ សកម្មភាព ដែលទ្រព្យសកម្មត្រូវបានប្រើ ឬត្រូវបានរំពឹងនឹងប្រើ។ ការផ្លាស់ប្តូរទាំងនេះរួមបញ្ចូលទ្រព្យសកម្មដែលបានទំនេរផែនការមិនបន្តឬរៀបចំរចនាសម្ព័ន្ធប្រតិបត្តិការដែលទ្រព្យសកម្មមានផែនការលក់ចោលទ្រព្យសកម្មមុនពេលថ្ងៃដែលបានរំពឹងទុកពីមុន និងការវាយតម្លៃឡើងវិញនូវអាយុកាលរបស់ទ្រព្យសកម្មដែលមានកាលកំណត់ជាជាងមិនមានកាលកំណត់។

(ឆ)មានភស្តុតាងពីការរាយការណ៍ខាងក្នុងដែលបញ្ជាក់ថាដំណើរការសេដ្ឋកិច្ចនៃទ្រព្យសកម្មមានភាពអាក្រក់ ឬនឹងអាក្រក់ជាងការរំពឹងទុក។ នៅក្នុងបរិការណ៍នេះ ដំណើរការសេដ្ឋកិច្ចរួមបញ្ចូលលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់។

២៧.១០ ប្រសិនបើមានសញ្ញាដែលថាទ្រព្យសកម្មធ្លាក់ចុះតម្លៃ នេះអាចបញ្ជាក់ថាអង្គភាពត្រូវពិនិត្យមើលឡើងវិញនូវអាយុកាលប្រើប្រាស់ដែលនៅសល់**វិធីសាស្ត្ររំលស់ឬតម្លៃកាកសំណល់**សម្រាប់ទ្រព្យសកម្ម និងកែសម្រួលដោយអនុលោមតាមផ្នែកនៃស្តង់ដារនេះដែលអនុវត្តចំពោះទ្រព្យសកម្ម(ឧ. ផ្នែកទី១៧ *ទ្រព្យ រោងចក្រ និង*

*ឧបករណ៍* និងផ្នែកទី ១៨ *(ទ្រព្យសកម្មអរូបីលើកលែងមូលនិធិពាណិជ្ជកម្ម)* ទោះបីមិនមានការខាត ដោយសារការធ្លាក់ចុះត្រូវបានទទួលស្គាល់ចំពោះទ្រព្យសកម្មក៏ដោយ។

*វាស់វែងតម្លៃដែលអាចទទួលបាន*

២៧.១១តម្លៃដែលអាចបាននៃទ្រព្យសមកម្មឬអង្គភាពរកសាច់ប្រាក់គឺជាតម្លៃខ្ពង់ជាង**នៅតម្លៃសមស្របដកថ្លៃដើមដើម្បីលក់និងតម្លៃកំពុងប្រើប្រាស់ ។** ប្រសិនបើគេមិនអាចប៉ាន់ស្មានពីតម្លៃដែលអាចទទួលបាននៃទ្រព្យសកម្មនីមួយៗដោយយោងតាមកថាខណ្ឌ ២៧.១២ -២៧.២០ ចំពោះទ្រព្យសកម្មត្រូវបានអានដោយយោងទៅអង្គភាពរកសាច់ប្រាក់។

២៧.១២ គេមិនចាំបាច់តែងតែកំណត់ទាំងតម្លៃសមសបដកថ្លៃដើមដើម្បីលក់និងតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្មនោះទេ។ប្រសិនបើចំនួនទឹកប្រាក់ណាមួយនៃតម្លៃទាំងពីរលើសតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្ម ទ្រព្យសកម្មមិនបានធ្លាក់ថ្លៃ ដូច្នេះអង្គភាពមិនចាំបាច់ប៉ាន់ស្មានចំនួនទឹកប្រាក់ផ្សេងទៀតទេ។

២៧.១៣ ប្រសិនបើពុំមានហេតុផលដើម្បីឲ្យជឿថាតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មមិនលើសច្រើនតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ តម្លៃសមស្របដកថ្លៃដើមលក់នៃទ្រព្យសកម្មអាចត្រូវបានប្រើជាតម្លៃអាចទទួលបានតែម្តង។ ជារឿយៗបញ្ហានេះជាករណីមួយសម្រាប់ទ្រព្យសកម្មដែលរក្សាទុកដើម្បីលក់ចោល។

*តម្លៃសមស្របដកថ្លៃដើមដើម្បីលក់*

២៧.១៤ តម្លៃសមស្របដកថ្លៃដើមដើម្បីលក់គឺជាចំនួនទឹកប្រាក់ដែលអាចទទួលបានពីការលក់ទ្រព្យសកម្មនៅក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានការយល់ដឹងដកថ្លៃលក់ចោល។ភស្តុតាងល្អបំផុតនៃ តម្លៃសមស្របដកថ្លៃដើមដើម្បីលក់នៃទ្រព្យសកម្មគឺជាតម្លៃក្នុងកិច្ចសន្យាលក់ជាប្រតិបត្តិការបណ្តោយដៃឬតម្លៃទីផ្សារក្នុងទីផ្សារសកម្ម។ប្រសិនបើមិនមានកិច្ចសន្យាលក់ ឬ ទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម តម្លៃសមស្របដកថ្លៃដើម្បីលក់ត្រូវផ្អែកលើព័ត៌មានដ៏ល្អបំផុតដែលមានមានដើម្បីឆ្លុះបញ្ចាំងចំនួនទឹកប្រាក់ដែលអង្គភាព អាចទទួលបាននៅថ្ងៃរាយការណ៍ពីការលក់ចោលនៃទ្រព្យសកម្មក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានចំណេះដឹងបន្ទាប់ពីការដកចេញថ្លៃដើមលក់ចោល។នៅក្នុងកំណត់ចំនួនទឹកប្រាក់ អង្គភាពពិចារណាពីលទ្ធផលនៃប្រតិបត្តិការថ្មីៗសម្រាប់ទ្រព្យសកម្មស្រដៀងគ្នានៅក្នុងឧស្សាហកម្មដូចគ្នា។

*តម្លៃកំពុងប្រើ*

២៧.១៥ តម្លៃកំពុងប្រើប្រាស់គឺ**ជាតម្លៃបច្ចុប្បន្ន**នៃលំហូរសាច់ប្រាក់អនាគតដែលបានរំពឹងទុកនឹងត្រូវទទួលបានពីទ្រព្យសកម្ម។ ការគណនាតម្លៃបច្ចុប្បន្ននេះទាក់ទិននឹងដំណាក់ខាងក្រោមៈ

(ក) ប៉ាន់ស្មានលំហូរសាច់ប្រាក់ចូលនិងហូរចេញអនាគតនឹងត្រូវទទួលបានពីបន្តការប្រើប្រាស់ទ្រព្យសកម្មនិងពីការលក់ចោលចុងក្រោយ និង

(ខ) អនុវត្តអត្រាអប្បហារសមស្របចំពោះលំហូរសាច់ប្រាក់អនាគតទាំងនោះ

២៧.១៦ ធាតុខាងក្រោមត្រូវបានឆ្លុះបញ្ចាំងក្នុងការគណនាតម្លៃកំពុងប្រើនៃទ្រព្យសកម្មៈ

(ក) ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគតដែលអង្គភាពរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម

(ខ)ការរំពឹងទុកពីការប្រែប្រួលដែលអាចកើតមានឡើងជាចំនួនទឹកប្រាក់ឬពេលវេលានៃលំហូរសាច់ប្រាក់អនាគតទាំងនោះ។

(គ) តម្លៃពេលវេលានៃលុយ ដែលតំណាងដោយអត្រាការប្រាក់ទីផ្សារបច្ចុប្បន្នគ្មានហានិភ័យ

(ឃ) តម្លៃដែលមានភាពមិនប្រាកដប្រជាដែលមានចំពោះទ្រព្យសកម្ម

(ង)កត្តាផ្សេងទៀត ដូចជាភាពមិនអាចប្តូរជាសាច់ប្រាក់ អ្នកចូលរួមទីផ្សារគួរឆ្លុះបញ្ចាំងក្នុងការកំណត់ថ្លៃលំហូរសាច់ប្រាក់អនាគត អង្គភាពរំពឹងថានឹងទទួលបានពីទ្រព្យ។

២៧.១៧ នៅក្នុងការវាស់វែងតម្លៃកំពុងប្រើប្រាស់ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់អនាគតត្រូវរួម បញ្ចូលៈ

(ក) ការប៉ាន់ស្មានលំហូរចូលសាច់ប្រាក់ពីការបន្តប្រើប្រាស់ទ្រព្យសកម្ម។

(ខ)ការប៉ាន់ស្មានលំហូរចេញសាច់ប្រាក់ដែលកើតឡើងជាចាំបាច់ដើម្បីបង្កើតលំហូរសាច់ប្រាក់ចូលពីការបន្តប្រើប្រាស់ទ្រព្យសកម្ម(រួមបញ្ចូលលំហូរសាច់ប្រាក់ចេញដើម្បីរៀបចំទ្រព្យសកម្មសម្រាប់ប្រើប្រាស់) ហើយអាចចូលរួមដោយផ្ទាល់ ឬ ត្រូវបែងចែកដោយឈរមូលដ្ឋានសមស្របនិងសង្គតភាព ចំពោះទ្រព្យសកម្ម។

(គ)លំហូរសាច់ប្រាក់ ប្រសិនបើមាន ត្រូវបានរំពឹងថានឹងទទួលបាន (ឬបង់) សម្រាប់ការលក់ចោលទ្រព្យសកម្មនៅចុងអាយុកាលប្រើប្រាស់របស់វាក្នុងប្រតិបត្តិការបណ្តោយដៃរវាងភាគីដែលមានចំណេះដឹងដូចគ្នា។

អង្គភាពអាចមានបំណងប្រើប្រាស់នូវការធ្វើគំរោងផែនការហិរញ្ញវត្ថុឬការប៉ាន់ស្មានហិរញ្ញវត្ថុដើម្បីប៉ាន់ស្មានលំហូរសាច់ប្រាក់ ប្រសិនបើមាន។ ដើម្បីប៉ាន់ស្មានគំរោងលំហូរសាច់ប្រាក់ក្រោយគ្រា ដែលបានគ្របដណ្តប់ដោយគំរោងឬការព្យាករណ៍ថវិកាថ្មីៗបំផុត អង្គភាពអាចមានបំណងសរុបនូវផែនការដែលផ្អែកលើគំរោងថវិកាឬព្យាករណ៍ដោយប្រើអត្រាកំណើនថេរ ឬថយចុះសម្រាប់ឆ្នាំបន្តបន្ទាប់ លើកលែងតែអត្រាកើនឡើងអាចត្រូវបានកែសម្រួល។

២៧.១៨ ការព្យាករណ៍លំហូរសាច់ប្រាក់មិនត្រូវបញ្ចូលៈ

(ក) លំហូរសាច់ប្រាក់ចូល ឬ លំហូរសាច់ប្រាក់ចេញ ពីសកម្មភាពហិរញ្ញប្បទាន ឬ

(ខ) ចំណូល ឬចំណាយជាប់ពន្ធលើប្រាក់ចំណេញ

២៧.១៩ លំហូរសាច់ប្រាក់អនាគតត្រូវបានព្យាករណ៍សម្រាប់ទ្រព្យសកម្មនៅក្នុងស្ថានភាពបច្ចុប្បន្ន។ការព្យាករណ៍នៃលំហូរសាច់ប្រាក់អនាគតមិនត្រូវបញ្ចូលលំហូរចូលឬលំហូរចេញសាច់ប្រាក់ដែលត្រូវបានរំពឹងថានឹងកើតមានឡើងៈ

(ក) ការរុះរើនាពេលអនាគតដែលអង្គភាពមិនទាន់មានការតាំងចិត្ត ឬ

(ខ) ការធ្វើឱ្យប្រសើរ ឬការបង្កើនស្នាដៃរបស់ទ្រព្យសកម្ម

២៧.២០ អត្រាអប្បហារ (អត្រា) ដែលត្រូវបានប្រើក្នុងការគណនាតម្លៃបច្ចុប្បន្នត្រូវតែជាអត្រាមុនការបង់ពន្ធ(អត្រា) ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃៈ

(ក) តម្លៃពេលវេលានៃលុយ និង

(ខ) ហានិភ័យជាក់លាក់ចំពោះទ្រព្យសកម្មដែលការព្យាករណ៍លំហូរសាច់ប្រាក់អនាគតមិនត្រូវបានកែសម្រួល។

អត្រាអប្បហារ(អត្រា) ដែលបានប្រើដើម្បីវាស់វែងពីតម្លៃកំពុងប្រើប្រាស់នៃទ្រព្យសកម្មមិនឆ្លុះបញ្ចាំងពីហានិភ័យដែលការព្យាករណ៍លំហូរសាច់ប្រាក់អនាគតត្រូវបានកែសម្រួល ដើម្បីជៀសវាងការរាប់ទ្វេដង។

**ការទទួលស្គាល់ និងការវាស់វែងការខាតបង់ដោយការធ្លាក់ថ្លៃសម្រាប់អង្គនាពរកសាច់ប្រាក់**

២៧.២១ ការការខាតបង់ដោយការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់អង្គភាពរកសាច់ប្រាក់ ប្រសិនបើចំនួនទឹកប្រាក់ដែលទទួលបានមកវិញនៃអង្គភាពតិចជាងតម្លៃក្នុងបញ្ជីនៃអង្គភាព។ការខាត បង់ដោយការធ្លាក់ចុះតម្លៃត្រូវបានបែងចែកដើម្បីកាត់បន្ថយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនៃអង្គភាព តាមលំដាប់លំដោយដូចខាងក្រោមៈ

(ក) ដំបូង ត្រូវកាត់បន្ថយតម្លៃក្នុងបញ្ជីនៃកេរ្តិ៍ឈ្មោះដែលបានបែងចែកទៅអង្គភាពរកសាច់ប្រាក់និង

(ខ) បែងចែកទៅទ្រព្យសកម្មផ្សេងទៀតនៃអង្គភាពតាមសមាមាត្រដោយផ្អែកលើមូលដ្ឋាននៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនីមួយៗ នៅក្នុងអង្គភាពរកសាច់ប្រាក់

២៧.២២ ប៉ុន្តែអង្គភាពមិនត្រូវកាត់បន្ថយតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មណាមួយនៅក្នុងអង្គភាពរកសាច់ប្រាក់ខាងក្រោមតាមតម្លៃខ្ពស់បំផុតនេះ នៃៈ

(ក) តម្លៃសមស្របដកថ្លៃដើម្បីលក់ (ប្រសិនអាចកំណត់បាន)

(ខ) តម្លៃកំពុងប្រើប្រាស់ (ប្រសិនបើអាចកំណត់បាន) និង

(គ) សូន្យ

២៧.២៣ចំនួនទឹកប្រាក់ដែលលើសនៃការខាតដោយការធ្លាក់ចុះតម្លៃដែលមិនអាចត្រូវបានបែងចែកទៅទ្រព្យសកម្ម ដោយសារតែការហាមឃាត់នៅក្នុងកថាខណ្ឌ២៧.២២ត្រូវបានបែងចែកទៅទ្រព្យសកម្មផ្សេងទៀតនៃអង្គភាព តាមសមាមាត្រតាមមូលដ្ឋាននៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មផ្សេងទៀតទាំងនោះ។

## ការតម្រូវបន្ថែមសម្រាប់ការធ្លាក់ចុះតម្លៃនៃមូលនិធិពាណិជ្ជកម្ម

២៧.២៤មូលនិធិពាណិជ្ជកម្មមិនអាចត្រូវបានលក់ដោយអង្គភាពខ្លួនឯង។មូលនិធិពាណិជ្ជកម្មមិនបានបង្កើតលំហូរសាច់ប្រាក់មកឲ្យអង្គភាពដែលផ្អែកលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងទៀតទេ។ជាលទ្ធផល តម្លៃសមស្របនៃមូលនិធិពាណិជ្ជកម្មមិនអាចត្រូវបានវាស់វែងដោយផ្ទាល់។ដូច្នេះ តម្លៃសមស្របនៃមូលនិធិពាណិជ្ជកម្មត្រូវកើតចេញពីការវាស់វែងនៃតម្លៃសមស្របនៃអង្គភាពរកសាច់ប្រាក់ដែលមានមូលនិធិពាណិជ្ជកម្មមួយផ្នែក។

២៧.២៥សម្រាប់គោលបំណងនៃការធ្វើតេស្តពីការធ្លាក់ចុះតម្លៃមូលនិធិពាណិជ្ជកម្មដែលបានទិញក្នុងការបញ្ចូលអាជីវកម្មចាប់ពីថ្ងៃទិញមកត្រូវបានបែងចែកទៅអង្គភាពរកសាច់ប្រាក់នីមួយៗដែលរំពឹងថានឹងទទួលបានអត្ថប្រយោជន៍ពីផលនៃការបញ្ចូលអាជីវកម្មមិនថាទ្រព្យសកម្មឬបំណុលទាំងនោះរបស់អ្នកលក់ ត្រូវបានកំណត់ចំពោះអង្គភាពទាំងនោះ។

២៧.២៦ផ្នែកនៃចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់បានចូលរួមដោយផ្ទាល់ចំពោះភាគកម្មអប្បភាគនៅក្នុងមូលនិធិពាណិជ្ជកម្ម។សម្រាប់គោលបំណងនៃការធ្វើតេស្តពីការធ្លាក់ចុះតម្លៃ អង្គភាពរកសាច់ប្រាក់មិនបានទាំងស្រុងជាមួយនឹងមូលនិធិពាណិជ្ជកម្មតម្លៃក្នុងបញ្ជីនៃអង្គភាពនោះត្រូវបានកែសម្រួលយ៉ាងត្រឹមត្រូវ ដូច្នេះមុនពេលធ្វើការប្រៀបធៀបជាមួយចំនួនទឹកប្រាក់ដែលត្រូវទទួលបានមកវិញ ដោយការបូកបញ្ចូលគ្នានូវតម្លៃក្នុងបញ្ជីនៃមូលនិធិពាណិជ្ជកម្មដែលបានបែងចែកទៅឲ្យអង្គភាពត្រូវបញ្ចូលមូលនិធិពាណិជ្ជកម្មដែលត្រូវបែងចែកទៅឲ្យភាគកម្មអប្បភាគ។តម្លៃក្នុងបញ្ជីដែលបានកែសម្រួលត្រឹមត្រូវនិង ត្រូវបានប្រៀបធៀបជាមួយចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃអង្គភាពដើម្បីកំណត់ថាតើអង្គភាពរកសាច់ប្រាក់ត្រូវបានធ្លាក់ចុះ។

២៧.២៧ប្រសិនបើមូលនិធិពាណិជ្ជកម្មមិនអាចបែងចែកទៅអង្គភាពរកសាច់ប្រាក់នីមួយៗទេ(ឬក្រុមនៃអង្គភាពរកសាច់ប្រាក់)តាមមូលដ្ឋានមិនស្មើភាព ដូច្នេះសម្រាប់គោលបំណងនៃការធ្វើតេស្តមូលនិធិពាណិជ្ជកម្ម អង្គភាពត្រូវធ្វើតេស្តការធ្លាក់ចុះនៃតម្លៃមូលនិធិពាណិជ្ជកម្មដោយកំណត់ពីចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃចំណុច(ក)ឬ(ខ)

(ក)អង្គភាពដែលបានទិញទាំងស្រុង ប្រសិនមូលនិធិពាណិជ្ជកម្មទាក់ទងនឹងអង្គភាពដែលបានទិញ ដែលមិនត្រូវបាបញ្ចូលគ្នា។វិធីសាស្ត្របញ្ចូលគ្នា អាជីវកម្មដែលបានទិញត្រូវបានរៀបចំឡើងវិញឬត្រូវបានរំលាយចូលទៅក្នុងអង្គភាពរាយការណ៍ ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀត។

(ខ) ក្រុមអង្គភាពទាំងមូល ដោយមិនបញ្ចូលអង្គភាពណាដែលមិនត្រូវបានបញ្ចូល ប្រសិនមូលនិធិពាណិជ្ជកម្មទាក់ទងនឹងអង្គភាពដែលបានបញ្ចូលគ្នា។

នៅក្នុងការអនុវត្តកថាខណ្ឌ អង្គភាពនឹងត្រូវបំបែកចេញ មូលនិធិពាណិជ្ជកម្មចូលទៅក្នុងមូលនិធិពាណិជ្ជកម្មដែលទាក់ទងនឹងអង្គភាពទាំងឡាយណាដែលត្រូវបានបញ្ចូលគ្នា ហើយ មូលនិធិពាណិជ្ជកម្មដែលទាក់ទងនឹងអង្គភាពដែលមិនបានបញ្ចូលគ្នា។អង្គភាពក៏ត្រូវអនុវត្តតាមការតម្រូវសម្រាប់អង្គភាពរកសាច់ប្រាក់នៅក្នុងផ្នែកនេះ ពេលគណនាតម្លៃដែលអាចទទួលបានមកវិញ និងបែងចែកការខាតដោយការធ្លាក់ចុះតម្លៃ និង ការបញ្ច្រាស់មកវិញនៃទ្រព្យសកម្មកើតមាន អង្គភាពដែលបានទិញ ឬ ក្រុមអង្គភាព។

**ការប្រែត្រឡប់វិញនៃការខាតដោយសារការធ្លាក់ចុះតម្លៃ**

២៧.២៨ ការខាតដោយសារការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់សម្រាប់មូលនិធិពាណិជ្ជកម្មមិនត្រូវប្រែត្រឡប់វិញនៅក្នុងគ្រាបន្ទាប់នោះទេ។

២៧.២៩សម្រាប់គ្រប់ទ្រព្យសកម្មទាំងអស់ក្រៅពីមូលនិធិពាណិជ្ជកម្មអង្គភាពត្រូវវាយតម្លៃនៅថ្ងៃរាយការណ៍ នីមួយៗ ថាតើមានសញ្ញាដែលការខាតដោយសារការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងគ្រាមុនអាចមិនកើតមានទៀតដែរឬទេ ឬ អាចថយចុះ។ សញ្ញាដែលការធ្លាក់ចុះតម្លៃបានថយចុះ ឬ មិនកើតមានតទៅទៀតជាទូទៅគឺជាតម្លៃផ្ទុយនៃការធ្លាក់ចុះនោះដែលបានកំណត់នៅក្នុងកថាខណ្ឌ ២៧.៩។ ប្រសិនបើមានសញ្ញាណាមួយកើតឡើង អង្គភាពត្រូវកំណត់ថាតើការខាតដោយសារការធ្លាក់ចុះតម្លៃមួយផ្នែកឬទាំងអស់កាលពីគ្រាមុនត្រូវបានប្រែត្រឡប់មកវិញ។នីតិវិធីសម្រាប់ការកំណត់នោះ នឹងត្រូវផ្អែកលើថាតើការខាតដោយសារការធ្លាក់ចុះតម្លៃពីមុនលើតម្លៃទ្រព្យសកម្មត្រូវបានពឹងផ្អែកលើៈ

(ក) ចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យសកម្មនីមួយៗ (សូមមើលកថាខណ្ឌ ២៧.៣០) ឬ

(ខ) ចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មមាន(សូមមើលកថាខណ្ឌ ២៧.៣១)។

**ការប្រែត្រឡប់មកវិញដែលចំនួនទឹកប្រាក់អាចទទួលបានមកវិញត្រូវបានប៉ាន់ស្មានសម្រាប់ទ្រព្យសកម្មដែលបានធ្លាក់ថ្លៃនីមួយៗ**

២៧.៣០ នៅពេលការខាតដោយសារធ្លាក់ចុះតម្លៃគ្រាមុនត្រូវបានពឹងផ្អែកលើចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យសកម្មធ្លាក់ថ្លៃនីមួយៗ ការតម្រូវខាងក្រោមអនុវត្តៈ

(ក) អង្គភាពត្រូវប៉ាន់ស្មានពីចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យសកម្មនៅថ្ងៃរាយការណ៍បច្ចុប្បន្ន។

(ខ) ប្រសិនបើចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញប៉ាន់ស្មាននៃទ្រព្យសកម្មលើសតម្លៃក្នុងបញ្ជី អង្គភាពត្រូវបង្កើនតម្លៃក្នុងបញ្ជីទៅស្មើនឹងតម្លៃដែលអាចទទួលបានមកវិញជាកម្មវត្ថុចំពោះ ការកម្រិតដែលរៀបរាប់ក្នុង (គ) ខាងក្រោម។ការកើនឡើងនោះគឺជាការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃ។អង្គភាពត្រូវទទួលស្គាល់ការប្រែត្រឡប់ភ្លាមនៅក្នុងរបាយការណ៍ចំណេញ ឬ ខាត។

(គ) ការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃមិនបង្កើនតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មលើសពីតម្លៃក្នុងបញ្ជីដែលបានកំណត់នោះទេ (ក្រោយពីការដករំលស់) មិនមានការខាតដោយសារការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មនៅក្នុងឆ្នាំមុនៗ។

(ឃ) បន្ទាប់ពីការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ អង្គភាពត្រូវកែសម្រួលចំណាយរំលស់សម្រាប់ទ្រព្យសកម្មនៅគ្រាខាងមុខដើម្បីបែងចែកតម្លៃក្នុងបញ្ជីកែរួចនៃទ្រព្យសកម្ម ដកចេញនូវតម្លៃកាកសំណល់ (ប្រសិនបើមាន) តាមមូលដ្ឋានជាប្រព័ន្ធលើអាយុកាល ដែលនៅសល់។

**ការប្រែត្រឡប់ពេលដែលតម្លៃអាចទទួលបានមកវិញត្រូវបានប៉ាន់ស្មានសម្រាប់អង្គភាពរកសាច់ប្រាក់**

២៧.៣១ពេលការខាតដោយសារការធ្លាក់ចុះតម្លៃពេលដំបូងបានពឹងផ្អែកលើតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់ដែលទ្រព្យសកម្មមាន ការតម្រូវខាងក្រោមអនុវត្តៈ

(ក) អង្គភាពត្រូវប៉ាន់ស្មានពីតម្លៃអាចទទួលបានមកវិញនៃអង្គភាពរកសាច់ប្រាក់នោះនៅថ្ងៃរាយការណ៍បច្ចុប្បន្ន។

(ខ) ប្រសិនបើតម្លៃអាចទទួលប៉ាន់ស្មាននៃអង្គភាពរកសាច់ប្រាក់លើសពីតម្លៃក្នុងបញ្ជីផ្នែកដែលលើសគឺជាការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃ។អង្គភាពត្រូវបែងចែកចំនួនទឹកប្រាក់នៃការប្រែត្រឡប់នោះទៅទ្រព្យសកម្មនៃអង្គភាព លើកលែងតែកេរ្តិ៍ឈ្មោះ សមាមាត្រជាមួយនឹងតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មទាំងនោះជាកម្មវត្ថុចំពោះការកម្រិតដែលបានរៀបរាប់ នៅក្នុង(គ) ខាងក្រោម។ ការកើនឡើងទាំងនោះនៅក្នុងតម្លៃក្នុងបញ្ជីត្រូវចាត់ទុកជាការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃសម្រាប់ទ្រព្យសកម្មនីមួយៗ ហើយត្រូវបានទទួលស្គាល់ភ្លាមនៅក្នុង របាយការណ៍ចំណេញ ឬ ខាត។

(គ) នៅក្នុងការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃសម្រាប់អង្គភាពរកសាច់ប្រាក់ ការប្រែត្រឡប់មិនត្រូវបង្កើនតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មលើសតម្លៃទាបជាងនេះ

(១) តម្លៃអាចទទួលបាន និង

(២) តម្លៃក្នុងបញ្ជីដែលបានកំណត់(ក្រោយពីដករំលស់) ពុំមានកាខាតដោយសារការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មក្នុងគ្រាមុន!។

(ឃ) ចំនួនទឹកប្រាក់ដែលលើសនៃការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃដែលមិនអាចបែងចែកទៅទ្រព្យសកម្មបានដោយសារការហាមឃាត់នៅក្នុង(គ) ខាងលើត្រូវបានបែងចែកតាមសមាមាត្រទៅទ្រព្យសកម្មផ្សេងទៀតនៃអង្គភាពរកសាច់ប្រាក់ លើកលែងស្នេហ៍លនិធិពាណិជ្ជកម្ម។

(ង) បន្ទាប់ពីការការប្រែត្រឡប់នៃការខាតដោយសារការធ្លាក់ចុះតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើអាចអនុវត្តបានអង្គភាពត្រូវកែសម្រួលចំណាយរំលស់សម្រាប់ទ្រព្យសកម្មនីមួយៗនៅក្នុង អង្គភាពរកសាច់ប្រាក់ក្នុងគ្រាខាងមុខ ដើម្បីបែងចែកតម្លៃក្នុងបញ្ជីបានកែប្រែនៃទ្រព្យសកម្មដកចេញនូវតម្លៃកាកសំណល់ (ប្រសិនបើមាន) លើមូលដ្ឋានជាប្រព័ន្ធលើអាយុកាលនៅសល់។

## ការលាតត្រដាងព័ត៌មាន

២៧.៣២ អង្គភាពត្រូវបង្ហាញព័ត៌មានខាងក្រោមសម្រាប់**ថ្នាក់ទ្រព្យសកម្ម**នីមួយៗដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ២៧.៣៣ ÷

(ក) ចំនួនទឹកប្រាក់នៃការខាតដោយសារការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញឬខាតក្នុងគ្រា និងធាតុគណនីនៅក្នុងរបាយការណ៍លទ្ធផលសរុប (និង ក្នុងរបាយការណ៍ លទ្ធផល (ប្រសិនបើត្រូវ បានបង្ហាញ) ដែលការខាតដោយសារការធ្លាក់ចុះតម្លៃទាំងនោះត្រូវបានរួម បញ្ចូល។

(ខ) ចំនួនទឹកប្រាក់នៃការប្រែត្រឡប់ការខាតដោយសារការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញឬខាតក្នុងគ្រានិងធាតុគណនីនៅក្នុងរបាយការណ៍លទ្ធផលសរុប (និងក្នុងរបាយការណ៍លទ្ធផល ប្រសិនបើត្រូវបានបង្ហាញ) ដែលការខាតដោយសារការធ្លាក់ចុះតម្លៃ ទាំងនោះត្រូវបានប្រែត្រឡប់។

២៧.៣៣ អង្គភាពត្រូវបង្ហាញព័ត៌មានដែលបានតម្រូវដោយកថាខណ្ឌ ២៧.៣២ សម្រាប់ថ្នាក់ទ្រព្យសកម្មនីមួយៗ ខាងក្រោមៈ

(ក) សន្និធិ

(ខ) ទ្រព្យ រោងចក្រ និងបរិក្ខារ (រួមបញ្ចូលទ្រព្យវិនិយោគ ដែលបានទទួលស្គាល់វិធីសាស្ត្រថ្លៃ ដើម)

(គ) មូលនិធិពាណិជ្ជកម្ម

(ឃ) ទ្រព្យសកម្មអរូបី ក្រៅពីមូលនិធិពាណិជ្ជកម្ម

(ង) ការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ

(ច) ការវិនិយោគនៅក្នុងក្រុមហ៊ុនចូលរួមទុន

## ផ្នែកទី២៨
## អត្ថប្រយោជន៍និយោជិត

វិសាលភាពនៃផ្នែកនេះ

២៨.១ **អត្ថប្រយោជន៍និយោជិត**គឺជាទម្រង់ទាំងអស់នៃតម្លៃតបស្នងដែលបានផ្តល់ដោយអង្គភាពក្នុងការដោះដូរសេវាកម្ម ដែលបានផ្តល់ដោយនិយោជិករួមបញ្ចូលទាំងនាយកនិងគណៈគ្រប់គ្រង។ផ្នែកនេះអនុវត្តចំពោះអត្ថប្រយោជន៍ និយោជិកទាំងអស់ លើកលែងតែ **ប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹក ហ៊ុន** ដែលគ្របដណ្តប់ដោយផ្នែកទី២៦ *ការទូទាត់ផ្អែកលើសន្លឹកហ៊ុន*។ អត្ថប្រយោជន៍និយោជិកដែលគ្របដណ្តប់ដោយផ្នែកនេះនឹងជាប្រភេទមួយក្នុង ចំណោមប្រភេទទាំង៤ខាងក្រោម:

(ក)អត្ថប្រយោជន៍និយោជិករយៈពេលខ្លីដែលអត្ថប្រយោជន៍និយោជិក (ក្រៅពី **អត្ថប្រយោជន៍ ពេលបញ្ឈប់ពីការងារ)** ដែលដល់ពេលត្រូវសងក្នុងរយៈពេល១២ខែបន្ទាប់ពីចុងគ្រាដែលនិយោជិកផ្តល់សេវាកម្ម

(ខ) **អត្ថប្រយោជន៍ក្រោយបំពេញការងារ**ដែលអត្ថប្រយោជន៍និយោជិក(ក្រៅពីអត្ថប្រយោជន៍ ពេលបញ្ឈប់ពីការងារ)ដែលត្រូវសងបន្ទាប់ពីការបញ្ចប់ការងារ

(គ)អត្ថប្រយោជន៍និយោជិករយៈពេលវែងផ្សេងទៀតដែលអត្ថប្រយោជន៍និយោជិក (ក្រៅពី អត្ថប្រយោជន៍ក្រោយបំពេញការងារ និងអត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារ) ដែលមិនទាន់ដល់ពេលសងក្នុងរយៈពេល១២ ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិកផ្តល់សេវាកម្មដែលទាក់ទិន។

(ឃ) អត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារ ដែលអត្ថប្រយោជន៍និយោជិកត្រូវសងដែលកើតចេញពីៈ

(១) ការសម្រេចចិត្តរបស់អង្គភាពដើម្បីបញ្ឈប់ការងាររបស់និយោជិកមុនពេលចូលនិវត្តន៍ធម្មតា ឬ

(២)ការសម្រេចចិត្តរបស់និយោជិកដើម្បីទទួលយកភាពទំនេរដោយស្ម័គ្រចិត្តក្នុងការដោះដូរសម្រាប់ អត្ថប្រយោជន៍ទាំងនោះ។

២៨.២ អត្ថប្រយោជន៍និយោជិកត្រូវបញ្ចូលផងដែរនូវប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនដែលនិយោជិកទទួល ឧបករណ៍ដើមទុន(ដូចជា ភាគហ៊ុនឬសិទ្ធិពិសេសទិញភាគហ៊ុន) ឬសាច់ប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតរបស់ អង្គភាពជាចំនួនទឹកប្រាក់ដែលផ្អែកលើតម្លៃនៃភាគហ៊ុនរបស់អង្គភាពឬ ឧបករណ៍ដើមទុនផ្សេងទៀតរបស់ អង្គភាព។អង្គភាពត្រូវអនុវត្តផ្នែកទី២៦ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុន។

### គោលការណ៍ទទួលស្គាល់ជាទូទៅសម្រាប់អត្ថប្រយោជន៍និយោជិកទាំងអស់

២៨.៣ អង្គភាពត្រូវទទួលស្គាល់ចំណាយនៃអត្ថប្រយោជន៍និយោជិកទាំងអស់ដែលនិយោជិករបស់ខ្លួនបានទទួលសិទ្ធិ ដែលកើតចេញពីសេវាកម្មដែលបានផ្តល់មកឱ្យអង្គភាពក្នុងកំឡុង**គ្រារាយការណ៍**:

(ក) ជាបំណុល បន្ទាប់ពីការដកចេញចំនួនទឹកប្រាក់ដែលត្រូវបានបង់ដោយផ្ទាល់ទៅឲ្យនិយោជិកឬ ជាវិភាគទានទៅឲ្យមូលនិធិអត្ថប្រយោជន៍និយោជិក។ ប្រសិនបើចំនួនទឹកប្រាក់ដែលបានបង់ លើសពីកាតព្វកិច្ចដែលកើតចេញពីសេវាកម្មមុនពេល**ថ្ងៃរាយការណ៍** អង្គភាពត្រូវទទួលស្គាល់ផ្នែកលើសជាទ្រព្យសកម្មរហូតដល់ការបង់មុននឹងនាំដល់ការកាត់បន្ថយក្នុងការទូទាត់នាពេលអនាគត ឬ ការបង្វិលសងសាច់ប្រាក់។

(ខ) ជាចំណាយ លុះត្រាផ្នែកផ្សេងទៀតនៃស្តង់ដារនេះតម្រូវឲ្យចំនាយត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃចំណាយនៃទ្រព្យសកម្ម ដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

## អត្ថប្រយោជន៍និយោជិករយៈពេលខ្លី

### ឧទាហរណ៍

២៨.៤ អត្ថប្រយោជន៍និយោជិករយៈពេលខ្លីរួមបញ្ចូលធាតុដូចខាងក្រោមៈ

(ក) ប្រាក់ឈ្នួល ប្រាក់ខែ និង វិភាគទានសម្រាប់សុវត្ថិភាពសង្គម

(ខ) ការតបស្នងរយៈពេលខ្លីពេលអវត្តមាន (ដូចជា ការឈប់ប្រចាំឆ្នាំមានប្រាក់ខែ និង ការឈប់ពេលឈឺមានប្រាក់ខែ) ពេលដែលភាពអវត្តមានត្រូវបានរំពឹងថានឹងកើតមានឡើងក្នុងរយៈពេល១២ ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិកផ្តល់សេវាកម្មដែលទាក់ទិន

(គ) បំណុលប្រាក់បន្ថែមនិងការចែកប្រាក់ចំណេញនៅក្នុងរយៈពេល១២ខែ បន្ទាប់ពីចុងគ្រាដែលនិយោជិកផ្តល់សេវាកម្មទាក់ទិន និង

(ឃ) អត្ថប្រយោជន៍មិនមែនរូបិយវត្ថុ (ដូចជា ការថែទាំសុខភាព ការស្នាក់នៅ រថយន្ត និង ទំនិញ ឬសេវាកម្មឧបត្ថម្ភធន ឬមិនគិតកំរៃ) សម្រាប់និយោជិកបច្ចុប្បន្ន។

### ការវាស់វែងនៃអត្ថប្រយោជន៍រយៈពេលខ្លីជាទូទៅ

២៨.៥ ពេលនិយោជិកបានផ្តល់សេវាកម្មទៅឲ្យអង្គភាពក្នុងកំឡុងគ្រារាយការណ៍ អង្គភាពត្រូវវាស់វែងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ ២៨.៣ តាមតម្លៃមិនទាន់ធ្វើអប្បហារនៃអត្ថប្រយោជន៍និយោជិករយៈពេលខ្លីដែលត្រូវបានរំពឹងថានឹងសងក្នុងការដោះដូរសេវាកម្ម នោះ។

### ការទទួលស្គាល់ និង ការវាស់វែង - ការអវត្តមានរយៈពេលខ្លីមានការតបស្នង

២៨.៦ អង្គភាពអាចតបស្នងនិយោជិកពេលអវត្តមានសម្រាប់ហេតុផលមួយចំនួន រួមមាន ការឈប់វិសមកាលប្រចាំឆ្នាំ និងការឈប់ពេលឈឺ។ការអវត្តមានរយៈពេលខ្លីមានការតបស្នងខ្លះបូកបន្ត អត្ថប្រយោជន៍ត្រូវបានយោងទៅពេលខាងមុខនិងត្រូវបានប្រើក្នុងគ្រាខាងមុខ ប្រសិនបើនិយោជិកមិនប្រើសិទ្ធិទទួលបានសម្រាប់គ្រា

បច្ចុប្បន្នទាំងស្រុងទេ។ឧទាហរណ៍ រួមមានការឈប់វិសមកាលប្រចាំឆ្នាំ និងការឈប់សំរាកពេលឈឺ។ អង្គភាពត្រូវទទួលស្គាល់ចំណាយនៃការប្តូកបន្តនៃការតបស្នងពេលអវត្តមាន នៅពេលដែលនិយោជិកផ្តល់សេវាកម្មដែលបង្កើនសិទ្ធិទទួលរបស់គេ ទៅការអវត្តមានទទួលបានការតបស្នងអនាគត។ អង្គភាពត្រូវវាស់វែងចំណាយរំពឹងទុកនៃការប្តូកបន្តតម្លៃតបស្នងពេលអវត្តមាន តាមចំនួនបន្ថែមមិនទាន់ធ្វើអប្បហារដែលអង្គភាពរំពឹងថានឹងទូទាត់ជាលទ្ធផលនៃសិទ្ធិទទួលបានមិនបានប្រើ ដែលបានប្តូកបន្តនៅចុងគ្រារាយការណ៍។ អង្គភាពត្រូវបង្ហាញចំនួនទឹកប្រាក់នេះ ជា**បំណុល រយៈពេលខ្លី**នៅថ្ងៃរាយការណ៍។

២៨.៧ អង្គភាពត្រូវទទួលស្គាល់ចំណាយនៃតម្លៃតបស្នងពេលអវត្តមាន(មិនប្តូកបន្ត)ផ្សេងទៀត ពេលអវត្តមានកើតមានឡើង។អង្គភាពត្រូវវាស់វែងចំណាយនៃតម្លៃតបស្នងពេលអវត្តមានមិនប្តូកបន្ត តាមចំនួនប្រាក់ខែ និងប្រាក់ឈ្នួលបានបង់មិនទាន់ធ្វើអប្បហារ ឬ បំណុលសម្រាប់គ្រាអវត្តមាន។

**ការទទួលស្គាល់ - ការចែកប្រាក់ចំណេញ និង ផែនការប្រាក់បន្ថែម**

២៨.៨ អង្គភាពត្រូវទទួលស្គាល់ចំណាយរំពឹងនៃការចែកប្រាក់ចំណេញ និង ការទូទាត់ប្រាក់បន្ថែម តែនៅពេលៈ

(ក)អង្គភាពមានកាតព្វកិច្ចស្របច្បាប់ឬ**កាតព្វកិច្ចសាងសង់**ដើម្បីធ្វើការទូទាត់ដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាល (នេះមានន័យថា អង្គភាពមិនមានជម្រើសជាក់លាក់ ប៉ុន្តែនឹងធ្វើការទូទាត់) និង

(ខ) ការប៉ាន់ស្មានដ៏ជឿជាក់នៃកាតព្វកិច្ចអាចធ្វើទៅបាន។

**អត្ថប្រយោជន៍ក្រោយការបំពេញការងារ: ភាពខុសគ្នារវាងផែនការវិភាគទានកំណត់ និង ផែនការអត្ថប្រយោជន៍ កំណត់**

២៨.៩ អត្ថប្រយោជន៍ក្រោយបំពេញការងារ រួមមាន ជាឧទាហរណ៍:

(ក) អត្ថប្រយោជន៍ចូលនិវត្តន៍ ដូចជា ប្រាក់សោធន និង

(ខ)អត្ថប្រយោជន៍ក្រោយបំពេញការងារផ្សេងទៀត ដូចជា ធានារ៉ាប់រងជីវិតក្រោយបំពេញការងារ និង ការថែទាំសុខភាពក្រោយបំពេញការងារ

ការរៀបចំទាំងឡាយដែលអង្គភាពមួយផ្តល់អត្ថប្រយោជន៍ក្រោយបំពេញការងារគឺជា**ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ។** អង្គភាពត្រូវអនុវត្តផ្នែកនេះចំពោះការរៀបចំបែបនេះថាតើ ពួកគេជាប់ទាក់ទងនឹងការបង្កើតឡើងនូវអង្គភាពដាច់ដោយឡែកដើម្បីទទួលវិភាគទាន និង បង់អត្ថប្រយោជន៍។ នៅក្នុងករណីខ្លះ ការរៀបចំទាំងនេះត្រូវបានកំណត់ដោយច្បាប់ជាជាងដោយសកម្មភាពរបស់អង្គភាព។ នៅក្នុងករណីខ្លះទៀត ការរៀបចំទាំងនេះកើតឡើងពីសកម្មភាពរបស់អង្គភាព ទោះបីក្នុងភាពអវត្តមាននៃផែនការផ្លូវការជាលាយលក្ខអក្សរក្តី។

២៨.១០ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារត្រូវបានចាត់ថ្នាក់ជា**ផែនការវិភាគទានកំណត់ ឬផែនការអត្ថប្រយោជន៍កំណត់**ដោយផ្អែកលើលក្ខខណ្ឌសួលរបស់គេ។

(ក)ផែនការវិភាគទានកំណត់គឺជាផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារដែលអង្គភាពបង់វិភាគទានថេរទៅឱ្យអង្គភាពដោយឡែក(មូលនិធិ) និង មិនមានកាតព្វកិច្ចស្របច្បាប់ ឬសាងសង់ ដើម្បីបង់វិភាគទានបន្ថែម ឬធ្វើការទូទាត់សងអត្ថប្រយោជន៍ដោយផ្ទាល់ទៅឱ្យនិយោជិកប្រសិនបើ មូលនិធិមិនមានទ្រព្យសកម្មគ្រប់គ្រាន់ដើម្បីបង់អត្ថប្រយោជន៍និយោជិកទាំងអស់ដែលទាក់ទងនឹងសេវានិយោជិកក្នុងគ្រាមុននិងបច្ចុប្បន្ន។ ដូច្នេះចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ក្រោយបំពេញការងារ ដែលបានទទួលដោយនិយោជិកត្រូវបានកំណត់ដោយចំនួនទឹកប្រាក់នៃវិភាគទានដែលបានបង់ដោយអង្គភាព(និងប្រហែលដោយនិយោជិកផងដែរ) ទៅឱ្យផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ឬ ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ជាមួយគ្នាទៅនឹងចំណូលពីការវិនិយោគដែលកើតពីការបង់វិភាគទាន។

(ខ)ផែនការអត្ថប្រយោជន៍កំណត់គឺជាផែនការអត្ថប្រយោជន៍ក្រោយពេលបំពេញការងារជាជាងផែនការវិភាគទានកំណត់។ក្រោមផែនការអត្ថប្រយោជន៍កំណត់ កាតព្វកិច្ចរបស់អង្គភាពគឺត្រូវ ផ្តល់អត្ថប្រយោជន៍ដែលបានយល់ព្រមចំពោះនិយោជិកអតីតកាលនិងបច្ចុប្បន្ននិងហានិយភ័យជាក់ស្តែង(ដែលអត្ថប្រយោជន៍នឹងមានតម្លៃលើសឬតិចជាងការរំពឹងទុក) ហើយហានិភ័យវិនិយោគ(ដែលចំណូលលើទ្រព្យសកម្មបានដាក់បញ្ចូលទៅក្នុងមូលនិធិអត្ថប្រយោជន៍នឹងខុសពីការរំពឹងទុក)ត្រូវទទួលខុសត្រូវដោយអង្គភាពជាសារៈសំខាន់។ ប្រសិនបើបទពិសោធន៍វិនិយោគឬជាក់ស្តែងអាក្រក់ជាងការរំពឹងទុក កាតព្វកិច្ចរបស់អង្គភាពអាចត្រូវបានបង្កើន និង ផ្ទុយមកវិញ ប្រសិនបើបទពិសោធន៍វិនិយោគ ឬ ជាក់ស្តែងល្អជាងការរំពឹងទុក។

ផែនការពហុនិយោជកនិង ផែនការរបស់រដ្ឋ

២៨.១១ផែនការពហុនិយោជកនិងផែនការរបស់រដ្ឋត្រូវបានចាត់ថ្នាក់ជាផែនការវិភាគទានកំណត់ឬ ផែនការអត្ថប្រយោជន៍កំណត់ដោយឈរលើមូលដ្ឋាននៃរយៈពេលផែនការ រួមបញ្ចូលកាតព្វកិច្ចសាងសង់ណាដែលលើសពីរយៈពេលផ្លូវការ។ប៉ុន្តែប្រសិនបើពុំមានព័ត៌មានគ្រប់គ្រាន់ ដើម្បីប្រើអត្ថប្រយោជន៍កំណត់ដែលទទួលស្គាល់សម្រាប់ផែនការពហុនិយោជកដែលជាផែនការអត្ថប្រយោជន៍កំណត់ទេ នោះអង្គភាពត្រូវទទួលស្គាល់ផែនការដោយអនុលោមតាមកថាខណ្ឌ២៨.១៣ ប្រសិនបើវា គឺជាផែនការវិភាគទានកំណត់ និងធ្វើការលាតត្រដាងព័ត៌មានដែលតម្រូវដោយកថាខណ្ឌ២៨.៤០។

អត្ថប្រយោជន៍ដែលបានធានា

២៨.១២ អង្គភាពអាចបង់បុព្វលាភធានារ៉ាប់រងដើម្បីផ្តល់មូលនិធិទៅផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ។ អង្គភាពត្រូវទទួលស្គាល់ផែនការបែបនេះជាផែនការវិភាគទានកំណត់ លុះត្រាតែ អង្គភាពមានកាតព្វកិច្ចស្របច្បាប់ ឬ សាងសង់៖

(ក) បង់អត្ថប្រយោជន៍និយោជិកដោយផ្ទាល់ពេលអត្ថប្រយោជន៍បានដល់កំណត់សង ឬ

(ខ) បង់ចំនួនទឹកប្រាក់បន្ថែមប្រសិនក្រុមហ៊ុនធានារ៉ាប់រងមិនបង់អត្ថប្រយោជន៍និយោជិកសម្រាប់ ពេលអនាគតទាំងអស់ដែលទាក់ទងនឹងសេវាកម្មនិយោជិកក្នុងគ្រាមុន និង បច្ចុប្បន្ន។

កាតព្វកិច្ចសាងសង់គួរកើតមានឡើងដោយប្រយោលតាមរយៈផែនការ តាមរយៈយន្តការសម្រាប់ កំណត់តម្លៃបុព្វលាភអនាគត ឬ តាមរយៈទំនាក់ទំនងភាគីពាក់ព័ន្ធ ជាមួយក្រុមហ៊ុនធានារ៉ាប់រង។ ប្រសិនបើអង្គភាពរក្សានូវកាតព្វកិច្ចសាងសង់ ឬ ស្របច្បាប់ អង្គភាពត្រូវទទួលស្គាល់ផែនការជាផែនការអត្ថប្រយោជន៍កំណត់។

## អត្ថប្រយោជន៍ក្រោយបំពេញការងារ: ផែនការវិភាគទានកំណត់

### ការទទួលស្គាល់ និង ការវាស់វែង

២៨.១៣ អង្គភាពត្រូវទទួលស្គាល់បំណុលវិភាគទានសម្រាប់គ្រា:

(ក) ជាបំណុល បន្ទាប់ពីដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានបង់រួច។ ប្រសិនបើ ការទូទាត់វិភាគទានលើសពីវិភាគទានត្រូវបង់សម្រាប់សេវាកម្មមុនថ្ងៃរាយការណ៍ នោះអង្គភាពត្រូវទទួលស្គាល់ផ្នែកដែលលើសជាទ្រព្យសកម្ម។

(ខ) ជាចំណាយលុះត្រាតែផ្នែកផ្សេងទៀតនៃស្តង់ដារនេះតម្រូវឲ្យចំណាយនឹងត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្មដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

## អត្ថប្រយោជន៍ក្រោយបំពេញការងារ: ផែនការអត្ថប្រយោជន៍កំណត់

### ការទទួលស្គាល់

២៨.១៤ ក្នុងការអនុវត្តគោលការណ៍ទទួលស្គាល់ជាទូទៅក្នុងកថាខណ្ឌ ២៨.៣ ចំពោះផែនការអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវទទួលស្គាល់:

(ក) ជាបំណុលសម្រាប់កាតព្វកិច្ចក្រោមផែនការអត្ថប្រយោជន៍កំណត់ដកចេញទ្រព្យសកម្មផែនការ ពោលគឺ **បំណុលអត្ថប្រយោជន៍កំណត់**(សូមមើលកថាខណ្ឌ ២៨.១៥- ២៨.២៣)។

(ខ) ទទួលស្គាល់ការប្រែប្រួលសុទ្ធក្នុងបំណុលនោញក្នុងកំឡុងគ្រាដែលថ្លៃដើមនៃផែនការអត្ថប្រយោជន៍កំណត់ក្នុងកំឡុងគ្រា (សូមមើលកថាខណ្ឌ ២៨.២៤២៨.២៧)។

### ការវាស់វែងនៃបំណុលអត្ថប្រយោជន៍កំណត់

២៨.១៥អង្គភាពត្រូវវាស់វែងបំណុលអត្ថប្រយោជន៍កំណត់សម្រាប់កាតព្វកិច្ចក្រោមផែនការអត្ថប្រយោជន៍តាមតម្លៃសរុបសុទ្ធនៃចំនួនទឹកប្រាក់ខាងក្រោម:

(ក)**តម្លៃបច្ចុប្បន្ន** នៃកាតព្វកិច្ចក្រោមផែនការអត្ថប្រយោជន៍កំណត់ ( **កាតព្វកិច្ចអត្ថប្រយោជន៍ កំណត់)** តាមថ្ងៃរាយការណ៍ (កថាខណ្ឌ២៨.១៦ - ២៨.២២ ផ្តល់ការណែនាំសម្រាប់ការវាស់វែងកាតព្វកិច្ចនេះ) ដក ចេញនូវៈ

(ខ) តម្លៃសមស្របនៅថ្ងៃរាយការណ៍**នៃទ្រព្យសកម្ម**(ប្រសិនបើមាន) ក្រៅពីកាតព្វកិច្ចនឹងត្រូវ ទូទាត់សងដោយផ្ទាល់។ កថាខណ្ឌ ១១.២៧ - ១១.៣២ បង្កើតការតម្រូវទាំងឡាយសម្រាប់កំណត់តម្លៃ សមស្របនៃទ្រព្យសកម្មផែនការទាំងនោះដែលជា**ទ្រព្យសកម្មហិរញ្ញវត្ថុ។**

## ការបញ្ចូលគ្នានូវអត្ថប្រយោជន៍ផ្ទេរនិងមិនផ្ទេរ

២៨.១៦តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចរបស់អង្គភាពក្រោមផែនការអត្ថប្រយោជន៍កំណត់នៅថ្ងៃរាយការណ៍ត្រូវឆ្លុះបញ្ចាំងពីតម្លៃប៉ាន់ស្មាននៃអត្ថប្រយោជន៍ដែលនិយោជិករកបានជាចំណូលសម្រាប់សេវាកម្មរបស់គេក្នុងគ្រាបច្ចុប្បន្ន និងអនាគត រួមបញ្ចូលទាំងអត្ថប្រយោជន៍ដែលមិនទាន់បានផ្ទេរ (សូមមើលកថាខណ្ឌ ២៨.២៦) និង រួមមានផលប៉ះពាល់នៃរូបមន្តអត្ថប្រយោជន៍ដែលផ្តល់ឲ្យនិយោជិកច្រើនជាងសម្រាប់សេវានៅឆ្នាំក្រោយៗ។ នេះបានតម្រូវឲ្យអង្គភាពត្រូវកំណត់ពីតម្លៃអត្ថប្រយោជន៍ប៉ុន្មាន ដែលត្រូវបែងចែកទៅឲ្យគ្រាបច្ចុប្បន្ននិង អនាគតដោយផ្អែកលើរូបមន្តអត្ថប្រយោជន៍របស់ផែនការ និង ដើម្បីប៉ាន់ស្មាន(ការសន្មតជាក់លាក់) អំពីអថេរប្រជាសាស្ត្រ(ដូចជាផលរបរនិយោជិក និង ចំនួនមរណ ភាព) និង អថេរហិរញ្ញវត្ថុដូចជាការកើនឡើងពេល អនាគតនូវប្រាក់ខែនិងចំណាយថែទាំសុខភាព)ដែលមានឥទ្ធិពលលើថ្លៃនៃអត្ថប្រយោជន៍។ការសន្មតជាក់លាក់ ត្រូវមានភាពច្បាស់លាស់ (មិនធ្វេស ប្រហែស និងមិនអភិរក្សខ្លាំងពេក) ស្របគ្នា និង ត្រូវបានជ្រើសរើសដើម្បី ឈានទៅដល់ការប៉ាន់ស្មាន នៃលំហូរសាច់ប្រាក់អនាគត ដែលនឹងកើតឡើងក្រោមគំរោង។

## ការធ្វើអប្បហារ

២៨.១៧អង្គភាពត្រូវវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់លើមូលដ្ឋានតម្លៃបច្ចុប្បន្ន។អង្គភាពត្រូវកំណត់អត្រាដែល បានប្រើដើម្បីធ្វើអប្បហារការទូទាត់អនាគតដោយយោងតាមចំណូលទីផ្សារនៅថ្ងៃរាយការណ៍លើសញ្ញាប័ណ្ណ សាជីវកម្មមានគុណភាពខ្ពស់។នៅក្នុងប្រទេសដែលមិនមានទីផ្សារសកម្ម នៅក្នុងសញ្ញាប័ណ្ណបែបនេះ អង្គភាព ត្រូវប្រើចំណូលទីផ្សារ( នៅថ្ងៃរាយការណ៍)តាមសញ្ញាប័ណ្ណរដ្ឋាភិបាល។ រូបិយប័ណ្ណ និងរយៈពេលនៃសញ្ញាប័ណ្ណ សាជីវកម្មឬសញ្ញាប័ណ្ណរដ្ឋាភិបាលត្រូវមានសង្គតិភាពជាមួយរូបិយប័ណ្ណ និងរយៈពេលប៉ាន់ស្មាននៃការទូទាត់នាពេលអនាគត។

## វិធីសាស្ត្រវាយតម្លៃជាក់ស្តែង

២៨.១៨ដោយគ្មានចំណាយ ឬការខិតខំច្រើនហួសហេតុ ប្រសិនបើអង្គភាពអាចប្រើប្រាស**វិធីសាស្ត្រឥណទានជាឯកត្តាប៉ាន់ស្មាន** ដើម្បីវាស់វែងនូវកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ និងការចំណាយទាក់ទិន អង្គភាពតែធ្វើតែម្តង។ ប្រសិនបើអត្ថប្រយោជន៍កំណត់ផ្អែកលើប្រាក់ខែអនាគត វិធីសាស្ត្រឥណទានឯកត្តាប៉ាន់ស្មាន តម្រូវឲ្យអង្គភាព

ត្រូវវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់លើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីការកើនឡើងប្រាក់ខែអនាគតប៉ាន់ស្មាន។លើសពីនេះទៅទៀត វិធីសាស្ត្រឥណទានឯកត្តាប៉ាន់ស្មានតម្រូវឱ្យអង្គភាពធ្វើការសន្មតជាក់ស្តែងផ្សេងៗក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ រួមបញ្ចូលអត្រាអប្បហារ អត្រាចំណេញប៉ាន់ស្មានលើទ្រព្យសកម្មផែនការ អត្រាកើនឡើងប្រាក់ខែប៉ាន់ស្មាន ផលរបរនិយោជិក ចំនួនមរណភាព និង(សម្រាប់ផែនការអត្ថប្រយោជន៍ថែទាំសុខភាពកំណត់) អត្រាគន្លងចំណាយលើការថែទាំសុខភាព។

២៨.១៩ដោយគ្មានចំណាយ ឬ ការខិតខំហួសហេតុ ប្រសិនបើអង្គភាពមិនអាចប្រើវិធីសាស្ត្រឥណទានឯកត្តាប៉ាន់ស្មានដើម្បីវាស់វែងកាតព្វកិច្ច និងចំណាយក្រោមផែនការអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវបានអនុញ្ញាតឱ្យធ្វើការវាស់វែងងាយៗនូវកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ទាក់ទងនឹងនិយោជិកបច្ចុប្បន្ន

(ក)មិនអើពើនឹងការកើនឡើងប្រាក់ខែអនាគត(ពោលគឺ សន្មតប្រាក់ខែបច្ចុប្បន្ននៅបន្តរហូតដល់និយោជិកបច្ចុប្បន្នត្រូវបានរំពឹងថានឹងចាប់ផ្តើមទទួលអត្ថប្រយោជន៍ក្រោយបំពេញការងារ)

(ខ)មិនអើពើនឹងសេវាអនាគតរបស់និយោជិកបច្ចុប្បន្ន(សន្មតបិទចោលផែនការសម្រាប់និយោជិកមានស្រាប់ក៏ដូចជានិយោជិកថ្មីៗ) និង

(គ) មិនអើពើនឹងចំនួនមរណភាពក្នុងផ្នែកសេវាដែលអាចកើតមានឡើងនៃនិយោជិករវាងថ្ងៃរាយការណ៍ និងថ្ងៃដែលនិយោជិកត្រូវបានរំពឹងថានឹងចាប់ផ្តើមទទួលបានអត្ថប្រយោជន៍ក្រោយបំពេញការងារ(ពោលគឺសន្មតនិយោជិកបច្ចុប្បន្នទាំងអស់នឹងទទួលបានអត្ថប្រយោជន៍ក្រោយបំពេញការងារ)។ ប៉ុន្តែ ចំនួនមរណភាពបន្ទាប់ពីសេវាកម្ម(ពោលគឺ អាយុកាលមធ្យម) នឹងនៅចាំបាច់ដើម្បីពិចារណា។

អង្គភាពដែលទទួលផលប្រយោជន៍ពីការធ្វើឱ្យសាមញ្ញនូវការវាស់វែងខាងមុខ ទោះបីជាយ៉ាងក៏ដោយត្រូវរួមបញ្ចូលទាំងអត្ថប្រយោជន៍ផ្ទេរ និង អត្ថប្រយោជន៍មិនផ្ទេរក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់។

២៨.២១ស្តង់ដារនេះមិនតម្រូវឱ្យអង្គភាពធ្វើឱ្យជាការពិតដែលមានលក្ខណៈឯករាជ្យដើម្បីអនុវត្តការវាយតម្លៃពិតរួមមួយដែលចាំបាច់ដើម្បីគណនាកាតព្វកិច្ចអត្ថប្រយោជន៍កំណត់។ថែមទាំងមិនតម្រូវថា ការវាយតម្លៃជាក់ស្តែងរួមត្រូវធ្វើជារៀងរាល់ឆ្នាំ។ក្នុងគ្រាចន្លោះការវាយតម្លៃជាក់ស្តែង ប្រសិនបើការសន្ម ត់ជាក់ស្តែងស្នូលមិនបានផ្លាស់ប្តូរខ្លាំងទេ កាតព្វកិច្ចអត្ថប្រយោជន៍កំណត់អាចត្រូវបានវាស់វែងដោយ ការកែសម្រួលពីការវាស់វែងគ្រាមុនសម្រាប់ការផ្លាស់ប្តូរក្នុងប្រជាសាស្ត្រនិយោជិកដូចជា ចំនួននិយោជិក និង កម្រិតប្រាក់ខែ។

### ការដាក់ឲ្យប្រើផែនការ ការផ្លាស់ប្តូរ និង ការកាត់បន្ថយ និង ការទូទាត់

២៨.២១ ប្រសិនបើផែនការអត្ថប្រយោជន៍កំណត់ត្រូវដាក់ឲ្យប្រប្រាស់ ផ្លាស់ប្តូរក្នុងគ្រាបច្ចុប្បន្ន អង្គភាពត្រូវបង្កើន ឬបន្ថយបំណុលអត្ថប្រយោជន៍កំណត់របស់ខ្លួនដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ និងត្រូវទទួលស្គាល់ការកើនឡើង(ការថយចុះ)ជាចំណាយ(ចំណូល)ក្នុងការវាស់វែងប្រាក់ចំណេញឬខាតក្នុងគ្រាបច្ចុប្បន្ន។ផ្ទុយមកវិញ ប្រសិនបើ

ផែនការត្រូវបានកាត់បន្ថយ (ពោលគឺ អត្ថប្រយោជន៍ ឬ ក្រុមនៃនិយោជិកដែលបានគ្របដណ្តប់ត្រូវបាន កាត់បន្ថយ) ឬ ទូទាត់សង (កាតព្វកិច្ចរបស់និយោជកត្រូវបានទាត់ចោលទាំងស្រុង) ក្នុងគ្រាបច្ចុប្បន្ន កាតព្វកិច្ច អត្ថប្រយោជន៍កំណត់ត្រូវបានបន្ថយឬលុបចោល និង អង្គភាពត្រូវទទួលស្គាល់ជាលទ្ធផលចំណេញ ឬខាតក្នុង ប្រាក់ចំណេញឬខាតក្នុងគ្រាបច្ចុប្បន្ន។

ទ្រព្យសកម្មផែនការអត្ថប្រយោជន៍កំណត់

២៨.២២ប្រសិនបើតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចនៅថ្ងៃរាយការណ៍តូចជាងតម្លៃសមស្របនៃទ្រព្យសកម្ម ផែនការនៅថ្ងៃ នោះ ផែនការមានអតិរេក។ អង្គភាពត្រូវទទួលស្គាល់អតិរេកផែនការជាទ្រព្យសកម្មផែន ការអត្ថប្រយោជន៍ កំណត់តែប៉ុណ្ណោះរហូតដល់អង្គភាពអាចទទួលបានមកវិញនូវអតិរេកតាមរយៈវិភាគទានដែលថយចុះក្នុង ពេលអនាគត ឬតាមរយៈការបង្វិលសងមកវិញពីផែនការ។

ថ្លៃនៃផែនការអត្ថប្រយោជន៍កំណត់

២៨.២៣អង្គភាពត្រូវទទួលស្គាល់ការផ្លាស់ប្តូរសុទ្ធនៅក្នុងបំណុលអត្ថប្រយោជន៍កំណត់របស់ខ្លួនក្នុងគ្រា ជាជាងការផ្លាស់ ប្តូរដែលបែងចែកចំពោះអត្ថប្រយោជន៍ដែនបានបង់ទៅឲ្យនិយោជិកក្នុងគ្រា ឬ វិភាគទានពីនិយោជក ជាថ្លៃនៃ ផែនការអត្ថប្រយោជន៍កំណត់ក្នុងគ្រា។ ថ្លៃនោះត្រូវបានទទួលស្គាល់ ទាំងស្រុងនៅក្នុងរបាយការណ៍ចំណេញ ឬខាត ជាចំណាយ ឬ មួយផ្នែកនៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត និង មួយផ្នែកជាធាតុមួយនៃចំណូល សរុបផ្សេងទៀត( សូមមើលកថាខណ្ឌ ២៨.២៤) លុះត្រាតែផ្នែកផ្សេងទៀតនៃស្តង់ដារនេះតម្រូវឲ្យថ្លៃត្រូវបាន ទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមទ្រព្យ សកម្មដូចជាសន្និធិ ឬ ទ្រព្យ រោងចក្រ និង បរិក្ខារ។

ការទទួលស្គាល់ - ការជ្រើសរើសគោលនយោបាយគណនេយ្យ

២៨.២៤ អង្គភាពត្រូវបានតម្រូវឲ្យទទួលស្គាល់ចំណេញ និងខាតជាក់ស្តែងនៅក្នុងគ្រាដែលពួកវាបានកើតឡើង។ អង្គភាពត្រូវៈ

(ក) ទទួលស្គាល់ចំណេញ និងខាតជាក់ស្តែងក្នុងរបាយការណ៍ចំណេញ ឬខាត ឬ

(ខ)ទទួលស្គាល់ចំណេញនិងខាតជាក់ស្តែងទាំងអស់នៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត ជាការជ្រើស រើសគោលនយោបាយគណនេយ្យ។អង្គភាពត្រូវអនុវត្តគោលនយោបាយដែលបានជ្រើសរើសឲ្យមានសង្គតិភាព ចំពោះគ្រប់ផែនការអត្ថប្រយោជន៍អត្ថប្រយោជន៍កំណត់ និង ចំណេញនិងខាតជាក់ស្តែងទាំងអស់។ ចំណេញ និងខាតជាក់ស្តែងដែលបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀតត្រូវបានបង្ហាញនៅក្នុង របាយការណ៍លទ្ធផលសរុប។

២៨.២៥ការផ្លាស់ប្តូរសុទ្ធនៅក្នុងបំណុលអត្ថប្រយោជន៍កំណត់ដែលត្រូវបានទទួលស្គាល់ជាថ្លៃនៃផែន ការអត្ថប្រយោជន៍ កំណត់ រួមបញ្ចូលៈ

(ក) ការផ្លាស់ប្តូរក្នុងបំណុលអត្ថប្រយោជន៍កំណត់ដែលកើតចេញពីសេវានិយោជិកដែលបាន ផ្តល់ក្នុងគ្រារាយការណ៍។

(ខ) ការប្រាក់លើកាតព្វកិច្ចអត្ថប្រយោជន៍ក្នុងគ្រារាយការណ៍

(គ) ចំណូលពីទ្រព្យសកម្មផែនការណាមួយ និងការប្រែប្រួលសុទ្ធក្នុងតម្លៃសមស្របនៃសិទ្ធិទទួលសំណងដែលបានទទួលស្គាល់ (សូមមើលកថាខណ្ឌ ២៨.២៨) ក្នុងគ្រារាយការណ៍។

(ឃ) ចំណេញ និងខាតជាក់ស្តែងកើតឡើងក្នុងគ្រារាយការណ៍។

(ង) ការកើនឡើង ឬថយចុះក្នុងបំណុលអត្ថប្រយោជន៍កំណត់កើតចេញពីការដាក់ឲ្យប្រើប្រាស់ផែនការថ្មី ឬ ការផ្លាស់ប្តូរផែនការមានស្រាប់ក្នុងគ្រារាយការណ៍ (សូមមើលកថាខណ្ឌ ២៨.២១) ។

(ច) ការថយចុះក្នុងបំណុលអត្ថប្រយោជន៍កំណត់កើតចេញពីការកាត់បន្ថយឬការទូទាត់សង ផែនការមានស្រាប់ក្នុងគ្រា (សូមមើលកថាខណ្ឌ ២៨.២១) ។

២៨.២៦ សេវារបស់និយោជិកផ្តល់ការកើនឡើងចំពោះកាតព្វកិច្ចក្រោមផែនការអត្ថប្រយោជន៍កំណត់ ទោះបីជាអត្ថប្រយោជន៍មានលក្ខខណ្ឌចំពោះការងារពេលអនាគត(ម្យ៉ាងវិញទៀតអត្ថប្រយោជន៍នោះមិនត្រូវបានផ្ទេរ)។ សេវានិយោជិកមុនថ្ងៃផ្ទេរផ្តល់ការកើនឡើងចំពោះកាតព្វកិច្ចសាងសង់ពីព្រោះនៅ ថ្ងៃរាយការណ៍ថ្មីនីមួយៗ ចំនួនទឹកប្រាក់នៃសេវាអនាគតដែលនិយោជិកនឹងផ្តល់មុនពេលមានសិទ្ធិ ទទួលចំពោះអត្ថប្រយោជន៍ត្រូវបានកាត់បន្ថយ។ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ អង្គភាពពិចារណាពីភវនីយភាពដែលនិយោជិកមួយចំនួនអាចមិនពេញចិត្តនឹងការតម្រូវផ្ទេរ។ស្រដៀងគ្នានេះដែរទោះបីជាអត្ថប្រយោជន៍ក្រោយបំពេញការងារខ្លះ (ដូចជាអត្ថប្រយោជន៍ថែទាំសុខភាពក្រោយបំពេញការងារ) បានដល់ពេលសងតែប៉ុណ្ណោះ ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់កើតឡើងពេល និយោជិកមិនត្រូវបានជួលតទៅទៀត (ដូចជាការឈឺ) កាតព្វកិច្ចត្រូវបានបង្កើតឡើងពេលនិយោជិកផ្តល់សេវាកម្មដែលនឹងផ្តល់សិទ្ធិក្នុងការទទួលបានផលប្រយោជន៍ ប្រសិនបើព្រឹត្តិការណ៍ជាក់លាក់កើតឡើង។ភវនីយភាពដែលព្រឹត្តិការណ៍ជាក់លាក់នឹងកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការវាស់វែងនៃកាតព្វកិច្ច ប៉ុន្តែមិនកំណត់ថាតើកាតព្វកិច្ចកើតឡើងនោះទេ។

២៨.២៧ប្រសិនអត្ថប្រយោជន៍កំណត់ត្រូវបានកាត់បន្ថយនូវចំនួនទឹកប្រាក់ដែលត្រូវបានបង់ទៅឲ្យនិយោជិកក្រោម ផែនការឧបត្ថម្ភរបស់រដ្ឋាភិបាល អង្គភាពត្រូវវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ លើមូលដ្ឋានដែលឆ្លុះបញ្ចាំងពីអត្ថប្រយោជន៍ត្រូវសងក្រោមផែនការរបស់រដ្ឋាភិបាល ប៉ុន្តែក្នុងករណីដែលៈ

(ក) ផែនការទាំងនោះត្រូវបានអនុម័តមុនថ្ងៃរាយការណ៍ ឬ

(ខ)ប្រវត្តិអតីតកាល ឬ ភស្តុតាងដែលអាចជឿជាក់បានផ្សេងទៀត បានបង្ហាញថាអត្ថប្រយោជន៍របស់រដ្ឋទាំងនោះនឹងប្រែប្រួលក្នុងតរិយាបទដែលអាចដឹងបានមួយចំនួន ឧទាហរណ៍ ដោយអនុលោមតាមការប្រែប្រួលអនាគតក្នុងកម្រិតតម្លៃទូទៅ ឬ កម្រិតប្រាក់ខែ។

### សំណង

២៨.២៨ប្រសិនបើអង្គភាពមួយស្ទើរតែច្បាស់ថាអង្គភាពមួយទៀតនឹងសងនូវចំណាយមួយចំនួន ឬទាំងអស់ដែលបានតម្រូវឱ្យសងនូវកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ អង្គភាពត្រូវទទួលស្គាល់សិទ្ធិរបស់ខ្លួនចំពោះសំណងជាទ្រព្យសកម្មដោយឡែក។ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មតាមតម្លៃសមស្រប។ ក្នុងរបាយការណ៍លទ្ធផលសរុប (ឬក្នុងរបាយការណ៍លទ្ធផល ប្រសិនបើបានបង្ហាញ) ចំណាយទាក់ទិនងនឹងផែនការអត្ថប្រយោជន៍កំណត់អាចត្រូវបានបង្ហាញជាតម្លៃសុទ្ធនៃចំនួនទឹកប្រាក់ដែលបាន ទទួលស្គាល់សម្រាប់សំណង។

### អត្ថប្រយោជន៍និយោជិករយៈពេលវែងផ្សេងទៀត

២៨.២៩ អត្ថប្រយោជន៍និយោជិករយៈពេលវែងផ្សេងទៀតរួមបញ្ចូល ឧទាហរណ៍ៈ

(ក)អវត្តមានទទួលបានការតបស្នងរយៈពេលវែង ដូចជា ការឈប់សំរាកពេលបំពេញសេវា យូរ ឬ ការឈប់សំរាកថ្ងៃបុណ្យ

(ខ) អត្ថប្រយោជន៍សេវាកម្មរយៈពេលយូរ

(គ) អត្ថប្រយោជន៍បាត់បង់សមត្ថភាពធ្វើការរយៈពេលយូរ

(ឃ)ការចែកប្រាក់ចំណេញ និង ប្រាក់បន្ថែមដែលត្រូវសងក្នុងរយៈពេល១២ខែ ឬច្រើនជាងបន្ទាប់ពីចុងគ្រាដែលនិយោជិកផ្តល់សេវាកម្មទាក់ទិន។

(ង)តម្លៃតបស្នងពន្យាដែលបានបង់រយៈពេល១២ខែ ឬច្រើនជាងបន្ទាប់ពីចុងគ្រាដែលតម្លៃតបស្នង នោះត្រូវគេរកបាន។

២៨.៣០ អង្គភាពត្រូវទទួលស្គាល់បំណុលសម្រាប់អត្ថប្រយោជន៍និយោជិករយៈពេលវែងផ្សេងទៀត តាមតម្លៃសុទ្ធសរុបនៃចំនួនទឹកប្រាក់ខាងក្រោមៈ

(ក) តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចនៅចុងថ្ងៃរាយការណ៍ ដក

(ខ)តម្លៃសបស្របនៅថ្ងៃរាយការណ៍នៃទ្រព្យសកម្មផែនការ(ប្រសិនបើមាន)ក្រៅពីកាតព្វកិច្ចនឹងត្រូវបានទូទាត់សងដោយផ្ទាល់ អង្គភាពត្រូវទទួលស្គាល់ការផ្លាស់ប្តូរក្នុងបំណុលដោយអនុលោមតាមកថាខណ្ឌ ២៨.២៣។

## អត្ថប្រយោជន៍ពេលបញ្ឈប់ការងារ

២៨.៣១ តាមច្បាប់ អង្គភាពមួយអាចមានការតាំងចិត្តដោយកិច្ចព្រមព្រៀងឬកិច្ចសន្យាផ្សេងទៀតជាមួយនិយោជិក ឬ តំណាងរបស់គេ ឬ ដោយកាតព្វកិច្ចសាងសង់ផ្អែកលើអនុវត្តប្រពៃណីឬការចង់បានក្នុងអាជីវកម្ម ដើម្បីធ្វើសកម្មភាពប្រកបដោយសមធម៌ ដើម្បីធ្វើការទូទាត់(ឬផ្តល់អត្ថ ប្រយោជន៍ផ្សេងទៀត)ទៅឲ្យនិយោជិក ពេលអង្គភាពបញ្ឈប់ការងាររបស់គេ។ ការទូទាត់បែបនេះគឺជា អត្ថប្រយោជន៍ពេលបញ្ឈប់ការងារ។

## ការទទួលស្គាល់

២៦.៣២ដោយសារតែអត្ថប្រយោជន៍មិនផ្តល់ឲ្យអង្គភាពនូវអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគត អង្គភាពត្រូវទទួលស្គាល់ អត្ថប្រយោជន៍នោះជាចំណាយក្នុងរបាយការណ៍ចំណេញ ឬ ខាតភ្លាម។

២៨.៣៣ ពេលដែលអង្គភាពទទួលស្គាល់អត្ថប្រយោជន៍ពេលបញ្ឈប់ការងារ អង្គភាពអាចទទួលស្គាល់ផងដែរនូវ ការកាត់បន្ថយនៃអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ឬ អត្ថប្រយោជន៍និយោជិកផ្សេងទៀត។

២៨.៣៤ អង្គភាពត្រូវទទួលស្គាល់អត្ថប្រយោជន៍ពេលបញ្ឈប់ការងារជាបំណុលនិងជាចំណាយតែប៉ុណ្ណោះ ពេលដែល អង្គភាពបានបង្ហាញការប្តេជ្ញាៈ

(ក) ដើម្បីកំណត់ការងាររបស់និយោជិក ឬ ក្រុមនិយោជិកមុនពេលថ្ងៃចូលនិវត្តន៍ធម្មតា ឬ

(ខ)ដើម្បីផ្តល់អត្ថប្រយោជន៍ពេលបញ្ឈប់ការងារជាលទ្ធផលនៃការផ្តល់ឲ្យដែលបានធ្វើឡើងដើម្បីលើកទឹកចិត្ត ឲ្យមានភាពទំនេរដោយស្មគ្រ័ចិត្ត។

២៨.៣៥ អង្គភាពបានបង្ហាញការតាំងចិត្តចំពោះការបញ្ឈប់តែនៅពេលដែលអង្គភាពមានផែនការផ្លូវការលំអិតសម្រាប់ ការបញ្ឈប់ និងពុំមានភាវនីយភាពជាក់លាក់នៃការដកចេញពីផែនការ។

## ការវាស់វែង

២៨.៣៦អង្គភាពត្រូវវាស់វែងអត្ថប្រយោជន៍ពេលបញ្ឈប់ការងារតាមការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតនៃការចំណាយដែល បានតម្រូវឲ្យទូទាត់សងកាតព្វកិច្ចនៅថ្ងៃរបាយការណ៍។ក្នុងករណីនៃការផ្តល់ដែលបាន ធ្វើដើម្បីលើកទឹកចិត្តឲ្យ មានភាពទំនេរដោយស្មគ្រ័ចិត្ត ការវាស់វែងនៃអត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារត្រូវផ្អែកលើចំនួននិយោជិក ដែលរំពឹងថានឹងទទួលយកការផ្តល់ឲ្យ។

២៨.៣៧ នៅពេលអត្ថប្រយោជន៍ពេលបញ្ឈប់ការងារហួសរយៈពេល១២ខែបន្ទាប់ពីចុងគ្រារាយការណ៍ អត្ថប្រយោជន៍ ត្រូវវាស់វែងតាមតម្លៃបច្ចុប្បន្នដែលបានធ្វើអប្បហាររួច។

## ផែនការក្រុម

២៨.៣៨ ប្រសិនបើក្រុមហ៊ុនមេ ផ្តល់អត្ថប្រយោជន៍ទៅឲ្យនិយោជិកនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយឬច្រើន ក្នុងក្រុម ហើយក្រុមហ៊ុនមេបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមដោយប្រើស្តង់ដាររាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមឬស្តង់ដាររាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពេញលេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានអនុញ្ញាតឲ្យទទួលស្គាល់និងវាស់វែងចំណាយអត្ថប្រយោជន៍និយោជិកលើមូលដ្ឋាននៃការបែងចែកសមស្របនៃចំណាយដែលបានទទួលស្គាល់សម្រាប់ក្រុម។

## ការលាតត្រដាងព័ត៌មាន

### ការបង្ហាញពីអត្ថប្រយោជន៍និយោជិករយៈពេលខ្លី

២៨.៣៩ ផ្នែកនេះមិនតម្រូវឲ្យមានការលាតត្រដាងព័ត៌មានជាក់លាក់អំពីអត្ថប្រយោជន៍និយោជិក។

### ការលាតត្រដាងព័ត៌មានអំពីផែនការវិភាគទានកំណត់

២៨.៤០អង្គភាពមួយត្រូវបង្ហាញចំនួនទឹកប្រាក់ដែលមានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតជាចំណាយសម្រាប់ផែនការវិភាគទានកំណត់។ ប្រសិនបើអង្គភាពទទួលស្គាល់ផែនការអត្ថប្រយោជន៍កំណត់ពហុនិយោជកជាផែនការវិភាគទានកំណត់ពីព្រោះព័ត៌មានគ្រប់គ្រាន់មិនមានដើម្បីប្រើប្រាស់គណនេយ្យសម្រាប់អត្ថប្រយោជន៍កំណត់ (សូមមើលកថាខណ្ឌ ២៨.១១) អង្គភាពត្រូវបង្ហាញនូវហេតុការដែលវាជាផែនការអត្ថប្រយោជន៍កំណត់និង ហេតុផលដែលវាត្រូវបានទទួលស្គាល់ជាផែនការវិភាគទានកំណត់ ជាមួយនឹងព័ត៌មានដែលមានអំពីអតិរេកផែនការ ឱនភាព និង ព័ត៌មានជាប់ទាក់ទិនផ្សេងទៀត ប្រសិនបើមាន សម្រាប់អង្គភាព។

### ការលាតត្រដាងព័ត៌មានអំពីផែនការអត្ថប្រយោជន៍កំណត់

២៨.៤១អង្គភាពត្រូវបង្ហាញនូវព័ត៌មានខាងក្រោមអំពីផែនការអត្ថប្រយោជន៍កំណត់ (លើកលែងផែន ការអត្ថប្រយោជន៍ពហុនិយោជកកំណត់ដែលត្រូវបានទទួលស្គាល់ជាផែនការវិភាគទានកំណត់ដោយអនុលោមតាមកថាខណ្ឌ ២៨.១១ដែលការលាតត្រដាងបង្ហាញក្នុងកថាខណ្ឌ២៨.៤០អនុវត្តជំនួស)។ ប្រសិនបើអង្គភាពមានផែនការអត្ថប្រយោជន៍កំណត់លើសពី១ នោះការលាតត្រដាងបង្ហាញព័ត៌មានអាចត្រូវធ្វើជាសរុប បំបែកជាគំរោងនីមួយៗ ឬការបញ្ចូលបែបនេះត្រូវបានគិតថានឹងមានប្រយោជន៍ច្រើនបំផុត:

(ក) ការពិពណ៌នាទូទៅពីប្រភេទនៃផែនការ រួមបញ្ចូលគោលនយោបាយផ្តល់លុយ

(ខ)គោលនយោយបាយគណនេយ្យសម្រាប់ការទទួលស្គាល់ចំណេញនិងខាតជាក់ស្តែង(ក្នុងរបាយការណ៍ចំណេញឬខាត ឬ ក្នុងជាធាតុមួយនៃរបាយការណ៍លទ្ធផលសរុបផ្សេងទៀតក៏បាន) និងចំនួនទឹកប្រាក់នៃការចំណេញឬខាតជាក់ស្តែងដែលបានទទួលស្គាល់ក្នុងកំឡុងគ្រា។

(គ) ការពន្យល់ពីប្រតិបត្តិការប្រសិនបើអង្គភាពប្រើប្រាស់នូវវិធីសាស្ត្រសាមញ្ញណាមួយក្នុង កថាខណ្ឌ២៨.១៩ ក្នុងការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់។

(ឃ)ថ្ងៃនៃការវាយតម្លៃជាក់ស្តែងសរុបថ្មីៗបំផុត និង ប្រសិនបើវាមិននៅថ្ងៃរាយការណ៍ទេ ការរៀបរាប់នៃការកែសម្រួលដែលបានធ្វើឡើងដើម្បីវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ នៅថ្ងៃរាយការណ៍។

(ង)ការផ្ទៀងផ្ទាត់នៃសមតុល្យដើមគ្រានិងចុងគ្រានៃកាតព្វកិច្ចអត្ថប្រយោជន៍កំណត់ដោយបង្ហាញអត្ថប្រយោជន៍ដាច់ដោយឡែកដែលបានបង់ និង ការផ្លាស់ប្តូរទាំងអស់ផ្សេងទៀត។

(ច)ការផ្ទៀងផ្ទាត់នៃសមតុល្យដើមគ្រានិងចុងគ្រានៃតម្លៃសមស្របនៃទ្រព្យសកម្មផែនការនិងសមតុល្យចុងដើមគ្រានិងចុងគ្រានៃសិទ្ធិទទួលសំណងណាមួយដែលបានទទួកស្គាល់ជាទ្រព្យសកម្ម ដោយបង្ហាញដោយឡែកប្រសិនបើអាចអនុវត្តបានៈ

(១) វិភា គទាន

(២) អត្ថប្រយោជន៍បានបង់ និង

(៣) ការប្រែប្រួលផ្សេងៗ ក្នុងទ្រព្យសកម្មផែនការ

(ឆ) ថ្លៃដើមសរុបដែលទាក់ទងនឹងផែនការអត្ថប្រយោជន៍សម្រាប់គ្រា ត្រូវបង្ហាញដោយឡែក នូវចំនួនទឹកប្រាក់

(១) ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ប្រាក់ចំណេញ ឬ ខាតជាចំណាយ និង

(២) រួមបញ្ចូលក្នុងថ្លៃដើមទ្រព្យកម្ម

(ជ)សម្រាប់ថ្នាក់ទ្រព្យសកម្មផែនកការសំខាន់នីមួយៗដែលត្រូវបញ្ចូលប៉ុន្តែត្រូវបានមិនកម្រិតឧបករណ៍ដើមទុនឧបករណ៍បំណុល ទ្រព្យ និង ទ្រព្យសកម្មផ្សេងទៀតទាំងអស់ ភាគរយ ឬ ចំនួនទឹកប្រាក់ដែលចំណាត់ថ្នាក់សំខាន់នីមួយៗបង្កើតឲ្យមានតម្លៃសមស្របនៃទ្រព្យសកម្ម ផែនការសរុបនៅថ្ងៃរាយការណ៍។

(ឈ) ចំនួនទឹកប្រាក់ដែលរួមបញ្ចូលក្នុងតម្លៃសមស្របនៃទ្រព្យសកម្មផែនការសំរាប់ៈ

(១)ថ្នាក់នីមួយៗនៃឧបករណ៍ហិរញ្ញវត្ថុផ្ទាល់របស់អង្គភាពនិង

(២)ទ្រព្យសកម្មនីមួយៗដែលបានកាន់កាប់ដោយឬទ្រព្យសកម្មផ្សេងទៀតដែលត្រូវបានប្រើដោយអង្គភាព។

(ញ) ចំណូលជាក់ស្តែងលើទ្រព្យសកម្មផែនការ

(ដ) ការសន្មតជាក់ស្តែងស្នូលដែលបានប្រើ រួមបញ្ចូល ពេលអាចអនុវត្តបានៈ

(១) អត្រាអប្បហារ

(២)អត្រាចំណូលរំពឹងទុកលើទ្រព្យសកម្មផែនការណាមួយសម្រាប់គ្រាដែលបានបង្ហាញ នៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ

(៣) អត្រារំពឹងទុកនៃកំណើនប្រាក់ខែ

(៤) អត្រាគន្លងចំណាយថែទាំសុខភាព និង

(៥) ការសន្មតជាក់ស្តែងធំៗផ្សេងទៀតដែលបានប្រើ។

ការផ្ទៀងផ្ទាត់នៅក្នុង (ង) និង (ច) ខាងលើមិនចាំបាច់ត្រូវបង្ហាញសម្រាប់គ្រាមុនៗទេ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលទទួលស្គាល់និងវាស់វែងចំណាយអត្ថប្រយោជន៍និយោជិកលើមូលដ្ឋាននៃការបែងចែកសមស្របនៃចំណាយដែកបានទទួលស្គាល់សម្រាប់ក្រុម (សូមមើលកថាខណ្ឌ ២៨.៣៨)ក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ត្រូវរៀបរាប់ពីគោលនយោបាយសម្រាប់ការធ្វើការបែងចែក និងត្រូវបង្ហាញនៅក្នុង (ក) ដល់ (ជ)ខាងលើ សម្រាប់ផែនការទាំងមូល។

**ការលាតត្រដាងព័ត៌មានអំពីអត្ថប្រយោជន៍រយៈពេលវែង**

២៨.៤២សម្រាប់ខ្ទង់នៃអត្ថប្រយោជន៍រយៈពេលវែងដែលអង្គភាពផ្តល់ទៅឲ្យនិយោជិក អង្គភាពត្រូវបង្ហាញប្រភេទនៃអត្ថប្រយោជន៍ ចំនួនទឹកប្រាក់នៃកាតព្វកិច្ច និង ទំហំដែលថវិកាតនៅថ្ងៃរាយការណ៍។

**ការលាតត្រដាងព័ត៌មានអំពីអត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារ**

២៨.៤៣សម្រាប់ខ្ទង់នីមួយៗនៃអត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារដែលអង្គភាពផ្តល់ទៅឲ្យនិយោជិក អង្គភាពត្រូវបង្ហាញពីប្រភេទនៃអត្ថប្រយោជន៍ គោលនយោបាយគណនេយ្យនិងចំនួនទឹកប្រាក់នៃកាតព្វកិច្ចនិង ទំហំនៃថវិកានៅថ្ងៃរាយការណ៍។

២៨.៤៤នៅពេលដែលមានភាពមិនច្បាស់លាស់អំពីចំនួននិយោជិកដែលនឹងទទួលយកនូវការផ្តល់អត្ថប្រយោជន៍ពេលបញ្ឈប់ពីការងារ បំណុលយថាហេតុកើតមានឡើង។ ផ្នែកទី២១ *សំវិធានធន និង យថាហេតុ* តម្រូវឲ្យអង្គភាពត្រូវបង្ហាញពីព័ត៌មានអំពីបំណុលយថាហេតុលុះត្រាតែវនីយភាពលំហូរចេញក្នុងការទូទាត់សង នៅឆ្ងាយ។

# ផ្នែកទី២៩

# ពន្ធលើប្រាក់ចំណេញ

## វិសាលភាពនៃផ្នែកនេះ

២៩.១សម្រាប់គោលបំណងនៃស្តង់ដារនេះ**ពន្ធលើប្រាក់ចំណេញ**រួមបញ្ចូលទាំងពន្ធក្នុងប្រទេសនិងក្រៅ ប្រទេសដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។ ពន្ធលើប្រាក់ចំណូលរួមបញ្ចូលផងដែរនូវពន្ធទាំងឡាយ ដូចជាពន្ធកាត់ទុកដែលដល់ពេលសងដោយក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនរួមទុននៅពេលបែងចែក ទៅឱ្យអង្គភាពរាយការណ៍។

២៩.២ផ្នែកនេះគ្របដណ្តប់លើគណនេយ្យកម្មពន្ធលើប្រាក់ចំណូល។អង្គភាពតម្រូវឱ្យអង្គភាពត្រូវទទួលស្គាល់លទ្ធផលពន្ធបច្ចុប្បន្ននិងអនាគតនៃប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតដែលត្រូវបានទទួល ស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ទាំងអស់នេះដែលត្រូវបានទទួលស្គាល់ជាប្រាក់ពន្ធរួមមាន**ពន្ធបច្ចុប្បន្ន**និង **ពន្ធពន្យា**។ ពន្ធបច្ចុប្បន្នគឺជាប្រាក់ពន្ធដែលត្រូវបង់(ដែលទទួលបានមកវិញ) ទាក់ទិន នឹងប្រាក់ចំណេញជាប់ពន្ធ(ខាតប្រាក់ពន្ធ) សម្រាប់គ្រាបច្ចុប្បន្ន ឬ គ្រាមុន។ ពន្ធពន្យាគឺជាពន្ធដែលត្រូវសង ឬ ទទួលបានមកវិញក្នុងគ្រាខាងមុខ ជាទូទៅកើតចេញពីអង្គភាពដែលទទួលបានមកវិញ ឬ ទូទាត់**ទ្រព្យសកម្ម**និង **បំណុល** សម្រាប់តម្លៃក្នុងបញ្ជីឆ្នាំបច្ចុប្បន្នរបស់គេ ហើយឥទ្ធិពលពន្ធពេលខាងមុខខាតប្រាក់ពន្ធដែលមិនបានប្រើបច្ចុប្បន្ន និង ឥណទានពន្ធ។

## ដំណាក់កាលក្នុងការធ្វើគណនេយ្យកម្មសម្រាប់ពន្ធលើប្រាក់ចំណូល

២៩.៣ អង្គភាពត្រូវធ្វើគណនេយ្យកម្មពន្ធលើប្រាក់ចំណូលតាមដំណាក់កាលពី(ក) ដល់(ឈ) ខាងក្រោមៈ

(ក)ទទួលស្គាល់ពន្ធឆ្នាំបច្ចុប្បន្នដែលបានវាស់វែងតាមតម្លៃដែលរួមបញ្ចូលឥទ្ធិពលនៃលទ្ធផលនៃការពិនិត្យឡើងវិញដោយអាជ្ញាធរពន្ធដារ(កថាខណ្ឌ ២៩.៤- ២៩.៨)

(ខ)កំណត់ពីទ្រព្យសកម្មនិងបំណុលដែលត្រូវបានរំពឹងថានឹងប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធ ប្រសិនបើទ្រព្យសកម្មត្រូវទទួលបានមកវិញ ឬ បំណុលត្រូវបានទូទាត់សម្រាប់តម្លៃក្នុងបញ្ជីបច្ចុប្បន្ន (សូមមើលកថាខណ្ឌ ២៩.៩ និង ២៩.១០)។

(គ) នៅចុងគ្រារាយការណ៍ ត្រូវកំណត់**មូលដ្ឋានពន្ធ**នៃធាតុខាងក្រោមៈ

(១)ទ្រព្យសកម្មនិងបំណុលក្នុង(ខ)។មូលដ្ឋានពន្ធនៃទ្រព្យសកម្មនិងបំណុលត្រូវបានកំណត់ដោយលទ្ធផលនៃការលក់ទ្រព្យសកម្ម ឬ ការទូទាត់សងបំណុលសម្រាប់តម្លៃក្នុងបញ្ជីបច្ចុប្ប ន្ន(កថាខណ្ឌ ២៩.១១ និង ២៩.១២)។

(២) ធាតុផ្សេងទៀតដែលមានមូលដ្ឋានពន្ធទោះបីធាតុទាំងនោះមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម

ឬបំណុល ពោលគឺធាតុដែលបានទទួលស្គាល់ជាចំណូល ឬ ចំណាយដែលនឹង ត្រូវបង់ពន្ធ ឬ អាចកាត់ចេញពីពន្ធក្នុងគ្រាខាងមុខ (សូមមើលកថាខណ្ឌ ២៩.១៣)។

(ឃ) គណនានូវភាពខុសគ្នាបណ្តោះអាសន្ន ការខាតបង់ប្រាក់ពន្ធមិនបានប្រើ និង ឥណទាន ពន្ធមិនបានប្រើ (កថាខណ្ឌ២៩.១៤)។

(ង) ទទួលស្គាល់ **ទ្រព្យសកម្មពន្ធពន្យា** និង **បំណុលពន្ធពន្យា** ដែលកើតពីភាពខុសគ្នាបណ្តោះ អាសន្ន ការខាតប្រាក់ពន្ធមិនបានប្រើប្រាស់ និង ឥណទានពន្ធមិនបានប្រើ (សូមមើលកថាខណ្ឌ២៩.១៥២៩.១៧)។

(ច)វាស់វែងទ្រព្យសកម្ម និងបំណុលពន្ធពន្យា តាមចំនួនទឹកប្រាក់ដែលរួមបញ្ចូលនូវឥទ្ធិពលនៃលទ្ធផលនៃការពិនិត្យមើលឡើងវិញដោយអាជ្ញាធរពន្ធដារដោយប្រើអត្រាពន្ធ ដែលត្រូវបានរំពឹងថានឹងអនុវត្តនៅពេលដែលទ្រព្យសកម្មពន្ធពន្យាត្រូវបានទទួលស្គាល់ ឬ បំណុលពន្ធពន្យាត្រូវបានទូទាត់សង (សូមមើលកថាខណ្ឌ ២៩.១៨- ២៩.២៥)។

(ឆ)ទទួលស្គាល់ឲ្យមានការវាយតម្លៃទល់នឹងទ្រព្យសកម្មពន្ធពន្យាដូច្នេះចំនួនទឹកប្រាក់សុទ្ធ ស្មើនឹងចំនួនទឹកប្រាក់ខ្ពស់បំផុតដែលទំនងជាមិនត្រូវបានគេទទួលស្គាល់ដោយឈរលើមូលដ្ឋាននៃប្រាក់ចំណេញជាប់ពន្ធបច្ចុប្បន្ន ឬអនាគត (កថាខណ្ឌ ២៩.២១ និង ២៩.២២)។

(ជ) បែងចែកពន្ធពន្យានិងបច្ចុប្បន្នទៅសមាសធាតុដែលទាក់ទិននៃរបាយការណ៍ **ប្រាក់ចំណេញឬខាត, របាយការណ៍លទ្ធផលសរុបផ្សេងទៀត**និង ដើមទុន (សូមមើលកថាខណ្ឌ ២៩.២៧)។

(ឈ) ដាក់បង្ហាញ និង លាតត្រដាងបង្ហាញពីព័ត៌មានដែលបានតម្រូវ (កថាខណ្ឌ ២៩.២៨ - ២៩.៣២)

## ការទទួលស្គាល់និងការវាស់វែងពន្ធបច្ចុប្បន្ន

២៩.៤ អង្គភាពមួយត្រូវទទួលស្គាល់បំណុលពន្ធពន្យាបច្ចុប្បន្នសម្រាប់ពន្ធដែលត្រូវសងលើប្រាក់ចំណេញជាប់ពន្ធក្នុងគ្រាមុននិងគ្រាបច្ចុប្បន្ន។ប្រសិនបើចំនួនទឹកប្រាក់បានបង់សម្រាប់គ្រាមុននឹងគ្រាបច្ចុប្បន្នលើសពីចំនួនទឹកប្រាក់ដែលត្រូវបង់សម្រាប់គ្រាទាំងនោះ អង្គភាពត្រូវទទួលស្គាល់ផ្នែកដែល លើសនោះជាទ្រព្យសកម្មពន្ធបច្ចុប្បន្ន។

២៩.៥ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មពន្ធបច្ចុប្បន្នសម្រាប់អត្ថប្រយោជន៍នៃប្រាក់ខាតពន្ធដែលអាចយកត្រឡប់មកវិញដើម្បីកាត់កងប្រាក់ពន្ធដែលបានបង់នៅក្នុងគ្រាមុន។

២៩.៦ អង្គភាពត្រូវវាស់វែងបំណុលពន្ធបច្ចុប្បន្ន(ទ្រព្យសកម្ម)តាមចំនួនទឹកប្រាក់ដែលរំពឹងថានឹងបង់(ទទួលបានមកវិញ)ដោយប្រើអត្រាពន្ធនិងច្បាប់ដែលបានអនុម័តឬបានអនុម័តជាក់ស្តែងនៅថ្ងៃរាយការណ៍។ អង្គភាពត្រូវប្រើអត្រាពន្ធដែលបានអនុម័តជាក់ស្តែងពេលដែលព្រឹត្តិការណ៍អនាគតដែលបានតម្រូវដោយដំណើរការ

អនុម័តពីមុនមិនបានប៉ះពាល់ដល់លទ្ធផល ហើយមិនទំនងនឹងត្រូវប្រើ។ កថាខណ្ឌ២៩.២៣ - ២៩.២៥ ផ្ដល់ការណែនាំពីការវាស់វែងបន្ថែម។

២៩.៧ អង្គភាពត្រូវទទួលស្គាល់ការផ្លាស់ប្ដូរក្នុងបំណុលពន្ធពន្យាបច្ចុប្បន្ន ឬ ទ្រព្យសកម្មពន្ធបច្ចុប្បន្ន ជា **ចំណាយពន្ធ** នៅក្នុងរបាយការណ៍ចំណេញឬខាត លើកលែងតែការផ្លាស់ប្ដូរដែលបានបែងចែកទៅធាតុមួយនៃចំណូល ឬ ចំណាយដែលបានទទួលស្គាល់ក្រោមស្តង់ដារនេះជាចំណូលផ្សេងទៀតត្រូវបានទទួលស្គាល់ផងដែរក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត។

២៩.៨ អង្គភាពត្រូវរួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ ២៩.៤ និង ២៩.៥ ផលប៉ះពាល់នៃលទ្ធផលដែលអាចកើតមានពីការពិនិត្យមើលឡើងវិញដោយអាជ្ញាធរពន្ធដារ ត្រូវបានវាស់វែងដោយអនុលោមតាមកថាខណ្ឌ ២៩.២៤។

## ការទទួលស្គាល់ពន្ធពន្យា

### គោលការណ៍ទទួលស្គាល់ជាទូទៅ

២៩.៩ អង្គភាពមួយត្រូវទទួលស្គាល់ទ្រព្យសកម្មឬបំណុលពន្ធពន្យាសម្រាប់ពន្ធដែលអាចទទួលបានមកវិញ ឬ ដែលត្រូវសងក្នុងគ្រាអនាគតកើតចេញពីប្រតិបត្តិការឬព្រឹត្តិការអតីតកាល។ពន្ធបែបនេះកើតពី ភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ចំពោះទ្រព្យសកម្មនិងបំណុលរបស់អង្គភាពក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងការទទួលស្គាល់ទ្រព្យសកម្មនិងបំណុលទាំងនោះដោយអាជ្ញាធរពន្ធដារ និងការយោងបន្តទៅមុខនៃប្រាក់ខាតពន្ធដែលមិនបានប្រើ និងឥណទានពន្ធ។

### ទ្រព្យសកម្មនិងបំណុលដែលការទទួលបានមកវិញឬការទូទាត់នឹងមិនប៉ះពាល់ដល់ប្រាក់ចំណេញជាប់ ពន្ធ

២៩.១០ ប្រសិនបើអង្គភាពរំពឹងថានឹងទទួលបានមកវិញនូវតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្ម ឬ ទូទាត់តម្លៃក្នុងបញ្ជីនៃបំណុលដោយគ្មានប៉ះពាល់ប្រាក់ចំណេញជាប់ពន្ធ ពុំមានពន្ធពន្យាកើតឡើងទាក់ទងនឹង ទ្រព្យសកម្ម ឬ បំណុល។ ដូច្នេះកថាខណ្ឌ១៩.១១-២៩.១៧ អនុវត្តតែចំពោះទ្រព្យសកម្មនិងបំណុលសម្រាប់ដែលអង្គភាពនោះរំពឹងថាការទទួលបានមកវិញ ឬ ការទូទាត់នៃតម្លៃក្នុងបញ្ជីនឹងប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធ និងប៉ះពាល់ធាតុផ្សេងទៀតដែលមានមូលដ្ឋានពន្ធ។

### មូលដ្ឋានពន្ធ

២៩.១១អង្គភាពត្រូវកំណត់ពីមូលដ្ឋានពន្ធនៃទ្រព្យសកម្ម បំណុល ឬ ធាតុផ្សេងទៀតដោយអនុលោម តាមច្បាប់ដែលបានអនុម័តឬអនុម័តជាក់ស្ដែង។ប្រសិនអង្គភាពរៀបចំលិខិតប្រកាសពន្ធរួម មូលដ្ឋានពន្ធត្រូវបានកំណត់ដោយច្បាប់ពន្ធដែលគ្រប់គ្រងលិខិតប្រកាសពន្ធរួម។ប្រសិនបើអង្គភាពរៀបចំលិខិតប្រកាសពន្ធដាច់ដោយឡែក

សម្រាប់ប្រតិបត្តិការខុសគ្នា មូលដ្ឋានពន្ធត្រូវបានកំណត់ដោយច្បាប់ពន្ធដែលគ្រប់គ្រងលិខិតប្រកាសពន្ធនីមួយៗ។

២៩.១២ មូលដ្ឋានពន្ធកំណត់ពីចំនួនទឹកប្រាក់ដែលត្រូវបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធលើការទទួលបានមកវិញ ឬការទូទាត់សងនៃតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មឬបំណុល។ ជាពិសេសៈ

(ក) មូលដ្ឋានពន្ធនៃទ្រព្យសកម្មស្មើនឹងចំនួនទឹកប្រាក់ដែលអាចកាត់បន្ថយត្រឹមប្រាក់ចំណេញជាប់ពន្ធប្រសិនបើតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មត្រូវបានទទួលមកវិញតាមរយៈការលក់នៅចុងគ្រា។ ប្រសិនបើការទទួលបានមកវិញនៃទ្រព្យសកម្មតាមរយៈការលក់មិនបង្កើនប្រាក់ចំណេញជាប់ពន្ធ មូលដ្ឋានពន្ធត្រូវបានចាត់ទុកថាស្មើនឹងតម្លៃក្នុងបញ្ជី។

(ខ) មូលដ្ឋានពន្ធនៃបំណុលស្មើនឹងតម្លៃក្នុងបញ្ជីដកនូវចំនួនទឹកប្រាក់ដែលអាចកាត់បន្ថយបាន ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ(ឬបូកនឹងចំនួនទឹកប្រាក់ដែលបានបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធ) ដែលបានកើតឡើងប្រសិនបើបំណុលត្រូវបានទូទាត់សម្រាប់តម្លៃក្នុងបញ្ជីនៅចុងគ្រារាយការណ៍។ ក្នុងករណីនៃចំណូលពន្យា មូលដ្ឋានពន្ធបំណុលគឺជាតម្លៃក្នុងបញ្ជី ដកចេញចំនួនទឹកប្រាក់ ដែលចំណូលមិនជាប់ពន្ធក្នុងគ្រាអនាគត។

២៩.១៣ ធាតុមួយចំនួនមានមូលដ្ឋានពន្ធប៉ុន្តែមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មនិងបំណុល។ឧទាហរណ៍ ចំណាយស្រាវជ្រាវត្រូវបានទទួលស្គាល់ជាចំណាយពេលដែលវាបានកើតឡើងប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យកាតបន្ថយណាមួយក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធរហូតដល់គ្រាអនាគត។ដូច្នេះ តម្លៃក្នុងបញ្ជីនៃចំណាយស្រាវជ្រាវគឺគ្មាននិងមូលដ្ឋានពន្ធគឺជាចំនួនទឹកប្រាក់ដែលនឹងត្រូវកាត់ចេញក្នុងគ្រាអនាគត។ប្រសិនបើមិនមានទ្រព្យសកម្មឬបំណុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុប៉ុន្តែមូលដ្ឋានពន្ធគឺជាចំនួនទឹកប្រាក់នៃការកាត់បន្ថយនាពេលអនាគត។

ភាពខុសគ្នាបណ្តោះអាសន្ន

២៩.១៤ ភាពខុសគ្នាបណ្តោះអសន្នកើតឡើងៈ

(ក) ពេលមានភាពខុសគ្នារវាងតម្លៃក្នុងបញ្ជីនិងមូលដ្ឋានពន្ធលើការទទួលស្គាល់ទ្រព្យសកម្ម បំណុលលើកដំបូង ឬនៅពេលមូលដ្ឋានពន្ធត្រូវបានបង្កើតឡើងសម្រាប់ធាតុទាំងនោះដែលមានមូលដ្ឋានប៉ុន្តែមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មនិងបំណុល។

(ខ) ពេលភាពខុសគ្នារវាងតម្លៃក្នុងបញ្ជីនិងមូលដ្ឋានពន្ធកើតឡើងបន្ទាប់ពីការទទួលស្គាល់លើកដំបូងពីព្រោះចំណូលឬចំណាយត្រូវបានទទួលស្គាល់ក្នុងចំណូលផ្សេងៗឬដើមទុនក្នុងគ្រារាយការណ៍មួយប៉ុន្តែត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញជាប់ពន្ធក្នុងគ្រាផ្សេង។

(គ) ពេលមូលដ្ឋាននៃទ្រព្យសកម្មឬបំណុលផ្លាស់ប្តូរនិងការបផ្លាស់ប្តូរមិនត្រូវបានទទួលស្គាល់ក្នុងតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្ម ឬ បំណុលក្នុងគ្រាណាមួយឡើយ។

**បំណុលពន្ធ និងទ្រព្យសកម្មពន្យា**

២៩.១៥ លើកលែងលក្ខខណ្ឌដែលបានតម្រូវដោយកថាខណ្ឌ២៩.១៦ អង្គភាពត្រូវទទួលស្គាល់:

(ក) បំណុលពន្ធពន្យាសម្រាប់ភាពខុសគ្នាបណ្តោះអសន្នទាំងអស់ដែលត្រូវបានរំពឹងទុកថានឹង បង្កើនប្រាក់ចំណេញជាប់ពន្ធក្នុងពេលអនាគត។

(ខ) ទ្រព្យសកម្មពន្ធពន្យាសម្រាប់ភាពខុសគ្នាបណ្តោះអសន្នដែលត្រូវបានរំពឹងថានឹងបន្ថយប្រាក់ចំណាយជាប់ពន្ធក្នុងពេលអនាគាត។

(គ) ទ្រព្យសកម្មពន្ធពន្យាសម្រាប់ការយោងបន្តនៃការខាតប្រាក់ពន្ធមិនបានប្រើ និង ឥណទាន ពន្ធដែលមិនបានប្រើ។

២៩.១៦ ខាងក្រោមគឺជាការលើកលែងចំពោះការតម្រូវនៃកថាខណ្ឌ២៩.១៥÷

(ក) អង្គភាពមិនត្រូវទទួលស្គាល់ទ្រព្យសកម្មឬបំណុលពន្ធពន្យាសម្រាប់ភាពខុសគ្នាបណ្តោះ អាសន្នដែលជាប់ទាក់ទងនឹងប្រាក់ចំណេញដែលមិនបានផ្ញើមកពីក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ក្រុមហ៊ុនរួមទុនរហូតដល់ការវិនិយោគមានភាពអចិន្រ្តៃយ៍ក្នុងកំឡុងពេលមួយ លុះត្រាតែវាបង្ហាញថា ភាពខុសគ្នាបណ្តោះអសន្ននឹងប្រែត្រឡប់មកវិញក្នុងអនាគតដែលអាចដឹងបាន

(ខ) អង្គភាពមួយមិនត្រូវទទួលស្គាល់បំណុលពន្ធពន្យាសម្រាប់ភាពខុសគ្នាបណ្តោះអសន្នដែលជាប់ទាក់ទងជាមួយនឹងការទទួលស្គាល់កេរ្តិ៍ឈ្មោះលើកដំបូង។

២៩.១៧អង្គភាពមួយត្រូវទទួលស្គាល់ការផ្លាស់ប្តូរក្នុងបំណុលពន្ធពន្យា ឬ ទ្រព្យសកម្មពន្ធពន្យាជាចំណាយពន្ធក្នុងរបាយការណ៍ចំណេញឬខាត លើកលែងតែការផ្លាស់ប្តូរដែលបែងចែកទៅថាតុមួយនៃ ចំណូល ឬ ចំណាយដែលបានទទួលស្គាល់ក្រោមស្តង់ដារនេះជាចំណូលផ្សេងទៀតត្រូវបានទទួល ស្គាល់ផងដែរក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត។

## ការវាស់វែងពន្ធពន្យា

---

**អត្រាពន្ធ**

២៩.១៨ អង្គភាពមួយត្រូវវាស់វែងបំណុលពន្ធពន្យា (ទ្រព្យសកម្ម) ដោយប្រើអត្រាពន្ធ និងច្បាប់ដែលត្រូវបានអនុម័ត ឬអនុម័តជាក់ស្តែងនៅត្រឹមថ្ងៃរាយការណ៍។អង្គភាពត្រូវប្រើអត្រាពន្ធដែលបានអនុម័តជាក់ស្តែងនៅពេល

ព្រឹត្តិការណ៍អនាគតដែលបានតម្រូវដោយដំណើរការអនុម័តជាប្រវត្តិសាស្ត្រមិនបានប៉ះពាល់ដល់លទ្ធផល ហើយមិនទំនងជានឹងអាចកើតមាន។

២៩.១៩ពេលអត្រាពន្ធអនុវត្តចំពោះប្រាក់ចំណេញជាប់ពន្ធដែលមានកំរិតខុសគ្នាអង្គភាពត្រូវវាស់វែងចំណាយពន្ធពន្យា (ចំណូល)និងបំណុលពន្ធពន្យាទាក់ទិន(ទ្រព្យសកម្ម)ដោយប្រើអត្រាពន្ធមធ្យមដែលបានអនុម័ត ឬអនុម័តជាក់ស្តែងដែលអង្គភាពរំពឹងអាចអនុវត្តបានចំពោះប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) នៃគ្រាដែលអង្គភាពរំពឹងថាទ្រព្យសកម្មពន្យានឹងត្រូវទទួលស្គាល់ ឬ បំណុលពន្ធពន្យា នឹងត្រូវបានទូទាត់សង។

២៩.២០ ការវាស់វែងនៃបំណុលពន្ធពន្យា និងទ្រព្យសកម្មពន្ធពន្យាត្រូវឆ្លុះបញ្ចាំងពីលទ្ធផលពន្ធដែល គួរតាមដានពីឥរិយាបទដែលអង្គភាពរំពឹងទុកនៅថ្ងៃរាយការណ៍ ដើម្បីទទួលបានមកវិញឬទូទាត់នូវ តម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនិងបំណុលទាក់ទិន។ឧទាហរណ៍ ប្រសិនបើភាពខុសគ្នាបណ្តោះអសន្ន កើតចេញពីធាតុមួយនៃចំណូលដែលត្រូវបានរំពឹងថានឹងជាប់ពន្ធជាចំណេញមូលធនក្នុងគ្រាអនាគត ចំណាយពន្ធពន្យាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធចំណេញមូលធន។

### វិភាជន៍ពីការវាយតម្លៃ

២៩.២១អង្គភាពមួយត្រូវទទួលស្គាល់វិភាជន៍ពីការវាយតម្លៃទល់នឹងទ្រព្យសកម្មពន្ធពន្យាដូច្នេះតម្លៃក្នុងបញ្ជីសុទ្ធស្មើនឹងចំនួនទឹកប្រាក់ដែលមានទំនងច្រើនជាងការមិនទទួលបានមកវិញ ដោយផ្អែកលើប្រាក់ចំណេញជាប់ពន្ធបច្ចុប្បន្ន ឬ អនាគត។

២៩.២២អង្គភាពត្រូវពិនិត្យមើលឡើងវិញពីតម្លៃក្នុងបញ្ជីសុទ្ធនៃទ្រព្យសកម្មពន្ធពន្យានៅថ្ងៃរាយការណ៍នីមួយៗ និងត្រូវកែសម្រួលប្រាក់វាយតម្លៃដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃបច្ចុប្បន្ននៃប្រាក់ចំណេញជាប់ពន្ធអនាគត។ ការកែសម្រួលបែបនេះត្រូវបានទទួលស្គាល់ដោយអនុលោមតាមស្តង់ដារនេះជាចំណូលផ្សេងទៀតត្រូវបានទទួលស្គាល់ផងដែរនៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត។

### ការវាស់វែងនៃពន្ធពន្យា និង ពន្ធបច្ចុប្បន្ន

២៩.២៣ អង្គភាពមិនត្រូវធ្វើអប្បហារទ្រព្យសកម្ម និងបំណុលពន្ធពន្យា ឬពន្ធបច្ចុប្បន្នទេ។

២៩.២៤ភាពមិនប្រាកដប្រជាថាតើអាជ្ញាធរពន្ធនឹងទទួលយកចំនួនទឹកប្រាក់ដែលបានរាយការណ៍ឲ្យពួកគេដោយអង្គភាពប៉ះពាល់ដល់ចំនួនទឹកប្រាក់នៃពន្ធពន្យា និងពន្ធបច្ចុប្បន្ន។ អង្គភាពត្រូវវាស់វែង ទ្រព្យសកម្មពន្ធពន្យា និងពន្ធបច្ចុប្បន្ន និង បំណុលដោយប្រើចំនួនទឹកប្រាក់មធ្យមភវនីយភាពនៃលទ្ធ ផលដែលអាចកើតមានទាំងអស់ ដោយសន្មតថា អាជ្ញាធរពន្ធនឹងពិនិត្យមើលឡើងវិញនូវចំនួនទឹកប្រាក់ដែលបានរាយការណ៍ និងមានចំណេះដឹងពេញលេញនៃព័ត៌មានទាក់ទិនទាំងអស់។ការផ្លាស់ប្តូរក្នុងចំនួនទឹកប្រាក់មធ្យមភវនីយភាព

នៃលទ្ធផលដែលអាចកើតមានទាំងអស់ត្រូវផ្អែកលើព័ត៌មានថ្មី មិនមែនការបកស្រាយដោយអង្គភាពនៃព័ត៌មានដែលមានពីមុនរបស់អង្គភាពនោះទេ។

២៩.២៥នៅក្នុងប្រទេសខ្លះ ពន្ធលើប្រាក់ចំណូលត្រូវបង់តាមអត្រាខ្ពស់ឬទាប ប្រសិនបើមួយផ្នែកឬប្រាក់ចំណេញទាំងអស់ ឬ ប្រាក់ចំណេញរក្សាទុកត្រូវបានបង់ជាភាគលាភទៅឲ្យម្ចាស់ភាគហ៊ុនរបស់អង្គភាព។ ក្នុងប្រទេសខ្លះទៀត ពន្ធលើប្រាក់ចំណូលអាចបង្វិលសងវិញ ឬ អាចសងប្រសិនបើមួយ ផ្នែក ឬ ប្រាក់ចំណេញទាំងអស់ឬប្រាក់ចំណេញរក្សាទុកត្រូវបានបង់ជាភាគលាភទៅឲ្យម្ចាស់ភាគហ៊ុនរបស់អង្គភាព។នៅក្នុងកាលៈទេសៈទាំងនេះអង្គភាពមួយត្រូវវាស់វែងពន្ធពន្យានិងពន្ធបច្ចុប្បន្នតាមអត្រាពន្ធដែលអនុវត្តចំពោះប្រាក់ចំណេញដែលមិនទាន់បែងចែករហូតដល់អង្គភាពទទួលស្គាល់បំណុលត្រូវបង់ភាគលាភ។ពេលដែលអង្គជាពទទួលស្គាល់បំណុលដែលត្រូវបង់ភាគលាភ អង្គភាពត្រូវទទួលស្គាល់បំណុលពន្ធពន្យាឬពន្ធបច្ចុប្បន្ន (ទ្រព្យសកម្ម) និង ចំណាយពន្ធទាក់ទិន (ចំណូល)។

## ពន្ធកាត់ទុកលើភាគលាភ

២៩.២៦ពេលដែលអង្គភាពមួយបង់ភាគលាភទៅឲ្យម្ចាស់ភាគហ៊ុន អង្គភាពអាចត្រូវបានតម្រូវឲ្យបង់មួយចំណែកនៃភាគលាភទៅឲ្យអាជ្ញាធរពន្ធដារជំនួសឲ្យម្ចាស់ភាគហ៊ុន។ចំនួនទឹកប្រាក់ដែលបានបង់ឬនឹងត្រូវបង់ទៅឲ្យអាជ្ញាធរពន្ធដារគឺត្រូវបានគិតចូលទៅក្នុងដើមទុនជាផ្នែកមួយនៃភាគលាភ។

## ការបង្ហាញ

### ការបែងចែកនៅក្នុងលទ្ធផលសរុបនិងដើមទុន

២៩.២៧អង្គភាពត្រូវទទួលស្គាល់ចំណាយពន្ធក្នុងសមាសធាតុដូចគ្នានៃរបាយការណ៍លទ្ធផលសរុបពោលគឺប្រតិបត្តិការបន្ត **ប្រតិបត្តិការមិនបន្ត**លទ្ធផលសរុបផ្សេងទៀត) ឬ ដើមទុន ជាប្រតិបត្តិការ ឬព្រឹត្តិការផ្សេងទៀតដែលបានលទ្ធផលជាចំណាយពន្ធ។

### ភាពខុសគ្នារយៈពេលវែង/រយៈពេលខ្លី

២៩.២៨ ពេលដែលអង្គភាពបង្ហាញទ្រព្យសកម្មរយៈពេលវែងនិងរយៈពេលខ្លី និងបណុលរយៈពេល វែងនិងរយៈខ្លីជាការចាត់ថ្នាក់ដាច់ដោយឡែកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ  អង្គភាពមិនត្រូវចាត់ថ្នាក់ទ្រព្យសកម្មពន្ធពន្យាណាមួយ (បំណុល) ជាទ្រព្យសកម្មរយៈពេលខ្លី (បំណុល)។

### ការកាត់កង

២៩.២៩អង្គភាពមួយត្រូវកាត់កងទ្រព្យសកម្មពន្ធពន្យា និង បំណុលពន្ធពន្យារយៈពេលខ្លី ឬកាត់កងទ្រព្យសកម្មពន្ធពន្យានិងបំណុលពន្ធពន្យានៅពេលដែលអង្គភាពមានសិទ្ធិតាមផ្លូវច្បាប់ឲ្យកាត់កង នូវចំនួនទឹកប្រាក់ ហើយអង្គភាពមានបំណងទូទាត់ដោយឈរលើមូលដ្ឋានសុទ្ធ ឬ ទទួលស្គាល់ទ្រព្យ កម្ម និង ទូទាត់បំណុលព្រមជាមួយគ្នា។

២៩.៣០អង្គភាពមួយត្រូវបង្ហាញព័ត៌មានដែលផ្ដល់លទ្ធភាពឲ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃពីប្រភេទនិងផលប៉ះពាល់ហិរញ្ញវត្ថុនៃលទ្ធផលពន្ធពន្យានិងពន្ធបច្ចុប្បន្ននៃប្រតិបត្តិការនិងព្រឹត្តិការណ៍ដែលបានទទួលស្គាល់។

២៩.៣១អង្គភាពត្រូវបង្ហាញពីសមាសធាតុសំខាន់ៗនៃចំណាយពន្ធ(ចំណូល)ដោយឡែក។សមាសធាតុនៃចំណាយពន្ធ (ចំណូល)នេះ រួមបញ្ចូលៈ

(ក) ចំណាយពន្ធបច្ចុប្បន្ន (ចំណូល)

(ខ) ការកែសម្រួលណាមួយដែលបានទទួលស្គាល់ក្នុងគ្រាសម្រាប់ពន្ធបច្ចុប្បន្ននៃគ្រាមុន។

(គ)ចំនួនទឹកប្រាក់នៃចំណាយពន្ធពន្យា(ចំណូល)ដែលទាក់ទងនឹងបង្កើតនិងការប្រែត្រឡប់មកវិញនៃភាពខុសគ្នាបណ្ដោះអសន្ន។

(ឃ)ចំនួនទឹកប្រាក់នៃចំណាយពន្ធពន្យា(ចំណូល)ដែលទាក់ទងនឹងការផ្លាស់ប្ដូរក្នុងអត្រាពន្ធឬការកំណត់អត្រាពន្ធថ្មី។

(ង)ផលប៉ះពាល់លើចំណាយពន្ធពន្យាដែលកើតឡើងពីការផ្លាស់ប្ដូរក្នុងឥទ្ធិពលនៃលទ្ធផល នៃការពិនិត្យមើលឡើងវិញដោយអាជ្ញាធរពន្ធដារ (សូមមើលកថាខណ្ឌ ២៩.២៤)។

(ច) ការកែសម្រួលចំពោះចំណាយពន្ធពន្យាកើតពីការផ្លាស់ប្ដូរក្នុងស្ថានភាពពន្ធនៃអង្គភាព ឬ ម្ចាស់ភាគហ៊ុន។

(ឆ) ការផ្លាស់ប្ដូរណាមួយក្នុងចំនួនទឹកប្រាក់វាយតម្លៃ (សូមមើលកថាខណ្ឌ ២៩.២១ និង ២៩.២២)។

(ជ)ចំនួនទឹកប្រាក់នៃចំណាយពន្ធដែលទាក់ទងនឹងការផ្លាស់ប្ដូរក្នុងគោលនយោបាយគណនេយ្យនិង កំហុសឆ្គង (សូមមើលផ្នែកទី១០ *គោលនយោបាយគណនេយ្យ ការប៉ាន់ស្មាន និង កំហុសឆ្គង)*។

២៩.៣២ អង្គភាពមួយត្រូវបង្ហាញដាច់ដោយឡែកដូចខាងក្រោមៈ

(ក)ពន្ធពន្យានិងពន្ធបច្ចុប្បន្នសរុបដែលទាក់ទងនឹងធាតុដែលត្រូវបានទទួលស្គាល់ជាធាតុនៃចំណូលសរុបផ្សេងទៀត។

(ខ)ការពន្យល់នៃភាពខុសគ្នាសំខាន់ៗក្នុងចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ លទ្ធផលសរុប និងចំនួនទឹកប្រាក់ដែលបានរាយការណ៍ទៅឲ្យអាជ្ញាធរពន្ធដារ។

(គ) ការពន្យល់ពីការផ្លាស់ប្ដូរក្នុងអត្រាពន្ធដែលអាចប្រើបានប្រៀបធៀបជាមួយនឹងគ្រារាយ ការណ៍មុនៗ។

(ឃ) សម្រាប់ប្រភេទនៃភាពខុសគ្នានីមួយៗនិងសម្រាប់ប្រភេទនៃការខាតប្រាក់ពន្ធមិនបានប្រើនិង ឥណទានពន្ធ:

(១) ចំនួនទឹកប្រាក់នៃបំណុលពន្ធពន្យា ទ្រព្យសកម្មពន្ធពន្យា និង ចំនួនទឹកប្រាក់វាយ តម្លៃនៅចុងគ្រា រាយការណ៍ និង

(២) ការវិភាគនៃការផ្លាស់ប្តូរក្នុងបំណុលពន្ធពន្យា ទ្រព្យសកម្មពន្ធពន្យា និង ចំនួនទឹក ប្រាក់វាយតម្លៃ ក្នុងកំឡុងគ្រា។

(ង) ប្រសិនបើមាន ថ្ងៃផុតកំណត់នៃភាពខុសគ្នាបណ្តោះអសន្ន ការខាតប្រាក់ពន្ធមិនបានប្រើ និង ឥណទានពន្ធ មិនបានប្រើ។

(ច) ក្នុងហេតុការណ៍ទាំងឡាយដែលបានរៀបរាប់ក្នុងកថាខណ្ឌ ២៩.២៥ ការពន្យល់នៃប្រភេទ លទ្ធផលពន្ធលើ ប្រាក់ចំណូលដែលមានសក្តានុពលដែលនឹងកើតចេញពីការទូទាត់នៃភាគលាភទៅឲ្យ ម្ចាស់ភាគហ៊ុន។

# ផ្នែកទី៣០
# ការបកប្រែរូបិយប័ណ្ណបរទេស

## វិសាលភាពនៃផ្នែកនេះ

៣០.១ អង្គភាពមួយអាចអនុវត្តសកម្មភាពបរទេសតាមវិធីពីរយ៉ាង។ អង្គភាពអាចប្រតិបត្តិការជារូបិយ ប័ណ្ណបរទេស ឬ អង្គភាពអាចមានប្រតិបត្តិការក្រៅប្រទេស។លើសពីនេះទៅទៀត អង្គភាពអាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេស។ផ្នែកនេះបង្ហាញពីរបៀបត្រូវបញ្ចូលប្រតិបត្តិការរូបិយប័ណ្ណបរទេស និង ប្រតិបត្តិការក្រៅប្រទេសនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពនិងរបៀបត្រូវបកប្រែរបាយការណ៍ហិរញ្ញវត្ថុទៅជា**រូបិយប័ណ្ណសម្រាប់បង្ហាញ**។ ការធ្វើគណនេយ្យកម្មសម្រាប់ **ឧបករណ៍ហិរញ្ញវត្ថុ**ដែលបានកំណត់ជារូបិយប័ណ្ណបរទេស និង គណនេយ្យទប់ស្កាត់ហានិយភ័យនៃ ធាតុទាំងឡាយជារូបិយប័ណ្ណបរទេស ត្រូវបានដោះស្រាយដោយផ្នែកទី ១១ *ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញ* និង ផ្នែកទី១២ *បញ្ហាឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត*។

## រូបិយប័ណ្ណមុខងារ

៣០.២ អង្គភាពនីមួយៗត្រូវកំណត់**រូបិយប័ណ្ណមុខងារ**របស់ខ្លួន។រូបិយប័ណ្ណមុខងាររបស់អង្គភាពមួយ គឺជារូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចសំខាន់ដែលអង្គភាពនោះមានប្រតិបត្តិការ។

៣០.៣ បរិស្ថានសេដ្ឋកិច្ចសំខាន់ដែលអង្គភាពមានប្រតិបត្តិការគឺធម្មតាជាបរិស្ថានមួយដែលអង្គភាពបង្កើតសាច់ប្រាក់ និងចំណាយសាច់ប្រាក់ជាសំខាន់។ដូច្នេះខាងក្រោមគឺជាកត្តាសំខាន់បំផុតដែលអង្គភាពមួយពិចារណាក្នុងការកំណត់រូបិយប័ណ្ណមុខងាររបស់ខ្លួនៈ

(ក) រូបិយប័ណ្ណៈ

(១)ដែលមានឥទ្ធិពលសំខាន់លើតម្លៃលក់សម្រាប់ទំនិញ និងសេវាកម្ម (ជារឿយៗនេះនឹងជារូបិយប័ណ្ណដែលតម្លៃលក់សម្រាប់ទំនិញ និងសេវាកម្មត្រូវកំណត់និងទូទាត់) និង

(២)នៃប្រទេសដែលកំលាំងប្រកួតប្រជែងនិងបទដ្ឋានរបស់ប្រទេសនោះកំណត់ពីតម្លៃលក់នៃទំនិញ និង សេវាកម្ម ជាសំខាន់។

(ខ)រូបិយប័ណ្ណដែលមានឥទ្ធិពលសំខាន់លើចំណាយពលកម្ម វត្ថុធាតុដើម និង ចំណាយផ្សេងទៀតក្នុងការផ្តល់ទំនេញ ឬសេវា (ជារឿយៗ នេះជារូបិយប័ណ្ណដែលចំណាយបែបនេះគឺត្រូវ បានកំណត់ និងទូទាត់)។

៣០.៤ កត្តាខាងក្រោមអាចផ្តល់ផងដែរនូវភស្តុតាងនៃរូបិយប័ណ្ណមុខងាររបស់អង្គភាពៈ

(ក)រូបិយប័ណ្ណដែលមូលនិធិពីសកម្មភាពហិរញ្ញប្បទាន(បោះផ្សាយឧបករណ៍បំណុលនិងដើមទុន) ត្រូវបានបង្កើតឡើង។

(ខ) រូបិយប័ណ្ណដែលទទួលបានពីសកម្មប្រតិបត្តិការត្រូវបានរក្សាទុក។

៣០.៥ កត្តាបន្ថែមទៀតខាងក្រោមត្រូវបានពិចារណាក្នុងការកំណត់ពីរូបិយប័ណ្ណមុខងារនៃប្រតិបត្តិការក្រៅប្រទេស ហើយថារូបិយប័ណ្ណមុខងាររបស់អង្គភាពដូចគ្នានឹងរូបិយប័ណ្ណនៃអង្គភាពរាយការណ៍ (អង្គភាពរាយការណ៍នៅក្នុងបរិការណ៍នេះជាអង្គភាពដែលមានប្រតិបត្តិការក្រៅប្រទេសគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន) ÷

(ក)ថាតើសកម្មភាពនៃប្រតិបត្តិការក្រៅប្រទេសត្រូវបានអនុវត្តជាវិសាលភាពនៃអង្គភាពរាយការណ៍ជាជាងកំពុងអនុវត្តជាមួយកម្រិតនៃស្វ័យតភាព។ ឧទាហរណ៍សម្រាប់ករណីទី១ គឺពេលដែលប្រតិបត្តិការ ក្រៅប្រទេសលក់ទំនិញដែលបាននាំចូលពីអង្គភាពរាយការណ៍ និងផ្ទេរប្រាក់លក់បាននោះទៅឲ្យអង្គភាពរាយការណ៍។ ឧទាហរណ៍ករណីទី២ នៅពេលដែលប្រតិបត្តិការប្រមូលបន្តសាច់ប្រាក់ និង ធាតុហិរញ្ញវត្ថុផ្សេងទៀត កើតឡើងចំណាយ រកបានចំណូល និង ខ្ចីប្រាក់ ទាំងអស់នេះ ជារូបិយប័ណ្ណក្នុងប្រទេស។

(ខ)ថាតើប្រតិបត្តិការជាមួយអង្គភាពរាយការណ៍គឺជាចំណែកច្រើនឬទាបនៃសកម្មភាពប្រតិបត្តិការក្រៅប្រទេស។

(គ)ថាតើលំហូរសាច់ប្រាក់ពីសកម្មភាពនៃប្រតិបត្តិការក្រៅប្រទេសប៉ះពាល់ដោយផ្ទាល់លើ លំហូរសាច់ប្រាក់នៃអង្គភាពរាយការណ៍ និងបានត្រៀមរួចរាល់ដើម្បីផ្ទេរទៅឲ្យអង្គភាពរាយការណ៍។

(ឃ)ថាតើលំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការគឺគ្រប់គ្រាន់ចំពោះសេវាកម្មដែលមានស្រាប់ និងចំពោះកាតព្វកិច្ចបំណុលដែលបានរំពឹងទុកធម្មតាត្រូវបានបង្កើតឲ្យមានដោយអង្គភាពរាយការណ៍។

## ការរាយការណ៍ប្រតិបត្តិការរូបិយប័ណ្ណបរទេសជារូបិយប័ណ្ណមុខងារ

### ការទទួលស្គាល់ដំបូង

៣០.៦ ប្រតិបត្តិការរូបិយប័ណ្ណបរទេសគឺជាប្រតិបត្តិការដែលកំណត់ ឬ តម្រូវឲ្យមានការទូទាត់ជារូបិយ ប័ណ្ណបរទេស ដោយរួមមានប្រតិបត្តិការដែលកើតឡើងនៅពេលអង្គភាព:

(ក) ទិញ ឬលក់ទំនិញ ឬសេវាដែលតម្លៃរបស់វាត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស

(ខ) ខ្ចី ឬ ផ្តល់កំចី ពេលដែលចំនួនទឹកប្រាក់ដែលត្រូវសង ឬ ត្រូវទទួល ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស

(គ) ឬក៏ ទិញ ឬ លក់ចោលទ្រព្យសកម្ម ឬ កើតឡើង ឬ ទូទាត់បំណុល ត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស

៣០.៧ អង្គភាពមួយត្រូវកត់ត្រាប្រតិបត្តិការរូបិយប័ណ្ណបរទេស នៅពេលទទួលស្គាល់ដំបូងរូបិយប័ណ្ណបរទេស ដោយអនុវត្តចំពោះចំនួនទឹកប្រាក់រូបិយប័ណ្ណបរទេសតាមអត្រាប្តូរប្រាក់បច្ចុប្បន្នរវាងរូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបរទេសនៅថ្ងៃប្រតិបត្តិការ។

៣០.៨ ថ្ងៃប្រតិបត្តិការគឺជាថ្ងៃដែលប្រតិបត្តិការបំពេញការទទួលស្គាល់លើកដំបូងដោយអនុលោមតាមស្តង់ដារនេះ។ សម្រាប់ហេតុផលអនុវត្ត អត្រាដែលប្រហែលនឹងអត្រាជាក់ស្តែងនៅថ្ងៃប្រតិបត្តិការជារឿយៗត្រូវបានគេប្រើជាអត្រាមធ្យមសម្រាប់សប្តាហ៍ ឬ ខែ ដែលអាចត្រូវបានប្រើសម្រាប់ប្រតិបត្តិការទាំង អស់ក្នុងរូបិយប័ណ្ណបរទេសដែលកើតឡើងនៅក្នុងគ្រានោះ។ប៉ុន្តែប្រសិនបើអត្រាប្តូរប្រាក់ឡើងចុះខ្លាំង ការប្រើអត្រាមធ្យមសម្រាប់គ្រានោះមិនត្រឹមត្រូវទេ។

### ការរាយការណ៍នៅចុងគ្រារាយការណ៍បន្តបន្ទាប់

៣០.៩ នៅចុងគ្រារាយការណ៍នីមួយៗ អង្គភាពត្រូវៈ

(ក) បកប្រែធាតុរូបិយវត្ថុរូបិយប័ណ្ណបរទេសដោយប្រើអត្រាថ្ងៃបិទបញ្ជី

(ខ) បកប្រែធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមជារូបិយប័ណ្ណបរទេសដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ និង

(គ) បកប្រែធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្របជារូបិយប័ណ្ណបរទេសដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃដែលតម្លៃសមស្របត្រូវបានកំណត់។

៣០.១០ អង្គភាពត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញឬខាត ក្នុងគ្រាដែលវាកើតឡើងនូវភាពខុសគ្នាដែលកើតឡើងចំពោះការទូទាត់ធាតុរូបិយវត្ថុ ឬ ធាតុរូបិយវត្ថុបកប្រែតាមអាត្រាខុសគ្នាពី អត្រានៅថ្ងៃដែលធាតុទាំងនោះត្រូវបានបកប្រែនៅពេលទទួលស្គាល់លើកដំបូងក្នុងគ្រាឬក្នុងគ្រាមុនៗ លើកលែងតែបានរៀបរាប់ក្នុងកថាខណ្ឌ ៣០.១៣។

៣០.១១ នៅពេលផ្នែកផ្សេងមួយទៀតនៃស្តង់ដារនេះតម្រូវឱ្យចំណេញ ឬខាតលើធាតុមិនមែនរូបិយវត្ថុ ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត អង្គភាពត្រូវទទួលស្គាល់នូវសមាសធាតុនៃចំណេញឬខាតពីប្តូរណាមួយនៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត។ផ្ទុយទៅវិញនៅពេលដែលចំណេញ ឬខាតលើធាតុមិនមែនរូបិយវត្ថុត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត អង្គភាពត្រូវទទួលស្គាល់សមាសធាតុប្តូរណាមួយនៃចំណេញ ឬខាតក្នុង របាយការណ៍ចំណេញ ឬខាត។

## ការវិនិយោគសុទ្ធក្នុងប្រតិបត្តិការបរទេស

៣០.១២ អង្គភាពអាចមានធាតុរូបិយវត្ថុដែលត្រូវទទួលពីឬត្រូវសងទៅឲ្យប្រតិបត្តិការក្រៅប្រទេស។ ធាតុដែលការទូទាត់សងមិនត្រូវបានធ្វើផែនការឬមិនទំនងជាកើតឡើងក្នុងអនាគតដែលអាចប៉ាន់ស្មានបានគឺជាផ្នែកមួយនៃការវិនិយោគសុទ្ធរបស់អង្គភាពនៅក្នុងប្រតិបត្តិការនោះនិងត្រូវបានធ្វើ គណនេយ្យកម្មដោយអនុលោមតាមកថាខណ្ឌ៣០.១៣។ ធាតុរូបិយវត្ថុនេះអាចរួមបញ្ចូលគណនីត្រូវ ទទួល ឬ កំចីរយៈពេលវែង។ ពួកគេមិនរួមបញ្ចូលគណនីត្រូវទទួលពាណិជ្ជកម្ម ឬ គណនីត្រូវសងពាណិជ្ជកម្ម។

៣០.១៣ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលកើតឡើងចំពោះធាតុរូបិយវត្ថុដែលបង្កើតចំណែកនៃការវិនិយោគសុទ្ធរបស់អង្គភាពរាយការណ៍ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាត ក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកនៃអង្គភាពរាយការណ៍ ឬរបាយាការណ៍ហិរញ្ញវត្ថុនីមួយៗនៃប្រតិបត្តិការក្រៅប្រទេស បើសមស្រប។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលប្រតិបត្តិការក្រៅ ប្រទេស និង អង្គភាពរាយការណ៍ ( ឧទាហរណ៍ របាយការណ៍ហិរញ្ញវត្ថុរួមពេលដែលប្រតិបត្តិការ ក្រៅប្រទេសជាក្រុមហ៊ុនបុត្រសម្ព័ន្ធ) ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណបរទេសត្រូវបានទទួលស្គាល់ដំបូង នៅក្នុងរបាយការណ៍លទ្ធផលសរុបផ្សេងទៀត ហើយរាយការណ៍ជាធាតុមួយនៃដើមទុន។ជាថ្មីម្តងទៀត ពួកគេមិនត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតនៅពេលលក់ចោលនៃការ វិនិយោគសុទ្ធនោះទេ។

## ការប្តូររូបិយប័ណ្ណមុខងារ

៣០.១៤ពេលមានការប្តូររូបិយប័ណ្ណមុខងាររបស់អង្គភាព អង្គភាពត្រូវអនុវត្តនីតិវិធីបកប្រែដែលអាចប្រើបានចំពោះរូបិយប័ណ្ណមុខងារថ្មីចាប់ពីថ្ងៃប្តូរតទៅ។

៣០.១៥ ដូចបានបញ្ជាក់ក្នុងកថាខណ្ឌ ៣០.២- ៣០.៥ រូបិយប័ណ្ណមុខងាររបស់អង្គភាពមួយឆ្លុះបញ្ចាំងពីប្រតិបត្តិការព្រឹត្តិការណ៍និងលក្ខខណ្ឌកំពុងកើតឡើងដែលទាក់ទងនឹងអង្គភាព។ដូច្នេះ នៅពេលដែលរូបិយប័ណ្ណមុខងារត្រូវបានកំណត់ រូបិយប័ណ្ណមុខងារអាចត្រូវបានផ្លាស់ប្តូរតែនៅពេលមានការផ្លាស់ប្តូរចំពោះប្រតិបត្តិការព្រឹត្តិការណ៍និងលក្ខខណ្ឌកំពុងកើតឡើងទាំងនោះ។ ឧទាហរណ៍ ការផ្លាស់ប្តូររូបិយប័ណ្ណដែលមានឥទ្ធិពលលើតម្លៃលក់នៃទំនិញនិងសេវាអាចនាំដល់ការផ្លាស់ប្តូររូបិយប័ណ្ណមុខងាររបស់អង្គភាព។

៣០.១៦ ឥទ្ធិពលនៃការផ្លាស់ប្តូររូបិយប័ណ្ណមុខងារត្រូវបានគេធ្វើគណនេយ្យកម្មសម្រាប់ពេលអនាគត។ ម្យ៉ាងវិញទៀត អង្គភាពមួយត្រូវបកប្រែធាតុទាំងអស់ទៅរូបិយប័ណ្ណមុខងារថ្មីដោយប្រើអត្រានៅថ្ងៃប្តូរ។ ចំនួនទឹកប្រាក់ដែលបានបកប្រែរួចសម្រាប់ធាតុមិនមែនរូបិយវត្ថុត្រូវបានចាត់ទុកជាថ្លៃប្រវត្តិសាស្រ្ត។

ការបកប្រែទៅរូបិយប័ណ្ណសម្រាប់បង្ហាញ

៣០.១៧ អង្គភាពមួយអាចដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុជារូបិយប័ណ្ណណាមួយ (ឬរូបិយប័ណ្ណផ្សេងទៀត)។ រូបិយប័ណ្ណសម្រាប់បង្ហាញខុសពីរូបិយប័ណ្ណមុខងាររបស់អង្គភាព អង្គភាពត្រូវបកប្រែធាតុនៃចំណូលនិង ចំណាយ និង**ស្ថានភាពហិរញ្ញវត្ថុ**ទៅជារូបិយប័ណ្ណសម្រាប់បង្ហាញ។ ឧទាហរណ៍ នៅពេល **ក្រុម** រួមមានអង្គភាព នីមួយៗជាមួយនឹងរូបិយប័ណ្ណមុខងារផ្សេងគ្នា ធាតុនៃចំណូល និងចំណាយ និង ស្ថានភាពហិរញ្ញវត្ថុនៃ អង្គភាពនីមួយៗត្រូវបានបង្ហាញជារូបិយប័ណ្ណរួមមួយដូច្នេះរបាយការណ៍ហិរញ្ញវត្ថុរួមអាចត្រូវបានបង្ហាញ។

៣០.១៨អង្គភាពមួយដែលរូបិយប័ណ្ណមុខងារមិនមែនជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាលោតផ្លោះត្រូវបកប្រែ ស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍លទ្ធផលទៅជារូបិយប័ណ្ណសម្រាប់បង្ហាញខុសគ្នាដោយប្រើវិធីសាស្ត្រ ដូចខាងក្រោមៈ

(ក) ទ្រព្យសកម្ម និង បំណុលសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ (ពោលគឺ រួមបញ្ចូលតួលេខប្រៀបធៀប) ត្រូវបានបកប្រែតាមអត្រាចុងគ្រានៅថ្ងៃនៃរបាយការណ៍ស្ថាន ភាពហិរញ្ញវត្ថុ។

(ខ)ចំណូល និងចំណាយសម្រាប់របាយការណ៍លទ្ធផលសុបនីមួយៗ (ពោលគឺ រួមបញ្ចូលតួលេខប្រៀបធៀប) ត្រូវបានបកប្រែតាមអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ និង

(គ) ភាពខុសគ្នាពីការប្តូរប្រាក់ទាំងអស់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលផ្សេងទៀត។

៣០.១៩ សម្រាប់ហេតុផលអនុវត្ត អង្គភាពអាចប្រើអត្រាដែលប្រហែលនឹងអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការ ឧទាហរណ៍ អត្រាមធ្យមសម្រាប់គ្រា ដើម្បីបកប្រែធាតុចំណូល និងចំណាយ។ ប៉ុន្តែ ប្រសិនបើ អត្រាប្តូរប្រាក់ប្រែប្រួលខ្លាំង ការប្រើអត្រាមធ្យមសម្រាប់គ្រាមិនសមស្របទេ។

៣០.២០ ភាពខុសគ្នាពីការប្តូរប្រាក់ ត្រូវបានសំដៅទៅកថាខណ្ឌ ៣០.១៨ (គ) កើតចេញពីៈ

(ក)ការបកប្រែចំណូលនិងចំណាយតាមអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនិងទ្រព្យសកម្មនិង បំណុលតាមអត្រា ថ្ងៃបិទបញ្ជី និង

(ខ) ការបកប្រែនូវទ្រព្យសកម្មសុទ្ធដើមគ្រាតាមអត្រាថ្ងៃបិទបញ្ជីដែលខុសពីអត្រាបិទបញ្ជីមុនៗនៅពេលដែល ភាពខុសគ្នាពីការប្តូរប្រាក់ទាក់ទងទៅនឹងប្រតិបត្តិការក្រៅប្រទេសដែលត្រូវបានបញ្ចូលគ្នា ប៉ុន្តែ មិនកាន់កាប់ ទាំងស្រុង ភាពខុសគ្នាពីការប្តូរប្រាក់បូកបន្តដែលកើតពីការបកប្រែ និងដែលបែងចែកទៅ **ភាគកម្មអប្បភាគ** ត្រូវបានបែងចែក និង ទទួលស្គាល់ជាផ្នែកមួយនៃ ភាគកម្មអប្បភាគក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម។

៣០.២១ អង្គភាពមួយដែលរូបិយប័ណ្ណមុខងារគឺជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាលោតផ្លោះត្រូវបកប្រែរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍លទ្ធផលទៅរូបិយប័ណ្ណសម្រាប់បង្ហាញផ្សេងគ្នា ដោយប្រើនីតិវិធីដែលបញ្ជាក់នៅក្នុងផ្នែកទី៣១*អតិផរណាលោតផ្លោះ*។

## ការបកប្រែប្រតិបត្តិការក្រៅប្រទេសទៅរូបិយប័ណ្ណសម្រាប់បង្ហាញ

៣០.២២ ក្នុងការបញ្ចូលទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ នៃប្រតិបត្តិការក្រៅប្រទេសជាមួយ ទ្រព្យសកម្ម បំណុល ចំណូល និងចំណាយរបស់អង្គភាពរាយការណ៍ អង្គភាពត្រូវអនុវត្តតាមនីតិវិធីរួម បញ្ចូលគ្នាធម្មតា ដូចជាការលុបចោលនូវសមតុល្យក្នុងក្រោមប្រតិបត្តិការក្នុងក្រុមរបស់ក្រុមហ៊ុនបុត្រ សម្ព័ន្ធ ( សូមមើលផ្នែកទី៩ *របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកនិងរួម)*។ ប៉ុន្តែទ្រព្យសកម្ម (បំណុល) រូបិយវត្ថុក្នុងក្រុម មិនថាតើរយៈពេលខ្លីឬរយៈពេលវែង មិនអាចត្រូវបានលុបចោលទល់នឹង បំណុល (ឬទ្រព្យសកម្ម) ក្នុងក្រុមដែលស្របគ្នា ដោយគ្មានការបង្ហាញលទ្ធផលនៃការឡើងចុះនៃរូបិយ ប័ណ្ណក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទេ។ នេះដោយសារតែធាតុរូបិយវត្ថុតំណាងឱ្យការប្តេជ្ញាដើម្បីបំលែងរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀត និង បង្ហាញអង្គភាពរាយការណ៍ចំពោះចំណេញឬខាតតាមរយៈការឡើងចុះរូបិយប័ណ្ណ។ដូច្នេះ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម អង្គភាពរាយការណ៍បន្តទទួលស្គាល់ភាពខុសគ្នាពីការប្តូរប្រាក់នេះនៅក្នុងរបាយការណ៍ចំណេញឬខាតឬ ប្រសិនបើវាកើតឡើងពីហេតុការណ៍ដែលបានរៀបរាប់ក្នុងកថាខណ្ឌ៣០.១៣អង្គភាពត្រូវចាត់ថ្នាក់វាជាដើមទុន។

៣០.២៣ មូលនិធិពាណិជ្ជកម្មដែលកើតឡើងពីការទិញប្រតិបត្តិការក្រៅប្រទេស ហើយការកែសម្រួលតម្លៃសមស្របទៅជាតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មនិងបំណុលដែលកើតឡើងលើការទិញប្រតិបត្តិការបរទេសនោះ ត្រូវចាត់ទុកជាទ្រព្យសកម្មនិងបំណុលនៃប្រតិបត្តិក្រៅប្រទេស។ដូច្នេះ ទ្រព្យសកម្ម និង បំណុលទាំងនោះត្រូវបានបង្ហាញជារូបិយប័ណ្ណមុខងារនៃប្រតិបត្តិការក្រៅប្រទេស ហើយត្រូវបកប្រែតាមអត្រាថ្ងៃបិទបញ្ជី ដោយអនុលោមតាមកថាខណ្ឌ ៣០.១៨។

## ការលាតត្រដាងព័ត៌មាន

---

៣០.២៤ ក្នុងកថាខណ្ឌ ៣០.២៦ និង ៣០.២៧ យោងតាម"រូបិយប័ណ្ណមុខងារ" អនុវត្តចំពោះរូបិយប័ណ្ណ មុខងាររបស់ក្រុមហ៊ុនមេក្នុងករណីជាក្រុម។

៣០.២៥ អង្គភាពត្រូវបង្ហាញដូចខាងក្រោមៈ

(ក) ចំនួនទឹកប្រាក់នៃខុសគ្នាពីការប្តូរប្រាក់ ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតក្នុងគ្រាលើកលែងតែភាពខុសគ្នាដែលកើតពីឧបករណ៍ហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃសមស្របតាមរយៈរបាយការណ៍ចំណេញ ឬខាតដោយអនុលោមតាមផ្នែកទី១១ និង១២

(ខ) ចំនួនទឹកប្រាក់នៃភាពខុសគ្នាពីការប្តូរប្រាក់ដែលកើតឡើងក្នុងគ្រានិងត្រូវបានចាត់ថ្នាក់ជាធាតុដោយឡែកនៃដើមទុននៅចុងគ្រា។

៣០.២៦ អង្គភាពមួយត្រូវបង្ហាញពីរូបិយប័ណ្ណដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានដាក់បង្ហាញ។ ពេលរូបិយប័ណ្ណសម្រាប់បង្ហាញខុសពីរូបិយប័ណ្ណមុខងារ អង្គភាពត្រូវបង្ហាញពីហេតុការណ៍នោះ ហើយត្រូវបង្ហាញរូបិយប័ណ្ណមុខងារ និងហេតុផលសម្រាប់ការប្រើប្រាស់រូបិយប័ណ្ណសម្រាប់បង្ហាញផ្សេងទៀត។

៣០.២៧ នៅពេលមានការផ្លាស់ប្តូររូបិយប័ណ្ណមុខងារនៃអង្គភាពរាយការណ៍ ឬ ប្រតិបត្តិការក្រៅប្រទេសសំខាន់ អង្គភាពនោះត្រូវបង្ហាញពីហេតុការណ៍នោះ និងមូលហេតុសម្រាប់ការផ្លាស់ប្តូររូបិយប័ណ្ណមុខងារ។

# ផ្នែកទី៣៦

# អតិផរណាខ្ពស់

## វិសាលភាពនៃផ្នែកនេះ

៣៦.១ផ្នែកនេះអនុវត្តចំពោះអង្គភាពដែល**រូបិយបណ្ណ័មុខងារ**របស់គេគឺជារូបិយប័ណ្ណនៃសេដ្ឋកិច្ចអតិផរណាខ្ពស់។ អង្គភាពតម្រូវឱ្យអង្គភាពត្រូវរៀបចំ**របាយការណ៍ហិរញ្ញវត្ថុ**ដែលត្រូវបានកែសម្រួលសម្រាប់ផលប៉ះពាល់ពីអតិផរណាខ្ពស់។

## សេដ្ឋកិច្ចអតិផរណាលោតផ្លោះ

៣៦.២ផ្នែកនេះមិនបង្កើតឡើងនូវអត្រាដាច់ខាតដែលសេដ្ឋកិច្ចត្រូវបានចាត់ទុកថាមានអតិផរណាលោតផ្លោះ។ អង្គភាពត្រូវធ្វើការវិនិច្ឆ័យដោយពិចារណាគ្រប់ព័ត៌មានទាំងអស់ដែលមាន ប៉ុន្តែមិនបានកម្រិតទេចំពោះសូចនាករដែលអាចកើតឡើងនៃអតិផរណាលោតផ្លោះដូចខាងក្រោមៈ

(ក)ប្រជាពលរដ្ឋទូទៅចូលចិត្តរក្សាទ្រព្យសម្បត្តិជាទ្រព្យសកម្មមិនមែនរូបិយវត្ថុ ឬរូបិយប័ណ្ណបរទេសដែលមានស្ថេរភាព។ចំនួនទឹកប្រាក់នៃរូបិយប័ណ្ណវត្ថុក្នុងស្រុកដែលបានរក្សាគឺត្រូវបានវិនិយោគភ្លាមដើម្បីរក្សាអំណាចទិញ។

(ខ)ប្រជាពលរដ្ឋទូទៅចាត់ទុកចំនួនទឹកប្រាក់រូបិយវត្ថុមិនស្ថិតក្នុងលក្ខខណ្ឌនៃរូបិយប័ណ្ណក្នុងស្រុក ប៉ុន្តែក្នុងលក្ខខណ្ឌនៃរូបិយបណ្ណ័បរទេសដែលមានស្ថេរភាព។ តម្លៃអាចត្រូវបានលើកឡើងក្នុងរូបិយប័ណ្ណនោះ

(គ) ការលក់ និងការទិញជំពាក់កើតឡើងតាមតម្លៃដែលសងការខាតរំពឹងទុកនៃអំណាចទិញ ក្នុងគ្រាជំពាក់នោះបីគ្រានោះខ្លីក៏ដោយ។

(ឃ) អត្រាការប្រាក់ ថ្លៃឈ្នួល និង តម្លៃត្រូវផ្សារភ្ជាប់ទៅនឹងសន្ទស្សន៍ថ្លៃ។

(ង) អត្រាអតិផរណាបូកបន្តក្នុងរយៈពេល៣ឆ្នាំគឺខិតជិត ឬ លើស ១០០ ភាគរយ។

## រង្វាស់ខ្នាតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣៦.៣ចំនួនទឹកប្រាក់ទាំងអស់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពមួយដែលរូបិយបណ្ណ័មុខងារគឺជារូបិយប័ណ្ណនៃសេដ្ឋកិច្ចលោតផ្លោះត្រូវបានបង្ហាញក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងគ្រារាយការណ៍។ ព័ត៌មានប្រៀបធៀបសម្រាប់គ្រាមុនដែលបានតម្រូវដោយកថាខណ្ឌ ៣.១៤ និង ព័ត៌មានដែលបានបង្ហាញទាក់ទងនឹងគ្រាមុន ក៏ត្រូវបានបង្ហាញក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ន**នៅថ្ងៃរាយការណ៍**។

៣.១៤ការបង្ហាញឡើងវិញនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមផ្នែកនេះតម្រូវឲ្យប្រើប្រាស់សន្ទស្សន៍តម្លៃទូទៅដែលឆ្លុះបញ្ចាំងក្នុងអំណាចទិញទូទៅ។នៅក្នុងសេដ្ឋកិច្ចភាគច្រើនមានសន្ទស្សន៍តម្លៃទូទៅ ធម្មតាត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលដែល អង្គភាពនោះនឹងយកតាម។

## នីតិវិធីសម្រាប់ការបង្ហាញឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុតាមថ្លៃដើម

### របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

៣១.៥ចំនួនទឹកប្រាក់នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលមិនបានបញ្ជាក់ក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងគ្រារាយការណ៍ត្រូវបានបង្ហាញឡើងវិញដោយអនុវត្តសន្ទស្សន៍តម្លៃទូទៅ។

៣១.៦ ធាតុហិរញ្ញវត្ថុមិនត្រូវបានបង្ហាញឡើងវិញដោយសារធាតុនោះត្រូវបានបញ្ជាក់ក្នុងធាតុនៃឯកត្តាវាស់វែងបច្ចុប្បន្ននៅចុងគ្រារាយការណ៍។ ធាតុរូបិយវត្ថុគឺជាប្រាក់ដែលរក្សាទុក និងធាតុត្រូវបានទទួល ឬ បង់ជាប្រាក់។

៣១.៧ទ្រព្យសកម្ម និងបំណុលដែលភ្ជាប់ដោយកិច្ចព្រមព្រៀងចំពោះការផ្លាស់ប្តូរតម្លៃ ដូចជាសញ្ញាប័ណ្ណនិងកំចីភ្ជាប់នឹងសន្ទស្សន៍ថ្លៃត្រូវបានកែសម្រួលដោយអនុលោមតាមកិច្ចព្រមព្រៀង និងត្រូវបានបង្ហាញតាមចំនួនទឹកប្រាក់ដែលបានកែតម្រូវរួចនេះក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបង្ហាញឡើងវិញ

៣១.៨ គ្រប់ទ្រព្យសកម្ម និង បំណុលផ្សេងទៀត មិនមែនហិរញ្ញវត្ថុៈ

(ក)ធាតុមិនមែនហិរញ្ញវត្ថុមួយចំនួនត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៅចុងគ្រារាយការណ៍ ដូចជាតម្លៃទទួលស្គាល់ពិតនិងតម្លៃសបស្រម ដូច្នេះពួកគេមិនត្រូវបានបង្ហាញឡើងវិញទេ។គ្រប់ទ្រព្យសកម្មនិងបំណុលមិនមែនហិរញ្ញវត្ថុផ្សេងទៀត ត្រូវបានបង្ហាញឡើងវិញ។

(ខ)ធាតុមិនមែនហិរញ្ញវត្ថុភាគច្រើនត្រូវបានកត់ត្រាតាមថ្លៃដើម ឬ ថ្លៃដើមដករំលស់ ដូច្នេះ ពួកគេត្រូវបានបង្ហាញតាមចំនួនទឹកប្រាក់នៅថ្ងៃទិញ។ ថ្លៃដើមបង្ហាញឡើងវិញឬថ្លៃដើមដករំលស់នៃធាតុនីមួយៗត្រូវបានកំណត់ដោយអនុវត្តចំពោះថ្លៃដើមប្រវត្តិសាស្ត្រ និងរំលស់បូកបន្ត ការប្រែប្រួលក្នុងសន្ទស្សន៍តម្លៃទូទៅពីថ្ងៃទិញដល់ចុងគ្រារាយការណ៍។

(គ) ចំនួនទឹកប្រាក់បង្ហាញឡើងវិញនៃធាតុមិនមែនរូបិយវត្ថុត្រូវបានកាត់បន្ថយ ដោយអនុលោមតាមផ្នែកទី២៧ *ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម*ពេលតម្លៃនោះលើសពី**តម្លៃត្រូវទទួលបាន។**

៣១.៩ នៅដើមគ្រាដំបូងនៃការអនុវត្តនៃផ្នែកនេះ សមាសធាតុនៃ**ដើមទុន** លើកលែងប្រាក់ចំណេញរក្សាទុក ត្រូវបានបង្ហាញឡើងវិញដោយប្រើសន្ទស្សន៍តម្លៃទូទៅពីថ្ងៃដែលសមាសធាតុត្រូវបានបញ្ចូលឬក៏បានកើតឡើង។ ប្រាក់ចំណេញរក្សាទុកបង្ហាញឡើងវិញបានទទួលពីចំនួនទឹកប្រាក់ផ្សេងទៀតទាំងអស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបង្ហាញឡើងវិញ។

៣១.១០នៅចុងគ្រាដំបូងនិងគ្រាបន្តបន្ទាប់ គ្រប់សមាសធាតុទាំងអស់នៃដើមទុនម្ចាស់ត្រូវបានបង្ហាញឡើងវិញដោយប្រើសន្ទស្សន៍ថ្លៃទូទៅពីដើមគ្រាដំបូងឬថ្ងៃវិភាគទាន ប្រសិនបើយឺតយ៉ាង។ ការផ្លាស់ប្តូរសម្រាប់គ្រាក្នុងដើមទុនម្ចាស់ត្រូវបានលាតត្រដាងដោយអនុលោមតាមផ្នែកទី៦*របាយការណ៍ប្រែប្រួលដើមទុននិងរបាយការណ៍លទ្ធផល និងប្រាក់ចំណេញរក្សាទុក*។

## របាយការណ៍លទ្ធផលសរុបនិងរបាយការណ៍លទ្ធផល

៣.១១ ធាតុទាំងអស់នៅក្នុងរបាយការណ៍លទ្ធផលសរុប (និងរបាយការណ៍លទ្ធផល ប្រសិនបើបានបង្ហាញ) ត្រូវបានបញ្ចាក់ក្នុងលក្ខខណ្ឌនៃឯកត្តាវាស់វែងនៅចុងគ្រារាយការណ៍។ដូច្នេះចំនួនទឹកប្រាក់ទាំងអស់ចាំបាច់ត្រូវរាយការណ៍ឡើងវិញដោយប្រើការផ្លាស់ប្តូរក្នុងសន្ទស្សន៍តម្លៃទូទៅពីថ្ងៃដែល ធាតុនៃចំណូល និងចំណាយត្រូវបានទទួលស្គាល់ជាលើកដំបូងក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ប្រសិនបើអតិផរណាទូទៅសឹងតែស្មើគ្នាពេញមួយគ្រា ហើយធាតុនៃចំណូលនិងចំណាយដែលបានកើតឡើងក៏មានលក្ខណៈស្មើគ្នាពេញមួយគ្រានោះអត្រាមធ្យមនៃអតិផរណាអាចមានលក្ខណៈសមស្រប។

### របាយការណ៍លំហូរសាច់ប្រាក់

៣១.១២អង្គភាពមួយត្រូវបង្ហាញធាតុទាំងអស់នៅក្នុង**របាយការណ៍លំហូរសាច់ប្រាក់**ក្នុងលក្ខខណ្ឌនៃការវាស់វែងឯកត្តានៅចុងគ្រារាយការណ៍។

### ចំណេញ ឬ ខាត លើស្ថានភាពរូបិយវត្ថុសុទ្ធ

៣១.១៣ នៅក្នុងគ្រាមានអតិផរណា អង្គភាពដែលមានទ្រព្យសកម្មរូបិយវត្ថុច្រើនជាងបំណុលរូបិយវត្ថុបាត់បង់អំណាចទិញ ហើយអង្គភាពដែលមានបំណុលរូបិយវត្ថុច្រើនជាងទ្រព្យសកម្មរូបិយវត្ថុ ទទួលបានអំណាចទិញ រហូតដល់ទ្រព្យសកម្ម និងបំណុលមិនត្រូវបានភ្ជាប់ទៅនឹងកម្រិតតម្លៃ។ អង្គភាពត្រូវ រួមបញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាតលើស្ថានភាពរូបិយវត្ថុសុទ្ធ។អង្គភាពត្រូវកាត់កងការកែសម្រួលចំពោះទ្រព្យសកម្មនិងបំណុលទាំងនោះដែលភ្ជាប់ដោយកិច្ចព្រមព្រៀងចំពោះការផ្លាស់ប្តូរតម្លៃ ដែលបានធ្វើដោយអនុលោមតាមកថាខណ្ឌ៣១.៧ ទល់នឹងចំណេញ ឬខាត លើស្ថានភាពរូបិយវត្ថុសុទ្ធ

## សេដ្ឋកិច្ចឈប់មានអតិផរណា

៣១.១៤នៅពេលដែលសេដ្ឋកិច្ចឈប់មានអតិផរណា ហើយអង្គភាពមិនបន្តរៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយអនុលោមតាមផ្នែកនេះ អង្គភាពនោះត្រូវចាត់ទុកចំនួនទឹកប្រាក់ដែលបានបង្ហាញជារូបិយប័ណ្ណសម្រាប់បង្ហាញនៅចុងគ្រារាយការណ៍មុនជាមូលដ្ឋានសម្រាប់តម្លៃក្នុងបញ្ជីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំបន្តបន្ទាប់។

៣១.១៥ អង្គភាពដែលអនុវត្តផ្នែកនេះត្រូវបង្ហាញដូចខាងក្រោមៈ

(ក)ហេតុការណ៍ដែលរបាយការណ៍ហិរញ្ញវត្ថុនិងទិន្នន័យគ្រាមុនៗត្រូវបានរាយការណ៍ឡើងវិញសម្រាប់ការផ្លាស់ប្តូរក្នុងអំណាចទិញទូទៅនៃរូបិយប័ណ្ណមុខងារ។

(ខ)អត្តសញ្ញាណនិងកម្រិតនៃសន្ទស្សន៍តម្លៃដែលថ្ងៃរាយការណ៍និងការផ្លាស់ប្តូរក្នុងគ្រាបច្ចុប្បន្ន និងគ្រារាយការណ៍មុន។

(គ) ចំនួនទឹកប្រាក់ចំណេញឬខាតលើធាតុរូបិយវត្ថុ

## ផ្នែកទី ៣២
## ព្រឹត្តិការណ៍ក្រោយពីបញ្ចប់ការិយបរិច្ឆេទរាយការណ៍

### វិសាលភាពនៃផ្នែកនេះ

៣២.១ ផ្នែកនេះកំណត់ពីព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍និងដាក់ចេញនូវគោលការណ៍សម្រាប់ការទទួលស្គាល់ការវាស់វែង និងការលាតត្រដាងបង្ហាញព័ត៌មានទាក់ទងនឹងព្រឹត្តិការណ៍នោះ។

### និយមន័យនៃព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍

៣២.២ព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍គឺជាព្រឹត្តិការណ៍ទាំងឡាយណាដែលល្អនិងមិនល្អដែលកើតឡើងរវាងចុងគ្រារាយការណ៍និងថ្ងៃពេលដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឲ្យបោះផ្សាយ។ មានព្រឹត្តិការណ៍២ប្រភេទៈ

(ក) ព្រឹត្តិការណ៍ទាំងឡាយណាដែលផ្តល់ភស្តុតាងនៃលក្ខខណ្ឌដែលបានកើតឡើងនៅចុងគ្រារាយការណ៍ (ព្រឹត្តិការណ៍កែសំរួលបន្ទាប់ពីចុងគ្រារាយការណ៍) និង

(ខ) ព្រឹត្តិការណ៍ដែលបញ្ជាក់ពីលក្ខខណ្ឌដែលបានកើតឡើងបន្ទាប់ពីចុងគ្រារាយការណ៍(ព្រឹត្តិការណ៍មិនកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍)

៣២.៣ព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍រាប់បញ្ចូលនូវព្រឹត្តិការណ៍ទាំងអស់រហូតមកដល់របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតិឲ្យបោះផ្សាយ ទោះបីជាព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីការប្រកាសជាសាធារណៈនូវប្រាក់ចំណេញ ឬខាតនៃព័ត៌មានហិរញ្ញវត្ថុជ្រើសរើសផ្សេងៗ។

### ការទទួលស្គាល់ និងការវាស់វែង

#### ព្រឹត្តិការកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍

៣២.៤ អង្គភាពមួយត្រូវកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយបញ្ចូលនូវការលាតត្រដាងព័ត៌មានផង ដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍កែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍។

៣២.៥ខាងក្រោមគឺឧទាហរណ៍នៃព្រឹត្តិការណ៍កែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍ដែលតម្រូវឲ្យអង្គភាព ធ្វើការកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុឬដើម្បីទទួលស្គាល់ធាតុទាំងឡាយដែលកាលពីគ្រាមុនបានទទួលស្គាល់ៈ

(ក) ការទូទាត់សងបន្ទាប់ពីចុងគ្រារាយការណ៍នៃករណីតុលាការដែលបញ្ជាក់ថាអង្គភាពមានកាតព្វកិច្ចបច្ចុប្បន្ននៅចុងគ្រារាយការណ៍។អង្គភាពកែសម្រួលនូវសំវិធានធនដែលបានទទួលស្គាល់ពីមុន ដែលទាក់ទិននឹងករណីតុលាការដោយអនុលោមតាមផ្នែកទី២១ *សំវិធានធន និង យថាហេតុ* ឬ ទទួលស្គាល់សំវិធានធនថ្មី។ អង្គភាពមិនលាតត្រដាងទាំងអស់នូវបំណុលយថាហេតុ។លើសពីនេះ ការទូទាត់សងផ្តល់ភស្តុតាងបន្ថែមដើម្បីពិចារណា

ក្នុងការកំណត់សំវិធានធនដែលត្រូវបានទទួលស្គាល់ នៅចុងគ្រារាយការណ៍ដោយអនុលោមតាមផ្នែកទី២១។

(ខ) ការទទួលព័ត៌មានបន្ទាប់ពីចុងគ្រារាយការណ៍ដែលបង្ហាញថាទ្រព្យសកម្មបានធ្លាក់ចុះតម្លៃនៅចុងគ្រារាយការណ៍ឬថាចំនួនទឹកប្រាក់នៃការខាតដោយសារការធ្លាក់ចុះតម្លៃដែលបានទទួលស្គាល់ពីមុនសម្រាប់ទ្រព្យសកម្មនោះចាំបាច់ត្រូវធ្វើការកែតម្រូវ។ ឧទាហរណ៍:

(១) ការក្ស័យធនរបស់អតិថិជនដែលកើតបន្ទាប់ពីចុងគ្រារាយការណ៍ ជាធម្មតាបញ្ជាក់ ថាការខាតបង់ដែលបានកើតឡើងនៅចុងគ្រារាយការណ៍លើគណនីត្រូវទទួលពាណិជ្ជកម្ម ហើយថា អង្គភាពចាំបាច់ត្រូវកែសម្រួលតម្លៃក្នុងបញ្ជីនៃគណនីត្រូវទទួលពាណិជ្ជកម្ម និង

(២) ការលក់សន្និធិបន្ទាប់ពីចុងគ្រារាយការណ៍អាចផ្តល់ភស្តុតាងអំពីតម្លៃលក់របស់គេនៅចុងគ្រារាយការណ៍សម្រាប់គោលបំណងវាយតម្លៃពីការធ្លាក់ចុះនៅថ្ងៃនោះ។

(គ) ការកំណត់បន្ទាប់ពីចុងគ្រារាយការណ៍នៃតម្លៃទ្រព្យសកម្មដែលបានទិញឬចំណូលពីការលក់ទ្រព្យ មុនពេលចុងគ្រារាយការណ៍។

(ឃ) ការកំណត់បន្ទាប់ពីចុងគ្រារាយការណ៍នៃចំនួនទឹកប្រាក់នៃប្រាក់ចំណេញត្រូវចែក ឬ ការ បង់ប្រាក់បន្ថែម ប្រសិនបើអង្គភាពមានកាតព្វកិច្ចសាងសង ឬស្របច្បាប់ នៅចុងគ្រារាយការណ៍ ដើម្បីធ្វើការទូទាត់បែបនេះជាលទ្ធផលនៃព្រឹត្តិការណ៍មុនថ្ងៃនោះ (សូមមើលផ្នែកទី២៨*អត្ថប្រយោជន៍និយោជិក*)។

(ង) ការរកឃើញនៃការកេងបន្លំឬកំហុសអចេតនា ដែលបង្ហាញថារបាយការណ៍ហិរញ្ញវត្ថុ មិនមានភាពត្រឹមត្រូវ។ ព្រឹត្តិការណ៍មិនកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍។

៣២.៦ អង្គភាពមិនកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍។

៣២.៧ ឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍រួមមាន:

(ក) ការធ្លាក់ចុះតម្លៃទីផ្សារនៃការវិនិយោគចន្លោះចុងគ្រារាយការណ៍និងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។ការថយចុះក្នុងតម្លៃទីផ្សារជាធម្មតាមិនទាក់ទងនឹងលក្ខខណ្ឌនៃការវិនិយោគនៅចុងគ្រារាយការណ៍ទេ ប៉ុន្តែឆ្លុះបញ្ចាំងពីហេតុការណ៍ដែលបានកើតឡើងបន្តបន្ទាប់។ ដូច្នេះ អង្គភាពមិនកែសម្រួលចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការវិនិយោគទេ។ ស្រដៀងគ្នានេះដែរ អង្គភាពមិនធ្វើបច្ចុប្បន្នភាពលើចំនួនទឹកប្រាក់ដែលបានបង្ហាញសម្រាប់ការវិនិយោគនៅចុងគ្រារាយការណ៍ទោះបីជាអង្គភាពចាំបាច់ត្រូវផ្តល់ការលាតត្រដាងបង្ហាញដោយអនុលោមតាមកថាខណ្ឌ ៣២.១០។

(ខ) ចំនួនទឹកប្រាក់ដែលក្លាយជាគណនីត្រូវទទួលដែលកើតឡើងពីការវិនិច្ឆ័យល្អ ឬ ការទូទាត់ សងលើករណីតុលាការបន្ទាប់ថ្ងៃរាយការណ៍ ប៉ុន្តែ មុនពេលរបាយការណ៍ហិរញ្ញវត្ថុចេញផ្សាយ។ នេះអាចជាទ្រព្យសកម្មយថាហេតុនៅថ្ងៃរាយាការណ៍ (សូមមើលកថាខណ្ឌ ២១.១៣) និង ការលាតត្រដាងបង្ហាញអាច ត្រូវបានតម្រូវដោយកថាខណ្ឌ ២១.១៦។ ប៉ុន្តែ កិច្ចព្រមព្រៀងលើចំនួនទឹកប្រាក់ដែលខូចខាតសម្រាប់ការវិនិច្ឆ័យ ដែលបានធ្វើឡើងមុនពេលថ្ងៃរាយការណ៍ ប៉ុន្តែមិនត្រូវបានទទួលស្គាល់លើពីមុនដោយសារចំនួនទឹកប្រាក់នោះ អាចត្រូវបានវាស់វែងដោយជឿជាក់ អាចបង្កើតជាព្រឹត្តិការណ៍កែសម្រួល។

ភាគលាភ

៣២.៨ប្រសិនបើអង្គភាពប្រកាសពីភាគលាភទៅឱ្យអ្នកកាន់ឧបករណ៍ដើមទុនបន្ទាប់ពីចុងគ្រារាយការណ៍ អង្គភាពមិនត្រូវទទួលស្គាល់ភាគលាភទាំងនោះជាបំណុលនៅចុងគ្រារាយការណ៍ទេ។ចំនួនទឹកប្រាក់នៃភាគលាភអាចត្រូវបានបង្ហាញជាសមាសធាតុដាច់ដោយឡែកមួយនៃប្រាក់ចំណេញរក្សាទុកនៅចុងគ្រារាយការណ៍។

## ការលាតត្រដាងព័ត៌មាន

### កាលបរិច្ឆេទអនុញ្ញាតចេញផ្សាយ

៣២.៩ អង្គភាពត្រូវលាតត្រដាងព័តិមានទាក់ទងនឹងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ និងអ្នកជាអ្នកផ្តល់ការអនុញ្ញាត។ប្រសិនបើម្ចាស់អង្គភាពឬអ្នកផ្សេងទៀតមានអំណាចដើម្បីកែប្រែរបាយការណ៍ហិរញ្ញវត្ថុបន្ទាប់ពីការចេញផ្សាយ អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ

### ព្រឹត្តិការណ៍មិនកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍

៣២.១០អង្គភាពត្រូវលាតត្រដាងព័តិមានដូចខាងក្រោមសម្រាប់ខ្ទង់នីមួយៗនៃព្រឹត្តិការណ៍មិនកែសម្រួល បន្ទាប់ពីចុងគ្រារាយការណ៍:

(ក) ប្រភេទព្រឹត្តិការណ៍ និង

(ខ) ការប៉ាន់ស្មាននៃឥទ្ធិពលហិរញ្ញវត្ថុ ឬ របាយការណ៍ដែលការប៉ាន់ស្មានបែបនេះមិនអាចត្រូវ បានធ្វើឡើង។

៣២.១១ខាងក្រោមគឺជាឧទាហរណ៍នៃព្រឹត្តិការណ៍មិនកែសម្រួលបន្ទាប់ពីចុងគ្រារាយការណ៍ដែលទូទៅត្រូវលាតត្រដាងព័តិមាន ការលាតត្រដាងព័តិមាននឹងឆ្លុះបញ្ចាំងពីព័តិមានដែលកើតឡើងបន្ទាប់ពីចុងគ្រារាយការណ៍ ប៉ុន្តែមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យចេញផ្សាយ:

(ក) ការបញ្ចូលអាជីវកម្មរួមគ្នា ឬ ការលក់ចោលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធសំខាន់មួយ

(ខ) សេចក្តីប្រកាសពីផែនការមិនបន្តប្រតិបត្តិការ

(គ) ការទិញទ្រព្យសកម្មសំខាន់ ការលក់ចោល ឬ ផែនការលក់ចោលទ្រព្យសកម្ម ឬ ការដកហូតទ្រព្យសកម្ម ស្របច្បាប់ដោយរដ្ឋាភិបាល។

(ឃ) ការបំផ្លាញនៃរោងចក្រផលិតសំខាន់ដោយអគ្គីភ័យ។

(ង) សេចក្តីប្រកាស ឬ ការចាប់ផ្តើមនៃការអនុវត្តនៃការរុះរើរចនាសម្ព័ន្ធ

(ច) ការបោះផ្សាយ ឬការទិញមកវិញនូវឧបករណ៍ដើមទុន ឬ ឧបករណ៍បំណុលរបស់អង្គភាព

(ឆ) ការផ្លាស់ប្តូរទ្រង់ទ្រាយធំមិនធម្មតានៅក្នុងតម្លៃទ្រព្យសកម្មឬ អត្រាប្តូរប្រាក់បរទេស

(ជ) ការផ្លាស់ប្តូរអត្រាពន្ធ ឬ ច្បាប់ពន្ធដារដែលបានអនុម័ត ឬបានប្រកាសដែលមានឥទ្ធិពលសំខាន់លើទ្រព្យសកម្ម និងបំណុលពន្ធពន្យា។

(ឈ) ឈានចូលក្នុងការសន្យាសំខាន់ៗ ឬ បំណុលយថាហេតុ ឧទាហរណ៍ ដោយការបោះផ្សាយឯកសារធានាសំខាន់ៗ

(ញ) ការចាប់ផ្តើមនៃការប្តឹងសំខាន់ៗដែលកើតពីព្រឹត្តិការដែលបានកើតឡើងបន្ទាប់ពីចុងគ្រារាយការណ៍។

## ផ្នែកទី៣៣
## ការលាតត្រដាងពីភាគីពាក់ព័ន្ធ

### វិសាលភាពនៃផ្នែកនេះ

៣៣.១ផ្នែកនេះតម្រូវឲ្យអង្គភាពបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនូវការលាតត្រដាងព័ត៌មានចាំបាច់ ទាំងឡាយដើម្បីទាញការយកចិត្តទុកដាក់ចំពោះភវនីយភាពដែលស្ថានភាពហិរញ្ញវត្ថុចំណេញឬខាតត្រូវបានប៉ះពាល់ដោយសារកើតមានឡើងនៃ**ភាគីពាក់ព័ន្ធ** និង ដោយប្រតិបត្តិការ ព្រមទាំងសមតុល្យជាភាគីបែបនេះ។

### និយមន័យភាគីពាក់ព័ន្ធ

៣៣.២ ភាគីពាក់ព័ន្ធគឺជាបុគ្គលឬអង្គភាពដែលមានទំនាក់ទំនងទៅនឹងអង្គភាពដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (អង្គភាពរាយការណ៍)

(ក) បុគ្គលម្នាក់ឬសមាជិកជិតស្និតនៃគ្រួសាររបស់បុគ្គលនោះមានទំនាក់ទំនងទៅនឹងអង្គភាពរាយការណ៍ ប្រសិនបើបុគ្គលនោះ÷

(១) សមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាពរាយការណ៍ឬមានអំណាចបោះ ឆ្នោតសំខាន់

(២) មានសិទ្ធិគ្រប់គ្រងលើអង្គភាពរាយការណ៍ ឬ

(៣) មានសិទ្ធិគ្រប់គ្រងរួមឬឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ឬមានអំណាចបោះសំខាន់ក្នុងអង្គភាពនោះ។

(ខ) អង្គភាពមានទំនាក់ទំនងចំពោះអង្គភាពរាយការណ៍ប្រសិនបើលក្ខខណ្ឌណាមួយខាងក្រោមត្រូវបានអនុវត្តៈ

(១)អង្គភាពនិងអង្គភាពរាយការណ៍គឺជាសមាជិកនៃក្រុម(ដែលមានន័យថាក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធដូចគ្នា មានទំនាក់ទំនងនឹងគ្នា)។

(២)អង្គភាពជាក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន នៃអង្គភាពផ្សេងទៀត (ឬ ជាសមាជិកនៃក្រុមដែលអង្គភាពផ្សេងទៀតគឺជាសមាជិក)។

(៣) អង្គភាពទាំងពីរគឺជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣។

(៤)អង្គភាពគឺជាអង្គភាពរួមទុននៃអង្គភាពទី៣ហើយអង្គភាពផ្សេងទៀតគឺជាក្រុមហ៊ុនញាតិសម្ពន្ធ័នៃអង្គភាពទី៣។

(៥)អង្គភាពគឺជាផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារសម្រាប់អត្ថប្រយោជន៍ និយោជិកនៃអង្គភាពរាយការណ៍ឬអង្គភាពដែលទាក់ទងទៅនឹងអង្គភាពរាយការណ៍។ប្រសិនបើអង្គភាពរាយការណ៍ជានិយោជកឧបត្ថម្ភខ្លួនឯងក៏មានការទាក់ទងចំពោះផែនការផងដែរ។

(៦) អង្គភាពត្រូវបានគ្រប់គ្រងឬគ្រប់គ្រងរួមដោយបុគ្គលម្នាក់ដែលបានកំណត់ក្នុង (ក)

(៧) បុគ្គលដែលកំណត់ក្នុង (ក)(១) មានអំណាចបោះឆ្នោតសំខាន់ក្នុងអង្គភាព។

(៨)បុគ្គលដែលកំណត់ក្នុង (ក)(២) មានឥទ្ធិពលសំខាន់លើអង្គភាពឬអំណាចបោះឆ្នោតសំខាន់នៅក្នុងអង្គភាពនោះ។

(៩)បុគ្គលឬសមាជិកជិតស្និតនៃគ្រួសាររបស់បុគ្គលនោះមានឥទ្ធិពលសំខាន់លើអង្គភាពផង ឬ អំណាចបោះឆ្នោតសំខាន់ផងក្នុងអង្គភាពនោះ ហើយមានការគ្រប់គ្រងរួមលើអង្គភាពរាយការណ៍។

(១០)សមាជិកនៃបុគ្គលិកគ្រប់គ្រងសំខាន់របស់អង្គភាពឬរបស់ក្រុមហ៊ុនមេនៃអង្គភាពឬសមាជិកជិតស្និទ្ធនៃគ្រួសារនៃសមាជិកនោះមានការគ្រប់គ្រងឬការគ្រប់គ្រងរួមលើអង្គភាពរាយការណ៍ឬអំណាចបោះឆ្នោតសំខាន់នៅក្នុងអង្គភាពនោះ។

៣៣.៣ ក្នុងការពិចារណាពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធដែលកើតមាននីមួយៗអង្គភាពត្រូវវាយតម្លៃពីស្ថានភាពពិតនៃទំនាក់ទំនង និង មិនលើទម្រង់ច្បាប់ទាំងស្រុងនោះទេ។

៣៣.៤ នៅក្នុងបរិការណ៍នៃស្តង់ដារនេះ ខាងក្រោមគឺជាភាគីពាក់ព័ន្ធចាំបាច់នោះទេ:

(ក)អង្គភាពទាំងពីរធ្វើឲ្យងាយពីព្រោះពួកគេមាននាយក១រូបឬសមាជិកផ្សេងទៀតនៃបុគ្គលិកគ្រប់គ្រងសំខាន់ជាទូទៅ។

(ខ) **អ្នកចូលរួមទុន២នាក់**ធ្វើឲ្យងាយពីព្រោះពួកគេចែកការគ្រប់គ្រងលើគ្រុមហ៊ុនរួមទុន។

(គ)អង្គភាពណាមួយនៃអង្គភាពខាងក្រោមធ្វើឲ្យងាយដោយអាស្រ័យលើការជាប់ពាក់ព័ន្ធ ជាធម្មតាជាមួយអង្គភាព(ទោះបីជាពួកគេអាចប៉ះពាល់ដល់សេរីភាពនៃសកម្មភាពរបស់អង្គភាព ឬចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត)÷

(១) អ្នកផ្តល់ហិរញ្ញវត្ថុ

(២)សហជីពពាណិជ្ជកម្ម

(៣) អង្គភាពសាធារណៈ

(ឃ) នាយកដ្ឋាន និង ភ្នាក់ងាររបស់រដ្ឋាភិបាល

(ឃ)អតិថិជន អ្នកផ្គត់ផ្គង់ អ្នកលក់សិទ្ធិជួញដូរ អ្នកចែកចាយ ឬ ភ្នាក់ងារដែលអង្គភាពមានប្រតិ បត្តិការអាជីវកម្មទំហំធំ ដោយអាស្រ័យទាំងស្រុងនៃអនិស្សរភាពសេដ្ឋកិច្ច។

## ការលាតត្រដាងព័ត៌មាន

### ការលាតត្រដាងព័ត៌មានពីទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

៣៣.៥ទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបង្ហាញមិនគិតថាមានប្រតិបត្តិការ ភាគីពាក់ព័ន្ធទេ។ អង្គភាពត្រូវបង្ហាញនូវឈ្មោះរបស់ក្រុមហ៊ុនមេ និង ភាគីគ្រប់គ្រងចុងក្រោយប្រសិនបើខុសគ្នា។ ប្រសិនបើទាំងអង្គភាពរបស់ក្រុមហ៊ុនមេទាំងភាគីគ្រប់គ្រងចុងក្រោយមិនបានផលិតរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការប្រើប្រាស់ជាសាធារណៈទេ ឈ្មោះនៃក្រុមហ៊ុនមេធំជាងគេបន្ទាប់ដែលបានផលិតរបាយការណ៍ហិរញ្ញវត្ថុ(ប្រសិនបើមាន)ក៏ត្រូវលាតត្រដាងផងដែរ។

### កាតលាតត្រដាងនៃការតបស្នងបុគ្គលិកគ្រប់គ្រងសំខាន់

៣៣.៦បុគ្គលិកគ្រប់គ្រងសំខាន់ៗគឺជាបុគ្គលដែលមានសិទ្ធិអំណាចនិងការទទួលខុសត្រូវធ្វើផែនការដឹកនាំ និង ត្រួតពិនិត្យសកម្មរបស់អង្គភាពដោយផ្ទាល់ឬដោយប្រយោលរួមបញ្ចូលនូវនាយកណាមួយ (ថាតើជាអ្នកប្រតិបត្តិ ឬមិនប្រតិបត្តិនោះទេ)នៃអង្គភាពនោះ។ការតបស្នងរួមបញ្ចូលអត្ថប្រយោជន៍និយោជិកទាំងអស់ (ដែលបានកំណត់ក្នុងផ្នែកទី២៨*អត្ថប្រយោជន៍និយោជិក*)រួមមានអត្ថប្រយោជន៍ទាំងឡាយក្នុងទម្រង់ការទូទាត់ផ្អែកលើសន្លឹកហ៊ុន( សូមមើលផ្នែកទី២៦ *ការទូទាត់ផ្អែកលើសន្លឹកហ៊ុន*)។ អត្ថប្រយោជន៍និយោជិករួមមានគ្រប់ទម្រង់ទាំងអស់នៃតម្លៃតបស្នងដែលបានបង់ ត្រូវបង់ ឬ ផ្តល់ដោយអង្គភាព ឬ តំណាងឲ្យអង្គភាព (ឧ. ដោយក្រុមហ៊ុនមេរបស់គេ ឬដោយម្ចាស់ភាគហ៊ុន)ក្នុងការដោះដូរសេវាដែលបានផ្តល់ទៅឲ្យអង្គភាព។ អត្ថប្រយោជន៍និយោជិកក៏បញ្ចូលផងដែរនូវការតម្លៃ តបស្នងដែលបានបង់ជំនួសក្រុមហ៊ុនមេរបស់អង្គភាពទាក់ទងនឹងទំនិញ ឬសេវាដែលបានផ្តល់ទៅឲ្យ អង្គភាព។

៣៣.៧ អង្គភាពត្រូវលាតត្រដាងបង្ហាញនូវការតម្លៃតបស្នងបុគ្គលិកគ្រប់គ្រងសំខាន់ជាចំនួនសរុប។

### ការលាតត្រដាងពីប្រតិបត្តិការភាគីពាក់ពន្ធ័

៣៣.៨ **ប្រតិបត្តិការភាគីពាក់ព័ន្ធ**គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងអង្គភាពរាយការណ៍ និង ភាគីពាក់ព័ន្ធ ដោយមិនគិតថាតម្លៃត្រូវបានគេគិតនោះទេ។ ឧទាហរណ៍នៃប្រតិបត្តិការភាគីពាក់ព័ន្ធដែលជាទូទៅចំពោះ អេស អ៊ីម អ៊ី រួមបញ្ចូលប៉ុន្តែមិនបានកម្រិតចំពោះ÷

(ក) ប្រតិបត្តិការរវាងអង្គភាព និង ម្ចាស់ភាគហ៊ុន

(ខ)ប្រតិបត្តិការរវាងអង្គភាពនិងអង្គភាពផ្សេងទៀតពេលដែលអង្គភាពទាំពីរស្ថិតនៅក្រោម ការគ្រប់គ្រ ងរបស់អង្គភាពទោល ឬ បុគ្គលទោល។

(គ)ប្រតិបត្តិការដែលអង្គភាព ឬបុគ្គលដែលគ្រប់គ្រងអង្គភាពរាយការណ៍បានកើតឡើងចំណាយដោយផ្ទាល់ បើមិនដូច្នេះទេ ត្រូវទទួលរ៉ាប់រងដោយអង្គភាពរាយការណ៍។

៣៣.៩ ប្រសិនបើអង្គភាពមានប្រតិបត្តិការភាគីពាក់ពន្ធ័ អង្គភាពត្រូវលាតត្រដាងបង្ហាញនូវទំនាក់ទំនង ភាគីពាក់ព័ន្ធក៏ដូចជាព័ត៌មានអំពីប្រតិបត្តិការ សមតុល្យចុងគ្រា និង ការសន្យាចាំបាច់ទាំងឡាយសម្រាប់ការយល់ដឹងនៃឥទ្ធិពលនៃទំនាក់ទំនងដែលមានសក្តានុពលលើរបាយការណ៍ហិរញ្ញវត្ថុ។ការតម្រូវសម្រាប់ការលាតត្រដាងបន្ថែមលើការតម្រូវក្នុងកថាខណ្ឌ៣៣.៧ដើម្បីលាតត្រដាងពីតម្លៃតបស្នងបុគ្គលិកសំខាន់ៗ។ ការលាតត្រដាងព័ត៌មានត្រូវបញ្ចូលជាអប្បបរមាៈ

(ក) ចំនួនទឹកប្រាក់នៃប្រតិបត្តិការ

(ខ) ចំនួនទឹកប្រាក់នៃសមតុល្យចុងគ្រា និងៈ

(១)លក្ខខណ្ឌរបស់គេរួមបញ្ចូលថាតើលក្ខខណ្ឌទាំងនោះត្រូវបានធានានិងប្រភេទនៃការតបស្នងដែលត្រូវផ្តល់ក្នុងការទូទាត់ និង

(២) ព័ត៌មានលំអិតនៃការធានាដែលបានផ្តល់ ឬ បានទទួល។

(គ)សំវិធានធនសម្រាប់ប្រាក់ត្រូវទទួលមិនអាចប្រមូលបានដែលទាក់ទិននឹងចំនួនទឹកប្រាក់នៃសមតុល្យចុងគ្រា។

(ឃ) ចំណាយដែលបានទទួលស្គាល់ក្នុងគ្រាទាក់ទងនឹងបំណុលជាប់សង្ស័យឬបំណុលអាក្រក់ពីភាគីពាក់ពន្ធ័។

៣៣.១០ អង្គភាពត្រូវធ្វើការលាតត្រដាងបង្ហាញដែលបានតម្រូវដោយកថាខណ្ឌ៣៣.៩ ដោយឡែកសម្រាប់ខ្ទង់នីមួយៗដូចខាងក្រោមៈ

(ក) អង្គភាពទាំងឡាយជាមួយនឹងការគ្រប់គ្រង ការគ្រប់គ្រងរួម ឬ ឥទ្ធិពលសំខាន់ៗលើអង្គភាព។

(ខ) អង្គភាពទាំងឡាយលើអង្គភាពដែកឱលមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬឥទ្ធិពលសំខាន់ៗ

(គ) បុគ្គលិកគ្រប់គ្រងសំខាន់ៗនៃអង្គភាពឬក្រុមហ៊ុនមេរបស់គេ(ក្នុងចំនួនសរុប)ឮ

(ឃ) ភាគីទាក់ទងផ្សេងទៀត។

៣៣.១១ អង្គភាពដែលទទួលបានការលើកលែងពីការតម្រូវលាតត្រដាងព័ត៌មាននៃកថាខណ្ឌ ៣៣.៩ ទាក់ទងនឹង:

(ក) អង្គភាពរដ្ឋ (រដ្ឋាភិបាលជាតិ រដ្ឋាភិបាលតំបន់ ឬ រដ្ឋាភិបា លស្រុក) ដែលមានការគ្រប់គ្រង រួម ឬ ឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ និង

(ខ)អង្គភាពដែលជាភាគីពាក់ពន្ធ័ពីព្រោះរដ្ឋដូចគ្នាមានការគ្រប់គ្រង ការគ្រប់គ្រងរួម ឬ ឥទ្ធិពលសំខាន់ៗលើទាំងអង្គភាពរាយការណ៍ និងអង្គភាពផ្សេងទៀត។

ប៉ុន្តែអង្គភាពត្រូវតែលាតត្រដាងពីទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានតម្រូវ ដោយកថាខណ្ឌ ៣៣.៥

៣៣.១២ខាងក្រោមគឺជាឧទាហរណ៏នៃប្រតិបត្តិការដែលត្រូវបានលាតត្រដាងប្រសិនបើប្រតិបត្តិការនោះធ្វើឡើងជាមួយភាគីពាក់ពន្ធ័:

(ក) ការទិញ ឬលក់ទំនិញ (បានបញ្ចប់ ឬមិនទាន់បញ្ចប់)។

(ខ) ការទិញ ឬការលក់ទ្រព្យ និង ទ្រព្យសកម្មផ្សេងទៀត។

(គ) ការផ្តល់សេវាកម្ម ឬការទទួលស្គាល់សេវាកម្ម។

(ឃ) ភតិសន្យា

(ង) ការផ្ទេរការសិក្សាស្រាវជ្រាវ និង ការអភិវឌ្ឍន៍

(ច) ការផ្ទេរក្រោមកិច្ចព្រមព្រៀងមានអជ្ញាប័ណ្ណ

(ឆ) ការផ្ទេរក្រោមកិច្ចព្រមព្រៀងហិរញ្ញវត្ថុ (រួមបញ្ចូលកំចី និង ការចូលរួមទុនជាសាច់ប្រាក់ ឬ ជាសំភារៈ

(ជ) សំវិធានធននៃការធានា ឬ ទ្រព្យដាក់ធានា

(ឈ) ការទូទាត់បំណុលក្នុងនាមអង្គភាព ឬ ដោយអង្គភាពក្នុងនាមភាគីមួយទៀត។

(ញ)ការចូលរួមដោយក្រុមហ៊ុនមេឬក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងផែនការអត្ថប្រយោជន៏កំណត់ដែលចែករំលែកហានិភ័យរវាងអង្គភាពក្នុងក្រុម។

៣៣.១៣ អង្គភាពមិនត្រូវបង្ហាញថាប្រតិបត្តិការភាគីពាក់ព័ន្ធត្រូវបានធ្វើឡើងលើលក្ខខណ្ឌដែលសមមូលទៅនឹងលក្ខខណ្ឌដែលមានប្រៀបក្នុងប្រតិបត្តិការបណ្តោយដៃលុះត្រាតែលក្ខខណ្ឌនេះអាចត្រូវបានបង្ហាញច្បាស់លាស់។

៣៣.១៤អង្គភាពអាចលាតត្រដាងបង្ហាញធាតុដែលមានលក្ខណៈស្រដៀងគ្នាជាចំនួនសរុបលើកលែងតែពេលការលាតត្រដាងដោយឡែកចាំបាច់សម្រាប់ការយល់ដឹងនៃឥទ្ធិពលនៃប្រតិបត្តិការភាគីពាក់ព័ន្ធលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

## ផ្នែកទី៣៤

## សកម្មភាពពិសេស

### វិសាលភាពនៃផ្នែកនេះ

៣៤.១ ផ្នែកនេះផ្តល់នូវការណែនាំពីការរាយការណ៍ហិរញ្ញវត្ថុដោយ សហគ្រាសធុនតូចនិងមធ្យម ដែលទាក់ទិននឹងសកម្មភាពពិសេសចំនួន០៣ រួមមាន កសិកម្ម, សកម្មភាពនិស្សារណ, សម្បទានសេវាកម្ម។

### កសិកម្ម

៣៤.២ដោយប្រើស្តង់ដារនេះ អង្គភាពដែលមាន**សកម្មភាពកសិកម្ម**ត្រូវកំណត់គោលនយោបាយគណនេយ្យរបស់ខ្លួនសម្រាប់ថ្នាក់ទ្រព្យសកម្មជីវសាស្ត្រនីមួយៗ ដូចខាងក្រោមៈ

(ក)អង្គភាពត្រូវប្រើវិធីសាស្ត្រតម្លៃសមស្របក្នុងកថាខណ្ឌ៣៤.៤ ដល់ ៣៤.៧ សម្រាប់ទ្រព្យសកម្មជីវសាស្ត្រដែលតម្លៃសមស្របត្រូវបានកំណត់រួចរាល់ដោយគ្មានចំណាយ ឬការខិតខំប្រឹងប្រែង ហួសហេតុ។

(ខ) អង្គភាពត្រូវប្រើវិធីសាស្ត្រថ្លៃដើមក្នុងកថាខណ្ឌ៣៤.៨ ដល់ ៣៤.១០ សម្រាប់ទ្រព្យសកម្មជីវសាស្ត្រ។

### ការទទួលស្គាល់

៣៤.៣ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មជីវសាស្ត្រឬ**ផលិតផលកសិកម្ម**ពេល និង នៅពេលដែលៈ

(ក) អង្គផាពគ្រប់គ្រងទ្រព្យសកម្មដែលកើតចេញពីព្រឹត្តិការណ៍អតីតកាល

(ខ) វាទំនងជាថាអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលជាប់ទាក់ទងនឹងទ្រព្យសកម្មនឹងហូរមកកាន់អង្គភាព និង

(គ)តម្លៃសបស្រុបឬថ្លៃដើមទ្រព្យសកម្មអាចត្រូវបានវាស់វែងបានដោយជឿជាក់ដោយគ្មានចំណាយ ឬការខិតខំហួសហេតុ។

### ការវាស់វែង -វិធីសាស្ត្រតម្លៃសមស្រប

៣៤.៤ អង្គភាពត្រូវវាស់វែងទ្រព្យសកម្មជីវសាស្ត្រពេលទទួលស្គាល់លើកដំបូងនិងនៅថ្ងៃរាយការណ៍នីមួយៗ តាមតម្លៃសមស្របដកថ្លៃដើម្បីលក់។ការប្រែប្រួលតម្លៃសបស្របដកថ្លៃដើម្បីលក់ត្រូវបាន ទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។

៣៤.៥ ផលិតផលកសិកម្មដែលបានប្រមូលផលពីទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាពត្រូវបានវាស់វែងតាមតម្លៃសមស្របដកថ្លៃដើម្បីលក់នៅពេលប្រមូលផល។ការវាស់វែងនេះគឺជាថ្លៃដើមនៅថ្ងៃនោះនៅពេលអនុវត្តផ្នែកទី១៣ *សន្និធិ* ឬ ផ្នែកដែលអាចអនុវត្តបានផ្សេងទៀតនៃស្តង់ដារនេះ។

៣៤.៦ ក្នុងការកំណត់តម្លៃសបស្រប អង្គភាពត្រូវពិចារណាដូចខាងក្រោមៈ

(ក) ប្រសិនបើទីផ្សារសកម្មមានសម្រាប់ទ្រព្យសកម្មជីវសាស្ត្រ ឬ ផលិតផលកសិកម្មក្នុងលក្ខខណ្ឌនិងទីតាំងបច្ចុប្បន្នថ្លៃលើកឡើងនៅក្នុងទីផ្សារនោះគឺជាមូលដ្ឋានសមស្របសម្រាប់កំណត់ តម្លៃសមស្របនៃទ្រព្យសកម្មនោះប្រសិនបើអង្គភាពមានព័ត៌មានចំពោះទីផ្សារសកម្មផ្សេងទៀតអង្គភាពត្រូវប្រើតម្លៃដែលមានក្នុងទីផ្សារដែលអង្គភាពរំពឹងថានឹងប្រើ។

(ខ) ប្រសិបើទីផ្សារសកម្មមិនកើតមានទេ អង្គភាពត្រូវប្រើ មួយឬច្រើននៃតម្លៃខាងក្រោម ពេលដែលមានក្នុងការកំណត់តម្លៃសមស្របៈ

(១)តម្លៃប្រតិបត្តិការទីផ្សារថ្មីៗបំផុត ដែលផ្តល់ថា មិនមានការផ្លាស់ប្តូរសំខានក្នុងស្ថានភាពសេដ្ឋកិច្ចនៅចន្លោះថ្ងៃនៃប្រតិបត្តិការនោះ និង ចុងគ្រារាយការណ៍។

(២) តម្លៃទីផ្សារសម្រាប់ទ្រព្យសកម្មស្រដៀងគ្នាមានការកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីភាពខុសគ្នា និង

(៣) ការដកស្រង់តាមវិស័យដូចជាតម្លៃនៃចំការផ្លែឈើក្នុងមួយថាស មួយល្អី មួយហិចតា និងតម្លៃនៃគោក្របី ដែលបានបញ្ជាក់ក្នុងមួយគីឡូនៃសាច់នាំចេញ ។

(គ)ក្នុងករណីខ្លះ ប្រភពព័ត៌មានដែលនៅក្នុង(ក)ឬ(ខ) អាចស្នើឲ្យមានការសន្និដ្ឋានខុសគ្នា ចំពោះតម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រឬផលិតផលកសិកម្ម។អង្គភាពពិចារណាពីមូលហេតុ ពីភាពខុសគ្នា ដើម្បីនាំទៅដល់ការប៉ាន់ស្មានដែលគួរឲ្យជឿជាក់បំផុតនៃតម្លៃសមស្របក្នុងចំណោម ការប៉ាន់ស្មានដែលសមស្របដែលទាក់ទង។

(ឃ)ក្នុងហេតុការណ៍មួយចំនួនតម្លៃសមស្របអាចកំណត់បានរួចរាល់ដោយគ្មានចំណាយនិង ការខិតខំហួសហេតុ ទោះបីទីផ្សារបានកំណត់ថ្លៃឬតម្លៃមិនមានសម្រាប់ទ្រព្យសកម្មជីវសាស្ត្រក្នុងលក្ខខណ្ឌបច្ចុប្បន្ន។ អង្គភាពត្រូវពិចារណាថាតើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់សុទ្ធដែលរំពឹងទុកពី ទ្រព្យសកម្មដែលបានធ្វើអប្បហារតាមទីផ្សារបច្ចុប្បន្ន បានកំណត់អត្រាក្នុងការវាស់វែងតម្លៃសបស្រម ដែលគួរឲ្យជឿជាក់។

ការលាតត្រដាងព័ត៌មាន - វិធីសាស្ត្រតម្លៃសមស្រប

៣៤.៧អង្គភាពត្រូវលាតត្រដាងព័ត៌មានដូចខាងក្រោមទាក់ទិននឹងទ្រព្យសកម្មជីវសាស្ត្រដែលបានវាស់វែងតាមតម្លៃសមស្របៈ

(ក) ការរៀបរាប់ពីថ្នាក់ទ្រព្យសកម្មនីមួយៗ

(ខ)វិធីសាស្ត្រនិងការសន្មតសំខាន់ៗដែលបានប្រើក្នុងការកំណត់តម្លៃសមស្របនៃខ្ទង់ផលិតផលកសិកម្មនីមួយៗនៅពេលប្រមូលផល និង ខ្ទង់នៃទ្រព្យសកម្មជីវសាស្ត្រនីមួយៗ។

(គ)ការផ្ទៀផ្ទាត់ការប្រែប្រួលតម្លៃក្នុងបញ្ជីនៃទ្រព្យសកម្មជីវសាស្ត្ររវាងដើមគ្រានិងចុងគ្រាបច្ចុប្បន្ន។ការផ្ទៀង ផ្ទាត់ត្រូវបញ្ចូលៈ

(១) ចំណេញ ឬ ខាតកើតចេញពីការប្រែប្រួលតម្លៃសមស្របដកថ្លៃដើម្បីលក់។

(២) ការកើនឡើងពីការទិញ។

(៣) ការថយចុះពីការប្រមូលផល។

(៤) ការកើនឡើងពីការបញ្ចូលអាជីវកម្ម។

(៥)ភាពខុសគ្នាសុទ្ធពីការប្តូរប្រាក់ដែលកើតឡើងលើការបកប្រែរបាយការណ៍ហិរញ្ញវត្ថុទៅជារូបិយប័ណ្ណសម្រាប់ បង្ហាញផ្សេង និង លើការបកប្រែប្រតិបត្តិការបរទេសទៅជារូបិយប័ណ្ណ សំរាបើបង្ហាញរបស់អង្គភាពរាយការណ៍។

(៦) ការប្រែប្រួលផ្សេងទៀត។

ការវាស់វែង - វិធីសាស្ត្រថ្លៃដើម

៣៤.៨អង្គភាពត្រូវវាស់វែងតាមថ្លៃដើមដករំលស់បូកបន្តនិងការខាតដោយការធ្លាក់ចុះតម្លៃបូកន្តនូវទ្រព្យសកម្ម ជីវសាស្ត្រទាំងនោះដែលតម្លៃសមស្របមិនអាចកំណត់បានរួចរាល់ដោយគ្មានចំណាយ ឬ ការខិតខំប្រឹងប្រែង ហួសហេតុ។

៣៤.៩អង្គភាពត្រូវវាស់វែងផលិតផលកសិកម្មដែលបានប្រមូលផលពីទ្រព្យសកម្មជីវសាស្ត្រតាមតម្លៃសមស្របដកថ្លៃ ប៉ាន់ស្មានដើម្បីលក់នៅពេលលក់។ការវាស់វែងបែបនេះគឺជាថ្លៃដើមនៅថ្ងៃនោះពេល អនុវត្តផ្នែក១៣ ឬ ផ្នែកផ្សេងទៀតនៃស្តង់ដារនេះ។

ការលាតត្រដាងព័ត៌មាន -វិធីសាស្ត្រថ្លៃដើម

៣៤.១០អង្គភាពត្រូវលាតត្រដាងដូចខាងក្រោមទាក់ទងនឹងទ្រព្យសកម្មជីវសាស្ត្រដែលបានវាស់វែងដោយប្រើ វិធីសាស្ត្រថ្លៃដើមៈ

(ក) ការរៀបរាប់ពីថ្នាក់ទ្រព្យសកម្មជីវសាស្ត្រនីមួយៗ

(ខ) ការពន្យល់ពីមូលហេតុដែលតម្លៃសមស្របមិនអាចត្រូវបានវាស់វែងដោយជឿជាក់

(គ) វិធីសាស្ត្ររំលស់ដែលបានប្រើ

(ឃ) អាយុកាល ឬ អត្រារំលស់ដែលបានប្រើ

(ង)តម្លៃក្នុងបញ្ជីដុលនិងរំលស់បូកបន្ត (បញ្ចូលជាមួយការខាតដោយការធ្លាក់ចុះតម្លៃ)នៅដើមគ្រា និងចុងគ្រា។

## សកម្មភាពនិស្សារណា

៣៤.១១ដោយប្រើស្តង់ដារនេះ អង្គភាពមួយដែលមានសកម្មភាពរុករក វាយតម្លៃ ការទាញយកធនធានរ៉ែ (សកម្មភាពនិស្សារណា)ត្រូវធ្វើគណនេយ្យកម្មចំណាយនៅពេលទិញឬអភិវឌ្ឍន៍ទ្រព្យសកម្មរូបីឬទ្រព្យសកម្មអរូបីសម្រាប់ប្រើប្រាស់ ក្នុងសកម្មភាពនិស្សារណដោយប្រើផ្នែកទី១៧ *ទ្រព្យ រោងចក្រ និង បរិក្ខារ* និង ផ្នែកទី១៨ *ទ្រព្យសកម្មអរូបី លើកលែងកេរ្តិ៍ឈ្មោះ*។ នៅពេលដែលអង្គភាពមានកាតព្វកិច្ច ដើម្បីរុះរើ ឬ យកចេញធាតុ ឬ ស្តារឡើងវិញនូវទីតាំង កាតព្វកិច្ចនិងចំណាយនេះត្រូវបានធ្វើគណនេយ្យកម្មដោយអនុលោមតាមផ្នែកទី១៧ និង ផ្នែកទី២១ *សំវិធានធន និង យថាហេតុ*។

## ការរៀបចំសម្បទានសេវាកម្ម

៣៤.១២ ការរៀបចំសម្បទានសេវាកម្មគឺជាការរៀបចំដែលរដ្ឋាភិបាល ឬ ស្ថាប័នវិស័យសាធារណៈ(អ្នកផ្តល់ជំនួយ) ធ្វើកិច្ចសន្យាជាមួយប្រតិបត្តិការឯកជនដើម្បីអភិវឌ្ឍ(ឬបង្កើន)ប្រតិបត្តិនិងថែទាំ ទ្រព្យសកម្មជាហេដ្ឋារចនាសម្ព័ន្ធរបស់អ្នកផ្តល់ជំនួយ ដូចជា ផ្លូវ ស្ពាន ផ្លូវក្រោមដី ព្រលានយន្តហោះ បណ្តាញចែកចាយថាមពល ពន្ធធនាគារ ឬមន្ទីរពេទ្យ។នៅក្នុងការរៀបចំទាំងនោះ អ្នកផ្តល់ជំនួយ ត្រួតពិនិត្យឬដាក់បទបញ្ញត្តិលើសេវា កម្មណាដែលជាប្រតិបត្តិករត្រូវផ្តល់ដោយប្រើទ្រព្យសកម្មនិងតាមតម្លៃប៉ុន្មាន ក៏ដូចជាការគ្រប់គ្រងនូវផលប្រយោជន៍នៅសល់សំខាន់ៗនៅក្នុងទ្រព្យសកម្មនៅចុង បញ្ចប់នៃការរៀបចំ។

៣៤.១៣ មានខ្នង់សំខាន់ៗចំនួន២ នៃការរៀបចំសម្បទានសេវាកម្មៈ

(ក)ខ្នង់ទី១ ប្រតិបត្តិការទទួលទ្រព្យសកម្មហិរញ្ញវត្ថុ -សិទ្ធិគ្មានលក្ខខណ្ឌដើម្បីទទួលចំនួនសាច់ប្រាក់ជាក់លាក់ ឬអាចកំណត់ ឬ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតពីរដ្ឋាភិបាលក្នុងការទទួលបាន មកវិញនូវការសាងសង់ ឬ បង្កើនទ្រព្យវិស័យសាធារណៈ និង បន្ទាប់មកប្រតិបត្តិការ និងថែទាំទ្រព្យសកម្មក្នុងរយៈពេលមួយជាក់លាក់។ ខ្នង់នេះរួមបញ្ចូលការធានាដោយរដ្ឋានភិបាលដើម្បីទូទាត់ការខ្វះខាតរវាងចំនួនទឹកប្រាក់ដែលបានទទួលពីអ្នកប្រើប្រាស់សេវាសាធារណៈនិងចំនួនទឹកប្រាក់ជាក់លាក់ ឬ អាចកំណត់។

(ខ)ខ្នង់ទី២ ប្រតិបត្តិករទទួលបានទ្រព្យសកម្មអរូបី -សិទ្ធិដើម្បីដើម្បីប្រើទ្រព្យសកម្មវិស័យសាធារណៈដែលប្រតិបត្តិករសាងសង់ឬបង្កើន និង បន្ទាប់មកប្រតិបត្តិ និងថែទាំក្នុងរយៈពេលមួយជាក់លាក់។សិទ្ធិដាក់បន្ទុកចំពោះអ្នកប្រើប្រាស់គឺមិនមែនមានសិទ្ធិគ្មានលក្ខខណ្ឌដើម្បីទទួលសាច់ប្រាក់ ពីព្រោះចំនួនទឹកប្រាក់យថាហេតុរហូតដល់សាធារណៈប្រើប្រាស់សេវា។

ពេលខ្លះ កិច្ចសន្យាទោលអាចមានប្រភេទទាំងពីរ÷ រហូ តដល់រដ្ឋាភិបាលបានផ្តល់ការធានាគ្មានលក្ខ ខណ្ឌនៃការទូទាត់លើការសាងសង់ទ្រព្យសកម្មវិស័យសាធារណៈ ប្រតិបត្តិករមានទ្រព្យសកម្ម រហូតដល់ប្រតិបត្តិករត្រូវពឹងផ្អែកលើសាធារណៈដោយប្រើប្រាស់សេវាដើម្បីទទួលបានការទូទាត់ ប្រតិករមានទ្រព្យសកម្មអរូបី។

គណនេយ្យ - វិធីសាស្ត្រទ្រព្យសកម្មហិរញ្ញវត្ថុ

៣៤.១៤ ប្រតិបត្តិករត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុរហូតដល់ប្រតិបត្តិករមានសិទ្ធិឥតលក្ខខណ្ឌដើម្បីទទួលសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬ តាមការណែនាំរបស់អ្នកផ្តល់ជំនួយសម្រាប់សេវាកម្មសាងសង់។ ប្រតិបត្តិករត្រូវវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប។ ដូច្នេះប្រតិបត្តិករត្រូវអនុវត្តតាមផ្នែកទី១១ *ឧបករណ៍ហិរញ្ញវត្ថុសាមញ្ញ* និងផ្នែកទី១២ *ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត* ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ។

គណនេយ្យ -វិធីសាស្ត្រទ្រព្យសកម្មអរូបី

៣៤.១៥ ប្រតិបត្តិករត្រូវទទួលស្គាល់ទ្រព្យសកម្មអរូបីរហូតដល់ប្រតិបត្តិករទទួលសិទ្ធិ(អជ្ញាប័ណ្ណ)ដើម្បីដាក់បន្ទុកអ្នកប្រើប្រាស់សេវាសាធារណៈ។ ប្រតិបត្តិករត្រូវវាស់វែងលើកដំបូងនូវទ្រព្យសកម្មអរូបី តាមតម្លៃសមស្រប។ ដូច្នេះប្រតិបត្តិករត្រូវអនុវត្តតាមផ្នែកទី១៨ ក្នុងការធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្ម។

ចំណូលប្រតិបត្តិការ

៣៤.១៦ ប្រតិបត្តិករនៃការរៀបចំសម្បទានសេវាត្រូវទទួលស្គាល់ វាស់វែង និងលាតត្រដាងចំណូលដោយអនុលោមតាមផ្នែកទី២៣ *ចំណូល* សម្រាប់សេវាកម្មដែលប្រតិបត្តិការបំពេញ។

## ផ្នែកទី៣៥
## អន្តរកាលចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម

### វិសាលភាពនៃផ្នែកនេះ

៣៥.១ ផ្នែកនេះអនុវត្តចំពោះអង្គភាពដែលអនុវត្តស្តង់ដារនៃរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមលើកដំបូងដោយមិនគិតពីក្របខណ្ឌគណនេយ្យពីមុនជា ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិឬគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅផ្សេង(ជី អេ អេ ភី) ដូចជាស្តង់ដារគណនេយ្យជាតិ ឬ ក្របខណ្ឌផ្សេងទៀតដូចជាមូលដ្ឋានពន្ធលើប្រាក់ចំណូលក្នុងស្រុក។

៣៥.២ អង្គភាពអាចជាអង្គភាពអនុវត្តស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមលើកដំបូងតែម្តង។ដោយប្រើប្រាស់ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម អង្គភាពឈប់ប្រើប្រាស់ស្តង់ដារនេះសម្រាប់គ្រារាយការណ៍មួយឬច្រើន និងក្រោយមក ត្រូវបានតម្រូវឬជ្រើសរើស ដើម្បីប្រើប្រាស់ស្តង់ដារនេះម្តងទៀតពេលក្រោយ ការលើកលែងពិសេស ភាពសាមញ្ញនិងការតម្រូវផ្សេងទៀតនៅក្នុងផ្នែកនេះមិនអនុវត្តចំពោះការប្រើឡើងវិញ។

### ការប្រើប្រាស់លើកដំបូង

៣៥.៣ អង្គភាពអនុវត្តស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសហគ្រាសធុនតូចនិងមធ្យម លើកដំបូងត្រូវអនុវត្តផ្នែកនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងដែលស្របតាមស្តង់ដារ។

៣៥.៤ របាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលស្របតាមស្តង់ដារនេះ គឺជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដំបូងដែលអង្គភាពត្រូវធ្វើការបញ្ជាក់ឲ្យបានច្បាស់និងឥតលាក់លៀមក្នុងរបាយការណ៍ហិរញ្ញវត្ថុពីភាពអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយអនុលោមតាមស្តង់ដារនេះគឺជារបាយការណ៍ហិរញ្ញវត្ថុលើកទី១របស់អង្គភាព ប្រសិនអង្គភាព ឧទាហរណ៍:

(ក) មិនបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គ្រាមុន

(ខ) បានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុគ្រាមុនថ្មីៗបំផុតក្រោមការតម្រូវថ្នាក់ជាតិដែលមិនមានសង្គតិភាពជាមួយស្តង់ដារនេះ ឬ

(គ) បានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុគ្រាមុនថ្មីៗបំផុតស្របតាមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។

៣៥.៥ កថាខណ្ឌ ៣.១៧ នៃស្តង់ដារនេះកំណត់នូវសំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ។

៣៥.៦ កថាខណ្ឌ៣.១៤តម្រូវឲ្យអង្គភាពលាតត្រដាងក្នុងសំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញនូវព័ត៌មានប្រៀបធៀបទាក់ទងនឹងគ្រាមុនសម្រាប់ចំនួនទឹកប្រាក់រូបិយវត្ថុទាំងអស់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏ដូចជាព័ត៌មានពិពណ៌នា និងពន្យល់ប្រៀបធៀបជាក់លាក់។អង្គភាពអាចបង្ហាញព័ត៌មាន ប្រៀបធៀបនៃគ្រាមុនលើសពីមួយឆ្នាំ។ ដូច្នេះ ថ្ងៃអន្តរកាលរបស់អង្គភាពចំពោះស្តង់ដា រនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមគឺជាគ្រាដំបូងបង្អស់ដែល អង្គភាពបង្ហាញព័ត៌មានប្រៀបធៀបដោយអនុលោមតាមស្តង់ដារនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុដំបូងដែលស្របតាម ស្តង់ដារនេះ។

## នីតិវិធីសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅថ្ងៃអន្តរកាល

៣៥.៧លើកលែងដូចបានបផ្តល់ក្នុងកថាខណ្ឌ៣៥.៩៣៥.១១នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅថ្ងៃអន្តរកាលចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម(ពោលគឺការចាប់ផ្តើមនៃគ្រាដំបូងបង្អស់ដែលបានបង្ហាញ) អង្គភាពត្រូវៈ

(ក)ទទួលស្គាល់គ្រប់ទ្រព្យសកម្មនិងបំណុលដែលការទទួលស្គាល់ត្រូវបានតម្រូវដោយស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម

(ខ)មិនទទួលស្គាល់ធាតុជាទ្រព្យសកម្ម ឬបំណុលប្រសិនបើស្តង់ដារនេះមិនអនុញ្ញាតឲ្យមានការទទួលស្គាល់បែបនេះ

(គ)ចាត់ថ្នាក់ឡើងវិញនូវធាតុដែលអង្គភាពបានទទួលស្គាល់ក្រោមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុនជាប្រភេទមួយនៃទ្រព្យសកម្ម បំណុល ឬជាសមាសធាតុនៃដើមទុន ប៉ុន្តែជាប្រភេទទ្រព្យផ្សេង ពីបំណុល ឬសមាសធាតុនៃដើមទុនក្រោមស្តង់ដារនេះ និង

(ឃ) អនុវត្តស្តង់ដារនេះក្នុងការវាស់វែងទ្រព្យសកម្មនិងបំណុលដែលទទួលស្គាល់ទាំងអស់

៣៥.៨គោលនយោបាយគណនេយ្យដែលអង្គភាពប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដំបូងក្រោមស្តង់ដារនេះអាចខុសពីគោលនយោបាយដែលបានប្រើសម្រាប់ថ្ងៃដូចគ្នាដោយប្រើក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុន។ការកែសម្រួលទាំងឡាយកើតឡើងពីប្រតិបត្តិការ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌផ្សេងទៀតមុនពេលថ្ងៃអន្តរកាលចំពោះស្តង់ដារនេះ។ ដូច្នេះ អង្គភាពភាពត្រូវទទួលស្គាល់ការកែសម្រួលទាំងនោះដោយផ្ទាល់ក្នុងប្រាក់ចំណេញរក្សាទុក(ឬ ប្រសិនបើសមស្រប ខ្ទង់មួយទៀតនៃដើមទុន)នៅថ្ងៃអន្តរកាលចំពោះស្តង់ដារនេះ។

៣៥.៩នៅពេលមានការអនុវត្តស្តង់ដារនេះលើកដំបូង អង្គភាពមិនត្រូវប្តូរគណនេយ្យត្រឡប់ក្រោយដែលអង្គភាពបានអនុវត្តតាមក្រោមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុនសម្រាប់ប្រតិបត្តិការណាមួយនៃប្រតិបត្តិការខាងក្រោមៈ
(ក)**ការឈប់ទទួលស្គាល់**ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ។ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់ក្រោមក្របខណ្ឌគណនេយ្យពីមុនរបស់អង្គភាពមុនថ្ងៃអន្តរកាលមិនត្រូវបានទទួលស្គាល់

នៅពេលប្រើប្រាស់ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ផ្ទុយមកវិញសម្រាប់ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ ក្រោមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងប្រតិបត្តិការដែលបានកើតឡើងមុនពេលថ្ងៃអន្តរកាល ប៉ុន្តែទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុមិនត្រូវបានឈប់ទទួលស្គាល់ទេ ក្រោមក្របខណ្ឌគណនេយ្យពីមុនរបស់អង្គភាព អង្គភាពអាចជ្រើស

(ក) ដើម្បីឈប់ទទួលស្គាល់ពួកគេ នៅពេលប្រើប្រាស់ ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ឬ(ខ) ដើម្បីបន្តទទួលស្គាល់ពួកគេរហូតដល់ទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុត្រូវបានគេលក់ចោល ឬទូទាត់។

(ខ)គណនេយ្យទប់ស្កាត់ហានិភ័យ។អង្គភាពមិនត្រូវផ្លាស់គណនេយ្យទប់ស្កាត់ហានិភ័យមុន ថ្ងៃអន្តរកាលចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមសម្រាប់ការទស្កា ត់ហានិភ័យដែលមិនកើតឡើងតទៅទៀតនៅថ្ងៃអន្តរកាល។សម្រាប់ទំនាក់ទំនងទប់ស្កាត់ហានីយភ័យដែលកើតឡើងនៅថ្ងៃអន្តរកាល អង្គភាពត្រូវអនុវត្តតាមការតម្រូវសម្រាប់គណនេយ្យទប់ស្កាត់ហានិភ័យនៃផ្នែកទី១២ *ការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត*រួមបញ្ចូលទាំងការតម្រូវសម្រាប់ការមិនបន្តគណនេយ្យទប់ស្កាត់ហានិភ័យសម្រាប់ទំនាក់ទំនងហានិភ័យដែលមិនបានបំពេញលក្ខខណ្ឌនៃ ផ្នែកទី១២។

(គ) ការប៉ាន់ស្មានគណនេយ្យ

(ឃ) **ប្រតិបត្តិការមិនបន្ត**

(ង)វាស់វែង***ភាគកម្មអប្បបភាគ*** ការតម្រូវរបស់កថាខណ្ឌ៥.៦ ដើម្បីបែងចែកប្រាក់ចំណេញឬខាតនិងលទ្ធផលសរុបរវាងភាគកម្មអប្បបភាគ និង ម្ចាស់របស់ក្រុមហ៊ុនមេ ត្រូវបានអនុវត្តទៅអនាគត ចាប់ពីថ្ងៃអន្តរកាលចំពោះស្តង់ដាររាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់ អេស អ៊ឹម អ៊ី( ឬ ចាប់ ពីថ្ងៃពីមុនខណៈពេលដែលស្តង់ដារនេះត្រូវបានប្រើដើម្បីបង្ហាញឡើងវិញនូវការបញ្ចូលអាជីវកម្មរួមគ្នា- សូមមើលកថាខណ្ឌ ៣៥.១០)។

៣៥.១០អង្គភាពអាចប្រើការលើកលែងមួយឬច្រើនក្នុងចំណោមការលើកលែងខាងក្រោមក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងដែលស្របតាមស្តង់ដារនេះ÷

(ក) ***ការបញ្ចូលអាជីវកម្មរួមគ្នា។*** អង្គភាពអនុវត្តនៅពេលដំបូងអាចជ្រើសរើសមុនអនុវត្តផ្នែកទី ១៩ *ការបញ្ចូលអាជីវកម្មរួមគ្នានិងមូលនិធិពាណិជ្ជកម្ម*ចំពោះការបញ្ចូលអាជីវកម្មរួមគ្នាដែលដែលចូលជាធរមានមុនថ្ងៃអន្តរកាលចំពោះស្តង់ដារនេះ។ប៉ុន្តែ ប្រសិនបើអង្គភាពអនុវត្តលើកដំបូងបង្ហា ញឡើងវិញនូវការបញ្ចូលអាជីវកម្មរួមគ្នាដើម្បីអនុលោមតាមផ្នែកទី១៩ អង្គភាពត្រូវបង្ហាញឡើងវិញនូវការបញ្ចូលអាជីវកម្មរួមគ្នាទាំងអស់ពេលក្រោយ។

(ខ) ***ប្រតិបត្តិការទូទាត់សងផ្អែកលើសន្លឹកហ៊ុន*** អង្គភាពអនុវត្តលើកដំបូងមិនតម្រូវឲ្យអនុវត្តផ្នែកទី២៦ *ការទូទាត់ផ្អែកលើសន្លឹកហ៊ុន* ចំពោះឧបករណ៍ដើមទុនដែលត្រូវបានផ្តល់មុនថ្ងៃ អន្តរកាលចំពោះស្តង់ដារនេះ ឬចំពោះបំណុលដែលកើតឡើងពីប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន ដែលត្រូវបានទូទាត់មុនថ្ងៃអន្តរកាល ចំពោះស្តង់ដារនេះ។

(គ) ***តម្លៃសមស្របជាថ្លៃដើមជំនួស*** អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសដើម្បីវាស់វែង ធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ ទ្រព្យវិនិយោគ ឬ ទ្រព្យសកម្មអរូបីនៅថ្ងៃអន្តរកាលចំពោះ ស្តង់ដារនេះតាមតម្លៃសមស្រប និងប្រើប្រាស់តម្លៃសមស្របនោះជាថ្លៃដើមជំនួសនៅថ្ងៃនោះ។

(ឃ) ***ការវាយតម្លៃជាថ្លៃដើមជំនួស*** អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសប្រើការវាយតម្លៃតាម គោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅពីមុនសម្រាប់ធាតុទ្រព្យ រោងចក្រ និង បរិក្ខារ ទ្រព្យវិនិយោគ ឬ ទ្រព្យសកម្មអរូបី នៅ ឬមុនថ្ងៃអន្តរកាលចំពោះស្តង់ដារនេះជាថ្លៃដើមជំនួសនៅថ្ងៃវាយតម្លៃឡើងវិញ។

(ង) ***ភាពខុសគ្នាពីការបកប្រែប្តូកបន្ត*** ផ្នែកទី៣០ *ការបកប្រែរូបិយប័ណ្ណបរទេស* តម្រូវឲ្យអង្គភាពត្រូវចាត់ថ្នាក់ភាពខុសគ្នាពីការបកប្រែមួយចំនួនជាសមាសធាតុដើមទុនដាច់ឡែក។អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសជំនួសភាពខុសគ្នាពីការបកប្រែប្តូកបន្តសម្រាប់ប្រតិបត្តិការក្រៅប្រទេសទាំងអស់ទៅជាសូន្យនៅថ្ងៃអន្តរកាល ចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម(ពោលគឺ ការចាប់ថ្មី)។

(ច) ***របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក*** នៅពេលអង្គភាពរៀបចំ **របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក** កថាខណ្ឌ ៩.២៦ តម្រូវអង្គភាពត្រូវធ្វើគណនេយ្យកម្មសម្រាប់ការវិនិយោគក្នុងក្រុមបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ និង អង្គភាពគ្រប់គ្រងរួមគ្នា÷

(១) តាមថ្លៃដើមដកការធ្លាក់ចុះតម្លៃ ឬ

(២) **តម្លៃសមស្រប** ជាមួយនឹងការផ្លាស់ប្តូរក្នុងតម្លៃសមស្របដែលបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬ ខាត។

ប្រសិនបើអង្គភាពអនុវត្តលើកដំបូងវាស់វែងការវិនិយោគតាមថ្លៃដើម អង្គភាពត្រូវវាស់វែងការវិនិយោគនោះតាមចំនួនទឹកប្រាក់មួយនៃចំនួនទឹកប្រាក់ខាងក្រោមក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដើមគ្រាដាច់ដោយឡែកដែលបានរៀបចំដោយអនុលោមតាមស្តង់ដារនេះ÷

(១) ថ្លៃដែលបានកំណត់ដោយអនុលោមតាមផ្នែកទី៩ *របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក* ឬ

(២) ថ្លៃដើមជំនួស ដែលត្រូវជាតម្លៃសមស្របនៅថ្ងៃអន្តរកាលចំពោះ ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ឬ តម្លៃក្នុងបញ្ជី នៃគោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ ពីមុន នៅលើថ្ងៃនោះ។

(ឆ) ***ឧបករណ៍ហិរញ្ញវត្ថុផ្សំ។*** កថាខណ្ឌ ២២.១៣ តម្រូវឱ្យអង្គភាពបំបែកឧបករណ៍ហិរញ្ញវត្ថុផ្សំទៅជាសមាសធាតុបំណុលនិងដើមទុននៅថ្ងៃបោះផ្សាយ។អង្គភាពអនុវត្តលើកដំបូងមិនចាំបាច់បំបែកសមាសធាតុទាំងពីរនោះទេ ប្រសិនសមាសធាតុបំណុលមិនមាននៅសល់នៅថ្ងៃ អន្តរកាលចំពោះស្តង់ដារនេះ។

(ជ) ***ពន្ធពន្យាលើប្រាក់ចំណូល*** អង្គភាពអនុវត្តលើកដំបូងមិនត្រូវបានតម្រូវឱ្យទទួលស្គាល់ នៅថ្ងៃអន្តរកាលចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់ អេស អ៊ឹម អ៊ី **ទ្រព្យសកម្មពន្ធពន្យា** ឬ **បំណុលពន្ធពន្យា** ដែលទាក់ទងនឹងភាពខុសគ្នារវាង**មូលដ្ឋានពន្ធ**និង**តម្លៃក្នុងបញ្ជី**នៃទ្រព្យសកម្មឬបំណុលដែលការទទួលស្គាល់នៃទ្រព្យសកម្មពន្ធពន្យាទាំងនោះ ឬ បំណុលនឹងទាក់ទងនឹងចំណាយ ឬការខិតខំប្រឹងប្រែងហួសហេតុ។

(ឈ) ***ការរៀបចំសម្បទានសេវាកម្ម*** អង្គភាពអនុវត្តលើកដំបូងត្រូវបានតម្រូវឱ្យអនុវត្តកថាខណ្ឌ ៣៤.១២ - ៣៤.១៦ ចំពោះការរៀបចំសម្បទានសេវាដែលបានចុះកិច្ចព្រមព្រៀងមុនថ្ងៃប្រតិបត្តិការចំពោះស្តង់ដារនេះ។

(ញ) ***សកម្មភាពនិស្សារណ។*** អង្គភាពអនុវត្តលើកដំបូងដោយប្រើគណនេយ្យថ្លៃដើមពេញលេញក្រោម ជី អេ អេ ភី ពីមុន អាចជ្រើសរើសវាស់វែងទ្រព្យសកម្មជាប្រេងនិងឧស្ម័ន (ទ្រព្យសកម្មដែលបានប្រើក្នុងការរុករក និងការវាយតម្លៃ និង ការអភិវឌ្ឍន៍ឬ ការផលិតប្រេង និង ឧស្ម័ន) នៅថ្ងៃអន្តរកាលចំពោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់ អេស អ៊ឹម អ៊ី តាមចំនួនទឹកប្រាក់ដែលកំណត់ក្រោម គោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ ពីមុន របស់អង្គភាព។អង្គភាពត្រូវធ្វើតេស្តទ្រព្យសកម្មសម្រាប់ការធ្លាក់តម្លៃនៅថ្ងៃអន្តរកាលចំពោះស្តង់ដារនេះ ដោយអនុលោមតាមផ្នែកទី២៧*ការធ្លាក់ចុះតម្លៃទ្រព្យសកម្ម។*

(ដ) ***ការរៀបចំមានភតិសន្យា*** អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសកំណត់ថាតើការរៀបចំកំពុងមាននៅថ្ងៃអន្តរកាលចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យមមានភតិសន្យា (សូមមើលកថាខណ្ឌ ២០.៣) ដោយផ្អែកលើមូលដ្ឋានហេតុការណ៍ និង សភាពការណ៍កំពុងកើតមាននៅថ្ងៃនោះ ជាជាងពេលការរៀបចំបានចូលជាធរមាន។

(ឋ) ***ការឈប់ទទួលស្គាល់បំណុលដែលរួមបញ្ចូលក្នុងថ្លៃទ្រព្យ រោងចក្រ និងបរិក្ខារ។*** កថាខណ្ឌ ១៧.១០ (គ) បង្ហាញថា ថ្លៃដើមនៃធាតុទ្រព្យ រោងចក្រ និង បរិក្ខារ រួមបញ្ចូលការប៉ាន់ស្មានដំបូងនៃចំណាយក្នុងការរុះរើនិងយកចេញនូវធាតុ និងស្តារឡើងវិញនូវទីតាំងដែលទ្រព្យ រោងចក្រ និង បរិក្ខារតាំងនៅ កាតព្វកិច្ចដែលអង្គភាពកើតមានពេលធាតុត្រូវបានទិញ ឬជាលទ្ធផលនៃការប្រើធាតុក្នុងកំឡុងគ្រាជាក់លាក់សម្រាប់គោលបំណងជាជាងដើម្បីផលិតសន្និធិក្នុងគ្រានោះ។អង្គភាពអនុវត្តលើកដំបូងអាចជ្រើសរើសវាស់វែងសមាសធាតុ

នេះនៃថ្ងៃដើមទ្រព្យ រោងចក្រ និងបរិក្ខារនៅថ្ងៃអន្តរកាលចំពោះ ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម ជាជាងនៅថ្ងៃដែលកាតព្វកិច្ចបានកើតឡើងដំបូង។

៣៥.១១ប្រសិនបើមិនអាចអនុវត្តបានសម្រាប់អង្គភាពមួយដើម្បីបង្ហាញឡើងវិញនូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដើមគ្រានៅថ្ងៃអន្តរកាលសម្រាប់ការកែសម្រួលមួយឬច្រើនដែលតម្រូវដោយកថាខណ្ឌ៣៥.៧ អង្គភាពត្រូវអនុ វត្តកថាខណ្ឌ៣៥.៧ - ៣៥.១០ សម្រាប់ការកែតម្រូវបែបនេះក្នុងគ្រាដំបូងបង្អស់ដែលអាចអនុវត្តបាន ហើយត្រូវកំណត់ទិន្នន័យដែលបានបង្ហាញសម្រាប់គ្រាមុនដែលមិនអាចប្រៀបធៀបគ្នាបានជាមួយទិន្នន័យសម្រាប់គ្រាដែល អង្គភាពបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដំបូងដែលស្របតាមស្តង់ដារនេះ។ ប្រសិនបើមិនអាចអនុវត្តបានសម្រាប់អង្គភាពដើម្បីផ្តល់ការលាតត្រដាងបង្ហាញណាមួយដែលបានតម្រូវដោយស្តង់ដារនេះសម្រាប់គ្រាណាមួយមុនគ្រាដែលអង្គភាពរៀបចំរបាយការណ៍ហិរញ្ញវត្ថុដំបូងដែលស្របតាមស្តង់ដារនេះ ការលុបចោលណាមួយត្រូវបានលាតត្រដាង។

## ការលាតត្រដាង

---

### ការពន្យល់នៃអន្តរកាលចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម

៣៥.១២ អង្គភាពត្រូវពន្យល់ពីរបៀបដែលអន្តរកាលពីក្របខណ្ឌរបាយការណ៍ហិរញ្ញវត្ថុមុនទៅស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម បានប៉ះពាល់ស្ថានភាពហិរញ្ញវត្ថុលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់។

### ការសម្របសម្រួល

៣៥.១៣ ដើម្បីអនុលោមកថាខណ្ឌ៣៥.១២ របាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់អង្គភាពដែលបានរៀបចំដោយអនុវត្តស្តង់ដារនេះត្រូវរួមបញ្ចូលៈ

(ក) ការរៀបរាប់ពីលក្ខណៈនៃការប្តូរគោលនយោបាយគណនេយ្យនីមួយៗ។

(ខ)ការសម្របសម្រួលដើមទុនរបស់អង្គភាពដែលបានកំណត់ដោយអនុលោមតាមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុមុនចំពោះដើមទុនដែលបានកំណត់ដោយអនុលោមតាមស្តង់ដារនេះសម្រាប់ ថ្ងៃទាំងពីរខាងក្រោមៈ

(១) ថ្ងៃអន្តរកាលចំពោះស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូចនិងមធ្យម និង

(២)ចុងបញ្ចប់នៃគ្រាចុងក្រោយដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំថ្មីៗបំផុតរបស់អង្គភាពដោយអនុលោមតាមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុមុន។

(គ)ការសម្របសម្រួលប្រាក់ចំណេញឬខាតដែលបានកំណត់ដោយអនុលោមតាមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុមុនសម្រាប់គ្រាចុងក្រោយបំផុតក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំថ្មីៗបំផុតរបស់អង្គភាពចំពោះចំណេញ ឬ ខាតរបស់អង្គភាពដែលបានកំណត់ដោយអនុលោមតាម ស្តង់ដារនេះសម្រាប់គ្រាដូចគ្នា។

៣៥.១៤ប្រសិនបើអង្គភាពបានដឹងពីកំហុសឆ្គងដែលបានកើតឡើងក្រោមក្របខណ្ឌរាយការណ៍ហិរញ្ញវត្ថុពីមុន ការសម្របសម្រួលដែលតម្រូវដោយកថាខណ្ឌ៣៥.១៣(ខ) និង(គ) ត្រូវញែកចេញការកែតម្រូវ នៃកំហុសទាំងនោះពីការផ្លាស់ប្តូរក្នុងគោលនយោបាយគណនេយ្យ។

៣៥.១៥ប្រសិនបើអង្គភាពមិនបង្ហាញរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គ្រាមុន អង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងដែលស្របតាមស្តង់ដារនេះ។

## សន្ទានុក្រម

| | |
|---|---|
| **គោលនយោបាយគណនេយ្យ** | គោលការណ៍ មូលដ្ឋាន ទ្រឹស្តី ច្បាប់ និងការអនុវត្តដែលបានអនុវត្តដោយអង្គភាព ក្នុងការរៀបចំនិងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ |
| **មូលដ្ឋានគណនេយ្យបង្គរ** | ឥទ្ធិពលនៃប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងទៀតត្រូវបានទទួលស្គាល់ពេលដែល ប្រតិបត្តិការ ឬ ព្រឹត្តិការនោះកើតឡើង (និងមិនមែនសាច់ប្រាក់ ឬសាច់ប្រាក់ សមមូល ត្រូវបានទទួល ឬបង់) និង ពួកគេត្រូវបានកត់ត្រាក្នុងឯកសារគណនេយ្យ និង រាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុនៃគ្រាដែលព្រឹត្តិការណ៍ ឬ ប្រតិបត្តិការ នោះកើតឡើង។ |
| **ការអវត្តមានមានតំលៃតបស្នង បូកបន្ត** | អវត្តមានមានតំលៃតបស្នងដែលត្រូវបានយោងទៅអនាគត និង អាចត្រូវបានប្រើក្នុ អនាគតប្រសិនសិទ្ធិទទួលនៃគ្រាបច្ចុប្បន្នមិនត្រូវបានប្រើពេញលេញ |
| **សកម្មភាពកសិកម្ម** | ការគ្រប់គ្រងដោយអង្គភាពនៃការបំលែងជីវសាស្ត្រនៃទ្រព្យសកម្មជីវសាស្ត្រសំរាប់ លក់ ទៅជាផលិតផលកសិកម្មឬ ទ្រព្យសកម្មជីវសាស្ត្របន្ថែមទៀត ។ |
| **ផលិតផលកសិកម្ម** | ផលិតផលនៃទ្រព្យសកម្មជីវសាស្ត្ររបស់អង្គភាពដែលបានប្រមូល |
| **ការរំលស់** | ការបែងចែកជាប្រព័ន្ធនៃចំនួនទឹកប្រាក់ដែលអាចរំលស់បាននៃទ្រព្យសកម្មលើ អាយុកាលប្រើប្រាស់ ។ |
| **ថ្លៃដើមទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែល បានរំលស់** | ចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាម តំលៃទទួលស្គាល់ដំបូងដកការសងប្រាក់ដើម បូក ឬ ដក ការរំលស់បូកបន្តដោយ ប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដំបូង និង ចំនួន ទឹកប្រាក់នៅកាលកំណត់ និង ដក ការបន្ថយណាមួយ (ដោយផ្ទាល់ ឬ តាមរយៈ ការប្រើគណនីដកបង្ការ) សំរាប់ការធ្លាក់ចុះតំលៃ ឬ ភាពមិនអាចប្រមូលបាន។ |
| **ទ្រព្យសកម្ម** | ធនធានដែលគ្រប់គ្រងដោយអង្គភាពដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល និងពី អត្ថប្រយោជន៍សេដ្ឋកិច្ចត្រូវបានរំពឹងថានឹងហូរមកកាន់អង្គភាព។ |
| **ក្រុមហ៊ុនញាតិសម្ព័ន្ធ** | ជាអង្គភាព រួមបញ្ចូលអង្គភាពរួមបញ្ចូលគ្នា ដូចជាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលអ្នក វិនិយោគ មិនមានឥទ្ធិពលសំខាន់ លើក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬមិនមានភាគកម្មក្នុង ក្រុមហ៊ុនរួមទុន ។ |
| **ទ្រព្យសកម្មជីវសាស្ត្រ** | ជាសត្វ ឬ រុក្ខជាតិដែលមានជីវិត |
| **បន្ទុកលើប្រាក់កំចី** | ជាការប្រាក់និងចំណាយផ្សេងទៀតដែលបានកើតឡើងដោយអង្គភាពក្នុងការខ្ចី មូលនិធិ |

**អាជីវកម្ម** ជាសំណុំសកម្មភាពបញ្ចូលគ្នានិងទ្រព្យសកម្មដែលត្រូវបានគេប្រើប្រាស់និងគ្រប់គ្រង សំរាប់គោលបំណងផ្តល់:

(ក) ចំណេញទៅឲ្យអ្នកវិនិយោគ ឬ

(ខ) ចំណាយទាប ឬ អត្ថប្រយោជន៍សេដ្ឋកិច្ចផ្សេងទៀតដោយផ្ទាល់ និង តាម សមាមាត្រទៅឲ្យអ្នកកាន់គោលនយោបាយ ឬ អ្នកចូលរួម។

អាជីវកម្មជាទូទៅរួមមានធាតុចូល ដំណើរការដែលបានប្រើចំពោះធាតុចូល និង ធា ចេញដែលត្រូវបានប្រើ ឬនឹងត្រូវប្រើដើម្បីបង្កើតចំណូល។ ប្រសិនបើកេរ្តិ៍ឈ្មោះកើ មានក្នុងសំណុំសកម្មភាពនិងទ្រព្យសកម្មផ្ទេរ សំណុំផ្ទេរទាំងនោះត្រូវបានសន្មតថាជា អាជីវកម្ម។

**ការបញ្ចូលអាជីវកម្ម រួមគ្នា** ជាការបញ្ចូលជាមួយគ្នានូវអង្គភាពឬអាជីវកម្មដោយឡែកទៅជាអង្គភាពរាយការណ៍ តែមួយ។

**តំលៃក្នុងបញ្ជី** ជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្ម ឬបំណុលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ ។

**សាច់ប្រាក់** សាច់ប្រាក់ក្នុងដៃ និង ប្រាក់បញ្ញើតាមតំរូវការ

**សាច់ប្រាក់សមមូល** ជាការវិនិយោគរយៈពេលខ្លី មានភាពងាយជាសាច់ប្រាក់ខ្ពស់ដែលអាចបំលែងទៅចំនួ សាច់ប្រាក់បានដឹងជាមុន និងជាកម្មវត្ថុចំពោះហានិភ័យមិនសំខាន់នៃការប្រែប្រួល តំលៃ។

**លំហូរសាច់ប្រាក់** ជាលំហូរសាច់ប្រាក់ និងសាច់ប្រាក់សមមូលចូលនិងចេញ

**អង្គភាពរកសាច់ប្រាក់** ជាក្រុមទ្រព្យសកម្មដែលអាចកំណត់បានតូចបំផុត ដែលបង្កើតលំហូរសាច់ប្រាក់ចូល ដែលពឹងផ្អែកខ្លាំងលើលំហូរសាច់ប្រាក់ចូលពីទ្រព្យសកម្មផ្សេងទៀតឬក្រុមទ្រព្យ សកម្ម។

**ប្រតិបត្តិការទូទាត់ផ្អែកលើចំណែកហ៊ុនដោយប្រើសាច់ប្រាក់** ជាប្រតិបត្តិការទូទាត់ផ្អែកលើចំណែកហ៊ុន ដែលអង្គភាពទិញទំនិញ ឬ សេវាកម្ម ដោយកើតឡើងបំណុលដើម្បីផ្ទេរសាច់ប្រាក់ឬទ្រព្យសកម្មផ្សេងទៀតទៅឲ្យអ្នក ផ្គត់ផ្គង់នៃទំនិញឬសេវាកម្មទាំងនោះ សំរាប់ចំនួនទឹកប្រាក់ដែលផ្អែកលើថ្លៃ(ឬតំលៃ) នៃភាគហ៊ុនរបស់អង្គភាពឬឧបករណ៍ដើមទុនផ្សេងទៀតរបស់អង្គភាព។

**ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ** ជាការកែសំរួលនៃតំលៃក្នុងបញ្ជីនៃទ្រព្យសកម្មឬបំណុល ឬ ចំនួនទឹកប្រាក់នៃការ ប្រើទ្រព្យសកម្មប្រចាំឆ្នាំ ដែលកើតពីការវាយតំលៃនៃស្ថានភាពបច្ចុប្បន្ននិង អត្ថប្រយោជន៍អនាគតដែលរំពឹងទុកនិងកាតព្វកិច្ចដែលភ្ជាប់មកជាមួយនឹង ទ្រព្យសកម្ម និងបំណុល។ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យកើតចេញពីព័ត៌មាន ថ្មី ឬ ការអភិវឌ្ឍន៍ថ្មី ដូច្នេះហើយមិនមែនជាការកែតំរូវកំហុសឆ្គងទេ។

**ថ្នាក់ទ្រព្យសកម្ម** ជាក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈនិងប្រើប្រាស់ស្រដៀងគ្នា ក្នុងប្រតិបត្តិការរបស់អង្គភាព។

**របាយការណ៍ហិរញ្ញវត្ថុ បញ្ចូលគ្នា** ជារបាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពពីរឬច្រើនដែលបានគ្រប់គ្រងដោយអ្នកវិនិយោ តែមួយ។

**សមាសធាតុរបស់អង្គភាព** ប្រតិបត្តិការនិងលំហូរសាច់ប្រាក់ដែលអាចត្រូវបាញែកឲ្យដាច់ច្បាស់លាស់ ជាលក្ខណៈប្រតិបត្តិការ និងសំរាប់គោលបំណងរាយការណ៍ហិរញ្ញវត្ថុ ពីផ្នែកផ្សេងទៀតរបស់អង្គភាព។

**ឧបករណ៍ហិរញ្ញវត្ថុផ្សំ** ជាឧបករណ៍ហិរញ្ញវត្ថុដែលមានទាំងសមាសធាតុបំណុល និង ដើមទុន តាមទស្សនៈរបស់អ្នកបោះផ្សាយ។

**របាយការណ៍ហិរញ្ញវត្ថុរួម** ជារបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនមេ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានបង្ហាញជារបាយការណ៍ហិរញ្ញវត្ថុនៃអង្គភាពសេដ្ឋកិច្ចតែមួយ ។

**កិច្ចសន្យាសាងសង់** ជាកិច្ចសន្យាដែលបានចរចារជាពិសេសសំរាប់ការសាងសង់ទ្រព្យសកម្មឬ ការបញ្ចូល គ្នានៃទ្រព្យសកម្មដែលមានទំនាក់ទំនងនឹងគ្នាជិតស្និត ឬ អាស្រ័យលើគ្នាទៅវិញទៅម ក្នុងក្របខណ្ឌរចនាបទ បច្ចេកវិជ្ជា និង មុខងារឬគោលបំណងនិងការប្រើប្រាស់ចុងក្រោយនៃទ្រព្យសកម្ម។

**កាតព្វកិច្ចសាងសង់** ជាកាតព្វកិច្ចដែលទទួលបានពីសកម្មភាពអង្គភាពដែលៈ

(ក)ដោយគំរូនៃការអនុវត្តពីអតីតកាល គោ លនយោបាយដែលបានផ្សាយ របាយការណ៍ជាក់លាក់បច្ចុប្បន្នមានភាពគ្រប់គ្រាន់ អង្គភាពបានបង្ហាញទៅឲ្យភាគីផ្សេងទៀតដែលអង្គភាពនឹងទទួលយកការទទួលខុសត្រូវជាក់លាក់ និង

(ខ) ជាលទ្ធផល អង្គភាពបានបង្កើតឡើងនូវការរពឹងទុកដ៏មានសុពលភាព លើផ្នែកនៃភាគីផ្សេងទៀត ដែលនឹងទទួលយកនូវការទទួលខុសត្រូវទាំងនោះ។

**ទ្រព្យសកម្មយថាហេតុ** ជាទ្រព្យសកម្មដែលអាចកើតឡើងពីព្រឹត្តិការណ៍អតីតកាល និង អត្ថិភាពរបស់វានឹងត្រូវបញ្ជាក់តែដោយការកើតមានឡើង ឬការមិនកើតមានឡើងនៃព្រឹត្តិការណ៍អនាគ មិនច្បាស់លាស់ច្រើន មិនឋិតក្នុងការគ្រប់គ្រថដោយអង្គភាព។

**បំណុលយថាហេតុ** (ក)ជាបំណុលដែលអាចកើតមានឡើងចេញពីព្រឹត្តិការអតីតកាលនិងអត្ថិភាពរបស់វ នឹងត្រូវបានបញ្ជាក់តែដោយការកើតមានឡើង ឬការមិនកើតមានឡើងនៃព្រឹត្តិការណ៍ អនាគតមិនច្បាស់លាស់ច្រើន មិនឋិតក្នុងការគ្រប់គ្រថដោយអង្គភាពឬ

(ខ)កាតព្វកិច្ចបច្ចុប្បន្នដែលកើតឡើងពីព្រឹត្តិការអតីតកាល ប៉ុន្តែមិនត្រូវបានទទួលស្គាល់ពីព្រោះ÷

(១)មិនប្រហែលថាការហូរចេញនូវធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ចនឹង

ត្រូវបានតំរូវឱ្យទូទាត់សងកាតព្វកិច្ច ឬ

(២)ចំនួនទឹកប្រាក់នៃកាតព្វកិច្ចមិនអាចត្រូវបានវាស់វែងជាមួយភាពជឿជាក់គ្រប់គ្រាន់។

| | |
|---|---|
| **ការគ្រប់គ្រង(នៃអង្គភាព)** | ជាអំណាចដើម្បីគ្រប់គ្រងគោលនយោបាយប្រតិបត្តិការនិងហិរញ្ញវត្ថុរបស់អង្គភាពដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គភាព។ |
| **ពន្ធបច្ចុប្បន្ន** | ជាប្រាក់ពន្ធលើប្រាក់ចំណូលត្រូវបង់(ត្រូវទទួលបាន)ទាក់ទងនឹងប្រាក់ចំណេញជាប់ពន្ធ(ខាតប្រាក់ពន្ធ) សំរាប់គ្រាបច្ចុប្បន្នឬគ្រារាយការណ៍អតីតកាល។ |
| **ថ្ងៃអន្តរកាលចំពោះស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម** | ជាដើមគ្រាដំបូងដែលអង្គភាពបង្ហាញព័ត៌មានហិរញ្ញវត្ថុប្រៀបធៀបពេញលេញតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកដំបូងដែលអនុលោមស្តង់ដានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម |
| **ពន្ធពន្យា** | ជាពន្ធលើប្រាក់ចំណូលត្រូវបង់ (ត្រូវទទួលបានមកវិញ) ទាក់ទងនឹងប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) សំរាប់គ្រារាយការណ៍អនាគត ដែលកើតចេញពីប្រតិបត្តិការ ឬព្រឹត្តិការណ៍អតីតកាល។ |
| **ទ្រព្យសកម្មពន្ធពន្យា** | ជាពន្ធលើប្រាក់ចំណូលដែលត្រូវទទួលបានក្នុងគ្រារាយការណ៍អនាគត ទាក់ទង នឹង<br>(ក) ភាពខុសគ្នាបណ្តោះអាសន្ន<br>(ខ) ការយោងបន្តនៃការខាតប្រាក់មិនបានប្រើ និង<br>(គ) ការយោងបន្តនៃឥណទានពន្ធដែលមិនបានប្រើ |
| **បំណុលពន្ធពន្យា** | ពន្ធលើប្រាក់ចំណូលដែលត្រូវបង់ក្នុងគ្រារាយការណ៍អនាគតទាក់ទងនឹងភាពខុសគ្នាបណ្តោះអសន្ន។ |
| **បំណុលអត្ថប្រយោជន៍កំណត់** | ជាតំលៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍កំណត់នៅថ្ងៃរាយការណ៍ដកតំលៃសមស្របនៃថ្ងៃរាយការណ៍នៃទ្រព្យសកម្មផែនការ (ប្រសិនបើមាន)ដកកាតព្វកិច្ចដែលនឹងត្រូវទូទាត់ដោយផ្ទាល់។ |
| **កាតព្វកិច្ចអត្ថប្រយោជន៍ កំណត់ (តំលៃសមស្របនៃ)** | ជាតំលៃបច្ចុប្បន្ន ដោយពុំមានការដកចេញទ្រព្យសកម្មផែនការ ដកចេញការទូទាត់អនាគតដែលបានតំរូវឱ្យទូទាត់កាតព្វកិច្ចកើតចេញពីសេវារបស់នយោជិកក្នុងគ្រាបច្ចុប្បន្ននិងអតីតកាល ។ |
| **ផែនការអត្ថប្រយោជន៍កំណត់** | ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ ក្រៅពីផែនការវិភាគទានកំណត់។ |
| **ផែនការវិភាគទានកំណត់** | ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារក្រោមអង្គភាពដែលបង់វិភាគទានថេរទៅឱ្យអង្គភាពដោយឡែក (មូលនិធិ) និង មិនមានកាតព្វកិច្ចសាសង់ ឬស្របច្បាប់ដើម្បីបង់វិភាគទានបន្ថែមឬដើម្បីធ្វើការទូទាត់ប្រយោជន៍ផ្ទាល់ចំពោះនិយោជិក |

ប្រសិនបើមូលនិធិមិនមានទ្រព្យសកម្មគ្រប់គ្រាន់ដើម្បីទូទាត់អត្ថប្រយោជន៍និយោជិក ទាំងអស់ ទាក់ទងនឹងសេវាកម្មរបស់និយោជិកក្នុងគ្រាបច្ចុប្បន្ននិងអតីតកាល។

**ចំនួនទឹកប្រាក់ដែលអាចរំលស់បាន** ជាថ្លៃដើមទ្រព្យសកម្មឬចំនួនទឹកប្រាក់ផ្សេងទៀតដែលជំនួសថ្លៃដើម (ក្នុងរបាយការណ៍ ហិរញ្ញវត្ថុ ដកតំលៃកាកសំណល់។

**រំលស់** ជាការបែងជាប្រព័ន្ធនៃចំនួនទឹកប្រាក់ដែលអាចរំលស់បាននៃទ្រព្យសកម្មលើអាយុកលប្រើប្រាស់របស់ទ្រព្យសកម្ម ។

**ការឈប់ទទួលស្គាល់** ជាការយកចេញនូវទ្រព្យសកម្មឬបំណុលដែលបានទទួលស្គាល់ពីមុន ពីរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព។

**ការអភិវឌ្ឍន៍** ជាការអនុវត្តការស្រាវជ្រាវឬចំណេះដឹងផ្សេងទៀតចំពោះផែនការឬការរចនាសម្រាប់ការផលិតសំភារៈ ឧបករណ៍ ផលិតផល ដំណើការ ប្រព័ន្ធ ឬ សេវាកម្មថ្មី ឬកែលំអថ្មី មុនពេលចាប់ផ្ដើមផលិត ឬប្រើប្រាស់ក្នុងគោលបំណងពាណិជ្ជកម្ម ។

**ប្រតិបតិការមិនបន្ត** សមាសធាតុរបស់អង្គភាពដែលត្រូវបានលក់ចោល ឬ រក្សាទុកសំរាប់លក់ និង

(ក) តំណាងខ្សែសង្វាក់អាជីវកម្មសំខាន់ដោយឡែកឬតំបន់ប្រតិបត្តិការតាមភូមិសាស្រ្ត

(ខ) ជាផ្នែកនៃផែនការសំរបសំរួលទោលដើម្បីលក់ចោលនូវសង្វាក់អាជីវកម្មសំខាន់ៗដោយឡែក ឬ តំបន់ប្រតិបត្តិការតាមភូមិសាស្រ្ត

(គ) ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញផ្ដាច់មុខក្នុងគោលបំណងលក់វិញ

**វិធីសាស្រ្តការប្រាក់ប្រសិទ្ធិភាព** ជាវិធីសាស្រ្ដីនៃការគណនាថ្លៃដើមបានរំលស់នៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ (ឬក្រុមនៃទ្រព្យសកម្មឬបំណុលហិរញ្ញវត្ថុ) និងជាវិធីសាស្រ្តនៃការបែងចែកចំណូលការប្រាក់ ឬ ចំណាយការប្រាក់ លើគ្រាពាក់ព័ន្ធ។

**អត្រាការប្រាក់ប្រសិទ្ធិភាព** អត្រាដែលធ្វើអប្បហារជាក់ស្តែងនូវប្រាក់ចំណូល ឬចំណាយប៉ាន់ស្មានទាពេលអនាគត សម្រាប់រយៈពេញអាយុកាលប៉ាន់ស្មាននៃឧបករណ៍ហិរញ្ញវត្ថុ ឬ នៅពេលសមស្រប រយៈពេលខ្លីចំពោះតំលៃក្នុងបញ្ជីសុទ្ធនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

**ប្រសិទ្ធិនៃការទប់ស្កាត់** ជាកំរិតដែលការផ្លាស់ប្ដូរក្នុងតំលៃសមស្របឬលំហូរសាច់ប្រាក់នៃធាតុបានទប់ស្កាត់ដែលកំណត់ឲ្យបានចំពោះហានិភ័យដែលបានទប់ស្កាត់ត្រូវបានកាត់កងដោយការផ្លាស់ប្ដូរ ក្នុងតំលៃសមស្របឬលំហូរសាច់ប្រាក់នៃឧបករណ៍ទប់ស្កាត់ហានិភ័យ។

**អត្ថប្រយោជន៍និយោជិក** គ្រប់ទំរង់ទាំងអស់នៃការតបស្នងដែលបានផ្តល់ដោយអង្គភាពក្នុងការដោះដូរសេវាដែលផ្តល់ដោយនិយោជិក។

| | |
|---|---|
| **ដើមទុន** | ភាគកម្មនៅសល់ក្នុងទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីដកចេញបំណុលទាំងអស់របស់អង្គ ភាព។ |
| **ប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុន ទូទាត់ដោយប្រើដើមទុន** | ជាប្រតិបត្តិការទូទាត់ផ្អែកលើសន្លឹកហ៊ុនដែលអង្គភាពទទួលទំនិញឬសេវាជាការតបស្នង សំរាប់ឧបករណ៍ដើមទុនរបស់អង្គភាព (រួមមានភាគហ៊ុន ឬ សិទ្ធិពិសេសទិញភាគហ៊ុន) |
| **កំហុសឆ្គង** | ជាការលុបចេញពី និង កំហុសក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់គ្រាមុនមួយឬច្រើន ដែលកើតចេញពីការខកខានមិនបានប្រើ ឬ ការប្រើខុសនៃព័ត៌មានដែលជឿជាក់បាន ដែលៈ<br>(ក) មានពេលរបាយការណ៍ហិរញ្ញវត្ថុសំរាប់គ្រាទាំងនោះត្រូវបានអនុញ្ញាតបោះផ្សាយ និង<br>(ខ) អាចត្រូវបានរពឹងថានឹងត្រូវបានទទួលនិងពិចារណាក្នុងការរៀបចំនិងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។ |
| **ចំណាយ** | ការថយចុះក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចកំឡុងគ្រារាយការណ៍ក្នុងទំរង់នៃការហូរចេញ ឬការសឹករិចរិលនៃទ្រព្យសកម្ម ឬ ការកើតមានឡើងនៃបំណុលដែលផ្តល់ឲ្យមានការថយចុះក្នុងដើមទុន លើកលែងចំណាយទាំងឡាយដែលទាក់ទងនឹងការបែងចែកទៅឲ្យអ្នកវិនិយោគដើមទុន។ |
| **ការបង្ហាញត្រឹមត្រូវ** | ការបង្ហាញត្រឹមត្រូវនៃឥទ្ធិពលនៃប្រតិបត្តិការ ព្រឹត្តិការណ៍និងលក្ខខណ្ឌផ្សេងទៀត ដោយអនុលោមតាមនិយមន័យ និង លក្ខណៈវិនិច្ឆ័យទទួលស្គាល់សំរាប់ទ្រព្យសកម្ម បំណុល ចំណូល និង ចំណាយ។ |
| **តំលៃសមស្រប** | ចំនួនទឹកប្រាក់ដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ បំណុលត្រូវបានទូទាត់ ឬ ឧបករណ៍ដើមទុនត្រូវបានផ្តល់អាចត្រូវបានដោះដូរ រវាងភាគីដែលមានការយល់ដឹង និង ដោយការស្ម័គ្រចិត្ត ក្នុងប្រតិបត្តិការបណ្តោយដៃ។ |
| **តំលៃសមស្របដកថ្លៃដើមដើម្បីលក់** | ចំនួនទឹកប្រាក់ដែលអាចសំរេចបានពីការលក់ទ្រព្យសកម្ម ឬ អង្គភាពរកសាច់ប្រាក់ក្នុងប្រតិបត្តិការបណ្តោយដៃ រវាងភាគីដែលមានចំណេះដឹង និង ដោយស្ម័គ្រចិត្ត ដកចេញ នូវចំណាយលក់ចោល។ |
| **ភតិសន្យាហិរញ្ញវត្ថុ** | ភតិសន្យាដែលផ្ទេរហានិភ័យ និង ផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះការកាន់កាប់ទ្រព្យសកម្ម។កម្មសិទ្ធិអាច ឬមិនអាចត្រូវបានផ្ទេរនៅពេលចុងក្រោយ។ភតិសន្យាដែលមិនមែនជាភតសិន្យាហិរញ្ញវត្ថុគឺជាភតិសន្យាប្រតិបត្តិការ |

**ទ្រព្យសកម្មហិរញ្ញវត្ថុ** ទ្រព្យសកម្មណាដែល ÷

(ក) សាច់ប្រាក់

(ខ) ឧបករណ៍ដើមទុនរបស់អង្គភាពមួយទៀត

(គ) សិទ្ធិតាមកិច្ចសន្យាៈ

1. នឹងទទួលសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតពីអង្គភាព ឬ
2. នឹងដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាព ផ្សេងទៀតក្រោមលក្ខខណ្ឌដែលមានផលល្អចំពោះអង្គភាព ឬ

(ឃ)កិច្ចសន្យាដែលនឹងឬអាចនឹងទូទាត់ក្នុងឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាព និងៈ

1. ក្រោមអង្គភាពដែលត្រូវបាន ឬអាចត្រូវបានតំរូវឲ្យទទួលនូវចំនួនអថេរ នៃឧបករណ៍ដើមទុនផ្ទាល់ខ្លួនរបស់អង្គភាព ឬ
2. ដែលនឹង ឬ អាចត្រូវបានទូទាត់ក្រៅដោយដោះដូរនៃចំនួនសាច់ប្រាក់ ថេរឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតសំរាប់ចំនួនថេរនៃឧបករណ៍ ដើមទុនផ្ទាល់របស់អង្គភាព។សំរាប់គោលបំណងនេះឧបករណ៍ដើមទុន ផ្ទាល់របស់អង្គភាមិនបញ្ចូលឧបករណ៍ទាំងឡាយណាដែលជាកិច្ចសន្យា ខ្លួនឯងសំរាប់ការទទួលឬការប្រគល់ឧបករណ៍ដើមទុនផ្ទាល់របស់ អង្គភាពនាពេលអនាគត។

**ឧបករណ៍ហិរញ្ញវត្ថុ** ជាកិច្ចសន្យាដែលផ្តល់ការកើនឡើងចំពោះទ្រព្យសកម្មហិរញ្ញវត្ថុរបស់អង្គភាពមួយ និង បំណុលហិរញ្ញវត្ថុ ឬ ឧបករណ៍ដើមទុនរបស់អង្គភាពមួយទៀត។

**បំណុលហិរញ្ញវត្ថុ** ជាបំណុលណាដែលៈ

(ក) កាតព្វកិច្ចតាមកិច្ចសន្យាៈ

1. ដើម្បីប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតទៅឲ្យ អង្គភាពផ្សេងទៀត ឬ
2. ដើម្បីដោះដូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុជាមួយអង្គភាព មួយទៀតក្រោមលក្ខខណ្ឌដែលមិនអំណោយផលខ្លាំងចំពោះអង្គភាព ឬ

(ខ)កិច្ចសន្យាដែលនឹងឬអាចត្រូវបានទូទាត់ក្នុងឧបករណ៍ដើមទុនផ្ទាល់របស់ អង្គភាព និងៈ

1. ក្រោមអង្គភាពដែលមានកាតព្វកិច្ច ឬ អាចមានកាតព្វកិច្ចប្រគល់ចំនួន អថេរនៃឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាព ឬ

2. នឹងឬអាចត្រូវបានទូទាត់លើកលែងដោយការផ្លាស់ដោះដូរនៃចំនួនសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយទៀតសំរាប់ចំនួនថេរនៃឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាព។សំរាប់គោលបំណងនេះ ឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាពមិនបញ្ចូលឧបករណ៍ទាំងឡាយណាដែលជាកិច្ចសន្យាខ្លួនឯងសំរាប់ការទទួល ឬ ការប្រគល់ឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាពនាពេលអនាគត។

**ស្ថានភាពហិ ញ្ញវត្ថុ** ជាទំនាក់ទំនងនៃទ្រព្យសកម្ម បំណុល និង ដើមទុន របស់អង្គភាពមួយដែលត្រូវបានរាយការណ៍ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**របាយការណ៍ហិរញ្ញវត្ថុ** ជាការបង្ហាញនៃស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព។

**សកម្មភាពហិរញ្ញប្បទាន** ជាសកម្មភាពដែលបង្ហាញពីការផ្លាស់ប្តូរទំហំនិងសមាសភាពនៃដើមទុនធ្វើវិភាគទាន និង ការខ្ចីរបស់អង្គភាព។

**ការសន្យារបស់ក្រុមហ៊ុន** ជាកិច្ចព្រមព្រៀងដែលបានចងសំរាប់ការដោះដូរនូវបរិមាណធនធានជាក់លាក់នៅថ្ងៃឬថ្ងៃផ្សេងទៀតអនាគតជាក់លាក់។

**អង្គភាពអនុវត្តលើកដំបូងនូវស្តង់ដារនៃការរៀបចំរបាយការណ ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម** ជាអង្គភាពដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំលើកដំបូងដែលអនុលោមតាមស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យមដោយមិនគិតពីក្របខណ្ឌគណនេយ្យពីមុនថាជាស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ឬ ស្តង់ដារគណនេយ្យផ្សេងទៀត។

**ប្រតិបត្តិការព្យាករណ៍** ជាប្រតិបត្តិការអនាគតដែលបានរំពឹងទុកមិនមែនជាការប្តេជ្ញាទេ។

**ស្តង់ដារនៃការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិ** ជា ស្តង់ដារ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែល មិនមែនជាស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**រូបិយប័ណ្ណមុខងារ** ជារូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចសំខាន់ ដែលអង្គភាពមានប្រតិបត្តិការ។

**ការផ្តល់មូលនិធិ (នៃអត្ថប្រយោជន៍ក្រោយបំពេញការងារ)** ជាវិភាគទានដោយអង្គភាព និង ជួលកាលដោយនិយោជិក ចូលទៅក្នុងអង្គភាព ឬ មូលនិធិ ដែលដាច់ដោយឡែកស្របច្បាប់ពីអង្គភាពរាយការណ៍ ហើយនិយោជិកត្រូវបានបង់ពីអង្គភាពរាយការណ៍នោះ

**ចំណេញ** ជាកើនឡើងក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបំពេញនិយមន័យនៃចំណូល ប៉ុន្តែមិនមែន ចំណូលពីប្រតិបត្តិការ។

**របាយការណ៍ហិរញ្ញវត្ថុ ដែលមានគោលបំណងទូទៅ** ជារបាយការណ៍ហិរញ្ញវត្ថុដែលសំដៅទៅតំរូវការនៃព័ត៌មានហិរញ្ញវត្ថុទូទៅរបស់អ្នកប្រើប្រាស់ផ្សេងៗដែលមិនមានជំហរដើម្បីទាមទាររបាយការណ៍ដែលបានរៀបចំដើម្បីបំពេញតំរូវការព័ត៌មានជាក់លាក់របស់គេ។

**និរន្តភាពអង្គភាព** អង្គភាពមួយមាននិរន្តភាពលុះត្រាតែគណៈគ្រប់គ្រងមិនមានបំណងជំរះបញ្ជីអង្គភាព ឬ បញ្ឈប់ការរកស៊ី ឬ មិនមានជំរើសច្បាស់លាស់ ប៉ុន្តែត្រូវធ្វើបែបនេះ។

**មូលនិធិពាណិជ្ជកម្ម** ជាអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតដែលកើតឡើងពីទ្រព្យសកម្មដែលមិនអាចត្រូវបានកំណត់ និង ទទួលស្គាល់ដាច់ដោយឡែក។

**អំណោយរបស់រដ្ឋាភិបាល** ជាជំនួយដោយរដ្ឋាភិបាលក្នុងទំរង់នៃការផ្ទេរធនធានចំពោះអង្គភាពជាថ្នូរនៃការអនុលោមទៅនឹងលក្ខខណ្ឌអតីតកាលឬអនាគតដែលទាក់ទិននឹងសកម្មភាពប្រតិបត្តិការរបស់អង្គភាព។

**ថ្ងៃផ្ដល់អំណោយ** ថ្ងៃដែលអង្គភាពមួយ និង អង្គភាពមួយទៀត (រួមទាំងនិយោជិក) យល់ព្រមចំពោះការរៀបចំទូទាត់ផ្អែកលើសន្លឹកហ៊ុន នៅពេលដែលអង្គភាព និង ភាគីម្ខាងទៀតមានភាពយោគយល់រួមគ្នានៃលក្ខខណ្ឌនៃការរៀបចំ។នៅថ្ងៃផ្ដល់អំណោយ អង្គភាពផ្ដល់ឲ្យ ភាគីម្ខាងទៀតនូវសិទ្ធិចំពោះសាច់ប្រាក់ ទ្រព្យសកម្មផ្សេងទៀត ឬ ឧបករណ៍ដើមទុនរបស់អង្គភាព ដោយដឹងថាលក្ខខណ្ឌផ្ទេរជាក់លាក់ត្រូវបានបំពេញ ប្រសិនបើមាន។ ប្រសិនបើកិច្ចព្រម ព្រៀងជាកម្មវត្ថុចំពោះដំណើរការអនុម័ត (ឧទាហរណ៍ ដោយម្ចាស់ភាគហ៊ុន) ថ្ងៃផ្ដល់អំណោយ គឺជាថ្ងៃដែលការអនុម័តត្រូវបានទទួល។

**ការវិនិយោគដុល ក្នុងភតិសន្យា** ជាការសរុបបញ្ចូលគ្នានៃៈ

(ក)ការទូទាត់ភតិសន្យាអប្បបរមាដែលត្រូវទទួលដោយភតិបតីក្រោមភតិសន្យាហិរញ្ញវត្ថុ និង

(ខ) តំលៃសល់ចុងក្រោយមិនធានាដែលបង្គរទុកចំពោះភតិបតី។

**ក្រុម** ជាក្រុមហ៊ុនមេ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**ធាតុទប់ស្កាត់ហានិភ័យ** សំរាប់គោលបំណងនៃគណនេយ្យទប់ស្កាត់ហានិភ័យដោយសហគ្រាសធុនតូចនិងមធ្យម ក្រោមផ្នែកទី ១២នៃស្តង់ដារនេះ ធាតុទប់ស្កាត់ហានិភ័យគឺៈ

(ក) ហានិភ័យអត្រាការប្រាក់នៃឧបករណ៍បំណុលដែលវាស់វែងតាមថ្លៃដើមរំលស់

(ខ)ហានិភ័យអត្រាការប្រាក់ ឬ ហានីភ័យអត្រាប្តូរប្រាក់ ក្នុងកិច្ចសន្យារបស់ក្រុមហ៊ុន ឬ ប្រតិបត្តិការព្យាករណ៍ដែលអាចកើតឡើងខ្ពស់

(គ) ហានិភ័យតំលៃនៃទំនិញដែលអង្គភាពមាន ឬ ក្នុងកិច្ចសន្យារបស់អង្គភាព ឬ ប្រតិបត្តិការព្យាករណ៍ដែលអាចកើតឡើងខ្ពស់ដើម្បីទិញ ឬ លក់ទំនិញ ឬ

(ឃ)ហានិភ័យអត្រាប្តូរប្រាក់បរទេសជាការវិនិយោគសុទ្ធក្នុងប្រតិបត្តិការក្រៅប្រទេស

| | |
|---|---|
| **ឧបករណ៍ទប់ស្កាត់ហានីភ័យ** | សំរាប់គោលបំណងនៃគណនេយ្យទប់ស្កាត់ហានិភ័យពិសេសក្រោមផ្នែកទី១២ នៃស្តងដារនេះ ឧបករណ៍ទប់ស្កាត់ហានិភ័យគឺជាឧបករណ៍ហិរញ្ញវត្ថុដែលបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោមៈ<br>(ក) វាជាដោះដូរការប្រាក់ ការដោះដូររូបិយប័ណ្ណបរទេស កិច្ចសន្យាដោះដូររូបិយប័ណ្ណបរទេសអនាគត ឬ កិច្ចសន្យាដោះដូរទំនិញអនាគតដែលត្រូវបានរំពឹងថាមានប្រសិទ្ធិខ្ពស់ក្នុងការកាត់កងហានិភ័យដែលបានកំណត់ក្នុងកថាខណ្ឌ ១២.១៧ ដែលត្រូវបានចាត់ទុកជា ហានិភ័យបានទប់ស្កាត់។<br>(ខ)វាជាប់ព័ន្ធភាគីខាងក្រៅចំពោះអង្គភាពរាយការណ៍ (អង្គភាពខាងក្រៅចំពោះក្រុមអង្គភាពនីមួយៗ ឬ ជាចំណែកដែលត្រូវបាយរាយការណ៍)<br>(គ) ចំនួនទឹកប្រាក់ដែលបានដឹងស្មើនឹងចំនួនទឹកប្រាក់នៃប្រាក់ដើមដែលបានកំណ ឬ ចំនួនទឹកប្រាក់ដែលដឹងនៃធាតុបានទប់ស្កាត់ហានីភ័យ។<br>(ឃ) វាមានថ្ងៃផុតកំណត់ជាក់លាក់មិនលើសពី<br>1. ការផុតកំណត់នៃឧបករណ៍ហិរញ្ញវត្ថុដែលកំពុងត្រូវបានទប់ស្កាត់<br>2. ការទូទាត់ដែលបានរំពឹងទុកនៃការទិញទំនិញ ឬ ការសន្យាលក់ ឬ<br>3. ការកើតមានឡើងនៃរូបិយប័ណ្ណបរទេសព្យាករណ៍ដែលអាចកើតមានខ្ពស់ ឬ ប្រតិបត្តិការទំនិញដែលកំពុងត្រូវបានទប់ស្កាត់។<br>(ង) វាពុំមានការបង់មុន ការបញ្ឈប់មុន ឬ ការពន្យាទេ<br>អង្គភាពមួយដែលជ្រើសរើសអនុវត្ត ស្តង់ដារគណនេយ្យអន្តរជាតិ ៣៩ នៅក្នុងគណនេយ្យសំរាប់ឧបករណ៍ហិរញ្ញវត្ថុត្រូវអនុវត្តនិយមន័យនៃឧបករណ៍ទប់ស្កាត់ហានីភ័យ នៅក្នុងស្តង់ដានោះ ជាជាងប្រេីនិយមន័យនេះ។ |
| **ភវនីយកំរិតខ្ពស់** | ទំនងច្រើនជាងភវនីយ |
| **ការខាតបង់ដោយសារការធ្លាក់ចុះតំលៃ** | ជាចំនួនទឹកប្រាក់ដែលតំលៃក្នុងបញ្ជីនៃទ្រព្យសកម្មមួយ លើសតំលៃលក់ដកថ្លៃដើមដើម្បីបញ្ចប់និងលក់ (ក) ក្នុងករណីសន្និធិ ឬ (ខ) តំលៃសមស្របដកថ្លៃដើមដើម្បីលក់ ក្នុងករណីទ្រព្យសកម្មផ្សេងទៀត។ |
| **ដែលមិនអាចបាន** | ការអនុវត្តការតំរូវមិនអនុវត្តបានពេលដែលអង្គភាពមិនអាចអនុវត្តការតំរូវនោះ បន្ទាប់ពី ការខិតខំព្យាយាមគ្រប់មធ្យោបាយដើម្បីអនុវត្ត។ |
| **អត្រាការប្រាក់ដែលដាក់បន្ទុក** | ជាការកំណត់ច្បាស់លាស់ច្រើននៃៈ<br>(ក) អត្រាធម្មតាសំរាប់ឧបករណ៍ស្រដៀងគ្នានៃអ្នកបោះផ្សាយជាមួយកំរិតជឿជាក់ស្រដៀងគ្នា ឬ<br>(ខ)អត្រាការប្រាក់ដែលធ្វើអប្បហារចំនួនទឹកប្រាក់ធម្មតានៃឧបករណ៍ទៅតំលៃលក់ |

ជាសាច់ប្រាក់បច្ចុប្បន្ននៃទំនិញ ឬ សេវាកម្ម។

**ចំណូល** ជាការកើនឡើងក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចកំឡុងគ្រារាយការណ៍ក្នុងទំរង់នៃការហូរចូល ឬ ការធ្វើឲ្យប្រសើរឡើងនៃទ្រព្យសកម្ម ឬ ការថយចុះក្នុងដើមទុន លើកលែងចំណូលដែលទាក់ ទងនឹងវិភាគទានពីអ្នកវិនិយោគដើមទុន។

**របាយការណ៍លទ្ធផល** ជារបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញគ្រប់ធាតុទាំងអស់នៃចំណូល និងចំណាយដែលបានទទួលស្គាល់ក្នុងគ្រារាយការណ៍ដោយមិនបញ្ចូលធាតុនៃចំណូលសរុបផ្សេងទៀត។

**ពន្ធលើប្រាក់ចំណូល** គ្រប់ពន្ធក្នុងស្រុកនិងក្រៅស្រុកដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។ពន្ធក៏បញ្ចូលផងដែរនូវ ពន្ធទាំងឡាយដូចជាពន្ធកាត់ទុក ដែលត្រូវបង់ដោយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន ពេលដែលបែងចែកទៅឲ្យអង្គភា រាយការណ៍។

**កិច្ចសន្យាធានារ៉ាប់រង** ជាកិច្ចសន្យាដែលភាគីមួយ (អ្នកបោះផ្សាយ) ទទួលយកនូវហានិភ័យធានារ៉ាប់រងសំខាន់ៗ ពីភាគីមួយទៀត (អ្នកកាន់គោលនយោបាយ) ដោយយល់ព្រមបង់ឲ្យអ្នកកាន់គោលនយោបាយ ប្រសិនបើព្រឹត្តិការណ៍នាពេលអនាគតមិនច្បាស់លាស់ (ព្រឹត្តិការណ៍ដែលបានធានា) ប៉ះពាល់ ធ្ងន់ធ្ងរដល់អ្នកកាន់គោលនយោបាយ។

**ទ្រព្យសកម្មអរូបី** ជាទ្រព្យសកម្មមិនមែនរូបិយវត្ថុដែលអាចកំណត់បាន ដោយគ្មានរូបរាងច្បាស់លាស់។ ទ្រព្យសកម្មនេះអាចកំណត់បាននៅពេលដែលទ្រព្យសកម្មនោះ
(ក) ដាច់ដោយឡែក ពោលគឺអាចបំបែក ឬបែងចែកពីអង្គភាពនិងអាចត្រូវបាន លក់ ត្រូវបានផ្ទេរ ផ្តល់អជ្ញាប័ណ្ណ ជួល ឬដោះដូរនីមួយៗឬរួមគ្នាជាមួយកិច្ចសន្យាទាក់ទិននឹងទ្រព្យសកម្ម ឬ បំណុល ឬ
(ខ)កើតឡើងពីសិទ្ធិស្របច្បាប់តាមកិច្ចសន្យា ឬ ផ្សេងទៀត ដោយមិនគិតពីសិទ្ធិទាំងនោះអាចផ្ទេរបាន ឬ បំបែកចេញពីអង្គភាព ឬ ពីសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀត។

**អត្រាការប្រាក់បង្កប់ក្នុងភតិសន្យ** នៅពេលចាប់ផ្តើមភតិសន្យាអត្រាអប្បហារធ្វើឲ្យតំលៃបច្ចុប្បន្នសរុបនៃ(ក) ការទូទា ភតិសន្យា អប្បបរមា និង (ខ) តំលៃកាកសំណល់មិនធានាស្មើនឹងផលបូកនៃ (១) តំលៃសមស្របនៃទ្រព្យសកម្មបានភតិសន្យា (២) ចំណាយផ្ទាល់ដំបូងរបស់ភតិបតី។

**របាយការណ៍ហិរញ្ញវត្ថុចន្លោះពេ** ជារបាយការណ៍ហិរញ្ញវត្ថុដែលមានសំណុំរបាយការណ៍ហិរញ្ញវត្ថុពេញលេញ ឬ សំណ នៃរបាយការណ៍ហិរញ្ញវត្ថុសំរាប់គ្រាបណ្តោះអាសន្ន។

**គ្រាបណ្តោះអាសន្ន** គ្រារាយការណ៍ហិរញ្ញវត្ថុដែលខ្លីជាងឆ្នាំហិរញ្ញវត្ថុពេញលេញ។

**ស្តង់ដារនៃការរៀបចំរបាយការណ ហិរញ្ញវត្ថុអន្តរជាតិ** ស្តង់ដារនិងការបកស្រាយដែលបានកំណត់ដោយស្តង់ដារគណនេយ្យអន្តរជាតិ។ ស្តង់ដារនិងការបកស្រាយទាំងនោះរួមមានៈ

(ក) ស្តង់ដារនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ

(ខ) ស្តង់ដារគណនេយ្យអន្តរជាតិ និង

(គ) ការបកស្រាយដែលបង្កើតឡើងដោយគណៈកម្មការបកស្រាយការរាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ឬ អតីតគណៈកម្មការបកស្រាយអចិន្ត្រៃយ៍។

**តំលៃមជ្ឈតិកៈ** ជាភាពខុសគ្នារវាងតំលៃសមស្របនៃភាគហ៊ុនដែលភាគីម្ខាងទៀតមាន(មានលក្ខ ណ្ឌឬគ្មានលក្ខ ណ្ឌ)សិទ្ធិដើម្បីទិញ ឬ ដែលអង្គភាពមានសិទ្ធិទទួល និងតំលៃ (ប្រសិនបើមាន) ភាគី ម្ខាងទៀតត្រូវបាន (ឬត្រូវបានតំរូវ) ឲ្យសងភាគហ៊ុនទាំងនោះ។ ឧទាហរណ៍ សិទ្ធិពិសេសទិញ ភាគហ៊ុនតាមតំលៃអនុវត្ត ១៥ ឯកត្តារូបិយវត្ថុលើភាគដែលមានតំលៃសមស្រប២០ឯកត្តារូបិយវត្ថុមានតំលៃមជ្ឈតិកៈ៥ឯកត្តារូបិយវត្ថុ

**សន្និធិ** ទ្រព្យសកម្មៈ

(ក) រក្សាទុកសំរាប់លក់ក្នុងដំណើរការអាជីវកម្មធម្មតា

(ខ) ក្នុងដំណើរការនៃការផលិតសំរាប់លក់ ឬ

(គ) ក្នុងទំរង់នៃវត្ថុធាតុដើម ឬ សំភារៈត្រូវប្រើក្នុងដំណើរការផលិតកម្ម ឬ ក្នុងការផ្តល់សេវាកម្ម

**សកម្មភាពវិនិយោគ** ការទិញនិងការលក់ចោលទ្រព្យសកម្មរយៈវែង និង ការវិនិយោគផ្សេងទៀតដែលមិនបញ្ចូលក្នុងសមមូលសាច់ប្រាក់។

**ទ្រព្យវិនិយោគ** ជាទ្រព្យ (ដី ឬ អគារ ឬ ផ្នែកនៃអគារ ឬ ទាំងពីរ) ដែលរក្សាទុកដោយម្ចាស់ ឬ ដោយភតិកៈ ក្រោមភតិសន្យាហិរញ្ញវត្ថុ ដើម្បីរកចំណូលតាមរយៈការជួល ឬ សំរាប់ការបង្កើនដើមទុន ឬ ទាំងពីរ លើកលែងតែៈ

(ក)ការប្រើប្រាស់ក្នុងការផលិតឬផ្គត់ផ្គង់ទំនិញឬសេវាឬសំរាប់គោលបំណងរដ្ឋបាល ឬ

(ខ) លក់ក្នុងដំណើរការអជីវកម្មធម្មតា

**ការគ្រប់គ្រងរួម** ជាការចែករំលែកនូវការគ្រប់គ្រងដែលបានព្រមព្រៀងតាមកិច្ចសន្យាលើសកម្មភាពសេដ្ឋកិច្ច។វាកើតឡើងតែពេលដែលការសំរេចចិត្តប្រតិបត្តិការនិងហិរញ្ញវត្ថុជាយុទ្ធសាស្ត្រទាក់ទងនឹងសកម្មភាពដែលតំរូវមានការយល់ព្រមពីភាគីដែលចែករំលែកការគ្រប់គ្រង (អ្នករួមទុន) ។

**ការរួមទុន** ជាការរៀបចំតាមកិច្ចសន្យាដែលភាគីពីរ ឬច្រើនអនុវត្តសកម្មភាពសេដ្ឋកិច្ចដែលជាកម្មវត្ថុនៃការគ្រប់គ្រងរួម។ការរួមទុនអាចបង្កើតជាទំរង់នៃប្រតិបត្តិការគ្រប់គ្រងរួម ការគ្រប់គ្រងទ្រព្យសកម្មរួម ឬ ការគ្រប់គ្រងអង្គភាពរួម។

**អង្គភាពគ្រប់គ្រងរួមគ្នា** ជាការរួមទុនដែលទាក់ទងនឹងការបង្កើតកិច្ចសហប្រតិបត្តិការវាងដៃគូ ឬ អង្គភាពផ្សេងទៀតដែលអ្នករួមទុននីមួយៗមានភាគកម្ម។ អង្គភាពប្រតិបត្តិតាមរបៀបដូចគ្នានឹងអង្គភាពផ្សេងទៀតដែរលើកលែងថា ការរៀបចំតាមកិច្ចសន្យារវាងអ្នកចូលរួមទុនបង្កើតការគ្រប់គ្រងរួមលើសមកម្មភាពសេដ្ឋកិច្ចរបស់អង្គភាព។

**ភតិសន្យា** ជាការរៀបចំដែលភតិបតីផ្ទេរទៅឲ្យភតិកៈសិទ្ធិដើម្បីប្រើទ្រព្យសកម្ម ក្នុងការតបស្នងជាការ ទូទាត់ ឬ ការទូទាត់ជាដំណាក់កាល ក្នុងគ្រាមួយដែលបានព្រមព្រៀងគ្នា។

**អត្រាការប្រាក់កំចីបន្ថែមរបស់ភតិកៈ** ជាអត្រាការប្រាក់ដែលភតិកៈត្រូវបង់លើភតិសន្យាស្រដៀងគ្នាឬបើមិនអាចកំណត់បាន នៅពេលចាប់ផ្តើមភតិសន្យា អត្រាដែលភតិកៈចំណាយដើម្បីខ្ចីប្រាក់ក្នុងរយៈស្រដៀងគ្នានិងមានធានាស្រដៀងគ្នានូវមូលនិធិដែលចាំបាច់ដើម្បីទិញទ្រព្យកម្ម។

**បំណុល** កាតព្វកិច្ចបច្ចុប្បន្នរបស់អង្គភាពដែលកើតពីព្រឹត្តិការអតីកាល ការទូទាត់ដែលត្រូវបានរំពឹងទុក ថា នឹងនាំឲ្យមានហូរចេញពីអង្គភាពនូវធនធានសេដ្ឋកិច្ច។

**កំចីត្រូវសង** ជាបំណុលហិរញ្ញវត្ថុជាជាងបំណុលពាណិជ្ជកម្មរយៈពេលខ្លីតាមលក្ខខណ្ឌឥណទានធម្មតា

**ភាពជាសារវ័ន្ត** ការលុបចោល ឬការបង្ហាញខុសនៃធាតុមានភាពជាសារវ័ន្តប្រសិនបើពួកគេ នីមួយៗ ឬរួមគ្នា មានឥទ្ធិពលលើការសំរេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ។ ភាពជាសារវ័ន្តផ្អែកលើទំហំ និង លក្ខណៈនៃការលុនចោល ឬការបង្ហាញខុសដែលវិនិច្ឆ័យក្នុងលក្ខខណ្ឌជុំវិញ។ទំហំឬ ប្រភេទនៃធាតុ ឬ ការបញ្ចូលគ្នានៃធាតុទាំងពីរ អាចជា កត្តាកំណត់។

**ការវាស់វែង** ជាដំណើរការនៃការកំណត់បរិមាណទឹកប្រាក់ជារូបិយវត្ថុរបស់ធាតុនៃរបាយការណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ និង កត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និង របាយការណ៍លទ្ធផលសរុប។

**ធាតុរូបិយវត្ថុ** ជាឯកត្តារូបិយវត្ថុដែលរក្សាទុក និង ទ្រព្យនិងបំណុលត្រូវទទួល ឬ ទូទាត់ជាចំនួនឯកត្តា រូបិយវត្ថុថេរឬអាចកំណត់បាន។

| | |
|---|---|
| **ផែនការ (អត្ថប្រយោជន៍) ពហុនិយោជក** | ផែនការវិភាគទានកំណត់ (ក្រៅពីផែនការរបស់រដ្ឋ) ឬ ផែនការអត្ថប្រយោជន៍កំណត់ (ក្រៅពីផែនការរបស់រដ្ឋ) ដែលៈ<br>(ក) ប្រមូលផ្ដុំទ្រព្យសកម្មដែលបានធ្វើវិភាគទានដោយអង្គភាពផ្សេងៗដែលមិនស្ថិតក្រោមការគ្រប់គ្រងរួម និង<br>(ខ) ប្រើទ្រព្យសកម្មទាំងនោះដើម្បីផ្ដល់អត្ថប្រយោជន៍ទៅឱ្យនិយោជិកច្រើនជាងមួយអង្គភាព ដោយឈរលើមូលដ្ឋានដែលកំរិតវិភាគទាននិងអត្ថប្រយោជន៍ត្រូវបានកំណត់ដោយគ្មានទាក់ទងនឹងអត្តសញ្ញាណនៃអង្គភាពដែលជួលនិយោជិកដែលពាក់ព័ន្ធ។ |
| **ការវិនិយោគពិតក្នុង ភតិសន្យា** | ការវិនិយោគដុលក្នុងភតិសន្យាដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ដែលបង្កប់នៅក្នុង ភតិសន្យា។ |
| **ភាគកម្មអប្បភាគ** | ដើមទុនក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនអាចបែងចែកដោយផ្ទាល់ឬដោយប្រយោលទៅក្រុមហ៊ុនមេ។ |
| **កំណត់សំគាល់ (ចំពោះរបាយការណ៍ហិរញ្ញវត្ថុ)** | កំណត់សំគាល់រួមមានព័ត៌មានបន្ថែមលើព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍លទ្ធផលសរុប របាយការណ៍លទ្ធផល (ប្រសិនបើបានបង្ហាញ) របាយការណ៍លទ្ធផលនិងប្រាក់ចំណេញរក្សាទុកបញ្ចូលគ្នា (ប្រសិនបើបានបង្ហាញ) របាយការណ៍ប្រែប្រួលដើមទុន និងរបាយការណ៍លំហូរសាច់ប្រាក់។ កំណត់សំគាល់ផ្ដល់ការពន្យល់លំអិត ឬ ការបំបែកធាតុទាំងឡាយដែលបានបង្ហាញក្នុងរបាយការណ៍ទាំងនោះ និង ព័ត៌មានអំពីធាតុ ដែលមិនបំពេញការទទួលស្គាល់ក្នុងរបាយការណ៍ទាំងនោះ។ |
| **បរិមា ណជាសញ្ញាណ** | បរិមាណនៃឯកតារូបិយវត្ថុ ភាគហ៊ុន  ល្អី ផោន ឬ ឯកតាផ្សេងទៀតដែលបញ្ជាក់ក្នុងកិច្ចសន្យា ឧបករណ៍ហិរញ្ញវត្ថុ។ |
| **គោលបំណងនៃរបាយការណ៍ហិរញ្ញវត្ថុ** | ដើម្បីផ្ដល់ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍សំរាប់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើជាច្រើន ដែលមានគោលជំហរទាមទាររបាយការណ៍ដែលរៀបចំដើម្បីបំពេញសេចក្ដីត្រូវការ ព័ត៌មានជាក់លាក់។ |
| **កិច្ចសន្យាដែលនាំឱ្យមានការខាតបង់** | ជាកិច្ចសន្យាដែលចំណាយមិនអាចជៀសវាងបានដើម្បីបំពេញកាតព្វកិច្ចក្រោមកិច្ចសន្យាលើសពីអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានរំពឹងទុកថានឹងត្រូវទទួលក្រោមកិច្ចសន្យានោះ។ |
| **សកម្មភាពប្រតិបត្តិការ** | សកម្មភាពផលិតចំណូលសំខាន់ៗរបស់អង្គភាពដែលមិនមែនជាសកម្មភាពវិនិយោគ ឬសកម្មភាពហិរញ្ញវត្ថុ។ |

**ភតិសន្យាប្រតិបត្តិការ** ជាភតិសន្យាដែលមិនផ្ទេរហានិភ័យនិងផលប្រយោជន៍សំខាន់ៗទាំងអស់ចំពោះកម្មសិទ្ធិ។ ភតិសន្យាដែលមិនមែនជាភតិសន្យាប្រតិបត្តិការគឺជាភតិសន្យាហិរញ្ញវត្ថុ។

**ចំណែកប្រតិបត្តិការ** ចំណែកប្រតិបត្តិការគឺជាសមាសធាតុនៃអង្គភាពមួយៈ

(ក)ដែលជាប់ទាក់ទងក្នុងសកម្មភាពដែលអង្គភាពអាចរកចំណូល និងកើតឡើងចំណាយ (រួមបញ្ចូលទាំងចំណូល និង ចំណាយដែលទាក់ទងនឹងប្រតិបត្តិការជាមួយសមាសធាតុផ្សេងទៀតរបស់អង្គភាពដូចគ្នា)

(ខ)លទ្ធផលប្រតិបត្តិការរបស់សមាសធាតុទាំងនោះជាប្រចាំត្រូវបានពិនិត្យឡើងវិញ ដោយប្រធានអ្នកធ្វើសេចក្តីសំរេចចិត្តរបស់អង្គភាព ដើម្បីធ្វើការសំរេចចិត្ត អំពីធនធាន ដែលត្រូវបែងចែកទៅចំណែក និង វាយតំលៃពីការបំពេញការងារ និង

(គ) សំរាប់ព័ត៌មានហិរញ្ញវត្ថុដាច់ៗពីគ្នាមាន។

**លទ្ធផលសរុបផ្សេងទៀត** ធាតុនៃចំណូលនិងចំណាយ (រួមមានការកែសំរួលការចាត់ថ្នាក់ឡើងវិញ) ដែលមិនត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ដែលបានត ម្រូវឬ អនុញ្ញាតដោយស្តង់ដារនេះ។

**ម្ចាស់** ជាអ្នកកាន់ឧបករណ៍ហិរញ្ញវត្ថុដែលបានចាត់ថ្នាក់ជាដើមទុន។

**ក្រុមហ៊ុនមេ** ជាអង្គភាពមួយដែលមានក្រុមហ៊ុនបុត្រសម្ព័ន្ធមួយឬច្រើន

**លទ្ធផល** ជាទំនាក់ទំនងនៃចំណូល និង ចំណាយរបស់អង្គភាព ដែលបានរាយការណ៍នៅក្នុងរបាយការណ៍លទ្ធផលសរុប។

**ទ្រព្យសកម្ម ផែនការ (នៃផែនការអត្ថប្រយោជន៍និយោជិក)** (ក) ទ្រព្យសកម្មដែលរក្សាទុកដោយក្រុមហ៊ុនមូលនិធិអត្ថប្រយោជន៍រយៈពេលវែង និង

(ខ) គោលនយោបាយធានារ៉ាប់រងកំពុងដំណើរការ

**អត្ថប្រយោជន៍ក្រោយបំពេញការងារ** ជាអត្ថប្រយោជន៍និយោជិក (លើកលែងអត្ថប្រយោជន៍ពេលបញ្ឈប់ការងារ) ដែលត្រូវសង បន្ទាប់ពីការបញ្ចប់ការងារ។

**ផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារ** ការរៀបចំផ្លូវការឬមិនផ្លូវការដែលអង្គភាពផ្តល់អត្ថប្រយោជន៍ក្រោយបំពេញការងារសម្រាប់និយោជិកមួយ ឬច្រើននាក់។

**តំលៃបច្ចុប្បន្ន** ការប៉ាន់ស្មានបច្ចុប្បន្ននៃតំលៃធ្វើអប្បហារបច្ចុប្បន្ននៃលំហូរសាច់ប្រាក់សុទ្ធអនាគតក្នុងដំណើរការអាជីវកម្មធម្មតា។

**រូបិយប័ណ្ណសំរាប់បង្ហាញ** ជារូបិយប័ណ្ណដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានដាក់បង្ហាញ។

**ភវនីយភាព** ប្រហែលច្រើនជាងមិនប្រហែល

**ចំណេញ ឬ ខាត** ជាចំណូលសរុប ដកចំណាយសរុប ដោយមិនបញ្ចូលសមាសធាតុនៃចំណូលផ្សេងៗទៀត។

**វិធីសាស្ត្រឥណទានឯកត្តាព្យាករណ៍** ជាវិធីសាស្ត្រវាយតំលៃជាក់ស្តែងដែលបង្ហាញគ្រាសេវាកម្មនីមួយៗដែលនាំឲ្យមានការកើនឡើងចំពោះឯកត្តាបន្ថែមនៃសិទ្ធិទទួលអត្ថប្រយោជន៍ និងវាស់វែងឯកត្តានីមួយៗដាច់ដោយឡែក ដើម្បីបង្កើតកាតព្វកិច្ចចុងក្រោយ (ជួលកាលត្រូវបានគេហៅថាជាវិធីសាស្ត្រអត្ថប្រយោជន៍បង្គរដែលគិតរួចជាស្រេចលើសេវាកម្ម ឬជាអត្ថប្រយោជន៍/ឆ្នាំនៃវិធិសាស្ត្រសេវាកម្ម)។

**ទ្រព្យ រោងចក្រ និង បរិក្ខារ** ទ្រព្យសកម្មរូបីដែលៈ

(ក) ត្រូវបានរក្សាទុកសំរាប់ប្រើប្រាស់ក្នុងផលិតកម្ម ឬផ្គត់ផ្គង់សេវា សំរាប់ការជួលទៅឲ្យអ្នកដទៃ សំរាប់វិនិយោគ ឬ សំរាប់គោលបំណងរដ្ឋបាល និង

(ខ) ត្រូវបានរំពឹងថានឹងប្រើក្នុងកំឡុងច្រើនជាងមួយគ្រា។

**ការអនុវត្តទៅមុខ (នៃការផ្លាស់ប្តូ គោលនយោបាយគណនេយ្យ)** ការអនុវត្តគោលនយោបាយគណនេយ្យថ្មីចំពោះប្រតិបត្តិការ ព្រឹត្តិការ ណ៍ និងលក្ខខណ្ឌផ្សេង ទៀតដែលបានកើតឡើងបន្ទាប់ពីថ្ងៃដែលគោលនយោបាយត្រូវបានប្តូរ។

**សំវិធានធន** ជាបំណុលនៃចំនួនពេលវេលា ឬ ចំនួនទឹកប្រាក់មិនច្បាស់លាស់

**ការប្រុងប្រយ័ត្ន** ការបញ្ចូលនៃកំរិតនៃការប្រុងប្រយ័ត្នក្នុងការអនុវត្តនៃការវិនិច្ឆ័យដែលចាំបាច់ក្នុងការធ្វើ ការប៉ាន់ស្មានដែលបានតំរូវក្រោមលក្ខខណ្ឌនៃភាពមិនប្រាកដប្រជា ទ្រព្យសកម្មបែបនេះ ឬចំណូលមិនត្រូវបានបង្ហាញលើស និង បំណុល ឬ ចំណាយមិនត្រូវបានបង្ហាញខ្វះ។

**ការទទួលខុសត្រូវជាសាធារណៈ** ជាការទទួលខុសត្រូវចំពោះអ្នកផ្តល់ធនធានដែលមានសក្តានុពល និង បច្ចុប្បន្ន និងអ្នកខាងក្រៅផ្សេងទៀត ចំពោះអង្គភាពដែលធ្វើការ សម្រេចចិត្តផ្នែកសេដ្ឋកិច្ច ប៉ុន្តែមិនមានជំហរដើម្បីទាមទាររបាយការណ៍ដែលរៀបចំដើម្បីបំពេញតំរូវការព័ត៌មានជាក់លាក់។ អង្គភាពមាន ការទទួលខុសត្រូវជាសាធារណៈ ប្រសិនៈ

(ក) ឧបករណ៍ដើមទុន ឬបំណុលត្រូវបានជួញដូរក្នុងទីផ្សារជាសាធារណៈ ឬ វាស្ថិតក្នុងដំណើរការនៃការបោះផ្សាយឧបករណ៍បែបនេះសំរាប់ការជួញដូរក្នុងទីផ្សារសាធារណៈ (ការជួញដូរមូលបត្របរទេស ឬ ក្នុងស្រុក ឬ ទីផ្សារមូលបត្រតាមអន្តរការីរួមមានទីផ្សារក្នុងតំបន់ និងក្នុងស្រុក) ឬ

(ខ) អង្គភាពកាន់កាប់ទ្រព្យសកម្មក្នុងសមត្ថភាពជាអ្នកធនាសំរាប់ក្រុមខាងក្រៅដែលជាអាជីវកម្មមួយក្នុងចំណោមអាជីវកម្មសំខាន់។ ធម្មតា នេះជាករណី សម្រាប់ធនាគារ ស ហភាពឥណទាន ក្រុមហ៊ុនធានារ៉ាប់រង អន្តរការីមូលបត្រ មូលនិធិសង្គហធន និង ធានាគារវិនិយោគ។

| | |
|---|---|
| **ជួញដូរជាសាធារណៈ (ឧបករណ៍បំណុល ឬដើមទុន)** | បានជួញដូរ ឬ ក្នុងដំណើរការបោះផ្សាយសំរាប់ជួញដូរ ក្នុងទីផ្សារសាធារណៈ (ការជួញដូរ ភាគហ៊ុនបរទេស ឬក្នុងស្រុក ឬ ទីផ្សារមូលបត្រតាមអន្តរការី រួមបញ្ចូលទាំងទីផ្សារក្នុងតំបន់ និង ក្នុងស្រុក)។ |
| **ការទទួលស្គាល់** | ដំណើរការនៃការបញ្ចូលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬ របាយការណ៍លទ្ធផលសរុបនូវធាតុមួយដែលបំពេញនិយមន័យនៃសមាសធាតុ និង ធាតុនោះបំពេញលក្ខខណ្ឌដូចខាងក្រោមៈ<br>(ក) វាប្រហែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចអនាគតភ្ជាប់នឹងធាតុនោះនឹងហូរមូលមក ឬ ពីអង្គភាព និង<br>(ខ) ធាតុមានថ្លៃដើម ឬ តំលៃដែលអាចត្រូវបានវាស់វែងដោយជឿជាក់។ |
| **ចំនួនទឹកប្រាក់អាចទទួលបានមកវិញ** | ជាតំលៃខ្ពស់ជាងនៃតំលៃសមស្របដកចំណាយដើម្បីលក់នៃទ្រព្យសកម្ម (អង្គភាពរកសាច់ប្រាក់) និង តំលៃប្រើប្រាស់របស់វា។ |
| **ភាគីពាក់ព័ន្ធ** | ភាគីពាក់ព័ន្ធគឺជាបុគ្គល ឬ អង្គភាពដែលមានទំនាក់ទំនងទៅអង្គភាពមួយទៀតដែលរៀបចំ របាយការណ៍ហិរញ្ញវត្ថុ (អង្គភាពរាយការណ៍) ។<br>(ក) បុគ្គលម្នាក់ ឬ សមាជិកជិតស្និតនៃគគ្រួសាររបស់បុគ្គលដែលមានទំនាក់ទំនងទៅនឹងអង្គភាពរាយការណ៍ ប្រសិនបើអង្គភាពនោះ៰:<br>1. ជាសមាជិកម្នាក់នៃបុគ្គលិកគ្រប់គ្រងសំខាន់នៃអង្គភាពរាយការណ៍ ឬ នៃក្រុម ហ៊ុនមេរបស់អង្គភាពរាយការណ៍<br>2. មានការគ្រប់គ្រងលើអង្គភាពរាយការណ៍ ឬ<br>3. ការការគ្រប់គ្រងរួម ឬ ឥទ្ធិពលសំខាន់លើអង្គភាពរាយការណ៍ ឬ មានអំណាចបោះឆ្នោតសំខាន់នៅក្នុងអង្គភាពនោះ។<br>(ខ) អង្គភាពមានទំនាក់ទំនងទៅនឹងអង្គភាពរាយការណ៍ប្រសិនបើលក្ខខណ្ឌខាងក្រោមអនុវត្តៈ<br>1. អង្គភាព និង អង្គភាពរាយការណ៍ជាសមាជិកនៃក្រុមជាមួយគ្នា (ដែលមានន័យថាក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដូចគ្នាមានទំនាក់ទំនងនឹងអង្គភាពផ្សេងទៀត)។<br>2. អង្គភាពជាក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុននៃអង្គភាពផ្សេងទៀត (ឬ ជាសមាជិកនៃក្រុមដែលអង្គភាពផ្សេងទៀតជាសមាជិក)។<br>3. អង្គភាពទាំងពីរជាក្រុមហ៊ុនរួមទុននៃអង្គភាពទី៣។<br>4. អង្គភាពជាអ្នកចូលរួមទុននៃភាគីទី៣ ហើយអង្គភាពផ្សេងទៀតគឺជាក្រុមហ៊ុនញាតិសម្ព័ន្ធនៃអង្គភាពទី៣។ |

5. អង្គភាពជាអង្គភាពផែនការអត្ថប្រយោជន៍ក្រោយបំពេញការងារសំរាប់អត្ថប្រយោជន៍និយោជិកនៃអង្គភាពរាយការណ៍ ឬ អង្គភាពដែលទាក់ទងនឹងអង្គភាពរាយការណ៍។ប្រសិនបើអង្គភាពរាយការណ៍ជាអង្គភាពធ្វើផែនការខ្លួនឯង និយោជកឧបត្ថម្ភក៏ត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយផែនការ។
6. អង្គភាពត្រូវបានគ្រប់គ្រង ឬ គ្រប់គ្រងរួមដោយបុគ្គលដែលបានកំណត់នៅក្នុង (ក)។
7. បុគ្គលម្នាក់ដែលបានកំណត់នៅក្នុង (ក) (១) មានអំណាចបោះឆ្នោតសំខាន់ក្នុងអង្គភាព។
8. បុគ្គលដែលកំណត់ក្នុង (ក) (២) មានឥទ្ធិពលសំខាន់លើអង្គភាព ឬ អំណាចបោះឆ្នោតសំខាន់ក្នុងអង្គភាពនោះ។
9. បុគ្គល ឬ សមាជិកជិតស្និតនៃគ្រួសាររបស់បុគ្គលនោះមានឥទ្ធិពល សំខាន់លើអង្គភាព ឬអំណាចបោះឆ្នោតសំខាន់ក្នុងអង្គភាពនោះ និង ការគ្រប់គ្រងរួមលើអង្គភាពរាយការណ៍។
10. ជាសមាជិកនៃបុគ្គលិកគ្រប់គ្រងនៃអង្គភាព ឬ នៃក្រុមហ៊ុនមេរបស់ អង្គភាព ឬ ជាសមាជិកជិតស្និតនៃគ្រួសារនៃសមាជិកនោះ មានការគ្រប់ គ្រង ឬ ការគ្រប់គ្រងរួម លើអង្គភាពរាយការណ៍ ឬ មានអំណាចបោះឆ្នោត សំខាន់ក្នុងអង្គភាពនោះ។

**ប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ** ជាការផ្ទេរធនធាន សេវាកម្ម ឬ កាតព្វកិច្ចរវាងភាគីពាក់ព័ន្ធ ដោយមិនគិតពីតំលៃត្រូវបានគិតបញ្ចូល។

**ភាពទាក់ទិន** គុណភាពព័ត៌មានដែលអនុញ្ញាតឲ្យព័ត៌មាននោះមានឥទ្ធិពលលើការសំរេចចិត្តរបស់អ្នកប្រើប្រាស់ ដោយជួយពួកគេវាយតំលៃព្រឹត្តិការណ៍អតីតកាល បច្ចុប្បន្ន ឬ អនាគត ឬ បញ្ជាក់ ឬ កែ តំរូវ នូវការវាយតំលៃអតីតកាលរបស់គេ។

**ភាពជឿជាក់** ជាគុណភាពព័ត៌មានដែលពុំមានកំហុសធំដុំ និង ភាពលំអៀង ព្រមទាំងបង្ហាញដោយស្មោះ ត្រង់ដែលព័ត៌មាននោះអះអាងដើម្បីបង្ហាញ ឬអាចត្រូវបានរំពឹងទុកថានឹងបង្ហាញដោយសមហេតុផល។

**ថ្ងៃរាយការណ៍** ជាចុងបញ្ចប់នៃគ្រាចុងក្រោយដែលបានគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ ឬ ដោយ របាយការណ៍បណ្តោះអាសន្ន។

**គ្រារាយការណ៍** គ្រាដែលបានគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុ ឬ ដោយរបាយការណ៍បណ្តោះអាសន្ន

**ការស្រាវជ្រាវ** ជាការអង្កេតដើមដំបូងនិងបានរៀបចំទុកមុនដែលត្រូវបានអនុវត្តក្នុងក្ដីសង្ឃឹមថានឹង ទទួលបានចំណេះដឹង និងការយល់ដឹងផ្នែកបច្ចេកទេស ឬខាងផ្នែកវិទ្យាសាស្ត្រថ្មីៗ។

**តំលៃកាកសំណល់ (នៃទ្រព្យសកម្ម)** ជាតំលៃប៉ាន់ស្មានដែលអង្គភាពគួរទទួលបានជាពេលបច្ចុប្បន្នពីការលក់ទ្រព្យសកម្ម ចោល បន្ទាប់ពីកាត់កងចំណាយលក់ចោល ប្រសិនបើទ្រព្យសកម្មបានអស់ អាយុកាល និង ក្នុងលក្ខខណ្ឌដែលបានរំពឹងទុកនៅចុងគ្រាអាយុកាលរបស់វា។

**ការអនុវត្តត្រឡប់ក្រោយ (នៃការ ប្ដូរគោលនយោបាយ គណនេយ្** ជាការអនុវត្តគោលនយោបាយថ្មីចំពោះប្រតិបត្តិការ ព្រឹត្តិការនិងលក្ខខណ្ឌផ្សេងទៀ ប្រសិនបើគោលនយោបាយនោះតែងតែត្រូវបានអនុវត្ត។

**ចំណូល** ជាការហូរចូលដុលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងគ្រាដែលបានកើតឡើងក្នុងសកម្ម ធម្មតា របស់អង្គភាពពេលដែលការហូរចូលទាំងនោះបានធ្វើឲ្យកើនឡើងក្នុងដើមទុ ជាជាងការកើន ឡើងបានមកពីវិភាគទានពីអ្នកចូលរួមដើមទុន។

**របាយការណ៍ហិរញ្ញវត្ថុដោយ ឡែ** ជារបាយការណ៍ដែលត្រូវបានបង្ហាញដោយក្រុមហ៊ុនមេ ជាអ្នកវិនិយោគក្នុងក្រុមហ៊ុ ញ្ញាតិសម្ព័ន្ធ ឬ អ្នកចូលរួមទុន ក្នុងអង្គភាពគ្រប់គ្រងរួម ដែលការវិនិយោគត្រូវបាន ធ្វើគណនេយ្យកម្ម ដោយឈរលើមូលដ្ឋាននៃភាគកម្មតាមដើមទុនដោយផ្ទាល់ជា ជាងឈរលើមូលដ្ឋាននៃលទ្ធផលបានរាយការណ៍ និងទ្រព្យសកម្មសុទ្ធនៃអ្នកទទួល បានការវិនិយោគ។

**ការរៀបចំសម្បទានសេវា** ជាការរៀបចំដែលរដ្ឋាភិបាល ឬ ស្ថាប័នសាធារណៈផ្សេងទៀតចុះកិច្ចសន្យាជាមួយ ប្រតិបត្តិករ ឯកជនដើម្បីអភិវឌ្ឍ (ឬ ធ្វើឲ្យប្រសើរឡើង) ប្រតិបត្តិ និងថែទាំនូវ ទ្រព្យសកម្មជាហេដ្ឋារចនា សម្ព័ន្ធរបស់អ្នកផ្ដល់ ដូចជាផ្លូវថ្នល់ ស្ពាន ផ្លូវក្រោមដី ព្រលានយន្តហោះ បណ្ដាញចែកចាយ ថាមពល ពន្ធធនាគារ ឬ មន្ទីរពេទ្យ។

**ប្រតិបត្តិការទូទាត់ផ្អែកលើ សន្លឹកហ៊ុន** ជាប្រតិបត្តិការដែលអង្គភាពទទួលបានទំនិញ ឬសេវា (រួមទាមងសេវានិយោជិក) ជាការតបស្នងសំរាប់ឧបករណ៍ដើមទុននៃអង្គភាព (រួមទាំង ភាគហ៊ុន ឬសិទ្ធិពិសេស ទិញភាគហ៊ុន) ឬទិញទំនិញឬសេវាដោយកើតឡើងនូវបំណុលចំពោះអ្នកផ្គត់ផ្គង់ទំនិ ឬសេវាចំពោះទឹកប្រាក់ ដែលផ្អែកលើតំលៃនៃភាគហ៊ុនរបស់អង្គភាព ឬ ឧបករណ៍ ដើមទុនផ្សេងទៀតរបស់អង្គភាព។

**អង្គភាពធុនតូច និង មធ្យម** ជាអង្គភាពដែលៈ

(ក) មិនមានការទទួលខុសត្រូវជាសាធារណៈ និង

(ខ) បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុសំរាប់គោលបំណងទូទៅដល់អ្នកប្រើប្រាស់ ខាង ក្រៅ។

អង្គភាពមានការទទួលខុសត្រូវជាសាធារណៈ ប្រសិនបើៈ

(ក) អង្គភាពរៀបចំ ឬ អង្គភាពកំពុងស្ថិតដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញ

វត្ថុជាមួយគណៈកម្មការមូលបត្រ ឬ អង្គភាពនិយ័តកម្មផ្សេងទៀត ក្នុងគោលបំណង បោះផ្សាយថ្នាក់ឧបករណ៍នីមួយៗក្នុងទីផ្សារសាធារណៈ ឬ
(ខ) អង្គភាពមានទ្រព្យសកម្មក្នុងសមត្ថភាពជាធនាសំរាប់ក្រុមខាងក្រៅជាផ្នែកមួយនៃអាជីវកម្មសំខាន់របស់គេ។ ជាធម្មតា នេះជាករណីសំរាប់ធនាគារ សហភាពឥណទាន ក្រុមហ៊ុនធានារ៉ាប់រង អន្តរការីមូលបត្រ មូលនិធិសង្គហធន និង ធនាគារវិនិយោគ។

**រដ្ឋ** ជារដ្ឋាភិបាលមូលដ្ឋាន តំបន់ ឬថ្នាក់ជាតិ

**ផែនការរដ្ឋ (អត្ថប្រយោជន៍និយោជិក)** ផែនការអត្ថប្រយោជន៍និយោជិកត្រូវបានបង្កើតឡើងដោយច្បាប់ដើម្បីគ្របដណ្តប់អង្គភាពទាំងអស់(ឬអង្គភាពទាំងអស់ក្នុងថ្នាក់ជាក់លាក់ណាមួយ ឧទាហរណ៍ ជាឧស្សាហកម្មជាក់លាក់) និងត្រូវបានប្រតិបត្តិដោយរដ្ឋាភិបាលមូលដ្ឋាន ឬ ថ្នាក់ជាតិ ឬដោយអង្គភាពផ្សេងទៀត( ឧទាហរណ៍ ជាភ្នាក់ងារស្វ័យតដែលបានបង្កើតឡើងសំរាប់គោលបំណងជាក់លាក់) ដែលមិនមែនជាកម្មវត្ថុចំពោះការគ្រប់គ្រង ឬ មានឥទ្ធិពលអង្គភាពរាយការណ៍។

**របាយការណ៍លំហូរសាច់ប្រាក់** របាយការណ៍ហិរញ្ញវត្ថុដែលផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរក្នុងសាច់ប្រាក់និងសាច់ប្រា សមមូល នៃអង្គភាពមួយសំរាប់គ្រា ដោយបង្ហាញការផ្លាស់ប្តូរដាច់ដោយឡែកក្នុងគ្រ ពីសកម្មភាព ប្រតិបត្តិការ វិនិយោគ និង ហិរញ្ញប្បទាន។

**របាយការណ៍បម្រែបម្រួលដើមទុន** របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញក្នុងរបាយការណ៍ចំណេញឬខាតសម្រាប់គ្រា ធាតុនៃចំណូល និងចំណាយដែលបានទទួលស្គាល់ដោយផ្ទាល់ក្នុងដើមទុនសំរាប់គ្រ ផលប៉ះពាល់ នៃការផ្លាស់ប្តូរក្នុងគោលនយោបាយគណនេយ្យនិងការកែតំរូវកំហុស ដែលបានទទួលស្គាល់ក្នុងគ្រានិង( ផ្អែកលើទំរង់នៃរបាយការណ៍បម្រែបម្រួលដើមទុ ដែលបានជ្រើសរើសដោយអង្គភាព) ចំនួនទឹកប្រាក់នៃប្រតិបត្តិការជាមួយអ្នកកាន់ដើមទុនដើរតួនាទីជាអ្នកកាន់ដើមទុន ក្នុងសមត្ថភាពរបស់គេក្នុងគ្រា។

**របាយការណ៍លទ្ធផលសរុប** ជារបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញគ្រប់ធាតុនៃចំណូល និង ចំណាយដែលបានទទួលស្គាល់ក្នុងគ្រា រួមទាំងធាតុទាំងឡាយដែលបានទទួលស្គាល់ក្នុងការកំណត់ចំណេញឬខាត (ដែលជា សរុបរងក្នុងរបាយការណ៍លទ្ធផលសរុប) និង ធាតុនៃចំណូលផ្សេងៗទៀត។ប្រសិនបើអង្គភាពជ្រើសរើសបង្ហាញទាំងបាយការណ៍លទ្ធផល និង របាយការណ៍លទ្ធផលសរុប នោះរបាយការណ៍លទ្ធផលសរុបចាប់ផ្តើមជាមួយនឹងប្រាក់ចំណេញ ឬខាត បន្ទាប់មកបង្ហាញ ធាតុនៃចំណូលសរុបសផ្សេងទៀត។

**របាយការណ៍ស្ថានភាព ហិរញ្ញវត្ថុ** របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីទំនាក់ទំនងនៃទ្រព្យសកម្ម បំណុល ដើមទុន របស់អង្គភាព នៅត្រឹមថ្ងៃជាក់លាក់មួយ (គេអាចហៅថាជាតារាងតុល្យការផងដែរ)។

| | |
|---|---|
| **របាយការណ៍លទ្ធផល និងប្រាក់ចំណេញរក្សាទុក** | របាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញប្រាក់ចំណេញឬខាត និង ការប្រែប្រួលក្នុងប្រាក់ចំណេញរក្សាទុកសំរាប់គ្រាមួយ។ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ** | អង្គភាពមួយរួមទាំងអង្គភាពមិនបញ្ចូលគ្នាដូចជាក្រុមហ៊ុនសហកម្មសិទ្ធិដែលគ្រប់គ្រងដោយអង្គភាពមួយទៀត (ហៅថាក្រុមហ៊ុនមេ) |
| **អនុម័តជាក់ស្តែង** | អត្រាពន្ធត្រូវបានចាត់ទុកថាបានអនុម័តជាក់ស្តែងពេលដែលព្រឹត្តិការណ៍អនាគតតម្រូវដោយដំណើរការអនុម័តនឹងមិនផ្លាស់ប្តូរលទ្ធផល។ |
| **មូលដ្ឋានពន្ធ** | ការវាស់វែងក្រោមច្បាប់ពន្ធដែលបានអនុម័តឲ្យប្រើជាក់ស្តែងនៃទ្រព្យសកម្ម ឧបករណ៍បំណុល ឬ ដើមទុន។ |
| **ចំណាយពន្ធ** | ចំនួនទឹកប្រាក់សរុបក្នុងរបាយការណ៍លទ្ធផលសរុបឬដើមទុនសំរាប់គ្រារាយការណ៍ទាក់ទងនឹងពន្ធបច្ចុប្បន្ន និង ពន្ធពន្យា។ |
| **ប្រាក់ចំណេញជាប់ពន្ធ(ខាតប្រាក់ពន្ធ)** | ជាប្រាក់ចំណេញ (ខាត) សំរាប់គ្រារាយការណ៍ដែលពន្ធលើប្រាក់ចំណូលត្រូវបង ឬត្រូវទទួលវិញត្រូវបានកំណត់ដោយច្បាប់ដែលបានបង្កើតឡើងដោយអាជ្ញាធរពន្ធដារ។ប្រាក់ចំណេញជាប់ពន្ធស្មើនឹងចំណូលជាប់ពន្ធ ដក ចំនួនទឹកប្រាក់ដែលអាចកាត់ចេញបានពីចំណូលជាប់ពន្ធ។ |
| **ភាពខុសគ្នាបណ្តោះអាសន្ន** | ជាភាពខុសគ្នារវាងតំលៃក្នុងបញ្ជីនៃទ្រព្យសកម្ម បំណុល ឬ ធាតុផ្សេងទៀតក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធ ដែលអង្គភាពរំពឹងនឹងប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធពេល តំលៃក្នុងបញ្ជីនៃទ្រព្យសកម្ម ឬបំណុលត្រូវបានទទួលវិញ ឬត្រូវទូទាត់ (ឬ ក្នុងករណីនៃធាតុ ទាំងក្រៅពីទ្រព្យសកម្ម និង បំណុល នឹងប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ |
| **អត្ថប្រយោជន៍ពេលបញ្ឈប់ការងារ** | អត្ថប្រយោជន៍និយោជិកដែលត្រូវសង ដែលជាលទ្ធផលនៃៈ<br>(ក) ការសំរេចិត្តរបស់អង្គភាពដើម្បីបញ្ឈប់ការងាររបស់បុគ្គលិកមុនពេលថ្ងៃចូលនិវត្តន៍ ធម្មតា ឬ<br>(ខ) ការសំរេចរបស់និយោជិកដើម្បីទទួលយកភាពនៅទំនេរជាថ្នូរនឹងអត្ថប្រយោជន៍ទាំងនោះ។ |
| **ភាពខុសគ្នាតាមពេលវេលា** | ចំណូលឬចំណាយដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតក្នុងគ្រាមួយ ប៉ុន្តែ ក្រោមច្បាប់ពន្ធឬលិខិតបទដ្ឋាន ត្រូវបានបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធក្នុងគ្រាផ្សេងគ្នា។ |
| **ភាពទាន់ពេល** | ការផ្តល់ព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងក្របខណ្ឌពេលវេលាសំរាប់ធ្វើសេចក្តីសម្រេចចិត្ត។ |

| | |
|---|---|
| **លទ្ធផលសរុប** | ជាការប្រែប្រួលក្នុងដើមទុនក្នុងគ្រាដែលកើតចេញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀត ជាជាងការប្រែប្រួលទាំងឡាយដែលកើតចេញពីប្រតិបត្តិការជាមួយម្ចាស់ក្នុងសមត្ថភាពជាម្ចាស់(ស្មើនឹងផលបូកនៃប្រាក់ចំណេញ ឬខាត និង ចំណូលសរុបផ្សេងទៀត)។ |
| **ភាគហ៊ុនរតនៈ** | ជាឧបករណ៍ដើមទុនផ្ទាល់របស់អង្គភាពដែលកាន់កាប់ដោយអង្គភាព ឬសមាជិកផ្សេងទៀតនៃក្រុមរួមគ្នា |
| **ភាពអាចយល់បាន** | គុណភាពព័ត៌មានក្នុងរបៀបដែលធ្វើឲ្យមានការយល់បានដោយអ្នកប្រើប្រាស់ដែលមានចំណេះដឹងផ្នែកអាជីវកម្មនិងសេដ្ឋកិច្ចនិងគណនេយ្យនិងមានភាពស្ម័គ្រស្មោះដើម្បីសិក្សា ព័ត៌មានដោយយកចិត្តទុកបំផុត។ |
| **អាយុកាលអាចប្រើបាន** | ជាគ្រាដែលទ្រព្យសកម្មត្រូវរំពឹងថាអាចប្រើបានដោយអង្គភាព ឬចំនួនផលិតកម្ម ឬឯកត្តាស្រដៀងគ្នាដែលបានរំពឹងថានឹងទទួលបានពីទ្រព្យសកម្ម ដោយអង្គភាព។ |
| **តំលៃប្រើប្រាស់** | តំលៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគតដែលបានរំពឹងថានឹងទទួលបានពីការប្រើទ្រព្យសកម្ម ឬ អង្គភាពរកសាច់ប្រាក់។ |
| **អ្នករួមទុន ផ្ទេរ** | ជាភាគីមួយចំពោះការចូលរួមទុនដែលមានការគ្រប់គ្រងរួមលើការចូលរួមទុននោះក្លាយជាអ្នកមានសិទ្ធិ។ក្រោមការរៀបចំទូទាត់ផ្នែកលើសន្លឹកហ៊ុន សិទ្ធិរបស់ភាគីម្ខាងទៀត ត្រូវទទួលបានសាច់ប្រាក់ ទ្រព្យសកម្ម ឬ ឧបករណ៍ដើមទុននៃអង្គភាពផ្ទេរពេលសិទ្ធិទទួល របស់ភាគីម្ខាងទៀតមិនជាប់លក្ខខណ្ឌតទៅទៀតលើការបំពេញចិត្តនៃលក្ខខណ្ឌផ្ទេរណាមួយ។ |
| **អត្ថប្រយោជន៍បានផ្ទេរ** | អត្ថប្រយោជន៍ ជាសិទ្ធដែលលក្ខខណ្ឌនៃផែនការអត្ថប្រយោជន៍ចូលនិវត្តន៍ មិនមានលក្ខខណ្ឌ លើការងារបន្ត។ |